រំលឹកប្រសាសន៍

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
ក្រុមព្រឹត្តិប័ត្រ រ៉ែបសាយត៍ កម្ពុជាទស្សនៈថ្មី
បោះពុម្ព លើកទីមួយ - មីនា ២០១៧

រំលឹកប្រសាសន៍

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
ជាឯកសារដកស្រង់ ចងក្រង និងបោះពុម្ព ដោយខុទ្ទកាល័យ
សម្តេចតេជោ សំរាប់ **ការប្រើប្រាស់ជាជំនួយស្មារតី**។
ហាមបោះពុម្ពឡើងវិញនូវផ្នែកណា ឬទាំងស្រុង ដោយសរសេរ
ដោយមធ្យោបាយអេឡិចត្រូនិច និង/ឬការថតចម្លង ដោយមិន
មានការអនុញ្ញាត។ ខុទ្ទកាល័យ សម្តេចតេជោ មិនទទួលខុស
ត្រូវចំពោះការដកស្រង់ និងប្រើប្រាស់ ផ្ទុយពីគំនិត និងគោល
បំណង ដែលបានជំរាបជូនឡើយ។

បុព្វកថា

ទិន្នន័យដ្ឋាន កម្ពុជាទស្សនៈថ្មី ដែលជាបណ្ណាល័យអត្ថបទចម្លងប្រសាសន៍ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន តាមវិស័យទាំងឡាយ បច្ចុប្បន្នមានអត្ថបទជាង ៥០០ ចំណងជើង កំពុងធ្វើបច្ចុប្បន្នភាព និងត្រូវបានហៅមកវិញប្រើប្រាស់ជាប្រចាំ។ អត្ថបទចម្លងពីសម្លេងជាអក្សរនូវសង្កថា និងសេចក្តីអធិប្បាយបន្ថែមលើសុន្ទរកថា មាន ៨១% នៃចំនួនឯកសារទាំងអស់ ក្នុងទិន្នន័យដ្ឋាន។

យោងតាមការកត់ត្រា គិតពីឆ្នាំ ២០០៩ ដល់ ឆ្នាំ ២០១៦ ក្រុមព្រឹត្តិប័ត្រ និងវ៉ែបសាយត៍ កម្ពុជាទស្សនៈថ្មី បានចម្លង និងផ្ទុកក្នុងទិន្នន័យដ្ឋាន ជាមធ្យម ៥៣ អត្ថបទ ក្នុងមួយឆ្នាំ ក្នុងនោះ ឆ្នាំ ២០១៣ មានចំនួន ៩០ និងឆ្នាំ ២០១៦ មានចំនួន ៧៧។ ពាក្យភ្ជាប់ ២៥ ក្នុងចំណោមពាក្យភ្ជាប់រាប់ពាន់ បង្ហាញថា រយៈពេល ៨ ឆ្នាំនេះ សម្តេចតេជោ បានមានប្រសាសន៍អំពីវិស័យ អប់រំ សេដ្ឋកិច្ច កសិកម្ម និងបក្សប្រឆាំង ច្រើនជាងគេ។

ចំនួនអត្ថបទតាមឆ្នាំ៖ ២០០៩ ដល់ ២០១៦

២០០៩	២០១០	២០១១	២០១២	២០១៣	២០១៤	២០១៥	២០១៦
៤៩	៤១	៥៥	៥៩	៩០	៦៣	៦៤	**៧៧**

ប្រភព៖ ទិន្នន័យដ្ឋាន កម្ពុជាទស្សនថ្មី, មករា ២០១៧

ក្នុងឆ្នាំ ២០១៣ ដែលមានការបោះឆ្នោតជាតិ ពាក្យភ្ជាប់ "អប់រំ" ឈរលើគេ (២១/៩០ អត្ថបទ) ហើយពាក្យភ្ជាប់ដែលបានប្រើញឹកញាប់ រួមមាន "គណបក្សប្រជាជន" "ប៉ុល ពត" "ពុទ្ធសាសនា" បានឡើងមកជំនួសលំដាប់ពាក្យភ្ជាប់លើគេ បន្ទាប់ពីអប់រំ។ បន្តទៅ ពាក្យភ្ជាប់ "កំពង់ចាម" "ភ្នំពេញ" ដែលបង្ហាញពីសារសំខាន់មណ្ឌលឆ្នោតមានអាសនៈច្រើន និង "យុវជន" បានលេចឡើង ច្រើនបង្ហូរ។

ឆ្នាំ ២០១៦ ក្នុងខណៈពាក្យភ្ជាប់ "អប់រំ" រក្សាលំដាប់លើគេបង្អស់ (២៤/៧៧ អត្ថបទ) សង្កថា និងសេចក្តីអធិប្បាយបន្ថែមលើសុន្ទរកថានៃសម្តេចតេជោ បានងាកទៅគ្រប

ដណ្តប់វិស័យថ្មីមួយចំនួន ដូចជាការប្រើប្រព័ន្ធព័ត៌មានសង្គម (ហ្វេសប៊ុក) នយោបាយ ឈ្នះឈ្នះ វិបាកក្នុងផ្នែកចរាចរណ៍/សាធារណការ ជីវភាពគ្រូបង្រៀន សុខាភិបាល និងជំហរកម្ពុជាស្តីពីទំនាស់អធិបតេយ្យសមុទ្រចិនខាងត្បូង។ កត់សម្គាល់ថា ក្នុងចំណោមពាក្យក្ដាប់ ២៥ លើគេ សម្តេចតេជោ បានមានប្រសាសន៍ច្រើនបង្ហូរ អំពីវិបត្តិថ្លៃស្រូវ ការប្រែប្រួលធាតុអាកាស និងការរាំងស្ងួត[1]។

ក្នុងគ្រាកន្លង ឯកសារទាំងនេះ ត្រូវបានប្រើប្រាស់ជាការរៀបចំជំនួយស្មារតី ជាប្រភពនៃការរកចំណុចសំខាន់ៗ នៃប្រសាសន៍អនុសាសន៍ ជាការផ្ទៀងផ្ទាត់មួយចំនួន និងជាការដកស្រង់បម្រើអោយការផលិតឧបករណ៍ព័ត៌មានតាមវិស័យនានា។

ស្របគ្នានឹងទិន្នន័យដ្ឋាន ដែលរក្សាខ្លឹមសារចម្លងស្ទើរតែទាំងស្រុង កម្ពុជាទស្សនៈថ្មី ក៏មានវ៉ែបសាយត៍ ជាភាសាខ្មែរ និងភាសាអង់គ្លេស ដែលក្រៅពីជូនព័ត៌មានអំពីសកម្មភាព និងការដកស្រង់ប្រសាសន៍ថ្លែងការណ៍នានា នៃសម្តេចតេជោ នៅបានធ្វើតួនាទីជាទិន្នន័យដ្ឋានសាធារណៈទៀតផង។ ចំនួនអ្នកចូលប្រើប្រាស់ វ៉ែបសាយត៍ កម្ពុជាទស្សនៈថ្មី មានត្រឹមប្រមាណជាពី ៧០០ ទៅ ៨០០ នាក់ក្នុងមួយខែ ប៉ុន្តែ ជាង ៦០% នៃអ្នកចូលប្រើប្រាស់វ៉ែបសាយត៍ ត្រូវបានកត់សំគាល់ថាជាអ្នកប្រើប្រាស់ប្រចាំ ហើយមើលលើច្រើនទំព័រ មិនមែនគ្រាន់តែចូលហើយចេញវិញនោះទេ។

[1] ទិន្នន័យក្រុមព្រឹត្តិប័ត្រ និងវ៉ែបសាយត៍ កម្ពុជាទស្សនៈថ្មី, ខុទ្ទកាល័យសម្តេចតេជោ

មាតិកា

	បុព្វកថា	i
	មាតិកា	iii
១	កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	១
២	កាកបាទក្រហមកម្ពុជា	១៥
៣	ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	២៣
៤	ការបរទេស	៣៣
៥	ការពារជាតិ	៥៩
៦	កិច្ចការនារី	៧១
៧	ទេសចរណ៍	៧៩
៨	ធនធានទឹក និងឧតុនិយម	៩១
៩	ធម្មការ និងសាសនា	១០៣
១០	បរិស្ថាន	១១៣
១១	ប្រៃសណីយ៍ និងទូរគមនាគមន៍	១២៣
១២	ផែនការ	១៣១
១៣	ពាណិជ្ជកម្ម	១៣៧
១៤	មហាផ្ទៃ	១៥១
១៥	មុខងារសាធារណៈ	១៦៧
១៦	រៀបចំដែនដី នគរូបនីយ៍កម្ម និងសំណង់	១៧៧
១៧	រ៉ែ និងថាមពល	១៨៧
១៨	វប្បធម៌ និងវិចិត្រសិល្ប:	១៩៧
១៩	សង្គមកិច្ច និងយុវនីតិសម្បទា	២០៩
២០	សាធារណការ និងដឹកជញ្ជូន	២១៩
២១	សុខាភិបាល	២៣៥
២២	សេដ្ឋកិច្ច និងហិរញ្ញវត្ថុ	២៤៩
២៣	អប់រំ យុវជន និងកីឡា	២៥៩

២៤	អភិវឌ្ឍន៍ជនបទ	២៧៣
២៥	ឧស្សាហកម្ម និងសិប្បកម្ម	២៨៥
២៦	ឧបសម្ព័ន្ធ ក៖ ការបកស្រាយប្រធានបទនយោបាយមួយចំនួន	២៩៧
២៧	ឧបសម្ព័ន្ធ ខ៖ បុព្វបទ អនុវត្តន៍ សមិទ្ធផលនយោបាយឈ្នះឈ្នះ	៣១៥

កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១	គម្រោងសុំឥណទានពីបរទេស(បំរើ)តម្រូវការធំបំផុតលើវិស័យកសិកម្ម	៣
២	ពង្រីកសមត្ថភាពចិញ្ចឹមលើផ្ទៃដីដែលមានស្រាប់	៣
៣	កុំឲ្យប្រជាពលរដ្ឋកម្ពុជាស្លាប់ដោយអត់បាយ	៤
៤	គណបក្សប្រជាជនបន្តមិនយកពន្ធដីធ្លីកសិកម្ម	៤
៥	ឆ្នាំនេះជួបគ្រោះរាំងស្ងួតធ្ងន់ធ្ងរ សូមពលរដ្ឋធ្វើស្រែប្រាំងម្តងបានហើយ	៥
៦	ស្បៀង/កសិកម្ម រួមចំណែកទប់ស្កាត់ផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ច	៥
៧	ចក្ខុវិស័យ ២០ ឆ្នាំមុន ពីការអភិវឌ្ឍទូលាយ មកការអភិវឌ្ឍស៊ីជម្រៅ	៦
៨	អំពៅ ជាកសិឧស្សាហកម្មផង ជាកសិពាណិជ្ជកម្មផង	៦
៩	បញ្ចុះថ្លៃភ្លើងអោយម៉ាស៊ីនស្រូវ កសិករនឹងលក់ស្រូវបានថ្លៃជាងមុនទេ?	៧
១០	វិស័យកសិកម្មត្រូវបោះពុម្ពសៀវភៅឲ្យបានច្រើន	៧
១១	វិធានការណ៍សរុប ៥ អន្តរាគមន៍ ស្តានភាពខ្វះទឹកនៃវិស័យកសិកម្ម	៨
១២	ធ្វើឲ្យកសិករទទួលប្រយោជន៍ ក្នុងស្ថានភាពពិភពលោកមិនអនុគ្រោះ	៨
១៣	គោលនយោបាយជំរុញផលិតកម្មស្រូវ ទទួលជោគជ័យ	៩
១៤	កត្តាសត្យានុម័ត/អត្តនោម័ត នាំឲ្យមិនសម្រេចគោលដៅនាំចេញអង្ករ	៩
១៥	ប្តូរការដាំដំណាំស្រូវនៅតំបន់អត់ទឹក មកដាំដំណាំផ្សេងបានផលជាង	១០
១៦	ស្រាវជ្រាវពូជ ដែលធន់នឹងការប្រែប្រួលអាកាសធាតុ	១០
១៧	ស្រាវជ្រាវផលិតជី/ថ្នាំសម្លាប់សត្វល្អិត និងយន្តតូបនីយកម្មវិស័យកសិកម្ម	១១
១៨	បន្តចិញ្ចឹមសត្ត អនុវត្តគោលការណ៍កសិកម្មសរីរាង្គ	១១
១៩	ជម្រុញការដាំដុះ និងចិញ្ចឹមសត្ត បន្ថយការនាំចូល	១១
២០	ជម្រុញការស្តារអាងទឹក បឹង និងការចិញ្ចឹមត្រី	១២
២១	ប្រគល់ឡូត៍នេសាទឲ្យប្រជាពលរដ្ឋ	១២
២២	ខណ្ឌព្រៃឈើ ជលផល នៅក្នុងគណៈបញ្ជាការខេត្ត	១៣
២៣	ដកហូតដីហើយ ឱ្យសងតម្លៃឈើទៀត	១៣
២៤	កៅស៊ូជាគម្របព្រៃឈើ និងទទួលផលច្រើន	១៤
២៥	ក្រសួងកសិកម្ម/បរិស្ថាន សុំបញ្ចូលឈើក្រញូង ក្នុងបញ្ជីរុក្ខជាតិកម្រ	១៤

១. គម្រោងសុំឥណទានពីបរទេស (បំរើ)តម្រូវការធំបំផុត គឺលើវិស័យកសិកម្ម

សម្ពោធដាក់ឱ្យប្រើប្រាស់កំណាត់ផ្លូវជាតិលេខ ១ ប្រវែង ៤២,៨៨ គីឡូម៉ែត្រ និង ការប្រកាសបើកការដ្ឋានស្ថាបនាបន្តជំណាក់កាលទី ៣, ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១០

... សូមបន្តការយកចិត្តទុកដាក់ទៅលើផ្នែកប្រព័ន្ធស្រោចស្រពជាអាទិភាព។ ឥឡូវនេះ មើលឃើញច្បាស់ហើយ ... ប្រជាពលរដ្ឋកំពុងសប្បាយនឹងស្រូវគាត់ល្អ ស្រូវឡើងថ្លៃ (ឆ្នាំ ២០១០) ពិភពលោកត្រូវការចំណីអាហារ ... ចំនួនមនុស្សកើនឡើង ផ្ទៃដីដាំដុះមួយចំនួននៅប្រទេសខ្លះ យកទៅផលិតអេតាណុលទៅហើយ គេហៅថាផលិតដើម្បីចិញ្ចឹមគ្រឿងចក្រ។ កម្ពុជាមានផ្ទៃដីសម្រាប់ការដាំដុះផលិតស្បៀង ដើម្បីចិញ្ចឹមមនុស្ស។ ដូច្នេះហើយ បានជា**យើងស្នើសុំពីជប៉ុននូវប្រព័ន្ធស្រោចស្រព និងប្រព័ន្ធផ្លូវថ្នល់ជាបន្តទៀត។ គម្រោងនានាដែលដាក់ចេញ ដើម្បីសុំឥណទានពីបរទេស តម្រូវការធំបំផុត គឺលើវិស័យកសិកម្ម ... បើកម្ពុជាពង្រីកប្រព័ន្ធស្រោចស្រពបាន បង្កើនផ្ទៃដាំដុះដោយធ្វើប្រពលវប្បកម្ម កម្ពុជាអាចមានសមត្ថភាពនាំចេញ បើមិនលើស ក៏ប្រហាក់ប្រហែលវៀតណាមដែរ ...**។

២. ពង្រីកសមត្ថភាពចិញ្ចឹមលើផ្ទៃដីដែលមានស្រាប់

សន្និបាតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៩

... និយាយតែពីវិស័យកសិកម្ម វាជាសក្តានុពលដ៏ធំរបស់កម្ពុជា ដោយមិនទាន់និយាយទៅដល់ការប្រើប្រាស់ប្រេង ឧស្ម័ន និងធនធានធម្មជាតិដទៃទៀត។ សេដ្ឋកិច្ចកម្ពុជាមានកំណើនមុនវិបត្តិ ២ ខ្ទង់ជាប់ៗ គ្នា ៤ ឆ្នាំ ខណៈដែលព្រៃឈើក៏មិនកាប់ ឡូត៍នេសាទ ដីកសិកម្មក៏មិនទាន់បង់ពន្ធ ... ខ្ញុំសូមលើកយកមកនិយាយឡើងវិញនូវ**ចក្ខុវិស័យតាំងពី ២០ ឆ្នាំមុន ស្តីពីការបង្វែរការអភិវឌ្ឍតាមបែបបើកទូលាយទៅជាការអភិវឌ្ឍតាមបែបស៊ីជម្រៅ**។ មានន័យថា **ត្រូវពង្រីកសមត្ថភាពចិញ្ចឹមលើផ្ទៃដីដែលមានស្រាប់ តាមរយៈការជោះស្រាយទឹក ការបង្កើនផ្ទៃដាំដុះ ការធ្វើប្រពលវប្បកម្ម ដែលក្នុងហ្នឹងមានការធ្វើដី ការប្រើប្រាស់ពូជ និងជី** ជាដើម ដែលយើងបាននិងកំពុងធ្វើ ហើយដឹកនាំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ដែលសកម្មភាព) ផុលផុសខ្លាំងនៅក្នុងស្រុក

ត្រាំកក់ ខេត្តតាកែវ ...។

៣. កុំឲ្យប្រជាពលរដ្ឋកម្ពុជាស្លាប់ដោយអត់បាយ

វេទិកាជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ , ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៩

... នៅពេលដែលមានវិបត្តិសេដ្ឋកិច្ចហិរញ្ញវត្ថុកើតមាននេះ តើយើងសម្រេចបានគោលដៅកាត់បន្ថយភាពក្រីក្រមួយឆ្នាំជាង ១% បានឬទេ? ចំណោទធំមួយទៀតគឺ តើអ្នកដែលបានឆ្លងផុតអត្រានៃភាពក្រីក្រហើយនោះ អាចនឹងធ្លាក់ទៅក្នុងភាពក្រីក្រវិញឬទេ? ... ចំណុចនេះ មិនត្រូវមើលរំលងនូវការខិតខំទាំងអស់ដែលយើងត្រូវធ្វើសកម្មភាពពេលខាងមុខ ... ពិសេស អំពីបញ្ហាសន្តិសុខស្បៀង សុវត្ថិភាពស្បៀង និងអាហារូបត្ថម្ភ។ នោះជាចំណុចចំគោលដៅហើយ ព្រោះ**បញ្ហាដែលធំជាងគេ គឺធ្វើម៉េចកុំឲ្យប្រជាជនកម្ពុជាស្លាប់ដោយអត់បាយ ដោយគ្មានអ្នកណាដឹង ហើយមិនបានដោះស្រាយ និងពាក្យខ្មែរហៅថា កុំឲ្យខ្ទះអង្ករច្រកឆ្នាំង។ យ៉ាងណាក្តី តម្រូវការរបស់សង្គមមិនមែនមានតែប៉ុណ្ណឹងទេ ...។**

៤. គណបក្សប្រជាជនបន្តមិនយកពន្ធដីធ្លីកសិកម្ម

បិទសន្និបាតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ ២០១២/១៣,
សាកលវិទ្យាល័យកូមិន្ទកសិកម្ម(ចំការដូង), ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣

... ទោះបីជា វិស័យកសិកម្មកម្ពុជារីកចម្រើនខ្លាំងយ៉ាងណាក៏ដោយ ក៏រាជរដ្ឋាភិបាល ដែលមានខ្ញុំជានាយករដ្ឋមន្ត្រីនោះ មិនអនុវត្តន៍ការយកពន្ធលើដីធ្លីកសិកម្មនោះឡើយ ... បានសេចក្តីថា មិនមែនឃើញកសិករ(មានចំណូល)កើនឡើងបបួលគ្នាយកពន្ធទេ។ នយោបាយ(យកពន្ធដីធ្លីកសិកម្ម)នេះ មិនត្រូវបានអនុវត្តដោយគណបក្សប្រជាជនទេ។ មិនថា មានវត្តមានរបស់ខ្ញុំ ឬអវត្តមានរបស់ខ្ញុំទេ សុំផ្តាំផ្ញើអ្នកដឹកនាំគណបក្សប្រជាជន ដែលនឹងបន្តវេនពីខ្ញុំនៅពេលក្រោយ សូមកុំលេងនយោបាយយកពន្ធដីធ្លីកសិកម្មនេះ។ ធ្វើម៉េចឲ្យប្រជាជនគាត់ទទួលផលគាត់នឹងចាយវាយ ដល់ពេលចាយវាយនោះហើយ ដែល(គាត់)ចាប់ផ្តើម(បង់ពន្ធ) ដូចជាពន្ធ VAT ... ផឹកទឹកក្រូចមួយកំប៉ុង វាមានពន្ធនៅក្នុងហ្នឹង ... ប្រាកដ(ជាដូចនេះ)ត្រឹមតែគណបក្សប្រជាជនកម្ពុជាដឹកនាំតែប៉ុណ្ណោះ។ បើគណបក្ស

ដ៏ទៃ(ដឹកនាំវិញ) យើងមិនហ៊ានអះអាងទេ ព្រោះ(វានឹង)ជាគោលនយោបាយ របស់គេ ដូចជា ដើម្បីតម្រូវទៅលើបញ្ហាបៀវត្ស គេអាចចាប់ផ្តើមយកពន្ធ ...។

៥. ឆ្នាំនេះជួបគ្រោះរាំងស្ងួតធ្ងន់ធ្ងរ សូមប្រជាជនធ្វើស្រែប្រាំងម្តងបានហើយ

ពិធីកាត់ឫសសីមាព្រះវិហារ វត្តឥន្ទមុនី ហៅវត្តព្រៃជ្រាំង, ថ្ងៃទី ១១ មេសា ឆ្នាំ ២០១៦

... ឥឡូវនេះ ប្រទេសយើងកំពុងជួបប្រទះនូវការរាំងស្ងួតដ៏ធ្ងន់ធ្ងរ។ ការរាំងស្ងួតនេះ វាមិនមែនជាការដាច់ដោយឡែកទេ ក៏ប៉ុន្តែ វាជាបញ្ហារួមរបស់តំបន់ ... ឥឡូវនេះ ទឹកសមុទ្រចូលក្នុងទឹកដីវៀតណាម ប្រមាណជាង ១០០ គីឡូម៉ែត្រ ទៅហើយ។ កាលណាទឹកទន្លេមេគង្គរបស់យើងវាមិនខ្ពស់ អាទឹកសមុទ្រនោះ វាដោរ(ឡើង) ... ជាមហន្តរាយមួយ ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងពិភពលោកទាំងមូល ... ឆ្នាំកន្លងទៅ ភ្លៀង(មិនចំ)បាសាំងមេគង្គរបស់ យើងតែម្តង ... **រាជរដ្ឋាភិបាលយកវិធានការតាំងពីប៉ុន្មានខែមុន អំពាវនាវចំពោះ ប្រជាពលរដ្ឋរបស់យើង សូមមេត្តាធ្វើស្រែប្រាំងតែម្តងបានហើយ ដើម្បីយើងទប់ ទឹកសម្រាប់ប្រើប្រាស់ ...**។

៦. ស្បៀង/កសិកម្ម រួមចំណែកទប់ស្កាត់ផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ច

ពិធីបិទសន្និបាត កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០០៩

... ដោគជ័យក្នុងវិស័យកសិកម្មរបស់យើង បានជួយទប់ស្កាត់នូវផលប៉ះពាល់ ដែលកើតចេញពីវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាសកល មកលើសេដ្ឋកិច្ចរបស់ កម្ពុជា។ ខ្ញុំតែងបាននិយាយថា ត្រូវក្តាប់ឲ្យជាប់នូវដើពចរខាងសេដ្ឋកិច្ច ឬថា ធានា កុំឲ្យប្រជាជនកម្ពុជាខ្វះអង្ករច្រកឆ្នាំង។ គ្មានប្រេងវាមិនធ្វើអោយងាប់ទេ ប៉ុន្តែការ អត់ស្បៀងទើបវាងាប់។ **សន្តិសុខស្បៀងត្រូវបានធានាក្នុងទីផ្សារកម្ពុជា ដោយ យើងមិនបានប៉ះប៉ូវដោយការនាំចូលស្បៀងពីបរទេសទេ។ យើងធានាស្បៀងក្នុង ប្រទេសបាន ទោះបីមានមហន្តរាយកើតឡើងដោយព្យុះកេតសាណា និងជំនន់ មេគង្គក៏ដោយ។ យើងបានសង្គ្រោះ(ស្ថានការណ៍)ទាន់ពេលវេលា ដោយមាន ស្បៀងក្នុងដៃ មិនចាំបាច់រង់ចាំជំនួយបរទេស ... បញ្ជាក់ពីការរួមចំណែកដ៏ធំធេង (ពីផលិតកម្មស្បៀង/កសិកម្ម)ដល់ការការក្សាស្ថិរភាពនយោបាយ ស្ថិរភាពម៉ាក្រូ**

សេដ្ឋកិច្ច និងបញ្ហាបណ្តាលពីមានវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាសកល ...៖

៧. ចក្ខុវិស័យ ២០ ឆ្នាំមុន ពីការអភិវឌ្ឍទូលាយ មកការអភិវឌ្ឍស៊ីជម្រៅ

បិទសន្និបាតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០០៩

... កុំទាន់និយាយទៅដល់ធនធានរ៉ែ និយាយតែពីវិស័យកសិកម្ម ដែលជាសក្តានុពលដ៏ធំរបស់កម្ពុជា ... សេដ្ឋកិច្ចកម្ពុជាមានកំណើនមុនវិបត្តិ ២ ខ្ទង់ជាប់ៗ គ្នា ៤ ឆ្នាំ ខណៈដែលព្រៃឈើក៏មិនកាប់ ឡូត៍នេសាទ ដីកសិកម្ម ក៏មិនទាន់បង់ពន្ធ ... **ខ្ញុំសូមលើកយកមកនិយាយឡើងវិញនូវចក្ខុវិស័យតាំងពី ២០ ឆ្នាំមុន ស្តីពីការបង្វែរការអភិវឌ្ឍតាមបែបបើកទូលាយទៅជាការអភិវឌ្ឍតាមបែបស៊ីជម្រៅ។ មានន័យថា ត្រូវពង្រីកសមត្ថភាពចិញ្ចឹមលើផ្ទៃដីដែលមានស្រាប់ តាមរយៈការដោះស្រាយទឹក ការបង្កើនផ្ទៃដាំដុះ ការធ្វើប្រពលរឫកម្ម ដែលក្នុងហ្នឹងមានការធ្វើដី ការប្រើប្រាស់ពូជ និងដីជាដើម** ដែលយើងបាន និងកំពុងធ្វើ ហើយដឹកនាំយុទ្ធនាការដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ជាមួយនឹងសកម្មភាព) ផុលផុសខ្លាំងនៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ...៖

៨. អំពៅ ជាកសិឧស្សាហកម្មផង ជាកសិពាណិជ្ជកម្មផង

ពិធីសម្ពោធរោងចក្រផលិតស្ករស ក៏ឫបទឹកអំពៅ ក្រុមហ៊ុនចិន Rui Feng Cambodia International Co., Ltd, ថ្ងៃទី ១៩ មេសា ឆ្នាំ ២០១៦

... បន្ទាប់ពីការដាច់ឆ្នាំចាស់ចូលឆ្នាំថ្មី ចាប់ផ្តើមមកសម្ពោធដាក់ឲ្យប្រើប្រាស់នូវរោងចក្រផលិតស្ករស វិនិយោគពីសំណាក់ក្រុមហ៊ុន Rui Feng International មកពីប្រទេសចិន។ **នេះជាផ្នែកទាក់ទិនទៅនឹងឧស្សាហកម្ម ក៏ប៉ុន្តែយើងមើលឲ្យជ្រៅ នេះគឺជាកសិឧស្សាហកម្ម ហើយក៏ជាកសិពាណិជ្ជកម្មផងដែរ។ ទីតាំងមួយនេះ ដែលយើងធ្វើការសម្ពោធដាក់ឲ្យប្រើប្រាស់ជាមួយនឹងរោងចក្រផលិតស្ករស ក៏ប៉ុន្តែយើងមិនត្រូវភ្លេចថា កន្លែងនេះ គឺជាទីផ្សារដ៏សំខាន់របស់កសិករសម្រាប់ការដាំអំពៅ ហើយលក់មកកាន់រោងចក្រ ដែលហៅថាកសិឧស្សាហកម្ម គឺឧស្សាហកម្មកែច្នៃវត្ថុធាតុដើមដែលចេញពីកសិកម្ម។ ស្របពេលជាមួយគ្នាកសិករបស់យើងក៏នឹងត្រូវលក់កសិផល** ជាពិសេសគឺអំពៅដែលខ្លួនដាំបាន ដែលយើងប្រើ

ពាក្យថា កសិពាណិជ្ជកម្ម សម្រាប់ទីផ្សារមួយនៅទីនេះផងដែរ ... យើងទាំងអស់គ្នាបានប្រឹងប្រែងឈានឡើងពីមួយឆ្នាំទៅមួយឆ្នាំ ចេញពីបាតដៃទទេ ...។

៩. តើបញ្ចុះថ្លៃភ្លើងសម្រាប់ម៉ាស៊ីនកិនស្រូវ កសិករនឹងលក់ស្រូវបានថ្លៃជាងមុនឬទេ?

ពិធីសំណេះសំណាលជាមួយកម្មករ/ការិនី បុគ្គលិក មន្ត្រីកំពង់ផែស្វយ័តក្រុងព្រះសីហនុ, ថ្ងៃ ១ ឧសភា ឆ្នាំ ២០១៦

... **ខាងក្រសួងកសិកម្ម កំពុងតែស្នើដើម្បីសុំឲ្យអ្នករោងចក្រម៉ាស៊ីនកិនស្រូវប្រើប្រាស់ភ្លើងឲ្យបានថោកបន្តិច។ ប៉ុន្តែ ខ្ញុំក៏បាននិយាយបន្តិចថា ឥឡូវ បើសិនជាចុះតម្លៃនៃ(ភ្លើងប្រើសម្រាប់)ម៉ាស៊ីនកិនស្រូវ តើអ្នកដែលទៅទិញស្រូវហ្នឹងហ៊ានតម្លើងតម្លៃស្រូវពីកសិករឬអត់? បើមិនអញ្ចឹងបានទៅលើតែគាត់(ម្ចាស់ម៉ាស៊ីនកិនស្រូវ)ហ្នឹង**។ ឯកឧត្តម រ៉ង សុខុន ជាអ្នកស្នើ រដ្ឋមន្ត្រីកសិកម្មថ្មី ... ត្រូវប្រជុំខាងសមាគមកិនស្រូវអង្ករ ជាមួយនឹងផ្នែកណាទៀត មានពាណិជ្ជកម្ម ជាដើម ដើម្បីថាតើហ៊ានតទល់ឬទេ? ឥឡូវ ឧបមាថា ខាងនោះ គេចុះតម្លៃភ្លើងឲ្យមកខាងហ្នឹង ២០% តើលោកឯងហ៊ានតម្លើងថ្លៃស្រូវ ១០% ឬអត់? ហ៊ានលេងទៅលេងមក។ បើមិនអញ្ចឹង បាន(ចំណេញ)តែថៅកែម៉ាស៊ីនកិនស្រូវ វាមិនងាប់ទៅហើយ ...។

១០. វិស័យកសិកម្មត្រូវបោះពុម្ពសៀវភៅឲ្យបានច្រើន

ពិធីបើកយុទ្ធនាការអក្ខរកម្មជាតិឆ្នាំ ២០១៥, ថ្ងៃទី ០២ មីនា ២០១៥

... នៅទីនេះ រឿងមួយត្រូវពង្រឹងសមត្ថភាពនៃការរៀនអក្សររៀនលេខ ប៉ុន្តែមួយទៀត គ្រោះភ្លេចលេខ ភ្លេចអក្សរ ក៏ត្រូវតែគិត។ វិធីដោះស្រាយបញ្ហា គឺការបោះពុម្ពសៀវភៅ ហើយបើយកល្អ **ខាងវិស័យកសិកម្ម បោះឲ្យច្រើន (នូវសៀវភៅណែនាំអំពី)របៀបចិញ្ចឹមត្រី របៀបដាំបន្លែ ... ចំណេញបានគោលដៅ ២ គឺអភិវឌ្ឍផង (និងចំណេះផង)** ... អញ្ចឹងទេ វិធីដែលល្អជាងគេ គឺផ្សព្វផ្សាយចំណេះវិជ្ជាខាងវិស័យកសិកម្ម ខាងវិស័យសុខាភិបាល (ដូចជា)ការពារសុខភាព ... គាត់អានចុះអានឡើង គាត់អត់ភ្លេចទេ...។

១១. វិធានការណ៍សរុប ៥ យ៉ាង អន្តរាគមន៍ ចំពោះស្ថានភាពខ្វះទឹក នៃវិស័យកសិកម្ម

ប្រភពពីទំព័រហ្វេសប៊ុកសម្តេចតេជោ, ថ្ងៃទី ៧ ធ្នូ ២០១៥

... ឆ្នាំនេះ ដំណាំកសិកម្មនានា ពិសេសដំណាំស្រូវ ទាំងស្រូវវស្សា ទាំងស្រូវប្រាំងបាននិងកំពុងប្រឈមនឹងការខ្វះទឹក។ សភាពការណ៍បែបនេះ ជាមួយវិធានការដែលរាជរដ្ឋាភិបាលបានដាក់ចេញរួចមកហើយ សូមយកចិត្តទុកដាក់(**១)អន្តរាគមន៍ជួយបូមទឹកសង្គ្រោះស្រូវប្រជាពលរដ្ឋ** ដោយមិនទុកឲ្យស្រូវខូចនៅតំបន់ដែលមានប្រភពទឹកឡើយ ... (**២) ជួយច្រូតកាត់ប្រមូលផល**សំរាប់គ្រួសារដែលខ្វះកម្លាំងពលកម្ម ... (**៣)ផ្តល់ពូជដំណាំជល់ប្រជាកសិករ** ដែលមិនអាចធ្វើស្រែប្រាំងបាន ដំរុញឲ្យពួកគាត់ដាំដុះដំណាំរួមផ្សំវិញ ... ត្រៀមអន្តរាគមន៍(**៤)កំចាត់សត្វបំផ្លាញដំណាំ** និងទប់ស្កាត់ជម្ងឺសត្វគ្រប់ប្រភេទ។ ... ស្ថាប័នហិរញ្ញវត្ថុ និងធនាគារ ធ្វើការជាមួយស្ថាប័នមីក្រូហិរញ្ញវត្ថុ រកវិធី(**៥)អនុគ្រោះជូនប្រជាជនរងគ្រោះ ដូចជាពន្យារពេលសង ឬសងដោយមិនយកការប្រាក់ ឬបន្ថយការប្រាក់** ទប់ស្កាត់ការឆ្លៀតឱកាសរឹបអូសដីធ្លី ផ្ទះសម្បែង ទ្រព្យសម្បត្តិ។ល។ ពីម្ចាស់បំណុលចំពោះកូនបំណុល ដែលកំពុងជួបការលំបាកដោយសារគ្រោះធម្មជាតិ ...។

១២. ធ្វើឲ្យកសិករទទួលបានប្រយោជន៍ ក្នុងស្ថានភាពពិភពលោកមិនអនុគ្រោះ

សម្ពោធអាគារសិក្សា ប៊ុនរ៉ានី ហ៊ុន សែន អម្ពវ័ន្ត និងស្ពានបេតុង ប្រវែង ១៨០ ម៉ែត្រ
នៅឃុំជំនីក ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ, ថ្ងៃទី ៣០ មីនា ២០១៦

... ទាក់ទិនជាមួយនឹងកសិផល មិនថាស្រូវ ពោត ដំឡូង ឬស្ពឺទេ ពិភពលោកកំពុងជួបប្រទះនូវបញ្ហាដូចៗគ្នា។ នៅប្រទេសថៃ ចំការកៅស៊ូចូលដល់លានហិកតាអត់ចាក់ជ័រទេ ព្រោះមិនរួចថ្លៃដើម។ នៅម៉ាឡេស៊ី ក្រៅពីកៅស៊ូ នៅមានបញ្ហាប្រេងដូងទៀត។ ពិភពលោកកំពុងមានបញ្ហា។ ប្រទេសផលិតប្រេងក៏កំពុងមានបញ្ហាដោយសារប្រេងហ្នឹងវាថោក។ ប៉ុន្តែ**យើងខិតខំរកវិធីយ៉ាងណា ដើម្បីធានាថា កសិកររបស់យើងនឹងទទួលបានផលប្រយោជន៍កាន់តែច្រើនទៅ។ ក្នុងស្ថានភាពដែលពិភពលោកមិនអនុគ្រោះ** ...។

១៣. គោលនយោបាយជំរុញផលិតកម្មស្រូវ ទទួលជោគជ័យ

ពិធីប្រកាសផ្សព្វផ្សាយរបាយការណ៍ជាតិ នៃលទ្ធផលចុងក្រោយជំរឿនកសិកម្ម
នៅ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៣, ថ្ងៃទី ១០ ធ្នូ ២០១៥

... ទាក់ទិនគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ... អ្វីដែលខ្ញុំចង់និយាយ គឺយើងបានដាក់ចេញគោលនយោបាយមានគោលដៅពីរ ទី ១ គឺជំរុញផលិតកម្មស្រូវ និងទី ២ គឺការជំរុញការនាំចេញអង្ករ។ ... ឥឡូវ **យើងអាចនិយាយបានយ៉ាងដូច្នេះថា (យើងបាន)សម្រេចគោលដៅទី ១ គឺការជំរុញផលិតកម្មស្រូវ ជាគោលដៅដែលយើងសម្រេចបានជោគជ័យបានពេញលេញ។ ចាប់ពីប្រទេសយើងសល់អតិរេកស្បៀងតិចតួច (ឥឡូវ)យើងមានអតិរេកស្បៀងស្រូវរហូត ៥ លានតោនក្នុងមួយឆ្នាំ អាចចាត់ទុកថា វាជាជោគជ័យមួយក្នុងវិស័យផលិតកម្មស្រូវរបស់យើង។ ខ្ញុំមិននិយាយទាំងស្រុងអំពីវិស័យកសិកម្មដែលមានជំណាំជទៃទៀតនោះទេ ...**។

១៤. កត្តាអត្តនោម័ត និងកត្តាសត្យានុម័ត នាំឲ្យមិនសម្រេចបានគោលដៅនាំចេញអង្ករ

ពិធីប្រកាសផ្សព្វផ្សាយរបាយការណ៍ជាតិ នៃលទ្ធផលចុងក្រោយជំរឿនកសិកម្ម
នៅ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៣, ថ្ងៃទី ១០ ធ្នូ ២០១៥

... ទី ២ គឺ **ការជំរុញការនាំចេញអង្ករឲ្យបានមួយលានតោនក្នុងមួយឆ្នាំ** ។ គោលដៅនេះ មិនអាចសម្រេចបានទេ។ បើយោងទៅលើតួលេខដែលយើងប្រមូលបានការនាំចេញនៅចុងឆ្នាំ ២០១៥ នេះ បានប្រហែលជាកន្លះលានតោនតែប៉ុណ្ណោះ។ ... មានកត្តា ២ គឺកត្តាអត្តនោម័ត និងកត្តាសត្យានុម័ត។ **កត្តាអត្តនោម័ត ដោយសារយើងធ្លាប់ជាប្រទេសខ្វះស្បៀង ធ្លាប់ជាប្រទេសនាំចូលស្បៀង ... យើងមិនបានត្រៀមខ្លួនសម្រាប់តម្រូវការនៃការនាំចេញទេ។ អ្នកវិនិយោគមួយចំនួន មិនបានសម្លឹងឃើញពីការកើនឡើងយ៉ាងឆាប់រហ័សនៃផលិតកម្មស្រូវរបស់កម្ពុជា ...** ឆ្នាំក្រោយៗ ទៅ យើងនឹងឡើងបណ្តើរៗ(នូវការនាំចេញ)។ ... **អ្វីទៅដែលហៅកត្តាសត្យានុម័ត? នេះមិនមែនជារឿងជាប់ជោយឡែករបស់ប្រទេសកម្ពុជាទេ ក៏ប៉ុន្តែវាជារឿងរបស់តំបន់ និងរបស់ពិភពលោក ដែលថាបណ្តាប្រទេសកំពុង**

អកិវឌ្ឍន៍ផលិតទំនិញដូចៗគ្នា ...៖

១៥. ផ្លាស់ប្តូរការដាំដំណាំស្រូវនៅតំបន់អត់ទឹក មកដាំដំណាំផ្សេងដែលទទួលផលជាង

ពិធីប្រកាសផ្សព្វផ្សាយរបាយការណ៍ជាតិ នៃលទ្ធផលចុងក្រោយជំរឿនកសិកម្ម
នៅ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៣, ថ្ងៃទី ១០ ធ្នូ ២០១៥

... **នេះក៏ជាចំណុចជាក់លាក់មួយ ការធ្វើអង្កេតនេះ គឺតម្រូវឲ្យយើងរៀបចំផែនការដាំដុះ** ... ខ្ញុំបានរំលឹកស្ទើរតែរៀងរាល់ឆ្នាំ។ ឥឡូវយើងមានស្ថិតិ ហើយផែនការដាំដុះនេះទៀតសោតក៏តម្រូវទៅលើស្ថានភាពដី។ យើងអាចផ្លាស់ប្តូរដីតំបន់(គ្មានទឹកនោះ) ឲ្យដាំនូវដំណាំផ្សេង ដែលទទួលផលលើសពីដំណាំស្រូវ។ **ផ្នែកដ៏សំខាន់មួយនៃការរៀបចំផែនការដាំដុះរបស់យើង ហើយផ្នែកកសិកម្មត្រូវប្រើប្រាស់ឲ្យបានល្អបំផុតទៅលើទិន្នន័យ។** ខ្ញុំនៅចាំបានថា **និស្សិតសាកលវិទ្យាល័យកសិកម្មចម្ការដូង សុទ្ធតែបានចុះធ្វើសារណាទាក់ទងនឹងកសិកម្ម ដែលសិក្សាតាំងពីដីអាចដាំអ្វីបាននៅកន្លែងនោះ និងមួយផ្នែកទៀត ពីតម្រូវការទីផ្សារអន្តរជាតិ ...**៖

១៦. ស្រាវជ្រាវពូជ ដែលធន់នឹងការប្រែប្រួលអាកាសធាតុ

សន្និបាតបូកសរុបការងារកសិកម្ម ក្នុងប្រមាញ់ និង នេសាទ ឆ្នាំ ២០១៤/១៥ និង
ទិសដៅ ឆ្នាំ ២០១៥/១៦, ថ្ងៃទី ៨ មេសា ២០១៥

... **កំណើនប្រជាពលរដ្ឋ ជាមួយនឹងទំហំផ្ទៃដីដែលត្រូវបានពង្រីក គឺមានចំនួនមិនតុល្យភាពគ្នា នៅរយៈពេលមធ្យម និងវែងខាងមុខ ... មួយផ្នែកទៀត គឺការប្រែប្រួលអាកាសធាតុនេះតែម្តង។ យើងត្រូវខិតខំធ្វើការស្រាវជ្រាវជាបន្តបន្ទាប់(នូវពូជស្រូវនានា ដែលនឹងមាន)ភាពធន់ជាមួយនឹងការប្រែប្រួលអាកាសធាតុនេះ។** ... ពូជស្រូវយើងធ្លាប់ទ្រាំជាមួយ(សីតុណ្ហភាព) ៣៤-៣៥°c ដល់ឥឡូវឡើងដល់ ៣៨-៤០°c អី តើស្រូវហ្នឹងទ្រាំបានដែរឬអត់? ... តម្លៃផលិតបូកជាមួយធម្មជាតិមិនអនុគ្រោះបែបនេះ ធ្វើឲ្យតម្លៃផលិតកាន់តែខ្ពស់ កសិករនឹងមិនទទួលបានផលចំណេញ ដោយចំណាយច្រើន ...៖

១៧. ស្រាវជ្រាវការផលិតដី/ថ្នាំសម្លាប់សត្វល្អិត និងយន្តតូបនីយកម្មវិស័យកសិកម្ម

សន្និបាតសរុបការងារ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ ២០១៣/១៤ និង ទិសដៅការងារឆ្នាំ ២០១៤/១៥, ថ្ងៃទី ២៨ មីនា ២០១៤

... **ត្រូវខិតខំបន្តធ្វើការស្រាវជ្រាវ ដើម្បីឲ្យការផលិតដី ឬក៏ថ្នាំសត្វល្អិតមានតម្លៃថោក សម្រាប់លក់ជូនដល់កសិករ ... ហើយដំណាក់កាលនៃការធ្វើយន្តតូបនីយកម្មក្នុងវិស័យកសិកម្មនេះ** ក៏ត្រូវតែខិតខំដែរ។ ... កិច្ចព្រមព្រៀងប្រហែលជា ១០ ដែលត្រូវចុះហត្ថលេខានៅក្នុងខែមេសា (២០១៤) ទៅកាន់បេឡារុស និងអាហ្សេរបៃហ្សង់ ... **គ្រឿងយន្តកសិកម្ម ដែលផលិតនៅក្នុងប្រទេសរបស់យើងមិនត្រឹមតែជួយលើកកម្ពស់ការផ្គត់ផ្គង់ខាងផ្នែកកសិកម្មក្នុងស្រុកទេ ក៏ប៉ុន្តែអាចនឹងនាំចេញទៅកាន់ប្រទេសជិតខាង** ដែលត្រូវការនូវគ្រឿងយន្តនេះផងដែរ ...៖

១៨. បន្តចិញ្ចឹមសត្ว អនុវត្តគោលការណ៍កសិកម្មសរីរាង្គ

សន្និបាតបូកសរុបការងារកសិកម្ম រុក្ខាប្រមាញ់ និង នេសាទ ឆ្នាំ ២០១៤/១៥ និង ទិសដៅ ឆ្នាំ ២០១៥/១៦, ថ្ងៃទី ៨ មេសា ២០១៥

... ខ្ញុំកំពុងតែកង្វល់ថា (ចំនួន)កសិករចិញ្ចឹមគោក្របីនៅសល់តិច បានធ្វើឲ្យបាត់បង់ចំនួនគោក្របីរហូតដល់បាត់បង់ជីធម្មជាតិទៀតផង។ កសិករយើងយល់ថាគោដូចគ្នា គោមួយឲ្យស្មៅស៊ី និងឲ្យទឹកផឹក ចង់ទៅណាក៏មិនរួច, ដល់គោមួយទៀត ប្រើវារួចហើយ ទុកចោលនៅផ្ទះ គឺគោយន្ត។ ហ្នឹង គឺជារឿងពិត ... **ខ្ញុំសង្ឃឹមថា ប្រជាពលរដ្ឋបន្តការចិញ្ចឹមសត្ว ទោះបីជាមានគោយន្តក៏ដោយ ព្រោះវាក៏ផ្តល់ឲ្យយើងនូវជីធម្មជាតិ អនុវត្តនូវគោលការណ៍កសិកម្មសរីរាង្គ** ...៖

១៩. ជម្រុញការដាំដុះ និងចិញ្ចឹមសត្ว បន្តយការនាំចូល

សន្និបាតក្រសួងទេសចរណ៍, សាលសន្និសីទ ចតុមុខ, ០៨ កក្កដា ២០១២

... និយាយពី**ពងមាន់ពងទាដែលកសិករចិញ្ចឹម តម្រូវការផ្គត់ផ្គង់ក្នុងស្រុករបស់យើងវាស្ទើរតែគ្រប់**ទៅហើយ។ អ្វីដែលយើងនៅខ្វះ មានដូចជាសាច់គោ។ សាច់គោរបស់យើងអាចបម្រើបានតាមភោជនីយដ្ឋានខ្លះ ប៉ុន្តែមិនទាន់ត្រូវតាម

ស្ដង់ដារថ្នាក់ផ្កាយ ៥ របស់គេទេ។ ចំណុចនេះហើយ ដែលយើងត្រូវ **ជម្រុញការដាំដុះ និងការចិញ្ចឹមសត្ព ដើម្បីធានាការផ្ដត់ផ្ដង់ និងកាត់បន្ថយការនាំចូល។ មុននេះ យើងថាត្រូវឲ្យមានខ្សែក្រវ៉ាត់បៃតងនៅជុំវិញតំបន់ទេសចរណ៍ យោងលើប្រការថា ទេសចរពង្រាយទៅគ្រប់ទីកន្លែង ទាំងទេសចរបរទេស និងទេសចរក្នុងស្រុក ... ត្រូវបន្ដជម្រុញការផលិត ចិញ្ចឹមសត្ព ការនាំចេញនៅនឹងកន្លែង ពោលគឺនាំចូលទៅក្នុងសណ្ឋាគារ និងភោជនីយដ្ឋាន ...**។

២០. ជម្រុញការស្ដារអាងទឹក បឹង និងការចិញ្ចឹមត្រី

ទិវាមច្ឆជាតិ ១ កក្ដដា អាងទឹកខ្នាច, ភូមិវត្ត ឃុំទួលព្រះឃ្លាំង ស្រុកស្ទឹងត្រង់ ខេត្ដកំពង់ចាម, ថ្ងៃទី ០១ កក្ដដា ២០១៥

... យោងរបាយការណ៍(ឯកឧត្ដម អ៊ុក រ៉ាប៊ុន) ឆ្នាំ ២០១៤ ចំនួនត្រីចិញ្ចឹមបានឡើងទៅដល់ ៣០ ម៉ឺនតោន ប្រៀបទៅនឹងឆ្នាំមុននោះ គឺបានត្រឹមតែ ១២ ម៉ឺនតោន ... **យើងចង់ឲ្យមានការចិញ្ចឹមត្រីឲ្យបានច្រើន។ បើយើងពិនិត្យមើល ពិភពលោក មានប្រទេសមិនច្រើនទេ ដែលប្រើប្រាស់ត្រីជម្មជាតិចិញ្ចឹមប្រជាពលរដ្ឋ ... រហូតមានប្រទេសខ្លះ ចិញ្ចឹមត្រីបម្រើឲ្យការនាំចេញផង ដូចជាប្រទេសវៀតណាម** (ឯកឧត្ដមនាយករដ្ឋមន្ត្រីវៀតណាម ប្រាប់ថាវៀតណាមចិញ្ចឹម និងនាំចេញត្រីទីឡាព្យ៉ា បានជាង ២.០០០ លានដុល្លារសហរដ្ឋអាមេរិក) ... ដូចជានៅទីនេះ ពេលយើងបានស្ដារអាងទឹក យើងព្រលែងកូនត្រី ...។

២១. ប្រគល់ឡូត៍នេសាទឲ្យប្រជាពលរដ្ឋ

ចែកសញ្ញាបត្រជូននិស្សិតសកលវិទ្យាល័យបៀលប្រាយ,
ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១២

... ដើម្បីលុបឡូត៍នេសាទ យើងត្រូវរកឯកសារតាំងពីដើមមក ដូចជាព្រះរាជបញ្ញត្ដិរបស់សម្ដេចព្រះនរោត្ដម ស្ដីពីការធានាចរាចរណ៍ផ្លូវទឹក ... ការដាក់ធ្នស់ ដាក់ព្ជួល កាត់ព្រៃក។លម។ ព្រះរាជបញ្ញត្ដិរបស់ព្រះបាទស៊ីសុវត្ថិ នៅឆ្នាំ ១៩០៨ ស្ដីពីការបង្កើតឲ្យមានឡូត៍នេសាទ ហើយផ្ដាច់មុខឲ្យពួកថៅកែ។ និងមួយផ្នែកទៀតអនុញ្ញាតឲ្យនេសាទដោយសេរី ប៉ុន្ដែត្រូវបង់ពន្ធលើឧបករណ៍ជាដើម។ ...

ដល់ឆ្នាំ ២០០០ យើងកាត់ឡូត៍នេសាទក្នុងកំណែទម្រង់ទី ១ តែវានៅមានបញ្ហាច្របូកច្របល់រវាងម្ចាស់ឡូត៍នេសាទ និងប្រជាពលរដ្ឋ។ ជាជំហានចុងក្រោយ គឺលុបចោលឡូត៍នេសាទទាំងអស់តែម្តង ប្រគល់ឡូត៍នេសាទនោះឲ្យប្រជាពលរដ្ឋ។ នៅប្រទេសកម្ពុជាចាប់ពីថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០១២ មក គ្មានម្ចាស់ឡូត៍នេសាទទេ ហើយផ្នែកខាងលើនេះ ចាប់ពីថ្ងៃទី ១០ ខែ មេសា មកគ្មានម្ចាស់ឡូត៍នេសាទទៀតទេ។ អ្វីដែលនៅសេសសល់ គឺឡូត៍តំបន់អភិរក្ស ហើយដែលតំបន់អភិរក្សនេះ អត់មានអ្នកណាមានសិទ្ធិចាប់ត្រីទេ ទាំងរដ្ឋ ទាំងឯកជន។ គឺជាកន្លែងចិញ្ចឹមត្រីទុកឲ្យប្រជាពលរដ្ឋតែប៉ុណ្ណោះ ...។

២២. ខណ្ឌព្រៃឈើ ជលផល នៅក្នុងគណៈបញ្ជាការខេត្ត

> សន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឆ្នាំ ២០១៤/១៥ និងទិសដៅ ឆ្នាំ ២០១៥/១៦, ថ្ងៃទី ៨ មេសា ២០១៥

... ព្រៃឈើ ជាបញ្ហាធ្ងន់ធ្ងរ ទាមទារនូវការទទួលខុសត្រូវ ដែលមិនអាចឆ្លើយដាក់គ្នានោះទេ។ រឿងនេះ មិនមែននិយាយម្តង ឬពីរម្តងនោះទេ។ ឥឡូវនេះ **អំណាចបានទំលាក់ទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិហើយ។ បើទោះបីជា ច្បាប់ស្តីអំពីបញ្ហាព្រៃឈើ និងច្បាប់ស្តីអំពីនេសាទ មិនទាន់បានធ្វើវិសោធនកម្មអំពីរចនាសម្ព័ន្ធរបស់វាក៏ដោយចុះ ក៏យើងបានឲ្យរដ្ឋបាល ហៅថា ខណ្ឌព្រៃឈើ ឬខណ្ឌជលផល ទៅនៅក្នុងគណៈបញ្ជាការខេត្តហើយ** ...។

២៣. ដកហូតដីហើយ ឱ្យសងតម្លៃឈើទៀត

> សន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឆ្នាំ ២០១៤/១៥ និងទិសដៅ ឆ្នាំ ២០១៥/១៦, ថ្ងៃទី ៨ មេសា ២០១៥

... យើងមានយន្តការវាស់វែង និងពិនិត្យដីសម្បទានទាំងអស់។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺប្រមាណជាង ១៧ ម៉ឺនហិកតា បានដកចេញពី ៨ ក្រុមហ៊ុន, ក្រសួងបរិស្ថាន ប្រមាណជាជាង ១០ ម៉ឺនហិកតា ពី ២៣ ក្រុមហ៊ុន។ នៅមានបន្តទៀត។ ... **បើត្រឹមតែដកដី វាមិនទាន់គ្រប់តម្លៃដែលអ្នកឯងបំផ្លាញទេ ... ដីខ្លះ អ្នកឯងមិនបានធ្វើអីផង បានត្រឹមតែកាប់ឈើ។ យើងទៅដកហូតដីហ្នឹង**

ដូចជាឲ្យគាត់រួចខ្លួនយ៉ាងស្រួល។ ត្រូវចាប់ឲ្យគាត់សងការកាប់ព្រៃនោះ ទើបវាគ្រប់គ្រាន់នឹងតម្លៃ ... អស់លោកត្រូវមើល ចំណុចទី ១ គាត់ធ្វើកន្លែងណាដែលមានដើមឈើ ដើម្បីគាត់កាប់ឈើ និងចំណុចទី ២ ធ្វើកន្លែងណាដែលពាក់ព័ន្ធជាមួយប្រជាជន ...។

២៤. កៅស៊ូជាគម្របព្រៃឈើ និងទទួលផលច្រើន

សន្និបាតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ ២០១២/១៣, សាកលវិទ្យាល័យកូមិន្ទកសិកម្ម(ចំការដូង), ថ្ងៃទី ២៦ ខែ មេសា ២០១៣

... កៅស៊ូ គឺជាផ្នែកដ៏សំខាន់មួយ ដែលយើងអាចនឹងមានការប្រកួតប្រជែង។ តម្រូវការកៅស៊ូអត់មានការថយចុះទេ។ វាដូចគ្នានឹងស្រូវអង្ករដែរ។ អញ្ចឹងទេ ដោយសារកៅស៊ូជាប្រភេទគម្របព្រៃឈើ ដូច្នេះ (គប្បី)**ជម្រុញការដាំកៅស៊ូទាំងលើផ្ទៃដីដែលយើងបានផ្តល់ជាសម្បទានសេដ្ឋកិច្ចក្តី ឬក៏ផ្តល់ជូនប្រជាជននៅក្នុងក្របខណ្ឌនយោបាយចាស់សកម្មភាពថ្មី លើវិស័យដីធ្លីក្តី។ ... ដាំកៅស៊ូបានកាន់តែច្រើន គម្របព្រៃឈើវាកាន់តែច្រើន ហើយទទួលផលត្រឡប់មកវិញ ក៏វាច្រើនដែរ**។ កៅស៊ូ ១ តោន ឥឡូវនៅប៉ុន្មាន ... វាឡើងចុះអញ្ចឹង។ កាលពីឆ្នាំ ១៩៩៧ (តម្លៃកៅស៊ូ)ធ្លាក់រហូត ដល់ ៦០០ ដុល្លារ/តោន។ ពេលនោះសុំថាឲ្យយកពន្ធសូន្យ ... ចំណុចសំខាន់គឺប្រជាជនចង់ដាំកៅស៊ូលក្ខណៈគ្រួសារ ...។

២៥. ក្រសួងកសិកម្ម ... ឬក្រសួងបរិស្ថាន សុំបញ្ចូលឈើក្រញូង ក្នុងបញ្ជីរុក្ខជាតិកម្រ

សន្និបាតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ ២០១២/១៣
(សាកលវិទ្យាល័យ កូមិន្ទកសិកម្ម), ថ្ងៃទី ២៦ មេសា ២០១៣

... **បញ្ហាឈើក្រញូង ខ្ញុំបានលើកក្នុងអង្គប្រជុំ CLV, CLMV និង ACMECS ផងដែរ ... ស្នើឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬក្រសួងបរិស្ថានសរសេរលិខិត(សុំ)បញ្ចូល(ឈើក្រញូង)ទៅក្នុងបញ្ជីរុក្ខជាតិកម្រជិតផុតពូជ** ... យើងមិនមានឈើក្រញូងច្រើនទេ ក៏ប៉ុន្តែគេកាប់ និងបញ្ជូនមកក្នុងប្រទេសកម្ពុជា ហើយនាំចេញទៅទៀត។ បើកាលណាយើងដាក់ឈើប្រភេទនេះចូលក្នុងបញ្ជី បាន នរណាក៏មិនហ៊ានទិញដែរ ...។

កាកបាទក្រហមកម្ពុជា

១	បង្កើតក្រុមយុវជនកាកបាទក្រហមតាមវិទ្យាល័យ/សាកលវិទ្យាល័យ	១៧
២	ការបំពេញឲ្យគ្នា រវាងអាជ្ញាធរ ជាមួយនិងកាកបាទក្រហមកម្ពុជា	១៧
៣	ឯកភាពជាមួយនឹងវិស័យស្នូលទាំង ៤ របស់កាកបាទក្រហម	១៨
៤	វិមជ្ឈការ៖ កាកបាទក្រហម ដើរមុខស្ថាប័នរដ្ឋ	១៨
៥	កាកបាទក្រហមកម្ពុជា ជួយទ្រទ្រង់សភាពការណ៍ធំៗ ៣ ក្នុងប្រទេស	១៩
៦	សេវាសង្គ្រោះដោយកាកបាទក្រហម លឿនជាងរដ្ឋបាល	១៩
៧	សិល្ប:នៃការចែករំលែក មាន ២ ប្រភេទ លើពិភពលោក	១៩
៨	កាកបាទក្រហមចូលរួម កំចាត់មីន និងគ្រាប់មិនទាន់ផ្ទុះ	២០
៩	ហេដ្ឋារចនាសម្ព័ន្ធសហគមន៍ ផលប្រយោជន៍មិនចេះរីងស្ងួត	២០
១០	បន្តអនុវត្តនូវប្រធានបទ «កម្លាំងស្ម័គ្រចិត្ត ប្រសិទ្ធិភាព មនុស្សធម៌»	២១
១១	«ខ្ញុំ និងកាកបាទក្រហម» សាមញ្ញ តែស៊ីជំរៅ	២១
១២	កាកបាទក្រហមត្រូវការ ការចូលរួមពីរាជរដ្ឋាភិបាល តែត្រូវរក្សាឯករាជ្យ	២២

១. បង្កើតក្រុមយុវជនកាកបាទក្រហមតាមវិទ្យាល័យ និងសាកលវិទ្យាល័យ

ពិធីប្រគល់សញ្ញាបត្រដល់ និស្សិតនៃសាកលវិទ្យាល័យធនធានមនុស្ស,
វិទ្យាស្ថានជាតិអប់រំ, ថ្ងៃទី ០១ កញ្ញា ២០១០

... បន្ទាប់ពីកម្មវិធីបង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ៤ កន្លែង នៅអង្គស្ទួល ក្រាំងចេក ពោធិសាត់ និងព្រះវិហារ ជាពិសេស ផ្តោតទៅលើស្ត្រី លើវិស័យកាត់ដេរ តម្បាញ តុបតែង ការអ៊ុតសក់ កែសម្ផស្ស ស្ទីវ ជាដើម ។ល។ (ភរិយាខ្ញុំ) បានដើរមួយជំហានទៀត ដោយបង្កើតឡើងនូវក្រុមយុវជន កាកបាទក្រហម ក្នុងចំណោមសិស្សវិទ្យាល័យ និងនិស្សិតនៅតាមសាកលវិទ្យាល័យ ...។ (ភរិយាខ្ញុំ) បានស្នើសុំអាហារូបករណ៍ ដែលខ្ញុំបានទទួលពីសាកលវិទ្យាល័យនានា អោយចែករំលែកជូនគាត់ខ្លះ ដើម្បីគាត់ផ្តល់ឱ្យយុវជន កាកបាទក្រហមដែលប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ តែខ្វះលទ្ធភាពបង់ថ្លៃសិក្សា ដើម្បីបានចូលរៀនមហាវិទ្យាល័យ ...។

២. ការបំពេញឲ្យគ្នាទៅវិញទៅមក រវាងអាជ្ញាធរ ជាមួយនិងកាកបាទក្រហមកម្ពុជា

ពិធីបិទសន្និបាតកាកបាទក្រហមអាណត្តិទី ៥ នៅស្នាក់ការកាកបាទក្រហម,
រាជធានី ភ្នំពេញ, ថ្ងៃទី ០៥ សីហា ២០១០

... រយៈពេលកន្លងទៅ ហាក់ដូចជា **មានសមាហរណកម្មជាធម្មជាតិ រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និយាយឱ្យចំថ្នាក់ខេត្ត ស្រុក ជាមួយនឹងយន្តការកាកបាទក្រហមកម្ពុជា។ នេះមិនមែនជាការងាយស្រួលទេ។ ប៉ុន្តែ ដោយសារការគិតគូរខ្ពស់ និងវិធីដ៏ឈ្លាសវៃស្របតាមកាលៈទេសៈ និងស្ថានភាពជាក់ស្តែងរបស់កម្ពុជា យើងអាចធ្វើបាន** ដោយអភិបាលខេត្ត ជាប្រធានកិត្តិយសនៃកាកបាទក្រហមកម្ពុជាថ្នាក់ខេត្ត ក្នុងហ្នឹងក៏មានភរិយា ឬក៏មានអនុខេត្ត ជាប្រធានសាខាកាកបាទក្រហមកម្ពុជាផង ... ពេលកើតគ្រោះអាសន្ន យើងបានឃើញទិដ្ឋភាពរួមគ្នា ជាធម្មជាតិ ធ្វើសកម្មភាពព្រមគ្នា។ ពេលខ្លះចៅហ្វាយខេត្ត ពាក់អាវកាកបាទក្រហមតែម្តង។ នេះបង្ហាញឱ្យឃើញអំពីការបំពេញរួមគ្នា ព្រោះបើធ្វើបែកគ្នា វាមិនអាចក្លាយទៅជាកម្លាំងសរុបបានទេ ...។

៣. ឯកភាពជាមួយនឹងវិស័យស្នូលទាំង ៤ របស់កាកបាទក្រហម

ខួបលើកទី ១៥៣ ទិវាពិភពលោក កាកបាទក្រហម និងអឌ្ឍចន្ទក្រហម, ថ្ងៃទី ៨ ឧសភា ឆ្នាំ ២០១៦

... សូមយកឱកាសនេះ សម្តែងនូវការឯកភាពជាមួយនឹងយុទ្ធសាស្ត្រដែលប្រធានកាកបាទក្រហមកម្ពុជាបានលើកឡើង រួមមានវិស័យស្នូលទាំង ៤៖ **ការគ្រប់គ្រងគ្រោះមហន្តរាយ, សុខភាព និងការថែរក្សាសុខភាពក្នុងសហគមន៍, លើកកម្ពស់គោលការណ៍គ្រឹះនៃតម្លៃមនុស្សធម៌, ការអភិវឌ្ឍស្ថាប័ន និងធនធានកាកបាទក្រហមកម្ពុជា** ចូលរួមចំណែកជាមួយនឹងរាជរដ្ឋាភិបាលក្នុងការកសាង និងអភិវឌ្ឍប្រទេសជាតិតាមរយៈគម្រោង និងកម្មវិធីនៅតាមបណ្តាសហគមន៍ ក្នុងខេត្តនានា ដូចជាគម្រោងទឹកស្អាត និងអនាម័យ គម្រោងប្រាក់កម្ចីខ្នាតតូចពុំយកការប្រាក់ ... សុវត្ថិភាពចរាចរណ៍ សុខភាពសហគមន៍មូលដ្ឋាន វិជ្ជាសង្គ្រោះបឋម ជាដើម។ល។ ដែលដើរស្របជាមួយនឹងគម្រោងរបស់រាជរដ្ឋាភិបាល ...។

៤. វិមជ្ឈការ៖ កាកបាទក្រហម ដើរមុខស្ថាប័នរដ្ឋ

សន្និបាតកាកបាទក្រហម អាណត្តិទី ៥, ស្នាក់ការកាកបាទក្រហម រាជធានីភ្នំពេញ, ថ្ងៃទី ០៥ សីហា ២០១០ និង ទិវាកាកបាទក្រហមពិភពលោក លើកទី ១៥១ ថ្ងៃទី ០៨ ឧសភា ២០១៤

... មកដល់ពេលនេះ សាខាទាំងនោះមានធនធានចាំបាច់នៅក្នុងដៃ ... បានសេចក្ដីថា ពេលដំណើរការ គឺមានថវិកាក្នុងដៃកាកបាទក្រហម។ ក្នុងទិវាកន្លងទៅនេះ ទទួលបានជាង ៧ លានដុល្លារ ហើយនៅតាមសាខាមួយៗ ... ឯ ៧ លានដុល្លារនេះ **ថ្នាក់កណ្តាល ក៏ បានចែករំលែក គេហៅថា ធ្វើវិមជ្ឈការ វិសហមជ្ឈការ ផ្តល់អំណាចឱ្យទៅមូលដ្ឋាន ដោយមិនចាំបាច់មានអន្តរាគមន៍ពីថ្នាក់លើទេ។ នេះជាចំណុចមួយ ដែលកាកបាទក្រហមកម្ពុជា បានដើរមុខស្ថាប័នរដ្ឋ បានសេចក្ដីថា អាចជាបទពិសោធន៍គំរូមួយរបស់ស្ថាប័នរដ្ឋ អំពីការធ្វើវិមជ្ឈការ ឱ្យអំណាចទៅសាខានៅឯមូលដ្ឋាន** ក៏ដូចជាក្រសួងស្ថាប័ន ដែលត្រូវឱ្យអំណាចទៅថ្នាក់ខេត្តផងដែរ ...។

៥ .កាកបាទក្រហមកម្ពុជា ជួយទ្រទ្រង់សភាពការណ៍ធំៗ ៣ ក្នុងប្រទេស

ពិធីមិទ្ធិញរំលឹកខួបទី ១៤៨ ទិវាពិភពលោក កាកបាទក្រហម អឌ្ឍចន្ទក្រហម, ស្នាក់ការកណ្តាល កាកបាទក្រហម, រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ឧសភា ២០១១

... (កាកបាទក្រហម បាន) ទ្រទ្រង់សភាពការណ៍ធំៗ បី ពាក់ព័ន្ធជាមួយនឹងមហន្តរាយធ្ងន់ធ្ងរនៅក្នុងប្រទេស ... មហន្តរាយ**ទី ១ គឺឧបទ្ទវហេតុលើស្ពានពេជ្រ** ដែលបានកើតឡើងក្រោយការប្រារព្ធពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុកសំពះព្រះខែ នៅរាជធានីភ្នំពេញ ... ជួយសង្គ្រោះ និងកាត់បន្ថយការលំបាកដល់ជនរងគ្រោះ, **ទី ២ ជួយដល់ជនភៀសសឹកនៅខេត្តព្រះវិហារ ខែ កុម្ភៈ ឆ្នាំ ២០១១** បណ្តាលមកពីការឈ្លានពាននៃកងទ័ពថៃ ... និង**សភាពការណ៍ ទី ៣ គឺជនភៀសសឹក នៅខេត្ត ឧត្តរមានជ័យ** ជាង ១ ម៉ឺនគ្រួសារ ស្មើនឹងមនុស្សជាង ៤ ម៉ឺននាក់ ដែលជាទំហំមួយដ៏ធំ ...។

៦. សេវាសង្គ្រោះដោយកាកបាទក្រហម លឿនជាងរដ្ឋបាល

ពិធីចែកវិញ្ញាបនបត្រដល់កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ និងមធ្យម និងបើកវគ្គបណ្តុះបណ្តាល ឆ្នាំ ២០០៩ ភ្នំពេញ, សាលាភូមិន្ទរដ្ឋបាល, ថ្ងៃទី ១៧ មិថុនា ២០០៩

... ពេលខ្លះ **សេវាកាកបាទក្រហមលឿនជាងសេវារដ្ឋបាល។ បើនិយាយពីផ្នែកគ្រប់គ្រងគ្រោះមហន្តរាយវិញ សេវាកាកបាទក្រហមលឿនជាង ... (នេះ) សុទ្ធតែស្រីៗ ផង ... អាចនិយាយបានថា ផ្នែកសេវាទាក់ទងនឹងការសង្គ្រោះប្រជាពលរដ្ឋនៅពេលខេត្តមានអាសន្នអន់ក្រ ផ្នែករដ្ឋបាលទៅយឺត ជាងកាកបាទក្រហមជានិច្ច**។ អញ្ចឹងទេ សុំសរសើរកាកបាទក្រហមគ្រប់ថ្នាក់ ជាពិសេសសាខា នៅតាមបណ្តាខេត្ត ដែលជួយដល់ផ្នែករដ្ឋបាលថ្នាក់ក្រោមជាតិបានច្រើន សូម្បីសេវាចរាចរណ៍ ក្នុងក្រុងភ្នំពេញក៏យុវជនកាកបាទក្រហមក្រុងភ្នំពេញជួយធ្វើ ...។

៧. សិល្បៈនៃការចែករំលែក មាន ២ ប្រភេទ លើពិភពលោក

ខួបលើក ទី ១៥៣ ទិវាពិភពលោក កាកបាទក្រហម និងអឌ្ឍចន្ទក្រហម, ថ្ងៃទី ៨ ឧសភា ឆ្នាំ ២០១៦

... សូមសម្តែងនូវការអរគុណ ចំពោះសប្បុរសជននានា ដែលបានជួយដល់កាកបាទក្រហមកម្ពុជា តាមរយៈទិវានេះក្តី និងតាមរយៈនៃការធ្វើសកម្មភាពដោយផ្ទាល់ ចុះទៅដល់មូលដ្ឋាន ចូលរួមចំណែកសង្គ្រោះ និងជួយដល់ប្រជាជនក្រីក្រ ... នេះជា**សិល្ប៍ៈនៃការចែករំលែក ដែលពិភពលោកទាំងមូលកំពុងតែប្រើប្រាស់ ...វិធីនៃការចែករំលែកមានពីរប្រភេទ គឺ ទី ១ ការចែករំលែកដោយកាតព្វកិច្ចដែលច្បាប់តម្រូវ ដូចជាអ្នកដែលមានលទ្ធភាព អ្នកធ្វើធុរកិច្ច ធ្វើការបង់ពន្ធជូនរដ្ឋ ធ្វើឲ្យរាជរដ្ឋាភិបាលមានលទ្ធភាពប្រើប្រាស់នូវថវិកា បានមកពីការបង់ពន្ធ សម្រាប់អភិវឌ្ឍ និងដោះស្រាយបញ្ហាទាំងឡាយ ជាតម្រូវការរបស់ប្រទេសជាតិ និងសិល្ប៍ៈនៃការចែករំលែកតាមរយៈនៃសកម្មភាពមនុស្សធម៌ ប្រមូលផ្តុំធនធាន ជាវិធីដែលផ្សារភ្ជាប់រវាងអ្នកមាន និងអ្នកខ្វះលទ្ធភាព ...**។

៨. កាកបាទក្រហមចូលរួម កំចាត់មីន និងគ្រាប់មិនទាន់ផ្ទុះ

ពិធីមិទ្ធិញរំលឹកខួបទី ១៤៨ ទិវាពិភពលោក កាកបាទក្រហម អឌ្ឍចន្ទក្រហម,
ស្នាក់ការកណ្តាលកាកបាទក្រហម, រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ឧសភា ២០១១

... ក្នុងបញ្ហាមីន និងគ្រាប់មិនទាន់ផ្ទុះ សូមអំពាវនាវចំពោះកាកបាទក្រហមកម្ពុជា អាជ្ញាធរប្រតិបត្តិការបំផ្លាញចោលគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ យកចិត្តទុកដាក់លើតំបន់ប្រយុទ្ធគ្នាកាលពីខែកុម្ភៈដែលមានគ្រាប់បែកចង្កោម និងគ្រាប់មិនទាន់ផ្ទុះមួយចំនួន (ដែល)មិនទាន់បានបំផ្លាញ ... សូមឲ្យ**អាជ្ញាធរគ្រប់ថ្នាក់ផ្នែកពាក់ព័ន្ធ ដូចជាកាកបាទក្រហមកម្ពុជា ចូលរួមអប់រំប្រជាពលរដ្ឋ ឲ្យមានការប្រុងប្រយ័ត្ន និងត្រូវធ្វើសកម្មភាពយកគ្រាប់ដែលមិនទាន់ផ្ទុះនោះចេញ បញ្ចៀសគ្រោះថ្នាក់ដល់អាយុជីវិតប្រជាពលរដ្ឋ ... (នេះជាបទពិសោធន៍មួយថា យើងត្រូវចៀសវាងសង្គ្រាម)**។

៩. ហេដ្ឋារចនាសម្ព័ន្ធសហគមន៍ ផលប្រយោជន៍មិនចេះរីងស្ងួត

ខួបលើក ទី ១៥៣ ទិវាពិភពលោក កាកបាទក្រហម និងអឌ្ឍចន្ទក្រហម,
ថ្ងៃទី ៨ ឧសភា ឆ្នាំ ២០១៦

... សូមកាកបាទក្រហមកម្ពុជា **បន្តប្រើប្រាស់មូលនិធិដែលទទួលបានពីសប្បុរសជននៅថ្ងៃនេះ ឬនៅថ្ងៃក្រោយទៀត សំដៅដោះស្រាយបញ្ហាហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ជាពិសេសការផ្គត់ផ្គង់ទឹក តាមរយៈការផ្តល់ស្រះ និងឬ អណ្តូងដល់សហគមន៍មូលដ្ឋាន។ នេះជាការទទួលផលពិតប្រាកដ ហើយជាការទទួលផលដោយមិនចេះរីងស្ងួត។** ទោះបីជាថ្ងៃក្រោយ កាកបាទក្រហមកម្ពុជា គ្មានសមត្ថភាពដើម្បីនឹងរៃអង្គាសបន្តទៀត ប៉ុន្តែអណ្តូងទឹក និងស្រះទឹកដែលបានផ្តល់ជូនទៅសហគមន៍មូលដ្ឋាននោះ មិនរីងស្ងួតទេ។ **អំពាវនាវកាកបាទក្រហមកម្ពុជា ស្ថាប័នរដ្ឋ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ បន្តការខិតខំជីកស្រះថ្មី ស្តារស្រះចាស់ ជីកអណ្តូងថ្មី និងស្តារអណ្តូងចាស់ ដើម្បីផ្តល់នូវលទ្ធភាពជូនប្រជាពលរដ្ឋរបស់យើងនៅពេលក្រោយ ... ការអំពាវនាវរបស់ខ្ញុំនេះ ដើរស្របគ្នាជាមួយនឹងតួនាទី និងសមត្ថកិច្ចរបស់កាកបាទក្រហមកម្ពុជា ជាជំនួយការឲ្យអាជ្ញាធរសាធារណៈក្នុងវិស័យមនុស្សធម៌ ...**។

១០. បន្តអនុវត្តនូវប្រធានបទ «កម្លាំងស្មគ្រចិត្ត ប្រសិទ្ធភាពមនុស្សធម៌»

ពិធីមិទ្ធិញរំលឹកខួបទី ១៤៨ ទិវាពិភពលោក កាកបាទក្រហម អឌ្ឍចន្ទក្រហម, ស្នាក់ការកណ្តាល កាកបាទក្រហម, រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ឧសភា ២០១១

... ប្រធានបទ "កម្លាំងស្មគ្រចិត្ត ប្រសិទ្ធភាពមនុស្សធម៌" សមស្របជាមួយប្រធានបទ ដែលកម្ពុជាបានឆ្លងកាត់រយៈកាលមួយឆ្នាំកន្លងផុតទៅ ... **កម្លាំងស្មគ្រចិត្ត ប្រសិទ្ធភាពមនុស្សធម៌នេះឯង (ជួយអោយ)យើងជំនះបាន សូម្បីតែសង្គ្រាមជាយជែននៅខេត្តឧត្តរមានជ័យ ដែលមានការចិញ្ចឹមមនុស្សជាង ៤ ម៉ឺននាក់ ... មានការចូលរួមពីគ្រប់មជ្ឈដ្ឋាន យើងជំនះបាននូវការលំបាក មិនទុកឱ្យប្រជាពលរដ្ឋណាម្នាក់ស្លាប់ដោយជាប់បាយ បន្ទាប់ពីការត់ចោលផ្ទះសម្បែង មកកាន់តំបន់សុវត្ថិភាព ...** ។

១១. «ខ្ញុំ និងកាកបាទក្រហម» សាមញ្ញ តែស៊ីជំរៅ

ទិវាកាកបាទក្រហមពិភពលោក លើកទី ១៥១, ថ្ងៃទី ០៨ ឧសភា ២០១៤

... ប្រធានបទ **«ខ្ញុំ និងកាកបាទក្រហម» ជាឃ្លាសាមញ្ញ ក៏ប៉ុន្តែគឺជាប្រធានបទដែលមានភាពស៊ីជម្រៅ ... ប្រធានបទនេះ បានទៅដល់អ្នកកំពុងធ្វើ សកម្មភាពនៃកាកបាទក្រហម** ក្នុងនោះ មានតាំងពីមន្ត្រីកាកបាទក្រហមថ្នាក់កណ្តាលតាមសាខា អនុសាខាយុវជនកាកបាទក្រហម និងអ្នកស្ម័គ្រចិត្ត ... **អ្នកផ្តល់ជំនួយសម្រាប់សកម្មភាពមនុស្សធម៌ (រាប់ទាំង) ការរួមចំណែកជាថវិកា/សម្ភារៈ រហូតដល់អ្នកដែលបានបរិច្ចាគឈាម** ... ។

១២. កាកបាទក្រហមត្រូវការ ការចូលរួមពីរាជរដ្ឋាភិបាល តែត្រូវរក្សាឯករាជ្យភាព

ទិវាកាកបាទក្រហមពិភពលោក លើកទី ១៥១, ថ្ងៃទី ០៨ ឧសភា ២០១៤

... កាកបាទក្រហមកម្ពុជាត្រូវការពីរយ៉ាង ក្នុងសកម្មភាព(របស់ខ្លួន) **ទី១ ការចូលរួមជាមួយភ្នាក់ងាររាជរដ្ឋាភិបាល ដែលមានទាំងកងកម្លាំងប្រដាប់អាវុធ ទាំងមន្ត្រីនៅឯមូលដ្ឋាន ដើម្បីឱ្យពួកគាត់អាចចូលទៅតំបន់រងគ្រោះ ជួយដល់ប្រជាជនរងគ្រោះបាន**។ គាត់មិនអាចទៅម្នាក់ឯងបានទេ ត្រូវការនូវការសម្របសម្រួលដើម្បីអាចធ្វើដំណើរទៅដល់មុខសញ្ញាដែលត្រូវជួយសង្គ្រោះ។ ម្ខាងទៀត **គាត់ត្រូវរក្សាឯករាជ្យភាព ដែលចំណុចនេះមានសារៈសំខាន់ណាស់។ បើសិនជាអាជ្ញាធរបង្ហាប់បញ្ជាទៅលើកាកបាទក្រហមកម្ពុជា វានឹងធ្វើឱ្យបាត់បង់ឯករាជ្យភាព** ដែលជាគោលការណ៍មួយរបស់កាកបាទក្រហម ...។

ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១	រកទីផ្សារការងារក្នុង និងក្រៅប្រទេស ទប់ស្កាត់ចំណាកស្រុកខុសច្បាប់	២៥
២	រាជរដ្ឋាភិបាលស្វែងរកទីផ្សារនាំចេញ និងវិនិយោគ ដើម្បីបង្កើតការងារ	២៥
៣	ខំបង្កើតការងារ និងយកចិត្តទុកដាក់ផ្សព្វផ្សាយពីការងារក្នុងស្រុក	២៦
៤	ដោះស្រាយការបញ្ជូនពលករពីប្រទេសថៃ ត្រឡប់មកកម្ពុជាវិញ	២៧
៥	លិខិតឆ្លងដែនមិនយកប្រាក់, ធ្វើលិខិតឆ្លងដែនតាមគោលដៅអាទិភាព	២៧
៦	យកចិត្តទុកដាក់ពីពលកម្មជំនាញ ចូលសហគមន៍សេដ្ឋកិច្ចអាស៊ាន	២៨
៧	ស្រាយបញ្ហាផ្លែទឹក និងអគ្គិសនី ជូនកម្មករ/ការិនី	២៨
៨	កម្មករ-សហជីព និងថៅកែរោងចក្រ/សហគ្រាស ជាដៃគូខ្វះមិនបាន	២៩
៩	កម្មករសុខភាពល្អ ទិន្នផលការងារល្អ	៣០
១០	កម្មករ/ការិនី រួមចំណែករក្សាការងារ កំណើន ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច	៣០

១. រកទីផ្សារការងារទាំងក្នុង និងក្រៅប្រទេស ទប់ស្កាត់ចំណាកស្រុកខុសច្បាប់

ពិធីសម្ពោធសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ, ថ្ងៃទី ១១ កុម្ភៈ ២០១៦

... អ្វីដែលរាជរដ្ឋាភិបាលត្រូវតែខិតខំទប់ស្កាត់ គឺចំណាកស្រុកខុសច្បាប់។ ទៅរកការងារដែលត្រូវច្បាប់ គឺជាវិធីដោះស្រាយការងារធ្វើឲ្យពលរដ្ឋ។ ... ហ្វីលីពីន មានពលករចេញទៅក្រៅប្រទេសជាង ១០ លាននាក់។ ឥឡូវ ជនជាតិហ្វីលីពីន ដែលមកធ្វើការនៅប្រទេសយើងរាំតាមបារធំៗ ភោជនីយដ្ឋានធំៗ អ្នកមើលកូនជនបរទេសក្នុងប្រទេសយើង(មាន)លើសម៉ឺន អញ្ចឹង **វិធីដោះស្រាយការងារធ្វើ មិនមែនគ្រាន់តែដោះស្រាយការងារក្នុងស្រុកទេ ការរកទីផ្សារការងារនៅក្រៅស្រុក ក៏ជាផ្នែកមួយនៃកិច្ចការរបស់រាជរដ្ឋាភិបាលត្រូវរកឲ្យពលរដ្ឋរបស់ខ្លួន** ...។

២. រាជរដ្ឋាភិបាលស្វែងរកទីផ្សារនាំចេញ និងវិនិយោគ ដើម្បីបង្កើតការងារ

ពិធីសំណេះសំណាល ជាមួយនិយោជិត កម្មករ-កម្មការិនី នៅកំពង់ផែស្វយ័ត, ក្រុងព្រះសីហនុ, ថ្ងៃទី ០១ ឧសភា ២០១៣

... **យើងអនុវត្តនយោបាយបែរមុខទៅខាងក្រៅ។ មានន័យថា យើងកំពុងប្រែក្លាយខ្លួនទៅជាប្រទេសនាំចេញ ដែលត្រូវជម្រុញការផលិតនៅក្នុងប្រទេស ដើម្បីជម្រុញការនាំចេញ។ រាជរដ្ឋាភិបាលប្រឹងរកទីផ្សារនៅខាងក្រៅ សម្រាប់ផលិតផលរបស់កម្ពុជាទាំងវិស័យកសិកម្ម ទាំងវិស័យឧស្សាហកម្ម** ... ទៅបើកនៅអាមេរិក បើកនៅអឺរ៉ុប បើកនៅកាណាដា បើកនៅចិន បើកនៅជប៉ុន បើកនៅកូរ៉េ បើកនៅតំបន់អាស៊ាន ... (ទោះ)មិនទាន់ដល់ឆ្នាំ ២០១៥ មែនពិត ក៏ប៉ុន្តែប្រឹងបើក។ រាជរដ្ឋាភិបាលដើររកទីផ្សារនៅខាងក្រៅ (រួម)ជាមួយនឹងការទាក់ទាញ ការវិនិយោគមកក្នុងស្រុក ដើម្បីធ្វើការជាំដុះ និងកែច្នៃ។ ខាងផ្នែកកាត់ដេរ ក៏ដូចគ្នាដែរ យើងប្រឹងបើកទីផ្សារ បើមិនអាចបើកទីផ្សារបានទេ មិនអាចមានការវិនិយោគបន្ថែមនូវរោងចក្រកាត់ទេ។ (ការប្រឹងប្រែងទាំងនេះ ធ្វើឡើង) ដើម្បីបង្កើតការងារធ្វើឲ្យកម្មករ/ការិនី ជាកូនកសិករ កូនប្រជាពលរដ្ឋរបស់យើង ...។

ពិធីចែកសញ្ញាបត្រ និស្សិត គរុនិស្សិត នៃវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស, ថ្ងៃទី ៧ វិច្ឆិកា ឆ្នាំ ២០១៦

... នៅខាងក្រៅ(ប្រទេស)យើងដើរសុំការងារគេទៀត។ នៅកូរ៉េយើងសុំគេ ឥឡូវយើងកំពុងបើកទៅរកទីផ្សារសម្រាប់ពលករបស់យើង នៅអារ៉ាប៊ីសាអូឌីត នៅគូវ៉ែត នៅបាហ៍រ៉ែន នៅកាតា និងនៅប្រទេសដទៃទៀត ក្នុងតំបន់ឈូងសមុទ្រពែក្ស។ នៅម៉ាឡេស៊ី យើងផ្ទាក់ចំណាកស្រុកការងារទាក់ទិនជាមួយនឹងពលករជាស្ត្រី នៅសាំងហ្គាពួរ យើងកំពុងតែសាកល្បង។ នៅប្រទេសថៃ យើងបានប្រឹងប្រែង ដើម្បីឲ្យបងប្អូនពលករបស់យើងរស់នៅដោយស្របច្បាប់ ធ្វើការដោយស្របច្បាប់។ តែមិនត្រូវភ្លេចថា ថៃបានបញ្ជូនពលករបស់គេទៅកូរ៉េខាងត្បូង ទៅតៃវ៉ាន់ និងទៅមជ្ឈិមបូព៌ា ដើម្បីទៅរកប្រាក់ខែខ្ពស់ជាង ហើយកង្វះពលករនៅខាងក្នុង គេប្រើពលករទៅពីកម្ពុជា មកពីឡាវ និងមកពីមីយ៉ាន់ម៉ា ...។

៣. ខំបង្កើតការងារ និងយកចិត្តទុកដាក់ផ្សព្វផ្សាយពីការងារក្នុងស្រុក

ពិធីអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, ថ្ងៃទី ២៦ មិថុនា ២០១៤

... ត្រូវខិតខំរកការងារក្នុងស្រុក។ ខេត្តមួយចំនួន កំពុងប្រឹងប្រែងដោះស្រាយតាមរយៈនៃការចុះឈ្មោះស្វែងរក និងទាក់ទងយកពលករ ដែលទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់ បម្រើឲ្យសេចក្តីត្រូវការនៃការងាររបស់ខ្លួន។ ក្នុងនោះក៏មានមួយផ្នែកធំ ជាពលករដែលនៅជាកសិករ ហើយដែលបានធ្វើចំណាកស្រុកក្នុងរយៈពេលខ្លីទៅរកការងារធ្វើក្នុងរដូវប្រាំង (ហើយ)វិលត្រឡប់មកវិញ ក្នុងរដូវវស្សា (ដើម្បី)បង្កបង្កើនផល នៅក្នុងវិស័យកសិកម្មលក្ខណៈគ្រួសារ។ ប៉ុន្តែ មានពលករមួយចំនួន ដែលធ្វើចំណាកស្រុក (ដល់)ត្រឡប់មកវិញ គឺមិនមានដីគ្រប់គ្រាន់ដើម្បីបង្កបង្កើនផល។ ការងារនៅមានច្រើនក្នុងប្រទេសរបស់យើង។ ... សុំក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ យកចិត្តទុកដាក់ទៅលើកិច្ចការនេះ។ ខ្ញុំក៏បានដឹងដែរថា ខេត្តកំពង់ឆ្នាំងមួយ រកការងារឲ្យកម្មករបានប៉ុន្មានពាន់នាក់ នៅក្នុងវិស័យកសិកម្ម ឧស្សាហកម្ម និងសេវា។ បើពឹងពាក់ទៅលើថ្នាក់ជាតិ គឺតែក្រសួងការងារតែមួយគត់ គឺមិនបានទេ។ **ត្រូវពឹងពាក់លើកិច្ចសហប្រតិបត្តិការ**

ទាំងឡាយ អាជ្ញាធរថ្នាក់ក្រោមជាតិ មានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្វើជាសេនាធិការ ... ពេលខ្លះ ខ្វះព័ត៌មានស្តីអំពីការងារនៅក្នុងកម្ពុជា។ វិទ្យុមួយចំនួនផ្សព្វផ្សាយ អំពីការជ្រើសរើសពលករទៅបរទេស ប៉ុន្តែ ដូចជាមិនបានលើផ្សព្វផ្សាយអំពីតម្រូវការពលករនៅក្នុងប្រទេស ...។

៤. ដោះស្រាយការបញ្ជូនពលករពីប្រទេសថៃ ត្រឡប់មកកម្ពុជាវិញ

ពិធីអបអរសាទរ ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿនញៀន, ២៦ មិថុនា ២០១៤

... ការដែលអាជ្ញាធរប្រទេសថៃ បន្ទាប់ពីការធ្វើរដ្ឋប្រហារ និងអនុវត្តនូវច្បាប់អាជ្ញាសឹក បានបង្កើតឡើងនូវស្ថានភាពមួយដែលយើងនឹកស្មានមិនដល់។ តាមតួលេខនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គិតត្រឹមថ្ងៃទី ២៣ ខែមិថុនា មាន(ពលករ)ចំនួនជាង ២៤ ម៉ឺននាក់។ បើគិតមកដល់ពេលនេះ ប្រហែលជាកើនឡើងជាង ២៥ ម៉ឺននាក់។ **នេះជាចំនួនមួយដ៏ច្រើន ដែលយើងត្រូវទទួលបន្ទុកដោះស្រាយភ្លាមៗ នៅនឹងកន្លែង ដោយមិនរង់ចាំលិខិតស្នាមអ្វីទាំងអស់ ... នេះបង្ហាញឲ្យឃើញអំពីការទទួលខុសត្រូវនៃស្ថាប័នថ្នាក់ជាតិ ជាពិសេស អាជ្ញាធរនៅតាមបណ្តាយព្រំដែនកម្ពុជា-ថៃ ក្នុងនោះ ខេត្តបន្ទាយមានជ័យ គឺជាខេត្តដែលត្រូវទទួលធ្ងន់ធ្ងរជាងគេនូវអំរែកនេះ ... ទោះបីថា គាត់បានឆ្លងកាត់ទៅធ្វើការខុសច្បាប់ក៏ដោយ ប៉ុន្តែជាសាច់ឈាមរបស់យើងៗ ត្រូវទទួលបន្ទុកដោះស្រាយ ...។**

៥. លិខិតឆ្លងដែនមិនយកប្រាក់, កន្លែងធ្វើលិខិតឆ្លងដែនតាមគោលដៅអាទិភាព

ពិធីអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន, ថ្ងៃទី ២៦ មិថុនា ២០១៤

... ខ្ញុំសូមជម្រាបថា លិខិតឆ្លងដែន (តាមអនុក្រិត្យ)ត្រូវបានផ្តល់ឱ្យពលករដោយមិនយកប្រាក់ទេ ពាក្យដែលថា អាករជាបន្ទុករបស់រដ្ឋ បានសេចក្តីថា រដ្ឋឱ្យលិខិតឆ្លងដែនទទេតែម្តង ... បានណែនាំ**ឱ្យពង្រាយកន្លែងធ្វើលិខិតឆ្លងដែន មិនប្រមូលផ្តុំតែនៅទីក្រុងភ្នំពេញមួយទេ ដើម្បីចៀសវាងការធ្វើដំណើរដ៏វែងឆ្ងាយរបស់ប្រជាជន មកកាន់ទីក្រុងភ្នំពេញ។ ចាប់ផ្តើមពីគោលដៅអាទិភាពមួយចំនួន** ដូចជា ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ធំ ខេត្តសៀមរាប

ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង អាចថា ពោធិ៍សាត់ តាកែវ កំពត ជាដើម។ យកល្អ ថ្ងៃក្រោយកុំឱ្យវាពិបាក អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ផ្នែកអត្តសញ្ញាណកម្មនេះ បង្កើតកន្លែងធ្វើលិខិតឆ្លងដែននៅគ្រប់ខេត្ត-ក្រុង លើកលែងតែភ្នំពេញ និងកណ្តាល ... **ក្រសួងការងារ និងក្រសួងមហាផ្ទៃ ត្រូវធ្វើការរួមគ្នា ...**។

៦. យកចិត្តទុកដាក់ពីពលកម្មជំនាញ ពេលចូលសហគមន៍សេដ្ឋកិច្ចអាស៊ាន

ពិធីប្រកាសផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ, ឆ្នាំ ២០១៥/២០២៥, ថ្ងៃទី ២២ តុលា ២០១៦

... **បន្ទាប់ពីថ្ងៃ ៣១ ខែធ្នូ នេះទៅ សហគមន៍សេដ្ឋកិច្ចអាស៊ាន (នឹងដំណើរការ ដែល)លំហូរទាំងទំនិញ សេវា ពលកម្ម នឹងត្រូវចាប់ផ្តើម។ ត្រូវតាមដានឲ្យបានដិតដល់អំពីបញ្ហានេះ។ ជួនកាល យើងហូរចេញពលកម្មជំនាញទៅក្រៅច្រើន (ធ្វើឲ្យ)ខ្វះពលកម្មជំនាញក្នុងស្រុក។** និយាយពីលំហូរពលកម្ម សាំងហ្គាពួរ និងម៉ាឡេស៊ី បាននិយាយពាក្យថា លំហូរពលកម្មជំនាញ ពលករជំនាញ។ គេប្រើពាក្យជំនាញ។ ឯសម្រាប់ពលកររបស់យើង ភាគច្រើនមិនមានជំនាញទេ។ យើងត្រូវតាមដានឲ្យដិតដល់ ពេលដែលចាប់ផ្តើម តើអ្វីនឹងកើតឡើង? តើយើងតម្រង់ទិសបែបណា នៅពេលនោះ? ពិតមែនថា យើងដឹងសញ្ញាខ្លះ។ រួចមកហើយដែរ បានជាយើងខិតខំធ្វើកិច្ចការទាំងអស់នេះ...។

៧. ស្រាយបញ្ហាថ្លៃទឹក និងអគ្គិសនី ជូនកម្មករ/ការិនី

ពិធីចែកសញ្ញាបត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ថ្ងៃទី ១០ កុម្ភៈ ២០១៥

... **សូមកោតសរសើរចំពោះក្រសួងរ៉ែ និងថាមពល អាជ្ញាធរអគ្គិសនី ជាពិសេសក្រុមហ៊ុនអគ្គិសនីកម្ពុជា ដែលបានភ្ជាប់នូវកុងទ័រសម្រាប់ផ្ទះដែលកម្មករស្នាក់នៅ (ធ្វើអោយពួកគាត់)ទទួលថ្លៃភ្លើងពិតប្រាកដ ក្នុង ១ គីឡូវ៉ាត់ម៉ោង ៦១០ រៀល ... ម្ខាងទៀត ថ្លៃទឹក ... បានឲ្យគោលការណ៍ និងសូមឯកឧត្តម ចម ប្រសិទ្ធ និងឯកឧត្តម ប៉ា សុជាតិវង្ស បន្តកិច្ចការនេះ** ជាមួយនឹងរដ្ឋាភិបាលទីក្រុងភ្នំពេញ ជាមួយនឹងម្ចាស់ផ្ទះ ដែលមាន ៤.៣៥៦ នាក់ធ្វើអាជីវកម្មបន្ទប់ជួល ... ឥឡូវនេះ

សម្រាប់ការសុំមតិពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម គឺក្រសួងលក់ក្នុងតម្លៃថេរមួយឲ្យម្ចាស់ផ្ទះ ក្នុងមួយម៉ែត្រគូប ១.០៣០ រៀល ហើយម្ចាស់ផ្ទះត្រូវលក់ឲ្យបន្ទប់ជួលកម្មករ ក្នុងចន្លោះ ១.១០០ ទៅ ១.២០០ រៀល ក្នុងមួយម៉ែត្រគូប ... ក្រៅពីនោះ សាលារាជធានីភ្នំពេញ បានឯកភាពកាត់ចេញ ១០% ពីវិក័យបត្រទឹកនូវបណ្តាផ្ទះជួលឲ្យកម្មករសម្រាប់លូទឹកស្អុយ ...។

៨. កម្មករ-សហជីព និងថៅកែរោងចក្រ/សហគ្រាស ជាដៃគូខ្វះមិនបាន

សម្ពោធមធ្យោបាយលើកដាក់កុងតែនរ និងជួបសំណេះសំណាលជាមួយកម្មករ និងនិយោជិតកំពង់ផែស្វយ័តក្រុងព្រះសីហនុ, ថ្ងៃទី ៣០ មេសា ២០០៩

... សូមកម្មករ-កម្មការិនីនៅទូទាំងប្រទេស បន្តការខិតខំដើម្បីជំនះនូវការលំបាកក្នុងដំណាក់កាលនៃ(វិបត្តិ)សេដ្ឋកិច្ចពិភពលោក ហើយ**បន្តការងារក្នុងក្របខណ្ឌច្បាប់ការងារ ដែលទាមទារឱ្យមានការយោគយល់គ្នារវាងកម្មករ-និយោជិតជាមួយនឹងម្ចាស់រោងចក្រ។ អ្នកទាំងពីរនេះ គឺជាដៃគូមិនអាចខ្វះបានក្នុងដំណើរការរីកលូតលាស់នៃរោងចក្រ ក៏ដូចជាការរីកលូតលាស់នៃជីវភាពរបស់កម្មករ-កម្មការិនី**របស់យើងដែរ ... កម្មករមិនមែនជាសត្រូវនៃថៅកែ ហើយថៅកែក៏មិនជាសត្រូវរបស់កម្មករទេ ... ខ្ញុំមិនម៉ាក្ស៊ីស (Marxist ឬម៉ាក្សនិយម) ទេ ប៉ុន្តែ **ខ្ញុំក៏ធ្លាប់បានអានគោលនយោបាយសេដ្ឋកិច្ចថ្មីរបស់ លេនីន ដែលសរសេរតាំងពីឆ្នាំ១៩២០ ថា វណ្ណៈកម្មករលំបាក បើសិននាយទុនមិនរីកចំរើន** ... ខ្ញុំមើលទ្រឹស្តីរបស់ គេង ស៊ាវពីង ...។

ពិធីអបអរសាទររោងចក្រទី ១០០ នៅតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ , ថ្ងៃទី ៧ មិថុនា ២០១៦

... បើសិនជារោងចក្រទាំងឡាយក្នុងតំបន់សេដ្ឋកិច្ចពិសេសនេះបិទ ក្ជយៗនឹងវិលត្រឡប់ទៅធ្វើស្រែចំការវិញ។ **សង្ឃឹមថា កម្មករ/ការិនី ខិតខំដើម្បីឆ្នាំងបាយរបស់ខ្លួន ចាត់ទុកតំបន់សេដ្ឋកិច្ចពិសេស ចាត់ទុករោងចក្រសហគ្រាសដែលយើងកំពុងធ្វើការ គឺជាឆ្នាំងបាយរបស់ខ្លួន។** សូមកុំភ្លេចថា នៅពេលដែលមានការដកចេញនូវវិនិយោគចេញពីប្រទេសកម្ពុជា អ្នកដែលខាតបង់មុនគេ គឺកម្មករ/ការិនី

កម្ពុជានោះឯង ... ពេលរោងចក្រត្រូវឆេះ ឬក៏ធ្វើអំពើណាមិនគប្បីឈានទៅដល់ការដកចេញនូវរោងចក្រ ជាពិសេសបង្កើតឡើងនូវចលាចល ឬសង្គ្រាមណាមួយ តើមានអ្នកណាមកវិនិយោគទៀត? ... **សូមអំពាវនាវដល់អ្នកគ្រប់គ្រងរោងចក្រ ក៏ដូចជាតំបន់(សេដ្ឋកិច្ចពិសេស)ទាំងមូល យកចិត្តទុកដាក់សម្របសម្រួល ព្រោះនេះជាទំនាក់ទំនងទ្វេទិស ដែលមានចរិកបំពេញឲ្យគ្នាទៅវិញទៅមក ... ធ្វើការងារបានល្អ ទិន្នផលកាន់តែខ្ពស់** ថៅកែរោងចក្រត្រូវខិតខំតម្លើងបៀវត្សឲ្យកម្មករ ក្នុងពេលជាមួយគ្នា ថៅកែរោងចក្រ និងអ្នកគ្រប់គ្រងត្រូវដឹងសុខទុក្ខពីកម្មករ ហើយកុំឲ្យរឿងតូចតាចក្លាយទៅជារឿងធំ ដោះស្រាយភ្លាមៗ ...។

៩. កម្មករសុខភាពល្អ ទិន្នផលការងារល្អ

ពិធីសំណេះសំណាល ជាមួយនិយោជិត កម្មករ-កម្មការិនី នៅកំពង់ផែស្វយ័ត
ក្រុងព្រះសីហនុ, ថ្ងៃទី ០១ ឧសភា ២០១៣

... ខ្ញុំសូមលើកទឹកចិត្ត ឲ្យក្រុមហ៊ុនបន្ត បើចង់បានកម្មករ ដំបូងបំផុតត្រូវដោះស្រាយផ្ទះនៅរបស់កម្មករ ព្រោះកម្មករមិនអាចមកបោះតង់នៅបានទេ។ ឥឡូវ ទីផ្សារការងារ គឺប្រកួតប្រជែងគ្នាខ្លាំងណាស់។ ខ្ញុំព្រះករុណាខ្ញុំ តែងតែផ្តល់ដំបូន្មានដល់ក្រុមហ៊ុននានា ទាំងតូចទាំងធំ ផ្នែកកសិកម្ម ទាំងនៅរតនគិរី មណ្ឌលគិរី នៅស្ទឹងត្រែង ព្រះវិហារ និងនៅខេត្តមួយចំនួនផ្សេងទៀត ថាការប្រកួតប្រជែងអំពីតម្លៃពលកម្ម ហ្នឹងមួយហើយ ប៉ុន្តែមួយទៀតត្រូវមានផ្ទះឲ្យកម្មករនៅ ... **ត្រូវធ្វើផ្ទះអោយបានល្អដើម្បីអោយកម្មករស្នាក់នៅបាន និងត្រូវមានប្រាក់ខែសមរម្យ មានការលើកទឹកចិត្ត និងថ្នាក់ថ្នមកម្មករ។ បើកម្មករមានសុខភាពល្អ ទិន្នផលការងារសម្រាប់រោងចក្រ និងកសិដ្ឋានរបស់លោកក៏ល្អដូចគ្នា មានទៅមានមក ...**។

១០. កម្មករ/ការិនីយោគយល់ រួមចំណែករក្សាការងារ កំណើន ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច

ពិធីជួបសំណេះសំណាលជាមួយកម្មករ/ការិនី តំណាងមន្ត្រីរាជការ និយោជិក,
ថ្ងៃទី ១៩ មេសា ២០១៥

... បើសិនជាទៅតាមការញុះញង់របស់បក្សប្រឆាំង ប្រហែលជាកម្ពុជានៅពេលនេះ មិនមានផលិតផល រហូតទៅដល់ប្រមាណជាង ៦ ពាន់លានដុល្លារ សម្រាប់

នាំចេញទេ ... **ប្រទេសមួយចំនួនដូចជាឡាវ មីយ៉ាន់ម៉ា បង់ក្লាដេស (ដែលប្រាក់ប៉ៃវ៉ាស្យូ៉ូរបស់គេប្រហាក់ប្រហែលជាង ៦០ ដុល្លារប៉ុណ្ណោះក្នុងមួយខែ ក្នុងពេលដែលឆ្នាំទៅ យើងឡើងដល់ ១០០ ដុល្លារ** (ឆ្នាំនេះឡើងដល់ ១២៨ ដុល្លារ)បានរង់ចាំស្វាគមន៍អ្នកវិនិយោគដែលចេញពីកម្ពុជា ដោយសារហេតុផលមួយចំនួន ក្នុងហ្នឹងមានហេតុផលទាក់ទងនឹងកូដកម្ម/បាតុកម្មច្រើនពេកផងដែរ។ ប៉ុន្តែ **ការដឹកនាំគ្រប់គ្រងម៉ត់ចត់ និងស្មារតីយោគយល់របស់កម្មករ/ការិនី បានជួយរក្សាបាននូវការងារ កំណើនសេដ្ឋកិច្ច និងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច** ...។

ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

១	ទណ្ឌកម្មសេដ្ឋកិច្ច/នយោបាយការទូតលើកម្ពុជា គួរអោយអៀនខ្មាស	៣៥
២	កម្ពុជាប្រកាន់នយោបាយការបរទេសឯករាជ្យ អធិបតេយ្យភាព	៣៥
៣	កម្ពុជាធ្វើបង្ការជម្លោះរវាងប្រទេសអាស៊ានមួយចំនួន ជាមួយចិន	៣៦
៤	គោលជំហរ ៣ នៃកម្ពុជា ពាក់ព័ន្ធនឹងបញ្ហាសមុទ្រចិនខាងត្បូង	៣៦
៥	តើប្រធានអាស៊ានមុន និងក្រោយវេនកម្ពុជាណា ធ្វើក្រមប្រតិបត្តិបាន?	៣៧
៦	កម្ពុជាមិនចូលរួមសេចក្ដីថ្លែងការណ៍គាំទ្រការសម្រេចនៃតុលាការណាទេ	៣៨
៧	សូមកុំលូកលាន់កិច្ចការផ្ទៃក្នុងកម្ពុជាៗ មិនលូកលាន់កិច្ចការអ្នកដ៏ទៃដែរ	៣៩
៨	មិនឲ្យនរណាម្នាក់បំផ្លាញសន្តិភាព និងស្ថេរភាពនៅកម្ពុជាឡើយ	៣៩
៩	កត្តាធំៗ ៤ ដែលកម្ពុជាចូលអាស៊ាន	៤០
១០	ផែនទីដែលរដ្ឋាភិបាលប្រើ គឺជាផែនទីស្របច្បាប់	៤១
១១	កុំអោយជម្លោះ ការមិនចុះសម្រុងរដ្ឋ រារាំងសកម្មភាពប្រឆាំងភេរវកម្ម	៤១
១២	ទទួលប្រតិបត្តិការមួកខៀវ បង្កើតជំនឿ រកសន្តិភាពនិងបង្រួបបង្រួមជាតិ	៤២
១៣	បញ្ជូនកងទ័ពក្រោមឆ័ត្រអង្គការសហប្រជាជាតិ ជាការសម្រេចត្រឹមត្រូវ	៤២
១៤	មហិច្ឆតាពង្រីកការបញ្ជូនកម្លាំងរក្សាសន្តិភាព និងជំនួយ	៤៣
១៥	បើថវិការប្រើមិនចំគោលដៅ ប្រទេសផ្តល់ជំនួយឈប់ឲ្យហើយ	៤៤
១៦	កសាងព្រំដែនកម្ពុជា និងថៃ សន្តិភាព មិត្តភាព និងសហប្រតិបត្តិការ	៤៤
១៧	ចិនជួយកម្ពុជាស្ថាបនា មិនបានជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងឡើយ	៤៥
១៨	ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញប្បទានពីចិន និងដៃគូ ផ្តល់កំណើនសេដ្ឋកិច្ច	៤៥
១៩	ជាដៃគូយុទ្ធសាស្ត្រអាស៊ាន-ចិន មានប្រយោជន៍ដល់ប្រទេសទាំង ១០	៤៦
២០	ផ្លូវសូត្រសមុទ្រសតវត្សរ៍ទី ២១, ក្រវ៉ាត់មួយ ផ្លូវមួយ, ធនាគារ AIIB	៤៧
២១	BRICS, AIIB, មូលនិធិផ្លូវសូត្រអាស៊ី មិនជាសត្រូវ World Bank ទេ	៤៨
២២	ជប៉ុនចូលរួមច្រើន ហេដ្ឋារចនាសម្ព័ន្ធ សុខាភិបាល អប់រំ និងវិស័យដទៃ	៤៩
២៣	ជំនួយរបស់ជប៉ុន គឺជប៉ុនជាអ្នកគ្រប់គ្រងផ្ទាល់	៤៩
២៤	ទំនាក់ទំនងកម្ពុជា-ជប៉ុន ដល់កម្រិតដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ	៥០
២៥	ផ្សារភ្ជាប់ឡើងវិញនូវទំនាក់ទំនងកម្ពុជា-កូរ៉េ នៅឆ្នាំ ១៩៩៦	៥០

២៦	**បើមានសង្គ្រាមនៅឧបទ្វីបកូរ៉េ រាជរដ្ឋាភិបាលមានវិធានការជាក់លាក់**	៥១
២៧	**ដាក់ទណ្ឌកម្មរុស្សុ ចំណេញដល់អាស៊ាននាំចេញទៅរុស្សុ**	៥២
២៨	**ពិភពលោកជ្ជួលច្របល់, ចង់ចេញពីសហភាពអឺរ៉ុប, សង្គ្រាម Ukraine**	៥២
២៩	**បដិវត្តពណ៌ ក្រោមលេសសិទ្ធិមនុស្ស, ប្រជាធិបតេយ្យបន្សល់ទុកអ្វី ?**	៥៣
៣០	**គប្បីវាយតម្លៃពីបដិវត្តន៍ពណ៌ ក្រោមលេសប្រជាធិបតេយ្យ សិទ្ធិមនុស្ស**	៥៤
៣១	**ប្រធានាធិបតីអាមេរិកថ្មី នឹងស្រុះស្រួលជាមួយរុស្សុ**	៥៤
៣២	**រដ្ឋាភិបាលថ្មី លោក ដូណាល់ ត្រាំម៍ គួរពិចារណាលុបបំណុលកម្ពុជា**	៥៥
៣៣	**អ្វីដែលកើតនៅកម្ពុជា ឥឡូវវាក៏កើតនៅអាមេរិកដែរ**	៥៦
៣៤	**កុំសួរប្រទេសត្រៀមចេញពីអាស៊ាន? សួរថាប្រទេសណានឹងចេញពីអឺរ៉ុប**	៥៦

១. ទណ្ឌកម្មសេដ្ឋកិច្ច និងនយោបាយការទូតលើកម្ពុជា ជាការគួរអោយអៀនខ្មាស

ពិធីប្រគល់សញ្ញាបត្រ និងសម្ពោធអគារសិក្សាថ្មី នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ១២ សីហា ២០០៩

... ស្ថានភាពយើង **ចាប់ផ្តើមពីគេហ៊ុំព័ទ្ធនយោបាយ និងសេដ្ឋកិច្ច ទណ្ឌកម្ម ចំពោះយើងគ្រប់ផ្នែក។ រួចពី ប៉ុល ពត សម្លាប់ហើយ គេបន្តសម្លាប់យើងទៀត។ ឥឡូវនេះ ទើបគេកាត់ទោស ប៉ុល ពត។ ៣០ ឆ្នាំក្រោយ ទើបគេទទួលស្គាល់នូវរឿងនេះ។ ប៉ុន្តែ ពួកគេមិនដែលទទួល(ថាមាន)វិប្បដិសារី ចំពោះកំហុស (ដែលគេបានធ្វើ)ចំពោះយើងឡើយ។ គួរអោយមានការអៀនខ្មាសខាងនយោបាយ និងការទូតខ្លាំងណាស់** ... ដែលហៅថា ប្រទេសជាប់ទណ្ឌកម្មសេដ្ឋកិច្ច គឺគេមិនផ្តល់ឲ្យនូវជំនួយអភិវឌ្ឍ រាប់ទាំងដីស សៀវភៅ គឺគេផ្តល់តែជំនួយមនុស្សធម៌ ... កុំថាឡើយក្ជយ។ ជានិស្សិត គេមិនទទួលយកទៅសិក្សាឯបរទេស សូម្បីតែពួនេះ ក្នុងហានៈជារដ្ឋមន្ត្រីការបរទេស ជាឧបនាយករដ្ឋមន្ត្រីពេលនោះ និងក្រោយមកជានាយករដ្ឋមន្ត្រី និងបន្តធ្វើជារដ្ឋមន្ត្រីការបរទេស ចាប់ដៃត្រឹមតែប្រធាននាយកដ្ឋានរបស់គេ ... ព្រោះគេអត់ទទួលស្គាល់យើង គេទទួលស្គាល់ ប៉ុល ពត នៅអង្គការសហប្រជាជាតិ។ រដ្ឋមន្ត្រីការបរទេសប៉ែកខាងលិច ដែលហៅថាបស្ចិមប្រទេសលើកដំបូងដែលបានចាប់ដៃសន្ធនាជាមួយ ខ្ញុំព្រះករុណាខ្ញុំ គឺអតីតរដ្ឋមន្ត្រីការបរទេសបៀល ហៃឌិន របស់អូស្ត្រាលី ... មិននិយាយពីឥណ្ឌាទេ និយាយតែបស្ចិមប្រទេស និងប្រទេសក្នុងអាស៊ីអាគ្នេយ៍ គឺគេទទួលស្គាល់ ប៉ុល ពត ...។

២. កម្ពុជាប្រកាន់នយោបាយការបរទេសឯករាជ្យ អធិបតេយ្យភាព

ពិធីចែកសញ្ញាបត្រជូននិស្សិត នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង,
ថ្ងៃទី ០៥ កុម្ភៈ ២០១៦

... មានការធ្វើអត្ថាធិប្បាយថាឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង ទៅទីក្រុងប៉េកាំងប្រញាប់ប្រញាល់ ហាក់ដូចជាទៅលួងលោមចិនកុំឲ្យខឹង ដោយសារតែរដ្ឋមន្ត្រីការបរទេសអាមេរិក ជន ឃែរី មកកាន់ទីក្រុងភ្នំពេញ។ ហើយ លោក ហ៊ុន សែន នឹងទៅប្រជុំអាស៊ាន-អាមេរិក នាអាទិត្យក្រោយ ... **ខ្ញុំសូមបញ្ជាក់ថា នយោបាយ**

ការបរទេសឯករាជ្យ អធិបតេយ្យភាព របស់កម្ពុជាមិនតម្រូវឲ្យសុំយោបល់អ្នកណាទាំងអស់ ... បើកម្ពុជាមិនមាននយោបាយការបរទេសឯករាជ្យមួយទេ កម្ពុជាមិនអាចចេញពីអន្លង់គ្រោះថ្នាក់នៃស្រមោលអតីតកាល តាមរយៈនយោបាយឈ្នះ-ឈ្នះ របស់ខ្លួននោះទេ ... គ្មានការចាំបាច់ទៅរាយការណ៍ឲ្យចិនថា ខ្ញុំធ្វើជាមួយអាមេរិកអញ្ចុះ ហើយមិនចាំបាច់រាយការណ៍ទៅអាមេរិកថា ខ្ញុំធ្វើជាមួយចិនអញ្ចុះទេ។ ហើយក៏គ្មានការចាំបាច់ទៅក្រុងតូក្យូ ដើម្បីប្រាប់ជប៉ុនថា នែ!ខ្ញុំត្រូវធ្វើអញ្ចុះ (នោះទេ)។ ខ្មែរគឺខ្មែរ។ គ្មានអ្នកណាស្គាល់ខ្មែរលើសខ្មែរទេ ហើយមានតែខ្មែរមួយគត់ ដែលមានសិទ្ធិសម្រេចលើជោគវាសនារបស់ខ្មែរ...។

៣. កម្ពុជាធ្វើឲ្យមានការស្ងប់ស្ងាត់ បង្កាជម្លោះរវាងប្រទេសអាស៊ានមួយចំនួន ជាមួយចិន

ពិធីចែកវិញ្ញាបនបត្រមន្ត្រីជាន់ខ្ពស់ មន្ត្រីក្រមការ សាលាភូមិន្ទរដ្ឋបាល, ថ្ងៃទី ២០ មិថុនា ២០១៦

... កាលកម្ពុជាមានបញ្ហា កម្ពុជាក៏ដោះជាមួយថៃដែរ។ ខ្ញុំមិនបានទៅរំខានអាស៊ានទេ។ មិនមែនខឹងទេ ប៉ុន្តែកុំឲ្យប្រមាថកម្ពុជា ... ការលើកឡើងថា "កម្ពុជាបានធ្វើឲ្យខូចកិច្ចប្រជុំអាស៊ាន" មួយទៀតទាក់ទិននឹងសមុទ្រចិនខាងត្បូងមានន័យថា យើងជាអ្នកបំផ្លាញសុទ្ធ។ អត់អីទេ អ្នកឯងប្រើទៀតក៏បាន **តែអ្នកឯងត្រូវទទួលស្គាល់តួនាទីមួយឲ្យច្បាស់ កម្ពុជាបានធ្វើឲ្យមានការស្ងប់ស្ងាត់ កុំឲ្យជម្លោះវារីករាលដាលរវាងប្រទេសអាស៊ានមួយចំនួនជាមួយនឹងចិន។ កម្ពុជាបានខិតខំរក្សារវាងទំនាក់ទំនងអាស៊ាន-ចិន ដែលជាផលប្រយោជន៍រួម។ កម្ពុជាបានដើរតួនាទីរក្សាស្ថេរភាពក្នុងតំបន់ ធ្វើឲ្យមានទំនាក់ទំនងល្អប្រសើររវាងអាស៊ាន-ចិន។ អ្នកឯងត្រូវយល់តួនាទីនេះ។** បើសិនជាកម្ពុជាចង់ដុត គឺកម្ពុជានឹងធ្វើតាមការស្នើសុំរបស់ប្រទេសពីរ មួយ(អំពី)តំបន់សេដ្ឋកិច្ចផ្តាច់មុខ និងមួយ(ទៀតអំពី)កោះ។ កម្ពុជា ជាប្រទេសតូចមួយ ប៉ុន្តែកម្ពុជាជាប្រទេសឯករាជ្យ និងមានខ្ជីរក្បាលនយោបាយក្នុងប្រទេស និងក្រៅប្រទេសជាក់លាក់ ...។

៤. គោលជំហរ ៣ នៃកម្ពុជា ៣ក់ព័ន្ធនឹងបញ្ហាសមុទ្រចិនខាងត្បូង

ពិធីចែកវិញ្ញាបនបត្រមន្ត្រីជាន់ខ្ពស់ មន្ត្រីក្រមការ សាលាភូមិន្ទរដ្ឋបាល, ២០ មិថុនា

២០១៦

... Cambodia Daily ផ្សាយថា "មានការលើកឡើងថា កម្ពុជាធ្វើឲ្យខូចកិច្ចប្រជុំអាស៊ានមួយទៀត ទាក់ទិននឹងបញ្ហាសមុទ្រចិនខាងត្បូង"។ ខ្ញុំសុំនិយាយទៅកាន់ប្រជាជាតិទូទាំងប្រទេស ហើយក៏និយាយទៅកាន់មិត្តភក្តិជាដៃគូនៅក្នុងក្របខណ្ឌអាស៊ាន ថា **ជំហររបស់កម្ពុជាតាំងពីដើមទី គឺ ទី ១ ប្រើប្រាស់យន្តការអាស៊ាន-ចិន ដើម្បីអនុវត្តឲ្យបានត្រឹមត្រូវនូវ DOC គឺសេចក្តីថ្លែងការណ៍ភាគីសមុទ្រចិនខាងត្បូង, ទី ២ ខិតខំអោយអាស៊ាន និងចិនធ្វើឲ្យចេញនូវក្រមប្រតិបត្តិដែលអាចហៅថា COC និង ទី ៣ ប្រទេសដែលជាប់ទាក់ទងជាមួយគ្នា ត្រូវដោះស្រាយជាមួយគ្នា**។ អាស៊ានមិនអាចទៅរាស់ដីឲ្យបានទេ។ អយុត្តិធម៌ពេកហើយ។ កម្ពុជា មិនមែនជាផ្នែកមួយនៃការបំផ្លាញអាស៊ានទេ។ ... ក្នុងសេចក្តីថ្លែងការណ៍រួម ពេលអគ្គលេខាធិការបក្សកុំម្មុយនីស្តវៀតណាមទៅទស្សនកិច្ចនៅប្រទេសចិន **វៀតណាមខ្លួនឯង បាននិយាយថា តំបន់ណាដែលវាពាក់ព័ន្ធនឹងទ្វេភាគីដោះស្រាយដោយទ្វេភាគី តំបន់ណាដែលមានការពាក់ព័ន្ធពហុភាគី ត្រូវដោះស្រាយដោយពហុភាគី។ វៀតណាម និងចិន និយាយគ្នា (អ៊ីចឹង)។ ... ខ្ញុំមិនអាចចេះតែគាំទ្រ ដោយមិនគិតពីយុត្តិធម៌ និងមិនគិតពីប្រទេសជាតិរបស់ខ្លួនទេ។** ប្រជុំនៅទីក្រុងភ្នំពេញ ចេញសេចក្តីថ្លែងការណ៍មិនរួច មិនមែនមកពីកម្ពុជាទេ មកពីគេធ្វើបាបកម្ពុជា ...។

៥. តើប្រធានអាស៊ានមុន និងក្រោយវេនកម្ពុជាណា ធ្វើក្រមប្រតិបត្តិបាន?

ពិធីចែកវិញ្ញាបនបត្រមន្ត្រីជាន់ខ្ពស់ មន្ត្រីក្រមការ សាលាភូមិន្ទរដ្ឋបាល,
២០ មិថុនា ២០១៦

... **ក្នុងឋានៈជាប្រធានអាស៊ាន ប្រទេសមួយឲ្យយើងទទួលស្គាល់កោះមួយថាជាកោះរបស់ប្រទេសខ្លួន ប្រទេសមួយទៀតមកស្នើឲ្យប្រធានអាស៊ានទទួលស្គាល់តំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ខ្លួន។ កម្ពុជាមិនមែនជាចៅក្រមកាត់សេចក្តីទេ។ ការសម្របសម្រួលរបស់កម្ពុជា លើបញ្ហាសមុទ្រចិនខាងត្បូង ដើម្បីរក្សាសាមគ្គីភាព និងសុខដុមភាវូបនីយកម្មក្នុងទំនាក់ទំនងអាស៊ាន-ចិន។** ចាត់ទុកថា

កម្ពុជាបានដើរតួនាទីដ៏ល្អ។ នាយករដ្ឋមន្ត្រី ២ របស់បារាំងសរសើរកម្ពុជា។ អ្នកខ្លះ ថា មកពីកម្ពុជាជិតចិនពេក ទើបចេញសេចក្តីថ្លែងការណ៍មិនបាន ឬក៏ធ្វើក្រម ប្រតិបត្តិមិនបាន។ ប៉ុន្តែ ខ្ញុំសុំសួរបកត្រឡប់ទៅវិញ អ្នកធ្វើប្រធានអាស៊ានមុន កម្ពុជា រួមមាន វៀតណាម ២០១០ ឥណ្ឌូនេស៊ី ២០១១ ម៉េចក៏មិនធ្វើឲ្យចេញ ទៅ? ឥឡូវ ថាឆ្នាំ ២០១២ កម្ពុជាធ្វើមិនចេញ, ចុះ ២០១៣ ប្រ៊ុយណេ ២០១៤ មីយ៉ាន់ម៉ា ២០១៥ ម៉ាឡេស៊ី ម៉េចក៏ធ្វើមិនចេញ? ឆ្លើយមក។ យើងជាប្រទេស តូច គេប្រមាថ។ ខ្ញុំមិនឲ្យអ្នកណាប្រមាថជាតិខ្មែរទេ ... ខ្ញុំសុំឲ្យប្រទេសទាំងអស់ អត់ធ្មត់កុំប្រើប្រាស់កម្លាំង ឬគំរាមប្រើប្រាស់កម្លាំងនៅក្នុងសមុទ្រចិនខាងត្បូង ហើយរួមគ្នាដើម្បីនឹងធ្វើក្រមប្រតិបត្តិ COC ... ប្រទេសជាប់ពាក់ព័ន្ធចរចាគ្នា ...។

៦. កម្ពុជា មិនចូលរួមចេញសេចក្តីថ្លែងការណ៍ គាំទ្រការសម្រេចរបស់តុលាការណាទេ

ពិធីចែកវិញ្ញាបនបត្រមន្ត្រីជាន់ខ្ពស់ មន្ត្រីក្រមការ សាលាភូមិន្ទរដ្ឋបាល,
២០ មិថុនា ២០១៦

... ជឿថា អគ្គរដ្ឋទូតប្រទេសនេះ នៅគ្រប់ប្រទេស ដើរចលនាដូចគ្នាថា នៅ ពេលដែលតុលាការចេញសាលដីកា សុំអាស៊ានមានសម្លេងតែមួយ គឺការគាំទ្រ សេចក្តីសម្រេចរបស់តុលាការ។ អញ្ចឹងមានន័យថា គេបានទំនាក់ទំនងជាមួយ តុលាការនោះរួចហើយ។ អញ្ចឹង តុលាការហ្នឹង ក៏មិនយុត្តិធម៌ដែរ។ ខ្ញុំនិយាយទុក មុនអញ្ចឹងតែម្តង។ **ខ្ញុំសុំប្រកាសជំហរថា កម្ពុជាមិនចូលរួមចេញសេចក្តីថ្លែង ការណ៍ លើការគាំទ្រសេចក្តីសម្រេចរបស់តុលាការទេ។ ជាជម្លោះរវាងហ្វីលីពីន ប្តឹងចិន។ អញ្ចឹងទុកឲ្យហ្វីលីពីនដោះស្រាយជាមួយគ្នាទៅ ម៉េចក៏ចាំបាច់មកឲ្យ អាស៊ានគាំទ្រ។** ហើយរឿងអាស៊ានគាំទ្រហ្នឹងទៀត តុលាការមិនទាន់ដឹងបែរមុខ ទៅខាងណាផង មកស្នើឲ្យយើងគាំទ្រ។ កម្ពុជានឹងមានសេចក្តីថ្លែងការណ៍មួយ ជាប់ជោយឡែក ... បើអញ្ចឹង (គេថា)កម្ពុជាអត់សាមគ្គីជាមួយអាស៊ានទេ។ ឥឡូវ ខ្ញុំសួរបកត្រឡប់ទៅវិញ តើពេលហ្វីលីពីន ប្តឹងចិនទៅតុលាការមានបានសួរ អាស៊ាន ឬអត់? ... **លោកឯងមកចុះហត្ថលេខានៅភ្នំពេញជាមួយខ្ញុំ កំពុងតែប្រើ ប្រាស់យន្តការអាស៊ាន/ចិន លើបញ្ហា DOC ឆ្ពោះទៅ COC ដល់លោកឯងទៅ តុលាការ លោកឯងមានបានសួរអាស៊ានថាត្រូវ ឬអត់? លោកឯងបានដើរចេញពី**

យន្តការហ្នឹងទៅហើយ។ សង្ឃឹមថា មិត្តអាស៊ានដទៃទៀតយល់អំពីបញ្ហានេះ... កម្ពុជាអត់មានអីខាតបង់លើសពីឆ្នាំ ២០១២ទេ...ឥឡូវប្រធានាធិបតី(ហ្វីលីពីន) ថ្មី ជិតចូលកាន់តំណែង ហើយចង់ចរចាជាមួយចិន ...។

៧. សូមកុំលូកលាន់កិច្ចការផ្ទៃក្នុងកម្ពុជា។ ក៏មិនលូកលាន់កិច្ចការអ្នកដទៃដែរ

ពិធីសំណេះសំណាលជាកម្មករ កម្មការិនី បុគ្គលិក មន្ត្រីកំពង់ផែស្វយ័ត,
ក្រុងព្រះសីហនុ, ០១ ឧសភា ២០១៦

... គេសប្បាយប៉ុណ្ណឹង ទៅជាថាប្រទេស(កម្ពុជា)កំពុងវិបត្តិ។ ហើយបើ បរទេសណានិយាយថាប្រទេសនេះវិបត្តិ សូមមើលប្រទេសខ្លួនឯងមើល ថាវា យ៉ាងម៉េច? ដូចជាអឺរ៉ុប ការវាយប្រហារភេរវកម្ម វិបត្តិជនភៀសខ្លួន សិទ្ធិស៊ីវិល ជនភៀសខ្លួនទៅណា? ទីនេះ គេគ្រាន់តែប្រឆាំងជាមួយពួកអនាធិបតេយ្យ ព្រោះ កាលណាតែមិនមែននីតិរដ្ឋហើយ គឺអនាធិបតេយ្យហើយ។ ប្រជាធិបតេយ្យ ត្រូវ អមដោយនីតិរដ្ឋ។ សេរីភាពរបស់អ្នកមានព្រំដែនជាមួយសេរីភាពរបស់អ្នកដទៃ។ អ្នករំលោភ អ្នកត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។ យើងចាត់វិធានការមិនឲ្យខក ខាន ដើម្បីការពារនូវកិត្តិយស សេចក្តីថ្លៃថ្នូររបស់គណបក្សប្រជាជន និងរដ្ឋាភិបាល របស់យើង។ **សូមបរទេសកុំលូកដៃចូលកិច្ចការផ្ទៃក្នុងកម្ពុជា។ កម្ពុជាមិនបាន លូកលាន់ចូលកិច្ចការផ្ទៃក្នុងរបស់អ្នកដទៃទេ តែសូមអ្នកដទៃគោរពនូវឯការជ្យ អធិបតេយ្យភាព និងបូរណភាពទឹកដីរបស់កម្ពុជា។ កុំជ្រៀតជ្រែកអោយសោះ។ អ្នកធ្លាប់តែនិយាយថាសុំអោយបែងចែកអំណាច នីតិបញ្ញត្តិ នីតិប្រតិបត្តិ និង តុលាការ ក៏ប៉ុន្តែ អ្នកកំពុងជាក់សម្ពាធខ្លះមកឲ្យយើង ដើម្បីបំពានលើអំនាច របស់តុលាការ**...។

៨. មិនឲ្យនរណាម្នាក់បំផ្លាញ សន្តិភាព និងស្ថេរភាពនៅកម្ពុជាឡើយ

ពិធីចែកសញ្ញាបត្រជូននិស្សិត នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង,
ថ្ងៃទី ០៥ កុម្ភៈ ២០១៦

... អ្វីដែលសំខាន់ត្រូវរក្សាស្ថេរភាពឲ្យបាន។ បើគ្មានសន្តិភាព និងស្ថេរភាពទេ កុំថាឡើយដល់ការអភិវឌ្ឍ។ រឿងនេះត្រូវមើលឲ្យច្បាស់ មើលឲ្យឃើញ មើលឲ្យ

ស៊ីជម្រៅ។ ឥឡូវដូចជាគេនិយាយនៅអ៊ីតាលីថា ដូចចង់ហួសពេលស្រោចស្រង់លីបីហើយ។ តើលទ្ធផលវាចេញពីអី? ... **កម្ពុជាក៏ត្រូវតែពិនិត្យពិច្ច័យម៉ត់ចត់លើការការក្សាសន្តិភាព ស្តេរភាពនយោបាយ។ ការបំផ្លាញវាជារឿងងាយ តែការស្វែងរកនិងការពារសន្តិភាព ទើបជាការលំបាក។ មិនត្រូវឲ្យពួកជ្រុលនិយមណាមួយបំផ្លាញនូវសន្តិភាពរបស់ព្រះរាជាណាចក្រកម្ពុជាទេ។ ទម្រាំរកបានប៉ុណ្ណោះ យើងលំបាកណាស់ យើងប្រើប្រាស់ជីវិតរបស់យើងធ្វើដើមទុន ដើម្បីនាំមកនូវសេចក្តីសុខ ការរស់រានមានជីវិតរបស់ប្រជាជន ដើម្បីការរួបរួមជាតិ ដើម្បីសន្តិភាព ឯកភាពជាតិ តាមរយៈនយោបាយឈ្នះ-ឈ្នះ។** សង្ឃឹមថា និស្សិត សាស្ត្រាចារ្យ និងប្រជាពលរដ្ឋរបស់យើង យល់អំពីហេតុផលទាំងអស់នេះ និងមើលពិភពលោកទាំងមូលកំពុងកើតមានអ្វី? ...។

៩. កត្តាធំៗ ៤ ដែលកម្ពុជាចូលអាស៊ាន

ពិធីចែកវិញ្ញាបនបត្រមន្ត្រីជាន់ខ្ពស់ មន្ត្រីក្រមការ សាលាភូមិន្ទរដ្ឋបាល,
២០ មិថុនា ២០១៦

... ហេតុអីបានជា ហ៊ុន សែន ប្រឹងម្ល៉ះក្នុងការចូលអាស៊ាន។ **មានកត្តាបួនៗ ទីមួយ គោលការណ៍មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង** ... កម្ពុជា នៅក្នុងចន្លោះប្រទេសអាស៊ានធំៗ ពីរ រៀតណាមម្ខាង ថៃម្ខាង។ បើយើងនៅតែឯង គឺជាប្រទេសឯកោ។ **ទីពីរ ស្មារតីសហគមន៍ គឺអាស៊ានធ្វើការតាមកុងសង់ស៊ីស មិនថាប្រទេសមាន មិនថាប្រទេសក្រ មិនថាប្រទេសធំ មិនថាប្រទេសតូច សម្លេងស្មើគ្នាទាំងអស់**។ ខ្ញុំបានតស៊ូ មិនឲ្យមានការបោះឆ្នោតក្នុងអាស៊ានពេលកសាងធម្មនុញ្ញអាស៊ាន ហើយដែលសម្រេចនៅសេប៊ូ ប្រទេសហ្វីលីពីន។ ពេលហ្នឹងចង់ឲ្យមានការបោះឆ្នោត។ ខ្ញុំថាអត់បានទេ។ តែបោះឆ្នោតមានសម្លេងភាគច្រើនភាគតិចហើយ។ វានឹងបែកបាក់។ ដូច្នេះ ត្រូវរក្សាគោលការណ៍កូសង់ស៊ីសតទៅទៀត។ **ទីបី កម្ពុជា ទទួលផលប្រយោជន៍ពីសមាហរណកម្មអាស៊ាន ទាក់ទងនឹងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការតភ្ជាប់ ឯទីបួន វាជាច្រកចេញការទូតដ៏ធំរបស់កម្ពុជា ដោយសារអាស៊ានមានដៃគូច្រើន** ... កត្តាបួននេះគ្រប់គ្រាន់ដើម្បីយល់ថាកម្ពុជាមានការចាំបាច់ចូលអាស៊ាន ...។

១០. ផែនទីដែលរដ្ឋាភិបាលប្រើ គឺជាផែនទីស្របច្បាប់

ពិធីប្រកាសផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យ
ឧស្សាហកម្មកម្ពុជា ២០១៥-២០២៥, ២៦ សីហា ២០១៥

... **បើយោងទៅលើផ្លូវច្បាប់ ខ្ញុំអត់ត្រូវការកផែនទីណាមកផ្ទៀងទេ។ ព្រោះអី? នៅឆ្នាំ ២០០៥ សភាបានឲ្យសត្យាប័នលើសន្ធិសញ្ញាបំពេញបន្ថែម ព្រឹទ្ធសភាបានឆ្លងព្រះមហាក្សត្របានឡាយព្រះហស្តលេខាឲ្យប្រើនូវផែនទីហ្នឹងឯង។ ប៉ុន្តែដើម្បីឲ្យពលរដ្ឋខ្មែរអស់ចិត្ត គឺយើងត្រូវកផែនទីយកមកផ្ទៀង។** ប៉ុន្តែ មិនមែនបានសេចក្ដីថា យើងយកផែនទីផ្លូវការរបស់យើងទៅផ្ទៀងរបស់គេទេ, យកផែនទីរបស់គេមកផ្ទៀងរបស់យើង។ ... ផែនទីដែល(ថា បានយកទៅ)តម្កល់(នៅអង្គការសហប្រជាជាតិ) អគ្គលេខាអង្គការសហប្រជាជាតិថារកមិនឃើញ ប៉ុន្តែយើងនៅតែបន្តការរុករកតទៅទៀត។ ... ខ្ញុំសូមបញ្ជាក់ (ផែនទី)ផ្លូវការ ២៦ ផ្នាំងនៅទីនេះដែលច្បាប់អនុញ្ញាតឲ្យប្រើរួចហើយ អ្នកណាក៏ដោយ ហ៊ានប្រើប្រាស់នូវពាក្យថាផែនទីចោរ ឬផែនទីក្លែងក្លាយត្រូវប្រឈមនឹងផ្លូវច្បាប់ជាបន្ទាន់ អត់មានការលើកលែង ហើយអត់រង់ចាំពេលវេលាទេ ...។

១១. កុំអោយជម្លោះ ការមិនចុះសម្រុងរដ្ឋ រារាំងសកម្មភាពប្រឆាំងភេរវកម្ម

ពិធីបើកវេទិកាសេដ្ឋកិច្ចអាស៊ីលើកទី ៤ ឆ្នាំ ២០០៨, ១៤ តុលា ២០០៨

... អ្វីដែលបាន និងកំពុងកើតនៅលើពិភពលោក(ដូចជា)ភេរវកម្មវាអត់ទាន់ស្ងប់ទេ។ វាក៏ជាគ្រោះគំរាមកំហែងមួយ ... ត្រូវធ្វើកិច្ចសហការយ៉ាងច្បាស់លាស់ មិនត្រូវបណ្ដោយឲ្យជម្លោះបណ្ដារដ្ឋលើបញ្ហាព្រំដែន ឬបញ្ហាការទូត ក្លាយទៅជាឧបសគ្គនៃការប្រយុទ្ធប្រឆាំងភេរវកម្មទេ។ កម្ពុជាជាមួយថៃ ទោះបីមានបញ្ហាព្រំដែនតែកម្ពុជា និងថៃ មិនបានបណ្ដោយឲ្យជម្លោះព្រំដែននេះ ក្លាយទៅជាឧបសគ្គនៃកិច្ចសហប្រតិបត្តិការដទៃទៀត រាប់ទាំងការប្រយុទ្ធប្រឆាំងភេរវកម្ម ... **បើសិនជាជាក់ប្រទេសមួយឲ្យឯកោ តាមរយៈលក្ខខណ្ឌនេះលក្ខខណ្ឌនោះ រហូតដល់រារាំងនូវសកម្មភាពសហប្រតិបត្តិការប្រឆាំងភេរវកម្ម វាអាចជាចំណុចខ្សោយយ៉ូអង្ហែងក្នុងការដោះស្រាយបញ្ហាប្រឈមដ៏ធំនេះ។ បើទោះបីជាមានបញ្ហាជា**

មួយគ្នាលើផ្នែកនយោបាយក្តី ជម្លោះនេះជម្លោះនោះ ដែលបានកើតឡើងចំពោះបណ្តារដ្ឋ មិនគួរឲ្យជម្លោះទាំងនោះ ការមិនចុះសម្រុងទាំងនោះ ក្លាយទៅជាឧបសគ្គរារាំង យ៉ាងហោចណាស់សកម្មភាពដែលចំបងជាងគេ គឺការប្រយុទ្ធប្រឆាំងភេរវកម្មឡើយ ...។

១២. ទទួលយកប្រតិបត្តិការមួកខៀវ បង្កើតជំនឿ ស្វែងរកសន្តិភាព និងបង្រួបបង្រួមជាតិ

> បិទសន្និបាតបូកសរុបលទ្ធផល ការងារបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ រយៈពេល ១០ ឆ្នាំ (២០០៦-២០១៦), ០១ មីនា ២០១៦

... នៅក្នុងប្រវត្តិជីវិតនយោបាយរបស់ខ្ញុំ ខ្ញុំពិតជាបានសម្រេចចិត្តលើបញ្ហាធំៗជាច្រើន តាំងពីការចាប់ផ្តើមធ្វើសកម្មភាពវាយផ្ទួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត និងជាបន្តបន្ទាប់ គឺធ្វើការសម្រេចចិត្តពាក់ព័ន្ធជាមួយនឹងបញ្ហាសង្គ្រាម ឬសន្តិភាព។ ការសម្រេចចិត្តទទួលយកប្រតិបត្តិការអង្គការសហប្រជាជាតិ នៅក្នុងប្រទេសកម្ពុជា មិនមែនជាបញ្ហាងាយស្រួលទេនៅក្នុងកាលៈទេសៈនោះ។ **ក្នុងហានៈជាប្រធាននៃអ្នកចរចា ក្នុងហានៈជានាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលមួយ ដែលកំពុងមានជម្លោះជាមួយភាគីជម្រៃ។ ភាគីផ្សេងៗ និងសហគមន៍អន្តរជាតិ បានទទួចឲ្យមានប្រតិបត្តិការអង្គការសហប្រជាជាតិ។ ខ្ញុំខ្លួនឯងបានពិភាក្សាជាមួយសហការីក្នុងពេលវេលានៃការចរចាដ៏លំបាកនោះ សម្រេចថា យើងត្រូវទទួលយកនូវកម្លាំងមួកខៀវរបស់អង្គការសហប្រជាជាតិមកប្រតិបត្តិការក្នុងប្រទេស ដើម្បីបង្កើតនូវជំនឿទុកចិត្តគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ឲ្យពួកគេចូលរួមនៅក្នុងការរកសន្តិភាព និងការបង្រួបបង្រួមជាតិ ...។**

១៣. ការបញ្ជូនកងទ័ពកម្ពុជាក្រោមឆ័ត្រអង្គការសហប្រជាជាតិ ជាការសម្រេចត្រឹមត្រូវ

> បិទសន្និបាតបូកសរុបលទ្ធផល ការងារបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ រយៈពេល ១០ ឆ្នាំ (២០០៦-២០១៦), ០១ មីនា ២០១៦

... ក្រោយមក **យើងត្រូវធ្វើការសម្រេចចិត្តមួយទៀត ដែលក៏មិនមែនជាការងាយស្រួលដែរ គឺកម្ពុជាខ្លួនឯងកំពុងតែលំបាក ប៉ុន្តែបែរជាថ្លើមធំចិត្តធំហ៊ានបញ្ជូនកងទ័ពទៅក្រៅប្រទេស** ... ខ្ញុំធ្លាប់បានជួបជនជាតិកម្ពុជាហើយ ដែលគាត់បានទទួលមរណភាពប្រហែលជា ១៥ ឆ្នាំមុន។ គាត់បានទៅប្រយុទ្ធនៅលើទឹកដីអាល់ហ្សេរី និងម៉ារ៉ុក ក៏ប៉ុន្តែនៅពេលនោះ គាត់ទៅក្នុងហាន:ជាទាហានរបស់បារាំង ព្រោះយើងស្ថិតនៅក្រោមអាណានិគម ... តែលើកនេះ យើងបានបញ្ជូន(កងទ័ព)ក្នុងនាមជារដ្ឋអធិបតេយ្យ ជាសមាជិកអង្គការសហប្រជាជាតិ ដើម្បីចូលរួមប្រតិបត្តិការការពារសន្តិភាពរបស់អង្គការសហប្រជាជាតិ ឆ្លើយតបជាមួយនឹងការអំពាវនាវរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលត្រូវការកម្លាំងដោះមីន។ **ថ្ងៃទី ១ មីនា គឺជាថ្ងៃដែលខ្ញុំធ្វើការសម្រេចចិត្ត ... ច្បាស់ណាស់ថានាយករដ្ឋមន្ត្រីត្រូវទទួលខុសត្រូវចំពោះប្រវត្តិសាស្ត្ររបស់ជាតិ។ កម្ពុជាបញ្ជូនកម្លាំងទៅក្រៅប្រទេស តែក្នុងក្របខណ្ឌនៃប្រតិបត្តិការរបស់អង្គការសហប្រជាជាតិតែប៉ុណ្ណោះ ...**។

១៤. មហិច្ឆតា ពង្រីកការបញ្ជូនកម្លាំងរក្សាសន្តិភាព និងជំនួយ(បើក្លាយជាប្រទេសមាន)

> បិទសន្និបាតបូកសរុបលទ្ធផលការងារបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ រយៈពេល ១០ ឆ្នាំ (២០០៦-២០១៦), ០១ មីនា ២០១៦

... ខ្ញុំពិតជាមានមហិច្ឆតាធំណាស់។ ខ្ញុំបានប្រាប់ថាមានផែនការពង្រីកកម្លាំងបញ្ជូនទៅក្រៅប្រទេស។ ឥឡូវ កម្ពុជាកំពុងស្ថិតក្នុងប្រព័ន្ធអង្គការសហប្រជាជាតិក្នុងការរៀបកម្លាំងរហ័ស។ យើងនឹងពិនិត្យបន្ត ក្នុងការចូលរួមចំណែកប្រតិបត្តិការទៅក្នុងប្រទេសមួយចំនួនទៀត នៅពេលមានសំណូមពរអង្គការសហប្រជាជាតិ។ មិត្តភក្តិបានជួយមកដល់យើងៗ ក៏បានជួយទៅមិត្តភក្តិវិញដែរ។ កម្ពុជាក្រប្រាក់កាស ប៉ុន្តែមិនក្រផ្លូវចិត្តនោះទេ ... **បើសិនកម្ពុជាទៅជាប្រទេសអ្នកមានខាងសេដ្ឋកិច្ចវិញ កម្ពុជានឹងផ្តល់ជំនួយទៅក្រៅប្រទេសឲ្យស្មើនឹង ០.៧% នៃ GDP។ នេះជាមហិច្ឆតារបស់ខ្ញុំ។ តែឥឡូវ នៅជាប្រទេសក្រីក្រ កម្ពុជាមានលទ្ធភាពត្រឹមតែបញ្ជូនកម្លាំងទៅជួយប្រតិបត្តិការការពារសន្តិភាព ដើម្បីបំបាត់**

ចោលនូវស្ថានភាពគ្រោះថ្នាក់ដោយសារមីន គ្រាប់មិនទាន់ផ្ទុះ ឬក៏ទាក់ទិននឹងគ្រូពេទ្យ និងអ្វីជាតម្រូវការ របស់អង្គការសហប្រជាជាតិនៅទីនោះ។ បន្ថែមម្តងៗ យើងបានត្រៀមខ្លួនបញ្ជូនជំនួយខ្លះទៅកាន់ប្រទេសអាហ្វ្រិក ដែលបានលើកសំណូមពរចំពោះខ្ញុំរួចមកហើយៗ កំពុងតែគិតគូរអំពីបញ្ហានេះ ដែលអាចធ្វើសកម្មភាពនៅពេលខាងមុខ ...។

១៥. បើថវិការប្រើមិនចំគោលដៅ ប្រទេសផ្តល់ជំនួយឈប់ឲ្យហើយ

ពិធីសម្ពោធជាផ្លូវការរោងចក្រប្រព្រឹត្តកម្មទឹកស្អាត និរោធ ជំហានទី ១, ០៤ មិថុនា ២០១៣

... សមិទ្ធផលសំរាប់ការផ្គត់ផ្គង់ទឹកនៅទីក្រុងភ្នំពេញថ្ងៃនេះ គឺសហហិរញ្ញប្បទានដោយជប៉ុន និងបារាំង ... ឯកឧត្តមអគ្គរដ្ឋទូតបារាំងបានលើកឡើងចំណុចមួយពាក់ព័ន្ធនឹងភាពជាគំរូ ជាសាក្សីបង្ហាញឲ្យឃើញពីកិច្ចសហប្រតិបត្តិការរវាងទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ AFB និងទីភ្នាក់ងារសហប្រត្តិការអន្តរជាតិជប៉ុន JICA ... ពិតជាមានមោទនភាពជាមួយសហប្រតិបត្តិការអន្តរជាតិបែបនេះ ... សូមបញ្ជាក់ជូនបន្ថែមថា **បើសិនជាកម្ពុជាយើងគ្មានកំណើតទេនោះ ពិតប្រាកដណាស់ថា គ្មាននរណាគេឲ្យលុយយើងទេ។ វាជាសច្ចធម៌ដែលមិនអាចអ្នកណាបំភ្លៃការពិតនេះបានទេ។ បើថវិការត្រូវបាត់បង់ តើអគ្គរដ្ឋទូតបារាំង និងអគ្គរដ្ឋទូតជប៉ុនគាត់សុខចិត្តទេ? ហើយតើសភាជប៉ុន ឬសភាបារាំងគាត់សុខចិត្តទេ? ក្នុងការដែលអនុម័តថវិកាមកឲ្យកម្ពុជានោះ ... សូម្បីតែសិក្សាអំពីប្រសិទ្ធភាពខាងសេដ្ឋកិច្ចមិនគ្រប់គ្រាន់ ក៏គេមិនឲ្យហិរញ្ញប្បទានដែរ ...។**

១៦. កសាងព្រំដែនកម្ពុជា និងថៃ សន្តិភាព មិត្តភាព និងសហប្រតិបត្តិការ

ពិធីសម្ពោធដាក់អោយប្រើប្រាស់តំបន់សេដ្ឋកិច្ចពិសេសកោះកុង និងសម្ពោធដាក់ឲ្យប្រើប្រាស់នូវរោងចក្ររបស់ក្រុមហ៊ុនយ៉ាសាគី, ១២ ធ្នូ ២០១២

... វត្តមានរបស់លោកជំទាវអភិបាលខេត្តត្រាត ក៏ដូចជាបណ្តាមេបញ្ជាការនៃកងទ័ពព្រះរាជាណាចក្រថៃ បានបង្ហាញពីចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងកម្ពុជា និងថៃ។ **ខ្ញុំចង់បានរបៀបនេះ ខ្ញុំចង់បានការកសាងព្រំដែនសន្តិភាព**

មិត្តភាព និងសហប្រតិបត្តិការ។ នេះជាអ្វីដែលប្រជាជនយើងទាំងពីរចង់បាន។ យើងត្រូវបន្តការខិតខំ ដើម្បីធ្វើឲ្យប្រជាជននៅតាមព្រំដែននៃប្រទេសទាំងពីរបានទៅមករកគ្នា រកស៊ីជាមួយគ្នា ដើម្បីរីបុលភាពជាមួយគ្នា។ ឥឡូវ យើងមានការតភ្ជាប់គ្នាច្រើនណាស់ សម្រាប់តំបន់កោះកុង (ដូចជាការ)តភ្ជាប់ជាផ្លូវថ្នល់ តភ្ជាប់ជាអគ្គិសនី តភ្ជាប់ជាទេសចរណ៍ តភ្ជាប់ពាណិជ្ជកម្ម តភ្ជាប់ជាផ្នែកដទៃទៀត រីឯធម៌ជាដើម។ សូមឲ្យបន្តរបៀបនេះជារៀងរហូតទៅ។ កងទ័ព និងកងទ័ពសហការគ្នា នគរបាល និងតម្រួតសហការគ្នា អាជ្ញាធរខេត្តទាំងពីរសហការគ្នា ប្រជាជនសហការគ្នា រកស៊ីជាមួយគ្នាទៅ ចំណេញទាំងសងខាង ហើយអ្នកវិនិយោគគ្មានការភ័យខ្លាច ជាមួយនឹងការវិនិយោគនៅក្បែរព្រំដែនកោះកុងទេ ...។

១៧. ចិនជួយកម្ពុជាស្ថាបនា មិនបានជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងឡើយ

ពិធីសម្ពោធដាក់អោយប្រើប្រាស់ស្ពានមិត្តភាពកម្ពុជាចិន, ៣ សីហា ២០១៥

... វាក៏គាប់ជួនជាមួយនឹងគំនិតផ្តួចផ្តើមរបស់មិត្តចិន ស្តីអំពី ខ្សែក្រវ៉ាត់មួយ និងផ្លូវមួយ ដោយការចាប់ផ្តើមទម្លាក់ថវិកាដំបូងចំនួន ៤០ ពាន់លានដុល្លារសហរដ្ឋអាមេរិក ហៅថាមូលនិធិផ្លូវសូត្រ ... បន្ថែមដោយ ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធ (AIIB) ដែលកម្ពុជាក៏ជាសហស្ថាបនិកមួយដែរ ហើយដែលផ្តួចផ្តើមដោយចិន ក្នុងទំហំទឹកប្រាក់ជំហានដំបូងសរុប ១០០ ពាន់លានដុល្លារសហរដ្ឋអាមេរិកទៀត។ កម្ពុជាសង្ឃឹមថា នឹងអាចទទួលបានឥណទានយកមកអភិវឌ្ឍគម្រោងថ្មីៗ របស់ខ្លួន (ហើយ)ដែលគំរោងទាំងនោះ បានបញ្ជូនទៅមិត្តចិនរួចហើយ(ប្រចាំឆ្នាំ) ... **(ចិន)រាល់តែរឿងជួយស្ថាបនាទេ មិនបានរាល់មកជួយដោះស្រាយរឿងនយោបាយអីឡើយ (ព្រោះ) ចិនគ្មានទម្លាប់មកជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់អ្នកណាទេ។ លោកជំទាវក៏មិនបានមករាល់ជាមួយខ្ញុំ ពីរឿងសិទ្ធិមនុស្ស ពីរឿងប្រជាធិបតេយ្យស្តីទេ លោកជំទាវមករាល់ជាមួយយើងខ្ញុំ លើការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងកាត់បន្ថយភាពក្រីក្រ និងការលំបាករបស់ប្រជាជនកម្ពុជា ...**។

១៨. អន្តរសកម្មហេដ្ឋារចនាសម្ព័ន្ធហិរញ្ញប្បទានពីចិន និងដៃគូ ផ្តល់កំណើនសេដ្ឋកិច្ច

ពិធីបើកការដ្ឋានស្ពានកោះធំ ឆ្លងកាត់ទន្លេបាសាក់ ប្រវែង ៤១៥ ម៉ែត្រ,

២៥ មីនា ២០១៣

... ខ្ញុំព្រះករុណាខ្ញុំ ពិតជាមានការរីករាយដោយបានឃើញថា ទំនាក់ទំនងរវាងកម្ពុជា-ចិន ត្រូវបានធ្វើឲ្យកាន់តែប្រសើរពីកម្រិតមួយទៅកាន់កម្រិតមួយទៀត ចាប់ពីឆ្នាំ ២០១០ រហូតមកដល់ពេលនេះ គឺភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយរវាងកម្ពុជា-ចិន កំពុងបាន និងអនុវត្ត ដោយនៅពេលខាងមុខ នឹងដាក់ចេញនូវផែនការសកម្មភាពគ្រប់ជ្រុងជ្រោយ ដើម្បីជោគជ័យនៃភាពជាដៃគូយុទ្ធសាស្ត្រនេះ។ ខ្ញុំសង្ឃឹមថា ទំនាក់ទំនងរវាងកម្ពុជា-ចិន នឹងរឹងមាំដូចជាស្ពានបេតុងឆ្លងកាត់ទន្លេទាំងអស់របស់យើង។ យើងបានសាកល្បងទំនាក់ទំនងនេះ ចាប់តាំងពីព្រះករុណាព្រះបាទ ព្រះនរោត្តម សីហនុ ជាមួយថ្នាក់ដឹកនាំចិន ដូចជាប្រធាន ម៉ៅ និងនាយករដ្ឋមន្ត្រី ជូ អេងឡាយ ជាដើម។ ឥឡូវ មកដល់ដំណាក់កាល ព្រះបាទ ព្រះបរមនាថ នរោត្តម សីហមុនី ជាមួយនឹងខ្ញុំព្រះករុណាខ្ញុំ នៅបន្ត ជាមួយនឹងមេដឹកនាំចិន ពីជំនាន់មុននេះ គឺប្រធានាធិបតី ហ៊ូ ជិនតាវ ជាមួយនាយករដ្ឋមន្ត្រី វ៉েন ជាប៉ាវ ឥឡូវមកដល់ដំណាក់កាលនៃប្រធានាធិបតី ស៊ី ជីនពីង និងនាយករដ្ឋមន្ត្រី លី ខឺឈាំង។ ខ្ញុំព្រះករុណាខ្ញុំ (បានធ្វើ)តាំងពីជំនាន់ប្រធានាធិបតី ហ្សាង ហ្សេមីង និងនាយករដ្ឋមន្ត្រី លី ភឹង ហើយបន្ទាប់ទៅ ជូ រុងជី ... **អន្តរសកម្មនៃការកសាងហេដ្ឋារចនាសម្ព័ន្ធ បានមកពីហិរញ្ញប្បទានរបស់សាធារណរដ្ឋប្រជាមានិតចិន ក៏ដូចជាដៃគូអភិវឌ្ឍជនៃទៀត បានធ្វើឲ្យកំណើនសេដ្ឋកិច្ចកម្ពុជារីកលូតលាស់ ក្នុងរយៈកាលជិតមួយទសវត្សរ៍កន្លះចុងក្រោយ បន្ទាប់ពីប្រទេសរបស់យើងមានសន្តិភាពពេញលេញ អាចថាពីឆ្នាំ ១៩៩៨ មកដល់ពេលនេះ គឺមួយទសវត្សរ៍កន្លះ ១៥ ឆ្នាំ** ...។

១៩. ភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-ចិន មានប្រយោជន៍ដល់ប្រទេសទាំង ១០

ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ ៤៤ ដែលតភ្ជាប់រវាងច្បារមន ឌ៉ាល់ អមលាំង ខេត្ត ទៅដល់ផ្លូវជាតិលេខ ៥, ០២ សីហា ២០១៦

... លោកជំទាវអគ្គរដ្ឋទូត នៃសាធារណរដ្ឋប្រជាមានិតចិន លើកឡើងអំពី**ទំនាក់ទំនងរវាងកម្ពុជា-ចិន។ នោះជាអាទិភាពនយោបាយការបរទេសរបស់កម្ពុជា**

ដែលត្រូវពង្រឹងជាមួយនឹងដៃគូខាងក្រៅ ដែលក្នុងនោះមានសាធារណរដ្ឋប្រជាមានិតចិន។ នៅក្នុងក្របខណ្ឌអាស៊ាន ទំនាក់ទំនងរវាងអាស៊ាន និងចិន គឺផ្តល់ផលប្រយោជន៍ដល់អាស៊ានខ្លាំងណាស់។ ដូច្នេះ ជានិច្ចជាកាល កម្ពុជារកការសម្របសម្រួល ធ្វើយ៉ាងណាធានាសុខដុមការវិបនីយកម្មទំនាក់ទំនងរវាងអាស៊ាន និងចិន (ដែលមាន)ទំហំពាណិជ្ជកម្មធំ ... ប្រទេសចិននាំចេញមកបណ្តាប្រទេសអាស៊ានទាំង ១០ មានទំហំតូចជាងទំហំដែលអាស៊ាននាំចូលទៅប្រទេសចិន។ ... ទោះបីយើងមាន(ប្រជាពលរដ្ឋ)ត្រឹមតែ ១៥ លាននាក់ ព្រុយនេមានតែជាង ៤០ ម៉ឺននាក់ និងប្រទេសខ្លះទៀត មានតែជាង ៤,៥ ម៉ឺននាក់នៃប្រជាពលរដ្ឋ ប៉ុន្តែគឺជារដ្ឋមួយ ដែលត្រូវធ្វើទំនាក់ទំនងដោយស្មើភាព និងស្មើសិទ្ធិ ហើយប្រទេសចិនគឺជាប្រទេស ដែលតែងតែគោរពឯករាជ្យអធិបតេយ្យភាពចំពោះប្រទេសដទៃទៀត ក្នុងនោះ យកចិត្តទុកដាក់ធ្វើទំនាក់ទំនងជាមួយប្រទេសដៃគូកំពុងអភិវឌ្ឍន៍ ...។

២០. ផ្លូវសូត្រសមុទ្រសតវត្សរ៍ទី ២១, ផ្លូវសូត្រ និងធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី

ពិធីចែកសញ្ញាបត្រសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងប្រកាសសម្ពោធមជ្ឈមណ្ឌលកម្ពុជា ដើម្បីស្រាវជ្រាវផ្លូវសូត្រសមុទ្រ, ១៣ មិថុនា ២០១៦

... នៅចុងឆ្នាំ ២០១៤ ធ្វើជាម្ចាស់ផ្ទះការប្រជុំ APEC ចិនបានយកចិត្តទុកដាក់ទៅលើដៃគូ ដែលមិនមែនជាសមាជិក APEC ដោយបានអញ្ជើញប្រមុខរដ្ឋាភិបាលមិនមែនជាសមាជិក APEC ទៅចូលរួមក្នុងការប្រជុំទាក់ទងនឹង **"ខ្សែក្រវ៉ាត់មួយវិថីមួយ" និង "ផ្លូវសូត្រសមុទ្រសតវត្សរ៍ទី ២១" ដែលក្នុងហ្នឹងមានកម្ពុជា មានឡាវ មានមីយ៉ាន់ម៉ា មាននាយករដ្ឋមន្ត្រីប៉ាគីស្ថាន មានប្រទេសមួយចំនួនផ្សេងទៀតដែលនៅជិតខាងចិន។ ខ្សែក្រវ៉ាត់មួយ ផ្លូវមួយនេះ មិនជាប់ទាក់ទងត្រឹមតែមកកាន់អាស៊ីអាគ្នេយ៍ទេ ជាប់ពាក់ព័ន្ធទៅនឹងតំបន់ដទៃទៀតរហូតតភ្ជាប់ទៅ តំបន់អឺរ៉ុបណោះ។ នៅពេលធ្វើបទអន្តរាគមន៍ ខ្ញុំបាននិយាយថា គំនិតផ្តួចផ្តើមនៅក្នុងតំបន់យើងមានច្រើនណាស់ ប៉ុន្តែសំខាន់ជាងគេ គឺខ្វះទុន។** យើងអរគុណចំពោះមិត្តចិន ដែលបានប្រកាសចេញនូវមូលនិធិសម្រាប់បណ្តាប្រទេសរៀបចំគម្រោងការ។ និយាយពីគំនិតផ្តួចផ្តើមទាក់ទងនឹង Highway Asia តាំងពីស្រុកចិន ទៅដល់តួគី សួរថា ឥឡូវមានលុយមកពីណា ... គំនិតផ្តួចផ្តើមផ្លូវ

ដៃកអាស៊ាន/គន់មិញ ដែលឆ្លងកាត់កម្ពុជា ឥឡូវអ្នកណាអ្នកចេញលុយ? ខ្ញុំបាននិយាយនឹងប្រធានាធិបតីចិន ក៏ដូចជាអ្នកចូលរួមថា តំបន់របស់យើងមានគំនិតផ្តួចផ្តើមច្រើន គម្រោងច្រើន ប៉ុន្តែរឿងធំគឺអត់លុយ។ អញ្ចឹង មិត្តចិនបានប្រកាសមូលនិធិផ្លូវសូត្រ ៣០ ៣ន់លានដុល្លារ ដើម្បីឲ្យបណ្តាប្រទេសយកមូលនិធិ ហ្នឹងទៅប្រើ តាមរយៈកម្ចីសម្បទាន ឬក៏កម្ចីបែបណាមួយនោះ ...។

២១. BRICS, AIIB និងមូលនិធិផ្លូវសូត្រអាស៊ី មិនជាសត្រូវ World Bank, ADB ទេ

ពិធីបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ ២០១៥៖ ភាពជាដៃគូរវាងវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា និងធនាគារអេអិនហ្ស៊ីតរ៉ូយ៉ាល់ «សហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ ២០១៥ និងតទៅអនាគត៖ របៀបវារៈការកែទម្រង់», ០៥ មីនា ២០១៥

... ខ្ញុំសង្ឃឹម ធនាគារពិភពលោក និងធនាគារនៃប្រទេសលូតលាស់ទាំង ៥ នេះ មិនប្រកួតប្រជែងគ្នាសម្លាប់គ្នាទេ តែគឺជាការបំពេញបន្ថែមឲ្យគ្នា។ ខ្ញុំជឿថា មានអ្នកមិនពេញចិត្តជាមួយនឹង BRICS ហើយខ្ញុំក៏ដឹងដែរថា ក៏មានអ្នកមិនចូលចិត្តជាមួយនឹងធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី ដែលកម្ពុជាក៏ជាសហស្ថាបនិកមួយ (តែ)វាមិនមែនជាគូប្រជែងធនាគារអភិវឌ្ឍន៍អាស៊ីទេ។ សង្ឃឹមថា ធនាគារអភិវឌ្ឍន៍អាស៊ីក៏មិនយកធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធធ្វើជាសត្រូវ តែផ្ទុយទៅវិញគឺជួយបំពេញឲ្យគ្នា។ នេះជាជម្រើសដ៏ល្អបំផុតសម្រាប់ពិភពលោក និងតំបន់ ហើយកាន់តែល្អជាងទៀត សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលត្រូវការដើមទុន។ ... ខ្ញុំសង្ឃឹមថា ធនាគារពិភពលោកមិនស្អប់ BRICS ទេ ហើយមិនច្រណែនដោយសារខ្លួនបាត់បង់តួនាទីខ្លះ (ព្រោះ)វាច្បាស់ហើយថា នឹងបាត់បង់តួនាទីខ្លះ ... **សូម្បីតណាទានគំនិតផ្តួចផ្តើមឈៀងម៉ែ ២៤០ ៣ន់លាន (ក៏)ធ្វើឲ្យអ្នកខ្លះមិនសប្បាយចិត្តទៅហើយ ... នៅពេល BRICS កើត នៅពេលធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ីកើត តួនាទីរបស់ក្រុមមួយចំនួននឹងត្រូវបាត់បង់។ (គួរ)កុំស្តាយការបាត់បង់តួនាទីដែលធ្លាប់មានពីមុននោះ ដើម្បីឲ្យអ្នកដទៃគេបានចូលរួមចំណែកអភិវឌ្ឍសម្រាប់តំបន់ និងពិភពលោកផង ...**។

២២. ជប៉ុនចូលរួមច្រើន ទាំងហេដ្ឋារចនាសម្ព័ន្ធ សុខាភិបាល អប់រំ និងវិស័យដទៃទៀត

ពិធីសម្ពោធមន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ, ២៩ កុម្ភៈ ២០១៦

... យើងរួមគ្នាសម្ពោធដាក់ឲ្យប្រើប្រាស់អគារសង្គ្រោះបន្ទាន់ អគារសម្ភព អគារជម្ងឺទូទៅ អគាររដ្ឋបាល និងអគារផ្តល់សេវាគាំទ្រ និងសម្ភារៈដទៃទៀត ដែលក្នុងនោះចំណាយថវិកាអស់ ១ ៥៥៤ លានយេន ស្មើនឹងជាង ១៥ លានដុល្លារ សហរដ្ឋអាមេរិកដែលជាការពង្រឹងនូវសមត្ថភាពនៃមន្ទីរពេទ្យនេះ (ក៏ដូចជាការ) ផ្តល់នូវការគាំទ្រខាងហិរញ្ញវត្ថុសម្រាប់កំពង់ផែទឹកជ្រៅ ដើម្បីជម្រុញការអភិវឌ្ឍប្រទេស ដែលខ្ញុំព្រះករុណាខ្ញុំតែងហៅថាជាក្បាលនាគ ដែលកន្ទុយនៅឯមុំបីខាងខេត្តស្ទឹងត្រែង រតនគិរី និងជាប់ព្រំដែនឡាវឯណោះ។ **វាជាផលប្រយោជន៍សម្រាប់ប្រជាជនកម្ពុជា ហើយយើងមានតម្រូវការច្រើនទៀត។ បើយោងតាមការកត់ត្រា ខ្ញុំព្រះករុណាខ្ញុំ បានចូលរួមសម្ពោធផ្នែកខាងវេជ្ជសាស្ត្រចំនួន ៤ លើករួចមកហើយ ... បើពិនិត្យទៅលើស្ថានភាពនេះ គឺជប៉ុនបានចូលរួមច្រើន មិនត្រឹមតែហេដ្ឋារចនាសម្ព័ន្ធទេ ក៏ប៉ុន្តែ លើវិស័យសុខាភិបាល អប់រំ និងវិស័យដទៃទៀត ក៏បានចូលរួមចំណែកច្រើនផងដែរ ...**។

២៣. ជំនួយរបស់ជប៉ុន គឺជប៉ុនជាអ្នកគ្រប់គ្រងផ្ទាល់

ពិធីសម្ពោធមន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ, ២៩ កុម្ភៈ ២០១៦

... **ខ្ញុំព្រះករុណាខ្ញុំ នៅតែបញ្ជាក់សាចុះសាឡើង ដើម្បីចៀសវាងមនុស្សមួយចំនួនបំផ្លាញកិត្តិនាមរបស់រាជរដ្ឋាភិបាលកម្ពុជាផង បំផ្លាញកិត្តិនាមរបស់រដ្ឋាភិបាលប្រទេសជប៉ុនផងនោះនៅត្រង់ថា គម្រោងដែលយើងបានសាងសង់ និងមកសម្ពោធថ្ងៃនេះ បើចង់ដឹងចាយអស់លុយប៉ុន្មាន (សូម)សួរអគ្គរដ្ឋទូតជប៉ុន សួរប្រធាន JICA សួររដ្ឋាភិបាលជប៉ុនទៅ**។ នៅស្រុកខ្មែរសំបូរណាស់អារឿងចោទគ្នាហ្នឹង មិនចប់មិនហើយទេ។ គេថាយើងហ្នឹងពុករលួយយកជំនួយបរទេសយកមកចាយ។ ប៉ុន្តែសួរអគ្គរដ្ឋទូតជប៉ុនទៅ សួរប្រធាន JICA ទៅ ហើយសួរក្រុមហ៊ុនសាងសង់ទៅ អស់លុយប៉ុន្មានអីប៉ុន្មាន ខ្ញុំព្រះករុណាខ្ញុំ ដឹងត្រឹមតែមកកាត់ខ្សែបូរឲ្យប្រើប្រាស់តែប៉ុណ្ណោះ។ ជំនួយរបស់ជប៉ុន គឺយ៉ាងដូច្នេះ។ ដេញថ្លៃក៏មិន

មែនដេញថ្លៃនៅស្រុកខ្មែរដែរ ដេញថ្លៃនៅតូក្យូឯណោះ ហើយបើថាជំនួយជប៉ុន ក៏មានតែក្រុមហ៊ុនជប៉ុនទៀត ទើបមានសិទ្ធិសាងសង់ ក្រៅពីក្រុមហ៊ុនជប៉ុនអត់មានសិទ្ធិសាងសង់ទេ។ (សូមជូន)សារនេះទៅអ្នកទាំងឡាយ ដែលតែងតែដឹងហើយតែធ្វើមិនដឹង។ តែមានអ្នកខ្លះក៏គ្នាមិនដឹងដែរ (ហើយ)ត្រូវបានអ្នកនយោបាយខ្លះមួលបង្កាច់។ សង្ឃឹមថា យើងនឹងយល់គ្នាពីបញ្ហាប្រើប្រាស់ជំនួយរបស់បរទេស ពិសេសការប្រើប្រាស់ជំនួយរបស់ជប៉ុន ...។

២៤. ទំនាក់ទំនងកម្ពុជា-ជប៉ុន ឡើងដល់កម្រិតដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ

ពិធីសម្ពោធ The Sunrise Japan Hospital, ២០ កញ្ញា ២០១៦

... ឯកឧត្តម ស៊ិនហ្សូ អាបេ ជាមួយខ្ញុំ គឺជាដៃគូដែលបានធ្វើការយ៉ាងច្រើនរវាងជប៉ុន និងកម្ពុជា។ **ខ្ញុំបានធ្វើការជាមួយនាយករដ្ឋមន្ត្រីជប៉ុនច្រើនហើយ ក៏ប៉ុន្តែតាមរយៈនៃការងារ ដែលធ្វើរយៈពេលកន្លងទៅនេះ ទំនាក់ទំនងដែលបានលើកកម្ពស់ដល់កម្រិតដៃគូជាយុទ្ធសាស្ត្ររវាងកម្ពុជា និងជប៉ុន ត្រូវបានធ្វើរវាងខ្ញុំជាមួយនឹងនាយករដ្ឋមន្ត្រីជប៉ុន ស៊ិនហ្សូ អាបេ។** យើងបានធ្វើកិច្ចការជាច្រើន ហើយសមិទ្ធផលក៏បានកើតឡើងច្រើនផងដែរកាលពីឆ្នាំទៅ (ដូចជា)ស្ពានអ្នកលឿង ដែលយើងរង់ចាំប៉ុន្មានសតវត្ស៍ បានដាក់សម្ពោធដាក់អោយប្រើប្រាស់នៅមុនចូលឆ្នាំថ្មី ដែលហៅថា ស្ពាន ត្សឹបាសា។ ជាមួយគ្នានោះដែរ កាលពីថ្ងៃទី ១ ខែ កញ្ញា កន្លងទៅនេះ ការហោះហើរត្រង់រវាងទីក្រុងតូក្យូ ណារីតា មកកាន់ទីក្រុងភ្នំពេញរបស់យើង ត្រូវបានចាប់ផ្តើម ...។

២៥. ផ្សារភ្ជាប់ឡើងវិញនូវទំនាក់ទំនងកម្ពុជា-កូរ៉េ នៅឆ្នាំ ១៩៩៦

ពិធីសម្ពោធអគារមជ្ឈមណ្ឌលចក្ខុរោគ មិត្តភាពកម្ពុជា-កូរ៉េ នៃមន្ទីរពេទ្យអង្គឌួង, ១៣ ឧសភា ២០១៦

... ខ្ញុំព្រះករុណាខ្ញុំ ពិតជាមានមោទនភាព ដោយសារតែអ្វីដែលបានកើតឡើងរវាងទំនាក់ទំនងកម្ពុជា-កូរ៉េ ក្នុងរយៈកាលជាងមួយទសវត្ស៍កន្លងផុតទៅនេះ បានផ្តល់នូវផ្លែផ្កាយ៉ាងច្រើនមកដល់ព្រះរាជាណាចក្រកម្ពុជា។ បញ្ហាដែលត្រូវចាទសួរនៅក្នុងបញ្ហានេះ តើ ហ៊ុន សែន ធ្វើខុស ឬធ្វើត្រូវ? នៅក្នុងដំណាក់កាលនៃការ

ចុះហត្ថលេខាលើកិច្ចព្រមព្រៀងដាក់ទំនាក់ទំនងការទូតឡើងវិញឆ្នាំ ១៩៩៦ ហើយពេលនោះ ខ្ញុំព្រះករុណាខ្ញុំ បានធ្វើទស្សនកិច្ចនៅសាធារណរដ្ឋកូរ៉េ គឺកូរ៉េខាងត្បូង បន្ទាប់ទៅ ដំឡើងដល់ថ្នាក់អគ្គរដ្ឋទូតនៅឆ្នាំ ១៩៩៧ ឥឡូវ នេះផ្លែផ្កានិងសមិទ្ធផលទំនាក់ទំនងរវាងកម្ពុជា-កូរ៉េ បានចេញជារូបរាងពិតប្រាកដហើយ។ ... ថ្លែងអំណរគុណតាមរយៈឯកឧត្តមប្រធានសភា ក៏ដូចជាប្រើយ៉ាមិត្តកូរ៉េទាំងឡាយ ដែលបានផ្តល់នូវការគាំទ្រ និងពង្រឹងនូវទំនាក់ទំនងរបស់យើង មិនគ្រាន់តែនៅក្នុងវិស័យនយោបាយតែប៉ុណ្ណោះទេ ប៉ុន្តែក៏ក្នុងផ្នែកវិនិយោគ ពាណិជ្ជកម្ម និងផ្នែកដទៃទៀត។ បើនិយាយពីប្រទេសនៅក្រៅតំបន់ គឺមានតែសាធារណរដ្ឋកូរ៉េមួយគត់ ដែលមានការហោះហើរត្រង់ច្រើនជាងគេ ចូលមកព្រះរាជាណាចក្រកម្ពុជា ...។

២៦. បើកើតមានសង្គ្រាមនៅឧបទ្វីបកូរ៉េ រាជរដ្ឋាភិបាលមានវិធានការជាក់លាក់

ពិធីបញ្ចុះខណ្ឌសីមាព្រះវិហារសិរីឧត្តម ហៅវត្តត្របែក, ស្រុកស្វាយអន្ទរ, ខេត្តព្រៃវែង, ២២ មេសា ២០១៣

... បញ្ហាសង្គ្រាមនៅកូរ៉េ។ រឿងនេះ ពេលដែលរាជរដ្ឋាភិបាលនិយាយ ក៏មានការបង្ហោះតាមហ្វេសប៊ុកវាយប្រហាររាជរដ្ឋាភិបាលថា មិនបានគិតគូរយកចិត្តទុកដាក់ ចំពោះពលរដ្ឋ និស្សិត និងអ្នកការទូតរបស់ខ្លួន ដែលធ្វើការ និងរៀនសូត្រនៅកូរ៉េខាងត្បូង។ តើរាជរដ្ឋាភិបាលធ្វើត្រឹមត្រូវ ឬមិនត្រឹមត្រូវ? បើសិនជាពេលនោះយើងជម្លៀសកម្មករ/ការិនីរបស់យើង ដែលកំពុងធ្វើការនៅកូរ៉េខាងត្បូងចេញពីប្រទេសកូរ៉េខាងត្បូង (ម្ល៉េះសមពេលនេះ)មិនចាំបាច់ទៅកទីផ្សារការងារឲ្យប្រជាពលរដ្ឋយើងនៅកូរ៉េខាងត្បូងទៀតទេ។ មិនទាន់ដឹងអីផង រត់ចោលគេទៅហើយ រឿងអីគេឲ្យទៅធ្វើការងារទៀត? អ្នកទាំងឡាយ ត្រូវចងចាំចំណុចនេះ។ នយោបាយមិនមែនចេះតែធ្វើភ្លាវ១ៗទេ ... ក្រសួងការងារក៏បានបញ្ជូនអគ្គនាយកទៅធ្វើការពិនិត្យនៅនឹងកន្លែង ហើយយើងតាមដានជាប់ អគ្គរាជទូតរបស់យើងធ្វើការតាមដានជាប់។ **ទោះបីជាសភាពការណ៍វានៅតានតឹង ក៏ប៉ុន្តែអត់វាយគ្នាទេ កុំភ័យពេក។ ខ្ញុំព្រះករុណាខ្ញុំ សូមអំពាវនាវឲ្យមានការស្ងប់ស្ងាត់ ហើយមេត្តាកុំបារម្ភចំពោះបញ្ហានេះ ព្រោះរាជរដ្ឋាភិបាលបានយកវិធានការជាក់លាក់ រួចស្រេច**

ហើយថា ត្រូវធ្វើបែបណា បើមានការកើតឡើងនូវសង្គ្រាមកូរ៉ា ...។

២៧. ដាក់ទណ្ឌកម្មរុស្សី ដូចសម្លាប់ខ្លួនឯង ហើយចំណេញដល់អាស៊ាននាំចេញទៅរុស្សី

ពិធីប្រកាសផ្សព្វផ្សាយរបាយការណ៍ជាតិ នៃលទ្ធផលចុងក្រោយជំរឿនកសិកម្ម
នៅព្រះរាជាណាចក្រកម្ពុជា, ២០ ធ្នូ ២០១៥

... នយោបាយដាក់ទណ្ឌកម្មហ្នឹង មិនមែនរុស្សីជាអ្នកខាតបង់ទេ គឺអ្នកដាក់ទណ្ឌកម្មរុស្សី ជាអ្នកខាត ... កសិករនៅអឺរ៉ុបដែលធ្លាប់លក់ដំណាំកសិកម្មឲ្យរុស្សី ទៅជាយ៉ាងម៉េច? អស់ទីផ្សារ។ អញ្ចឹងរុស្សីត្រូវបង្ខិលទិសមកដល់អាស៊ាន ជាការចាំបាច់។ អាហ្នឹងជាការដកពិសោធន៍មួយដែរ។ ដាក់ទណ្ឌកម្មគេ ត្រូវខ្លួនឯង ... ឥឡូវសួរថា កសិករដែលធ្លាប់លក់ផលិតផលទៅឲ្យរុស្សីនោះ លក់ឲ្យអ្នកណាទៀត បើរុស្សីឈប់ទិញ? អញ្ចឹងទេ ដាក់ទណ្ឌកម្មលើរុស្សី ប៉ុន្តែចំណេញអាស៊ាន ព្រោះរុស្សីបង្ខិលទីផ្សារ(ប្រពៃណី) មកបណ្តាប្រទេសក្នុងតំបន់នេះ។ (រុស្សី)មិនសុខចិត្ត នៅកន្លែងដាក់ទណ្ឌកម្មតទៅទៀតទេ។ ហ្នឹងជារឿងដែលខ្ញុំសុំនិយាយត្រង់ៗ ... រុស្សីចាំតែស្លាប់ទេតើ។ អ្នកដែលស្លាប់ពិតប្រាកដ គឺអ្នកដាក់ទណ្ឌកម្ម។ អញ្ចឹងរដ្ឋដែលដាក់ទណ្ឌកម្មគេនោះ ត្រូវផ្តត់ផ្ទង់ទៅកសិករដែលមិនអាចលក់ទំនិញបានហ្នឹង ...។

២៨. ពិភពលោកជ្រួលច្របល់, ប្រទេសខ្លះចង់ចេញពីសហភាពអឺរ៉ុប, សង្គ្រាម Ukraine

ពិធីចែកសញ្ញាបត្រ សាកលវិទ្យាល័យជាតិគ្រប់គ្រង, ២៣ ខែ កុម្ភៈ ២០១៥

... ឥឡូវពិភពលោកកំពុងជ្រួលច្របល់ ... អ្នកណាប៉ាន់ស្មានបានថា អឺរ៉ុបមានរឿងបែបហ្នឹង? សុខៗ ប្រទេសក្រិកបោះឆ្នោតកន្លងទៅ មានប្រធានបទ ២ សម្រាប់ឃោសនា ប្រធានបទមួយ គឺបក្សឈ្នះរាល់ថ្ងៃនេះថា បើឈ្នះនឹងបញ្ឈប់នយោបាយរឹតត្បិត ហើយអាចចេញពីតំបន់អឺរ៉ូ បក្សមួយទៀតនៅបន្តនយោបាយរឹតត្បិត ដល់អញ្ចឹង អាអ្នកដែលមិនរឹតត្បិតគឺឈ្នះទៅ។ ឆ្នាំ ២០១៦ នេះ មានការបោះឆ្នោតនៅអង់គ្លេស អាចជាប្រធានបទមួយធំទៀត ដែលថាអង់គ្លេសអាចចាកចេញពីសហភាពអឺរ៉ុប ... បន្ទាប់ពីសង្គ្រាមចុងក្រោយនៅ Kosovo ដែលផ្តាច់ខ្លួនចេញពីអតីត Yugoslavia ... មានសង្គ្រាមថ្មីៗនៅ Ukraine ... ប្រធានាធិបតី

Ukraine អំពាវនាវឲ្យអង្គការសហប្រជាជាតិទៅត្រួតពិនិត្យ តែបើគ្មានការអនុម័ត ពីក្រុមប្រឹក្សាសន្តិសុខ (ធ្វើ)ម៉េចនឹង(ទៅបាន)បាន ហើយបើក្រុមប្រឹក្សាសន្តិ សុខ រុស្សីគាត់វេតូតែមួយឈុចទៅ វាចប់រឿងហើយ ... បើអាមេរិកបញ្ជូនកាំភ្លើង ទៅឲ្យ Ukraine ទៀត សភាពការណ៍កាន់តែធ្ងន់ហើយ រុស្សីគាត់ធ្វើម៉េចសុខចិត្ត ... ខ្ញុំឯកភាពលើសម្តីរបស់ប្រធានាធិបតី ពូទីន ដែលថា "បើអាមេរិកបញ្ជូនកាំភ្លើង ឲ្យអ៊ុយក្រែន វាគ្មានធ្វើឲ្យសភាពការណ៍ផ្លាស់ប្តូរទេ អ្វីដែលផ្លាស់ប្តូរ (គឺ)ធ្វើឲ្យ មនុស្សងាប់ច្រើនជាងមុន" ...។

២៩. បដិវត្តន៍ពណ៌មជ្ឈិមបូព៌ា ក្រោមលេសសិទ្ធិមនុស្ស និងប្រជាធិបតេយ្យបន្សល់ទុកអ្វី

ពិធីផ្តល់រង្វាន់ដល់ជ័យលាភី កម្មវិធី ខ្ញុំជាយុវជនគំរូកម្ពុជា, ៣១ កក្កដា ២០១៦

... **រឿងធ្វើសាលាបាន ឬមិនបាន វាចំណុះលើបញ្ហាថាតើមានសន្តិភាព ឬអត់។ ចូរក្រឡេកមើលទៅមជ្ឈិមបូព៌ា បន្ទាប់ពីការជ្រៀតជ្រែករបស់ប្រទេស បង្កើតឲ្យមាន បដិវត្តពណ៌ តើនៅមជ្ឈិមបូព៌ា ពិសេសដូចជានៅ លីប៊ី, ស៊ីរី, យ៉េមែន, អេហ្ស៊ីប និងនៅអ៊ីរ៉ាក់ ផ្ទួលរំលំ សាដាម ហ៊ូសេន ដោយ អាមេរិក តើអ្នកទាំងនោះទទួល នូវសមិទ្ធផលអ៊ីទៅ? សិទ្ធិមនុស្ស និងប្រជាធិបតេយ្យនៅមជ្ឈិមបូព៌ានោះ តើ បានកើតជារូបរាងហើយឬនៅ?** បើមួយថ្ងៃ១ មនុស្សស្លាប់រាប់រយរាប់ពាន់យ៉ាង នេះ។ នេះហើយជាលទ្ធផលនៃការធ្វើនយោបាយខុស ហើយអ្នកដែលខុស គឺ អាមេរិក។ សូម្បី ដូណាល់ ត្រាំម៉ ដែលជាបេក្ខជនប្រធានាធិបតី នៃគណបក្ស សាធារណរដ្ឋ ក៏បានចេញមកអះអាងថាជាការខុសធ្ងងមួយ ដែលត្រឹមបានតែ សម្លាប់ សាដាម ហ៊ូសេន ហើយបន្ទាប់ពីហ្នឹងមក អ៊ីរ៉ាក់មិនបានសេចក្តីសុខ។ ឥឡូវទឹកដីមួយចំនួនត្រូវពួក ISIS កាន់កាប់។ វាយដណ្តើមរាប់ខែ យកកន្លែងនេះ យកកន្លែងនោះ តម្រូវឲ្យមានអន្តរាគមន៍ជើងអាកាសពីសហរដ្ឋអាមេរិក និង សម្ព័ន្ធមិត្ត។ ឥឡូវអឺរ៉ុបខ្លួនឯងកំពុងទទួលការលំបាក។ ទី ១ ពួក ISIS ចេញវាយ ដល់ប៉ារ៉ាំង ដល់អាល្លឺម៉ង់ ដល់ទួរគី ដល់ប្រទេសមួយចំនួនទៀតនៅអឺរ៉ុប ... ហើយរឿងដែលធំមួយទៀត គឺប្រជាជនរត់ចេញពីប្រទេសស៊ីរី, ពីប្រទេសលីប៊ី ឬពីប្រទេសនេះ ប្រទេសនោះ ទៅកាន់អឺរ៉ុប ...។

៣០. ត្រូវវាយតម្លៃពីបដិវត្តន៍ពណ៌ ក្រោមលេសប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស

ពិធីបើកមហាសន្និបាតលើកទី ៩ របស់សភាតំបន់អាស៊ី អេភីអេ(APA) ក្រោមប្រធានបទ «ការជំរុញសន្តិភាព និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅតំបន់អាស៊ី», ២៨ វិច្ឆិកា ២០១៦

... ខ្ញុំចង់យកឱកាសនេះ និយាយទៅកាន់លោកអ្នកថា **តើដល់ពេលដែលយើងត្រូវវាយតម្លៃពីបដិវត្តន៍ពណ៌ហើយ ឬនៅ? មកដល់ពេលនេះ អ្នកដែលបានផ្តួចផ្តើមធ្វើគំនិតបដិវត្តន៍ពណ៌ ហើយអ្នកដែលធ្លាប់អបអរសាទរនូវបដិវត្តន៍ពួនសម្ងំនៅទីណា? ទីកន្លែងដែលកើតឡើងនូវតំបន់សង្គ្រាមផ្តួលរំលំតាមកម្លាំងយោធា និងផ្តួលរំលំតាមរយៈរបស់ដែលហៅថាបដិវត្តន៍ពណ៌កំពុងតែរងនូវវិនាសកម្មយ៉ាងធ្ងន់ធ្ងរនោះ ក្រោមហេតុផលនៃលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។** ការផ្តួលរំលំរបប សាដាំ ហ៊ូសេន ការផ្តួលរំលំ បេន អាលី នៅទុយនេស៊ី, ការផ្តួលរំលំ ហ្គាដាហ្វី នៅលីប៊ី, ការផ្តួលរំលំ ហូស្នី មូបារ៉ាក់ នៅអេហ្ស៊ីប, ការប្រឆាំងនឹងរបបដែលដឹកនាំដោយប្រធានាធិបតី អាសាដ ក៏ដូចជាសង្គ្រាមដែលកំពុងផ្ទុះឡើងនៅយ៉េមែន តើអ្នកណាត្រូវទទួលខុសត្រូវ? តើដើម្បីប្តូរមនុស្សម្នាក់ និងប្តូរបុគ្គលម្នាក់ ឬក៏រដ្ឋាភិបាលមួយ នាំទៅដល់ការស្លាប់មនុស្សរាប់ម៉ឺន រាប់សែន រាប់លាននាក់បែបនេះ ឬ? តើបដិវត្តន៍ វាជាការគួរអោយជាទីស្រឡាញ់ ឬក៏ជាទីគួរអោយស្អប់ខ្ពើម? ហើយតើតុលាការឧក្រិដ្ឋកម្មអន្តរជាតិ គួរកាត់ទោសពួកមេក្លោងដែលធ្វើអោយប្រជាជនអ៊ីរ៉াক់ និងប្រជាជននៃបណ្តាប្រទេសនៃមជ្ឈិមបូព៌ា(រងទុក្ខវេទនា) ឬត្រូវពាក់មេដាយពានណូបែលអោយ?

៣១. ប្រធានាធិបតីអាមេរិកថ្មី នឹងធ្វើអោយស្រុះស្រួលរវាងរុស្ស៊ី ជាមួយនឹងសហរដ្ឋអាមេរិក

ពិធីបើកមហាសន្និបាតលើកទី ៩ របស់សភាតំបន់អាស៊ី អេភីអេ (APA) ក្រោមប្រធានបទ «ការជំរុញសន្តិភាព និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅតំបន់អាស៊ី», ២៨ វិច្ឆិកា ២០១៦

... ខ្ញុំមិនលូកលាន់ទៅលើកិច្ចការរបស់អាមេរិកនោះទេ អ្នកណាឈ្នះ គឺអ្នកហ្នឹងធ្វើជាប្រធានាធិបតី។ គឺជារឿងធម្មតា។ ពិតមែនហើយ នៅកម្ពុជា ៩៩%

ហើយ គឺគេថា ដូណាល់ ត្រាំម៍ ចាញ់។ មានតែ ហ៊ុន សែន មួយទេ ដែលនិយាយ ថា ដូណាល់ ត្រាំម៍ ឈ្នះ។ ក៏ប៉ុន្តែ អ្នកណាឈ្នះ អ្នកណាចាញ់ គឺជារឿងរបស់ ប្រជាជនអាមេរិកតែប៉ុណ្ណោះ។ យើងត្រូវទាក់ទងទាំងអស់។ **ខ្ញុំមិនបានបរិហារ វាយប្រហារទៅលើ Hillary Clinton ដូចមនុស្សមួយចំនួននោះទេ ប៉ុន្តែខ្ញុំយល់ថា នោះហើយជាពេលវេលាដ៏ល្អមួយដើម្បីធ្វើការស្រុះស្រួលរវាងរុស្ស៊ី ជាមួយនឹង សហរដ្ឋអាមេរិក ដែលក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ មានការតានតឹងយ៉ាងខ្លាំង ហើយក៏មានការព្រួយបារម្ភនៅក្នុងតំបន់របស់យើងផងដែរ។ ខ្ញុំមិនបានគាំទ្រថា អ្នកនេះត្រូវឈ្នះ អ្នកនោះត្រូវឈ្នះទេ ប៉ុន្តែសភាពការណ៍ទំនាក់ទំនងរវាងមហា អំណាចនុយក្លេអ៊ែរទាំងពីរ គឺរុស្ស៊ី និងសហរដ្ឋអាមេរិក មានការតានតឹងខ្លាំង ណាស់។ នយោបាយរបស់ ដូណាល់ ត្រាំម៍ តាមអ្វីដែលគាត់សន្យានៅក្នុងពេល បោះឆ្នោត សង្ឃឹមថា ប្រទេសមហាអំណាចនុយក្លេអ៊ែរទាំងពីរ នឹងមានការកែ សម្រួលទំនាក់ទំនងជាមួយគ្នា។** ខ្ញុំយល់ថា សំឡេងរបស់ខ្ញុំនេះ មិនបង្កើតអោយ មានការថ្នាំងថ្នាក់ពីប្រធានាធិបតីជិតចប់អាណត្តិ Barack Obama ឬក៏លោក ជំទាវ Hillary Clinton ដែលជាបេក្ខជនចាញ់ឆ្នោតទេ ...។

៣២. រដ្ឋាភិបាលថ្មីរបស់លោក ដូណាល់ ត្រាំម៍ គួរពិចារណាលុបបំណុលកម្ពុជា

ពិធីបុណ្យសមុទ្រលើកទី ៥ ក្រោមប្រធានបទ «ទីក្រុងបៃតង ផ្នែរស្អាត សមុទ្រខៀវ ស្រងាត់», ២៤ ធ្នូ ២០១៦

... តើគេត្រូវឆ្លើយតបយ៉ាងណាចំពោះអ្វីបានកើតតាំងពីពេលមុន ហើយប៉ះប៉ូវ ឲ្យកម្ពុជា។ **ខ្ញុំសង្ឃឹមថារដ្ឋាភិបាលរបស់លោក ដូណាល់ ត្រាំម៍ នឹងពិចារណាអំពី បំណុលរបស់កម្ពុជា បានជំពាក់សហរដ្ឋអាមេរិកក្នុងជំនាន់សាធារណរដ្ឋខ្មែររបស់ សេនាប្រមុខ លន់ នល់។ តើគួរត្រូវលុបចោលបំណុលនេះឬទេ? យើងខ្ញុំពិបាក នឹងពន្យល់ប្រជាជនកម្ពុជា ឲ្យទទួលស្គាល់បំណុលដែល(មេដឹកនាំពេលនោះ បាន)ទិញគ្រាប់បែក គ្រាប់កាំភ្លើងមកសម្លាប់ប្រជាជនកម្ពុជា(ខ្លួនឯង)។ សង្ឃឹម ថា រដ្ឋាភិបាលថ្មីរបស់សហរដ្ឋអាមេរិក នឹងពិចារណាដោយជិតដល់ទៅលើវិនាស កម្មដែលខ្លួនបានធ្វើនៅក្នុងប្រទេសកម្ពុជា** ... យ៉ាងហោចបំផុត លុបចោលបំណុល ដែលរបប លន់ នល់ បានជំពាក់នៅក្នុងអតីតកាល ដែលហៅថា បំណុលកខ្វក់ ...

លុប ឬមិនលុប គឺវាស្ថិតនៅក្នុងការពិចារណារបស់ប្រជាជនអាមេរិក និងការពិចារណារបស់មេដឹកនាំអាមេរិក ...។

៣៣. អ្វីដែលកើតនៅកម្ពុជា ឥឡូវវាក៏កើតនៅអាមេរិកដែរ

ពិធីពិសារបាយជួបជុំអ្នកសារព័ត៌មានក្នុងស្រុក, ១៤ មករា ២០១៧

... ពិភពលោកច្របូកច្របល់អស់ហើយ។ អ្នកដែលមានបច្ចេកវិទ្យាជាន់ខ្ពស់ មិនមែនអាមេរិកទេ។ បើ ប៉ារ៉ាក់ អូបាម៉ា គាត់ថា រុស្សុី hack ប្រព័ន្ធព័ត៌មាន(ពាក់ព័ន្ធនឹងការបោះឆ្នោត) បានសេចក្ដីថា រុស្សុីខ្លាំងជាងអាមេរិក។ ប៉ុន្មានថ្ងៃនេះ ប្រធានាធិបតី ប៉ារ៉ាក់ អូបាម៉ា ថា ចិន និងរុស្សុីមិនអាចតាមទាន់ទេ ប៉ុន្តែប៉ុន្មានថ្ងៃមុនប្រកាសថា រុស្សុីចូល hack ... អ្នកណាខ្ពស់ជាងអ្នកណាឥឡូវហ្នឹង។ ពិបាកយល់ដែរពិភពលោក។ ប៉ុន្តែណ្លើយ **រឿងអ្នកដទៃ ... អ្វីដែលមាននៅកម្ពុជាប៉ុន្មានទៅវិញហើយ "បោះឆ្នោតរួចហើយធ្វើបាតុកម្ម" ក៏ទៅកើតនៅអាមេរិកវិញ "ទាមទារអោយរាប់សន្លឹកឆ្នោតឡើងវិញ" ក៏ទៅកើតនៅអាមេរិកវិញ "បោះឆ្នោតរួចថាមានការបន្លំសន្លឹកឆ្នោត" ក៏ទៅកើតនៅអាមេរិកវិញ ... (នេះ)បានបង្ហាញថា អ្វីដែលអាមេរិកបានបង្កើតនៅកម្ពុជា ឥឡូវបាននាំទៅអាមេរិកវិញហើយ ...**។

៣៤. កុំសួរថាប្រទេសណាត្រៀមចេញពីអាស៊ាន? សួរថា ប្រទេសណានឹងចេញពីអឺរ៉ុបក្រោយពីអង់គ្លេស?

ពិធីបើកសន្និសីទលើកទី ៩ ស្ដីពីការវិនិយោគ និងពាណិជ្ជកម្ម ឆ្នាំ ២០១៧

... ក្នុងពិធីវេទិកាសេដ្ឋកិច្ចពិភពលោក នៅពេលបាយការងារមួយ មានការតាំងជាសំណួរ ដោយសាកលវិទ្យាធិការនៃសាកលវិទ្យាល័យមួយនៅខាងអឺរ៉ុប។ គាត់លើកជាសំណួរមកខ្ញុំ និងនាយករដ្ឋមន្ត្រីវៀតណាមថា **តើមានប្រទេសណាត្រៀមខ្លួនដើរចេញពីអាស៊ាន(ទេ)? ខ្ញុំថា សូមលោកកុំជាក់សំណួរថាប្រទេសណានឹងចាកចេញពីអាស៊ាន។ គួរតែជាក់ជាសំណួរថា តើប្រទេសនៅអឺរ៉ុបណា(ទៀត)ដែលនឹងចាកចេញពីអឺរ៉ុប ក្រោយពីអង់គ្លេស? ជាក់អញ្ចេះវិញបានវាត្រូវ ព្រោះអាស៊ានមិនមានបងធំទេ។ អឺរ៉ុបបានមានបងធំ។** ពួកយើងខ្ញុំសាមគ្គីគ្នា។ សំណួរហ្នឹង មិនស្របជាមួយនឹងបរិបទរបស់អាស៊ានទេ។ អ្នកណានឹងដើរចេញពីអឺរ៉ុប

ក្រោយពីអង់គ្លេសចាកចេញ? នេះជារឿងពិតៗ នៅបារាំង ប្រសិនបើកូន Le Pen ឈ្នះ ប្រហែលជាបារាំងនឹងចេញពីអឺរ៉ុបទៀត ...។

ការពារជាត

១	ផ្តោលទោសការឈ្លានពាន/ទំលាក់គ្រាប់បែក នៃសហរដ្ឋអាមេរិក	៦១
២	កងទ័ព គាំទ្ររាជរដ្ឋាភិបាលអនុវត្តការកែទំរង់ និងកំណើនសេដ្ឋកិច្ច	៦១
៣	មានផ្តាយមាសបួន តែបួននាក់បានហើយ ដើម្បីការកែទំរង់	៦២
៤	មិនអាចយកសង្គ្រាមបញ្ចប់សង្គ្រាមបានទេ	៦២
៥	សិល្ប:នៃការស្វែងរកសន្តិភាពនៅក្នុងខេត្តកំពង់ស្ពឺ ស្រុកឱ៉ាល់	៦៣
៦	ប្រវត្តិកំណើតកងរាជអាវុធហត្ថ	៦៣
៧	វិធានការណ៍ ៣ ដើម្បីសន្តិសុខផ្ទៃក្នុង	៦៤
៨	ភារកិច្ច ៣ នៃកងរាជអាវុធហត្ថ	៦៥
៩	គ្រប់សម័យកាល ប្តូរពីប្រដាប់អាវុធ ទៅចរចាការទូតដោយសន្តិវិធី	៦៥
១០	យុទ្ធសាស្ត្រទ័ព "ការអត់ធ្មត់ មិនមែនបានសេចក្តីថាចុះចាញ់ទេ"	៦៦
១១	ការពារជាតិ មិនមែនខ្លាំងដោយសញ្ញវុធ គឺខ្លាំងដោយទឹកចិត្ត	៦៦
១២	ប្រែក្លាយតំបន់សមរភូមិ ទៅជាតំបន់អភិវឌ្ឍន៍	៦៧
១៣	កត្តា ៣ បែងចែកពលកម្មសង្គម បំរើការអភិវឌ្ឍសេដ្ឋកិច្ច ការពារជាតិ	៦៧
១៤	ការសម្រេចចិត្តខាងនយោបាយត្រឹមត្រូវ និងគួរអោយមោទន:	៦៨
១៥	ចំណាត់ថ្នាក់កម្ពុជា ក្នុងការបញ្ជូនកងទ័ព ទៅក្រៅប្រទេស	៦៩
១៦	កម្ពុជា ស្ថិតក្នុងប្រព័ន្ធរៀបកម្លាំងរហ័សនៃសហប្រជាជាតិ	៦៩
១៧	បើកម្ពុជាគ្មានសន្តិភាពទេ អត់មានលទ្ធភាពបញ្ជូនកម្លាំងទៅក្រៅទេ	៧០

១. ថ្កោលទោសការឈ្លានពាន/ទំលាក់គ្រាប់បែក ពីសហរដ្ឋអាមេរិក និងវៀតណាមខាងត្បូង

ពិធីបញ្ចុះខណ្ឌសីមា ព្រះវិហារវត្តកំពង់ឫស្សី, ថ្ងៃទី ០១ មេសា ២០១៣

... ចេះតែរង់ចាំស្តាប់អ្នកនយោបាយដទៃ ក្រៅពីគណបក្សប្រជាជន និងគណបក្សហ៊ុនស៊ីនប៊ិច ព្រោះគណបក្សហ៊ុនស៊ីនប៊ិច ជាគណបក្សដែលមានព្រះរាជបុត្ររបស់ សម្តេចព្រះនរោត្តម សីហនុ ដឹកនាំថា តើគេហ៊ានថ្កោលទោសអ្នកធ្វើរដ្ឋប្រហារថ្ងៃទី ១៨ មីនា ឆ្នាំ ១៩៧០ ទម្លាក់ សម្តេចព្រះនរោត្តម សីហនុ ទេ? គណបក្ស ២ នេះ ជាគណបក្សដែលហ៊ានថ្កោលទោសការធ្វើរដ្ឋប្រហាររបស់ពួកលន់ នល់ ទម្លាក់ សម្តេច ព្រះនរោត្តម សីហនុ (ដែលនាំអោយ) បង្កើតឡើងនូវសង្គ្រាម។ ហើយក៏**មានតែគណបក្សប្រជាជន ដែលហ៊ានថ្កោលទោសការទម្លាក់គ្រាប់បែក ការឈ្លានពានពីសំណាក់សហរដ្ឋអាមេរិក និងវៀតណាមខាងត្បូងលើទឹកដីកម្ពុជា។ រដ្ឋប្រហារ ១៨ មីនា ឆ្នាំ ១៩៧០ (បាននាំអោយ) សម្តេច ព្រះនរោត្តម សីហនុ បង្កើតឡើងនូវណសិរ្ស្ជរួមជាតិកម្ពុជា ហើយអំពាវនាវឱ្យកូនចៅទាំងឡាយរត់ចូលព្រៃម៉ាគី ដើម្បីធ្វើការតស៊ូប្រឆាំងនឹងការឈ្លានពានរបស់**ហ**ទេស** ... អ្នកខ្លះមិនហ៊ាននិយាយពីប្រវត្តិសាស្ត្រទាក់ទងនឹងការខ្ជាចផ្សារ របស់ប្រជាពលរដ្ឋកម្ពុជាទេ ...។

២. កងទ័ព គាំទ្ររាជរដ្ឋាភិបាល ក្នុងការអនុវត្តការកែទំរង់ និងកំណើនសេដ្ឋកិច្ច

ពិធីស្វាគមន៍ការចូលកាន់តំណែងសហរដ្ឋមន្ត្រីការពារជាតិ, ១៧ កក្កដា ២០០៤

... សូមអនុញ្ញាតអោយខ្ញុំបានសំដែងនូវការអរគុណចំពោះគ្រប់អង្គភាពក្រោមឱ្យាតក្រសួងការពារជាតិ និងពិសេស ការអរគុណយ៉ាងកក់ក្តៅចំពោះនាយ និងនាយរងសេនាធិការនៃកងកម្លាំងប្រដាប់អាវុធទាំង ៣ ប្រភេទ ដែលបាន**ប្រឹងប្រែងជំនះគ្រប់ការលំបាក ក្នុងពេលដែលប្រទេសកំពុងមានធនធានមានកម្រិត។ ការប្រឹងប្រែង បានក្លាយជាចលនាមួយយ៉ាងសំខាន់គាំទ្រដល់ការអនុវត្តការកែទំរង់និងកំណើនសេដ្ឋកិច្ចនៃរាជរដ្ឋាភិបាល។ ក្នុងការវិវឌ្ឍថ្មីៗ នេះ យើងអាចនឹងរៀបរាប់ពីការរួមចំណែករបស់កងកម្លាំងប្រដាប់អាវុធ ក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចតាមរយៈការរួមចំណែកសាងសង់ផ្លូវ ស្ពាន ជាដើម។ ក្នុងពេលមានគ្រោះទឹក**

ជំនន់ កងទ័ពបានចូលរួមយ៉ាងសកម្ម ក្នុងការប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីសង្គ្រោះជីវិត និងទ្រព្យសម្បត្តិរបស់ប្រជាជនយើង។ សូមបន្ថែមដែរថា កងរាជអាវុធហត្ថ ក៏បានធ្វើសហប្រតិបត្តិការយ៉ាងសកម្ម ជាមួយកម្លាំងប៉ូលីសជាតិ ដើម្បីរាំងស្កាត់ឧក្រិដ្ឋកម្មនានា ...។

៣. មានផ្កាយមាសបួន តែបួននាក់បានហើយ ដើម្បីការកែទំរង់

ពិធីស្វាគមន៍ការចូលកាន់តំណែងសហរដ្ឋមន្ត្រីការពារជាតិ, ១៧ កក្កដា ២០០៤

... និយាយពីយុទ្ធសាស្ត្រចតុកោណ ការកែទំរង់ក្នុងវិស័យការពារជាតិជាការសំខាន់។ ក្រសួងការពារជាតិ និងកម្លាំងប្រដាប់អាវុធ មានតួនាទីធំធេងក្នុងគោលដៅនៃការកែទំរង់ទាំងឡាយរបស់រាជរដ្ឋាភិបាល ពិសេសក្នុងការការពារឯករាជជាតិ អធិបតេយ្យ និងបូរណភាពដែនដី។ នៅក្នុងអាណត្តិនេះ **ខ្ញុំគិតថា យើងគួរតែមានត្រឹមឧត្តមសេនីយ៍ផ្កាយមាសបួន បួននាក់បានហើយ គឺ ពីរនាក់ជាសហរដ្ឋមន្ត្រីការពារជាតិ ... ដោយសារយើងមានអតិផរណាសក្តិ និងដើម្បីការងារកែទំរង់ យើងត្រូវតែសម្រុតខ្លួនឯងម្នាក់មួយសក្តិ ពីផ្កាយមាសប្រាំមកនៅត្រឹមឧត្តមសេនីយ៍ផ្កាយមាសបួន**...។

៤. មិនអាចយកសង្គ្រាមបញ្ចប់សង្គ្រាមបានទេ

ពិធីសម្ពោធសមិទ្ធផលនានា ក្រុងប៉ៃលិន, ថ្ងៃទី ០៣ មករា ២០១៣

... ឥឡូវ អ្នកប៉ៃលិនខ្លួនឯងបានឃើញហើយ នូវសមិទ្ធផលទាំងឡាយដែលបានកើត។ ខ្ញុំធ្លាប់មកប៉ៃលិនមុនចូលឆ្នាំខ្មែរ ឆ្នាំ ១៩៩៤។ ពេលហ្នឹងកងទ័ពរបស់រាជរដ្ឋាភិបាល បានវ៉ៃចូលប៉ៃលិន។ ខ្ញុំមកឈរនៅម្តុំក្បែរៗហ្នឹង មកធ្វើសេចក្តីថ្លែងការណ៍។ ដល់ពេលឯងទៅដល់ភ្នំពេញវិញ អ៊ី ឈាន វ៉ៃចូលវិញបាត់ ... កាលពីដើមខាងនេះ ហៅខាងនោះថាអាយ៉ងយួន ខាងនោះហៅខាងនេះថាខ្មែរក្រហម។ ខ្មែរ និងខ្មែរសោះ បង្កើតជារឿង។ មានខ្មែរក្រហម ខ្មែរស ខ្មែរខៀវ ខ្មែរស៊ីជម្ពូ ខ្មែររដ្ឋាភិបាល។ វ៉ៃគ្នាអត់ឈប់។ **ខ្ញុំព្រះករុណាខ្ញុំ មើលឃើញច្បាស់ហើយថា តាំងពីការចាប់ផ្តើមធ្វើរដ្ឋមន្ត្រីការបរទេស បន្ទាប់ទៅធ្វើជានាយករដ្ឋមន្ត្រី ខ្ញុំព្រះករុណាខ្ញុំ មិនដែលជឿថា ត្រូវយកសង្គ្រាមដើម្បីបញ្ចប់សង្គ្រាមបានទេ។ អញ្ចឹង** បានជា

ត្រូវរកផ្លូវចរចាសន្តិភាព ដែលជំហានដំបូងនៅថ្ងៃទី ០២ ខែធ្នូ ឆ្នាំ ១៩៨៩ នៅហ្វ្រេ អង់តាដ៏ន័រ ជាមួយ សម្តេច ព្រះនរោត្តម សីហនុ ព្រះរាជបិតាជាតិខ្មែរ ដែលឥឡូវ ព្រះបរមនាមជា ព្រះបរមរតនកោដ្ឋ។ បន្តមកទៀត គឺការសាកល្បងនៅឯ ឌ៉ាល់ នូវនយោបាយឈ្នះ-ឈ្នះ ព្រឹញ្ចានសភាពការណ៍មកដល់ទីនេះ ...។

៥. សិល្ប:នៃការស្វែងរកសន្តិភាពនៅក្នុងខេត្តកំពង់ស្ពឺ ស្រុកឌ៉ាល់

ពិធីសម្ពោធផ្លូវជាតិលេខ ៤៤ រវាងច្បារមន ឌ៉ាល់ អមលាំង ឧត្តុង្គ ទៅ ផ្លូវជាតិលេខ ៥, ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៦

... តើត្រូវធ្វើវិធីយ៉ាងណា ដើម្បីបញ្ចប់សង្គ្រាមនៃតំបន់មួយ ដែលធ្លាប់តែជាតំបន់ប្រយុទ្ធស៊ីសាច់ហុតឈាម ពិសេស គឺនៅស្រុកឌ៉ាល់ដែលតភ្ជាប់តាមផ្លូវរបស់យើងនេះ មិនគួរត្រូវបានលាក់លៀមតទៅទៀតទេ។ និយាយពីសារបានប្រវត្តិតំបន់ឌ៉ាល់ រលាក់កងជើងអីនេះ គឺជាតំបន់ដែលរដ្ឋាភិបាលមុនៗ មិនអាចគ្រប់គ្រងបានទេ រាប់ទាំងរដ្ឋាភិបាលជំនាន់បារាំង រាប់ទាំងជប៉ុនចូលស្រុកខ្មែរ និងបន្តបន្ទាប់មកទៀត។ ឌ៉ាល់ គឺជាតំបន់ជ្រកកោន ដែលតភ្ជាប់រវាងរលាក់កងជើងរហូតតភ្ជាប់ទៅសំឡូតឯណោះ ... យើងទាក់ថ្ពក់បាន កែវ ពង្ស ដែលមានបំណងក្នុងការចូលរួមជាមួយរាជរដ្ឋាភិបាល ... ខ្ញុំព្រះករុណាខ្ញុំ ត្រូវនិយាយឲ្យបានដឹងថា **ការគិតខុសតែបន្តិច សន្តិភាពនឹងមិនអាចកើតមាន ប៉ុន្តែបើយើងគិតត្រូវ យើងនឹងទទួលបានផលធំ។ ន័យដូចគ្នានេះ ខ្ញុំព្រះករុណាខ្ញុំ បាននិយាយប្រាប់ទៅដល់ម្តាយ និងម្តាយធំ ដែលគាត់បាននិយាយមកកាន់ខ្ញុំថា: ហ្អែង! ចូលទៅក្នុងតំបន់ខ្មែរក្រហម មិនខ្លាចគេសម្លាប់ទេអី? ខ្ញុំព្រះករុណាខ្ញុំ បានឆ្លើយតបជាមួយគាត់ថា ម៉ែ! ធំ! បើសិនជាស្លាប់ (គឺ)ស្លាប់តែខ្ញុំម្នាក់ និងអ្នកអមដំណើរខ្ញុំតែប៉ុណ្ណោះ ប៉ុន្តែ បើបានត្រឡប់មកវិញ គឺផែនដីទាំងមូលតែម្តង ...។**

៦. ប្រវត្តិកំណើតកងរាជអាវុធហត្ថ

ពិធីសម្ពោធអគារ និងសមិទ្ធផល របស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ទួលគោក, រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កក្កដា ២០១៦

... យើងពិតជាបានដឹងពីប្រវត្តិនៃកងរាជអាវុធហត្ថ ឆ្លងពីដំណាក់កាលមួយ មកកាន់ដំណាក់កាលមួយ លើកលែងតែក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត ប៉ុណ្ណោះ ដែលពុំមានកងរាជអាវុធហត្ថលើផ្ទៃប្រទេសនោះទេ។ **នៅក្នុងសម័យសង្គមរាស្ត្រនិយម ក៏មានត្រឹមតែគេហៅថា តម្រួតយោធា ... នៅក្នុងរបបសាធារណរដ្ឋខ្មែរក៏ដូចគ្នា ហើយមកដល់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា ក៏យើងមានត្រឹមក្របខណ្ឌតម្រួតយោធា ធ្វើការកិច្ចត្រឹមតែតម្រួតយោធាតែប៉ុណ្ណោះ។ និយាយដល់ការចាប់កំណើតរបស់កងរាជអាវុធហត្ថ នៅទីនេះ យើងគួររំលឹកដល់ ឯកឧត្តម ស ក្ដិ ស៊ីតសាខន ពេលនោះជាទីប្រឹក្សារដ្ឋាភិបាល ហើយក៏បានជួយព្រៀងឡើងនូវព្រះរាជក្រឹត្យ ទាក់ទិនជាមួយនឹងការបង្កើតឡើងនូវកងរាជអាវុធហត្ថលើផ្ទៃប្រទេស** ... ការបង្កើតឡើងនូវកងរាជអាវុធហត្ថនេះ បានឆ្លងកាត់មេបញ្ជាការ តាំងពីឧត្តមសេនីយ៍ កែវ សាមួន ដែលឥឡូវនេះ គាត់មរណកាលទៅហើយ មុនគាត់ទៅកាន់យោធភូមិភាគទី ៣ បន្ទាប់មក ឧត្តមសេនីយ៍ គៀង សាវុធ ហើយបន្តទៅ គឺនាយឧត្តមសេនីយ សៅ សុខា។ បច្ចុប្បន្ននេះ មានការរីកចម្រើន គួរឲ្យកត់សម្គាល់ ...។

៧. វិធានការ ៣ ដើម្បីសន្តិសុខផ្ទៃក្នុង

ពិធីសម្ពោធអគារ និងសមិទ្ធផល របស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស, ទួលគោក, រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កក្កដា ២០១៦

... នេះជាដំណាក់កាលដែលយើងត្រូវចាត់វិធានការប្រឆាំងនឹងបទឧក្រិដ្ឋនានា ព្រោះថាមួយរយៈចុងក្រោយនេះ ពិតមែនតែក្នុងក្របខណ្ឌនៃទំនាក់ទំនងតាមបណ្ដាព្រំដែនជាមួយប្រទេសជិតខាងមានសុវត្ថិភាពល្អ ប៉ុន្តែសន្តិសុខនៅខាងផ្ទៃក្នុងរបស់យើងមានបញ្ហា។ ជួនកាលប៉ះទៅលើពលរដ្ឋស្លូតត្រង់ ឥឡូវប៉ះទៅដល់អ្នកនយោបាយ ប៉ះទៅដល់អ្នកធ្វើធុរកិច្ច ហើយរហូតប៉ះទៅដល់សមត្ថកិច្ច ... ទាមទារនូវការបើកយុទ្ធនាការទ្រង់ទ្រាយធំមួយ ដើម្បីពង្រឹងនូវសន្តិសុខរបស់យើងឡើងវិញ។ **ទីមួយ ទាមទារការចាត់វិធានការប្រឆាំងនឹងឃាតកម្ម ការប្លន់ប្រដាប់អាវុធ និងត្រូវការពារប្រជាជនគ្រប់រូប មិនថាអ្នកនយោបាយ ឬជាធុរជន ឬប្រជាជននោះទេ ... ទីពីរ គ្រឿងញៀនជាបញ្ហាកាន់តែធ្ងន់ធ្ងរទៅ។ ទាមទារអោយមាន**

ការចូលរួមពីគ្រប់មជ្ឈដ្ឋាន។ ប្រទេសរបស់យើងមិនមែនជាប្រទេសផលិតគ្រឿងញៀននោះទេ ជាប្រទេស(ដែលគ្រឿងញៀន)ឆ្លងកាត់ ... ឥឡូវនេះ វាមិនមែនគ្រាន់តែជាប្រទេសឆ្លងកាត់ទេ ប៉ុន្តែជាទីផ្សារនៃការប្រើប្រាស់គ្រឿងញៀនទៅហើយ។ **យើងត្រូវតែខិតខំរួមទាំងអស់គ្នា មិនអាចត្រឹមតែកងនគរបាលជាតិ និងកងរាជអាវុធហត្ថនោះទេ ប៉ុន្តែត្រូវមានការចូលរួមពីគ្រប់តួអង្គ ជាពិសេសគឺប្រជាពលរដ្ឋខ្លួនឯង ... ទី ៣ គ្រប់គ្រងអាវុធជាតិផ្ទុះអោយម៉ត់ចត់ ... ត្រូវរកវិធីកុំឲ្យអាវុធអាចធ្វើចរាចរឆ្លងកាត់ក្នុងប្រទេស ...**។

៨. ភារកិច្ច ៣ នៃកងរាជអាវុធហត្ថ

ពិធីសម្ពោធអគារ និងសមិទ្ធផល របស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស, ទួលគោក, រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កក្កដា ២០១៦

... អបអរការរីកលូតលាស់នៃកម្លាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស ដែលមានអាយុកាល ២៣ ឆ្នាំ ... សង្ឃឹមថា ប្រតិបត្តិការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ ទទួលនូវបទបញ្ជាពីរាជរដ្ឋាភិបាល ការដឹកនាំ(ពី)មេបញ្ជាការរបស់ខ្លួន ប្រតិបត្តិការ(ប្រឆាំង)ឧក្រិដ្ឋកម្មព្រៃឈើ ... សង្ឃឹមថា កងរាជអាវុធហត្ថដែលមានវត្តមាននៅទីនេះក្តី និងកងរាជអាវុធហត្ថនៅទូទាំងប្រទេស សហការជាមួយនឹងស្ថាប័នពាក់ព័ន្ធ ស្របតាម**តួនាទីការកិច្ចរបស់ខ្លួន ៣ សំខាន់ គឺទី ១ ជាតម្រួតយោធាដែលមានចែងនៅក្នុងអនុក្រិត្យ ទី ២ ផ្នែកសណ្តាប់ធ្នាប់សាធារណៈ ជាកងជំនួយឲ្យនគរបាលជាតិរបស់យើង និងទី ៣ ដើរតួនាទីជានគរបាលយុត្តិធម៌ ដើម្បីបម្រើទៅឲ្យផ្នែកតុលាការ ...**។

៩. ពីសម័យកាលមួយទៅមួយ ប្តូររូបភាពពីប្រដាប់អាវុធ ទៅចរចាការទូតដោយសន្តិវិធី

ពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី ២០ នៃថ្ងៃកំណើតកងពលតូចលេង ៧០, ថ្ងៃទី ១៣ តុលា ២០១៤

... **កងទ័ពកម្ពុជា ខិតខំរៀនសូត្រចំណេះដឹង បំប៉ងជំនាញជាប់លាប់ ក្នុងន័យលើកកម្ពស់សមត្ថភាព ធ្វើឲ្យកងទ័ពយើងពោរពេញដោយជំនាញ សមត្ថភាព និងពិសោធន៍ការងារយ៉ាងពេញលេញ ...** កងទ័ពកម្ពុជាត្រូវបន្តដឹកនាំអនុវត្ត រៀន

សូត្រ ស្វែងយល់ ដោះស្រាយ និងដកស្រង់បទពិសោធពីសភាពការណ៍ដែលវិវឌ្ឍគ្មានទីបញ្ចប់ ទើបអាចទទួលបានជោគជ័យលើសមរភូមិយោធា ការទូត និងការរួមចំណែកអភិវឌ្ឍសង្គមសេដ្ឋកិច្ចជាតិ ... **ពីសម័យកាលមួយទៅកាន់សម័យកាលមួយតែងតែមានការផ្លាស់ប្តូររូបភាពយុទ្ធសាស្ត្រ និងយុទ្ធវិធីពីការប្រើប្រាស់កម្លាំងប្រដាប់អាវុធ ទៅការចរចាការទូតដោយសន្តិវិធី ពីសង្គ្រាមដោយអាវុធទៅសង្គ្រាមកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាដើម ...**។

១០. យុទ្ធសាស្ត្រទ័ព "ការអត់ធ្មត់ មិនមែនបានសេចក្តីថាចុះចាញ់ទេ"

ពិធីបិទសិក្ខាសាលាបូកសរុបការងារកែទម្រង់កងយោធពលខេមរភូមិន្ទ ៥ ឆ្នាំ (២០១០-២០១៤) និងទិសដៅអនុវត្ត ៥ ឆ្នាំ (២០១៥-២០១៩), ថ្ងៃទី ០៤ មីនា ២០១៥

... ប្រហែលជានៅក្នុងជួរនាយទាហានយើង បានកត់ត្រាហើយ, ថ្ងៃដែលមិនឱ្យវ៉ៃ(តបជាមួយទាហានថៃ) ឱ្យតម ១០០ ម៉ោងជាងនោះ ខ្ញុំគិតថា មេបញ្ជាការទាំងអស់ពិតជាខឹងខ្ញុំ (និងឆ្ងល់ថា)ម៉េចបានមិនឱ្យតបតទាល់តែសោះ។ **តបត លឿនពេកមិនល្អទេ។ យើងខ្វះធនធ្ន:។ អញ្ចឹងឱ្យវ៉ៃជាង ១០០ ម៉ោង។ ដល់(តែយើង)បកវិញត្រឹម ១៧ នាទី គឺថា អាចចរចាបានហើយ។ នេះជាយុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រកងទ័ព។ ត្រូវចាំ។ ... ការអត់ធ្មត់ មិនមែនបានសេចក្តីថាជាការចុះចាញ់នោះទេ** ... យុទ្ធជនរបស់យើងមួយចំនួនមិនសប្បាយចិត្តក្នុងកាល:ទេស:នោះ ប៉ុន្តែដល់ទៅផ្ទុ:ព្រឹប កងទ័ពយល់។ អត់មានការស្តីបន្ទោសឱ្យខ្ញុំទេ ...។

១១. ខឿនការពារជាតិ មិនមែនខ្លាំងដោយសញ្ញវុធ គឺខ្លាំងដោយទឹកចិត្ត

ពិធីសម្ពោធទីបញ្ជាការវរសេនាតូចលេខ ៤២២, ថ្ងៃទី ០៨ កុម្ភ: ២០១០

... អរគុណចំពោះសប្បុរសជននានា ដែលបានជួយកសាងទីតាំង បន្ថែមទៅដោយការមកសួរសុខទុក្ខជាច្រើនលើកច្រើនសានៃបណ្តាខេត្ត បណ្តាស្ថាប័ននិងសប្បុរសជននានា ... **ខ្ញុំបាននិយាយហើយ ទាក់ទងនឹងនយោបាយខឿនការពារជាតិរបស់ប្រជាជនដែលបានផ្សារភ្ជាប់រវាងខាងក្រោយ និងខាងមុខ។ សប្បុរសជន**

ជាច្រើនបានធ្វើដំណើរមកកាន់ទីនេះ និងរហូតទៅដល់ខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ។ កម្លាំងការពារជាតិរបស់យើងពិតជាខ្លាំង មិនមែនខ្លាំងដោយសញ្ញារុំធនោះទេ គឺខ្លាំងដោយទឹកចិត្តស្នេហាជាតិ ស្នេហាប្រជាជន ស្នេហាទឹកដី។ ព្រះមហាក្សត្រជាទីសក្តារបស់យើង សម្តេចព្រះរាជបិតាជាតិខ្មែរ និងសម្តេចព្រះមហាក្សត្រីព្រះវររាជជាតិខ្មែរ ព្រះអង្គមិនដែលភ្លេចនៅក្នុងការគិតគូរមកដល់កងទ័ព និងប្រជាជននៅតាមព្រំដែននោះទេ ...។

១២. ប្រែក្លាយតំបន់សមរភូមិ ទៅជាតំបន់អភិវឌ្ឍន៍

សិក្ខាសាលា បូកសរុបការងារកែទម្រង់ កងយោធពលខេមរភូមិន្ទ ៥ ឆ្នាំ (២០១០-១៤) និងទិសដៅអនុវត្ត ៥ ឆ្នាំ (២០១៥-១៩), ថ្ងៃ ០៤ មីនា ២០១៥

... ទាក់ទិនជាមួយនឹងបញ្ហាមូលដ្ឋានទីតាំង កុំជ្រុលនិយមហួស។ កន្លងទៅ ក៏មានការលើកឡើងអំពីបញ្ហាថា លោក ហ៊ុន សែន កំពុងតែលុបលេណដ្ឋានយុទ្ធសាស្ត្រ។ បានខ្ញុំសួរត្រឡប់ទៅវិញថា ស្អីទៅមូលដ្ឋានយុទ្ធសាស្ត្រ? ឃ្លាតពីព្រំដែនត្រឹមតែ ២០០ ម៉ែត្រ? ខ្ញុំមិនថាកន្លែងណាៗ ទេ ... សូមបញ្ជាក់ពីដើមលេណដ្ឋានរបស់យើងនៅពេញមួយប្រទេសហ្នឹង រាប់ទាំងភ្នំពេញ ក៏សុទ្ធតែលេណដ្ឋានដែរ។ ឥឡូវខ្ញុំលុបចោល កសាងសណ្ឋាគារទៅ វាមិនល្អ? កសាងផ្ទះទៅ ធ្វើជាកន្លែងដាំដុះទៅ។ ពិតហើយ នៅកន្លែងកងទ័ព បើគ្មានលេណដ្ឋាន គេមិនហៅថាទីតាំងកងទ័ពទេ។ ឯនៅតាមទល់ដែន កន្លែងណាដែលអាចធ្វើបាន គឺលុបលេណដ្ឋាន ... **ខ្ញុំបានដាក់ចេញនូវគោលការណ៍ ដោយប្រែក្លាយអតីតតំបន់ប្រយុទ្ធឱ្យទៅជាតំបន់អភិវឌ្ឍន៍, ប្រែក្លាយតំបន់ព្រំដែនទាំងអស់ ឱ្យទៅជាព្រំដែន សន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ ក្តាប់អាហ្នឹងឱ្យជាប់ ... យើងមិនមែនធ្វើតែការប្រយុទ្ធដោយទ័ពសុទ្ធទេ ត្រូវចេះធ្វើនយោបាយផង ... បើគេគ្មានចេតនាអាក្រក់ជាមួយយើងៗ ក៏មានមិត្តភាព ...។**

១៣. កត្តា ៣ បែងចែកពលកម្មសង្គម បម្រើការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ការពារជាតិ

ពិធីផ្សាព្វផ្សាយលទ្ធផលចុងក្រោយ នៃការជំរឿនប្រជារាស្ត្រ ២០០៨, ថ្ងៃទី ០៧ កញ្ញា ២០០៩

... ខ្ញុំបាននិយាយទុកជូចទៅហើយ ២០ ឆ្នាំមុននោះ គឺការបែងចែកពលកម្ម សង្គមឡើងវិញ ដើម្បីបំរើគោលដៅ អភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ព្រមទាំងវិស័យការពារជាតិ។ ពីមុន យើងខ្វះលទ្ធភាពធ្វើ។ ឥឡូវយើងមាន **ទី ១ សន្តិភាពគ្របដណ្ដប់នៅទូទាំងប្រទេស ទី ២ ប្រជាជនសាមគ្គីគ្នា មិនមានការសងសឹក មិនបែងចែកតំបន់និយម ទី ៣ ហេដ្ឋារចនាសម្ព័ន្ធរបស់យើងកាន់តែប្រសើរ** ... ហេដ្ឋារចនាសម្ព័ន្ធ សន្តិសុខល្អ យើងប្រែក្លាយតំបន់ប្រយុទ្ធ ទៅជាតំបន់មានការអភិវឌ្ឍវិញ ... ពង្រាយប្រជាជន ជាបឋម គ្រួសារកងទ័ព ត្រូវដោះស្រាយឲ្យពួកគាត់ បើតំបន់ប៉ៃលិន ភ្នំព្រឹក្ស សំពៅលូន គឺសំបើមណាស់ ... យើងមានប្រជាជននៅទីនោះ កាត់បន្ថយសម្ពាធប្រជាពលរដ្ឋនៅខាងក្រោម។ គ្រាន់តែបញ្ហាបែងចែកលំនៅដ្ឋាន តើបាត់ដំបងដីធ្លីបង្ករបង្កើនផលប៉ុន្មាន ការបំបែកគ្រួសារពីឆ្នាំ ១៩៩៨ ដល់ ២០០៨ មាន ៣០ ម៉ឺនគ្រួសារ ...។

១៤. ការសម្រេចចិត្តខាងនយោបាយត្រឹមត្រូវ និងគួរអោយមោទនៈ

> សន្និបាតបូកសរុប ការងារបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាព របស់អង្គការសហប្រជាជាតិ រយៈពេល ១០ ឆ្នាំ (២០០៦-១៦), ០១ មីនា ឆ្នាំ ២០១៦

... ប្រវត្តិជីវិតនយោបាយរបស់ខ្ញុំ ពិតជាបានសម្រេចចិត្តលើបញ្ហាធំៗ ជាច្រើនតាំងពីការចាប់ផ្ដើមធ្វើសកម្មភាពវាយផ្ដួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត និងជាបន្តបន្ទាប់ ធ្វើការសម្រេចចិត្ត ពាក់ព័ន្ធជាមួយនឹងសង្គ្រាម ឬសន្តិភាព។ ការសម្រេចចិត្ត ទទួលយកអង្គការសហប្រជាជាតិ ចូលប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា មិនមែនជាបញ្ហាងាយស្រួលទេ នៅក្នុងកាលៈទេសៈពេលនោះ ... **ក្រោយមកយើងត្រូវធ្វើការសម្រេចចិត្តមួយទៀត ដែលមិនមែនជាការងាយស្រួលនោះ នៅត្រង់ថា កម្ពុជាខ្លួនឯងកំពុងតែលំបាក ប៉ុន្តែបែរជាហ៊ានបញ្ជូនកងទ័ពទៅក្រៅប្រទេស ... ក្នុងនាមជារដ្ឋអធិបតេយ្យ ជាសមាជិកអង្គការសហប្រជាជាតិ ឆ្លើយតបនឹងការអំពាវនាវនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលត្រូវការកម្លាំងដោះមីន ចូលរួមប្រតិបត្តិការការក្សាសន្តិភាព** ... ថ្ងៃទី ១ មីនា នេះ គឺជាថ្ងៃដែលខ្ញុំធ្វើការសម្រេចចិត្ត (ដែល)នាយករដ្ឋមន្ត្រីត្រូវទទួលខុសត្រូវចំពោះប្រវត្តិសាស្ត្ររបស់ប្រទេសជាតិ ...។

១៥. ចំណាត់ថ្នាក់កម្ពុជា ក្នុងការបញ្ជូនកងទ័ព ទៅក្រៅប្រទេស

សិក្ខាសាលាបូកសរុប ការងារកែទម្រង់ កងយោធពលខេមរភូមិន្ទ ៥ ឆ្នាំ (២០១០-១៤) និងទិសដៅអនុវត្ត ៥ ឆ្នាំ (២០១៥-១៩), ថ្ងៃ ០៤ មីនា ២០១៥

... ការវាយតម្លៃចំណាត់ថ្នាក់កងទ័ព ដែលយើងបញ្ជូនចេញទៅក្រៅប្រទេស យើងជាប់ចំណាត់ថ្នាក់លេខ ៣៦ ក្នុងចំណោមប្រទេស ១២២ ដែលបញ្ជូនកងទ័ពចេញទៅក្រៅ, ប្រទេសបង់ក្លាដេស ជាប់ចំណាត់ថ្នាក់លេខមួយ ដែលបានបញ្ជូនកម្លាំងចេញទៅក្រៅប្រទេសច្រើនជាងគេ។ បន្ទាប់ទៅឥណ្ឌា, បន្ទាប់ទៀត ប៉ាគីស្តង់ បើក្នុងចំណោមអាស៊ាន អ្នកលេខ ១ គឺ ប្រទេសឥណ្ឌូនេស៊ី, លេខ ២ ម៉ាឡេស៊ី, លេខ ៣ កម្ពុជា, លេខ ៤ ថៃ, លេខ ៥ ហ្វីលីពីន, លេខ ៦ វៀតណាម, លេខ ៧ ប្រ៊ុយណេ។ ប៉ុន្តែ ក្នុងហ្នឹង **គេមានការបែងចែកមួយទៀត គឺផ្នែក យេនឌ័រ។ ក្នុងចំណោមប្រទេសក្នុងអាស៊ាន គឺយើងលេខមួយ ដោយសារយើងបានបញ្ជូនស្ត្រីទៅក្នុងប្រតិបត្តិការរក្សាសន្តិភាពបានច្រើនជាងគេ ហ្នឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ បាន គីមូន បានស្នើថា ធ្វើម៉េចឱ្យកម្ពុជាបញ្ជូនជាស្ត្រី ឱ្យបានច្រើន ក្នុងហ្នឹងគាត់ចង់បានផ្នែកអាវុធហត្ថជាស្ត្រី ...**។

១៦. កម្ពុជា ស្ថិតក្នុងប្រព័ន្ធរៀបកម្លាំងរហ័សនៃសហប្រជាជាតិ

សិក្ខាសាលាបូកសរុប ការងារកែទម្រង់ កងយោធពលខេមរភូមិន្ទ ៥ ឆ្នាំ (២០១០-១៤) និងទិសដៅអនុវត្ត ៥ ឆ្នាំ (២០១៥-១៩), ថ្ងៃ ០៤ មីនា ២០១៥

... ខ្ញុំពិតជាមានមហិច្ឆតាធំណាស់។ ខ្ញុំ**មានផែនការពង្រីកកម្លាំងបញ្ជូនទៅក្រៅប្រទេស។ កម្ពុជាកំពុងស្ថិតក្នុងប្រព័ន្ធរបស់អង្គការសហប្រជាជាតិ ក្នុងការរៀបកម្លាំងរហ័ស។ យើងនឹងពិនិត្យបន្ត ក្នុងការចូលរួមចំណែកប្រតិបត្តិការទៅក្នុងប្រទេសមួយចំនួនទៀត ពេលមានសំណូមពរអង្គការសហប្រជាជាតិ។ មិត្តភក្តិបានជួយដល់យើង យើងក៏ជួយទៅដល់មិត្តភក្តិវិញ។ ពិតមែនថា កម្ពុជាក្រ ប្រាក់កាស ក៏ប៉ុន្តែយើងខ្ញុំមិនក្រផ្លូវចិត្តទេ។** ជួបនាយករដ្ឋមន្ត្រីបារាំង ដែលមកកម្ពុជាចំនួនពីរគឺ Jean-Marc Ayrault និង Francois Fillon ក៏ដូចពេលជួបប្រធានាធិបតីបារាំង (លោក) ហូឡង់ នៅ អ៊ីតាលី និងទស្សនកិច្ចកន្លងទៅ ខ្ញុំក៏បានស្នើ

ឲ្យបារាំងបង្កើនការយកចិត្តទុកដាក់សហការខាងព័ត៌មាន ... ដើម្បីបញ្ចៀសគ្រោះថ្នាក់សម្រាប់កម្លាំងរបស់យើង និងពង្រឹងកិច្ចសហប្រតិបត្តិការដែលអាចធ្វើទៅបាន ... ខ្ញុំក៏ធ្លាប់ធ្វើការងារនេះ ជាមួយនាយករដ្ឋមន្ត្រីឥណ្ឌា ដែលនៅឯស៊ូដង់ខាងត្បូង កម្លាំងរបស់យើងបោះ(ជំរំ)មិនឆ្ងាយពីកងទ័ពឥណ្ឌា ហើយបានផលិតទឹកស្អាតចែកចាយជាមួយនឹងកងទ័ពឥណ្ឌា ...។

១៧. បើកម្ពុជាខ្លួនឯងអត់មានសន្តិភាពទេ អត់មានលទ្ធភាពបញ្ជូនកម្លាំងទៅក្រៅទេ

> សន្និបាតបូកសរុបការងារបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ រយៈពេល ១០ ឆ្នាំ, ថ្ងៃទី ០១ មីនា ២០១៦

... **បើកម្ពុជាខ្លួនឯងអត់សន្តិភាពទេ អត់មានលទ្ធភាពបញ្ជូនកម្លាំងទៅក្រៅទេ កុំថាអត់ មានលទ្ធភាពបញ្ជូនកម្លាំងទៅក្រៅ** នៅខាងក្នុងវានៅតែវ៉ៃគ្នាហ្នឹង សូម្បីតែធ្វើស្ពានក៏ដាច់ស្ពាន ធ្វើសាលាក៏ឆេះសាលា។ អម្បាញ់មិញ ចាក់រូបនយោបាយ ឈ្នះ-ឈ្នះ ... ហ្នឹងហើយ**នយោបាយឈ្នះ-ឈ្នះ ដែលកម្ពុជាឯកភាពទឹកដីជាលើកដំបូងក្នុងប្រវត្តិប្រមាណ ៥០០ ឆ្នាំ។ ពីកម្ពុជាមួយមានតំបន់ត្រួតត្រាច្រើន ទៅកម្ពុជាមួយមានតំបន់ត្រួតត្រាតែមួយទេ ដែលនៅក្នុងប្រវត្តិរបស់ខ្លួន កម្ពុជា(កម្រជាប្រទេសមាន)តំបន់ត្រួតត្រាមួយ...**។

កិច្ចការនារី

១	រើសអើង ហិង្សាលើស្ត្រី ជាការឈឺចាប់នៃគ្រួសារ សហគមន៍ សង្គមជាតិ	៧៣
២	ទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ	៧៣
៣	ការវិនិយោគលើស្ត្រី មិនមែនមានត្រឹមថវិកាក្រសួងកិច្ចការនារីទេ	៧៣
៤	ស្ត្រីក្នុងរចនាសម្ព័ន្ធដឹកនាំ និងបន្តវេន	៧៤
៥	ទុកអោយស្ត្រីអសមត្ថភាព ជាអំពើឆោតល្ងង់	៧៥
៦	គម្លាតរវាងបុរស និងស្ត្រី ពាក់ព័ន្ធនឹងការសិក្សា	៧៥
៧	រុញសាលារៀនទៅមូលដ្ឋាន ផ្លូវថ្នល់ និងសន្តិភាព ផ្តល់ឱកាសដល់ស្ត្រី	៧៦
៨	ស្ត្រីធ្វើសកម្មភាពក្នុងកិច្ចការអន្តរជាតិ	៧៦
៩	គ្រប់បក្សនយោបាយដាក់ស្ត្រីជាបេក្ខភាព, ស្ត្រីត្រូវប្រឹងប្រែងខ្លួនឯងផង	៧៧
១០	ផ្ទើការគោរពចំពោះស្ត្រីជាភរិយាសាច់ញាតិកម្លាំងប្រដាប់អាវុធនៅជាយដែន	៧៨

១. ការរើសអើង ហិង្សាលើស្ត្រី ជាការឈឺចាប់នៃគ្រួសារ សហគមន៍ និងសង្គមជាតិ

ខួបអនុស្សាវរីយ៍ លើកទី ៩៩ ទិវាអន្តរជាតិ នារី ៨ មីនា, ថ្ងៃទី ០៤ មីនា ២០១០

... បញ្ហាពេស្យាចារនៅតែជាបញ្ហាកង្វល់ ... ខ្ញុំបានតស៊ូលើរឿងនេះ កាលពីឆ្នាំ ២០០២ រហូតដល់មានប្រតិកម្មពីមជ្ឈដ្ឋានខ្លះទាក់ទងនឹង karaoke ... ខ្ញុំ សូមឲ្យ ឆ្នាំ ២០១០ ក្លាយទៅជាឆ្នាំយុទ្ធនាការនៃការបំផ្លាញចោលបនស្រី និងបន ល្បែង ខុសច្បាប់។ នៅក្នុងនេះ យើងបានលើកឡើងថា **រាល់ការរើសអើងចំពោះ ស្ត្រី រាល់អំពើហិង្សាលើស្ត្រី រាល់ការជួញដូរលើស្ត្រីមិនមែនជាក្តីឈឺចាប់របស់ស្ត្រីតែ ឯង, គ្រួសារតែមួយ ឬសហគមន៍ តែមួយនោះទេ បញ្ហានេះជាសោកនាដកម្ម របស់សង្គម និងសេដ្ឋកិច្ចជាតិ ...**។

២. ទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ

ខួបអនុស្សាវរីយ៍លើកទី ៩៩ ទិវាអន្តរជាតិនារី ៨ មីនា, ថ្ងៃទី ០៤ មីនា ២០១០

... ខ្ញុំសុំឲ្យអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ជាពិសេសរដ្ឋបាលដែនដីមើលឲ្យបានដិត ដល់នៅកន្លែងក្លឹបកំសាន្ត ឬក៏កន្លែងដ៏ទៃទៀត ... **សូមឲ្យយកចិត្តទុកដាក់ បើក យុទ្ធនាការបន្តការប្រយុទ្ធប្រឆាំង និងការជួញដូរស្ត្រី ហើយត្រូវរ៉ែឲ្យចំមេក្លោង ពិតប្រាកដ មិនមានការអត់ឱន និងលើកលែងណាមួយទេ។ អន្តរាគមន៍ ទោះបី ពីណាក៏ដោយ គឺមិនអាចទទួលបានឡើយ។ ខ្ញុំយល់ពីការលំបាក (ដែល)មាន ការធ្វើអន្តរាគមន៍ទៅតុលាការ ទៅនគរបាល ទៅកងរាជអាវុធហត្ថ។ អ្នកដែលធ្វើ អន្តរាគមន៍ទាំងឡាយទោះបីមានហានៈប៉ុណ្ណាក៏ដោយ ... នឹងត្រូវអស់បុណ្យស័ក្តិ ខ្លួនឯងតែម្តង**។ ... សូមអំពាវនាវ និងអង្វរក ចំពោះមេដឹកនាំ មិនថាគណបក្ស នយោបាយណាទេ សូមអនុវត្តត្រឹមត្រូវតាមច្បាប់ដែលមានជា ធរមាន ជាការគ្រប់ គ្រាន់ដើម្បីរក្សាតម្លៃច្បាប់ រក្សាតម្លៃសង្គម និងតម្លៃប្រទេសជាតិរបស់យើង ...។

៣. ការវិនិយោគលើស្ត្រី មិនមែនមានត្រឹមថវិកាក្រសួងកិច្ចការនារីទេ

ខួបអនុស្សាវរីយ៍លើកទី ៩៨ ទិវាអន្តរជាតិនារី ៨ មីនា, រាជធានីភ្នំពេញ, ថ្ងៃទី ០៥ មីនា ២០០៩

... ពេលប្រជុំក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី មានលើកឡើងពិភាក្សាប្រធានបទមួយចំនួន ... ជួនកាល គេមើលការវិនិយោគអោយស្ត្រីត្រឹម តែ(ជា)ថវិកាក្រសួងកិច្ចការនារី ... មនុស្សមួយចំនួនទិតៀនរាជ រដ្ឋាភិបាលលើបញ្ហាកញ្ចប់ថវិកាក្រសួងកិច្ចការនារី(ថា)តិចពេក។ ប៉ុន្តែការវិនិយោគឲ្យស្ត្រី មិនមែនវិនិយោគត្រឹមតែថវិកាក្រសួងកិច្ចការនារីនោះទេ។ ... **ការវិនិយោគទៅធ្វើផ្លូវថ្នល់ក៏មានផលប្រយោជន៍ដល់ស្ត្រី ការធ្វើសាលារៀន ការសង់ប្រឡាយទឹកសុទ្ធតែបានផលប្រយោជន៍ឲ្យស្ត្រីដែររាប់ទាំងការបណ្តុះបណ្តាលវិជ្ជាជីវៈសព្វបែបយ៉ាងទាំងអស់ ... នៅមានការវិនិយោគ និងវិធានការសម្រាប់ស្ត្រីដោយឡែកផ្សេងទៀត ដូចជាការការពារតាមផ្លូវច្បាប់ ការការពាររលើបញ្ហាហឹង្សារលើស្ត្រី និងកុមារ ...**។

៤. ស្ត្រីក្នុងរចនាសម្ព័ន្ធដឹកនាំ និងបន្តវេន

ប្រសាសន៍ក្រៅសុន្ទរកថា, អង្គប្រជុំគណៈរដ្ឋមន្ត្រី លើកទី ១ នីតិកាលទី ៥ នៃរដ្ឋសភា, ថ្ងៃទី ២៣ កញ្ញា ២០១៣

... **ក្នុងអាណត្តិនេះស្ថាប័ននីមួយៗ សុទ្ធតែមានស្ត្រីយ៉ាងតិច ២ រូប ហើយយើងមានស្ត្រី ៣ រូប ជារដ្ឋមន្ត្រី**។ ឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន គាត់កាន់ក្រសួងមួយ លោកជំទាវ អ៊ីង កន្ថាផារី បន្តកាន់ក្រសួងកិច្ចការនារី ហើយលោក ជំទាវ ភឿង សកុណា គាត់កាន់ក្រសួងវប្បធម៌ និងវិចិត្រសិល្ប:។ ក្រៅពីនោះរដ្ឋលេខាធិការនៅគ្រប់ក្រសួងយ៉ាងហោច ០១ រូប។ (ជា)អនុរដ្ឋលេខាធិការ មានក្រសួងខ្លះមានលើសមួយ ... បន្ថែមទៅដោយផែនការបន្តវេន ការដាក់ស្ត្រីនៅក្នុងថ្នាក់អនុរដ្ឋលេខាធិការ ក៏មានស្ត្រីជាយុវជន ...។ ផ្នែកខាងក្រោមទៀតមានថ្នាក់ស្រុក ថ្នាក់អភិបាលរងស្រុក ខណ្ឌ គឺភាគច្រើនស្ថិតនៅក្នុងចំណោមយុវជន នៅឡើយ ... ចំនុចនេះ **យើងបានឆ្លើយតបជាមួយបញ្ហាទាក់ទងស្ត្រី និងយុវជន ហើយនៅមានកិច្ចការច្រើនទៀត ដែលត្រូវជម្រុញ** ...។

សន្និបាតបូកសរុបសមិទ្ធិផលការងារក្រុមប្រឹក្សាឃុំ-សង្កាត់, ១៨ សីហា ២០១១

... សម្រាប់ការតែងតាំងវិញ យើងបានប្រឹងថា នៅថ្នាក់ស្រុក-ខណ្ឌ ក្រុង-ខេត្ត រាជធានី ហោចបំផុតឱ្យមានម្នាក់នៅក្នុងគណៈអភិបាល ... **យើញមានការតែង**

តាំងច្រើន ដែលសូមលើកទឹកចិត្ត ព្រោះនេះជាការចូលរួមរបស់ស្ត្រីក្នុងកិច្ចការអភិវឌ្ឍប្រទេសជាតិរបស់យើង ហើយក៏សូមផ្តាំលោកមេខេត្ត បើតែងតាំងអភិបាលរងជាស្ត្រីហើយ សូមកុំទុកគាត់គ្រាន់តែលំអា។ សូមប្រគល់ការងារឱ្យគាត់ផង។ ពេលប្រជុំក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ខ្ញុំបានលើកពីបញ្ហាហ្នឹង។ បានជួបមុខអភិបាលខេត្តហើយ (សូមផ្តាំ)បើមានស្ត្រីជាអភិបាលរង និងអភិបាល/រងស្រុក(ជាស្ត្រី) ក៏សូមប្រគល់ការងារឱ្យគាត់ផង ... តែងតាំងរួច ទុកចោលគ្រាន់តែឱ្យមានក្នុងបញ្ជីជានិមិត្តរូបមិនត្រូវទេ ឱ្យគាត់គ្រប់គ្រងធ្វើការងារឱ្យបានល្អ ...។

៥. ទុកអោយស្ត្រីអសមត្ថភាព ជាអំពើឆោតល្ងង់

អបអរសាទរខួប លើកទី ១០០ ទិវាអន្តរជាតិនារី ៨ មីនា, ថ្ងៃទី ០៧ មីនា ២០១១

... កាលពីកិច្ចប្រជុំកន្លងទៅ **ខ្ញុំបានលើកជាអនុសាសន៍ចំនួន ១០ សម្រាប់ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី ក្នុងនោះ (ខ្ញុំចាត់ទុកថា) ជាការឆោតល្ងង់មួយ ប្រសិនជាអ្នកណាទុកអោយស្ត្រី ពិសេសស្ត្រីក្នុងគ្រួសារ ជាប្រពន្ធក្តី ជាកូនក្តី ធ្លាក់ក្នុងស្ថានភាពពុំមានសមត្ថភាពគ្រប់គ្រាន់** ... ជាការឆោតល្ងង់បំផុតនៅក្នុងគ្រួសារមួយ ហើយក៏ជាការឆោតល្ងង់ នៃអ្នកដឹកនាំស្ថាប័ន ដែលមើលរំលងសមត្ថភាពរបស់ស្ត្រី ...។

៦. គម្លាតរវាងបុរស និងស្ត្រី ពាក់ព័ន្ធនឹងការសិក្សា

ពិធីចែកសញ្ញាបត្រដល់គ្រូបង្រៀនកម្រិតឧត្តម និងកម្រិតមូលដ្ឋានឯកទេសភាសាបារាំង-ខ្មែរ និងសម្ពោធអគារ B ០៧ កម្ពស់ ៥ ជាន់, ថ្ងៃទី ២៥ មីនា ២០១៥

... ជំទាវ ទី ១ ភរិយាប្រធានាធិបតីសហរដ្ឋអាមេរិក ម៉ីសែល អូបាម៉ា បានមកកម្ពុជា (ជាមួយ)ប្រធានបទ "ញុះស្ត្រីឲ្យរៀន"។ ការពិតរឿង ហ្នឹងមិនមែនជាបញ្ហារឿងថ្មីថ្មោងរបស់កម្ពុជាទេ។ ខ្ញុំបានលើករឿងនេះច្រើនដង រួមទាំងអោយក្រសួងអប់រំ ក្រសួងកិច្ចការនារី ធ្វើការសិក្សាជាមួយគ្នា ... (នៅបឋមសិក្សា សិស្សស្រី និងប្រុស)មានចំនួនប្រហាក់ប្រហែលគ្នា។ ចូលដល់វិទ្យាល័យចាប់ផ្តើមលំអៀងហើយ។ ស្ត្រីចុះទាប។ បុរសឡើង។ **ចូលដល់មធ្យមសិក្សាទុតិយភូមិ ការលំអៀងមានរហូតដល់បរិញ្ញាបត្ររង បរិញ្ញាបត្រ ចាប់ផ្តើមកាន់តែលំអៀង ជាពិសេស**

បរិញ្ញាជាន់ខ្ពស់ និងបណ្ឌិត ... (ដែលបានប្រាប់ថា) មានកត្តា(មូលហេតុ)ច្រើន (ដូចជា)ភាពក្រីក្រ ការខ្វះអន្តេវាសិកដ្ឋាន ... ហើយក៏មានរឿងប្រពៃណី ដូចជា ដល់អាយុយកប្តី ... បុរសជាស្វាមី ក៏ត្រូវបើកឱកាសឲ្យភរិយាបានទៅរៀនសូត្រដែរ។ បើមិនដូច្នោះទេ គឺគម្លាតរវាងបុរស និងស្ត្រីហ្នឹង គឺនៅតែមាន ...៕

៧. រុញសាលារៀនទៅមូលដ្ឋាន ផ្លូវថ្នល់ និងសន្តិភាព ផ្តល់ឱកាសដល់ស្ត្រី

ពិធីអបអរសាទរខួបលើកទី ១០០ ទិវាអន្តរជាតិនារី ៨ មីនា, ០៧ មីនា ២០១១

... យើងត្រូវយកចិត្តទុកដាក់ពាក់ព័ន្ធនឹងការវិនិយោគបន្ថែមអោយស្ត្រី ... យើងបានធ្វើសកម្មភាពច្រើនហើយ ប៉ុន្តែមិនទាន់ឆ្លើយតបបានទៅនឹងការចង់ បាននៅឡើយ។ ការ**វិនិយោគនេះ ត្រូវចាប់ផ្តើមពីខាងក្រោមមកខាងលើ គឺការរុញសាលារៀនអោយទៅដល់មូលដ្ឋាន បង្កើតលក្ខណៈសម្បត្តិអោយកូនសិស្ស ជាស្ត្រី មានឱកាសចូលរៀននៅបឋមសិក្សា នៅមធ្យមសិក្សាកម្រិតមួយ និងនៅមធ្យមសិក្សាកម្រិត ២**។ ទំនៀមទម្លាប់ខ្មែរយើង ពាក់ព័ន្ធជាមួយនឹងការធ្វើដំណើរឆ្ងាយរបស់ស្ត្រី ជាឧបសគ្គមួយរារាំងការចេះដឹងរបស់ស្ត្រី កាលពីសម័យដើម ... ប៉ុន្មានឆ្នាំចុងក្រោយ **សាលាយើងបានចុះទៅដល់មូលដ្ឋាន ផ្លូវថ្នល់យើងក៏ស្អាត សន្តិភាពក៏កើតមាន ចំនួនកូនស្រីអ្នកចុះឈ្មោះចូលរៀនបានកើនឡើង ... កត្តាសន្តិភាពពេញផ្ទៃប្រទេស បានបង្កើតឱកាសធំជាងគេសម្រាប់ស្ត្រី** ... ដូច្នេះ ត្រូវក្តាប់អោយជាប់ក្នុងដៃនូវសន្តិភាព ដែលយើងទទួលបានទាំងលំបាកនេះ ...៕

៨. ស្ត្រីធ្វើសកម្មភាពក្នុងកិច្ចការអន្តរជាតិ

បិទវេទិកាជាតិស្តីពីស្ត្រីជាថ្នាក់ដឹកនាំក្នុងវិស័យសាធារណៈ និងនយោបាយ,
ថ្ងៃទី ១៥ ធ្នូ ២០១៥

... **យើងមានថ្នាក់អគ្គរដ្ឋទូត និងអ្នកការទូតស្ត្រី ដែលធ្វើសកម្មភាពមិនចាញ់បុរសនោះទេ ទាក់ទងនឹងកិច្ចការអន្តរជាតិ។ ឥឡូវនេះ សូម្បីតែស្ត្រីដែលចូលរួមនៅក្នុងកងរក្សាសន្តិភាពអង្គការសហប្រជាជាតិ ក៏បានធ្វើសកម្មភាពនៅស៊ូដង់ខាងត្បូងច្រើនជាងគេ** ... ពេលជួបអគ្គលេខាធិការអង្គការសហប្រជាជាតិ បាន គឺមុន កាលពីឆ្នាំ ២០១៣ នៅ ប្រ៊ុយណេ គាត់ស្នើសុំឲ្យ(កម្ពុជា)បន្ថែមចំនួនស្ត្រី

នៅក្នុងកម្លាំងកងអាវុធហត្ថ ដែលបញ្ជូនទៅក្រៅប្រទេស ព្រោះប្រហែលជាមានការពាក់ព័ន្ធ ដូចជាធ្វើប្រតិបត្តិការពិនិត្យសន្តិសុខសណ្តាប់ធ្នាប់ស្ទីៗ ទៅលើស្ត្រីដែលត្រូវការស្ត្រី(ជាអ្នកធ្វើ) ... យើងក៏បានបញ្ជូនចំនួននេះ ទៅក្រៅប្រទេសផងដែរ...។

៩. គ្រប់បក្សនយោបាយ ដាក់ស្ត្រីជាបេក្ខភាព និងស្ត្រីត្រូវប្រឹងប្រែងខ្លួនឯងផង

បិទវេទិកាជាតិស្តីពីស្ត្រីជាថ្នាក់ដឹកនាំក្នុងវិស័យសាធារណៈ និងនយោបាយ,
ថ្ងៃទី ១៥ ធ្នូ ២០១៥

... ខ្ញុំសូមអំពាវនាវទៅគ្រប់បក្សនយោបាយ ដែលចូលរួមប្រកួតប្រជែងការ បោះឆ្នោតនៅកម្ពុជា គប្បីដាក់ស្ត្រីឲ្យចូលរួមនៅក្នុងការបោះឆ្នោតក្នុងគ្រប់កម្រិត ទាំងថ្នាក់ឃុំ ថ្នាក់ក្រុមប្រឹក្សាខេត្ត រាជធានី ក្រុង ខណ្ឌ ស្រុក ហើយសូម ដាក់ នៅថ្នាក់ជាតិ ដោយមានទាំងរដ្ឋសភា និងព្រឹទ្ធសភា។ សូមមេត្តារៀបចំដាក់ឲ្យជាប់។ កុំដាក់កំដរគ្រាង ... ដូចជាអង្គការ IRI ឬក៏ NDI គេបង្កើតវេទិកាដើម្បីពិភាក្សាលើស្ត្រី បេក្ខជនតំណាងរាស្ត្រជាស្ត្រី។ ស្រាប់តែមានបក្សនយោបាយមួយ អត់មាននឹងគេ ហើយបក្សនយោបាយហ្នឹងគឺខ្លាំងរឿងស្ត្រី ប៉ុន្តែដល់គេហៅបេក្ខជនស្ត្រីឡើងធ្វើការជជែកដេញដោលគ្នានោះ ស្រាប់តែបក្សហ្នឹង អត់មានស្ត្រីឈរឈ្មោះក្នុងមណ្ឌលហ្នឹងផង។ **មិនថាបក្សណាបក្សណាទេ គឺយើងត្រូវធ្វើសកម្មភាពពិតៗ ដើម្បីដាក់ឲ្យស្ត្រីចូលរួមនៅក្នុងការទទួលបានការបោះឆ្នោត ប៉ុន្តែធ្វើបាន(ជោគជ័យ) លុះត្រាតែស្ត្រីខ្លួនឯង មានគ្រប់លក្ខណៈសម្បត្តិ ... ប្រឹងខ្លួនឯងដែរ ដើម្បីឲ្យគេទទួលយកបាន ជ្រើសរើសបាន ហើយគណបក្សដាក់ទៅ ទទួលបានការគាំទ្រពីប្រជាពលរដ្ឋ** ...។

ពិធីបិទ សន្និបាតបូកសរុបសមិទ្ធិផលការងារក្រុមប្រឹក្សា ឃុំ-សង្កាត់ ,
ថ្ងៃ ១៨ សីហា ២០១១

... អាណត្តិក្រោយនេះ បោះឆ្នោតក្នុង ខែ មិថុនា ឆ្នាំ ២០១២ សង្ឃឹមថា សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលជាស្ត្រី នឹងមានចំនួនកើនឡើងលើសពីចំនួន ១៦% ព្រោះកាលពីអាណត្តិទី ១ មានជាង ៨% អាណត្តិទី ២ ឡើង ១៦%

ហើយសង្ឃឹមថា អាណត្តិទី ៣ លើសពី ២០%។ បើបានយ៉ាងដូច្នេះ វាជាការល្អ។ **កុំឱ្យគ្នាឈរកន្លែងដែលមិនជាប់ គួរតែដាក់ឱ្យឈរកន្លែងដែលជាប់។ គណបក្សនយោបាយខ្លះ ចេះតែដាក់ធ្វើម៉ូចឱ្យតែមានឈ្មោះ ដាក់ទៅចំអាកន្លែង ដែលមិនជាប់ ... ខ្ញុំអំពាវនាវដល់បក្សនយោបាយនានា បើសិនជាចង់លើកស្ទួយនូវសមធម៌យេនឌ័រ សូមមេត្តាដាក់នូវបេក្ខភាពស្ត្រីឱ្យបានច្រើន សម្រាប់ការជាប់ឆ្នោត(នៃស្ត្រី) ជាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ...**។

១០. ផ្ញើការគោរព ចំពោះស្ត្រីជាភរិយា សាច់ញាតិ កងកម្លាំងប្រដាប់អាវុធនៅជាយដែន

ពិធីអបអរសាទរខួបលើកទី ១០០ ទិវាអន្តរជាតិនារី ៨ មីនា, ០៧ មីនា ២០១១

... ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាមខ្លួនខ្ញុំ និងភរិយា **សូមផ្ញើជូន(នូវការគោរព)ចំពោះ បងស្រី ប្អូនស្រី ក្មួយស្រី អ្នកមីង អ៊ំស្រី ទាំងឡាយ ដែលមានសាច់ញាតិ ក្រុមគ្រួសារជាប្តី ជាកូន ជាចៅ កំពុងធ្វើជាកងកម្លាំងប្រដាប់អាវុធ កំពុងឈរជើងនៅឯជាយដែន។ ខ្ញុំដឹងថា ការឃ្លាតគ្នានេះ គឺជាការលំបាក ក៏ប៉ុន្តែនេះ គឺជាកាតព្វកិច្ចខានមិនបាន ដើម្បីប្រឆាំងនឹងសត្រូវឈ្លានពាន។ ពួកគាត់គ្មានឱកាសចូលរួមជាមួយក្រុមគ្រួសារនៅក្នុងពេលវេលានេះទេ (ព្រោះ)មានកាតព្វកិច្ចការពារទឹកដី** ... សូមផ្ញើជូនលោកអ៊ំ មាមីង បងស្រី ប្អូនស្រី នូវការគោរពចំពោះវីរភាពរបស់ស្ត្រី ដែលបានលះបង់កូនចៅ ប្តីសី ដើម្បីការពារជាតិមាតុភូមិ ទាំងក្នុងកងទ័ព ទាំងក្នុងនគរបាល និងក្នុងកងរាជអាវុធហត្ថ ...។

ទេសចរណ៍

១	ប្រតិសកម្មជម្រុញវិស័យទេសចរណ៍	៨១
២	ខិតខំរកទេសចរចិន អោយបាន ០,០០១% នៃប្រជាជនចិន	៨១
៣	រៀបចំខ្សែក្រវ៉ាត់បៃតង ជុំវិញតំបន់ទេសចរណ៍	៨២
៤	សេវាល្អ ទាញទេសចរណ៍មកជាថ្មី	៨២
៥	ក្រសួងត្រូវទប់ស្កាត់ការប្រើគ្រឿងញៀនតាមសណ្ឋាគារ ផ្ទះសំណាក់	៨៣
៦	រក្សាសន្តិសុខ និងសុវត្ថិភាព ជូនភ្ញៀវទេសចរ ជាកត្តាសំខាន់	៨៣
៧	កម្ពុជាផ្លាស់ប្តូរបែបរីកចំរើន ពីទេសចរ ០ មក ៤ លាន ៥ សែននាក់	៨៣
៨	តម្រង់ទិសវិស័យទេសចរណ៍ សំដៅជួយកាត់បន្ថយភាពក្រីក្រ	៨៤
៩	បង្កើតហេដ្ឋារចនាសម្ព័ន្ធមានប្រតិសកម្មដល់វិស័យទេសចរណ៍	៨៥
១០	ផ្តល់ទិដ្ឋាការរយៈពេលវែងសម្រាប់វិនិយោគិន	៨៥
១១	មន្ទីរពេទ្យស្តង់ដារអន្តរជាតិ បង្កើនទំនុកចិត្តអ្នកទេសចរ និងវិនិយោគិន	៨៦
១២	គោលនយោបាយបើកចំហរជើងមេឃ គិតពីសេដ្ឋកិច្ចជាតិទាំងមូល	៨៦
១៣	បង្កើនការយកចិត្តទុកដាក់អំពី អ្នកបើករថយន្តដឹកភ្ញៀវទេសចរ	៨៧
១៤	កសាងហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់មកតំបន់ឆ្នេរ និងក្នុងតំបន់ឆ្នេរ	៨៧
១៥	រក្សាគង់វង្ស តំបន់ឆ្នេរ ឆ្នេរខ្សាច់ ព្រៃ ព្រៃកោងកាង និងបណ្តាកោះ	៨៨
១៦	រក្សាបរិស្ថានល្អ ទាំងទឹក ខ្យល់ និងធម្មជាតិ	៨៨

១. ប្រតិសកម្មជម្រុញវិស័យទេសចរណ៍

ពិធីបិទសន្និបាតក្រសួងទេសចរណ៍, ថ្ងៃទី ៤ កក្កដា ២០១២

... យើងបានខិតខំទាក់ទាញទេសចរពីខាងក្រៅ តែទេសចរក្នុងស្រុក ក៏មានសារៈសំខាន់ណាស់ដែរ។ ប្រជាជនមានប្រាក់កាស គាត់ធ្វើដំណើរទេសចរណ៍នៅតាមបណ្តារមណីយដ្ឋាននានា។ **យើងបានឃើញហើយថា គ្រាន់តែចាប់ផ្តើមបូកគោមួយ (មាន)ប្រតិសកម្មអ្នកដែលទទួលផលច្រើននៅឯកែប និងកំពត ... នេះប្រតិសកម្ម មិនមែនប្រតិយាតទេ។ វាជម្រុញឲ្យវិស័យទេសចរ មានការកើនឡើង។ បន្ថែមដោយហេដ្ឋារចនាសម្ព័ន្ធ របស់យើងកាន់តែល្អប្រសើរ គឺអ្នកទេសចរគេទៅ ... រតនគិរី មណ្ឌលគិរី ស្ទឹងត្រែង និងកន្លែងដទៃទៀត ក៏ដូចគ្នា ... ប្រជាពលរដ្ឋស្វែងយល់ពីតំបន់មួយទៅកាន់តំបន់មួយ ក្នុងស្មារតីស្រឡាញ់ជាតិ ស្រឡាញ់ទេសភាព ជួយអភិរក្ស ធនធានធម្មជាតិរបស់យើងផងដែរ ...**។

២. ខិតខំរកទេសចរចិន អោយបាន ០,០១% នៃប្រជាជនចិន

ពិធីចែកសញ្ញាបត្រជូននិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ថ្ងៃទី ០៦ តុលា ២០១៦

... សំខាន់ គឺខិតខំបើកទីផ្សារប្រទេសចិន ដែលជាទីផ្សារដ៏ធំមួយ សម្រាប់វិស័យកសិផលរបស់កម្ពុជា ក្នុងហ្នឹង ក្រៅពីអង្ករ ដំឡូងមី ដែលយើងនាំចូលទៅ និងកសិផលមួយចំនួន។ យើងកំពុងបើកកសិផលមួយចំនួន រាប់ទាំងផ្លែចេក ជាដើម។ **ការវិនិយោគ ការផ្តល់ជំនួយនានា នឹងត្រូវបានធ្វើក្នុងទំនាក់ទំនងកម្ពុជា ចិន ហើយយើងខិតខំរកទេសចរចិនឲ្យបានក្នុងអត្រា ០,០១% ទៀត។ ថ្ងៃមុនគេថាអោយខ្ញុំ ថាបើថា ០,០១% អាហ្នឹង ស្មើ ១៣ លាននាក់ ប៉ុន្តែយើងត្រូវការតែ ១ លាន ៣ សែននាក់ទេ។ ចិនមាន ១៣០០ លាននាក់ ... ឆ្នាំកន្លងទៅទេសចរចិន មាន ៨០ ម៉ឺន នាក់រួចស្រេចទៅហើយ។ ការបើកជើងហោះហើរពីខេត្តនានារបស់ ចិនមកកាន់កម្ពុជា (នឹងធ្វើអោយចំនួន)ទេសចរចិននឹងឡើងដល់កម្រិតនោះ។** ឥឡូវ ពិបាកជាងគេគឺជាភ្នាក់ងារទេសចរណ៍ទៅវិញ បើម្ហូបចិន មិនពិបាកទេ ...។

៣. រៀបចំខ្សែក្រវ៉ាត់បៃតង ជុំវិញតំបន់ទេសចរណ៍

ពិធីប្រគល់ប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាជន ស្រុកដំណាក់ចង្អើរ ខេត្តកែប,
ថ្ងៃទី ១១ ធ្នូ ២០១២

... ពិតហើយ មុខទំនិញខ្លះ ម្ហូបអាហារខ្លះ មិនអាចផ្គត់ផ្គង់ពី ក្នុងស្រុកបានទេ ដូចជា Foie Gras, ដូចជា Fromage, ដូចជាប៊ីរ ... ត្រូវនាំចូល។ អ្វីដែលគួរអោយ សោកស្តាយនោះនៅត្រង់ថា **យើងនាំចូលទាំងបន្ថែពីប្រទេសក្រៅ យកមកផ្គត់ ផ្គង់អោយភោជនីយដ្ឋានក្នុងស្រុក ... នេះជាការហូរចេញនូវូបិយប័ណ្ណ ត្រឡប់ ទៅវិញ។ ទេសចរមក យើងគួរតែខ្ចប់លុយហ្នឹងទុកសម្រាប់ប្រជាពលរដ្ឋរបស់ យើង ... គួរតែត្រូវរៀបចំផែនការផ្សារភ្ជាប់រវាងសៀកម្មផ្នែកភោជនីយដ្ឋាន ជាមួយ នឹងតំបន់ដាំដុះ ... កន្លែងជាភោជនីយដ្ឋាន ឬក៏សណ្ឋាគារ ... ទីផ្សាររបស់កសិករ ដាំដុះ នៅតំបន់ជុំវិញ ទេសចរណ៍ រៀបចំជាខ្សែក្រវ៉ាត់បៃតង** ... អោយត្រូវស្តង់ដារ កុំអោយគេថាជាតិគីមីច្រើន ...។

៤. សៀវាល្ម ទាញទេសចរណ៍មកជាថ្មី

ពិធីប្រគល់ប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាជន ស្រុកដំណាក់ចង្អើរ ខេត្តកែប,
ថ្ងៃទី ១១ ធ្នូ ២០១២

... បច្ចុប្បន្ននេះ ទេសចរណ៍មានការប្រកួតប្រជែង។ ដំបូង និយាយពីការប្រកួត ប្រជែងក្នុងតំបន់ ។ នៅក្នុងអាស៊ាន ប្រទេសមួយណាក៏ខិតខំ ទាក់ ទាញភ្ញៀវទេសចរ ដែរ ... **(យើងមាន)គោលការណ៍ព្រះរាជាណាចក្រកម្ពុជា ព្រះរាជាណាចក្រ អច្ឆរិយៈ និងពាក្យស្លោក ទីក្រុងស្អាត រមណីយដ្ឋាន ស្អាត សៀវាល្ម ... សៀវាល្ម ហ្នឹងសំខាន់ណាស់ ដើម្បីឲ្យភ្ញៀវទេសចរគេទៅហើយគេត្រឡប់មកវិញ។ អ្នកធ្វើ សៀវាទេសចរណ៍ ទាំងឡាយ ត្រូវគិតអោយច្បាស់ ។ ពីដើមមានតែក្រុងព្រះសីហនុ ... ឥឡូវ គេទៅក្រុងព្រះសីហនុ មកបូកគោ មកកែប ទៅកំពត កោះកុង អង្គរវត្ត តំបន់ភូមិភាគឦសាន និងតំបន់អេកូទេសចរណ៍ដទៃ។** ឥឡូវ បើទោះបីមិនចេះ ញញឹម ក៏ត្រូវតែខំញញឹមដែរដើម្បីទាក់ ទាញភ្ញៀវទេសចរ ...។

៥. ក្រសួងទេសចរណ៍ ត្រូវទប់ស្កាត់ការប្រើគ្រឿងញៀនតាមសណ្ឋាគារ ផ្ទះសំណាក់

ពិធីផ្ទេរតំណែងប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន,
ថ្ងៃទី ១៩ ឧសភា ២០០៩

... **ក្រសួងទេសចរណ៍ត្រូវមើលផង។ ផ្ទះសំណាក់ សណ្ឋាគារមួយចំនួន និងកន្លែងរាំរែកមួយចំនួន មិនមែនទាំងអស់ទេ មានចែកចាយគ្រឿងញៀននៅហ្នឹង ... មានអ្នកខ្លះបាត់កូន ទៅរកឃើញញាក់ក្បាលនៅហ្នឹង ... ដូច្នេះ ផ្ទះសំណាក់ ឬ សណ្ឋាគារទាំងអស់ បើចង់រក្សាមុខរបរ គឺត្រូវកុំឲ្យមានការចែកចាយគ្រឿងញៀន នៅទីនោះ** ដោយសហការជាមួយអាជ្ញាធរ បើមិនដូច្នោះទេ ផ្ទះសំណាក់របស់ខ្លួន ប្រឈមមុខនឹងការបិទ ដកអាជ្ញាប័ណ្ណមិនឲ្យធ្វើអាជីវកម្ម ហើយជាប់ទោស ទៀតផង ...។

៦. រក្សាសន្តិសុខ និងសុវត្ថិភាព ជូនភ្ញៀវទេសចរ ជាកត្តាសំខាន់

សន្និបាតបូកសរុបការងាររបស់ក្រសួងទេសចរណ៍ ឆ្នាំ ២០០៨-២០០៩,
ថ្ងៃទី ៣០ កក្កដា ២០០៩

... ខ្ញុំសូមបញ្ជាក់ សន្តិសុខ សុវត្ថិភាព ជារឿងធំ។ បើប្រទេសយើង ពោរពេញដោយអស្ថេរភាព ទាំងនយោបាយក្តី សង្គ្រាមក្តី ភេរវកម្មវ៉ៃលុកក្តី គ្មានអ្នកណាចង់មកកម្សាន្តទេ។ ទោះបី គេទៅ ក៏ទៅទាំងភ្នែកសភ្នែកខ្ចៅ។ អញ្ចឹង ត្រូវធានាឱ្យបាន សុខសន្តិភាពសម្រាប់ភ្ញៀវទេសចរ។ ... **សន្តិភាពគ្របដណ្តប់ពេញផ្ទៃប្រទេសហើយ តែក្មេងពាល ឬហៅថា ក្មេងទំនើងនេះ(នៅមាន ហើយ)ក៏មានផ្នែកវំនានទៅដល់ទេសចរណ៍ដែរ ... ត្រូវបន្តទប់ស្កាត់លើចំណុចនេះ កុំឲ្យភ្ញៀវទេសចរ ភ័យព្រួយដោយសារកត្តាអសន្តិសុខ** ... សូមកោតសរសើរនគរបាលទេសចរដែល បានយកកាបូបដែលភ្ញៀវជ្រុះ ទៅជូនដល់ភ្ញៀវវិញ ... ជាកាយវិការមួយដ៏ល្អ ...។

៧. កម្ពុជាផ្លាស់ប្តូរបែបរីកចំរើន ពីទេសចរ ០ មក ៤ លាន ៥ សែននាក់

សន្និបាតការប្រឡងប្រណាំង "ទីក្រុងស្អាតរមណីយដ្ឋានស្អាត សេវាល្អ ឆ្នាំ ២០១៤",
ថ្ងៃទី ២២ កញ្ញា ២០១៥

... គ្មានទេសចរណាប្រជុំយប្រថានានឹងគ្រោះថ្នាក់ពីការវាយប្រហារភេរវកម្ម ឬក៏សង្គ្រាមនោះទេ ... រយៈពេលកន្លងទៅមាន កើតឡើងនូវការវាយប្រហារតាមបែបភេរវកម្ម (ដូចជា)នៅទីក្រុងបាងកក ... **បញ្ហារបស់យើងនៅទីនេះគឺ តើយើងទទួលទេសចរ ឬត្រូវទទួលជនភៀសខ្លួន? ពិភពលោកកំពុងប្រឈមបញ្ហានេះ ... មិនត្រូវមានការរើរវាយ ជាមួយនឹងទស្សនវិស័យ ដែលនិយាយហើយនិយាយទៀត តែអំពីការផ្លាស់ប្តូរៗ។ ឥឡូវ "ប្តូរពិតប្រាកដនៅមជ្ឈិមបូព៌ា, ការផ្លាស់ប្តូរនៅអឺរ៉ុប" ... (ឯ)យើង ត្រូវធ្វើឲ្យមានការផ្លាស់ប្តូរបែបរីកចម្រើន ពីទេសចរគ្មានសោះមកកាន់ទេសចរអាប់ម៉ឺននាក់ រាប់សែននាក់ និងមក ៤ លាន ៥ សែននាក់** ... ខ្ញុំអំពាវនាវឲ្យមានសហប្រតិបត្តិការ ការពារសន្តិសុខជាតិ ធានាសុវត្ថិភាពប្រជាជន និងវិស័យទេសចរណ៍ សហការជាមួយប្រទេសក្នុងតំបន់ និងអន្តរជាតិ ប្រឆាំងគ្រប់ទម្រង់នៃភេរវកម្ম ...។

ពិធីសម្ពោធស្ថានីយអ្នកដំណើរថ្មី នៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ,
ថ្ងៃទី ១៦ មីនា ២០១៦

... យើងពិតជាមានមោទនភាពជាមួយនឹងការកើនឡើងនៃចំនួនទេសចរ។ បើអត់មានទេសចរ គ្មានតម្រូវការសាងសង់អគារនោះទេ... ខ្ញុំមិននិយាយពីចំនួនប៉ុន្មានសិបម៉ឺននាក់ ខ្ញុំនិយាយពីកម្ពុជាសូន្យទេសចរ រហូតមកដល់ ៤ លាន ៧ សែននាក់ នៅឆ្នាំ ២០១៥ កន្លងទៅ។ ហេតុអីបានខ្ញុំ និយាយពីសូន្យទេសចរ? ... **ព្រលានយន្តហោះទៅទីក្រុងភ្នំពេញនេះ បានទទួលរងវិនាសកម្ম តាំងពីរដ្ឋប្រហារថ្ងៃ ១៨ មីនា ជាការចាប់ផ្តើមនៃភ្លើងវិនាសកម្ম ... ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ព្រលានយន្តហោះនេះ ស្ទើរតែបិទទាំងស្រុងទៅហើយ ... អត់បានលៃលកទុកដីសម្រាប់ពង្រីកព្រលានយន្តហោះទេ។ ឥឡូវប៉ុន្មាននាទីចុះមួយគ្រឿងៗ ... ដោយសារសន្តិភាពតាមនយោបាយឈ្នះ/ឈ្នះ ធ្វើអោយកម្ពុជាមានតំបន់ទេសចរច្រើន ភ្ញៀវទេសចរកើនពីសូន្យដល់ ៤ លាន ៧ សែននាក់ជាង** ...។

៨. តម្រង់ទិសវិស័យទេសចរណ៍ សំដៅជួយកាត់បន្ថយភាពក្រីក្រ

ពិធីសម្ពោធទីស្តីការក្រសួងទេសចរណ៍ថ្មី, ថ្ងៃទី ២៨ សីហា ២០០៩

... យើងកំពុងស្ថិតក្នុងដំណាក់កាលដើរទៅមុខ នៃព្រះរាជាណាចក្រកម្ពុជាអច្ឆរិយៈ ហើយក៏**កំពុងប្រឡងប្រណាំងអំពីទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ។ ការពិតក្រសួងគ្រាន់តែជាអ្នកដឹកនាំជានយោបាយទេ អ្នកដែលទទួលផលពិតប្រាកដជាអ្នកណា? គឺប្រជាពលរដ្ឋជាអ្នកទទួលផលពីវិស័យទេសចរណ៍នេះ។ យើងតម្រង់ទិសវិស័យទេសចរណ៍ ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ** ... គ្រប់រាជធានី ខេត្ត ក្រុង ត្រូវតែធ្វើសកម្មភាពឲ្យបានល្អលើបញ្ហាសន្តិ សុខ សណ្តាប់ធ្នាប់សង្គមក៏ដូចជាបញ្ហាពាក់ព័ន្ធទាំងឡាយ ... គ្រប់ទីកន្លែងទាំងអស់ដំបូងឡើយ ប្រជាជនយើងគាត់ទៅសិន បន្ទាប់ពីហ្នឹងទៅ ទេសចរណ៍អន្តរជាតិទៅតាមក្រោយ ...។

៩. បង្កើតហេដ្ឋារចនាសម្ព័ន្ធមានប្រតិសកម្មដល់វិស័យទេសចរណ៍

ពិធីសម្ពោធទីស្តីការក្រសួងទេសចរណ៍ថ្មី, ថ្ងៃទី ២៨ សីហា ២០០៩

... ទីក្រុងរបស់យើងកាន់តែស្អាត ហើយអំពាវនាវដល់ប្រជាពលរដ្ឋចូលរួមសម្អាតទីក្រុង ... **ការបង្កើតឡើងនូវហេដ្ឋារចនាសម្ព័ន្ធ សម្រាប់ផ្នែកទេសចរណ៍ ការបង្កើតឲ្យមាននូវសេវាកម្មល្អ ពង្រីកឲ្យមានរមណីយដ្ឋានថ្មីៗ ដើម្បីទាក់ទាញទេសចរណ៍ ការត្រៀមបម្រុងទុកដើម្បីជម្រុញការដាំដុះ ការចិញ្ចឹមសត្ត សម្រាប់បម្រើឲ្យការរីកចម្រើនខាងវិស័យទេសចរណ៍ សុទ្ធតែជាការងារក្នុងកញ្ចប់និយាយពីទេសចរណ៍** គឺជាបញ្ហាដែលមានប្រតិសកម្មចំពោះផ្នែកដទៃទៀត ...។

១០. ផ្តល់ទិដ្ឋាការរយៈពេលវែងសម្រាប់វិនិយោគិន

ពិធីបើកវេទិកាធុរកិច្ចកម្ពុជា-ចិន "កម្ពុជា៖ ព្រះរាជាណាចក្រនៃកាលានុវត្តភាពខ្សែក្រវ៉ាត់មួយ ផ្លូវមួយ", ថ្ងៃទី ០១ ធ្នូ ឆ្នាំ ២០១៦

... មុននឹងចាប់ផ្តើមនូវខ្លឹមសារ ខ្ញុំគួរតែនិយាយបន្តិច ... ប្រហែលជាដំណឹង រីករាយសម្រាប់វិនិយោគិនចិន ហើយពាក់ព័ន្ធនឹងអ្នកវិនិយោគិនរបស់កូរ៉េផងដែរ។ **កន្លងទៅ កម្ពុជាបានផ្តល់នូវភាពអនុគ្រោះសម្រាប់ទិដ្ឋាការរយៈពេលវែង ដោយចេញចូលច្រើនដងសម្រាប់អ្នកទេសចរចិន និងកូរ៉ូរួចហើយ។ ថ្ងៃនេះ តាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ បន្ទាប់ពីការពិគ្រោះយោបល់ជាមួយក្រសួង**

មហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខ្ញុំបានសម្រេចផ្តល់ជូនសម្រាប់អ្នកវិនិយោគ ដែលមកពីចិន និងកូរ៉េ នូវទិដ្ឋាការចេញចូលច្រើនដង និងរយៈពេលវែង សម្រាប់អ្នកកាន់លិខិតឆ្លងដែនធម្មតា ... សុំជូន ៣ ឆ្នាំ តែម្តង។ ចាប់ពីពេលនេះតទៅ អ្នកវិនិយោគទាំងឡាយរបស់ចិន ដែលកាន់ លិខិតឆ្លងដែនធម្មតា គឺមិនចាំបាច់ត្រូវការសុំវីសា (ទិដ្ឋាការ)ទៀតទេ ហើយក៏មិនចាំបាច់បង់ថ្លៃដែរ ក្នុងរយៈពេល ៣ ឆ្នាំ ចេញចូលប៉ុន្មានដងក៏បាន ប៉ុន្តែស្ថិតនៅក្នុងបែបបទថា ត្រូវបោះត្រាចេញចូល ...។

១១. មន្ទីរពេទ្យស្តង់ដារអន្តរជាតិ បង្កើនជំនឿទុកចិត្តដល់ អ្នកទេសចរ និងវិនិយោគិន

ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការមន្ទីរពេទ្យ រ៉ូយ៉ាល់ ភ្នំពេញ,
ថ្ងៃទី ១៨ វិច្ឆិកា ២០១៤

... សូមបញ្ជាក់ផងដែរថា **នៅពេលដែលយើងមានមន្ទីរពេទ្យ(ទំនើប) ក្រៅពីការជួយដល់ប្រជាជនកម្ពុជាក្នុងការស្វែងរកការព្យាបាល យើងក៏អាចបង្កើនជំនឿទុកចិត្តថែមទៀត សម្រាប់អ្នកទេសចរ និងអ្នកវិនិយោគឲ្យមកកាន់ព្រះរាជាណាចក្រកម្ពុជា ... សម្រាប់ទេសចរដែលមានវ័យចំណាស់ ឬអ្នកទេសចរដែលព្រួយបារម្ភអំពីជម្ងឺ មុននឹងមកកម្ពុជា គេត្រូវដឹងថាតើកម្ពុជាមានកន្លែងព្យាបាល ឬកន្លែងសង្គ្រោះជម្ងឺរបស់គេឬអត់?** ... ពេលបោះសៀវភៅយោសនា ដើម្បីឲ្យទេសចរមកកម្ពុជា កុំភ្លេចប្រាប់គេថា មានមន្ទីរពេទ្យរ៉ូយ៉ាល់ភ្នំពេញផង ... អ្នកមានមួយចំនួនមុនសម្រេចចិត្តមកធ្វើទេសចរណ៍ ឬមុនសម្រេចចិត្តមកធ្វើវិនិយោគ ត្រូវដឹងថា កម្ពុជាមានអ្វីអាចជួយសង្គ្រោះ និងព្យាបាលជម្ងឺរបស់គេបានឬទេ ...។

១២. គោលនយោបាយបើកចំហរជើងមេឃ គិតពីសេដ្ឋកិច្ចជាតិទាំងមូល

ពិធីសម្ពោធស្ថានីយអ្នកដំណើរថ្មី នៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ,
ថ្ងៃទី ១៦ មីនា ២០១៦

... **នៅក្នុងក្របខណ្ឌនយោបាយបើកចំហរជើងមេឃ បើកចំហរជើងគោក និងបើកចំហរជើងទឹក យើងពិតជាមានតម្រូវការហេដ្ឋារចនាសម្ព័ន្ធ ដើម្បីទ្រទ្រង់ដល់ការអភិវឌ្ឍរបស់ប្រទេស។ ខ្ញុំអាចនិយាយបានថា តាមរយៈការអនុវត្តនូវគោល**

នយោបាយបើកចំហរជើងមេឃនោះហើយ ដែលតម្រូវឲ្យយើងបានកែសម្រួលកិច្ចព្រមព្រៀងជាបន្តបន្ទាប់ ... យើងមិនបានគិតអំពីបញ្ហាតើក្រុមហ៊ុនអាកាសចរណ៍ណា ចំណេញ ឬខាតទេ ប៉ុន្តែពីសេដ្ឋកិច្ចជាតិទាំងមូលតែម្តង។ ពេលនោះ អ្នករកស៊ីសេវាទេសចរណ៍នៅទីក្រុងភ្នំពេញមានប្រតិកម្មយ៉ាងខ្លាំង ជាមួយនឹងការបើកចំហរអោយមានការចុះចតនៅសៀមរាប។ ប៉ុន្តែក្រោយមក គេបានឃើញច្បាស់ថា របៀបដែលយើងបានធ្វើនោះ ពិតជាត្រឹមត្រូវ ...។

១៣. បញ្ហាអ្នកបើករថយន្ត ដឹកភ្ញៀវទេសចរ

ពិធីបិទសន្និបាតក្រសួងទេសចរណ៍, ថ្ងៃទី ០៤ ខែ កក្កដា ២០១២

... ឯកឧត្តម ថោង ខុន បញ្ជាក់ថា បាន**រៀបចំព្រៀងការណែនាំអន្តរក្រសួង រវាងក្រសួងសាធារណការ និងក្រសួង(ទេសចរ) លើអ្វីដែលខ្ញុំបានលើកឡើងនៅខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី ៧ ខែ មិថុនា ក្នុងពិធីសម្ពោធបើកការដ្ឋានផ្លូវលេខ ៥៦ ឲ្យយកចិត្តទុកដាក់លើបញ្ហារថយន្តដឹកភ្ញៀវទេសចរ**។ ចុងក្រោយនេះ យើងឃើញមានគ្រោះថ្នាក់កើតឡើង ចំពោះរថយន្តដឹកភ្ញៀវទេសចរធនធំ នៅឯខេត្តកោះកុង ដែលបានធ្វើឲ្យជនជាតិរុស្សីម្នាក់ស្លាប់។ **ត្រូវបង្កើនការយកចិត្តទុកដាក់ មិនត្រឹមតែសម្រាប់វិស័យទេសចរណ៍ទេ គឺសម្រាប់ទាំងអស់។ ការកាន់ចង្កូតសម្រាប់រថយន្តធននេះ ត្រូវធានាឲ្យបាន ព្រោះមនុស្សជិះច្រើនណាស់ ក្នុងហ្នឹងមានទាំងទេសចរបរទេស។ ក្រុមហ៊ុននានា ត្រូវទទួលខុសត្រូវ ក្នុងការរៀបចំអ្នកបើកបរយ៉ាងម៉ាចដើម្បីធានាសុវត្ថិភាព** គ្មានអ្នកណាយកជីវិតមកបោះចោលនៅ កន្លែងខ្វះសុវត្ថិភាពទេ ...។

១៤. កសាងហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់មកតំបន់ឆ្នេរ និងក្នុងតំបន់ឆ្នេរ

ពិធីបុណ្យសមុទ្រលើកទី ៥ ក្រោមប្រធានបទ «ទីក្រុងបៃតង ឆ្នេរស្អាត សមុទ្រខៀវ ស្រងាត់», ២៤ ធ្នូ ២០១៦

... ចំណុចទី ២ ដែលខ្ញុំចង់និយាយ ដើម្បីរក្សាតួនាទីជា តារានាទិសនិរតី កិច្ចការដែលត្រូវធ្វើ គឺកសាងហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់មកតំបន់ឆ្នេរ និងក្នុងតំបន់ឆ្នេរដោយផ្ទាល់ ... រាជរដ្ឋាភិបាលបានដកយកផ្លូវជាតិលេខ ៤ មកគ្រប់គ្រង ខ្លួន

ឯងវិញ ... ប្រឹងប្រែងធ្វើផ្លូវជាតិលេខ ៣ តភ្ជាប់ភ្នំពេញ/កំពត/កែប និងតភ្ជាប់មកផ្លូវជាតិលេខ ៤ វិញ ... ប្រឹងប្រែងធ្វើផ្លូវជាតិលេខ ៤៨ តភ្ជាប់ពីផ្លូវជាតិលេខ ៤ ទៅកាន់ខេត្តកោះកុង។ យើងបានខិតខំស្តារឡើងវិញនូវផ្លូវដែកពីទីក្រុងភ្នំពេញមកកាន់ទីក្រុងព្រះសីហនុ ... បាននិងកំពុងពង្រីកសមត្ថភាពព្រលានយន្តហោះកងកេង ... ទេសចរណ៍មិនគ្រាន់តែមកដេកនៅក្នុងក្រុងព្រះសីហនុ ប៉ុណ្ណោះទេ ប៉ុន្តែអាចឆ្លៀតធ្វើដំណើរទៅកាន់កែប ទៅកាន់កំពត។ គេអាចឆ្លៀតទៅកាន់បូកគោ គេអាចឆ្លៀតធ្វើដំណើរទៅកាន់កោះកុងជាដើម។ ខ្ញុំអំពាវនាវអោយបន្តការខិតខំកសាងហេដ្ឋារចនាសម្ព័ន្ធលើវិស័យទេសចរណ៍ ដូចជាសណ្ឋាគារ ភោជនីយ៍ដ្ឋាន និងរមណីយដ្ឋានដទៃទៀត ដែលជាផ្នែកទាក់ទាញក្នុងតំបន់ទេសចរណ៍ ហើយជាទេសចរណ៍ធម្មជាតិរបស់យើង ...។

១៥. រក្សាគង់វង្ស តំបន់ឆ្នេរ ឆ្នេរខ្សាច់ ព្រៃ ព្រៃកោងកាង និងបណ្តាកោះ

ពិធីបុណ្យសមុទ្រលើកទី ៥ ក្រោមប្រធានបទ «ទីក្រុងបៃតង ឆ្នេរស្អាត សមុទ្រខៀវស្រងាត់», ២៤ ធ្នូ ២០១៦

... រក្សាអោយបានគង់វង្សនូវតំបន់ឆ្នេរ ទាំងឆ្នេរខ្សាច់ ទាំងព្រៃ ពិសេសព្រៃកោងកាង និងបណ្តាកោះ។ បង្កើតរមណីយដ្ឋានទេសចរណ៍ កន្លែងកម្សាន្តអោយបានច្រើន ... បើចង់អោយតំបន់ឆ្នេររបស់យើងនៅតែបន្តស្រស់ស្អាត យើងទាំងអស់គ្នាត្រូវខិតខំការពារតំបន់ឆ្នេរទាំងអស់ អោយនៅតែរក្សាបានតំណែងជាតំបន់ឆ្នេរស្អាត នៅមានព្រៃ ពិសេសព្រៃកោងកាង ដែលជៀសវាងនូវការបំផ្លិចបំផ្លាញណាមួយ។ ខ្ញុំនិយាយតាមត្រង់ ខ្ញុំដើរច្រើនណាស់នៅលើពិភពលោកនេះ ... ឆ្នេរសមុទ្រដែលខ្ញុំនឹកឃើញថាប្រហាក់ប្រហែលអូរឈើទាល គឺសមុទ្រនៅ Sierra Leone របស់អាហ្វ្រិកឯណោះ ...។

១៦. រក្សាបរិស្ថានល្អ ទាំងទឹក ខ្យល់ និងធម្មជាតិ

ពិធីបុណ្យសមុទ្រលើកទី ៥ ក្រោមប្រធានបទ «ទីក្រុងបៃតង ឆ្នេរស្អាត សមុទ្រខៀវស្រងាត់», ២៤ ធ្នូ ២០១៦

... ត្រូវរក្សាអោយបាននូវបរិស្ថានទាំងទឹក ទាំងខ្យល់ ទាំងធម្មជាតិ។ សំណល់រឹង ឬរាវ មិនត្រូវបញ្ចូលទៅក្នុងសមុទ្រ ហើយក៏មិនគប្បីផ្តល់ការអនុញ្ញាត អោយមានការសាងសង់ឧស្សាហកម្មណាដែលប៉ះពាល់ដល់បរិស្ថាន និងប៉ះពាល់ដល់តំបន់ទេសចរណ៍មាត់សមុទ្រ ឆ្នេរសមុទ្រនោះទេ្បីយ។ ចំណុចនេះ សំខាន់ខ្លាំងណាស់សម្រាប់យើងទាំងអស់គ្នា។ ប្រសិនបើអ្វីៗ ត្រូវបង្ហូរចូលទៅក្នុងទឹក តើទឹករបស់យើងត្រូវងូតរបៀបណាទៅ។ ខ្ញុំអបអរសាទរជាមួយនឹងការធ្វើអោយដំណើរការចម្រោះទឹក មុនបញ្ចូលទៅក្នុងសមុទ្រ។ ត្រូវបន្តការខិតខំ ហើយផ្នែកនេះ ទាំងវិស័យរដ្ឋ ទាំងវិស័យឯកជន ត្រូវរួមគ្នាការពារតំបន់ឆ្នេររបស់យើង ...។

ធនធានទឹក និងខ្យុតនិយម

១	ជីកអណ្តូង/ស្រះថ្មី ស្តារអណ្តូង/ស្រះចាស់ ត្រៀមការអត់ទឹកឆ្នាំខាងមុខ	៩៣
២	បូមទឹកបំពេញអាងតាមដងទន្លេមេគង្គ ទន្លេបាសាក់ និងទន្លេសាប	៩៣
៣	រំលាយ កែសម្រួលអាង ទប់ស្កាត់ការរានដីព្រៃលិចទឹកបឹងទន្លេសាប	៩៤
៤	ស្តារព្រែកនាំទឹកចូល នាំដីល្បាប់ចូល និងនាំកូនត្រីចូល(ចូលបឹង)	៩៤
៥	អនុវត្តលទ្ធិវ៉ាតទីនិយមផ្នែកទឹក	៩៥
៦	ធារាសាស្ត្រផ្ដ៏គោ បង្កើនការស្រោចស្រពកំពង់ចាម ព្រៃវែង ស្វាយរៀង	៩៥
៧	យុទ្ធនាការ អភិវឌ្ឍទិសខាងលិច និងទិសខាងជើង នៃរាជធានីភ្នំពេញ	៩៦
៨	រៀបចំប្រព័ន្ធដោះទឹក ដោះស្រាយការប្រឈមនឹងជំនន់ រយៈពេលវែង	៩៧
៩	ធារាសាស្ត្រជួយកសិករអនុវត្តកសិកម្មតាមបែបស៊ីជំរៅ (ធ្វើបានពីរដង)	៩៧
១០	វិស្វករកម្ពុជាធ្វើការសិក្សាគំរោងលឿន និងមិនមានតម្លៃសិក្សា	៩៨
១១	ទំនប់ចារ៉ែត នឹងក្លាយជាតំបន់កសិទេសចរណ៍	៩៩
១២	បង្កើតក្រសួងធនធានទឹក បង្កើនផ្ទៃស្រោចស្រប់ ៤% ក្នុង ១ ឬ ២ ឆ្នាំ	៩៩
១៣	កន្លែងមានទឹកសូមបង្កបង្កើនផល និងបង្កើនទិន្នផលច្រើន	១០០
១៤	ស្តារដែសមុទ្រអោយជ្រៅ	១០០

១. ជីកអណ្តូង/ស្រះថ្មី ស្តារអណ្តូង/ស្រះចាស់ ត្រៀមការអត់ទឹកនៅឆ្នាំខាងមុខ។

ពិធីប្រកាសផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ជាផ្លូវការ «គោលនយោបាយជាតិប្រជាជន ២០១៦-២០៣០», ថ្ងៃទី ៣ ឧសភា ២០១៦

... ស្ថិតនៅក្នុងស្ថានភាព ដែលព្រះរាជាណាចក្រកម្ពុជាកំពុងតែអនុវត្តនូវយុទ្ធនាការទ្រង់ទ្រាយធំដោះស្រាយទឹកជូនប្រជាជន ... ភ្លៀងបានធ្លាក់ក្នុងតំបន់មួយចំនួន បានថែមទៅដល់ខ្យល់កន្ត្រាក់ ធ្វើឲ្យប្រជាពលរដ្ឋមួយកន្លែងខ្លះ ទទួលបានទឹក ក៏ប៉ុន្តែ(ខ្លះទៀត)ក៏ទទួលបាននូវមហន្តរាយផ្សេងទៀត ដូចការបាក់ផ្ទះ បាក់ដើមឈើ ឬក៏រន្ទះបាញ់ជាដើម ... **មិនទាន់នឹងចប់ទេ យុទ្ធនាការ(ផ្គត់ផ្គង់) នឹងបន្តលាតសន្ធឹងទូទាំងប្រទេសតទៅទៀត លុះត្រាតែប្រជាជនមានទឹកទទួលទានគ្រប់គ្រាន់ ... កន្លែងដែលមានទឹកប្រើប្រាស់ហើយ ត្រូវបង្វែរនៅកន្លែងនោះ ពីការផ្គត់ផ្គង់ទឹកតាមផ្ទះ ទៅជាសកម្មភាពជីកអណ្តូងថ្មី ស្តារអណ្តូងចាស់ ជីកស្រះថ្មី ស្តារស្រះចាស់ និងស្តារប្រឡាយ ត្រៀមលក្ខណៈទប់ទល់បាតុភូតបែបនេះនៅឆ្នាំក្រោយៗទៀត ...**។

២. បូមទឹកបំពេញអាង នៅតាមដងទន្លេមេគង្គ ដងទន្លេបាសាក់ និងដងទន្លេសាប

ពិធីចែកសញ្ញាបត្រនិស្សិតនៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជា,
ថ្ងៃទី ៣ តុលា ២០១៦

... សូមអំពាវនាវប្រជាពលរដ្ឋរបស់យើងមេត្តាថែទាំទឹក។ សូមជូនជាព័ត៌មានទៅលើបញ្ហាពាក់ព័ន្ធជាមួយនឹងរឿងទឹក។ យើងអាចនិយាយបានថា រឿងគ្រោះទឹកជំនន់នឹងមិនមានទេ បើសិនជាមាន គឺមានត្រឹមតែជំនន់ទឹកភ្លៀងនៅតំបន់ខ្លះតែប៉ុណ្ណោះ។ ជំនន់មេគង្គ អាចថាចប់ហើយ។ ការព្យាករណ៍កាលពីដើមរដូវថា ទឹកនៅទីក្រុងភ្នំពេញបាន ៩,៣០ ម៉ែត្រ ប៉ុន្តែគិតកម្ពស់ទឹកដែលវាឡើងដល់កម្រិតអតិបរមារបស់វានៅថ្ងៃទី ២២ ខែកញ្ញា ទឹកបានតែ ៨,១៣ ម៉ែត្រតែប៉ុណ្ណោះ។ ដូច្នេះ ស្ថានភាពនេះ **តម្រូវអោយក្រសួងធនធានទឹក និងឧតុនិយម អន្តរាគមន៍ពីអាទិត្យរួចមកហើយ ធ្វើការបូមទឹកមួយចំនួន បំពេញអាងនៅតាមដងទន្លេមេគង្គ ដងទន្លេបាសាក់ និងដងទន្លេសាបរបស់យើងនេះ ដើម្បី(ឆ្លើយ**

គប)គម្រូវការធ្វើស្រែប្រាំង ធ្វើស្រែប្រដេញទឹករបស់ប្រជាពលរដ្ឋរបស់យើង ... ប្រជាជនខ្លួនឯងទប់ទឹកដើម្បីនឹងប្រើប្រាស់សម្រាប់ការបង្កបង្កើនផល មិនថាស្រែវស្សា មិនថាស្រែប្រដេញទឹក ឬស្រែប្រាំងនោះទេ ...។

៣. រំលាយចោល កែសម្រួលអាងទឹក និងទប់ស្កាត់ការរានយកដីព្រៃលិចទឹកបឹងទន្លេសាប

ប្រារព្ធទិវាមច្ឆាជាតិ, ថ្ងៃទី ០១ កក្កដា ២០១១

... យើងបានដំណើរការមួយដំហានហើយ **លើការទប់ស្កាត់កែសម្រួលរំលាយចោល កែសម្រួលអាងទឹក និងទប់ស្កាត់ការរានយកដីនៅតាមព្រៃលិចទឹកបឹងទន្លេសាប។ បន្ទាប់ទៅ យើងអនុវត្តដំណាក់កាលទី ១ នៃការរុះរើបំផ្លាញចោលព្រួល, ធ្នូល, សម្រាស់ នៅក្នុងអាងបឹងទន្លេសាប។ ប៉ុន្តែក៏មានការមើលស្រាលថាការធ្វើនេះត្រឹមតែរយៈពេលខ្លី ... តែខ្ញុំព្រះករុណាខ្ញុំ ប្រកាសជំរុញការអនុវត្តការពារបឹងទន្លេសាប ដែលជាបឹងដ៏សំខាន់បំផុត សម្រាប់ទ្រទ្រង់ជីវិតជាតិខ្មែរ បើសិនជាអន្តរាយបឹងទន្លេសាប ស្ពឹកក៏វាមិននៅដែរ**។ ឧទាហរណ៍ថា វាគោកវាក់ តើមានកន្លែងណាដែលអាចស្រូបយក កាត់បន្ថយទឹកជំនន់មេគង្គក្រោម ...។

៤. ស្តារព្រែកនាំទឹកចូល នាំដីល្អាប់ចូល និងនាំកូនត្រីចូល(ចូលបឹង)

ពិធីបិទកិច្ចប្រជុំ ស្តីពីវិធានការ និងការការពារតំបន់បឹងទន្លេសាប,
ថ្ងៃទី ១២ សីហា ២០១០

... **យើងខិតខំរកទុន ដើម្បីស្តារបូមនៅតំបន់ទន្លេ ដែលមានការគោកវាក់មួយចំនួន ... រាប់រយព្រែក ចាប់ពីស្ទឹងត្រែង រហូតដល់ព្រៃវែង កណ្តាល ព្រំដែនវៀតណាម ត្រូវបានគោកវាក់។** នៅផ្នែកខាងក្រោមសំណាងហើយ ដែលជប៉ុនបានជួយស្តារព្រែក នៅផ្លូវជាតិលេខ ១ តាមការពិតកន្លែងហ្នឹងខ្ញុំឱ្យ លឹម គានហោ កាត់ទេ ឆ្នាំ ២០០០ ព្រោះបើមិនកាត់អាហ្នឹង ទឹកបុកចូលភ្នំពេញត្រឹប ... ២ ថ្ងៃ ក្រោយ កាត់ផ្លូវជាតិលេខ ២ មួយទៀត ព្រោះជំនន់មកពីខាងលិច។ ពីដើមតំបន់ហ្នឹង ជាតំបន់ដែលមានព្រែក តែសម័យ ប៉ុល ពត បានកាត់ រឿងវាអញ្ចេះ ហើយក្រោយមក ខាងជប៉ុនក៏បានជួយស្តារព្រែកហ្នឹងវិញ។ **ការស្តារព្រែកនេះ មានសារសំខាន់ណាស់ នាំដីល្អាប់ចូល ហើយនឹងនាំទឹកចូល កាត់បន្ថយនូវ**

ជំនន់ប៉ុន្តែមួយផ្នែកទៀត បាននាំកូនត្រីសន្ទីកសន្ទាប់ចូល ...។

៥. អនុវត្តលទ្ធិវាតទីនិយមផ្នែកទឹក

សម្ពោធប្រព័ន្ធធារាសាស្ត្រចារឹក, ថ្ងៃទី ២១ ខែមីនា ២០០៩

... ទំនប់នេះ មានទ្វារទឹកស្វ័យប្រវត្តិ ៨ និងទ្វារបើកដោយដៃចំនួន ២, វាជាទំនប់ផង និងជាស្ពានឆ្លងកាត់បានទៀត គឺឡានតូចៗ អាចបើកកាត់បាន។ ... ប្រឡាយមេមានប្រវែង ១១ គីឡូម៉ែត្រ ... ផែនការរបស់យើងមិនគ្របដណ្ដប់ត្រឹមតែស្រូវវស្សា ១១.០០០ ហិកតា, ស្រូវប្រាំង ៣.៥០០ ហិកតា និងដីចំការ ២១០ ហិកតាទេ ... **គោលដៅរបស់ខ្ញុំព្រះករុណាខ្ញុំ នៅក្របខណ្ឌ ទូទាំងប្រទេស ត្រូវធ្វើអនុត្តរភាពធារាសាស្ត្រ, និយាយតាមមួយបែបគឺវាតទីនិយមផ្នែកទឹក។ កាលពីដើម គេប្រើពាក្យអនុត្តរភាពហ្នឹង ច្រើនតែប្រទេសមួយឈ្លានពានប្រទេសមួយ ដើម្បីពង្រីកទឹកដី មនោគមន៍វិជ្ជា ... តែឥឡូវ សម្រាប់កម្ពុជា គឺកំពុងអនុវត្តលទ្ធិវាតទីនិយមផ្នែកទឹក។ អញ្ចឹង ប្រព័ន្ធស្រោចស្រពនីមួយៗ ត្រូវតែប្រើប្រាស់សក្តានុពលទឹកដែលមាន ...។**

៦. អភិវឌ្ឍធារាសាស្ត្រវ៉ែគោ បង្កើនសមត្ថភាពស្រោចស្រពកំពង់ចាម ព្រៃវែង ស្វាយរៀង

ប្រារព្ធទិវាមច្ឆាជាតិ, ថ្ងៃទី ០១ កក្កដា ២០១១

... **សូមជូនពត៌មានចំពោះប្រជាពលរដ្ឋនៅខេត្តស្វាយរៀង ក៏ដូចជាព្រៃវែង កំពង់ចាម យើងបានចុះហត្ថលេខាជាមួយមិត្តចិន ... កាលពី(ទស្សនកិច្ច)ថ្ងៃ ១៣ ខែធ្នូ ឆ្នាំ ២០១០ ឆ្នាំទៅនេះ បានចុះហត្ថលេខាជាមួយនិងសាធារណរដ្ឋប្រជាមានិតចិនទឹកប្រាក់ចំនួន ៣០០ លានដុល្លារសហរដ្ឋអាមេរិក។ ក្នុង ៣០០ លានដុល្លារសហរដ្ឋអាមេរិក យើងរកមកប្រើគម្រោងអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រវ៉ែគោចំនួន ១០០ លាន ... គ្របដណ្ដប់វិសាលភាពចាប់តាំងពីខេត្តកំពង់ចាមកាត់ខេត្តព្រៃវែង រហូតមកទល់ជាមួយនឹងទន្លេវ៉ែគោនៃខេត្តស្វាយរៀង គឺត្រូវជីកព្រែក ៤០ គីឡូម៉ែត្រ** ពីស្រុកកោះសូទិន ខេត្តកំពង់ចាម ទៅដល់ឃុំតាដុក ស្រុកកំចាយមារ ខេត្តព្រៃវែង ... បើជំហានទាំងអស់នៃទន្លេវ៉ែគោនេះ សម្រេចបានទាំងជំហានទី ១ និងជំហានទី ២ នេះ ផ្ទៃដីស្រោចស្រពទាំងខេត្តកំពង់ចាម

ព្រៃវែង និងស្វាយរៀង គឺជាង ២៤ ម៉ឺនហិកតា ហើយដែលយើងអាចធានាបានថា តំបន់ខ្ទះទឹកនេះ គឺជាតំបន់ដែលទទួលបានសមិទ្ធផលសម្រាប់ប្រជាពលរដ្ឋពឹងផ្អែកក្នុងការអភិវឌ្ឍវិស័យកសិកម្ម ...។

៧. យុទ្ធនាការ អភិវឌ្ឍទិសខាងលិច និងទិសខាងជើង នៃរាជធានីភ្នំពេញ

ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់នូវអគារសិក្សាចំនួន ២ ស្រុកអង្គស្នួល ខេត្តកណ្តាល, ១៩ មិថុនា ២០១៣

... អង្គស្នួល ជាផ្នែកមួយនៃបណ្តាស្រុកដែលស្ថិតនៅក្នុងវង្វង់នៃប្រតិបត្តិការអភិវឌ្ឍទិសខាងលិចទីក្រុងភ្នំពេញ ... ខាងអង្គស្នួលយើងនេះ ទៅសំរោងទងជាប់ច្បារមន ហើយខាងផ្នែកគងពិសីហ្នឹងគឺថា នៅក្នុងផែនការនៃការអភិវឌ្ឍទិសខាងលិច នៃរាជធានីភ្នំពេញ។ មានមួយផ្នែកដែរ ភ្ជាប់ជាមួយការអភិវឌ្ឍទិសខាងជើង នៃរាជធានីភ្នំពេញ ... **ប្រហែលជាប្រជាពលរដ្ឋយើងនៅចាំបានការរាំងស្ងួតឆ្នាំ ២០០២។ ពេលនោះយើងបង្កើតឡើងនូវស្ថានភាពធ្វើម៉េចដោះស្រាយបញ្ហាឲ្យបានសិន គឺទាញទឹករលាំងជ្រៃផ្នែកខាងជើងនេះបន្តភ្ជាប់គ្នាសិន ... អម្បាញ់មិញ ខ្ញុំព្រះករុណាខ្ញុំ ដើរកាត់តាមប្រឡាយហ្នឹង, ទាញពីកំពង់ស្ពឺ ដើម្បីកាត់ទាំងសំរោងទង ច្បារមន អង្គស្នួល ទម្លាក់ទៅដល់ខ័ណ្ឌដង្កោ។** កាលហ្នឹង ទាញ(ទឹក) ឲ្យបានសិន បានគេហៅថា ប្រឡាយតាហោ ខាងត្បូង (**លឹម គានហោ**) នៅមានប្រឡាយតាហោខាងជើងទៀត ... ផ្នែកខាងត្បូងស្ទឹងព្រៃកត្នោតនោះ គេហៅថារលាំងជ្រៃត្បូង អាហ្នឹងកាត់ទាំងកំពង់ស្ពឺ ឆ្លងគងពិសី ហើយកាត់មួយភាគទៅដល់បាទី ទៅដល់ផ្លូវជាតិលេខ ៣ ដែល**យើងទម្លាក់ទឹកទៅអុំទូកនៅរលាំងកែន ដើម្បីបង្ហាញថា យើងមានលទ្ធភាពទាញទឹកយកមកប្រើប្រាស់។** ឥឡូវ**យើងកំពុងបន្តនូវផែនការរបស់យើង មានប្រឡាយរងរហូតដល់ ៨២ ខ្សែ ដែលមានចម្ងាយដល់ទៅ ៧២ គីឡូម៉ែត្រ សម្រាប់វិស័យកសិកម្ម។ ប៉ុន្តែ វិស័យកសិកម្ម មួយមិនគ្រប់គ្រាន់ទេ។ ការអភិវឌ្ឍ វាមិនមែនពឹងផ្អែកតែចំណែកណាមួយ ហើយ បោះបង់ចំណែកណាមួយទេ។ អ្វីដែលយើងអាចធ្វើបាន ក៏ត្រូវតែធ្វើ ...**។

៨. រៀបចំប្រព័ន្ធដោះទឹក ដោះស្រាយការប្រឈមនឹងជំនន់ រយៈពេលវែង

ពិនិត្យស្ថានភាពទឹកជំនន់ និងសួរសុខទុក្ខប្រជាពលរដ្ឋស្រុកបារាយណ៍ ខេត្តកំពង់ធំ, ២៥ កញ្ញា ២០១១

... ឆ្នាំនេះ ជាទូទៅ ជំនន់បានកើតឡើងតាមទន្លេមេគង្គ និងមកជួបគ្នាតាមបណ្តាខេត្ត ដែលមានទឹកភ្លៀងធ្លាក់ខ្លាំង ហើយធ្ងន់ជាងគេ គឺខេត្តកំពង់ធំនេះឯង (និងខេត្តដទៃទៀត) ... **កន្លែងខ្លះ ទឹកខាងធ្វេងដៃ(នៃផ្លូវ) កន្លែងខ្លះទឹកខាងស្តាំដៃ(នៃផ្លូវ) វាប្រហាក់ប្រហែលគ្នា តែមានកន្លែងខ្លះ ខាងស្តាំដៃខ្ពស់ជាង អាចហូរចេញទៅបាន។ ក្នុងចំណុចនេះ យើងបានពិចារណាថា តើគួរកាត់ផ្លូវជាតិលេខ ៦ ដើម្បីរំដោះការលិចលង់ផ្នែកខាងលើរបស់ខេត្តកំពង់ធំ ឬទេ?** ស្ថានភាពនេះ មិនដូចស្ថានភាពឆ្នាំ ២០០០ នៃទីក្រុងភ្នំពេញ(ទេ)។ (កាលនោះ ការ)គម្រាមកំហែងធ្ងន់ធ្ងរណាស់ តម្រូវឲ្យយើងកាត់ផ្លូវជាតិលេខ ១ ដើម្បីរំដោះទឹក ... ដល់ជំនន់ព្រែកត្នោតពីទិសខាងលិច (ខ្ញុំបាន)បញ្ជាឲ្យកាត់ផ្លូវជាតិលេខ ២ ដើម្បីបញ្ចៀសការលិចលង់ទីក្រុងភ្នំពេញខាងផ្នែកដង្កោ។ **បើនិយាយពីផ្លូវជាតិលេខ ៦ នេះ កាត់វាអត់បាន ហើយតិចបំផុតត្រូវកាត់ ១០ កន្លែង។ បើកាត់ផ្លូវនេះមិនខុសពីកាត់សរសៃឈាមរបស់យើង ព្រោះចរាចរណ៍ផ្លូវជាតិលេខ ៦ នេះ ជាចរាចរណ៍ធំណាស់ សម្រាប់សេដ្ឋកិច្ចរបស់ប្រទេស ... ត្រូវរកដំណោះស្រាយរយៈពេលវែងវិញ នៅក្នុងការដែលយើងរៀបចំប្រព័ន្ធដោះទឹកសម្រាប់ផ្លូវនេះ ដើម្បីកុំឲ្យឆ្នាំណាដូចឆ្នាំណាអញ្ចឹង ...**។

៩. ធារាសាស្ត្រ ជួយប្រជាកសិករ អនុវត្តកសិកម្មតាមបែបស៊ីជំរៅ (ធ្វើបានពីរដង)

សំណេះសំណាលជាមួយប្រជាពលរដ្ឋ ក្នុងពេលចុះពិនិត្យការងារបង្កបង្កើនផល ឃុំសន្ទុង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល, ២ សីហា ២០១៣

... ចាប់ផ្តើមដំបូង យើងធ្វើប្រឡាយដោយមិនទាន់មាំទាំ គឺធ្វើម៉េចឱ្យទាញទឹកមកបានសិន ហើយដាក់ស្ថានីយបូមទឹកម៉ាក ហ៊ុន សែន ទី ៤៤ មួយគ្រឿង ហើយបណ្តែតទៀត ... ក្រោយមកយើងបានប្រឡាយហ្នឹង ហើយ ២០០៦ ខ្ញុំមកចុះឧទ្ធម្ភាចក្រនៅទីនេះ ហើយលើកសំណូមពរបន្ថែមម៉ាស៊ីនបូមទឹក និង

សម្តេចជួយធ្វើស្ពានឆ្លងកាត់ ព្រោះកាលហ្នឹងអត់ទាន់ធ្វើស្ពានទេ ... ខ្ញុំបានប្រាប់ឯកឧត្តម លឹម គានហោ ថា **ត្រូវធ្វើអនុត្តរភាពទឹក មានន័យថា ធ្វើឲ្យទឹកវ៉ាតទីពង្រីកប្រព័ន្ធស្រោចស្រពនេះ ដោយរៀបចំជាប្រឡាយបន្ថែម ទាំងប្រឡាយមេ ទាំងប្រឡាយរង រៀបចំគេហៅថា សំណង់សិល្បការ** ដើម្បីបញ្ជាល់ទឹក ព្រោះបើយើងត្រូវបញ្ជូនទឹកទៅរកាជន្លឹង ទាល់តែយើងបិទអានោះសិន ទើបយើងបញ្ជូនទៅរកាជន្លឹង ហើយបានយើងបើកទម្លាក់មកខាងណោះ ... ថ្ងៃនេះ ខ្ញុំចង់ពិនិត្យការដ្ឋានមួយដែលខ្ញុំបានប្រគល់ភារកិច្ចឲ្យឯកឧត្តម លឹម គានហោ ឯកឧត្តម អូនព័ន្ធមុន្នីរ័ត្ន និង ក្រុមការងារគណបក្សប្រជាជន តើដល់ណាហើយ។ ខ្ញុំបានសួរថា តា ធីម មាន(ដី) ១ ហិកតា។ **គាត់ថា កាលពីមុននោះ គាត់ធ្វើបានតែម្តងទេ ឥឡូវនេះ គាត់ធ្វើស្រូវពង្រៃសនៅចុងខែ ៨ ចាប់ផ្តើមច្រូត រួចហើយបានចាប់ផ្តើមធ្វើម្តងទៀត។ បើអញ្ចឹងទេ តំបន់នេះ ជាតំបន់ដែលយើងចាប់ផ្តើមចូលទៅក្នុងអ្វីដែលខ្ញុំនិយាយថា អនុវត្តតាមបែបស៊ីជម្រៅ ...**។

១០. វិស្វករកម្ពុជាធ្វើការសិក្សាគំរោងលឿន និងមិនមានតម្លៃសិក្សា

ពិធីសម្ពោធប្រព័ន្ធធារាសាស្ត្រចារ៉ែក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់,
ថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០០៩

... ខ្ញុំព្រះករុណាខ្ញុំ យកឱកាសនេះ ថ្លែងនូវការកោតសរសើរចំពោះការខិតខំរបស់ក្រសួងធនធានទឹក និងឧតុនិយម ជាពិសេស ឯកឧត្តមរដ្ឋមន្ត្រី លឹម គានហោ តែម្តង ដែលគាត់ជាអ្នកធារាសាស្ត្រតាំងពីដំណាក់កាលក្រោយឆ្នាំ ១៩៧៩ ... នេះ បើទុកឲ្យបរទេសសិក្សាវិញ មកដល់ពេលនេះ មិនទាន់សិក្សាចប់ទេ, ចាយលុយមិនទាន់អស់ គឺមិនទាន់សិក្សាចប់ទេ ... **គាត់យកតែទិន្នន័យយើង រួចហើយធ្វើរបាយការណ៍យកលុយតែប៉ុណ្ណឹង, ដល់យើងធ្វើ តម្លៃសិក្សាអត់មានទេ ... ប្រទេសរបស់យើងរាល់ថ្ងៃនេះ វិស្វករបស់យើងក៏មានចំនួនមិនតិចទេ។ អ្នកបច្ចេកទេសរបស់យើង ធ្វើការនៅទីនេះមិនតិចទេ, អ្នកបច្ចេកទេសរបស់យើងបានប្រើពេលវេលាមិនដល់ ២ ឆ្នាំទេ គឺខ្ទះ ៩ ថ្ងៃ បានគ្រប់ ២ ឆ្នាំ បង្កើតបាននូវសមិទ្ធផលនេះ ...**។

១១. ទំនប់ចារ៉ែត នឹងក្លាយជាតំបន់កសិទេសចរណ៍

ពិធីសម្ពោធប្រព័ន្ធធារាសាស្ត្រចារ៉ែក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់,
ថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០០៩

... ទំនប់នេះ មានទ្វារទឹកស្វ័យប្រវត្តិ ៨ និងទ្វារបើកដោយដៃចំនួន ២, វាជាទំនប់ផង និងជាស្ពានឆ្លងកាត់ដោយឡានតូចៗ បាន ... តំបន់នេះ ថ្ងៃក្រោយនឹងក្លាយទៅជាតំបន់កសិទេសចរណ៍។ ... គោលដៅរបស់ខ្ញុំព្រះករុណាខ្ញុំ នៅក្របខណ្ឌ ទូទាំងប្រទេស ត្រូវធ្វើអនុត្តរភាពធារាសាស្ត្រ, និយាយតាមមួយបែប គឺវាតទីនិយមផ្ទៃកទឹក ... ប្រព័ន្ធស្រោចស្រពនីមួយៗ ត្រូវតែប្រើប្រាស់សក្តានុពលទឹកដែលមាន។ អញ្ចឹងទេ ឯកឧត្តម ឆាយ សារ៉ែត ស្នើសុំនៅដំណាក់អំពិល ១៦ គីឡូម៉ែត្រ ដើម្បីបញ្ជូនទៅស្វាយដូនកែវ ឯកឧត្តម លឹម គានហោ ថាមានលុយហើយ គ្រាន់តែចាំការបញ្ជាក់ពីឯកឧត្តម គាត ឈន់ ប៉ុណ្ណឹងទេ។ រឿងធ្វើនៅតែធ្វើ ទោះបីត្រូវរកពីប្រភពណាក៏ត្រូវរកឲ្យបានដែរ ព្រោះរឿងអីយើងធ្វើទំនប់ប៉ុណ្ណឹងហើយ បែរជាយើងមិនធ្វើប្រឡាយរុញទឹកទៅ។ នេះកុំថាត្រូវដឹក ១៧ ខ្សែ ... ឧបមាថា ទំនប់នេះអាចទាញទឹកទៅដល់ណា គឺត្រូវដឹកតទៅទៀត ព្រោះធ្វើបានប៉ុណ្ណោះ ហើយរឿងអីយើងមិនពង្រីក, យើងធ្វើបានរហូតទប់ដល់ស្ទឹង រឿងអីយើងគ្មានលទ្ធភាពដឹកបណ្តាញចែកចាយ? នៅទីនេះ គឺប្រព័ន្ធធារាសាស្ត្រ បានសេចក្តីថា វាមានទំនប់ផង ប្រឡាយផង ប្រឡាយរងផង មានទាំងប្រឡាយរងទី ១ និងរងទី ២ ប៉ុន្តែ បញ្ជូលស្រែ សុំបញ្ជូលខ្លួនឯង ...។

១២. បង្កើតក្រសួងធនធានទឹក ពិចារណាបង្កើនផ្ទៃស្រោចស្រប់ ៤% ក្នុង ១ ឬ ២ ឆ្នាំ

ពិធីសម្ពោធប្រព័ន្ធធារាសាស្ត្រចារ៉ែក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់,
ថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០០៩

... មានកំហុសមួយ នៅត្រង់អញ្ចេះ។ តាមការពិត ក្រសួងធនធានទឹក និងឧតុនិយម គួរត្រូវបានបង្កើតកាលអំឡុងទសវត្សរ៍ទី ៨០ មិនត្រូវរង់ចាំបង្កើតរហូតដល់ចុងទសវត្សរ៍ទី ៩០ នោះទេ។ **ក្រសួងនេះ ត្រូវបានបង្កើតនៅចុងអាណត្តិទី ២ នៃរាជរដ្ឋាភិបាល ហើយពេលនោះ ខ្ញុំព្រះករុណាខ្ញុំ បង្កើតក្រសួងថ្មី ២ បន្ថែម**

ទៀត ព្រោះពេលហ្នឹងលែងមានសហនាយករដ្ឋមន្ត្រីទៀតហើយ។ អញ្ចឹង ត្រូវមានការគិតគូរបង្កើតក្រសួងធនធានទឹក និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម ... ឯកឧត្តម លឹម គានហោ នៅធ្វើជាប្រធាននាយកដ្ឋានធារាសាស្ត្រ ក្រោយមកបង្កើតទៅជាអគ្គនាយកដ្ឋានធារាសាស្ត្រ ក៏ធ្វើជាទីប្រឹក្សាខ្ញុំព្រះករុណាខ្ញុំ លើបញ្ហាទឹកហ្នឹង។ ដល់ទៅត្រៀមបង្កើតក្រសួងហ្នឹង ក៏**ហៅគាត់មកពិភាក្សាជាក់ចេញនៅក្នុងកម្មវិធីនយោបាយ និងផែនការថា តើយើងអាចមានសមត្ថភាព ក្នុងការពង្រីកផ្ទៃដីស្រោចស្រពក្នុង ១ ឆ្នាំ ឬ ២ ឆ្នាំ ទៅ ៤% ឬទេ? កាលហ្នឹង យើងមានការយឺតយ៉ាវបន្តិច ក្នុងការបង្កើតរាជរដ្ឋាភិបាល ដោយសារតែការតវ៉ា ...**។

១៣. កន្លែងមានទឹកសូមបង្ករបង្កើនផល និងបង្កើនទិន្នផលច្រើន

ពិធីសម្ពោធប្រព័ន្ធធារាសាស្ត្រចារឹក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់,
ថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០០៩

... អ្នកពោធិ៍សាត់ ដូចជាមិនពិបាក សុំត្រង់ថា បើមានទឹកហើយ សុំបង្ករបង្កើនផល។ ឆ្នាំនេះ ប្រហែលជាលោកយាយលោកតា ញាតិញោមទាំងឡាយ ដែលនៅជាប់ប្រឡាយមិនទាន់មានទឹក ដោយសារតែទឹកនេះទើបបញ្ជាល់ចូលមកដែរ តែកសិកររបស់យើងបានធ្វើមួយចំនួនដែរ, មានស្រូវប្រាំង និងដំណាំមួយចំនួនដោយប្រើប្រាស់ទឹកនេះ ... នៅទីនេះ ធ្លាក់ភ្លៀង ឬមិនធ្លាក់ភ្លៀង (ក็)នៅកែ្ស្ប ប្រឡាយមានទឹកទៅហើយ។ អញ្ចឹងទេ សូមចាប់ផ្តើមការងារបង្ករបង្កើនផល។ **អ្វីដែលខ្ញុំព្រះករុណាខ្ញុំ សុំមិនធំទេ សុំគ្រាន់តែថា មានទឹកត្រូវបង្ករបង្កើនផល មិនកំណត់ថាតែស្រូវនោះទេ គឺរាប់ទាំងបន្លែបង្ការ និងដំណាំផ្សេងៗទៀត ដែលអាចផ្តល់នូវប្រាក់ចំណូលឲ្យយើង, ឯសុំទី ២ សុំធ្វើម្តេច គឺធ្វើឲ្យបានផលច្រើន អញ្ចឹងទេ វាមានទាំងការប្រើពូជ របៀបប្រើជីស្ពីៗជាដើម ព្រោះអ្នកពោធិ៍សាត់នេះ ធ្លាប់ជួបប្រវត្តិស្រូវនាងពួន ... បង្កើនទិន្នផលអោយបានខ្ពស់ ...**។

១៤. ស្តារដែសមុទ្រអោយជ្រៅ

ចុះពិនិត្យទឹកជំនន់ និងការបង្ការខូចខាត នៅខេត្តកំពត, ៨ កញ្ញា ២០០៩

... ឆ្នាំនេះខុសពីឆ្នាំទៅនៅត្រង់ថា ឆ្នាំ ២០០៦ ទឹកតូចជាងនេះ ក៏ប៉ុន្តែស្រកទៅវិញយឺតជាងឆ្នាំនេះ។ **យើងត្រូវតែស្តារដែសមុទ្ររបស់យើងនេះឲ្យជ្រៅ ដើម្បីទាញទឹកធ្លាក់ទៅសមុទ្រឲ្យបានរហ័ស អាហ្នឹងមួយផ្នែក។ មួយផ្នែកទៀត នៅខាងលើ គឺផ្នែកស្ទឹងកែវ ដែលក្រសួងធនធានទឹក និងសាធារណរដ្ឋប្រជាមានិតចិន កំពុងសិក្សារួមគ្នា ដើម្បីធ្វើទំនប់នៅផ្នែកខាងលើ កាត់បន្ថយការទម្លាក់ទឹកមកទីរួមខេត្ត និងស្រុកទឹកឈូរ** ... ជាចំណុចដែលយើងត្រូវយកចិត្តទុកដាក់បន្ត ព្រោះគ្មានជម្រើសណាផ្សេងទេ ...។

ធម្មការ និងសាសនា

១	សុខដុមភាវូបនីយកម្មជនជាតិ/សាសនា ពង្រឹងសាមគ្គីភាព អភិវឌ្ឍ	១០៥
២	ចំណងទាក់ទងរវាងផ្នែករដ្ឋ និងសាសនា	១០៥
៣	ការរីកចំរើននៃសាសនា វាស់ស្ទង់បាន នយោបាយបក្សកាន់អំណាច	១០៦
៤	ការរីកចំរើននៃសាសនា វាស់ស្ទង់បាន ជំនឿពលរដ្ឋចំពោះសាសនា	១០៦
៥	ការរីកចំរើននៃសាសនា វាស់ស្ទង់បាន ជីវភាពប្រជាពលរដ្ឋ	១០៧
៦	ការរីកចំរើននៃសាសនា វាស់បាន ទំនាក់ទំនងសាសនានិងអាណាចក្រ	១០៧
៧	មានគ្រូ មានពេទ្យ ខ្វះអាចារ្យ/អាចារិនី	១០៨
៨	បណ្តុះបណ្តាលយាយជី រួមអភិវឌ្ឍសង្គម វប្បធម៌ ប្រពៃណីជាតិ	១០៨
៩	សមាគមអាចារ្យ ដើម្បីឯកភាព/សាមគ្គីភាព និងចំណេះដឹង	១០៩
១០	ហ៊ុន សែន ជានាយករដ្ឋមន្ត្រី សាសនានៅជាមួយគ្នាដោយសុខដុម	១០៩
១១	ការជួបប្រជុំរវាងសាសនា ផ្សេងគ្នា ដើម្បីផ្លាស់ប្តូរបទពិសោធន៍	១១០
១២	សិស្សនិស្សិតស្ត្រីខ្មែរឥស្លាមអាចស្លៀកពាក់របៀបឥស្លាម	១១០
១៣	បញ្ចូលគ្រូបង្រៀនឥស្លាម ក្នុងក្របខណ្ឌរដ្ឋ	១១១

១. សុខដុមភាវូបនីយកម្មជនជាតិ/សាសនា ពង្រឹងសាមគ្គីភាព អភិវឌ្ឍប្រទេស

ពិធីទទួលទានអាហារស្រាយ បួសវ៉ាម៉ាដន លើកទី ៣, ១៤ មិថុនា ២០១៦

... **ខ្ញុំមានមោទនភាពនឹងក្របខណ្ឌគោលនយោបាយកម្ពុជា ក៏ដូចជារាជរដ្ឋាភិបាល តាំងពីអតីតកាល ដែលចាត់ទុកនយោបាយធ្វើសុខដុមភាវូបនីយ កម្មជនជាតិ និងសាសនា ជាអាទិភាពមួយ ក្នុងចំណោមអាទិភាពនានា នៃគោលនយោបាយក្នុងប្រទេស និងក្រៅប្រទេសរបស់ខ្លួន ... អ្វីដែលបាន និងកំពុងកើតនៅ ព្រះរាជាណាចក្រកម្ពុជា នោះគឺសុខដុមភាវូបនីយកម្មរវាងជនជាតិ និងសាសនា** (ក្នុងពេល)ដែលនៅលើពិភពលោកបច្ចុប្បន្ន ពោរពេញទៅដោយភាពចលាចលការរើសអើង និងប្រកាន់និកាយសាសនា។ សម្រាប់ព្រះរាជាណាចក្រកម្ពុជា ប្រការទាំងនេះ មិនស្ថិតនៅក្នុងរបៀបវារៈនយោបាយ ដែលត្រូវដោះស្រាយនោះទេ ... វាស្ថិតក្នុងរបៀបវារៈនៃការថែទាំពង្រឹង សុខដុមភាវូបនីយកម្ម ពង្រឹងសាមគ្គីភាព ដើម្បីអភិវឌ្ឍប្រទេស...។

២. ចំណងទាក់ទងរវាងផ្នែករដ្ឋ និងសាសនា

ពិធីជួបសំណេះសំណាលជា មួយថ្នាក់ដឹកនាំគ្រឹស្តបរិស័ទ,២៤ មិថុនា ២០១៦

... សង្ឃឹមថាព្រឹទ្ធាចារ្យ បូជាចារ្យ និងគ្រូបង្រៀន និងថ្នាក់ដឹកនាំនៃគ្រឹស្ត បរិស័ទទាំងអស់ដែលមកពីគ្រប់ទីកន្លែង និងបន្តខិតខំរួមដំណើរជាមួយរាជរដ្ឋាភិបាលជាមួយសាសនាដទៃទៀត ដើម្បីការរីកចម្រើនរបស់ប្រទេស ... **ន័យរួមដែល ខ្ញុំធ្លាប់ប្រើចំណងទាក់ទងរវាងពុទ្ធចក្រ និងអាណាចក្រ ប៉ុន្តែ ពុទ្ធចក្ត្រូវបានតែព្រះពុទ្ធទេ។ ឥឡូវខ្ញុំ និយាយថាចំណងទាក់ទងរវាងអាណាចក្រ គឺថាផ្នែករដ្ឋ ជាមួយនឹងសាសនាវិញ ទូលំទូលាយជាង ... បើជីវភាពប្រជាពលរដ្ឋមិនល្អទេ មិនមានសុខសន្តិភាពទេ ហើយបែរជាប្រទេសមានសង្គ្រាម សួរថា តើសាសនាអាចស្ថិតស្ថេរឬអត់?** ដូច្នេះ វាសំខាន់ណាស់ ត្រូវការនូវចូលរួមរបស់គ្រប់តួអង្គពាក់ព័ន្ធនៅក្នុងសង្គម...។

៣. ការរីកចំរើននៃសាសនា វ៉ាស់ស្ទង់បានក្របខណ្ឌនយោបាយនៃបក្សកាន់អំណាច

ពិធីកាត់ឫសសីមាព្រះវិហារ និងសម្ពោធសមិទ្ធផល ក្នុងវត្តព្រៃកប្រា, ០៨ កុម្ភៈ ២០១៧

... ការរីកចម្រើន(នៃសាសនា)នេះ អាចជាម៉ែត្រវ៉ាស់ស្ទង់លើបញ្ហាអ្វីខ្លះ? ខ្ញុំព្រះករុណាខ្ញុំយល់ថា **ការរីកចម្រើននៅក្នុងវិស័យពុទ្ធចក្រ ឬនិយាយដោយទូលំទូលាយជាងនេះ គឺវិស័យសាសនាជារួម ដែលរួមមានសាសនា ទាំងព្រះពុទ្ធ ទាំងមូស្លីម ទាំងគ្រីស្ត និងសាសនាផ្សេងៗទៀត អាច(អោយ)វ៉ាស់(ស្ទង់)បាននូវចំណុចមិនតិចជាង ៤ ទេ។ ទី ១ វ៉ាអាចវ៉ាស់ស្ទង់បាននូវ ក្របខណ្ឌ នយោបាយ របស់បក្សកាន់អំណាចនោះឯង។ តើបក្សកាន់អំណាចបើកទូលាយនូវសេរីភាពប៉ុណ្ណា សម្រាប់ប្រជាពលរដ្ឋក្នុងជំនឿលើសាសនានេះ?** មានឧទាហរណ៍ច្បាស់លាស់ គឺសម័យសង្គមរាស្ត្រនិយម ព្រះករុណា សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ព្រះអង្គបានផ្តល់ឱកាសសំរាប់ប្រជាពលរដ្ឋយើងជឿសាសនាណាក៏បាន។ ចាប់ពីរដ្ឋប្រហារ ឆ្នាំ ១៩៧០ មក ទីអារាមមួយចំនួនក្លាយទៅជាបន្ទាយទាហាន ទីកន្លែងមួយចំនួន ក្លាយទៅជាកន្លែងគោលដៅនៃការវាយប្រហារដោយគ្រាប់បែករបស់អាមេរិកាំង របស់វៀតណាមខាងត្បូង និង របស់ពួក លន់ នល់ ...។

៤. ការរីកចំរើននៃសាសនា វ៉ាស់ស្ទង់បានជំនឿរបស់ពលរដ្ឋចំពោះវិស័យសាសនា

ពិធីកាត់ឫសសីមាព្រះវិហារ និងសម្ពោធសមិទ្ធផល ក្នុងវត្តព្រៃកប្រា, ០៨ កុម្ភៈ ២០១៧

... ម៉ែត្រវ៉ាស់ទី ២ គឺបញ្ជាក់អំពីជំនឿរបស់ប្រជាពលរដ្ឋទៅលើវិស័យសាសនាក្នុងហ្នឹងព្រះពុទ្ធសាសនា តើប្រជាពលរដ្ឋនៅជឿទៀតឬអត់? តាមរយៈការកសាងទីអារាមនេះឯង តាមរយៈការចូលរួមធ្វើបុណ្យធ្វើទាននេះឯង។ ប្រទេសមួយចំនួននៅលើពិភពលោកនេះ ប្រទេសខ្លះ ប្រជាជនភាគច្រើនអត់ជឿសាសនាណាទាំងអស់។ ប្រទេសមួយចំនួន ដែលខ្ញុំព្រះករុណាខ្ញុំមិនចាំបាច់ចេញឈ្មោះ សាសនាអីក៏គេមិនជឿដែរ ... នៅប្រទេសយើង ឆ្នាំនេះទទួលទេវតាចុះម៉ោង ៣ ភ្លឺអញ្ចឹងទៅ ... ជាការវ៉ាស់នូវជំនឿរបស់ប្រជាជនចំពោះព្រះពុទ្ធសាសនា ហើយ

ចំពោះផងដែរលើទីអារាមណាខ្លះ ... ជួនកាលវត្តក្បែរគ្នា តែវត្តនោះសម្បូរចង្ហាន់ជាង វត្តនេះអត់ចង្ហាន់។ មូលហេតុមកពីអី? មកពីគេអត់ជឿ។ អញ្ចឹងបានការកសាងជំនឿពីសំណាក់ពុទ្ធសាសនា ទីអារាម ចំពោះពុទ្ធបរិស័ទដែលជាអ្នកគាំទ្ររបស់ខ្លួន ជាបញ្ហាមួយធំ ...។

៥. ការរីកចំរើននៃសាសនា វាស់ស្ទង់បានពីជីវភាពប្រជាពលរដ្ឋ

ពិធីកាត់ឫសសីមាព្រះវិហារ និងសម្ពោធសមិទ្ធផល ក្នុងវត្តព្រៃកប្រា, ០៨ កុម្ភៈ ២០១៧

ទី ៣ ជាម៉ែត្រវាស់ការរីកចម្រើននៃជីវភាពប្រជាពលរដ្ឋ ទើបយើងកសាងបាន នូវទីអារាម និងវិហារសាសនាជាទៃផ្សេងៗទៀត។ ខ្ញុំព្រះករុណាខ្ញុំ សុំនិយាយត្រឹមតែក្របខណ្ឌនៃព្រះពុទ្ធសាសនាដែលទាក់ទងទៅនឹងការកសាងព្រះវិហារ និងសេនាសនៈ ជាទីសក្តារៈបូជាដទៃទៀត សម្រាប់ប្រជាពលរដ្ឋតែប៉ុណ្ណោះ។ បើគ្មានការរីកចម្រើននៃជីវភាពរបស់ប្រជាពលរដ្ឋទេ ព្រះសង្ឆដាច់ចង្ហាន់ហើយ ... នៅពេលដែលប្រជាជនជួបការលំបាក ជាគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត ពេលនោះហើយដែលចង្ហាន់របស់ព្រះតេជព្រះគុណ ក៏តិចតួចទៅតាមហ្នឹងដែរ ព្រោះប្រជាពលរដ្ឋរកតែបាយហូបខ្លួនឯងមិនបាន មានបាយឯណាទៅដាក់(ប្រគេន)ព្រះសង្ឆ? ប៉ុន្តែ នៅពេលដែលប្រជាជនរកស៊ីមានបាន មិនគ្រាន់តែមានចង្ហាន់ឆ្ងាញ់នោះទេ ក៏ប៉ុន្តែ នៅមានការចូលរួមកសាងនូវសមិទ្ធផលនានានៅក្នុងទីអារាមនោះផង។ នេះបង្ហាញឲ្យឃើញថា **ប្រទេសរបស់យើងបានចេញពីស្ថានភាពលំបាកលំបិន មកកាន់ស្ថានភាពមួយ ដែលល្អប្រសើរជាង បានជាប្រជាពលរដ្ឋមានឱកាសមកធ្វើបុណ្យធ្វើទាន។** ជាកត្តាសំណាងហើយ ដែលប្រជាពលរដ្ឋយើងបានធ្វើបុណ្យធ្វើទាន ដោយសារប្រទេសយើងមានសន្តិភាព ...។

៦. ការរីកចំរើននៃសាសនា វាស់ស្ទង់បានពីទំនាក់ទំនងរវាងសាសនា និងអាណាចក្រ

ពិធីកាត់ឫសសីមាព្រះវិហារ និងសម្ពោធសមិទ្ធផល ក្នុងវត្តព្រៃកប្រា, ០៨ កុម្ភៈ ២០១៧

... ទី ៤ អាចឲ្យដឹងពីទំនាក់ទំនងរវាងខាងវិស័យពុទ្ធចក្រ (សាសនា) និងវិស័យអាណាចក្រ។ បើគ្មានការរីកចម្រើននៃវិស័យអាណាចក្រទេ ពុទ្ធចក្រគ្មានផ្លូវរស់រានបានទេ ... ជួនកាលនៅពេលសង្គ្រាម គេចូលជុតបំផ្លាញវត្តអារាមផង។ ប៉ុន្តែវិស័យអាណាចក្រ យើងបានពន្លត់ភ្លើងសង្គ្រាមនៅក្នុងក្របខណ្ឌទូទាំងប្រទេស បន្ថែមទៅដោយការកសាងហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ ទៅកាន់ទីអារាមដែលនៅឆ្ងាយៗ។ មុននេះ មានទីអារាមមួយចំនួនដែលយើងទៅមិនដល់។ តែមកដល់ពេលនេះ យើងទៅដល់អស់ហើយ។ អញ្ចឹង វាបញ្ជាក់អំពីការរីកចម្រើនផ្នែកអាណាចក្ររុញឲ្យមានការរីកចម្រើនផ្នែកពុទ្ធចក្រ។ ចំណុចនេះ ត្រូវមើលឲ្យឃើញ។ របស់ដែលក្តាប់ជាប់ក្នុងដៃហើយ កុំឲ្យវារបូតតាមរយៈការសន្យាខ្យល់នៃជនជំពូកជនណាមួយនោះ ... ធម្មតាស្រមោលវាតែងធំជាងរបស់ពិត ...។

៧. មានគ្រូ មានពេទ្យ ខ្វះអាចារ្យ/អាចារិនី

ពិធីសម្ពោធវិទ្យាល័យ ហ៊ុន សែន ត្រពាំងឆ្នោត ខេត្ត កណ្តាល, ២១ ឧសភា ២០០៩

... (២០០៩) កំពុងស្ថិតក្នុងស្ថានភាពវិបត្តិអាចារ្យ។ ពីដើមវិបត្តិគ្រូបង្រៀន វិបត្តិពេទ្យ ឥឡូវចូលមកដល់ដំណាក់កាលថ្មីហើយ ចូលដល់វិបត្តិអាចារ្យ ... ថ្ងៃមុននិយាយលេងថា គិតបង្កើតក្រុមហ៊ុនអាចារ្យ។ ប៉ុន្តែ រឿងនេះរឿងពិត គួរតែក្រសួងធម្មការ និងសាសនា យកចិត្តទុកដាក់អំពីបញ្ហាហ្នឹង។ អាចារ្យពិតជាខ្វះ ព្រោះមួយថ្ងៃ១ មិនដឹងថាការប៉ុន្មាន កន្លែងខ្លះ(រៀបពិធី)ការអត់អាចារ្យទេ រួចអាចារ្យខ្លះក៏ភ្លេចទាំងស្រែកជយឃោស ... គ្រូកំពុងបណ្តុះបណ្តាលបាន ហើយពេទ្យក៏កំពុងតែបណ្តុះបណ្តាលបាន តែវាទៅជាដំណាក់កាលវិបត្តិអាចារ្យវិញម្តង ... ទាល់តែមានការបណ្តុះបណ្តាលមួយជាក់លាក់ មើលស្រាលមិនបានទេ ... នេះក៏ជាបញ្ហាដែលយើងត្រូវរៀបរយជាមួយវិស័យព្រះពុទ្ធសាសនា ...។

៨. បណ្តុះបណ្តាលយាយជី រួមចំណែកអភិវឌ្ឍសង្គម វប្បធម៌ ប្រពៃណីជាតិ

ពិធីប្រគល់វិញ្ញាបនបត្រជូន ដល់អាចារ្យចំនួន ៣២៥៥ រូប, ១៥ ឧសភា ២០១២

... ក្រសួងធម្មការ និងសាសនា ត្រូវយកចិត្តទុកដាក់រៀបចំវគ្គ បណ្តុះបណ្តាលយាយជី អោយមានតួនាទី និងការកិច្ចក្នុងការ រួមចំណែកអភិវឌ្ឍន៍សង្គម និង

អកិវឌ្ឍន៍វប្បធម៌ ប្រពៃណីជាតិរបស់យើង។ ... យាយជីក៏មានតួនាទីមួយខ្លាំងដែរ ក្នុងការជួយដល់វត្តអារាម និងជួយដល់ប្រជាពលរដ្ឋ ... ប៉ុន្តែការរៀបចំបណ្តុះបណ្តាលយាយជីនេះ មិនបង្កើតសាលានៅភ្នំពេញទេ តាមយោបល់ខ្ញុំព្រះករុណាខ្ញុំ ទៅបង្រៀនតាមវត្តបណ្តាយទៅស្រួល។ ប្រគល់តួនាទីហ្នឹងទៅ ព្រះចៅអធិការវត្ត និងគណៈកម្មការអាចារ្យវត្តហ្នឹង ត្រឹមត្រូវហើយ មិនចាំបាច់បង្កើតទៅជាវគ្គសិក្សានោះទេ.។

៩. សមាគមអាចារ្យ ដើម្បីឯកភាព/សាមគ្គីភាព និងចំណេះដឹង

ពិធីប្រគល់វិញ្ញាបនបត្រជូន ដល់អាចារ្យចំនួន ៣២៥៥ រូប, ១៥ ឧសភា ២០១២

... ក្រសួងធម្មការ និងសាសនា ត្រូវពង្រីកការចងសម្ព័ន្ធជាសមាគមអាចារ្យ និងរៀបចំអោយមានការប្រជុំប្រចាំឆ្នាំច្បាស់លាស់ ដើម្បីអោយអាចារ្យបានផ្លាស់ប្តូរយោបល់ និងចែករំលែកចំណេះដឹង ព្រមទាំងស្តាប់សំណូមពរនានា របស់ប្រជាពលរដ្ឋមកបំភ្លឺ។ ... **ធ្វើយ៉ាងម៉េចអោយយន្តការ(សមាគមអាចារ្យ)ដើរ ហើយអោយមានប្រសិទ្ធិភាព ដើម្បីម្ខាងសាមគ្គីភាព ក្នុងចំណោមអាចារ្យ និងការឯកភាពខាងទស្សនៈការប្រព្រឹត្ត និងមួយផ្នែកទៀត គឺទទួលយកនូវសំណូមពរចំណេះដឹង...**។

១០. ហ៊ុន សែន ជានាយករដ្ឋមន្ត្រី សាសនាទាំងអស់នៅជាមួយគ្នាដោយសុខដុម

ទស្សនកិច្ចនៅអង្គការសង្គ្រោះកុមារ និងជនអស់សង្ឃឹមពោធិសែនជ័យ,
ភ្នំពេញ, ថ្ងៃទី ២៥ ធ្នូ ២០១៥

... ទោះបីថា មកពីណាក៏ដោយ នៅទីនេះ គ្មានការរើសអើងណាមួយនៅប្រទេសនេះទេ។ ខ្ញុំអាចនិយាយបានថា ក្នុងដំណាក់កាលខ្ញុំធ្វើជានាយករដ្ឋមន្ត្រីច្បាស់ណាស់ថា សាសនាទាំងអស់នៅព្រះរាជាណាចក្រកម្ពុជា ទាំងព្រះពុទ្ធ ទាំងគ្រីស្ត ទាំងមូស្លីម និងសាសនាដទៃទៀត អាចរួមរស់នៅជាមួយគ្នាបានយ៉ាងសុខុមដុមរមនា។ ប៉ុន្តែមិនប្រាកដទេថា អ្នកដែលទៅបន្ត ពីក្រោយខ្ញុំ គេមានគោលនយោបាយដូចខ្ញុំឬអត់? នេះក៏ជាបញ្ហាត្រូវធ្វើការពិចារណាផងដែរ។ អ្នកដែលកំពុងធ្វើពិត គឺវាពិត ប៉ុន្តែអ្នកដែលសន្យា គឺវាមិនទាន់ពិតទេ។ អ្នកដែលគ្រាន់តែ

ប្រកាសចេញតាមពាក្យសំដី ឬតាមលាយលក្ខណ៍អក្សរ មិនទាន់ជាការពិតទេ...។

១១. ការជួបប្រជុំរវាងសាសនា ផ្សេងគ្នា ដើម្បីផ្លាស់ប្តូរបទពិសោធន៍

កិច្ចប្រជុំផ្សព្វផ្សាយ «ការបញ្ជាបទស្សនាទានសីលធម៌សាសនា ដើម្បីសុខដុម ការបនីយកម្មនៅកម្ពុជា», ថ្ងៃទី ១៤ ធ្នូ ២០១៥

... ចំណុចនេះ ក្រសួងធម្មការ និងសាសនាត្រូវតែធ្វើឲ្យបាន ដិតដល់ តាមរយៈ ការពិគ្រោះពិភាក្សាជាមួយថ្នាក់ដឹកនាំសាសនា ដែលយើងអាចមានកម្មវិធីជួបប្រជុំ គ្នា។ ពិតហើយ សាសនានីមួយៗ មានការជួបប្រជុំតាម វិហាររៀងៗខ្លួន ... **ប៉ុន្តែ ក្រសួងធម្មការនៅកម្រិតថ្នាក់ជាតិ ឬមន្ទីរធម្មការនូវកម្រិតថ្នាក់ក្រោមជាតិគប្បី យកចិត្តទុកដាក់រៀបការជួបជុំ ជាមួយអង្គការសាសនានៃពុទ្ធបរិស័ទរបស់យើង ដើម្បីនឹងអាចសន្ទនាគ្នាផ្លាស់ប្តូរបទពិសោធន៍ ទោះបីថាធម៌អាចមិនត្រូវគ្នាក៏ ដោយចុះ ក៏ប៉ុន្តែ ទង្វើដើម្បីការពារជាតិ និងការអភិវឌ្ឍសង្គមជាតិ គឺជាតម្រូវការ ចាំបាច់របស់យើង ...**។

១២. សិស្សនិស្សិតស្ត្រីខ្មែរឥស្លាមអាចស្លៀកពាក់ររៀប ឥស្លាម

ពិធីពិសារអាហារស្រាយបួស រ៉ាម៉ាឌន លើកទី ២, ថ្ងៃទី ២៦ មិថុនា ២០១៥

... ខ្ញុំធ្លាប់បាននិយាយហើយ យើងផ្តល់ឱកាសដល់និស្សិតជាស្ត្រីនៃខ្មែរ ឥស្លាម បានស្លៀកជាសំលៀកបំពាក់ឥស្លាមចូលទៅកាន់មហាវិទ្យាល័យរបស់រដ្ឋ និងរបស់ឯកជន ដែលប្រទេសមួយចំនួន នៅមានការតឹងតែងលើបញ្ហានេះ។ ខ្ញុំ មិនជ្រៀតជ្រែកកិច្ចការរបស់ប្រទេសផ្សេងទេ ប៉ុន្តែ សម្រាប់កម្ពុជា ការធ្វើបែបនេះ ជាការផ្តល់ឱកាស ជាការគោរពដល់សាសនាឥស្លាមផង និងជាការផ្តល់ឱកាស ដល់ស្ត្រី ដែលជាខ្មែរឥស្លាមអាចនឹងរៀនសូត្របានកាន់តែខ្ពស់ទៅ ៗ ចំនួនបញ្ញ វន្តដែលជាសាសនិកឥស្លាមមានកាន់តែច្រើន។ ... នៅលើទឹកដីតែមួយ ប្រៀប ដូចជាដំ:ទូកតែមួយ បើទូកលិច មិនមែនតែខ្មែរ ឬឥស្លាមជាអ្នកទទួលគ្រោះថ្នាក់ ទេ គឺគ្រោះថ្នាក់ទាំងអស់គ្នា ...។

១៣. បញ្ជូលគ្រូបង្រៀនឥស្លាម ក្នុងក្របខណ្ឌរដ្ឋ

ដកស្រង់ពីហ្វេសប៊ុកសម្តេច តេជោ ហ៊ុន សែន, ថ្ងៃទី ០៧ មិថុនា ២០១៦

... កាលពីឆ្នាំកន្លងទៅនេះ នៅក្នុងពិធីរ៉ាម៉ាឌន ខ្ញុំបានធ្វើការសម្រេច ហើយក៏បានអនុវត្តរួចរាល់ហើយដែរ ការបញ្ជូលគ្រូបង្រៀនផ្នែកសាសនាអ៊ីស្លាមចំនួនជាង ១៥០០ នាក់ទៅក្នុងក្របខណ្ឌរដ្ឋ។ នេះជាផ្នែកមួយនៃការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលចំពោះសហគមន៍មូស្លីមនៅកម្ពុជា ... សង្ឃឹមថា ទាំងអស់នេះនឹងបានជាផលប្រយោជន៍សម្រាប់ទទួលបាននូវការអប់រំ ទទួលបាននូវការលើកកម្ពស់គុណភាពនៃជីវិត ក៏ដូចជាការគោរពបូជាចំពោះសាសនាឥស្លាមនៅកម្ពុជាផងដែរ ...។

បរិស្ថាន

១	សាយ សំអាល់ រដ្ឋមន្ត្រីទី ១ ស្នើធ្វើប្រតិភូកម្មមុខងារទៅក្រសួងផ្សេង	១១៥
២	បរិស្ថាន គ្រប់គ្រងដីព្រៃការពារ, កសិកម្ម គ្រប់គ្រងដីធ្វើអាជីវកម្ម	១១៥
៣	រដ្ឋបាលព្រៃឈើ និងជលផល ស្ថិតក្រោមការគ្រប់គ្រងថ្នាក់ក្រោមជាតិ	១១៦
៤	រដ្ឋ សង្គមស៊ីវិល ពលរដ្ឋ ដៃគូអភិវឌ្ឍន៍ ចូលរួមអភិរក្សធនធានធម្មជាតិ	១១៦
៥	បំរាមកាប់ឈើហ៊ុបនាំចេញអនុវត្តតាំងពី ១៩៩៨តែការកាប់នៅតែបន្ត	១១៧
៦	បើមានព្រៃត្រូវការពារ ត្រូវបញ្ជូលក្រោមគ្រប់គ្រងនៃក្រសួងបរិស្ថាន	១១៧
៧	បង្កើតមុខរបរសម្រាប់អ្នកអាស្រ័យផលពីផលព្រៃឈើ និងចាប់សត្វ	១១៨
៨	មិនយកទីតាញ៉ូមជីផាត ការពារបរិស្ថាន និងទេសចរណ៍	១១៨
៩	ថវិកាបានពីលក់កាបូនព្រៃឈើ ផ្តល់មកសម្រាប់ការការពារបរិស្ថានវិញ	១១៩
១០	ធ្វើអោយគំនិតផ្តើមសួនដាំឈើអាពាហ៍ពិពាហ៍ ដំណើរការជានិរន្ត	១១៩
១១	មិនឲ្យវិនិយោគផលិតល្ហាស្ថិក និងប្រេងរ៉ែអិលពីប្រេងប្រើហើយក្នុងស្រុក	១២០
១២	ការអភិវឌ្ឍតែងតែមានផលប៉ះពាល់ដល់ធនធានធម្មជាតិជានិច្ច	១២០
១៣	សូមប្រទេសខាងលើៗ ទម្លាក់ទឹកមកកម្ពុជា និងវៀតណាមផង	១២១
១៤	ទឹកទន្លេមេគង្គចុះទាប ទឹកប្រៃពីសមុទ្រគំរាមកំហែង	១២២

១. សាយ សំអាល់ រដ្ឋមន្ត្រីទី ១ ដែលស្នើផ្ទេរមុខងារ និងធ្វើប្រតិភូកម្ម ទៅក្រសួងផ្សេង

ពិធីសម្ពោធ «អគារមតកតេជោ» ក្រសួងបរិស្ថាន និងបើកសន្និបាតបូកសរុបលទ្ធផលការងារបរិស្ថានឆ្នាំ ២០១៥ និងទិសដៅការងារឆ្នាំ ២០១៦, ថ្ងៃទី ២៥ កុម្ភៈ ២០១៦

... អនុញ្ញាតឲ្យខ្ញុំយកវេទិកានេះ ដើម្បីនិយាយបន្តិចពាក់ព័ន្ធទៅលើរឿងនេះ។ ដំបូងខ្ញុំសុំកោតសរសើរចំពោះ **ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ដែលនេះជាលើកទីមួយក្នុងរយៈពេលជាង ៣០ ឆ្នាំ នៃការគ្រប់គ្រង(រាជ)រដ្ឋាភិបាល ទើបនឹងមានរដ្ឋមន្ត្រីម្នាក់គត់ ដែលបានស្នើសុំប្រគល់តួនាទីទៅឲ្យស្ថាប័នផ្សេង។ មុននេះ (រដ្ឋមន្ត្រី)តែងតែស្រវាទាញយកនូវអំណាចយកមកទុកនៅក្រសួងរបស់ខ្លួនជាប់ជានិច្ច។ ប៉ុន្តែ រដ្ឋមន្ត្រីរូបនេះ បែរជាធ្វើផ្ទុយពីនេះ។ បានសេចក្ដីថា ចង់បែងចែកមុខងារឲ្យជាច់។** នេះជាកំណែទម្រង់ដែលខ្ញុំចង់បាន។ ខ្ញុំកោតសរសើរ ហើយសង្ឃឹមថា រដ្ឋមន្ត្រីនានានឹងមិនអោបការងារនេះបន្តទៀតទេ ហើយកម្មវិធីផ្ទេរមុខងារ និងប្រតិភូកម្មទៅឲ្យថ្នាក់ក្រោមជាតិនោះ ក៏មិននៅស្រមើមស្រម៉ាមដូចសព្វថ្ងៃនេះដែរ។ សង្ឃឹមថាឯកឧត្តមរដ្ឋមន្ត្រីនានាដែលនៅទីនេះ នឹងមិនអោបការងារទៀតទេ ត្រូវទាក់ទងធ្វើប្រតិភូកម្មនឹងអាជ្ញាធរថ្នាក់ក្រោមជាតិ ... ។

២. ការផ្ទេរភារកិច្ច៖ ក្រសួងបរិស្ថាន គ្រប់គ្រងដីព្រៃការពារ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ្រប់គ្រងដីធ្វើអាជីវកម្ម

វេទិកា ស្ដីពីការការពារ និងអភិរក្សធនធានធម្មជាតិ, ថ្ងៃទី ២២ សីហា ២០១៦

... សូមទូលព្រះគេន គោរពជំរាបថា **យើងបានបែងចែកមុខងារ ហើយ(ដល់ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)។ ព្រៃត្រូវការពារ ត្រូវដាក់អោយនៅក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន។ ពីមុននេះ មានព្រៃពីរប្រភេទ ព្រៃការពារដូចគ្នា ប៉ុន្តែគ្រប់គ្រងដោយស្ថាប័នខុសគ្នា៖ មួយគ្រប់គ្រងដោយក្រសួងបរិស្ថាន មួយទៀតគ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ។ ឥឡូវនេះ គ្រប់គ្រងតែមួយកន្លែងបានហើយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវប្រគល់តំបន់ព្រៃការពារទាំងអស់ អោយក្រសួងបរិស្ថានគ្រប់គ្រង។ ផ្ទុយទៅវិញ ដីធ្វើអាជីវកម្មទាំងឡាយ ដែលមុននោះ វានៅក្នុងក្របខណ្ឌនៃដីរបស់**

ក្រសួងបរិស្ថានគ្រប់គ្រង ក៏ត្រូវប្រគល់អោយក្រសួងកសិកម្មគ្រប់គ្រងវិញ។ អ្នកឯងគិតពីរឿងធ្វើអាជីវកម្មទៅ អាហ្នឹងមួយផ្នែក ... ។

៣. រដ្ឋបាលព្រៃឈើ និងជលផលត្រូវស្ថិតនៅក្រោមការគ្រប់គ្រងថ្នាក់ក្រោមជាតិ

វេទិកាស្តីពីការការពារ និងអភិរក្សធនធានធម្មជាតិ, ថ្ងៃទី ២២ សីហា ២០១៦

... មួយផ្នែកទៀត មិនមែនធ្វើប្រតិកូកម្មទេ ត្រូវផ្តល់សិទ្ធិអំណាចអោយរដ្ឋបាលថ្នាក់ក្រោមជាតិតែម្តង។ **រដ្ឋបាលថ្នាក់ក្រោមជាតិនៅពេលនេះ កំពុងតែធ្វើការកែទម្រង់ ដោយពីរដ្ឋបាលថ្នាក់ក្រោមជាតិ អនុវត្តតាមរបៀបខ្សែបណ្តោយ ប៉ុន្តែទំនាក់ទំនងខ្សែទទឹងជួបការលំបាក។ ឥឡូវនេះ យើងកំពុងធ្វើកែទម្រង់មួយ ដោយផ្តល់សិទ្ធិអំណាចទៅអោយរដ្ឋបាលថ្នាក់ក្រោមជាតិ។** មុននេះ ពេលដែលគេកាប់ឈើនៅនឹងមុខ ចៅហ្វាយខេត្ត ឬអនុខេត្ត អត់មានយោបល់អីទាំងអស់ ព្រោះថាអាហ្នឹង គឺរឿងរបស់ក្រសួងបរិស្ថាន រឿងរបស់ក្រសួងកសិកម្ម, វាទៅជាអញ្ចេះ។ គេនេសាទនៅតំបន់ការពារហើយទៅទៀត គឺគេថា អាហ្នឹងរឿងរបស់ក្រសួងកសិកម្មតើ។ ឥឡូវនេះ **ត្រូវផ្តល់ទៅអោយគណៈអភិបាលខេត្ត ដែលក្នុងនោះ ... មិនអនុញ្ញាតតទៅទៀតទេ ទៅលើរបៀបគ្រប់គ្រងបច្ចុប្បន្ននេះ ... នៅថ្នាក់ក្រោមជាតិនោះ គេមានថវិកា ហើយថ្នាក់ជាតិត្រូវផ្តល់ធនធានមនុស្ស និងធនធានថវិកា ទៅឲ្យថ្នាក់ក្រោមជាតិអនុវត្ត** ...។

៤. រដ្ឋ សង្គមស៊ីវិល ប្រជាពលរដ្ឋ ដៃគូអភិវឌ្ឍន៍ ចូលរួមក្នុងការអភិរក្សធនធានធម្មជាតិ

ប្រារព្ធទិវាមច្ឆជាតិ នៅអាងទឹក អន្លង់ជ្រៃ ខេត្តកំពង់ស្ពឺ, ០១ កក្កដា ២០១៦

... យើងបានធ្វើកិច្ចការមួយចំនួនហើយ ក្នុងកំណែទម្រង់ដីធ្លី កំណែទម្រង់ព្រៃឈើ កំណែទម្រង់ឡូត៍នេសាទ។ ប៉ុន្តែអ្វីក៏ដោយ មិនអាចជោគជ័យដោយខ្វះការចូលរួមនោះទេ។ កិច្ចការពារធនធានធម្មជាតិ ត្រូវធ្វើឲ្យបានខ្លាំងជាងមុន (ឲ្យមាន)ប្រសិទ្ធភាពជាងមុន និងមានការចូលរួមទាំងអស់គ្នា ... **សុំយកឱកាសនេះ អំពាវនាវឲ្យទាំងផ្នែករដ្ឋ សង្គមស៊ីវិល និងប្រជាពលរដ្ឋ ក៏ដូចជា ដៃគូអភិវឌ្ឍន៍ ចូលរួមនៅក្នុងការអភិរក្សធនធានធម្មជាតិ**។ មុននេះ **សង្គមស៊ីវិល ឬក៏សកម្មជនការពារព្រៃឈើ និងខាងផ្នែករដ្ឋ ហាក់នៅម្ខាងម្ខាក់ ... នេះជាកំហុស**

មួយដែលយើងត្រូវកែប្រែវិយាបថ ហើយអ្នកដែលត្រូវកែប្រែវិយាបថ គឺផ្តើមចេញពីខាងផ្នែករាជរដ្ឋាភិបាលហ្នឹងតែម្តង ... ត្រូវរៀបចំឲ្យទៅជាចលនាជាតិ ទាំងផ្នែករដ្ឋ និងការចូលរួមរបស់ប្រជាពលរដ្ឋ ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាល ... **ការចូលរួមក្នុងការការពារព្រៃឈើ ធនធានធម្មជាតិ អត់មានអីខុសទេ។ អ្វីដែលខុសគឺការតាំងខ្លួនធ្វើជាអាជ្ញាធរ ជានគរបាលយុត្តិធម៌ ដូចមានអង្គការខ្លះក្លែងខ្លួនទៅដាក់បារ៉ាស់តាមផ្លូវ** ...។

៥. បំរាមការកាប់ឈើហ៊ុបនាំចេញ អនុវត្តតាំងពី ១៩៩៨ តែការកាប់ឈើនៅតែបន្ត

ពិធីបិទសន្និបាតបូកសរុបការងារកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ឆ្នាំ ២០១៥-២០១៦ និងទិសដៅការងារ ឆ្នាំ ២០១៦/១៧, ថ្ងៃទី ១២ ឧសភា ២០១៦

... ការបែងចែកមុខងារនៅទីនេះ យើងបានប្រគល់ព្រៃការពារទាំងឡាយ ក្នុងដៃក្រសួងកសិកម្ម ទៅឲ្យក្រសួងបរិស្ថាន ឯដីដែលក្រសួងបរិស្ថាន ផ្តល់ឲ្យធ្វើសម្បទានសេដ្ឋកិច្ចប៉ុន្មាន ត្រូវផ្តល់ទៅឲ្យក្រសួងកសិកម្មទាំងអស់ ... ត្រូវយកចិត្តទុកដាក់បន្តការងារ ដោយទទួលស្គាល់សហគមន៍ព្រៃឈើ ការពារធនធានធម្មជាតិទាំងអស់ គឺជាចង្កោមតែមួយ ... **យើងដាក់ចេញនូវគោលដៅការពារព្រៃឈើ ប៉ុន្តែយើងការពារបានក្នុងចំណែកណាមួយទេ។ បំរាមនៃការកាប់ឈើហ៊ុបនាំចេញត្រូវបានអនុវត្តចាប់តាំងពីឆ្នាំ ១៩៩៨ រហូតមកដល់ពេលនេះ ប៉ុន្តែការកាប់ឈើ ទន្ទ្រានយកដី ការលួចកាប់ឈើនៅតែបន្តការកើតមាន។ យើងត្រូវទទួលស្គាល់ព្រោះជាក់ស្តែងមានឈើល្មើសច្បាប់ក្នុងដៃ ៧ ម៉ឺនម៉ែត្រគូប** ... សមត្ថកិច្ចយើងតែមួយមុខមិនគ្រប់ទេ។ អំពាវនាវគ្រប់មជ្ឈដ្ឋាន ចូលរួមការពារព្រៃឈើ កុំមើលគ្នាក្នុងភាពជាសត្រូវ ...។

៦. បើមានព្រៃត្រូវការពារ ត្រូវបញ្ចូលក្នុងការគ្រប់គ្រងនៃក្រសួងបរិស្ថានជាស្វ័យប្រវត្តិ

ពិធីចែកសញ្ញាបត្រដល់និស្សិតសាកលវិទ្យាល័យធនធានមនុស្ស, ថ្ងៃទី ២៨ មេសា ២០១៦

... ពាក់ព័ន្ធនឹងបញ្ហាព្រៃឈើ ខ្ញុំព្រះករុណាខ្ញុំ ទើបនឹងចុះហត្ថលេខា ដើម្បីផ្ទេរការគ្រប់គ្រង ... មុននេះដីសម្បទានសេដ្ឋកិច្ចទាំងក្រសួងកសិកម្មក៏ផ្តល់ ក្រសួង

បរិស្ថានក៏ផ្ដល់។ ឥឡូវត្រូវផ្ទេរមុខងារ បែងចែកមុខងារវាឲ្យដាច់ ... មានគោលការណ៍មួយបន្ដទៅទៀត **បើសិនជាសិក្សាទៅឃើញថា មានព្រៃតំបន់ណាជា(អាចធ្វើជា)តំបន់ការពារ ជាស្វ័យប្រវត្ដិ(ត្រូវ)ចូលទៅក្នុងការគ្រប់គ្រងនៃក្រសួងបរិស្ថានតែម្ដង** ... ក្រសួងបរិស្ថានក៏បានធ្វើការជាមួយសហគមន៍អឺរ៉ុប អាមេរិក និងបងប្អូនប្រជាពលរដ្ឋរបស់យើង ដែលជាអ្នកស្រឡាញ់ព្រៃឈើ (ដោយ)យើងនឹងដាក់ព្រៃឈើប្រមាណជាជាង ១ លានហិកតាទៀតជាតំបន់ការពារ ក្នុងហ្នឹងមានព្រៃឡង់ ព្រៃភ្នំក្រ៉ាញ និងតំបន់មួយចំនួនផ្សេងទៀត ...។

៧. បង្កើតមុខរបរសម្រាប់អ្នកអាស្រ័យផលពីផលព្រៃឈើ និងចាប់សត្វ

ពិធីបិទសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឆ្នាំ ២០១៥-២០១៦ និងទិសដៅការងារ ឆ្នាំ ២០១៦/១៧, ថ្ងៃទី ១២ ឧសភា ២០១៦

... យើងជាជនជាតិខ្មែរដូចគ្នា ចង់ការពារនូវដើមឈើទាំងអស់គ្នា ... នៅក្នុងព្រៃឡង់ មិនមែនសុទ្ធតែជាព្រៃទាំងអស់នោះទេ។ មានស្ថានភាពស្បែកខ្លា ...**យើងត្រូវខិតខំបង្កើតមុខរបរថ្មីអោយពលរដ្ឋ ដែលមុននេះ ពឹងពាក់លើការកាប់អុស ការកាប់ឈើ ការចាប់សត្វព្រៃ និងអ្វីផ្សេងទៀត ដែលចេញពីអនុផលព្រៃឈើ ដើម្បីទទួលបានផលពីប្រភពផ្សេងវិញ** ... ដៃគូ មិត្ដភក្ដិ អាចចូលរួមចំណែក ក្នុងការ**បណ្ដុះបណ្ដាលវិជ្ជាជីវៈ(ជូនគាត់) ជួនកាលអាចអោយគាត់មានសិប្បកម្មអីនៅក្នុងហ្នឹង ឬក្លាយទៅជាគោលដៅទេសចរណ៍នៅក្នុងតំបន់ដែលពួកគាត់អាចនឹងរកទទួលទានបានច្រើនជាងការពឹងពាក់លើផលដែលបានមកពីឈើ** ...។

៨. មិនយកទីតាញ៉ូមជីផាត ការពារបរិស្ថាន និងទេសចរណ៍

ពិធីបិទសន្និបាតការប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ ២០១៤", ថ្ងៃទី ២២ កញ្ញា ២០១៥

... កុំព្រួយរឿងជីផាត ខ្ញុំមិនធ្វើឲ្យខូចទេ។ ទីតាញ៉ូម តម្លៃប្រមាណជាង ២០ ពាន់លានដុល្លារហ្នឹង ខ្ញុំមិនឲ្យធ្វើទេ ដើម្បីរក្សាទុកជីផាត ... ដើម្បីយក ២២ ពាន់លានដុល្លារ ពីទីតាញ៉ូមហ្នឹង ត្រូវកាប់ព្រៃនៅខាងលើ ... រួចហើយ វាមិនមែនទៅជាតំបន់ទេសចរណ៍រមណីយដ្ឋានជីផាតទៀតទេ។ **ទឹក(ក្ដៅ)ហូរទៅ ធ្វើ**

អោយទឹកសមុទ្រនៅតំបន់នោះ មិនមែនខៀវស្រងាត់ដូចសព្វថ្ងៃនេះទេ ទៅជាទឹកល្អក់តែម្តង។ អញ្ចឹងទេ ទុកសិនទៅ មិនទាន់ផ្ទូមទេ។ (ម្យ៉ាង) បើយើងចង់បានទីតាញ៉ូមនៅខាងក្រោមនោះ (វានឹងធ្វើអោយ)**រេចរឿលអស់តំបន់ដំរីស្នាក់នៅ**។ ខ្ញុំបញ្ជាក់ជាថ្មីម្តងទៀត កុំឲ្យអ្នកនៅជីផាតនោះព្រួយបារម្ភ អត់ធ្វើទេ ...។

៩. ថវិកាដែលបានមកពីការលក់កាបូនព្រៃឈើ ផ្តល់មកសម្រាប់ការការពារបរិស្ថានវិញ

វេទិកាស្តីពីការការពារ និងអភិរក្សធនធានធម្មជាតិ, ថ្ងៃទី ២២ សីហា ២០១៦

... អរគុណលោកដែលអញ្ជើញមកពីអង្គការ WTS។ អរគុណណាស់ ជាមួយនឹងការលើកឡើងនេះ ហើយខ្ញុំក៏អរគុណផងដែរ ការដែលបានជួយលក់កាបូន ហើយធ្វើឲ្យខ្ញុំនិយាយលើបញ្ហានេះបន្តិច ដែលទាក់ទងជាមួយនឹងកម្រៃដែលបានមកពីការលក់កាបូនព្រៃឈើ។ ពិតហើយ ចំណូលថវិកាជាតិ វាត្រូវឆ្លងកាត់នូវគណនេយ្យទោល រវាងចំណូល និងចំណាយ ក៏ប៉ុន្តែខ្ញុំសុំផ្តល់ការណែនាំមួយ ឥឡូវយើងទើបនឹងលក់បាន ២ លាន ៦ សែនដុល្លារ(អាមេរិក)តែប៉ុណ្ណោះ ប៉ុន្តែយើងនឹងអាចលក់បានច្រើនលើសនេះ ហើយខ្ញុំស្នើថា ... **យើងគប្បីប្រើប្រាស់នូវថវិកាដែលបានមកពីការលក់កាបូនព្រៃឈើនេះ ផ្តល់មកសម្រាប់ការការពារបរិស្ថានវិញ។ តាំងពីឆ្នាំ ១៩៩៨ ពេលដែលខ្ញុំព្រះករុណាខ្ញុំ ឲ្យបញ្ចប់ការកាប់ឈើហ៊ីប យើងអត់ដែលមានប្រាក់ចំណូលពីព្រៃឈើ ដើម្បីយកមកទ្រទ្រង់ថវិកាចរន្តរបស់យើងទេ។ ពេលនោះ យើងអាចលក់កាបូនព្រៃឈើបានច្រើនជាង យកវាមកប្រើប្រាស់នៅក្នុងការទ្រទ្រង់ការគាំពារបរិស្ថានវិញ យើងមិនប្រើប្រាស់ថវិកានេះដើម្បីយកទៅវិនិយោគផ្នែកនេះផ្នែកនោះឬក៏យកមកបើកប្រាក់ខែនោះទេ ...**។

១០. ធ្វើអោយគំនិតផ្តើមសួនដាំឈើអាពាហ៍ពិពាហ៍ ដំណើរការជានិរន្ត

ទិវាជាតិទីក្រុងស្ពាត, ថ្ងៃទី ២៤ កុម្ភៈ ២០១៥

... **ខ្ញុំបានផ្តើមគំនិតបង្កើតសួនអាពាហ៍ពិពាហ៍ សម្រាប់ការដាំកូនឈើលើកដំបូង គឺនៅក្រាំងយ៉ូវ ហើយបន្ទាប់ទៅក៏បានទៅកាន់តំបន់ដទៃទៀត។ ចលនានេះ ហាក់ដូចជាបានដើរទៅមុខ រួចហើយក៏ស្ងាត់។ ខ្ញុំក៏ចង់ឲ្យចលនានេះរស់ឡើងវិញ តាមរយៈការបំផុសឲ្យប្តីប្រពន្ធរៀបការថ្មី ដាំបានកូនឈើមួយដើមម្នាក់**

... និយាយទៅ ធ្វើទៅ។ ដល់ឈប់និយាយ វាឈប់ធ្វើដែរ។ ... នៅតាមទីអារាមនានា ក៏មានទីកន្លែងដាំកូនឈើខ្លះដែរ ហើយកន្លែងមួយចំនួនមានទីកន្លែងដាំកូនឈើ បើសិនជាអ្នកដែលរៀបអាពាហ៍ពិពាហ៍ហើយ គេចង់ទុកអនុស្សាវរីយ៍នោះ គេអាចទៅដាំកូនឈើ។ ចលនានេះ បានចាប់ផ្តើមពីតំបន់ក្រាំងយ៉ូវ នៅភ្នំទំពែក ក្នុងឆ្នាំ ១៩៩៥ ដែលខ្ញុំបានចុះទៅអភិវឌ្ឍ ...។

១១. មិនព្រមឲ្យវិនិយោគផលិតប្លាស្ទិក និងប្រេងរ៉ែអិលពីប្រេងប្រើហើយក្នុងស្រុក

ប្រារព្ធទិវាជាតិទីក្រុងស្ពាត, ថ្ងៃទៅ ២៤ កុម្ភៈ ២០១៥

... សុំសរសើរក្មួយៗ យុវជន ដែលបានចូលរួមចំណែកយ៉ាងធំ ហើយថង់ប្លាស្ទិក **សូមបញ្ជាក់ ការស្វះស្វែងរកការវិនិយោគមកលើទឹកដីកម្ពុជា ដែលខ្ញុំមិនព្រមឲ្យជាប់ខាត។ មានរឿង ២៖ រឿងទី ១ សុំបើករោងចក្រផលិតប្លាស្ទិក ដោយប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក ក្នុងករណីខ្វះ នាំចូលពីខាងក្រៅ ... ខ្ញុំ(មិនអនុញ្ញាត)ឲ្យទេ អាហ្នឹងទី ១។ ទី ២ ផលិតប្រេងរ៉ែអិល ដោយប្រើប្រាស់នូវប្រេងរ៉ែអិលក្នុងស្រុកដែលប្រើហើយ ប៉ុន្តែ ក្នុងករណីខ្វះ គឺនាំចូលប្រេងរ៉ែអិលដែលគេចោល គេច្នៃឡើងវិញពីខាងក្រៅ**។ រួចហើយសុទ្ធតែនិយាយទៀត ក្រៅពីប្រជុំនៅ CDC ហើយ សុទ្ធតែមានសំបុត្រអីណាមកថែមទៀត ហើយប្រទេសនេះ ប្រទេសនោះ គេសុំវិនិយោគ តែមិនព្រមវិនិយោគ គេស្រឡាញ់ខ្មែរ គេចង់មកខ្មែរ។ បានខ្ញុំថា អាហ្នឹងចង់យកខ្មែរធ្វើធុងសំរាមទេ ខ្ញុំមិនឲ្យ។ ឥឡូវខ្ញុំ សូមឲ្យយោបល់បន្តិចទៅ តើថៃគាត់ល្ងង់ រ៉ៃតណាមគាត់ល្ងង់ ឡាវគាត់ល្ងង់ឬអី? បានជាមិនព្រមឲ្យបង្កើតរោងចក្រហ្នឹងលើទឹកដីគាត់។ ... ដល់ប្លាស្ទិកក៏អញ្ចឹងដែរ ដល់យើងស៊ើបៗទៅ សកម្មជនការពារបរិស្ថាន អ្នកមានភាគហ៊ុនក្នុងហ្នឹង ឆ្ពុយទៅអញ្ចឹង។ អញ្ចឹងបានថា គ្រាន់តែនិយាយអត់ពិរោះទេ ត្រូវមើលសកម្មភាពជាក់ស្តែង ... ។

១២. ការអភិវឌ្ឍតែងតែមានផលប៉ះពាល់ដល់ធនធានធម្មជាតិជានិច្ច

វេទិកាស្តីពីការការពារ និងអភិរក្សធនធានធម្មជាតិ, ថ្ងៃទី ២២ សីហា ២០១៦

... ខ្ញុំចង់និយាយពីបរិការណ៍រួមបន្តិច រវាងការអភិវឌ្ឍ និងកិច្ចការអភិរក្សធនធានធម្មជាតិ។ តើមានប្រទេសណាមួយ ដែលចេញមកប្រកាសថា ប្រទេសខ្ញុំអភិ

វឌ្ឍដោយគ្មានរបៀបរៀប គ្មានប៉ះពាល់ដល់បរិស្ថានទេ? អត់មានទេ ... ប្រទេសដទៃៗ សុទ្ធតែបានអនុវត្តអស់ហើយ ទាំងលើដី ទាំងក្រោមដី ទាំងក្នុងទឹក ទាំងក្រោមទឹក ទាំងសមុទ្រ ទន្លេ បឹងបួ។ ឥឡូវ យើងពិនិត្យមើល បណ្តាប្រទេសផលិតប្រេងកាតទៅយកពីណា? មិនមែនទៅដងពីសមុទ្រមកឯណា អាហ្នឹង គេជីកនៅក្រោមសមុទ្រនោះ ឬក៏ក្រោមដីនោះ។ អញ្ចឹង គេអភិវឌ្ឍប្រទេសគេ ដោយផ្តើមចេញពីធនធានធម្មជាតិ ដែលគេយកមកប្រើ ... បន្ថែមលើនោះ **ប្រទេសឧស្សាហកម្មធំៗ គេត្រូវមានការទទួលខុសត្រូវលើសពីនេះ ដោយសារពួកគេបានបញ្ចេញផ្សែងយ៉ាងច្រើនដែលធ្វើឲ្យការប្រែប្រួលអាកាសធាតុ។ ពួកគេបានចំណេញច្រើនណាស់ ពីការអភិវឌ្ឍទាំងអស់នេះ។ ប៉ុន្តែ យើងមិនបានស្តីបន្ទោសគេទេ តែសុំឲ្យគេកុំស្តីបន្ទោសយើងហួសហេតុពេល សុំឲ្យនិយាយត្រឹមការពិតបានហើយ។ យើងទទួលយកនូវការពិតមួយ ដែលថាការគ្រប់គ្រងរបស់យើងមិនទាន់បានល្អ ដែលទាមទារនូវការពង្រឹងយន្តការដែលវេទិកាថ្ងៃនេះ គឺជាសក្តានុភាពនៃកិច្ចសហប្រតិបត្តិការដែលយើងត្រូវធ្វើ ...** ។

១៣. ចិនបើកទឹកពីឡានឆាង, សូមប្រទេសខាងលើៗ ទម្លាក់ទឹកមកកម្ពុជា/វៀតណាមផង

ពិធីកាត់ឫសសីមា ព្រះវិហារនៅវត្ត ឥន្ទមុនី ហៅវត្តព្រៃជ្រាំង,
ថ្ងៃទី ១១ មេសា ២០១៦

... ប្រទេសរបស់យើងកំពុងជួបប្រទះនូវការរាំងស្ងួតដ៏ធ្ងន់ធ្ងរ ហើយការរាំងស្ងួតនេះ មិនមែនជាការជាប់ដោយឡែកទេ ក៏ប៉ុន្តែ ជាបញ្ហារួមរបស់តំបន់។ កាលពីខែមុននេះ ខ្ញុំព្រះករុណាខ្ញុំ បានទៅប្រជុំជាលើកដំបូង ដែលហៅថា វេទិកាសហប្រតិបត្តិការវាងទន្លេ ២ គឺទន្លេមេគង្គរបស់ប្រទេសខាងក្រោម ដែលមាន មីយ៉ាន់ម៉ា ថៃ ឡាវ កម្ពុជា និងវៀតណាម គឺ ៥ ប្រទេស ជាមួយនឹងទន្លេឡានឆាងរបស់ប្រទេសចិន។ ចិនបានបើកទឹកចំនួន ២ ដង រួចមកហើយ សម្រាប់ទម្លាក់មកកាន់ទន្លេមេគង្គ ជួយដល់ប្រទេសដែលនៅផ្នែកខាងក្រោម ដែលកំពុងខ្វះទឹក ព្រោះទន្លេឡានឆាង គេមានវិធីទប់ទឹក ដើម្បីបម្រើឲ្យការប្រើប្រាស់របស់ប្រទេសចិន ... **ខ្ញុំព្រះករុណាខ្ញុំ បានអំពាវនាវថា ឲ្យចិនបន្តបើកបន្តទៀត តែក៏បានស្នើសុំឲ្យប្រទេសមីយ៉ាន់ម៉ា ប្រទេសថៃ និងប្រទេសឡាវ កុំទប់ស្កាត់ទឹកហ្នឹងប្រើប្រាស់**

ច្រើនពេក ដើម្បីទម្លាក់ឲ្យមកដល់កម្ពុជា និងវៀតណាមផងដែរ ...។

១៤. ទឹកទន្លេមេគង្គចុះទាប ទឹកប្រៃពីសមុទ្រគំរាមកំហែង

ពិធីកាត់ឫសសីមា ព្រះវិហារនៅវត្ត ឥន្ទមុនី ហៅវត្តព្រៃជ្រាំង,
ថ្ងៃទី ១១ មេសា ២០១៦

... ឯចំពោះវៀតណាមនៅខាងក្រោម ឥឡូវនេះ ទឹកសមុទ្រដែលមិនធ្លាប់មានបានចូលក្នុងទឹកដីវៀតណាមប្រមាណជាង ១០០ គីឡូម៉ែត្រទៅហើយ។ ... កាលណាទឹកទន្លេមេគង្គរបស់យើងវាមិនខ្ពស់ ទឹកសមុទ្រនោះវាដោរ (ឡើង) ហើយ ខ្ញុំព្រះករុណាខ្ញុំ **មានការព្រួយបារម្ភខ្លាំងណាស់ ព្រួយបារម្ភថា បើសិនជាឆ្លងកាត់វៀតណាម ១០០ គីឡូម៉ែត្រពីសមុទ្រចូលមកហើយនោះ ហើយបើសិនជាទឹកទន្លេមេគង្គបន្តធ្លាក់ចុះបន្តិចថែមទៀត ទឹកប្រៃនឹងអាចឡើង មកដល់អ្នកលឿងរបស់យើងក៏អាចថាបាន។ ពេលនោះ គឺជាមហន្តរាយមួយ ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុនៅក្នុងពិភពលោកទាំងមូល** មិនមែនគ្រាន់តែបញ្ហាប្រទេសកម្ពុជាដាច់ដោយឡែកនោះទេ ...។

ប្រែសណីយ៍ និងទូរគមនាគមន៍

១	ប្រែសណីយ៍ បច្ចេកវិទ្យាព័ត៌មាន ទូរគមនាគមន៍ ផ្លាស់ប្តូរជាវិជ្ជមាន	១២៥
២	បច្ចេកវិទ្យាព័ត៌មាន គមនាគមន៍ ជួយកសិករអោយទទួលបានព័ត៌មាន	១២៥
៣	មនុស្សមានការប្រាស្រ័យទាក់ទងតាមអេឡិចត្រូនិច (e-people)	១២៥
៤	ទាមទារអោយធ្វើអក្ខរកម្មព័ត៌មានវិទ្យា មុននឹងតែងតាំង	១២៦
៥	គាំទ្រធ្វើ Wifi ឥតគិតថ្លៃនៅព្រលានយន្តហោះ	១២៧
៦	អ្នកប្រើប្រាស់ហ្វេសប៊ីក គប្បីរក្សាគុណធម៌ និងតម្លៃរបស់ខ្លួន	១២៧
៧	កម្ពុជាមិនមែនជាធុងសំរាម បច្ចេកវិទ្យាហួសសម័យទេ	១២៧
៨	គួរមានការបាញ់បង្ហោះផ្កាយរណបរបស់កម្ពុជាផ្ទាល់	១២៨
៩	បច្ចេកវិទ្យាព័ត៌មានជាចំណែកមួយនៃការជម្រុញខាងផ្នែកវិស័យសេដ្ឋកិច្ច	១២៩

១. ប្រៃសណីយ៍ បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ មានការផ្លាស់ប្តូរជាវិជ្ជមាន

សុន្ទរកថាកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទូរគមនាគមន៍ និងបច្ចេកវិទ្យាព័ត៌មាន អាស៊ាន ទី ៧, ថ្ងៃទី ២៣ សីហា ២០០៧

... **កម្ពុជាមានសេចក្តីត្រូវការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងវិស័យទូរគមនាគមន៍ ដើម្បីគាំទ្រសកម្មភាពសេដ្ឋកិច្ច និងសេវាប្រាស្រ័យទាក់ទង ដែលមានការកើនឡើងយ៉ាងធំធេង និងលឿនរហ័សជារៀងរាល់ថ្ងៃ។** ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ **វិស័យប្រៃសណីយ៍ បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ ត្រូវបានធ្វើនីតិសម្បទា និងពង្រឹងខ្លួនជាបន្តបន្ទាប់ ធ្វើអោយមានការប្តូរផ្លាស់ជាវិជ្ជមាន រហូតមកទល់សព្វថ្ងៃ រួមចំណែកដល់ការងារសន្តិសុខ សុវត្ថិភាព និងការអភិវឌ្ឍជាតិ មិនតែប៉ុណ្ណោះ ជាច្រកចេញចូលទទួលបានព័ត៌មាន និងសេចក្តីត្រូវការប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ...**។

២. បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ជួយកសិករអោយទទួលបានព័ត៌មាន

សុន្ទរកថាកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទូរគមនាគមន៍ និងបច្ចេកវិទ្យាព័ត៌មាន អាស៊ាន ទី ៧, ថ្ងៃទី ២៣ សីហា ២០០៧

... **ការអភិវឌ្ឍបច្ចេកវិទ្យា បានបង្កើតអោយមានភាពខុសគ្នានៃភូមិសាស្ត្រសេដ្ឋកិច្ច ពីប្រទេសមួយទៅប្រទេសមួយ ពិសេសគម្លាតរវាងទីក្រុង និងជនបទ។ ពេលណាគម្លាតនោះត្រូវបានដោះស្រាយ នឹងមានផលប្រយោជន៍ដ៏ធំពិតប្រាកដ** ... ដូចជាមានរបាយការណ៍ថា ការប្រើទូរស័ព្ទចល័តនៅតំបន់ជនបទ នៃប្រទេសបង់ក្লাដែស អាចបង្កើនប្រាក់ចំណូលកសិករ បានដល់ទៅ ២០% ជាដើម ... **ដោយវាអាចកាត់បន្ថយចំណាយការប្រាស្រ័យទាក់ទង និងជួយអោយអាចតាមមើលយ៉ាងជិតដល់ នូវតម្លៃទីផ្សារសំរាប់មុខទំនិញនានា នៅទីក្រុង ...**។

៣. មនុស្សមានការប្រាស្រ័យទាក់ទងតាមអេឡិចត្រូនិច (e-people)

ពិធីប្រគល់ពានរង្វាន់ កម្មវិធី "ខ្ញុំជាយុវជនគំរូកម្ពុជា," ថ្ងៃទី ១០ មេសា ២០១៦

... **ខ្ញុំមិនចង់ត្រឹមតែ e-government ទេ ខ្ញុំចង់ទៅរក e-people។ បានសេចក្តីថា**

ប្រជាជនអេឡិចត្រូនិចតែម្តង ព្រោះឥឡូវស្ពីក៏ e ដែរ ... យើងចង់ទាញយុវជនរបស់យើង ចូលមកក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន ... យើងអត់មានឲ្យយកក្រដាសស្នាមមកទីស្តីការគណៈរដ្ឋមន្ត្រី យកមកវិមានសន្តិភាពទេ ... យើងឲ្យធ្វើតាមប្រព័ន្ធអេឡិចត្រូនិចទាំងអស់... ចូលទៅវេបសាយត៍ ដើម្បីដាក់ពាក្យ រួចហើយ vote តាមវេបសាយត៍ បន្ទាប់ពី vote តាមវេបសាយត៍រួចហើយ vote តាម ហ្វេសប៊ុក ... វាមានប្រតិសកម្មធំណាស់ ... សម័យនេះ សូម្បីនៅឆ្ងាយពីគ្នាផុត ដើងមេយក៏បញ្ជូនព័ត៌មានតាមកូនទូរស័ព្ទតូចមួយបាន ...។

៤. ទាមទារអោយធ្វើអក្ខរកម្មព័ត៌មានវិទ្យា មុននឹងតែងតាំង

ពិធីសម្ពោធអគារទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ថ្ងៃទី ១៥ ធ្នូ ២០១៦

... **ខ្ញុំទាមទារអោយធ្វើអក្ខរកម្មព័ត៌មានវិទ្យា ពីមុនអោយធ្វើអក្ខរកម្មកុំព្យូទ័រ ប៉ុន្តែមិនចាំបាច់ទេធ្វើអក្ខរកម្មព័ត៌មានវិទ្យា តែជុំវិញមួយស្មាតហ្វូនគឺល្អណាស់។ ខ្ញុំដាក់ចេញនូវនយោបាយមួយថាមុននឹងតែងតាំង សួរអ្នកឯងសិនថាចេះព័ត៌មានវិទ្យាទេ? បើមិនចេះទេ ចាំរៀនអោយចេះសិនចាំតែងតាំង ព្រោះគេធ្វើការត្រឹមតែ ២ នាទី ឯងធ្វើការ ២ ថ្ងៃ។** ឧទាហរណ៍ ត្រូវការយកឯកសារពីខេត្តឡើងមក ភ្នំពេញ គេគ្រាន់តែថតផ្ញើមកតាម Line ក្តី តាម WhatsApp ក្តី តាម Viber ក្តី តាម Telegram ក្តី ... មិនអាចធ្វើសេចក្តីសម្រេចតាមហ្នឹងទេ ក៏ប៉ុន្តែនៅពេលដែលឆ្លងឆ្លើយ នៅពេលដែលយើងចង់បានព័ត៌មាន នៅពេលដែលយើងចង់បានរូបភាព យើងត្រូវបញ្ជូនឃ្លីបនេះភ្លាម។ សូម្បីតែខ្ញុំនៅកណ្តាលមហាសន្និបាតអង្គការ សហប្រជាជាតិ ខ្ញុំក៏អាចដឹងសភាពការណ៍នៅក្នុងស្រុក ... បច្ចេកវិទ្យា កាន់តែ ខ្ពស់ តែបើមនុស្សមិនចេះប្រើ (វាក៏)មិនខ្ពស់ ... **អញ្ចឹងបានខ្ញុំទាមទារនូវលក្ខខណ្ឌចាំបាច់ បើមិនចេះបច្ចេកវិទ្យា កុំតែងតាំង នាំខាតគេខាតឯង នាំគេវេល់។ ខ្ញុំជឿជាក់ទៅលើសមត្ថភាពរបស់ប្រជាជនកម្ពុជារបស់យើង ជាពិសេសទៅលើយុវជន ដែលសព្វថ្ងៃនេះការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានកាន់តែជឿនលឿន កាន់តែមានប្រសិទ្ធភាព ...**។

៥. គាំទ្រធ្វើ Wifi ឥតគិតថ្លៃនៅព្រលានយន្តហោះ

ពិធីសម្ពោធស្ថានីយអ្នកដំណើរថ្មី នៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ,
ថ្ងៃ ១៦ មីនា ២០១៦

... **ដោយសារមានសន្តិភាព មិនមានសង្គ្រាមតទៅទៀត តាមនយោបាយ ឈ្នះ/ឈ្នះ ធ្វើឲ្យកម្ពុជាមានតំបន់ទេសចរណ៍ច្រើន ហើយភ្ញៀវទេសចរបានកើន ... មានតម្រូវការក្នុងការពង្រីកនូវព្រលានយន្តហោះ ស្ថានីយដឹកអ្នកដំណើរ** ...លោក Xavier Huillard បាននិយាយពី Wifi ឥតគិតថ្លៃ។ ខ្ញុំស្វាគមន៍ អារឿង Wifi អត់គិតថ្លៃ។ សូមធ្វើការនេះឲ្យជោគជ័យ។ កុំឲ្យមាន Wifi តែវាអត់ដើរ។ ទាំងគេ ទាំងខ្ញុំ ពិសេសតម្រូវការដំបូង ពេលចុះពីលើយន្តហោះ រកបណ្តាញអាំងទែរណែត ហើយ ... សូមធ្វើអាហ្នឹងទាំងនៅភ្នំពេញ ទាំងនៅសៀមរាប ទាំងនៅកំពង់សោម ក្រុងព្រះសីហនុ។ សូមឧស្សាហ៍ពិនិត្យ កុំអោយ Wifi ខ្លះ ដូចនៅ សភាជាតិ កម្ពុជា Wifi លោតសញ្ញាពេញទាំងអស់ ប៉ុន្តែស្រាប់តែវាមិនដើរ ...។

៦. អ្នកប្រើប្រាស់ហ្វេសប៊ីក គប្បីរក្សាគុណធម៌ និងតម្លៃរបស់ខ្លួន

ពិធីផ្តល់ពន់ង្វាន់ដ័យលាភី វគ្គពិសេស "ខ្ញុំជាយុវជនគំរូកម្ពុជា,"
ថ្ងៃទី ១០ មេសា ២០១៦

... **ខ្ញុំពិតជាចង់ឲ្យយុវជនប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យានេះបម្រើឲ្យសង្គមពិតៗ ជាជាងការជេរប្រទេច ដាក់បណ្តាសាតាមរយៈហ្វេសប៊ីក ... ហើយខ្ញុំសូមអំពាវនាវ អ្នកដែលចូលលេង ក្នុងហ្វេសប៊ីករបស់ខ្ញុំ មេត្តារក្សាគុណធម៌ និងតម្លៃរបស់ខ្លួន។ តើវាមានផលចំណេញអ្វីទៅ ដែលចូលមកជេរប្រទេចដាក់បណ្តាសាគ្នានោះ?** យើងប្រើប្រាស់នូវចំណុចដែលចង់ផ្តល់មតិ ដូចជាវិស័យអប់រំ ឬក៏ផ្តល់មតិ នេះ មតិនោះ យើងស្តាប់ទាំងអស់ ... ក្នុង Page របស់ខ្ញុំមានខ្លះ ប៉ុន្តែខ្ញុំឃើញ Page របស់អ្នកដទៃ ដែលយើងបើកសាកល្បងមើល ជេរគ្នាក៏អាក្រក់ម្ល៉េះ ...។

៧. កម្ពុជាមិនមែនជាធុងសំរាម សម្រាប់ចោះចោលបច្ចេកវិទ្យាហួសសម័យទេ

ពិធីសម្ពោធអគារទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ថ្ងៃទី ១៥ ធ្នូ ២០១៦

... ខ្ញុំពិតជាមានមោទនភាពលើនយោបាយ ដែលខ្ញុំបានដឹកនាំឆ្លងកាត់ពីដំណាក់កាលមួយទៅដំណាក់កាលមួយ នៅត្រង់ **ខ្ញុំប្រកាសថា កម្ពុជាមិនមែនជាធុងសំរាម ដើម្បីបោះចោលនូវបច្ចេកវិទ្យាហួសសម័យនោះទេ។ ចំណុចនេះ ខ្ញុំនិយាយតាំងពីទសវត្ស ៨០ នៅពេលដែលអឺរ៉ុបខាងកើត បានធ្វើការប្រែប្រួលបច្ចេកវិទ្យារបស់គេ ហើយលក់សម្ភារៈចាស់ៗអោយយើង**។ នៅចាំបានទេ ពួកខាងទូរទស្សន៍ជាតិ ដែលមានឡានសម្រាប់ថតទូរទស្សន៍ ចោះហើយដាក់ម៉ាស៊ីនត្រជាក់មួយចូល។ ពេលហ្នឹង មន្ត្រីរបស់យើងមួយចំនួនទៅទិញរបស់គេ ហើយអរគុណគេទៀត ថារបស់គេលក់អោយថោក។ ខ្ញុំថា តិចទៀតរកតែគ្រឿងបន្លាស់អត់បានផង គេឈប់ផលិត។ **អញ្ចឹងទេខ្ញុំប្រកាសថា កម្ពុជាមិនមែនជាធុងសំរាមសម្រាប់ការបោះចោលនៃបច្ចេកវិទ្យាហួសសម័យទេ។ នៅពេល ដែលឧកញ៉ា គិត ម៉េង បានចុះហត្ថលេខានៅទីក្រុងប៉ារីស ជាមួយក្រុមហ៊ុន អាល់កាតែលរបស់បារាំង ពេលហ្នឹងក៏ខ្ញុំនៅតែនិយាយថា កម្ពុជាត្រូវការបច្ចេក វិទ្យាថ្មី** ...។

៨. គួរមានការបាញ់បង្ហោះផ្កាយរណបរបស់កម្ពុជាផ្ទាល់

ពិធីសម្ពោធអគារទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍,
ថ្ងៃទី ១៥ ធ្នូ ២០១៦

... **ប្រព័ន្ធទូរគមនាគមន៍នៅក្នុងប្រទេសរបស់យើង បើទោះបីជាឥឡូវយើងនៅពឹងផ្អែកទៅលើហេដ្ឋារចនាសម្ព័ន្ធមួយចំនួននៅប្រទេសជុំវិញខ្លួន ប៉ុន្តែខ្ញុំសង្ឃឹមថានឹងមានការវិឌ្ឍខ្លាំងជាងនេះ តាមរយៈខ្សែកាប្លិក្រោមសមុទ្រ។ ខ្ញុំក៏សុំស្នើអោយមានការពិចារណា ទៅលើការបាញ់បង្ហោះផ្កាយរណបដោយកម្ពុជាខ្លួនឯង ពិនិត្យមើលអំពីបញ្ហាហ្នឹង។** ឧកញ៉ា គិត ម៉េង ល្មមចាប់ដៃគូជាមួយក្រុមហ៊ុនណាមួយ ដើម្បីបាញ់ផ្កាយរណបសម្រាប់ការប្រើប្រាស់នៅក្នុងប្រទេសរបស់យើង។ មិនខាតទេ។ បើផ្កាយរណបនឹងបាញ់ឡើងហើយ ទូរទស្សន៍ទាំងអស់ដែលកំពុងទិញ(សេវា)ផ្កាយរណបគេ បែរមកប្រើផ្កាយរណបរបស់យើង។ **ថ្ងៃក្រោយយើងត្រូវការផ្កាយរណប(ធ្វើការងារ)ច្រើនណាស់។ ផ្កាយរណបនេះខ្ញុំគិតគួរតាំងពីទសវត្ស ៩០ ប៉ុន្តែលទ្ធភាពតាមជំហានមួយៗ។ ឥឡូវនេះ យើងត្រូវការអ៊ីនធើណែតល្អ្ជ្ជ្ជ្ជ្ជ្ជ្ជ...**។

៩. បច្ចេកវិទ្យាព័ត៌មានជាចំណែកមួយនៃការជម្រុញខាងផ្នែកវិស័យសេដ្ឋកិច្ច

ពិធីសម្ពោធអគារទីស្តីការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍,
ថ្ងៃទី ១៥ ធ្នូ ២០១៦

... ចូលមកនៅដំបូង ភ្នំពេញមានមនុស្សតែ ៧០ នាក់ទេ ហើយពេលហ្នឹង មានទូរស័ព្ទ ២ លេខហ្នឹង ប្រឹងហៅទៅខេត្ត ឆ្លងតាមស្តង់ដា។ គេអត់ដឹងថា យើងអ្នកធំ គេក៏មិនប្តក់ឲ្យ ដល់គេដឹងថាធំគេប្តក់ឲ្យលឿនទៅ។ **ឥឡូវអត់មានត្រូវឆ្លងកាត់អ្នកណាទេ ស៊ីសងលើយើងចេះប្រើបច្ចេកទេសដើម្បីធ្វើទំនាក់ទំនង ជាមួយគ្នា។ វាលឿនវារហ័ស ហើយជាការពន្លឿន ជម្រុញសេដ្ឋកិច្ចឲ្យឈានឡើង។ កុំភ្លេចថាបញ្ហា Digital នេះ បច្ចេកវិទ្យាព័ត៌មាននេះ វាជាចំណែកមួយ នៃការជម្រុញខាងផ្នែកវិស័យសេដ្ឋកិច្ចកំណើនសេដ្ឋកិច្ចរបស់យើងផងដែរ** ...។

ផែនការ

១	លទ្ធផលជំរឿនជាទីទុកចិត្ត	១៣៣
២	នយោបាយឈ្នះឈ្នះ ១៩៩៨ អោយកម្ពុជាធ្វើអង្កេតប្រជាសាស្ត្របាន	១៣៣
៣	សន្តិភាព និងឯកភាពជាតិ ជាលក្ខខណ្ឌដំបូងបង្អស់	១៣៣
៤	ពី ១៩៧៩ ដល់ ១៩៩៨ កង្វល់ពីការធ្វើអង្កេត(ប្រជាសាស្ត្រ)	១៣៤
៥	ការតាំងលំនៅមិនទៀងទាត់ និងដង់ស៊ីតេប្រជាជន	១៣៥
៦	ឆ្នាំ ១៩៨៨ ខ្ញុំបានព្យាករណ៍ថានឹងមានការបែងចែកពលកម្មឡើងវិញ	១៣៥
៧	អនុសាសន៍ ៥ ក្នុងសុន្ទរកថា ស្តីពីការជំរឿន	១៣៦

១. លទ្ធផលជំរឿនជាទីទុកចិត្ត

ពីធីបង្ហាញលទ្ធផលជំរឿនប្រជាជនចុងក្រោយ នៃក្រសួងផែនការ,
ថ្ងៃ ៧ កញ្ញា ឆ្នាំ ២០០៩

... ការអង្កេតប្រជាសាស្ត្រ មានការពាក់ព័ន្ធ មិនត្រឹមតែការរាប់ចំនួនប្រជាជនទេ តែក៏មានទាំងទិន្នន័យពាក់ព័ន្ធនានា ក្នុងវិស័យជាច្រើន។ អ្វីដែលនៅជាការព្រួយបារម្ភគឺថា តើលទ្ធផលនៃការជំរឿននេះ អាចជឿទុកចិត្តបានទេ។ វាពិតជាអាចជឿទុកចិត្តបាន ពីព្រោះការធ្វើអង្កេតនេះ មានការសហការពីប្រជាជន និងក្រុមអង្កេតជាច្រើន ដែលមានការគាំទ្រ និងដឹកនាំពីឧបនាយករដ្ឋមន្ត្រី ស ខេង និងឯកឧត្តម ឆាយ ថន ... ដោយមានជំនួយពី UNFPA, JAICA និងរដ្ឋាភិបាលអាឡឺម៉ង់ ...។

២. ដោយសារគោលនយោបាយឈ្នះឈ្នះ ឆ្នាំ ១៩៩៨ កម្ពុជា ធ្វើអង្កេតប្រជាសាស្ត្របាន

ពីធីបង្ហាញលទ្ធផលជំរឿនប្រជាជនចុងក្រោយ នៃក្រសួងផែនការ,
ថ្ងៃ ៧ កញ្ញា ឆ្នាំ ២០០៩

... សូមបញ្ជាក់ថា វាជាអង្កេតទូទៅ ដែលមានន័យថា មិនមានអ្នកណាម្នាក់នៅកម្ពុជា ដែលមិនត្រូវបានកំណត់អត្តសញ្ញាណ ឬតាមភាសាសាមញ្ញថា "កាន់កាតឈ្លូស" ទេ។ ឈ្លូសមានន័យថា ជាបុគ្គលដែលលាក់បាំងខ្លួន។ បន្ទាប់ពីការអនុវត្តគោលនយោបាយឈ្នះ/ឈ្នះ ស្ថានការណ៍ប្រទេសបានធ្វើអោយមានលទ្ធភាព ដែលយើងអាចនឹងធ្វើអង្កេតនៅគ្រប់ទីកន្លែង។ ប្រទេសមួយចំនួន នៅមិនអាចធ្វើដូចនេះបានទេ ដោយសារកំពុងតែមានសង្គ្រាម ... យើងមានប្រជាជនជាង ១១ លាននាក់ ក្នុងឆ្នាំ ១៩៩៨។ មាន ១៣ លាននាក់ ក្នុងឆ្នាំ ២០០៨ និងរំពឹងថានឹងមាន ១៦ លាននាក់ នៅឆ្នាំ ២០១៨ ...។

៣. សន្តិភាព និងឯកភាពជាតិ ជាលក្ខខណ្ឌដំបូងបង្អស់

ពីធីបង្ហាញលទ្ធផលជំរឿនប្រជាជនចុងក្រោយ នៃក្រសួងផែនការ,
ថ្ងៃ ៧ កញ្ញា ឆ្នាំ ២០០៩

... មិនថាអ្នកឯងនិយាយពីអ្វីទេ សន្តិភាព និងការឯកភាពជាតិ ជាលក្ខខណ្ឌដំបូងបង្អស់ មុនចាប់ផ្តើមធ្វើកិច្ចការអ្វីៗ។ តើយើងអាចធ្វើអង្កេតបានទេ នៅក្រោយឆ្នាំ ១៩៧០? កាលនោះ យើងមិនអាចដឹងបានទេថា តើមានមនុស្សប៉ុន្មាននាក់ ដែលចូលទៅរស់នៅក្នុងព្រៃ? ... ប្រទេសត្រូវបានបែងចែកជា ច្រើនផ្នែក ក្រោមការគ្រប់គ្រងពីច្រើនភាគី តើអ្នកណាអាចផ្តល់តួលេខអំពីមនុស្សក្នុងតំបន់ខ្លួន? ... ខ្ញុំនឹងការពារសន្តិភាព និងមិនអនុញ្ញាតអោយជនណា/ក្រុមណាបំផ្លាញបានឡើយ។ ដោយហេតុនេះហើយ បានជាយើងអាចធ្វើអង្កេតនៅពេលយប់រាប់ចំនួនប្រជាជន។ ស្មានមើល តើយើងអាចធ្វើកើតទេ បើនៅក្នុងពេលមានសង្គ្រាម? ...។

៤. ពី ១៩៧៩ ដល់ ១៩៩៨ កង្វល់ពីការធ្វើអង្កេត(ប្រជាសាស្ត្រ)

ពីធីបង្ហាញលទ្ធផលជំរឿនប្រជាជនចុងក្រោយ នៃក្រសួងផែនការ,
ថ្ងៃ ៧ កញ្ញា ឆ្នាំ ២០០៩

... **ក្នុងរវាងឆ្នាំ ១៩៧៩ និង ១៩៩៨ មានការលំបាកណាស់ ដើម្បីនឹងធ្វើការអង្កេត ដែលកាលនោះ មានគោលបំណងមួយផ្នែកជាសំខាន់គឺស្រាយកង្វល់អំពីបញ្ហាជំងឺគ្រុនស្វិតដៃជើង។ ខ្ញុំទៅកំពត ដើម្បីផ្តល់វ៉ាក់សាំង ដែលពេលនោះ មានសំណួរមិនចេះចប់ថា តើយើងអាចធានាថា អោយកុមារគ្រប់គ្នាបានសុវត្ថិភាពពីជំងឺគ្រុនស្លាប់ដៃជើងបានដូចម្តេចទៅ ក្នុងពេលដែលយើងមិនទាន់បញ្ចូលមកក្នុងជាតិ នូវតំបន់ដូចជាភ្នំវល្លិ តាកែនកោះស្លា ជាដើម។** នៅភាគ ខាងជើងផ្លូវជាតិលេខ ៥ ពីម៉ាល័យ ដល់ប៉ៃលិន សំឡូត... ។ល។ ខ្ញុំបាននាំវ៉ាក់សាំងយកទៅផ្តល់នៅទីនោះ ... ក្រោយមក នៅឆ្នាំ ២០០២ មានការប្រកាសថា កម្ពុជាជាប្រទេសដែលរួចផុតពីជំងឺគ្រុនស្វិតដៃជើង។ នៅពេលបច្ចុប្បន្ន ប្រទេសមួយចំនួនដូចជា ហ្វីលីពីន ដែលមានតំបន់ស្ថិតក្រោមការត្រួតត្រារបស់ពួកម៉ុនរ៉ូ និងអ៊ីស្លាមនិយម Abu Sayaf ... តើពួកគេអាចរកបានតួលេខប្រជាជនត្រឹមត្រូវទេ?...។

៥. ការតាំងលំនៅមិនទៀងទាត់ និងដង់ស៊ីតេប្រជាជន

ពីធីបង្ហាញលទ្ធផលជំរឿនប្រជាជនចុងក្រោយ នៃក្រសួងផែនការ,
ថ្ងៃ ៧ កញ្ញា ឆ្នាំ ២០០៩

... និយាយពីការអង្កេត ខ្ញុំបានកត់សម្គាល់ពីក្តីបារម្ភរបស់យើង ស្តីពីភាពមិនទៀងទាត់នៃការតាំងលំនៅរបស់ប្រជាជនយើង ... មានការបង្ហាញនៅទីនេះថា ដង់ស៊ីតេប្រជាជនបានកើនពី ៧៤ ទៅ ៧៥ នាក់ ក្នុងមួយគីឡូម៉ែត្រក្រឡា។ ដង់ស៊ីតេប្រជាជននៅតំបន់ទំនាប ត្រូវបានកត់ត្រាថា មានដល់ ២៦១ នាក់/គីឡូម៉ែត្រក្រឡា។ នេះជាមោទនភាពជាតិយើង។ កាលពីឆ្នាំ ១៩៩៦ ខ្ញុំបានទីតំបន់សមាហរណកម្មនៅសំឡូត និងបានជួបអ្នកដែលទើបតែទៅពីភាគកណ្តាលប្រទេស។ ក្នុងប៉ុន្មានឆ្នាំចុងក្រោយ យើងបានកត់សម្គាល់ឃើញថា មានចំណាកស្រុកមួយផ្នែក ដើម្បីស្វែងរកការងារនៅភ្នំពេញ និងមួយផ្នែកទៀត ទៅខាងជើង និងឥសាន្ត ដើម្បីការងារក្នុងវិស័យកសិកម្ម ...។

៦. កាលពីឆ្នាំ ១៩៨៨ ខ្ញុំបានព្យាករណ៍ថានឹងមានការបែងចែកពលកម្មឡើងវិញ

ពិធីបង្ហាញលទ្ធផលជំរឿនប្រជាជនចុងក្រោយ នៃក្រសួងផែនការ,
ថ្ងៃ ៧ កញ្ញា ឆ្នាំ ២០០៩

... នេះជាអ្វីដែលខ្ញុំបានសរសេរ(១០ ឆ្នាំនៃដំណើរកម្ពុជា)កាលពីឆ្នាំ ១៩៨៨។ ខ្ញុំបានព្យាករណ៍ថា នឹងត្រូវការអោយមានការបែងចែកពលកម្មឡើងវិញ ក្នុងគោលដៅបម្រើការអភិវឌ្ឍសង្គម/សេដ្ឋកិច្ច និងក្នុងគោលដៅការពារជាតិ។ យើងមិនអាចធ្វើកាលពីពេលមុនបាន តែពេលនេះយើងមានលទ្ធភាពច្រើនជាងកាលពីមុន ... ទីមួយ, យើងមានសន្តិភាពនៅទូទាំងប្រទេស។ ទីពីរ, ប្រជាពលរដ្ឋយើងមានសាមគ្គីភាពគ្នាល្អ និងមិនសងសឹកគ្នា ឬប្រកាន់ទស្សនៈតំបន់និយម។ ទីបី, យើងមានហេដ្ឋារចនាសម្ព័ន្ធដែលល្អជាងមុន ... យើងបានប្រែក្លាយតំបន់អសន្តិសុខនានា អោយទៅជាតំបន់អភិវឌ្ឍ ...។

៧. អនុសាសន៍ ៥ ក្នុងសុន្ទរកថា

ពិធីបង្ហាញលទ្ធផលជំរឿនប្រជាជនចុងក្រោយ នៃក្រសួងផែនការ,
ថ្ងៃ ៧ កញ្ញា ឆ្នាំ ២០០៩

... **១. ការប្រើទិន្នន័យ**សម្រាប់ការជំរឿន ត្រូវតែមានគុណភាពជឿទុកចិត្តបាន និងធំទូលាយ ដើម្បីដាក់ចេញជាគោលនយោបាយ ផែនការកម្ម និងកម្មវិធីជាតិនានា, **២. វិភាគទិន្នន័យ**ជំរឿនអោយបានគ្រប់ជ្រុងជ្រោយ ដើម្បីជានាសេចក្ដីត្រូវការទិន្នន័យគ្រប់យ៉ាង សម្រាប់អ្នកស្រាវជ្រាវ និងសេចក្ដីត្រូវការទិន្នន័យ នៅថ្នាក់ក្រោមជាតិ, **៣. ប្រមូលធនធាន** ធ្វើការជំរឿនជាក់លាក់មួយចំនួនក្នុងពេល ៣ ឆ្នាំ ខាងមុខ ពិសេសសម្រាប់វិស័យឧស្សាហកម្ម និងកសិកម្ម, ៤. លើកកំពស់ការងារ បណ្ដុះបណ្ដាល កសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្សសម្រាប់ការងារស្ថិតិ និង ៥. **ពង្រឹងប្រព័ន្ធស្ថិតិជាតិ, បង្កើតប្រព័ន្ធសមស្របនឹងច្បាប់ស្ថិតិ** សង្គតភាពជាមួយផែនការមេស្ថិតិ ។

ពាណិជ្ជកម្ម

១	តម្រូវការទិញថយ ការនាំចេញតិច, ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច	១៣៩
២	បន្ថយអតុល្យភាពជញ្ជីងពាណិជ្ជកម្មកម្ពុជា-ថៃ	១៣៩
៣	គួរតែចៀសវាង ការធ្វើសង្គ្រាមពាណិជ្ជកម្ម	១៤០
៤	បំបាត់ចោលនូវការលួចគេចពន្ធ	១៤០
៥	នយោបាយបែរមុខទៅខាងក្រៅដើម្បីនាំអង្ករចេញ	១៤១
៦	ផ្ទៃកគយ កាំកុងត្រូល សូមជួយសម្រួលការនាំចេញស្រូវ-អង្ករ	១៤១
៧	បន្ទូរបន្ថយពន្ធ តែទំនិញអត់គុណភាពប្រកួតប្រជែង	១៤២
៨	នយោបាយនាំចេញនៅនឹងកន្លែង	១៤២
៩	សេដ្ឋកិច្ចផ្សារសេរី ប្រកួតប្រជែង មិនមានមនុស្សធម៌ទេ	១៤២
១០	វិធានក្នុងអង្គការពាណិជ្ជកម្មពិភពលោក	១៤៣
១១	កម្ពុជា សំរបសំរួលក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ក្នុងក្របខណ្ឌ WTO	១៤៣
១២	E-commerce ដើម្បីពន្លឿនការងារពាណិជ្ជកម្ម	១៤៤
១៣	ទំហំពាណិជ្ជកម្មវៀតណាម/កម្ពុជា ៥ ពាន់លានដុល្លារ មិនលំបាក	១៤៤
១៤	វិនិយោគិនវៀតណាម ឈរលេខ ៣ ក្នុងការអនុវត្តជាក់ស្តែង	១៤៥
១៥	ការវិនិយោគក្នុងប្រទេសរបស់ជនជាតិកម្ពុជា សម័យមុន និងបច្ចុប្បន្ន	១៤៥
១៦	គោលនយោបាយដ៏ត្រឹមត្រូវរបស់គណបក្សកាន់អំណាច	១៤៦
១៧	ការឈប់យកថ្លៃឆ្លងកាត់ផ្លូវជាតិលេខ ៤ ជួយសម្រួលដល់ពាណិជ្ជកម្ម	១៤៧
១៨	ការធ្វើពាណិជ្ជកម្ម គឺមានទាក់ទងជាមួយនឹងការដឹកជញ្ជូន	១៤៧
១៩	ខិតខំបើកទីផ្សារចិន សម្រាប់វិស័យកសិផលកម្ពុជា	១៤៨
២០	ទំហំពាណិជ្ជកម្មទ្វេទិសជាមួយចិនកាន់តែធំ	១៤៨
២១	រក្សាទីផ្សារចាស់ពង្រឹងទីផ្សារចាស់ និងបើកពង្រីកទីផ្សារថ្មី	១៤៩

១. ពេលតម្រូវការទិញថយចុះ ការនាំចេញរបស់យើងក៏ត្រូវ, ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច

ពិធីចែកសញ្ញាបត្រដល់និស្សិតសាកលវិទ្យាល័យអន្តរជាតិ (IU), ២៤ មីនា ២០០៩

... **សម័យកាលយើងស្ថិតនៅក្នុងដំណាក់កាលសង្គ្រាម តើយើងមានការនាំចេញទេ? វាអត់មានផលិតផលនាំចេញ។ យើងបានប្រឹងធ្វើតាំងពីកម្រិតឆ្នាំ ១៩៩៤ បានតែ ៤ លានដុល្លារទេ។ យើងធ្វើឲ្យឆ្នាំ ២០០៧ កន្លងទៅ នាំចេញបានជាង ៤ ៣ន់លាន តែលើវិស័យកាត់ដេរមួយទេ។ បើប្រទេសមិនរីកលូតលាស់ មិនមានទំនិញនាំចេញទេ ... (ជា)តថភាពសង្គម ការវិវឌ្ឍរបស់សង្គមពីប្រទេសមួយដែលចាំតែទទួលការទិញពីខាងក្រៅ ទៅជាប្រទេសមួយមានការនាំចេញ ហើយនាំចេញលើកនេះ ខុសពីដំណាក់កាល ១៩៩៣-៩៨ ដែលនាំឈើហ៊ីបចេញ។** ឥឡូវគ្មានឲ្យនាំចេញទេ ... ការ(ថយចុះនៃការ)បញ្ជាទិញនោះ ដោយសារប្រទេសមួយចំនួនគ្នាបាត់បង់ការងារធ្វើ ជាពិសេស នៅអាមេរិក និងអឺរ៉ុប ដល់បាត់បង់ការងារធ្វើ (នាំអោយ)តម្រូវការមានការថយចុះដែរ (ហើយ)វាប៉ះពាល់ដល់ការបញ្ជាទិញនៅប្រទេសយើងលើវិស័យកាត់ដេរ ...។

២. បន្ថយអតុល្យភាពជញ្ជីងពាណិជ្ជកម្មកម្ពុជា-ថៃ

ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់កំណាត់ផ្លូវជាតិលេខ ៦៧ ពីខេត្តសៀមរាប ទៅដល់ស្រុកអន្លង់វែង, ០៤ កក្កដា ២០០៩

... **អ្វីទៅជាសារៈសំខាន់ពីកិច្ចសហប្រតិបត្តិការទំនាក់ទំនងពាណិជ្ជកម្មរវាងប្រទេសទាំងពីរ? ក្នុងឆ្នាំ ២០០៨ កន្លងទៅមានជាង ១ ៧០០ លានដុល្លារអាមេរិក ក្នុងនេះ ថៃនាំចូលមកកម្ពុជាចំនួន ១ ៤០០ លានដុល្លារ ឯកម្ពុជានាំចូលទៅថៃវិញ មានចំនួនតែ ៣០០ លានដុល្លារទេ។ អញ្ចឹងហើយ បានជា ខ្ញុំអំពាវនាវក្នុងឱកាស នៃការប្រជុំចរចាទ្វេភាគី រវាងនាយករដ្ឋមន្ត្រីទាំងពីរ និងគណៈប្រតិភូ គឺសុំឱ្យខាងភាគីថៃជួយទិញកសិផលពីប្រជាកសិករកម្ពុជាតំបន់តាមព្រំដែនដើម្បីកាត់បន្ថយអតុល្យភាពនៃជញ្ជីងពាណិជ្ជកម្ម រវាងប្រទេសទាំងពីរ ... ឥឡូវនេះ ការធ្វើពាណិជ្ជកម្មរវាងប្រទេសទាំងពីរកាន់តែងាយស្រួល តាមរយៈហេដ្ឋារចនាសម្ព័ន្ធនេះ ... ចរាចរតាមផ្លូវនេះ គឺល្អហើយការផ្លាស់ប្តូរទំនិញតាម**

ច្រកប៉ោយប៉ែតក៏ប្រសើរ ដោយសារយើងបានធ្វើផ្លូវ ...។

៣. គួរតែចៀសវាង ការធ្វើសង្គ្រាមពាណិជ្ជកម្ម

ពិធីផ្សព្វផ្សាយគម្រោងគ្រប់គ្រង និងទប់ស្កាត់បន្ទាន់ជម្ងឺផ្តាសាយបក្សី
និងផ្តាសាយមនុស្ស, ១៧ មីនា ២០០៩

... ជួនកាលវាកាច់ក្បាងគ្នារវាងសាច់ជ្រូកជាមួយនឹងសាច់មាន់។ ដល់មាន់ចង់ឡើងថ្លៃ ថាសាច់ជ្រូកឆ្លុត ... អញ្ចឹងវាឆ្លុត ឲ្យវាឆ្លុតពិត ឈឺឲ្យវាឈឺពិត ព្រោះនៅលើពិភពលោក កន្លែងមួយចំនួនមាន ដែលគេហៅថាសង្គ្រាមពាណិជ្ជកម្មសាច់គោ ... នៅប្រទេសមួយចំនួនដែលគេមិនចង់ទទួលសាច់គោអាមេរិក គេថា គោអាមេរិកឆ្លុត ... វាទៅជាសង្គ្រាមពាណិជ្ជកម្ម ក៏ប៉ុន្តែ ត្រូវបានបំភ័យក្នុងចិត្តសាស្ត្ររបស់ប្រជាពលរដ្ឋ មិនថាប្រទេសមួយទេ គឺប្រទេសនៅលើពិភពលោក ... អញ្ចឹងបានទាមទារឲ្យមានតម្លាភាពនៅទីនេះ បើឈឺឲ្យប្រាកដឈឺហើយ ត្រូវហ៊ានប្តូរផ្តាច់សកម្មភាព ...។

៤. បំបាត់ចោលនូវការលួចគេចពន្ធ

ពិធីសម្ពោធមធ្យោបាយលើកដាក់ក្នុងតឺន័រ និងជួបសំណេះសំណាលជាមួយកម្មករ
និង និយោជិតកំពង់ផែស្វយ័តក្រុងព្រះសីហនុ, ៣០ មេសា ២០០៩

... គ្រប់ផ្នែកពាក់ព័ន្ធទាំងអស់ ពិសេសសមត្ថកិច្ច ទាំងគយ ទាំងនគរបាល ទាំងអាវុធហត្ថ ទាំងកងទ័ពពីរប្រភេទ សហប្រតិបត្តិការគ្នាបំបាត់ការលួចគេចពន្ធ ក៏ឲ្យវាឲ្យមកចូលច្រកបង់ពន្ធ ទើបធ្វើឲ្យថវិកាជាតិរបស់យើងមានកំណើនកើនឡើង។ ចូលតាមច្រកគយទាំងឡាយ កុំចូលតាមរបៀង ហើយវាយតម្លៃឲ្យបានត្រឹមត្រូវ។ ឧទាហរណ៍ថា អាហ្នឹងថ្លៃ ១០០ ត្រូវវាយតម្លៃថា ១០០ កុំលេងតម្លៃ ១០០ វាយតំលៃពន្ធតែ ៧០ ទុកអា ៣០ ចែកគ្នា។ ការគ្រប់គ្រងហានិភ័យ ទាក់ទងដល់សុវត្ថិភាពចំណីអាហារ ជាការៈគយ និងកាំកុងត្រូល ត្រូវធ្វើការជាមួយគ្នាយ៉ាងហ្មត់ចត់ ដើម្បីពិនិត្យមើល។ យើងត្រូវមានការទទួលខុសត្រូវជាមួយគ្នាលើសុវត្ថិភាពទំនិញទាំងអស់ ដែលនាំចូលមកក្នុងប្រទេស ...។

៥. នយោបាយបែរមុខទៅខាងក្រៅដើម្បីនាំអង្ករចេញ

ពិធីផ្សព្វផ្សាយឯកសារគោលនយោបាយ ជម្រុញផលិតកម្មស្រូវ និងការនាំចេញអង្ករ, ១៧ សីហា ២០១០

... យើងអាចនិយាយបានថា **ទីផ្សារអង្ករអាចទូលំទូលាយជាងទីផ្សារខាអារ។ ការនាំចេញសំលៀកបំពាក់របស់យើងកំពុងប្រកួតប្រជែងជាមួយប្រទេសច្រើនណាស់ ចំណែកឯអង្ករវិញ មិនមែនប្រទេសណាសុទ្ធតែជាប្រទេសនាំចេញអង្ករប្រកួតប្រជែងទេ។ មានមិនច្រើនទេ**។ ឥឡូវប្រទេសវៀតណាម និង ថៃ ជាប្រទេសដែលនាំចេញអង្ករនាំមុខ ក្រៅពីនោះ មិនមានប្រទេសច្រើនទេដែលនាំចេញអង្ករ ប៉ុន្តែ ប្រទេសច្រើនណាស់ដែលនាំចេញសំលៀកបំពាក់។ អញ្ចឹង **ការប្រកួតប្រជែងអង្ករនេះ គឺទីផ្សារនៅធំ ដែលយើងថានយោបាយបែរមុខទៅខាងក្រៅ ដើម្បីជម្រុញការនាំចេញអង្កររបស់យើង។ នេះជាចំណុចដែលយើងត្រូវមើលឃើញពីសក្តានុពលនៃទីផ្សារ។ យើងពង្រីកទីផ្សារបានឆាប់ជាង** ប៉ុន្តែវាទាមទារ កុំលេងដឹកដល់កណ្តាលសមុទ្រ ដិតដល់កំពង់ផែ ស្រាប់តែសុទ្ធតែខ្ជូត ...។

៦. ផ្នែកគយ កាំកុងត្រូល សូមជួយសម្រួលការនាំចេញស្រូវ-អង្ករ

ពិធីផ្សព្វផ្សាយឯកសារគោលនយោបាយ ជម្រុញផលិតកម្មស្រូវ និងការនាំចេញអង្ករ, ១៧ សីហា ២០១០

... ទាក់ទិនជាមួយនឹងការនាំចេញនាំចូលនេះ គឺត្រូវធ្វើយ៉ាងណាជម្រុញឲ្យវាមានទិដ្ឋភាពប្រហាក់ប្រហែល ដូចគ្នាជាមួយនឹងការដែលយើងធ្វើប្រព្រឹត្តកម្មសម្រាប់ការនាំចេញសំលៀកបំពាក់។ អញ្ចឹងផ្នែកគយក្តី កាំកុងត្រូលក្តី ស្ថាប័នពាក់ព័ន្ធស្មើៗ ជួយសម្រួលកុំពេលនាំចេញទៅខាងនេះយាត់ ខាងនោះយាត់ ពេលទៅដល់កំពង់ផែហើយវានៅត្រេតត្រតនៅហ្នឹង។ ជានាធ្វើម៉េចថា កុងត្រូលជជុះនេះ មិនថាតែស្រូវអង្ករទេ គឺមិនត្រូវឲ្យមានតែម្តង។ ចំណុចនេះ យើងត្រូវបន្តធ្វើ ដូចជាគយ យើងបានធ្វើការណែនាំកន្លងទៅ ទើបការនាំចេញអង្ករមានការកើនឡើង គ្រាន់តែ ៦ ខែដើមឆ្នាំ ស្មើនឹងរយៈពេលមួយឆ្នាំនៃឆ្នាំកន្លងទៅ (១៥៥ ពាន់តោន) យើងសង្ឃឹមថា នឹងមានការនាំចេញបន្ថែមទៀត ...។

៧. បន្ទូរបន្ថយពន្ធ តែទំនិញអត់គុណភាពប្រកួតប្រជែង

ពិធីបិទសន្និបាតបូកសរុបការងារប្រចាំឆ្នាំ ក្រសួងពាណិជ្ជកម្ម, ០៩ កុម្ភៈ ២០១១

... យើងគិតតែពីការនាំចេញ ដែលថាជម្រុញសុំប្រទេសនេះសុំប្រទេសនោះនូវអត្រាធ្លាក់ពន្ធអីចេះអីចុះ។ ប៉ុន្តែ **ទោះបីអត្រាពន្ធធ្លាក់ចុះ តែបើទំនិញរបស់យើងវាអត់គុណភាព ប្រកួតប្រជែងមិនបាន ក៏កុំសង្ឃឹមទៅលើបញ្ហានោះ ព្រោះទីផ្សារសេរីគ្មានត្រាប្រណីទេ។ កុំសង្ឃឹមខ្លាំងពេក លើការអនុគ្រោះពីប្រទេសនេះ ប្រទេសនោះ។ ការអនុគ្រោះសុំចូលបាន វាទាល់តែទំនិញរបស់យើងត្រូវតាមស្តង់ដា ដូច្នេះ ជម្រុញលើការផលិត អំពីបញ្ហានេះឲ្យបានខ្លាំង។ នេះជាចំណុចដែលខ្ញុំចង់និយាយបន្ថែមទៅលើវិស័យពាណិជ្ជកម្ម** ...។

៨. នយោបាយនាំចេញនៅនឹងកន្លែង

ពិធីបិទសន្និបាតបូកសរុបការងារប្រចាំឆ្នាំ ក្រសួងពាណិជ្ជកម្ម, ០៩ កុម្ភៈ ២០១១

... **នយោបាយនាំចេញនៅហ្នឹងកន្លែង តាមរយៈវិស័យទេសចរណ៍ គឺស្ថិតនៅតែជាវិធីសាស្ត្រដ៏ល្អ ដូចដែលខ្ញុំបានលើករឿងនេះជានិច្ចកាលថា ការនាំចេញមិនចាំបាច់និយាយតែរឿងការនាំចេញផ្ទុតព្រំដែនទេ នាំចេញចូលទៅតាមសណ្ឋាគារ បម្រើឲ្យទេសចរបរទេស ក៏ចាត់ទុកថា ជាការនាំចេញមួយនៅនឹងកន្លែងដែរ**។ យើងត្រូវធ្វើសកម្មភាពព្រមៗគ្នា ដើម្បីទាញយកផលប្រយោជន៍ជាអតិបរមាក្នុងក្របខណ្ឌនៃការរីកលូតលាស់ នៃសេដ្ឋកិច្ចរបស់យើង...។

៩. សេដ្ឋកិច្ចផ្សារសេរី ប្រកួតប្រជែង មិនមានមនុស្សធម៌ទេ

ពិធីចែកសញ្ញាបត្រ និស្សិតនៃសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ, ២៦ កុម្ភៈ ២០១៣

... នៅលើពិភពលោកបច្ចុប្បន្ននេះ សេដ្ឋកិច្ចផ្សារសេរីជាសេដ្ឋកិច្ចដែលជឿនលឿន ជាទម្រង់សេដ្ឋកិច្ចដែលត្រូវបានទទួលស្គាល់ ហើយបើចង់ក្លាយទៅជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោកបាន គឺត្រូវជាសេដ្ឋកិច្ចសេរី សេដ្ឋកិច្ចទីផ្សារ។ ហ្នឹង គឺជាវិធានដែលប្រទេសទាំងអស់នៅលើពិភពលោកទទួលយក។ ដែលហៅថា **សេដ្ឋកិច្ចផ្សារសេរី គឺអយុត្តិធម៌ណាស់ សម្រាប់ជនក្រីក្រ អយុត្តិធម៌**

គ្មានមនុស្សធម៌ទេ។ ដែលហៅថា សេដ្ឋកិច្ចផ្សារសេរី គឺការប្រកួតប្រជែង។ ត្រូវចាំអាកន្លែងហ្នឹង។ ខុសគ្នាជាមួយសេដ្ឋកិច្ចផែនការចាប់បង្ខំ ដែលបានកើតឡើងនៅក្នុងដំណាក់កាលនៃសង្គ្រាមត្រជាក់ និងមានប្រទេសដែលអនុវត្តសេដ្ឋកិច្ចផែនការ រហូតដល់រដ្ឋហ៊ានលូកដៃកំណត់ថ្លៃទំនិញ ហើយបើខាត រដ្ឋត្រូវបំពេញខាតឱ្យសហគ្រាស។ ដល់បំពេញយូរៗទៅ រដ្ឋហ្នឹងវាអស់លុយ វាចូលដល់គេហៅរដ្ឋក្សយ័យធនទៅទៀត ...។

១០. វិធានក្នុងអង្គការពាណិជ្ជកម្មពិភពលោក

ពិធីចែកសញ្ញាបត្រ និស្សិតនៃសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ, ២៦ កុម្ភៈ ២០១៣

... **វាស្ថិតនៅក្នុងវិធាននៃអង្គការពាណិជ្ជកម្មពិភពលោក ហើយប៉ុន្មានឆ្នាំ យើងត្រូវប្រជុំត្រួតពិនិត្យម្តង ជាមួយនឹងអង្គការពាណិជ្ជកម្មពិភពលោករួចហើយ ប្រទេសជាច្រើនដាក់សំណូរមកលើយើងឱ្យឆ្លើយ។ យើងក៏មានសិទ្ធិដាក់សំណូរទៅប្រទេស ដែលចូលជាសមាជិកថ្មី ដែលត្រូវប្រជុំត្រួតពិនិត្យជាមួយអង្គការពាណិជ្ជកម្មពិភពលោក ... គ្រាន់តែយើងប្រើឥណទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ីមួយនោះ (មាន)ភ្ជាប់ជាយលក្ខខណ្ឌ ៣ គឺ ទី ១ - ត្រូវធ្វើឯកជនូបនីយកម្មសហគ្រាស (ក្រុមហ៊ុននេសាទ ពីមុនជាក្រុមហ៊ុនរដ្ឋ) ទី ២ - ត្រូវធ្វើឯកជនូបនីយកម្ម ក្រុមហ៊ុនសម្ភារៈកសិកម្ម ដែលមុននេះគ្រប់គ្រងដោយរដ្ឋ មានតាំងពីត្រាក់ទ័រ មានតាំងពីជីកសិកម្មស្តីៗនេះ គឺគេឱ្យយើងធ្វើឯកជនូបនីយកម្ម និងទី ៣ - ត្រូវធ្វើឯកជនូបនីយកម្មចំការកៅស៊ូរដ្ឋទាំងអស់។ ឥណទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ីមួយទៀត តម្រូវឱ្យធ្វើឯកជនូបនីយកម្មផ្លូវជីក អត់ឱ្យរដ្ឋគ្រប់គ្រង ...។**

១១. កម្ពុជា សំរបសំរួលក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ក្នុងក្របខណ្ឌ WTO

ពិធីចែកសញ្ញាបត្រជូននិស្សិត នៃសាកលវិទ្យាល័យ ភ្នំពេញអន្តរជាតិ, ២២ កុម្ភៈ ២០១៧

... **កម្ពុជាបានទទួលនូវកិត្តិយស ជាប្រទេសសម្របសម្រួលនៃប្រទេសដែលអភិវឌ្ឍន៍តិចតួចក្នុងក្របខណ្ឌនៃអង្គការពាណិជ្ជកម្មពិភពលោក(WTO)។ យើង**

បានទទួលតំណែងនេះ មិនមែនជាតំណែងធម្មតា ដែលអ្នកណាក៏សុទ្ធតែបាននោះទេ។ ក្រៅពីតួនាទីជាអ្នកសម្របសម្រួលនៃបណ្តាប្រទេសអភិវឌ្ឍន៍តិចតួចក្រោមក្របខណ្ឌនៃអង្គការពាណិជ្ជកម្មពិភពលោក កម្ពុជាមានការកិច្ចនឹងទទួលជួយទីម័រលេស្តេ រៀបចំខ្លួនក្នុងការចូលអង្គការពាណិជ្ជកម្មពិភពលោក។ ចំណុចនេះ ស្តែងចេញពីកត្តាធនធានមនុស្សនេះឯង ដែលយើងត្រូវមើលឃើញថា ជាចំណុច ដែលមិនមែនចាប់ផ្តើមមកពីគ្រាន់តែរឿងសេដ្ឋកិច្ចរបស់យើងមានកំណើនទេ ប៉ុន្តែ វាផ្តើមចេញពីស្ថាប័ន និងធនធានមនុស្សរបស់យើងតែម្តង បានជាកម្ពុជាបានទទួលនូវកិត្តិយស ជាអ្នកសម្របសម្រួលនៃប្រទេសដែលមានការអភិវឌ្ឍតិចតួច ...។

១២. E-commerce ដើម្បីពន្លឿនការងារពាណិជ្ជកម្ម

រ៉ូទិការាជរដ្ឋាភិបាល-ផ្ទៃកឯកជន លើកទី ១៧, ០៤ មីនា ២០១៤

... រាជរដ្ឋាភិបាល តែងតែយកចិត្តទុកដាក់លើការផ្តោនកំណែទម្រង់ ក្នុងគោលដៅកែលម្អបរិយាកាសវិនិយោគ និងធុរកិច្ចនៅកម្ពុជា ... **ខ្ញុំសូមលើកទឹកចិត្តឲ្យយើងទាំងអស់គ្នាបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីសម្រួលពាណិជ្ជកម្មឲ្យកាន់តែស៊ីជម្រៅ និងល្បឿនលឿន។ យើងអាចនឹងរៀបចំឲ្យមាននូវប្រព័ន្ធស្វ័យប្រវត្តិកម្មផ្សេងៗ ឲ្យវាទៅលឿន។ ការចុះបញ្ជីពាណិជ្ជកម្មស្តីៗ ហ្នឹង ទៅឲ្យវាលឿន។ ឥឡូវគេចុះតាមអេឡិចត្រូនិច (E-commerce) ... ឲ្យវាទៅ E ទាំងអស់តែម្តងទៅ មិនចាំបាច់រត់ការមកដល់កន្លែងទេ**។ យើងអាចត្រួតពិនិត្យបាន ប៉ុន្តែកុំឲ្យមាន E បន្ថែ ... ដល់លេង E ទាំងអស់អញ្ចឹងទៅ វាល្បឿនលឿន...។

១៣. បើការជាវអគ្គិសនី ជាការដោះដូរទំនិញ ទំហំពាណិជ្ជកម្មវៀតណាម/កម្ពុជា ៥ ពាន់លានដុល្លារ មិនលំបាក

សន្និសីទកម្ពុជា-វៀតណាម លើកទី ៤ ស្តីពីកិច្ចសហប្រតិបត្តិការវិនិយោគ, ១៣ មករា ២០១៤

... យើងនៅមានសក្តានុពលទៅវិញទៅមកច្រើនណាស់ ព្រោះប្រជាជនវៀតណាម ក៏មានលុយមកចាយនៅកម្ពុជា ឥឡូវប្រជាជនកម្ពុជា ក៏មានលុយទៅចាយ

នៅវៀតណាមដែរ អាហ្នឹងគឺបំពេញឲ្យគ្នាទៅវិញទៅមក។ ទំហំនៃពាណិជ្ជកម្ម។ **ខ្ញុំមិនដឹងថា តើការលក់អគ្គិសនីឲ្យកម្ពុជា ១៧០ មេហ្គាវ៉ាត់ ឬកើនថែម ៣០ មេហ្គាវ៉ាត់ខាងមុខ គិតនៅក្នុងទំហំពាណិជ្ជកម្មនោះឬអត់? បើសិនជាអគ្គិសនីមិនទាន់បានគិតទេ តើគួរត្រូវគិតការលក់អគ្គិសនីនេះជាទំនិញមួយទេ? បើគិតរឿងហ្នឹងថែមទៀត ខ្ញុំរំពឹងថា ឆ្នាំ ២០១៥, ៥០០០ លានដុល្លារ វាអត់លំបាកទេ។** មិនដឹងថា ឯកឧត្តម ស៊ុយ សែម ឯកឧត្តម ចម ប្រសិទ្ធ ឯកឧត្តម ស៊ុន ចាន់ថុល ធ្លាប់បានគិតអគ្គិសនីនៅក្នុងការផ្លាស់ប្តូរទំនិញ ឬអត់? កន្លងទៅប្រហែលមិនទាន់បានគិតអាហ្នឹងចូលក្នុងវិស័យពាណិជ្ជកម្មដែរទេ? ... ខ្ញុំគ្រាន់តែបញ្ជាក់បន្ថែមអំពីការជម្រុញក្នុងមួយទសវត្សរ៍ចុងក្រោយ ...។

១៤. វិនិយោគិនវៀតណាម ឈរលេខ ៣ ក្នុងការអនុវត្តជាក់ស្តែង

> សន្និសីទកម្ពុជា-វៀតណាម លើកទី ៤ ស្តីពីកិច្ចសហប្រតិបត្តិការវិនិយោគ, ១៣ មករា ២០១៤

... **សូមទាញការយកចិត្តទុកដាក់អំពីអ្នកវិនិយោគិនមកពីវៀតណាម បើយើងពិនិត្យអំពីតួលេខអនុវត្តពិត ខ្ញុំមិននិយាយពីការចុះបញ្ជីទេ អ្នកវិនិយោគវៀតណាមកំពុងស្ថិតលំដាប់ទី ៣ ប៉ុន្តែ បើយើងនិយាយអំពីការចុះបញ្ជី គឺស្ថិតនៅលំដាប់ទី ១០ ឬ ១១ ... យើងធ្លាប់មានបទពិសោធន៍ហើយ កាលពីឆ្នាំ ១៩៩៤-៩៥ ថា មានវិនិយោគប៉ុន្មានពាន់លាន ប៉ុន្តែគ្រាន់តែមានក្នុងក្រដាស។** ឥឡូវនេះ បើនៅក្នុងក្រដាស វៀតណាមនៅក្នុងលំដាប់ទី ១០ ឬ ទី ១១ ប៉ុន្តែ លើការជាក់ស្តែង វៀតណាមកំពុងឈរក្នុងលំដាប់ទី ៣, ចិនទី ១, កូរ៉េខាងត្បូងទី ២, គឺវៀតណាមទី ៣ ...។

១៥. ភាពខុសគ្នានៃការវិនិយោគក្នុងប្រទេសរបស់ជនជាតិកម្ពុជា សម័យមុន និងបច្ចុប្បន្ន

> ពិធីពិសារអាហារសាមគ្គី ជាមួយនឹងក្រុមឧកញ៉ា អ្នកធុរកិច្ច និងមន្ត្រីជាន់ខ្ពស់ រៀបចំដោយ «សមាគមអ្នកឧកញ៉ា», ២២ សីហា ២០១៥

... យកឱកាសនេះ ធ្វើការប្រៀបធៀបបន្តិចរវាងអតីតកាល និងបច្ចុប្បន្ន។ ពិតណាស់ ការកាត់ផ្តាច់រវាងដំណាក់កាលអភិវឌ្ឍន៍មួយ ពីចន្លោះឆ្នាំ ១៩៥៣ ដល់

ឆ្នាំ ១៩៧០ ហើយការកាត់ផ្តាច់ដោយសង្គ្រាមឆ្នាំ ១៩៧០ ដល់ ១៩៧៥ និងរបបប្រល័យពូជសាសន៍ ឆ្នាំ ១៩៧៥ ដល់ ១៩៧៩។ ប៉ុន្តែអ្វីដែលគួរកត់សំគាល់ ហើយដែលខ្ញុំមានការគោរពយ៉ាងជ្រាលជ្រៅចំពោះ អ្នកឧកញ៉ាលោកឧកញ៉ា និងអ្នកធុរកិច្ចទាំងអស់ នៅត្រង់ថា **កាលពីសម័យមុនឆ្នាំ ១៩៧០ (ក្នុងពេលដែល) កម្ពុជាបានទទួលតិចតួចនូវការវិនិយោគពីខាងក្រៅ ជនជាតិកម្ពុជាដែលមានប្រាក់កាស បានយកប្រាក់កាសទៅវិនិយោគនៅប្រទេសក្រៅ តាមរយៈការដាក់ប្រាក់កាសនៅធនាគារប្រទេសស្វ៊ីស នៅហុងកុង និងទៅទិញផ្ទះនៅប្រទេសក្រៅយ៉ាងក្រាស់ក្រែល។ តែសម្រាប់អ្នកមានជំនាន់ក្រោយ ប៉ុល ពត បែរជាខិតខំថែរក្សានូវទ្រព្យសម្បត្តិ ប្រាក់កាសទាំងនេះ ដើម្បីវិនិយោគលើទឹកដីដ៏កម្សត់របស់ខ្លួន**។ ឥឡូវនេះ សូមសង្កេតមើលថា តើអគារធំៗខ្ពស់ៗ និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ផ្សេងៗ តើមានប៉ុន្មានជាអ្នកវិនិយោគនៅក្នុងប្រទេស និងប៉ុន្មានជាអ្នកវិនិយោគមកពីក្រៅប្រទេស? ... ជនជាតិកម្ពុជា បានរក្សាដើមទុននៅក្នុងប្រទេសរបស់ខ្លួន បង្កើតឡើងនូវមោទនភាពរបស់ជាតិ និងបង្កើតឡើងនូវសក្តានុពលដ៏ធំសម្រាប់ពេលខាងមុខ ដែលកម្ពុជាស្មើមុខស្មើមាត់ ជាមួយនឹងប្រទេសដទៃ ...។

១៦. គោលនយោបាយដ៏ត្រឹមត្រូវរបស់គណបក្សកាន់អំណាច

> ពិធីពិសារអាហារសាមគ្គី ជាមួយនឹងក្រុមឧកញ៉ា អ្នកធុរកិច្ច និងមន្ត្រីជាន់ខ្ពស់
> រៀបចំដោយ «សមាគមអ្នកឧកញ៉ា», ២២ សីហា ២០១៥

... មានមោទនភាពជាមួយនឹងគោលនយោបាយរបស់គណបក្ស ក៏ដូចជាការដឹកនាំរបស់ខ្លួនខ្ញុំ ដែលបានទទួលខុសត្រូវទៅលើនីតិប្រតិបត្តិជាង ៣០ ឆ្នាំកន្លងមកនេះ។ ប្រសិនបើអ្នកទាំងអស់មិនទុកចិត្តទៅលើសមត្ថភាពដឹកនាំរបស់គណបក្សប្រជាជន ការដឹកនាំរបស់រាជរដ្ឋាភិបាល និងស្ថេរភាពរបស់ប្រទេស អ្នកទាំងអស់ពិតជានឹងយកប្រាក់កាសនោះ ទៅផ្ញើនៅបរទេស ឬទៅទិញផ្ទះនៅបរទេសមិនរីរវល់នឹងការវិនិយោគនៅទីនេះនោះទេ។ **គណបក្សប្រជាជន ដែលដឹកនាំរាជរដ្ឋាភិបាល តែងបានខិតខំធ្វើនូវអ្វីៗទាំងអស់ ដើម្បីបង្កើតនូវបរិយាកាសអនុគ្រោះសម្រាប់ការរីកលូតលាស់នៃវិស័យសេដ្ឋកិច្ច ដែលក្នុងនោះទាក់ទិនជាមួយនិងការវិនិយោគ ដែលរាជរដ្ឋាភិបាលបានប្រឹង ទាំងផ្នែកវីង និងផ្នែកទន់**

រួមមានច្បាប់ ដំណោះស្រាយផ្សេងៗ ដែលទាក់ទងទៅនឹងសម្រួលកិច្ចការវិនិយោគ ក៏ដូចជាបង្កបរិយាកាសជឿទុកចិត្ត សម្រាប់ការជាក់ទុននៅកម្ពុជា ...។

១៧. ការឈប់យកថ្លៃឆ្លងកាត់ផ្លូវជាតិលេខ ៤ ជួយសម្រួលដល់ពាណិជ្ជកម្ម

វេទិកាស្រូវអង្ករកម្ពុជា លើកទី ៥, ២៥ មករា ២០១៦

... **បន្ទាប់ពីរាជរដ្ឋាភិបាល បញ្ចប់នូវកិច្ចសន្យាថែទាំផ្លូវ ជាតិលេខ ៤ ខ្ញុំសង្ឃឹមថា សហព័ន្ធស្រូវអង្ករ អ្នកនាំចេញរបស់យើង មិនថាតែស្រូវអង្ករមួយមុខទេ គ្រប់ទាំងអស់ដែលធ្លាប់បង់សេវាដឹកជញ្ជូននៅតាមផ្លូវជាតិលេខ ៤ នឹងត្រូវបានទទួលផល។ ចំណុចនេះ មិនត្រូវមើលឃើញត្រឹមតែការសម្រួលឲ្យប្រជាពលរដ្ឋ ដែលមិនបង់ប្រាក់តទៅទៀតនោះទេ ក៏ប៉ុន្តែវាក៏បានជួយផងដែរ ទៅដល់ការសម្រួលពាណិជ្ជកម្ម កាត់បន្ថយថ្លៃដើម បង្កើនការប្រកួតប្រជែងនៅក្នុងទីផ្សារខាងក្រៅ។** សង្ឃឹមថា ឆ្នាំក្រោយ នៅពេលដែលហ្វីលីពីនត្រូវការតម្រូវការផ្គត់ផ្គង់ថែមទៀត កម្ពុជានឹងមានសមត្ថភាពដេញថ្លៃជាមួយនឹងថៃ ឬវៀតណាម ដើម្បីបានផ្គត់ផ្គង់មួយផ្នែកទៅកាន់ទីផ្សាររបស់ហ្វីលីពីន ... អ្នកដឹកជញ្ជូនត្រូវបង់ថ្លៃសេវា ហើយម៉ុង ឫទ្ធី នេះ អ្នកតវ៉ាខ្លាំងជាងគេ ឥឡូវហ្នឹងបានហើយដោះស្រាយហើយ មិនមែនតែម៉ុង ឫទ្ធី មួយទេ ...។

១៨. ការធ្វើពាណិជ្ជកម្ម គឺមានទាក់ទងជាមួយនឹងការដឹកជញ្ជូន

ពិធីបើកការដ្ឋានសាងសង់ឡើងវិញផ្លូវជាតិលេខ ២១(តាខ្មៅ-ជ្រៃធំ),
២៨ មីនា ២០១៦

... បន្ទាប់ពីការសាងសង់រួចហើយ វាសម្រួលទៅដល់ប្រជាពលរដ្ឋដែលរស់នៅសងខាងផ្លូវ ចំណូលរបស់ប្រជាពលរដ្ឋ ក៏នឹងត្រូវកើនឡើង។ បន្ថែមលើនោះ ការដឹកជញ្ជូនដែលកំពុងតែមានចំណោទ ប្រកួតប្រជែងមិនឈ្នះជាមួយប្រទេសជិតខាង (ដោយសារខាងគេ)មានតម្លៃដឹកជញ្ជូនទាបជាង (នឹងមានសភាព)ប្រសើរឡើង តាមរយៈនៃការប្រឹងប្រែងកសាងផ្លូវ/ស្ពាន ... **សូមជម្រាបជូនថា នៅក្នុងការធ្វើពាណិជ្ជកម្ម មិនថាពាណិជ្ជកម្មក្នុងប្រទេស ឬក្រៅប្រទេសទេ គឺពិតជាមានការពាក់ព័ន្ធជាមួយនឹងការដឹកជញ្ជូននេះឯង។ ... យើងចង់ដឹកជញ្ជូនផលិតផលពី**

ស្រុកស្ពាងរកោះធំ ទៅកាន់ទីក្រុងភ្នំពេញ បើសិនជាផ្លូវលំបាក តម្លៃដឹកជញ្ជូនរបស់យើងវានឹងខ្ពស់ ធ្វើឲ្យផលិតផលអ្នកស្រុកកោះធំ ឬស្រុកស្ពាង មិនអាចប្រកួតប្រជែងបាន ជាមួយនឹងផលិតផលដែលមកពីកៀនស្វាយ ឬមកពីពញាឮ ឬមកពីតំបន់ផ្សេងទៀត ...៖

១៩. ខិតខំបើកទីផ្សារចិន សម្រាប់វិស័យកសិផលកម្ពុជា

ពិធីចែកសញ្ញាបត្រជូននិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ថ្ងៃ ០៦ តុលា ២០១៦

... សំខាន់នៅទីនេះគឺ**ខិតខំបើកទីផ្សារប្រទេសចិនដែលជាទីផ្សារដ៏ធំសម្រាប់វិស័យកសិផលរបស់កម្ពុជា ក្រៅពីអង្ករ ដំឡូងមី ដែលយើងនាំចូលទៅហើយ និងកសិផលមួយចំនួន។ យើងកំពុងបើកកសិផលមួយចំនួន រាប់ទាំងផ្លែចេកជាដើម។ ការវិនិយោគ ការផ្តល់ជំនួយនានានឹងត្រូវបានធ្វើក្នុងទំនាក់ទំនងកម្ពុជា-ចិន ... ជាទំនាក់ទំនងបំពេញឲ្យគ្នាទៅវិញទៅមក។ យើងទៅចិន ចិនមកយើង ហើយទំហំពាណិជ្ជកម្មត្រូវសម្រេចឲ្យបានចំនួន ៥ ពាន់លានដុល្លារសហរដ្ឋអាមេរិក នៅឆ្នាំ ២០១៧**។ គោលដៅនេះអាចនឹងសម្រេចបាន ដោយសារយើងបានសម្រេចលើសពី ៤ ពាន់លានដុល្លារ ឆ្នាំ ២០១៥ រួចស្រេចទៅហើយ។ ប្រទេសចិនមិនមែនប្រទេសដែលខ្វះស្រូវអង្ករនោះទេ ជាប្រទេសដែលមានស្រូវអង្ករគ្រប់គ្រាន់ ហើយមានស្តុកបម្រុងផង ក៏ប៉ុន្តែដោយសារការយោគយល់ ចិនបានបង្កើនពីចំនួន ១០ ទៅ ២០ ម៉ឺនតោន សម្រាប់ការនាំចេញរបស់កម្ពុជា ...**៖

២០. ទំហំពាណិជ្ជកម្មទ្វេទិសជាមួយចិនកាន់តែធំ

ពិធីសម្ពោធដាក់អោយប្រើប្រាស់ ស្ពានមិត្តភាពកម្ពុជា-ចិនតាខ្មៅ
០៣ សីហា ២០១៥

... មិត្តចិន ជាប្រទេសដែលបានរួមចំណែកច្រើនសម្រាប់ប្រទេសកំពុងអភិវឌ្ឍ មិនថាអាស៊ី មិនថាអាហ្វ្រិក មិនថាអាមេរិកឡាទីននោះទេ។ **កម្ពុជាជាប្រទេសមួយ ដែលមានទំនាក់ទំនងភាពជាដៃគូជាយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ(ជាមួយចិន) ដែលទាមទារឲ្យមានការសហការគ្នាកាន់តែស៊ីជម្រៅឡើង កាន់តែមាន**

ប្រសិទ្ធភាពឡើងលើគ្រប់វិស័យទាំងអស់ ជាពិសេស គឺទំនាក់ទំនងខាងសេដ្ឋកិច្ច ... យើងចង់បាន(ទំហំ)ពាណិជ្ជកម្មថេរ។ ទំហំពាណិជ្ជកម្មរបស់យើងជាមួយនឹងចិនកាន់តែធំទៅៗ ហើយចំនួនទេសចរចិនឆ្នាំនេះ គឺប្រហែលជាអាចនឹងទៅលើសកន្លះលាននាក់ ... យើងនឹងបើកកុងស៊ុលកន្លែងថ្មីៗទៀត សម្រាប់ការហោះហើររបស់ចិនពីគោលដៅផ្សេងៗ។ ចិនមកចាយលុយនៅស្រុកខ្មែរ។ បន្ថែមបង្ការស្ពឺ លក់ចូលផ្សារ លក់ចូលអូតែលរបស់យើង ...។

២១. រក្សាទីផ្សារចាស់ ពង្រឹងទីផ្សារចាស់ និងបើកពង្រីកទីផ្សារថ្មី

ពិធីចែកសញ្ញាបត្រជូននិស្សិតនៃសាកលវិទ្យាល័យកូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ថ្ងៃ ០៦ តុលា ២០១៦

... កំណើនសេដ្ឋកិច្ចនៅលើពិភពលោកត្រូវបានទម្លាក់ជាបន្តបន្ទាប់ដោយ IMF ព្រោះឃើញសេដ្ឋកិច្ចមិនល្អ។ ទម្លាក់(ហើយបាន)បន្តិចទម្លាក់(ទៀត) ហើយកាលប្រជុំអាស៊ាន និងកំពូលអាស៊ាន និងការប្រជុំពាក់ព័ន្ធដទៃទៀត មានជំនួបការងារមួយបានការងាររវាងមេដឹកនាំអាស៊ានជាមួយនឹងអគ្គនាយក IMF នូវអ្វីដែលហៅថា សុទិដ្ឋិនិយមលើបញ្ហាកំណើនសេដ្ឋកិច្ច ហាក់ដូចជាមិនមានសោះ។ សេដ្ឋកិច្ចអាមេរិកកើនយឺតៗ ក្នុងពេលដែល អឺរ៉ុបមិនទាន់ទាំងដោះបំណុលក្រិចរួចផង វិបត្តិការចាកចេញរបស់អង់គ្លេសចាកចេញពីអឺរ៉ុបបានចាប់ផ្តើម ... ដូចជាក្នុងខែ ១០ នេះដែរ ខ្ញុំក៏ត្រូវទទួលរដ្ឋមន្ត្រីបេសកជនរបស់អង់គ្លេសមួយមកកម្ពុជា ដែលកម្ពុជាត្រូវចរចាឡើងវិញជាមួយនឹងអង់គ្លេសតែម្តង។ កាលមុននេះ យើងនាំចេញទៅអង់គ្លេស ៨៨២ លាន ដុល្លារអាមេរិក ក្រោមរបបនៃពាណិជ្ជកម្មអឺរ៉ុប។ តែឥឡូវនេះ **យើងត្រូវចរចាជាមួយនឹងអង់គ្លេស តើយើងនាំចេញទៅអង់គ្លេសក្រោមរបបអឺរ៉ុបទៀតឬអត់? គាត់ផ្តល់ភាពអនុគ្រោះដល់យើងដូចអ្វីដែលគាត់ធ្លាប់នៅជាអឺរ៉ុបទៀតទេ? អញ្ចឹងទីផ្សារចាស់និងទីផ្សារថ្មី យើងទៅជាមួយគ្នា។ រក្សាទីផ្សារចាស់ ពង្រឹងទីផ្សារចាស់ និងបើកពង្រីកទីផ្សារថ្មី ទីផ្សារថ្មីហ្នឹងមានពង្រីកបន្តនៅទីផ្សារចាស់** ដែលមានរាប់ទាំងទីផ្សារចិន ទីផ្សារកូរ៉េ ខាងត្បូង ទីផ្សារជប៉ុន ទីផ្សារអឺរ៉ុប ទីផ្សារអាមេរិក ក៏ប៉ុន្តែយើងត្រូវរាប់ទីផ្សារដទៃទៀត ដូចជា ទីផ្សារនៅអឺរ៉ាស៊ី (Eurasia) ... បណ្តាប្រទេសនៃអតីតសហភាព

សូវៀត ដែលយើងបានចុះហត្ថលេខាធ្វើជាអ្នកសង្កេតការធ្វើជាដៃគូ ដើម្បីនាំចេញទៅប្រទេសទាំងនោះ ដើម្បីឈានឆ្ពោះមកមជ្ឈឹមបូព៌ា ...។

មហាផ្ទៃ

១	គណនេយ្យភាពជាមួយប្រជាពលរដ្ឋ	១៥៣
២	សេវាតម្រូវការជាសេវាចាំបាច់ត្រូវដោះស្រាយមុនសេវាសំណូមពរ	១៥៣
៣	ប្រជាពលរដ្ឋថ្នាំងថ្នាក់នឹងសេវាតំរូវការ	១៥៤
៤	សេវាតម្រូវការ ត្រូវ «ធ្វើឲ្យបាន ធ្វើឲ្យលឿន មានតម្លាភាព»	១៥៤
៥	ធ្វើរដ្ឋាភិបាលអេឡិចត្រូនិច តែប្រព័ន្ធរដ្ឋបាលនៅដដែល	១៥៥
៦	មន្ត្រីជាខ្ញុំបម្រើស្មោះត្រង់របស់ប្រជាជន មិនមែនជាចៅហ្វាយប្រជាជន	១៥៥
៧	ធ្វើមន្ត្រីជើង ២ ជួយដោះស្រាយការលំបាកប្រជាជន, មន្ត្រីគ្រាប់ល្ពៅ	១៥៦
៨	ចាត់វិធានការប្រឆាំងឃាតកម្ម ការប្លន់ប្រដាប់អាវុធ និងការពារប្រជាជន	១៥៦
៩	គ្រប់មជ្ឈដ្ឋានចូលរួមកំចាត់គ្រឿងញៀន	១៥៧
១០	រាជរដ្ឋាភិបាល គ្រួសារ សហគមន៍ រួមគ្នាវាយគ្រឿងញៀន/បទឧក្រិដ្ឋ	១៥៧
១១	គ្រប់គ្រងអាវុធជាតិផ្ទុះអោយហ្មត់ចត់	១៥៨
១២	ពន្លត់ភ្លើង ជាជាងការបក់ផ្សែង ក្នុងការបិទល្បែងស៊ីសង	១៥៩
១៣	ឈើប្រណិត គ្រឿងញៀន ឧក្រិដ្ឋកម្ម តាមច្រករបៀង	១៥៩
១៤	ភូមិ-ឃុំមានសុវត្ថិភាព ទូទាំងប្រទេសមានសុវត្ថិភាព	១៦០
១៥	ការដាក់ឲ្យចូលនិវត្តន៍គ្មានការលើកលែង	១៦០
១៦	ថ្នាក់ក្រោមជាតិទទួលខុសត្រូវ អំពី ជម្លោះដីធ្លី ព្រៃឈើ និងនេសាទ	១៦១
១៧	អ្នកនិយាយពីផែនទីក្លែងក្លាយ ជាបទល្មើសជាក់ស្តែង ត្រូវចាប់ខ្លួនភ្លាម	១៦១
១៨	បដិវត្តន៍ពណ៌អ៊ីក៏ដោយ អោយតែធ្វើខុសច្បាប់ ត្រូវតែចាប់	១៦២
១៩	សិក្សាផ្លូវច្បាប់ ដាក់ទោសអ្នកដើរជម្រុញឲ្យពលរដ្ឋខ្ចីមីក្រូហិរញ្ញវត្ថុ	១៦៣
២០	មន្ត្រីមូលដ្ឋាន ត្រួតពិនិត្យការមិនយកថ្លៃឯកសារ	១៦៣
២១	ថ្នាក់ក្រោមជាតិមើល តើមានអ្នកយកភាស៊ីការលក់តាមកញ្ជ្រង/ល្អីទេ	១៦៤
២២	ផ្ទេរមុខងារ ធនធានទៅថ្នាក់ក្រោមជាតិ រៀបចង្កោមផ្តល់សេវាជូនពលរដ្ឋ	១៦៤
២៣	បោះឆ្នោតឃុំ សុវត្ថិភាព សេរីភាព យុត្តិធម៌ ត្រឹមត្រូវ និងទទួលយកបាន	១៦៥

១. គណនេយ្យភាពជាមួយប្រជាពលរដ្ឋ

ពិធីបិទសន្និបាតបូកសរុបការងារឆ្នាំ ២០១៣ និងលើកទិសដៅការងារឆ្នាំ ២០១៤ របស់ក្រសួងមហាផ្ទៃ, ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤

... ដែលធ្វើគណនេយ្យភាពជាមួយនឹងប្រជាពលរដ្ឋ រកឃើញហើយត្រូវកែ។ មិនមែនកែត្រឹមកម្រិតថ្នាក់ក្រោមជាតិទេ កែទាំងថ្នាក់ជាតិ រាប់ទាំងកម្មវិធីនយោបាយ រាប់ទាំងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។ បើយើងឃើញថា វាមិនស្របយើងត្រូវកែ អនុក្រឹត្យក៏ដោយ ព្រះរាជក្រឹត្យក៏ដោយ យើងត្រូវកែរហូតទៅដល់យើងអាចធ្វើវិសោធនកម្មច្បាប់ទៀតផង។ ការនេះទាមទារនូវការគិតគូរគ្រប់ជ្រុងជ្រោយ តាមដានត្រួតពិនិត្យវាយតម្លៃ ដូចជាទទួលព័ត៌មានត្រឡប់មកវិញ តាមរយៈរបាយការណ៍ ហើយត្រួតពិនិត្យឲ្យបានត្រឹមត្រូវ និងចាត់វិធានការកែសម្រួល .. ឧទាហរណ៍ៈ ប្រជាពលរដ្ឋលើកឡើងអំពីការលំបាករបស់គាត់ពីការទទួលសេវាលើបញ្ហាផ្នែកណាមួយ។ បើពិនិត្យឃើញថារឿងនោះជារឿងពិត ត្រូវចាត់វិធានការកែ។ ពេលត្រឡប់ចុះទៅត្រួតពិនិត្យការងារហ្នឹងឡើងវិញ ជំហានដំបូងមុនចូលដល់បញ្ហាថ្មី ត្រូវពិនិត្យអាចាស់សិន អនុវត្តបានប៉ុន្មានហើយ។ ឲ្យពួកគាត់និយាយថា បានកែ ឬអត់ ? ... ត្រូវសង្កត់ធ្ងន់ទៅលើប្រសិទ្ធភាពនៃសេវាសាធារណៈ ហើយធ្វើដោយតម្លាភាព និងគណនេយ្យភាព ... យុទ្ធសាស្ត្រចតុកោណមានតែ ៤ ពាក្យទេ កំណើន ការងារ សមធម៌ និងចុងក្រោយគឺ ប្រសិទ្ធភាព ...។

២. សេវាតម្រូវការជាសេវាចាំបាច់ត្រូវដោះស្រាយមុនសេវាសំណូមពរ

ពិធីបិទសន្និបាតក្រសួងមហាផ្ទៃ, ថ្ងៃទី ២៥ កុម្ភៈ ២០១៦

... សេវាសាធារណៈដែលខ្ញុំចង់សង្កត់ធ្ងន់នៅពេលនេះ គឺត្រូវបែងចែកជាពីរ គឺសេវាតម្រូវការរបស់ប្រជាជន និងមួយទៀតជាសេវាសំណូមពររបស់ប្រជាជន។ អ្វីដែលគ្រប់ស្ថាប័ន គ្រប់ផ្នែក គ្រប់ថ្នាក់ ត្រូវខិតខំ និងមន្ត្រីគ្រប់រូបត្រូវខិតខំដោះស្រាយឲ្យខានតែបាន គឺសេវាតម្រូវការរបស់ប្រជាជនដែលច្បាប់តម្រូវ ដូចជា អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ សំបុត្រមរណភាព។ល។ ត្រូវធ្វើឲ្យបានឲ្យលឿន និងឲ្យមានតម្លាភាព ព្រោះជាតម្រូវ

ការរបស់ប្រជាជន។ សម្រាប់សេវាដែលជាសំណូមពរ ដូចជា ការសាងសង់សាលារៀន មន្ទីរពេទ្យ វត្តអារាម ហេដ្ឋារចនាសម្ព័ន្ធ។ល។ យើងដោះស្រាយទៅតាមលទ្ធភាពខាងថវិកា ...។

៣. ប្រជាពលរដ្ឋថ្នាំងថ្នាក់ នឹងសេវាតំរូវការ

ពិធីបិទសន្និបាតក្រសួងមហាផ្ទៃ, ថ្ងៃទី ២៥ កុម្ភៈ ២០១៦

... កន្លងទៅ មន្ត្រីរបស់យើងនៅមូលដ្ឋាន ឬក៏យើងបញ្ជូនមន្ត្រីទៅមូលដ្ឋាន តែងយកមកមួយកញ្ចប់ទាំងសេវាសំណូមពរ និងសេវាតម្រូវការ ... ខ្ញុំសូមបញ្ជាក់ បញ្ហាសេវាតម្រូវការ គឺជាសេវាដែលច្បាប់បានកំណត់ ហើយគ្មានការចាំបាច់ត្រូវបានប្រាក់កាក់ ទើបអាចធ្វើបាននោះទេ ហើយក៏មិនចាំបាច់ដល់ថ្នាក់ជាតិចុះទៅដែរ, ថ្នាក់ក្រោមជាតិ ជាពិសេសនៅមូលដ្ឋានគេធ្វើបានហើយ ... **កន្លងទៅ ប្រជាជនថ្នាំងថ្នាក់ដែលយើងមិនទៅធ្វើផ្លូវឲ្យគាត់ ហ្នឹងមួយផ្នែកទេ ប៉ុន្តែគាត់ស្រែកខ្លាំងជាងគេ គឺរឿងអ្វីដែលគាត់ពិបាកទទួលយកនោះ គឺការសូកប៉ាន់គេ (ដើម្បី)បាន(ការបម្រើសេវាតំរូវការ)នោះ។ មើលប្រមូលផ្តុំដោះស្រាយ ចៅហ្វាយខេត្តមួយតាមឲ្យជាប់មើល ហើយក៏មិនចាំបាច់ថ្នាក់ជាតិចុះទៅ ព្រោះអានេះវាអត់រាល់អីដល់ថ្នាក់ជាតិទេ។ វាជាកាតព្វកិច្ច។ បើនិយាយពីរឿងនៅថ្នាក់ឃុំ អស់លោក លោកស្រីជាមន្ត្រីឃុំ ប្រជាជនបោះឆ្នោតឲ្យតើ? បោះឆ្នោតដើម្បីបម្រើគាត់ ...**។

៤. សេវាតម្រូវការ ត្រូវ «ធ្វើឲ្យបាន ធ្វើឲ្យលឿន មានតម្លាភាព»

ពិធីបិទសន្និបាតក្រសួងមហាផ្ទៃ, ថ្ងៃទី ២៥ កុម្ភៈ ២០១៦

... **មិនមែនមានតែផ្នែកមហាផ្ទៃមួយទេ ដែលមានសេវាតម្រូវការ ក្រសួងនានាមានពាណិជ្ជកម្មជាដើម (ក៏មាន)សេវាតម្រូវការ(ដែរ)។ តើជាស្អី? គឺការចុះបញ្ជីពាណិជ្ជកម្ម។ នៅមានក្រសួងផ្សេងទៀតដែរ។ ត្រូវពិនិត្យមើល។ ខ្ញុំប្រើពាក្យបីពាក្យ «ធ្វើឲ្យបាន ធ្វើឲ្យលឿន និងមានតម្លាភាព»**។ វាត្រូវតែបាន ព្រោះអាហ្នឹងជាតម្រូវការរបស់មនុស្ស ... ម្សិលមិញ យប់ហើយ មកពីគណៈរដ្ឋមន្ត្រី ខ្ញុំសរសេរត្រង់ហ្នឹង ហើយខ្ញុំគូសបន្ទាត់ក្រហមត្រង់ហ្នឹង សម្រួចមាត់មកនិយាយអាហ្នឹង ...

«ធ្វើឲ្យបាន ធ្វើឲ្យលឿន និងមានតម្លាភាព» ពាក្យមានតម្លាភាពមួយម៉ាត់ មានន័យថា បើគេឲ្យយក ៥០០ យកតែ ៥០០ បានហើយ លើសពីហ្នឹងគឺអត់យក។ ហើយបើគេកំណត់ ៥ ថ្ងៃ គឺឲ្យតែ ៥ ថ្ងៃបានហើយ ហើយបើបានធ្វើត្រឹមតែ ២ ថ្ងៃ គឺកាន់តែល្អ តម្លាភាពនៅទីនេះ គឺចង់និយាយអញ្ចឹង ...។

៥. ធ្វើរដ្ឋាភិបាលអេឡិចត្រូនិច តែប្រព័ន្ធរដ្ឋបាលនៅដដែល

ពិធីសម្ពោធសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ, ថ្ងៃទី ១១ កុម្ភៈ ២០១៦

... ទោះបីជាយើងមិនមានហ្វេសប៊ុក ក៏ប្រជាពលរដ្ឋបញ្ជូនពាក្យបណ្តឹងហ្នឹងទៅឲ្យខ្ញុំព្រះករុណាខ្ញុំ នៅភ្នំពេញដែរ ជួនកាលលើកគ្នាធ្វើបាតុកម្មដើម្បីយកញត្តិទៅដល់ព្រឹទ្ធសភា ទៅដល់មុខផ្ទះនាយករដ្ឋមន្ត្រីទៅទៀត ... សួរថាយើងដោះស្រាយរបៀបម៉េច? មានតែមួយគត់ គឺបង្វិលទៅឲ្យក្រសួងណាដែលមានសមត្ថកិច្ចថា រឿងហ្នឹងវាយ៉ាងម៉េច ឲ្យយោបល់មក។ បើសិនទាក់ទងនឹងខេត្ត ក៏ត្រូវបញ្ជូនទៅឲ្យខេត្តហ្នឹងវិញដែរ ដើម្បីឲ្យខេត្តផ្តល់មតិ ... ប្រព័ន្ធរដ្ឋបាលនៅទាំងអស់។ **ខ្ញុំព្រះករុណាខ្ញុំ ខ្លួនឯងបានដឹកនាំគេឲ្យធ្វើអា E-Government រដ្ឋាភិបាលអេឡិចត្រូនិច (ដែល)មានគ្រប់ប្រព័ន្ធ រាប់ទាំងប្រព័ន្ធអ្វីដែលលឿនបំផុតដែលអាចដោះស្រាយបានការងារសម្រាប់ប្រជាពលរដ្ឋ។ គេមិនបោះបង់ចោលនូវប្រព័ន្ធ ដែលគេប្រើប្រាស់សព្វថ្ងៃ ហើយដែលមានចែងក្នុងច្បាប់ និងអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័ននោះទេ ... ខ្ញុំអត់ចោលប្រព័ន្ធការងារដែលធ្លាប់មានពីមុនទេ។** ខ្ញុំគ្រាន់តែបង្កើនល្បឿនឲ្យមន្ត្រីរបស់យើងគ្រប់ទីកន្លែងដោះស្រាយការងារឲ្យបានលឿនជូនប្រជាពលរដ្ឋ ...។

៦. មន្ត្រីជាខ្ញុំបម្រើដ៏ស្មោះត្រង់របស់ប្រជាជន មិនមែនជាចៅហ្វាយប្រជាជន

ពិធីបិទវគ្គ និងចែកសញ្ញាបត្រ/វិញ្ញាបនបត្រ សិស្សមន្ត្រីជាន់ខ្ពស់/សិស្សមន្ត្រីក្រមការ និងកម្មសិក្សាការី នៃសាលាភូមិន្ទរដ្ឋបាល, ថ្ងៃទី ១០ មីនា ២០១៥

... អ្វីដែលខ្ញុំព្រះករុណាខ្ញុំ ចង់និយាយផ្តាំផ្ញើ គឺ**យើងកុំភ្លេចឲ្យសោះថា មន្ត្រីជាខ្ញុំបម្រើដោយស្មោះត្រង់របស់ប្រជាជន មិនមែនជាចៅហ្វាយរបស់ប្រជាជនទេ។ ត្រូវយល់អំពីសារជាតិពិតប្រាកដនៃមន្ត្រី។ បើមិនដូច្នេះទេ មន្ត្រីរបស់យើង**

នឹងពើងទ្រូងជាក់ប្រជាជន ហើយតាំងខ្លួនជាចៅហ្វាយរបស់ប្រជាជន។ នេះជាចំណុចពិសេស ដែលទាមទារឲ្យមន្ត្រីរបស់យើងរំលឹកជាស់តឿនខ្លួនឯងជាប់ជានិច្ច ទង្វើខុសឆ្គងណាមួយ ដែលតាំងខ្លួនជាចៅហ្វាយរបស់ប្រជាពលរដ្ឋ ហើយមិនមែនជាខ្ទុំបម្រើស្មោះត្រង់របស់ប្រជាពលរដ្ឋ គឺសុទ្ធតែជាទង្វើខុស ... យើងមានឧទាហរណ៍ស្រាប់ហើយ កម្លាំងប្រដាប់អាវុធ និយាយជាទូទៅ គឺពួកគេបានបំពេញកាតព្វកិច្ច ជាអ្នកការពារ ជាអ្នកបម្រើប្រជាជន ...។

៧. ធ្វើមន្ត្រីជើង ២ ជួយដោះស្រាយការលំបាកប្រជាជន, មន្ត្រីគ្រាប់ល្ពៅ

ពិធីចែកវិញ្ញាបនបត្រមន្ត្រីជាន់ខ្ពស់ មន្ត្រីក្រមការ សាលាកូមិន្ទរដ្ឋបាល,
ថ្ងៃទី ២០ មីថុនា ២០១៦

... សុំធ្វើមន្ត្រីជើងពីរ កុំធ្វើមន្ត្រីជើង ១០។ ស្ពឹទ្ធមន្ត្រីជើង ១០? ជើងតុនោះវាមាន ៤, ជើងកៅអី ៤ ហើយជើងយើង ២ ទៀត វាគ្រប់ ១០។ ត្រូវធ្វើមន្ត្រីជើងពីរ តែមន្ត្រីជើងពីរនេះ ខ្ញុំសង្កេតឃើញថា អ្នកខ្លះក៏ពូកែជើរជែរ ទៅណាមានកូននៅហ្នឹង។ មិនត្រឹមតែប៉ុណ្ណឹងទេ រពឹសដៃទៅរកជីទៀត។ បង្កើតរឿង។ ជើងពីរនេះ ជើងទៅដោះស្រាយបញ្ហាអោយប្រជាជន មិនមែនទៅបង្កើតបញ្ហាទេ ...។ **សូមកុំធ្វើមន្ត្រីគ្រាប់ល្ពៅ។ ស្ពឹទ្ធមន្ត្រីគ្រាប់ល្ពៅ? ខ្ញុំធ្លាប់បាននិទានហើយរឿងហ្នឹង ... ដឹក(ល្ពៅ)មក ប៉ុន្តែពួកការពារវាំងមិនអោយនាំចូល។ នេះមិនត្រឹមតែកូតទេ ចង់សម្លាប់អ្នកការពារវាំងទៀត ... ត្រូវយកទៅបំបែកសាកសពដោយសេះ ៥ ឬយកអោយដំរីជាន់ ... មន្ត្រីបែបហ្នឹង ជាមន្ត្រីដែលនាំគ្រោះថ្នាក់(ដោយសារតែ)កាប់កុងគេ មួលបង្ការ៉ាប់គេ ...។**

៨. ចាត់វិធានការប្រឆាំងឃាតកម្ម ការប្លន់ប្រដាប់អាវុធ និងការពារប្រជាជនគ្រប់រូប

ពិធីសម្ពោធអគារសេនាធិការដ្ឋាន សមិទ្ធផលរបស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថ
លើផ្ទៃប្រទេស, ថ្ងៃទី ១១ កក្កដា ២០១៦

... មួយរយៈចុងក្រោយនេះ ពិតមែនតែនៅក្នុងក្របខណ្ឌនៃទំនាក់ទំនងទៅតាមបណ្តាព្រំដែនជាមួយប្រទេសជិតខាងមានសុវត្ថិភាពនិងទំនាក់ទំនងល្អ ប៉ុន្តែសន្តិសុខនៅផ្ទៃក្នុងរបស់យើង មានបញ្ហា (ដែល)ប៉ះទៅលើពលរដ្ឋស្លូតត្រង់

អ្នកនយោបាយ អ្នកធ្វើធុរកិច្ច ហើយរហូតប៉ះទៅដល់សមត្ថកិច្ច ... **ទាមទារនូវការបើកយុទ្ធនាការទ្រង់ទ្រាយធំមួយ ដើម្បីពង្រឹងនូវសន្តិសុខរបស់យើងឡើងវិញ។ ក្នុងនោះ ទីមួយ ទាមទារនូវការចាត់វិធានការប្រឆាំងនឹងឃាតកម្ម ការលួនប្រដាប់អាវុធ និងត្រូវការពារប្រជាជនគ្រប់រូប មិនថាអ្នកនយោបាយ ឬជាធុរជន ឬប្រជាជននោះទេ** ... រឿងខ្លះកើតឡើងគួរអោយសោកស្តាយ បែរជាកូនសម្លាប់ម្តាយ កូនសម្លាប់ឪពុក តាមរយៈនៃសារធាតុញៀនក៏មាន។ ដូច្នេះ យើងត្រូវរៀបចំផែនការជាកញ្ចប់ ដោះស្រាយបញ្ហាឧក្រិដ្ឋកម្មនៅក្នុងប្រទេស ...។

៩. គ្រប់មជ្ឈដ្ឋានចូលរួមកំចាត់គ្រឿងញៀន

ពិធីសម្ពោធអគារសេនាធិការដ្ឋាន សមិទ្ធផលរបស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថ លើផ្ទៃប្រទេស, ថ្ងៃទី ១១ កក្កដា ២០១៦

... **គ្រឿងញៀនជាបញ្ហាកាន់តែធ្ងន់ធ្ងរទៅ។ ទាមទារអោយមានការចូលរួមពីគ្រប់មជ្ឈដ្ឋាន។ ប្រទេសរបស់យើងមិនមែនជាប្រទេសផលិតគ្រឿងញៀននោះទេ ជាប្រទេសឆ្លងកាត់ ក៏ប៉ុន្តែ ឥឡូវនេះ(វាបានក្លាយទៅ)ជាទីផ្សារនៃការប្រើប្រាស់គ្រឿងញៀនទៅហើយ។ ដូច្នេះ យើងត្រូវតែខិតខំរួមទាំងអស់គ្នា ទើបអាចធ្វើទៅបាន។ ត្រឹមតែកងនគរបាលជាតិ និងកងរាជអាវុធហត្ថ (វាមិន)គ្រប់គ្រាន់នោះទេ ត្រូវមានការចូលរួមពីគ្រប់ភ្នាក់ងារទាំងអស់ ជាពិសេសគឺប្រជាពលរដ្ឋខ្លួនឯងហ្នឹងតែម្តង** ... ជាការល្អ បងត្រូវអប់រំប្អូន ទើបជាការត្រឹមត្រូវ ហើយធ្វើយ៉ាងម៉េចមនុស្សទាំងអស់ កុំប្រើប្រាស់គ្រឿងញៀន ... ដោយសារគ្រឿងញៀននេះហើយ វាបង្កើតទៅជាបញ្ហានៃឧក្រិដ្ឋកម្មមួយបែបផ្សេងទៀត ...។

១០. រាជរដ្ឋាភិបាល គ្រួសារ សហគមន៍ រួមគ្នាវាយប្រហារគ្រឿងញៀន/បទល្មើសឧក្រិដ្ឋ

ពិធីចែកសញ្ញាបត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងប្រកាសសម្ពោធមជ្ឈមណ្ឌលកម្ពុជាដើម្បីស្រាវជ្រាវផ្លូវសូត្រសមុទ្រ, ថ្ងៃទី ១៣ មីថុនា ២០១៦

... យើងនៅមានយុវជនមួយចំនួន ដែលបានដើរផ្លូវខុស ដែលយើងកំពុងខិតខំទាញពួកគេត្រឡប់មកតាមផ្លូវត្រូវវិញ។ មិនទាន់ហួសពេលទេ។ យុវជនមួយចំនួនដើរខុសផ្លូវទៅរកគ្រឿងញៀន តាមបងតូចបងធំ ធ្វើនូវអំពើខុសឆ្គងមួយ

ចំនួនដែលសង្គមស្អប់ខ្ពើម។ ទាមទារនូវការខិតខំទាំងអស់របស់សង្គម ... **ខ្ញុំសូមអំពាវនាវត្រឡប់ទៅវិញថា ទន្ទឹមនឹងការខិតខំរបស់អាជ្ញាធរវាយប្រហារទៅលើក្រុមគ្រឿងញៀន ឬបទល្មើសឧក្រិដ្ឋផ្សេងៗ ក៏សូមឲ្យក្រុមគ្រួសារនីមួយៗ ជួយផងដែរ ... យើងត្រូវប្រឹងទាំងអស់គ្នា**។ រាជរដ្ឋាភិបាលបង្កើតនូវឱកាសសម្រាប់ប្រជាពលរដ្ឋរបស់យើង តាមរយៈការបង្កើតឡើង សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម ដើម្បីបើកឱកាសឲ្យមានសាលារៀនគ្រប់កម្រិត មានការវិនិយោគសម្រាប់ការងារធ្វើក្នុងវិស័យឧស្សាហកម្ម សេវាកម្ម និងវិស័យដទៃទៀត ដូចជាវិស័យសំណង់ជាដើម ...។

១១. គ្រប់គ្រងអាវុធ ជាតិផ្ទុះអោយហ្មត់ចត់

ពិធីសម្ពោធអគារសេនាធិការដ្ឋាន សមិទ្ធផលរបស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថ
លើផ្ទៃប្រទេស, ថ្ងៃទី ១១ កក្កដា ២០១៦

... ត្រូវគ្រប់គ្រងអាវុធជាតិផ្ទុះឲ្យបានហ្មត់ចត់ ហើយខ្ញុំសូមយកឱកាសនេះ ដើម្បីថ្លែងនូវការកោតសរសើរចំពោះកងរាជអាវុធហត្ថលើផ្ទៃប្រទេស ដែលខ្ញុំបានតាមដានដោយផ្ទាល់ ... **យើងក៏ត្រូវរកវិធីដើម្បីកុំឲ្យអាវុធអាចធ្វើចរាចរឆ្លងកាត់នៅក្នុងប្រទេសយើងបាន ... ត្រូវតែខិតខំស្វែងរកពិនិត្យអាវុធជាតិផ្ទុះ ព្រោះការប្រើប្រាស់អាវុធ ឬក៏ជាតិផ្ទុះដើម្បីបំផ្លាញជីវិតមនុស្ស គឺជារឿងដែលធ្លាប់បានកើតប៉ុន្មានខែរួចមកហើយ** កន្លែងខ្លះមានការបាកគ្រាប់បែកទៅតាមទីកន្លែងដែលកំពុងមានការជួបជុំ ... **ពេលដែលខ្ញុំកំពុងនិយាយអំពីសន្តិភាព ការសប្បាយរីករាយរបស់ប្រជាជននៅក្នុងដំណាក់កាលសន្តិភាព និងស្ថិរភាពខាងនយោបាយ ... រឿងទាំងអស់នៅក្នុងប្រទេសរបស់យើង ងាយណាស់ក្នុងការប្រែពណ៌ពីឧក្រិដ្ឋកម្ម ទៅជារឿងនយោបាយ**។ សង្ឃឹមថា ប្រជាពលរដ្ឋរបស់យើងនឹងមិនប្រែក្លាយ បញ្ហាឧក្រិដ្ឋកម្មបែបនេះ ទៅជារឿងនយោបាយនោះទេ។ ប៉ុន្តែ សមត្ថកិច្ចត្រូវខិតខំធ្វើកិច្ចការងារនេះឲ្យអស់ពីដៃពីជើង ដើម្បីសុខសុវត្ថិភាពរបស់ប្រជាជន ...។

១២. យុទ្ធសាស្ត្រពន្លត់ភ្លើង ជាជាងការបក់ផ្សែង ក្នុងការបិទល្បែងស៊ីសង

ពិធីបិទសន្និបាតក្រសួងមហាផ្ទៃ,
ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៩

... **យើងបានអនុវត្តយុទ្ធសាស្ត្រពន្លត់ភ្លើង ជាជាងការបក់ផ្សែង ... យើងបានបញ្ចប់ជាស្ថាពរនូវបនល្បែងដែលមានចរិតខុសច្បាប់ ដូចជា ស្លតម៉ាស៊ីន ... អាចាក់ភ្នាល់បាល់ស្ពឺៗ នេះ។** ... យើងបានលុបហើយកន្លែងទៅដេកចាំមើលចាំចាក់នោះ ប៉ុន្តែក្នុងសារាចរណែនាំបានណែនាំឱ្យមើលកន្លែងដែលលួចលេង។ នៅមានវិធានការបន្តទៀត។ ខ្ញុំក៏ឱ្យក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច ទីស្តីការគណៈរដ្ឋមន្ត្រី អាចពិភាក្សាគ្នាបន្ថែមទៀត អំពីរូបភាពល្បែងមួយចំនួនដែលបង្កប់នៅក្នុងហ្នឹង។ ត្រូវមើលឱ្យបានគ្រប់ទិដ្ឋភាព គ្រប់ជ្រុងជ្រោយ ព្រោះវានៅមានរឿងច្រើន ... ទន្ទឹមពេលដែលប្រជាពលរដ្ឋកំពុងតែអបអរសាទរចំពោះការបិទល្បែងស៊ីសង យើងក៏ត្រូវតែដំណើរការពិនិត្យមើលអំពីទិដ្ឋភាពខុសច្បាប់ដទៃទៀត ក្នុងហ្នឹងមានកន្ទុយលេខនេះក៏ជាផ្នែកមួយដែរ ... យើងត្រូវខិតខំធ្វើឱ្យតម្លៃនិងសីលធម៌សង្គមរបស់យើង បានល្អប្រសើរឡើង ...។

១៣. ឈើប្រណិត គ្រឿងញៀន ឧក្រិដ្ឋកម្ម តាមច្រករបៀង

ពិធីបិទសន្និបាតក្រសួងមហាផ្ទៃ,
ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៩

... ការសិក្សាពីក្រុមជំនាញរបស់យើង ពួកក្រុមគ្រឿងញៀននៅតំបន់មួយចំនួន ដូចជា នៅអាហ្គានីស្ថាន និងប្រទេសខ្លះទៀត បានរីករាលធំ។ កម្ពុជាមិនមែនជាប្រទេសផលិតគ្រឿងញៀនទេ ក៏ប៉ុន្តែជាតំបន់ឆ្លងកាត់ និងប្រើប្រាស់គ្រឿងញៀនដែរ។ កាលពី **ខែមេសា ឆ្នាំ ២០០៧ នៅភ្នំស្រួច យើងបានរកឃើញករណីប៉ុនប៉ងផលិតគ្រឿងញៀន** តែយើងក៏បានវាយបំបែកសំបុករបស់វា។ ... ការពិភាក្សាក្នុងរយៈពេល ២ ថ្ងៃនេះ មានការលើកឡើងថា **បណ្តាវ៉ាឈរជើងតាមព្រំដែន មិនយកលុយពីប្រជាពលរដ្ឋដឹកកសិផលទេ** សូមអបអរសាទរ ប៉ុន្តែមានបញ្ហាស្មុគស្មាញត្រង់ថា **អ្នកដឹកកសិផលទៅលក់ មិនព្រមចេញតាមច្រកផ្លូវការ**

គឺលួចចេញតាមច្រករបៀងទៅវិញ។ ច្រករបៀងនេះ អាចដាក់ឈើប្រណិតតាមហ្នឹង ហើយជាផ្នែកមួយនៃចរាចរណ៍ចែកចាយគ្រឿងញៀនដែរ។ សូមអំពាវនាវអ្នករកស៊ីទាំងឡាយសូមដឹកកសិផលទៅលក់តាមច្រកផ្លូវការ ... ឈើក៏មានផ្ទៃពោះដែរ ដោយគេបង្កប់គ្រឿងញៀននៅដើមឈើហ្នឹង ... ឯកឧត្តម ស ខេង បានធ្វើរបាយការណ៍ឱ្យខ្ញុំរួចហើយ**អំពីការបង្ក្រាបក្មេងពាលា តាំងពីឆ្នាំ ២០០៥ រហូតមក** តាំងពីលាងលុយកខ្វក់ **ឧក្រិដ្ឋកម្មឆ្លងដែន** រហូតទៅដល់ការជ្រាបចូលភេរវកម្ម **ក៏មកតាមហ្នឹងដែរ** ...។

១៤. ភូមិ-ឃុំមានសុវត្ថិភាព ទូទាំងប្រទេសមានសុវត្ថិភាព

ពិធីបិទសន្និបាតក្រសួងមហាផ្ទៃ បូកសរុបការងារឆ្នាំ ២០១០ និងទិសដៅការងារ

ឆ្នាំ ២០១១ , ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១

... **យើងទាំងអស់គ្នានៅនឹងភូមិ។ ប្រសិនបើភូមិ-ឃុំមានសុវត្ថិភាពហើយ នៅក្របខណ្ឌទូទាំងប្រទេស និងអ្វីៗ ក៏មានសុវត្ថិភាព។ នេះ គឺជាការបំផុសចលនាធំណាស់ក្នុងការការពារប្រជាពលរដ្ឋខ្លួនឯង។ ហេតុនេះហើយបានជាការងារនេះ ត្រូវបានចាត់ទុកជាកិច្ចការអាទិភាព ដែលយើងរួមគ្នាបង្កើតឡើង។** មិនមែនជាកិច្ចការរបស់នគរបាលម្នាក់ឯងប៉ុណ្ណោះទេ មានប្រជាពលរដ្ឋ មន្ត្រីរាជការ ទោះបីថ្នាក់ណាក៏ដោយ សុទ្ធតែមានភូមិ ត្រូវមានការកិច្ចចូលរួម។ អញ្ចឹងយើងនឹងមានកម្លាំងរួមមួយ ទាំងអ្នកភូមិ ទាំងនគរបាលនៅទីនោះ និងទាំងមន្ត្រីរាជការដែលនៅក្នុងភូមិហ្នឹង។ ខ្ញុំនៅចាំបានថា ក្រសួងមហាផ្ទៃ និងនគរបាលជាតិ បានសុំការគាំទ្រ នៅក្នុងបុណ្យខួបគម្រប់ ៦៥ ឆ្នាំ នៃនគរបាលជាតិ ...។

១៥. ការដាក់ឲ្យចូលនិវត្តន៍គ្មានការលើកលែង

ពិធីបិទសន្និបាតក្រសួងមហាផ្ទៃ បូកសរុបការងារឆ្នាំ ២០១០ និងទិសដៅការងារ

ឆ្នាំ ២០១១ , ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១

... **ការដាក់ឱ្យចូលនិវត្តន៍គ្មានការលើកលែងទេ។ ការសម្រេចឱ្យលើកលែងណាមួយ គឺរដ្ឋមន្ត្រីមហាផ្ទៃបានពិគ្រោះយោបល់ជាមួយខ្ញុំ ហើយអនុញ្ញាតបាន**

តែចំពោះអភិបាលរាជធានី-ខេត្ត ដែលឱ្យបន្តរហូតដល់ឆ្នាំ ២០១៣។ ឆ្នាំនេះ មានអភិបាលរាជធានី និងខេត្តរហូតដល់ ៥ ដែលបន្ថែមលើចំនួនចាស់ ៥ សរុប គឺ ១០ រូប។ ថ្នាក់អភិបាលរាជធានី-ខេត្ត គឺអនុញ្ញាតឱ្យរក្សាតួនាទី រហូតដល់បោះឆ្នោតហើយ ២០១៣។ មិនអនុញ្ញាតអោយអភិបាលខេត្តរង អភិបាលស្រុក អភិបាលរងស្រុកបន្តទេ។ មិនថាតែក្នុងរចនាសម្ព័ន្ធស្ថាប័ននេះទេ ក្រសួងណាក៏ដូចក្រសួងណាដែរ អត់មានស្នើសុំមកខ្ញុំថា ពន្យាការចូលនិវត្តន៍ទេ។ បើឱ្យមួយ ត្រូវឱ្យមួយទៀត។ ខ្ញុំចង់បញ្ជាក់ថា **មិនមានការអនុញ្ញាតឱ្យពន្យាការចូលនិវត្តន៍ទេ។ ចូលនិវត្តន៍មុខងារសាធារណៈទៅ ហើយអាចតែងតាំងមុខងារនយោបាយ ឬការងារនេះការងារនោះ ព្រោះយើងក៏ត្រូវការធនធានមនុស្សជួយការងារបន្តទៀត។** ឧទាហរណ៍ជាទីប្រឹក្សាក្រសួង ព្រោះបទពិសោធន៍ជាង ៣០ ឆ្នាំ មិនធម្មតាទេ...។

១៦. ថ្នាក់ក្រោមជាតិទទួលខុសត្រូវ អំពី ជម្លោះដីធ្លី ព្រៃឈើ និងនេសាទ

ពិធីបិទសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឆ្នាំ ២០១៤-២០១៥ និងទិសដៅ ឆ្នាំ ២០១៥-២០១៦, ថ្ងៃទី ៨ ខែ មេសា ២០១៥

... ថ្ងៃមុនយើងបានទៅប្រជុំមន្ត្រីជាន់ខ្ពស់ប្រមាណជិត ១.០០០ នាក់ របស់រាជរដ្ឋាភិបាល ដែលបានចុះទៅពង្រឹងនៅតាមមូលដ្ឋាន។ ក្នុងហ្នឹង ក៏បានចូលរួមពីអាជ្ញាធរថ្នាក់ក្រោមជាតិ និងគ្រប់ផ្នែកពាក់ព័ន្ធទាំងអស់។ **បញ្ហាព្រៃឈើ ជាបញ្ហាធ្ងន់ធ្ងរ ទាមទារនូវការទទួលខុសត្រូវ ដែលមិនអាចឆ្លើយជាក់គ្នានោះទេ។ រឿងនេះ មិនមែននិយាយម្តង ឬពីរដងនោះទេ។ ឥឡូវនេះ អំណាចបានទំលាក់ទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិហើយ បើទោះបីជា ច្បាប់ស្តីអំពីបញ្ហាព្រៃឈើ និងច្បាប់ស្តីអំពីនេសាទ មិនទាន់បានធ្វើវិសោធនកម្មអំពីរចនាសម្ព័ន្ធរបស់វាក៏ដោយ យើងបានឲ្យរដ្ឋបាលដែលគេហៅថា ខណ្ឌព្រៃឈើ ឬខណ្ឌជលផលទៅនៅក្នុងគណៈបញ្ជាការខេត្តរួចទៅហើយ ...។**

១៧. អ្នកណានិយាយពីផែនទីភ្លែងភ្លាយ គឺត្រូវចាប់ខ្លួនភ្លាម ជាបទល្មើសជាក់ស្តែង

អញ្ជើញសួរសុខទុក្ខយោធិនពិការ ៣១៧ គូលែន, ថ្ងៃទី ១២ មេសា ២០១៦

... ខ្ញុំសូមប្រកាសជាច់ណាត់ អ្នកណានិយាយពីផែនទីក្លែងក្លាយ ត្រូវចាប់ខ្លួនក្លាម។ មិនថាអ្នកហ្នឹងជាអ្នកណាទេ។ ល្ងាចនេះ សកានឹងចោទសួរដេញដោលអំពីការចាប់តំណាងរាស្ត្រម្នាក់ គឺចាប់ពីសៀមរាបហ្នឹងទៅតែម្តង ... សំអាងលើចំណុច ២ ដែលត្រូវចាប់ខ្លួន ទី ១ រដ្ឋធម្មនុញ្ញកំណត់ឲ្យប្រើផែនទីខ្នាត ១/១០០ ៣ន់ ដែលបោះពុម្ពដោយក្រុមកូមិសាស្ត្រឥណ្ឌូចិន ក្នុងចន្លោះឆ្នាំ ១៩៣៣ ដល់ ១៩៥៣។ ទី ២ មានតែផែនទីរដ្ឋាភិបាលប្រើតែមួយគត់ ដែលមានសច្ចាប័នពីរដ្ឋសភា និងមានឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រ។ អត់មានអ្នកណាត្រូវយកផែនទីណាមកជំនួសទេ ... ខ្ញុំបានឲ្យឱកាសគ្រប់គ្រាន់ហើយ ដោយនាំយកផែនទីពីអង្គការសហប្រជាជាតិមកផ្ទៀងផ្ទាត់ជាមួយផែនទីរាជរដ្ឋាភិបាល មិនមែនយកផែនទីរាជរដ្ឋាភិបាលទៅផ្ទៀងផ្ទាត់ជាមួយនឹងអង្គការសហប្រជាជាតិទេ។ ទី ២ ខ្ញុំបានសុំប្រធានាធិបតីបារាំង នាំមកនូវផែនទីយកមកផ្ទៀងផ្ទាត់ជាមួយផែនទីរបស់រាជរដ្ឋាភិបាល ដែលបាននិងកំពុងប្រើ។ អត់មានអីខុសគ្នាទាំងអស់។ និយាយពីផ្លូវច្បាប់ គ្មានការចាំបាច់ដើម្បីផ្ទៀងផ្ទាត់បែបនេះទេ។ ប៉ុន្តែខ្ញុំចង់ឲ្យពលរដ្ឋកម្ពុជាយល់ ...។៖

១៨. បដិវត្តន៍ពណ៌អ៊ីក៏ដោយ អោយតែធ្វើខុសច្បាប់ ត្រូវតែចាប់

ពិធីចែកសញ្ញាបត្រដល់និស្សិត នៃវិទ្យាស្ថាន វ៉ាន់ដា, ថ្ងៃទី ១០ ឧសភា ២០១៦

... ខ្ញុំបានប្រាប់សម្តេច ស ខេង ប្រាប់ទៅថ្នាក់ដឹកនាំដ៏ទៃទៀត កុំខ្ជល់ពីរឿងពណ៌។ ចង់ពណ៌អ៊ីក៏ដោយ អោយតែធ្វើខុសច្បាប់ ដាក់ទាំងអស់ហ្នឹង។ ហើយអ្នកដែលបំផុសនោះ ត្រូវប្រយ័ត្នប្រយែងក្រែងលោវានាំទៅដល់នីតិបុគ្គល។ ខ្ញុំគ្រាន់តែផ្តាំផ្ញើទេ។ នៅកន្លែងខ្លះគេហៅពណ៌ទឹកក្រូច ខ្លះគេហៅពណ៌ក្រហម ខ្លះគេហៅពណ៌ខ្មៅ។ ខ្ញុំថា ពណ៌អ៊ីក៏ដោយ អោយតែធ្វើខុសច្បាប់ដាក់ទាំងអស់ហ្នឹង។ តុលាការគេបង្កើតឡើង ដើម្បីអនុវត្តច្បាប់ កម្លាំងប្រដាប់អាវុធគេបង្កើតឡើងដើម្បីការពាររដ្ឋ គុកគេបង្កើតឡើងដើម្បីដាក់អ្នកទោស ... អំណាចដំណើរការរបស់តុលាការ ខ្ញុំអត់មានសិទ្ធិលូកលាន់ទេ។ ប៉ុន្តែរួចពីដំណើរការរបស់តុលាការនោះ ពេលសាលក្រមចូលស្ថាពរ វាស្ថិតក្នុងដៃនាយករដ្ឋមន្ត្រីវិញ ព្រោះច្បាប់ពន្ធធនាគារ អនុញ្ញាតអោយនាយករដ្ឋមន្ត្រីធ្វើការស្នើសុំទៅព្រះមហាក្សត្រ ដើម្បី

លើកលែងទោស ឬបន្ធូរបន្ថយទោស ... ឥឡូវដំណើរការតាមផ្លូវច្បាប់ រកវិធីដោះបន្ទុកតាមរយៈការផ្តល់មេធាវី។ រកមេធាវីអោយពូកែ រកវិធីដោះស្រាយបន្ទុកទៅតាមផ្លូវច្បាប់ មិនអាចមកដាក់សម្ពាធតាមរយៈពណ៌នេះ ពណ៌នោះទេ ...។

១៩. សិក្សាផ្លូវច្បាប់ ដាក់ទោសអ្នកដើរជម្រុញឲ្យពលរដ្ឋខ្ជីមីក្រូហិរញ្ញវត្ថុ

ពិធីកាត់ឫសសីមាព្រះវិហារ និងសម្ពោធសមិទ្ធផល ក្នុងវត្តព្រៃកប្រា,

ថ្ងៃទី ០៨ កុម្ភៈ ២០១៧

... បក្សនយោបាយនានាកុំប្រើរឿងនេះ។ ទាល់តែលេងដែរ អារឿងដែលគេដើរ ខ្សឹបនេះ។ បើថាមានបទល្មើសដាក់ស្តែង គឺចាប់នៅនឹងកន្លែងតែម្តង។ ដើរបោកប្រាស់រាល់ថ្ងៃ "បោះឲ្យខ្ញុំទៅ ខ្ញុំឈ្នះ(ការបោះឆ្នោត)លុបចោលបំណុលហ្នឹង"។ **មើលសិក្សាខាងផ្លូវច្បាប់មើល តើអាចដោះស្រាយរឿងហ្នឹងបានទេ? ព្រោះហ្នឹងជាការជម្រុញមួយឲ្យប្រជាជនទៅខ្ជីបន្ថែមទៀត ហើយដូចជាសម្លាប់ប្រជាជនអញ្ចឹងដើម្បីតែសន្ធឹកឆ្នោត។** ខ្ញុំព្រះករុណាខ្ញុំ សុំអំពាវនាវចំពោះប្រជាពលរដ្ឋ មុននឹងទៅខ្ជីគេ ត្រូវគិត តើយកមកធ្វើអី? ជាធម្មតា អ្នកឲ្យខ្ជីត្រូវគិតថា អ្នកនេះមានសមត្ថភាពសងឬអត់? មីក្រូហិរញ្ញវត្ថុខ្លះចង់បានផ្ទះគេ មានរហូតទៅដល់គ្រាន់ មិនទាន់ទាំងដល់ម៉ោងផង ទៅរឹបអូសយកផ្ទះទៅហើយ ... ធុនហ្នឹងក៏ត្រូវមានវិធានការចំពោះមីក្រូហិរញ្ញវត្ថុ ...។

២០. មន្ត្រីមូលដ្ឋានត្រូវតាមមើលករណីរដ្ឋមិនយកកម្រៃលើឯកសារជាង ២០ មុខ

ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៦ និងលើកទិសដៅការងារឆ្នាំ ២០១៧ របស់ក្រសួងមហាផ្ទៃ, ថ្ងៃទី ២៤ កុម្ភៈ ២០១៧

... **ត្រូវដឹងថា (ឯកសារ)ច្រើនមុខណាស់ ដែលយើងបានលុបចោលនូវការបង់កម្រៃ ប៉ុន្តែយើងត្រូវមានការតាមដានអោយបានច្បាស់ តើអ្នកទាំងនោះបានធ្វើឬអត់?** ដូចជាអត្តសញ្ញាណប័ណ្ណដែលយើងតម្រូវធ្វើតាំងពីអាយុ ១៥ ឆ្នាំ ឡើង មិនមែនបម្រើគ្រាន់តែត្រឹមការបោះឆ្នោតទេ អត្តសញ្ញាណប័ណ្ណវាមានផលប្រយោជន៍ខ្លាំងណាស់។ អញ្ចឹងទេ កាលមុននេះ ក្នុងពេលដែលរដ្ឋមានការលំបាក រដ្ឋបានអំពាវនាវអោយប្រជាជនបង់ប្រាក់ ១០០០០ រៀល សម្រាប់អត្តសញ្ញាណ

ប័ណ្ណមួយសន្លឹក។ ប៉ុន្តែក្រោយមកនេះ **យើងបានលុបចោលនូវការយកសេវានេះ ទាំងបញ្ហាសំបុត្របញ្ជីជាតិ តាំងពីសំបុត្រមរណភាព អាពាហ៍ពិពាហ៍ សំបុត្រកំណើត សៀវភៅគ្រួសារស្តីៗ ... លុបចោលរហូតទៅដល់ ២០ មុខឆ្លាយ ហើយត្រូវតាមមើលអាហ្នឹង ...**។

២១. ថ្នាក់ក្រោមជាតិត្រូវមើល តើនៅមានអ្នកយកភាស៊ីការលក់តាមកញ្ច្រែង/ល្អីទេ

ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៦ និងលើកទិសដៅការងារឆ្នាំ ២០១៧ របស់ក្រសួងមហាផ្ទៃ, ថ្ងៃទី ២៤ កុម្ភៈ ២០១៧

... **ទាក់ទងជាមួយនឹងបញ្ហាផ្សារ ត្រូវតាមមើលផង អស់លោកនៅខេត្ត នៅថ្នាក់ក្រោមជាតិ។ លុបចោលនូវការយកភាស៊ីលើការលក់តាមកញ្ច្រែង ល្អីស្តីៗនេះ ក្រែងលោយើងលុបតែខាងលើ អាក្រោមវាអត់លុប។ តាមមើលអាហ្នឹង។ ការកិច្ចរបស់អស់លោក។ អោយធ្វើអាជ្ញាធរថ្នាក់ក្រោមជាតិ មើលអាហ្នឹងផង ដើម្បី(សំរួល)អោយប្រជាពលរដ្ឋគាត់លក់ដូរតិចតួចតាមកញ្ច្រែង តាមល្អី** ជាពិសេសអ្វីដែលជារបស់គាត់ ... ត្រកួនគាត់ដាំខ្លួនគាត់ ព្រលឹមឡើងគាត់បេះ គាត់យកមកដាក់លក់។ ជួនកាលត្រសក់របស់គាត់ ត្រឡាចរបស់គាត់ៗ យកមកលក់ រួចយើងទៅយកភាស៊ីពីគាត់ដែរ ... ត្រូវតាមមើលពិតប្រាកដ ធ្វើម៉េចធ្វើអោយ(ការសំរេច)បាន(ជាប្រយោជន៍)ដល់ប្រជាពលរដ្ឋ ...។

២២. បន្តផ្ទេរមុខងារ ធនធានទៅថ្នាក់ក្រោមជាតិ រៀបចំចង្កោមផ្តល់សេវាជូនប្រជាពលរដ្ឋ

ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៦ និងលើកទិសដៅការងារឆ្នាំ ២០១៧ របស់ក្រសួងមហាផ្ទៃ, ថ្ងៃទី ២៤ កុម្ភៈ ២០១៧

... មានរឿងមួយដែលខ្ញុំបាននិយាយនៅក្នុងពេលប្រជុំក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី អំពីបញ្ហារចនាសម្ព័ន្ធនៅថ្នាក់ស្រុក ... អស់លោកថ្នាក់ក្រោមជាតិ គឺមានមន្ទីរ ហើយថ្នាក់ស្រុក គឺមានថ្នាក់ការិយាល័យ ប៉ុន្តែមន្ត្រីរបស់អស់លោកមានម្នាក់ពីរនាក់ ... ធ្វើស្ពឹ(ទាន់ពេល)។ ធ្វើវាមិនចេញទេ។ **អញ្ចឹងខ្ញុំស្នើអោយសម្តេចក្រឡាហោម ពិភាក្សាជាមួយនឹងក្រសួងមុខងារសាធារណៈ ជាមួយនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រៀបចំទម្រង់បែងចែកជាផែន។ ឧទាហរណ៍ថា**

ចង្កោមផលិតកម្មមានស្អីខ្លះ? មានកសិកម្ម មានអភិវឌ្ឍន៍ជនបទ មានបរិស្ថាន មានឧស្សាហកម្ម មានរ៉ែ និងថាមពល ដែលទាក់ទងជាមួយនឹងបញ្ហាផលិតកម្ម អោយវាទៅមួយចង្កោមទៅ ... រៀបចំចង្កោមអញ្ចឹងបានមានកន្លែង និងមានមន្ត្រីធ្វើការ ... រៀបចំចងក្រងអោយស្រួតទៅ ហើយរុញទម្លាក់ថវិការទៅ។ ពីមុន ថ្នាក់ស្រុកជាថ្នាក់លើរបស់មូលដ្ឋាន ប៉ុន្តែគ្មានថវិការទេ។ មុននោះ យើងមានថវិកាថ្នាក់ឃុំ ខេត្ត និងជាតិ។ ឥឡូវយើងមានថ្នាក់ជាតិ ខេត្ត ស្រុក និងឃុំ ...។

២៣. បោះឆ្នោតក្រុមប្រឹក្សាឃុំ ត្រូវសុវត្ថិភាព សេរីភាព យុត្តិធម៌ ត្រឹមត្រូវ និងទទួលយកបាន

ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៦ និងលើកទិសដៅការងារឆ្នាំ ២០១៧ របស់ក្រសួងមហាផ្ទៃ, ថ្ងៃទី ២៤ កុម្ភៈ ២០១៧

... យើងត្រូវផ្តល់សារៈសំខាន់ថា នៅកម្ពុជាគឺបោះឆ្នោតទៀងទាត់តាមការកំណត់។ មានអ្នកខ្លះគេថាយើងលុបចោលការបោះឆ្នោត។ លុបចោលការបោះឆ្នោតអី បើនាយករដ្ឋមន្ត្រីប្រកាសកាលបរិច្ឆេទសម្រាប់ការបោះឆ្នោតនៅថ្ងៃទី ៤ ខែ មិថុនា ... ចុះបើ ហ៊ុន សែន អ្នកប្រកាសកាលបរិច្ឆេទបោះឆ្នោតហើយ លោកឯងនិយាយថាម៉េច។ (មិន)មួលបង្ហាច់គេ? ... **រឿងធំជាងគេត្រូវតែប្រតិបត្តិការនៃការបោះឆ្នោតឲ្យបាន ដើម្បីធានានូវដំណើរការនៃប្រជាធិបតេយ្យសម្រាប់ប្រទេសរបស់យើង ដែលយើងមានបោះឆ្នោតសកល និងបោះឆ្នោតអសកល ... រឿងឈ្នះឬមិនឈ្នះ គឺជារឿងបក្សនយោបាយ តែយើងក្នុងឋានៈជារាជរដ្ឋាភិបាល ត្រូវមានការទទួលខុសត្រូវលើបរិយាកាសទាំងមូលនៃការបោះឆ្នោត ដើម្បីអោយការបោះឆ្នោតនៅថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៧ ប្រព្រឹត្តទៅមានសុវត្ថិភាព សេរីភាព យុត្តិធម៌ ត្រឹមត្រូវ និងទទួលយកបាន** ...។

មុខងារសាធារណៈ

១	តែងតាំងគ្រូពេទ្យឯកទេសចូលនិវត្តមួយចំនួន ក្នុងមុខងារនយោបាយ	១៦៩
២	មន្ត្រីជាខ្ញុំបម្រើដ៏ស្មោះត្រង់ មិនមែនជាចៅហ្វាយប្រជាជននោះទេ	១៦៩
៣	សេវាសាធារណៈតម្រូវអោយមានការដូរផ្លាស់ឥរិយាបថ	១៧០
៤	សុខដុមភាវូបនីយកម្មមន្ត្រីដឹកនាំបីជំនាន់	១៧០
៥	វាយតម្លៃសភាពការណ៍ ដោយប្រាកដនិយម និងជាក់ស្តែងនិយម	១៧១
៦	មន្ត្រីផ្ទៃណ្តៅ ឬ ការឆ្លុះបញ្ចាំងព័ត៌មានត្រឹមត្រូវ ពីខាងក្រោមមកខាងលើ	១៧១
៧	ស្រាយសេវាសាធារណៈ បម្រើប្រជាជនដោយស្មោះត្រង់	១៧២
៨	មន្ត្រីស្រាយសភាពការ, មន្ត្រីរាយការណ៍អោយថ្នាក់លើ ...	១៧២
៩	ត្រូវប្រុងប្រៀបសំរាប់ករណីប្រធានសក្តិ ឬកត្តាចៃដន្យ	១៧៣
១០	គោលដៅបៀវត្ស៍ ឆ្នាំ ២០១៨	១៧៤
១១	កំណែទម្រង់ក្នុងប្រព័ន្ធបើកប្រាក់ខែ	១៧៤
១២	រំកិលប្រាក់បៀវត្សអ្នកចូលនិវត្តមុន ឲ្យកៀកអ្នកចូលនិវត្តក្រោយ	១៧៥

១. តែងតាំងគ្រូពេទ្យឯកទេសចូលនិវត្តមួយចំនួន ក្នុងមុខងារនយោបាយ

សេចក្តីអធិប្បាយ ក្នុងពិធីបិទសន្និបាតសុខាភិបាលប្រចាំឆ្នាំ លើកទី ៣៧, ថ្ងៃ១០ មីនា ២០១៦

... កន្លងទៅ ខ្ញុំបានឲ្យមានការតែងតាំងក្នុងក្របខណ្ឌទៅជាមុខងារនយោបាយ ដើម្បីពួកគាត់មានឱកាសធ្វើការបន្តទៅទៀត។ ប្រសិនបើកាលហ្នឹង យើងយល់ដឹងឲ្យបានច្បាស់ ដាក់(អាយុ) ៦៥ ឆ្នាំ ទាំងអស់តែម្តង ចាំចូលនិវត្ត។ ប៉ុន្តែកាលនោះខ្ញុំទារបានតែគ្រូទេ។ កាលនោះ គ្រូកំណត់អាយុ ៥៥ ឆ្នាំ, ៥៧ ឆ្នាំ, ៦០ ឆ្នាំ, ខ្ញុំទារបានគ្រូទាំងអស់ ឯចំពោះក្របខណ្ឌដទៃទៀតនៅសល់ ៥៥ ឆ្នាំ, ៥៨ ឆ្នាំ, ៦០ ឆ្នាំ សម្រាប់ខាងស្ត្រី។ បានស្ត្រីមួយ។ **ឥឡូវ លក្ខន្តិកៈមន្ត្រីរាជការរបស់ យើងកំណត់(អាយុ) ៦០ ឆ្នាំ។ ប៉ុន្តែ យើងអាចសម្រួលបាន។ គ្រូពេទ្យឯកទេសរបស់យើងមួយចំនួនដែលចូលនិវត្ត យើងតែងតាំងទៅមុខងារនយោបាយទៅ រួចហើយឲ្យគាត់ទៅធ្វើការនៅមន្ទីរពេទ្យណាមួយបន្ត។ គ្រូពេទ្យថ្មីដែលចេញមកហួសអាយុ គឺយើងបង្កើនអាយុដល់ ៣៥ ឆ្នាំដើម្បីប្រឡង។ ឥឡូវយើងប្រកាសទទួលយកគ្រូពេទ្យឯកទេសទាំងអស់ ... ប្រកាសបញ្ជូលក្របខណ្ឌតែម្តងទៅចាប់ទទួលប្រាក់ខែពីខែ មេសា អីហ្នឹងតែម្តងទៅ។** គ្រូពេទ្យឯកទេសដែលចូលនិវត្ត ខិតខំតែងតាំងក្នុងមុខងារនយោបាយ ឲ្យទៅបម្រើការងារទៅតាមមន្ទីរពេទ្យ ...។

២. មន្ត្រីជាខ្ញុំបម្រើដ៏ស្មោះត្រង់ មិនមែនជាចៅហ្វាយប្រជាជននោះទេ (មន្ត្រីជើង ១០)

ពិធីចែកវិញ្ញាបនបត្រ ដល់ កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ និងមធ្យម និងបើកវគ្គបណ្តុះបណ្តាលសាលាកូមិន្ទរដ្ឋបាល, ថ្ងៃទី ១០ មីនា ២០១៥

... ខ្ញុំព្រះករុណាខ្ញុំ **ចង់ផ្តាំផ្ញើថា កុំភ្លេចឲ្យ សោះថា មន្ត្រីជាខ្ញុំបម្រើដោយស្មោះត្រង់របស់ប្រជាជន មិនមែនជាចៅហ្វាយរបស់ប្រជាជនទេ** ... បើមិន(យល់ពីសារជាតិពិត)ដូច្នេះទេ មន្ត្រីរបស់យើងនឹងពើងទ្រូងដាក់ប្រជាជន ហើយតាំងខ្លួនជាចៅហ្វាយរបស់ប្រជាជន។ ចំណុចនេះ ទាមទារឲ្យមន្ត្រីរំលឹកដាស់តឿនខ្លួនឯងជាប់ជានិច្ច ... **យើងជាមន្ត្រីរាជការ ដែលមានកៅអីមានតុ ត្រូវខិតខំចៀសវាងឲ្យខានតែបាននូវ(ប្រការដែលថាជា)មន្ត្រីជើង ១០ ... មិនចេះរត់រកការងារធ្វើ ឲ្យការ**

ងារត់មករកវិញ។ មន្ត្រីធុននេះ មិនមែនជាមន្ត្រីដែលមានអនាគតល្អទេ យើងត្រូវ
បណ្តុះគំនិតនេះឲ្យបាន ...។

៣. សេវាសាធារណៈតម្រូវអោយមានការដូរផ្លាស់ឥរិយាបថ

> កិច្ចប្រជុំផ្សព្វផ្សាយសេចក្តីសម្រេចបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ត្រួតពិនិត្យ
> និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣,
> ថ្ងៃទី ២៩ មករា ឆ្នាំ ២០១៤

... ការកែទម្រង់ ត្រូវយកអ្វីជាគោល? គឺយកប្រជាពលរដ្ឋជាគោល ត្រូវបំរើពលរដ្ឋអោយចំគោលដៅ។ បើមិនធ្វើដូចនេះ តើធ្វើដើម្បីអ្វី? ត្រូវពិនិត្យសំណូមពរជាមូលដ្ឋាន ដើម្បីរៀបចំជាក្របខ័ណ្ឌគោលនយោបាយបម្រើ និងដោះស្រាយសំណូមពរប្រជាជន។ សេវាសាធារណៈ នឹងក្លាយជាចំណុចសំខាន់។ ការនៃ្លងខ្លះមិនត្រូវការទុនទេ ពោលគឺគ្រាន់តែកែទម្លាប់របស់យើងគឺជាការស្រេច។ ការកែប្រែឥរិយាបទជាការសំខាន់នៅទីនេះ ... អាចនឹងមានការដោះស្រាយដោយការទទួលខុសត្រូវជាអន្តរក្រសួងពីបញ្ហាមួយចំនួន។ យោងតាមសមាសភាពក្រុម កិច្ចការមួយចំនួនអាចត្រូវបានដោះស្រាយ មិនបាច់មករកដំណោះស្រាយពីលើទេ ...។

៤. សុខដុមភាវូបនីយកម្មមន្ត្រីដឹកនាំបីជំនាន់

> សង្គមថាពិធីប្រគល់សញ្ញាត្រ ដល់មន្ត្រីជាន់ខ្ពស់ជំនាន់កំណែទម្រង់រដ្ឋ សិស្សមន្ត្រីក្រម
> ការជំនាន់ ភក្តីភាព និងវិញ្ញាបនបត្រដល់កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់មធ្យម ២០១៣
> បើកវគ្គបណ្តុះបណ្តាល និងវិក្រិត្យការ ឆ្នាំ ២០១៤ នៃសាលាភូមិន្ទរដ្ឋបាល,
> ថ្ងៃទី ០៧ កុម្ភៈ ២០១៤

... មិនថាជំណាក់កាលណាៗ ទេ យើងឡើងពីទាបទៅខ្ពស់ ហើយការធ្វើដំណើររបស់យើងនៅវែងឆ្ងាយ។ ឥឡូវនេះចូលដល់(អ្វីដែល)ហៅថា រ៉ាប ត្តិមន្ត្រីបន្តវេន។ រឿងអីស្រាប់តែមកដល់កំឡុងក្រោយឆ្នាំ ២០១០ ប្រវត្តិរូបសុទ្ធតែមនុស្ស អាយុ ៦០ ... ត្រូវដូរអភិបាលខេត្ត អភិបាលរងខេត្ត អភិបាលស្រុកច្រើនណាស់។ ការរៀបចំមន្ត្រីបន្តវេន មិនមែនទើបនឹងចាប់ផ្តើមទេ។ ថ្ងៃនេះ យើងជាក្រមការ ជាអនុមន្ត្រី ជារ៉ាមន្ត្រី ប៉ុន្តែនៅពេលក្រោយ យើងឈានឡើងពីជំហានមួយ ទៅកាន់

ជំហានមួយ។ អាណត្តិនេះ (យើង)**បានឆ្លៀតជាក់មន្ត្រីវ័យក្មេងចូលជាសមាជិករាជរដ្ឋាភិបាល ជាថ្នាក់រដ្ឋមន្ត្រី ជាថ្នាក់រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការមួយចំនួនដែរ។ ត្រូវធ្វើសុខដុមភាវូបនីយកម្មរវាងជំនាន់ ៣ ចូលអ្នកចាស់ អ្នកមធ្យម និងអ្នកក្មេង ហៅថា ស្ថានភាពចម្រុះនៃថ្នាក់ដឹកនាំ តាមស្ថាប័នមួយៗ ដែលមានមនុស្សអាយុច្រើន អាយុមធ្យម និងតិច ...**។

៥. វាយតម្លៃសភាពការណ៍ ដោយប្រាកដនិយម និងជាក់ស្តែងនិយម

សង្គមថាពិធីចែកវិញ្ញាបនបត្របញ្ជាក់ការសិក្សាសិស្សមន្ត្រីនៃសាលាភូមិន្ទរដ្ឋបាល, ថ្ងៃទី ៧ មីនា ២០១៣

... ពេលធ្វើការវាយតម្លៃ សូមមន្ត្រីយើងកុំវាយតម្លៃតាមសង្ក្រាមចិត្តសាស្ត្រឱ្យសោះ។ ត្រូវវាយតម្លៃតាមរឿងពិត។ ចំណុចខ្សោយយើងនៅកន្លែងណា។ ចំណុចខ្លាំងយើងនៅកន្លែងណា? បើការបោះឆ្នោតវិញ គួរប្រកួតរបស់យើងគេខ្លាំងរឿងអី? ខ្សោយរឿងអី? **ដូចជាយើងជាក់ចេញនយោបាយអាទិភាព ទឹក ផ្លូវ ភ្លើង មនុស្ស ហើយបើមនុស្ស គឺត្រូវនិយាយពីសេវាអប់រំ សេវាសុខភាពស្ទីៗ ជាដើម។ ដើម្បីជាក់ចេញកម្មវិធីនយោបាយបាន ត្រូវតែមានព័ត៌មានត្រឹមត្រូវ វិភាគឱ្យត្រូវ វាយតម្លៃសភាពការណ៍ឱ្យត្រូវ កុំវាយតម្លៃសភាពការណ៍តាមខុស ... ម្ខាងមកប្រាប់រាជរដ្ឋាភិបាលថា ត្រូវគោរពច្បាប់ ត្រូវឱ្យតុលាការឯករាជ្យ ម្ខាងទៀតឱ្យរាជរដ្ឋាភិបាលលូកដៃទៅគាបសង្កត់តុលាការ ដើម្បីដោះលែងមនុស្សជាប់គុក ... ត្រូវប្រាកដនិយម, ជាក់ស្តែងនិយម ...**។

៦. មន្ត្រីផ្ទៃល្ពៅ ឬ ការឆ្លុះបញ្ចាំងព័ត៌មានត្រឹមត្រូវ ពីខាងក្រោមមកខាងលើ

ពិធីចែកវិញ្ញាបនបត្រដល់កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ និងមធ្យមនិងបើកវគ្គបណ្តុះបណ្តាលសាលាភូមិន្ទរដ្ឋបាល, ថ្ងៃទី ១០ មីនា ២០១៥

... ខ្ញុំក៏សូមផ្តាំផ្ញើ កុំឱ្យមន្ត្រីរបស់យើងក្លាយទៅជាមន្ត្រីគ្រាប់ល្ពៅ ... មន្ត្រីដែលអាក្រក់ជាងគេ គឺប្រភេទទី ១ ដែលមិនត្រឹមតែបោកស្តេចទេ ថែមទាំងធ្វើបាបអ្នកយាមទៀត។ ប្រភេទទី ២ អាចថា មិនដឹងថាពិត ឬមិនពិត ឆ្លើយយកតែរួចខ្លួន។ ដាំដែរតែ អត់បានបេះយកមក។ ឯប្រភេទទី ៣ អាចថាកណ្តុរស៊ីមែន ឬក៏ដឹងថា

គ្រាប់ល្ពៅស្ងោរ ក៏ប៉ុន្តែមិនហ៊ានទូលស្តេចត្រង់។ ចំពោះប្រភេទទី ៤ វិញ គឺជាមន្ត្រីស្មោះត្រង់ អស់តែ ៣ គ្រាប់ទេ ព្រោះយកតេស្តមើល ឃើញថាឆ្អិន ស៊ីអស់ ៣ គ្រាប់ សល់ប៉ុន្មានយកឱ្យស្តេចវិញទៅ។ **រីនិច្ឆ័យទៅលើចំណុចនេះវិញ តើផ្តល់ឱ្យយើងនូវការគ្រិះរិះបែបណា? ... បើមិនអាចឆ្លុះបញ្ចាំងការពិតបានទេ មានន័យថា ការដោះស្រាយនៅខាងលើក៏ខុសដែរ ... ចាំបាច់ត្រូវមានការឆ្លុះបញ្ចាំងត្រឹមត្រូវនូវព័ត៌មានពីខាងក្រោមមកខាងលើ ហើយខាងលើដោះស្រាយត្រឡប់ទៅវិញ ក៏ត្រឹមត្រូវទៅតាមព័ត៌មានហ្នឹង ...**។

៧. ស្រាយសេវាសាធារណៈ បម្រើប្រជាជនដោយស្មោះត្រង់

សង្គថាក្នុងពិធីសម្ពោធអគាររដ្ឋបាលថ្មី នៃសាលារាជធានី ភ្នំពេញ,
ថ្ងៃទី ៥ មេសា ២០១៦

... ថ្ងៃនេះមានមន្ត្រីថ្នាក់មូលដ្ឋានមក។ **រឿងសេវាសាធារណៈនេះ ជាចំណុចតួញ្ញត្ត្ម ... ខិតខំដោះស្រាយសេវាសាធារណៈ ពិសេសសេវាតម្រូវការ។ ត្រូវធ្វើអោយបាន។ បម្រើប្រជាជនឲ្យបានស្មោះត្រង់បំផុត។ កន្លែងខ្លះ មន្ត្រី ១ ៣ន់នាក់ មាន ៤ ឬ ៥ នាក់ទេ ដែលខិលខូច ធ្វើឲ្យខូចមន្ត្រី ១ ៣ន់នាក់ ... មួយចំនួនតូចមានចេតនារុញឲ្យខ្ជោចរោចឲ្យធៅ។ តាមការស្រាវជ្រាវ ខ្លះជាមនុស្សរបស់បក្សផ្សេង**។ គេចង់ធ្វើរឿងហ្នឹង(អីចឹង) ដើម្បីឲ្យរដ្ឋបាលរបស់យើងខូចឈ្មោះ។ រដ្ឋបាលសាធារណៈមិនមែនជារបស់បក្សនយោបាយណាមួយទេ ប៉ុន្តែ**មានបក្សនយោបាយខ្លះ** **បានប្រើប្រាស់មនុស្សដែលខ្លួនចាត់តាំងបាននៅក្នុងរដ្ឋបាលសាធារណៈ ដើម្បីបំផ្លាញកេរ្តិ៍ឈ្មោះមន្ត្រីរដ្ឋបាលសាធារណៈ។ ខ្ញុំសូមស្នើឲ្យមន្ត្រីដែលល្អ។ ចាប់ខ្លួនមនុស្សនោះ ដើម្បីផ្តន្ទាទោស លាងសងភាពស្អាតស្អំសម្រាប់យើងវិញ ...**។

៨. មន្ត្រីស្រាយសភាពការណ៍, មន្ត្រីរាយការណ៍អោយថ្នាក់លើ និងបន្ទោសថ្នាក់ក្រោម

សង្គថា, ពិធីចែកវិញ្ញាបនបត្របញ្ជាក់ការសិក្សា សិស្សមន្ត្រីនៃសាលាកូមិន្ទរដ្ឋបាល,
ថ្ងៃទី ៧ មីនា ២០១៣

... លេចឡើងនូវប្រភេទមន្ត្រីពីរបៃបមន្ត្រី ម្ចាស់ការដោះ ១ទី ,ស្រាយបញ្ហានៅហ្នឹងកន្លែង ដូចជា អភិបាលខេត្ត ធ្វើអភិបាលស្រុក ឬស្ថាប័ននានា ទ្រទ្រង់សភាពការណ៍ អត់ដើរចាលកន្លែង ប្រមូលផ្តុំដោះស្រាយបញ្ហា ទោះបីវាជំនន់ក្តី រាំងស្ងួតស្អី ត្រូវដោះស្រាយសិន ... ខ្ញុំចង់បានមន្ត្រីបែបនេះ។ **មន្ត្រីមួយប្រភេទទៀត ធ្វើកិច្ចការពីរ ទី ១ រាយការណ៍ឱ្យខាងលើ, ទី ២ បន្ទោសថ្នាក់ក្រោម។ មន្ត្រីប្រភេទនេះ កុំឱ្យកើតមាន។** ផ្តាំធ្វើម្ជុនៗ ក្ជយៗ ឱ្យហើយ ថ្ងៃក្រោយថ្ងៃមុខក្លាយទៅជាអ្នកធំហើយ។ មិនអត់ទេ។ ស្មានថាអ្នកទាំងអស់(អង្គុយខាងលើ)ហ្នឹងធ្វើអ្នកធំរហូតឬ? នេះសម័យកុំព្យូទ័រផង ...។

៩. ត្រូវប្រុងប្រៀបសំរាប់ករណីប្រធានសក្តិ ឬកត្តាចៃដន្យ

សង្គ្រាពិធីចែកវិញ្ញាបនបត្របញ្ជាក់ការសិក្សា សិស្សមន្ត្រីនៃសាលាភូមិន្ទរដ្ឋបាល, ថ្ងៃទី ៧ មីនា ២០១៣

... មិនដែលមានផែនការ ឬកម្មវិធីនយោបាយណាមួយត្រូវតតាខ្ជោ: ដោយមិនបានគិតកត្តាប្រធានសក្តិកើតឡើង ឬកត្តាចៃដន្យឡើយ។ តើអ្នកណាបានគិតថា ឆ្នាំថោ:ទៅជាទឹកធំទេ? អត់ទេ។ ចៃដន្យមែនទែន។ ហើយតើអ្នកណាបានគិតថា ឆ្នាំរោងបែរជាទឹកតូចទេ? អត់ទេ។ នេះហើយជាការលេចឡើងនូវកត្តាចៃដន្យក្នុងពេលដែលអនុវត្ត។ តាំងពីឆ្នាំ ២០០៤ រហូតមកដល់ឆ្នាំ ២០០៧ កំណើនសេដ្ឋកិច្ចកម្ពុជាឡើងដល់ ២ ខ្ជង់ មានមួយឆ្នាំ គឺឆ្នាំ ២០០៥ យើងឡើងដល់ ១៣,៣% បានសេចក្តីថា សេដ្ឋកិច្ចខ្ពស់ណាស់។ **តើអ្នកណាបានគិតថា នឹងមានវិបត្តិសេដ្ឋកិច្ចហិរញ្ញវត្ថុសកលកើតឡើង? ... យើងត្រូវផ្លាស់ប្តូរផែនការ។ ហ្នឹងជាសមត្ថភាពរបស់រដ្ឋក្នុងការគ្រប់គ្រងសភាពការណ៍។ តម្លៃប្រេងឡើងព្រឹប អគ្គិសនីនៅភ្នំពេញត្រូវឡើងថ្លៃឬអត់? ខ្ញុំបានប្រាប់ថា អត់ទេ។ យើងត្រូវបំពេញខាតមួយរយៈ ... យើងក៏បានដាក់ចេញនូវ(យុទ្ធសាស្ត្រ)បង្កើនចំណាយសម្រាប់ជម្រុញកំណើន** ហើយការសង្គ្រោះកម្មករដែលបាត់បង់ការងារដោយរៀបចំនូវកញ្ចប់ថវិកាមួយបណ្តុះបណ្តាលវិជ្ជាជីវៈ ...។

១០. គោលដៅបៀវត្ស៍ ឆ្នាំ ២០១៨

> សង្គថា ក្នុងឱកាសចែកសញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ គ្រូកម្រិតឧត្តម(បរិញ្ញាបូកមួយ) គ្រូកម្រិតមូលដ្ឋានឯកទេសភាសាបារាំង-ខ្មែរ, ថ្ងៃទី ៩ ខែ មីនា ឆ្នាំ២០១៦

... **ឆ្នាំ ២០១៨ គោលដៅទាបបំផុតត្រឹមចំនួន ១ លាន។ ត្រូវមានការខិតខំប្រឹងប្រែងច្រើន ដើម្បីធានាថា អ្វីដែលយើងត្រូវផ្តល់អោយមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធចំនួនដ៏ច្រើននេះ មិនតម្រូវអោយមានការទៅខ្ចីលុយធនាគារមកបើករហូតដល់ខ្ទះសាច់ប្រាក់ (ហើយធ្វើ)ការបោះក្រដាសប្រាក់បន្ថែមនោះទេ។ ក្នុងរយៈពីរខែដើមឆ្នាំនេះ យើងបានសាកល្បងចំណូល/ចំណាយ ឃើញថាកំណើនបែបនេះ យើងអាចស្នុះរួច**។ ខ្ញុំកំពុងអោយរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ ពិភាក្សាគ្នាអំពីប្រាក់ឧបត្ថម្ភសម្រាប់ភរិយា និងកូនរបស់មន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធ ... ចុងខែ មីនា (២០១៦) នាំគ្នាបើកប្រាក់ខែ មានកំណើន ១២% ធៀបនឹងឆ្នាំទៅ។ ១០ ថ្ងៃក្រោយ ត្រូវបើកមុនចូលឆ្នាំ ជាមួយនឹងប្រាក់មុខងារបន្ថែម ... ទំហំទឹកប្រាក់ទៅលើទីផ្សារវាធំណាស់ ទាមទារអោយមានការប្រយ័ត្នប្រយែងគ្រប់គ្រងសាច់ប្រាក់ ...។

១១. កំណែទម្រង់ក្នុងប្រព័ន្ធបើកប្រាក់ខែ

> ពិធីបិទវគ្គ និងចែកសញ្ញាបត្រ/វិញ្ញាបនបត្រ សិស្សមន្ត្រីជាន់ខ្ពស់/សិស្សមន្ត្រីក្រមការ និងកម្មសិក្សាការី នៃសាលាភូមិន្ទរដ្ឋបាល ថ្ងៃទី១៧ កុម្ភៈ ២០១៤

... **ធនាគារជាតិត្រូវចាត់ចែងយ៉ាងម៉េច ហើយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានរតនាគារជាតិសម្រួលយ៉ាងម៉េច ... ពីមុននេះ បន្តិចឮថាក្រសួងនេះបើកលុយបានហើយ ក្រសួងនោះមិនទាន់បាន។ ប៉ុន្តែបានប្រជុំកន្លងទៅ ហើយដាក់សារាចរ ហើយណែនាំតែម្តង ពេលណាអីពេលណា ត្រូវតែមានការទទួលខុសត្រូវអត់មានឆ្លើយដាក់គ្នាទេ។** រឿងសាច់ប្រាក់បើកប្រាក់ខែ អត់មានចំណោទចោទជាបញ្ហាទេ។ មុននេះ គឺថាក្រសួងនេះបើកបាន ក្រសួងនោះអត់បាន ស៊ីសងរដ្ឋមន្ត្រីគាត់ស៊ីញ៉ៀ ឬមិនស៊ីញ៉ៀ ... **ត្រូវរដ្ឋមន្ត្រីចុះហត្ថលេខា បើរដ្ឋមន្ត្រីមិនចុះហត្ថ**

លេខា ត្រូវផ្ទេរសិទ្ធិឱ្យអ្នកណាចុះហត្ថលេខា ដើម្បីនៅពេលដែលដាច់ខែបើកឱ្យបានតែម្តង។ ពិតមែនតែប្រាក់ខែវាតិចប៉ុន្តែបើសិនជាបើកបានទាន់ពេលវេលា អាហ្នឹងវាល្អ។ អាតិចហើយ បើកយូរទៀត អាហ្នឹងរឿង ... ផ្ទេលេខាធិការ/អនុផ្ទេលេខាធិការគណៈ ឬក៏អគ្គនាយកដ្ឋាន ឬក៏ប្រធាននាយកដ្ឋានបុគ្គលិកស៊ីញ៉ូ។ អាហ្នឹងជាផ្នែកមួយនៃកំណែទម្រង់ ដែលទាក់ទងទៅនឹងជីវភាពមន្ត្រីរាជការ ជាមួយនឹងការគ្រប់គ្រងកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ...។

១២. រំកិលប្រាក់បៀវត្សអ្នកចូលនិវត្តមុន ឲ្យកៀកអ្នកចូលនិវត្តក្រោយ

> សង្គ្រាជ ក្នុងឱកាសអញ្ជើញ សួរសុខទុក្ខយោធិនពិការ ៣១៧ គូលែន ថ្ងៃទី១២ មេសា ២០១៦

... ឥឡូវ **ខ្ញុំកំពុងតែផ្តល់ឲ្យក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ធ្វើការកែសម្រួលពីអ្នកចូលនិវត្តមុន និងអ្នកចូលនិវត្តក្រោយ។ ពិការមុនដែលទទួលរបបទាប និងពិការក្រោយដែលទទួលរបបខ្ពស់** ... ពីដើមកូនទាហានរបស់យើងប្រាក់ខែ ២០ ម៉ឺន ចាប់ពិការ ដល់ពេលចូលទៅទទួលរបបនៅខាងសង្គមកិច្ចនៅសល់ជាង ២០ ម៉ឺនរៀលប៉ុណ្ណឹងចុះ ប៉ុន្តែអ្នកដែលផ្ទេរទៅក្រោយស្រាប់តែមានប្រាក់របបដល់ទៅ ៧០ ម៉ឺន។ សក្តិប៉ុនគ្នា ... **ឆ្នាំនេះរុញមួយកម្រិត ឆ្នាំក្រោយរុញបន្ត។ ដើម្បីឲ្យអ្នកក្រោមហាក់ឡើងទៅតាមអ្នកមុន។ នេះមិនមែនការណីដាច់ដោយឡែកចំពោះជនពិការទេ។ ជាការណីទូទៅនៃមន្ត្រីរាជការ និងកម្លាំងប្រដាប់អាវុធរបស់យើង រវាងអ្នកចូលនិវត្តមុនដែលប្រាក់ខែទាប និងអ្នកចូលនិវត្តក្រោយ ដែលប្រាក់ខែខ្ពស់។ យើងត្រូវធ្វើយ៉ាងដូច្នេះ** ...។

ឧតត្តរូបនីយកម្ម រៀបចំដែនដី និងសំណង់

១	អតីតកាលជាម៉ែត្រវាស់ការរីកចំរើន	១៧៩
២	ភ្នំពេញ រីកតាមរបៀបជម្រៅ	១៧៩
៣	កំណើន(សេដ្ឋកិច្ចសង្គម)មានសម្ពាធ ទៅលើនគរូបនីយកម្ម	១៧៩
៤	គ្រប់ទីក្រុង ត្រូវតែស្អាត	១៨០
៥	ភ្នំពេញក្រុងសន្តិភាព ក្រុងលំហាត់ប្រាណ និងបង្កើតមិត្តភក្តិ	១៨០
៦	ផលវិបាកនៃការមិនមានប័ណ្ណកម្មសិទ្ធិដីធ្លី	១៨១
៧	មិនថានិន្នាការនយោបាយណាទេ ត្រូវទទួលបានការវាស់វែងដូចគ្នា	១៨២
៨	រដ្ឋមានសិទ្ធិកាត់ដីពាក់ព័ន្ធក្រុមហ៊ុន គំរបព្រៃ ជម្រកសត្ត	១៨២
៩	និរាករណ៍ព្រះរាជក្រឹត្យ បង្កើតតំបន់សហគ្រាសសេរីនៅកំពង់ឆ្នាំង	១៨៣
១០	ការផ្តល់ដីសម្បទានសេដ្ឋកិច្ចមិនអាក្រក់ តែការអនុវត្តមិនច្បាស់	១៨៣
១១	កាត់ដីចេញពីចំការកៅស៊ូជូនប្រជាពលរដ្ឋ	១៨៤
១២	ផ្អាកការផ្តល់ដីសម្បទានរយៈពេលវែង	១៨៤
១៣	ដកហូតដីពីក្រុមហ៊ុន សម្រាប់គោលដៅដីសម្បទានសង្គមកិច្ច	១៨៥
១៤	វាស់ដីធ្លីហើយ ចាំគូរផែនទីគម្របព្រៃឈើថ្មី	១៨៦

១. អតីតកាលជាម៉ែត្រវាស់ការរីកចំរើន

បើកការដ្ឋានស្ថាបនាទំនប់ការពារទឹកជំនន់ និងកែលម្អប្រព័ន្ធប្រឡាយ/លូ ជំហានទី២, ថ្ងៃទី ១៣ ធ្នូ ២០០៧

... ស្រមៃគិតឡើងវិញ កាលពីជិត ២០ ឆ្នាំមុន តើយើងមានអ្វី? សូម្បីតែប្រទេសជប៉ុនខ្លួនឯង ដែលមានវិនាសកម្មសង្គ្រាម ឬប្រទេសដទៃ កាលពី ៥០ ឬ ៦០ ឆ្នាំ មុន ... **គេអត់ភ្លេចពីអតីតកាលរបស់គេទេ (គេរក្សាវា)ដើម្បីយកមកធ្វើជាម៉ែត្រវាស់ការរីកចម្រើនរបស់គេដែរ មិនមែនបានសេចក្ដីថា ធ្ពុះដំបៅចាស់ អោយមានការឈឺចាប់នោះទេ ... អ្នកខ្លះលើកឡើងថា ធ្វើទៅកាន់តែក្រ ... ចុះមានក្រឯណា ជាងក្រជំនាន់ អា ពត ទៀត? ... ឥឡូវ ទីក្រុងភ្នំពេញមានអាយុ ៥៧៣ ឆ្នាំ (២០០៧) ប៉ុន្តែ យើងមិនបានទទួលមរតកណាមួយ លើកលែងតែអគារដែលនៅសេសសល់** ... ពិបាកថែទាំទៀត ...។

២. ភ្នំពេញ រីកតាមរបៀបជម្រៅ

ពិធីសម្ពោធស្ពានអាកាស ស្ទឹងមានជ័យ, ថ្ងៃទី ៣១ កក្កដា ២០១៤

... ជាមួយនឹងវត្តមានប្រជាពលរដ្ឋជាង ១ លាននាក់ ... អ្នករកការងារធ្វើ និងអ្នកឆ្លងកាត់ដទៃទៀត ក្នុងមួយថ្ងៃមិនតិចជាងប្រហែលនឹង ២ លាននាក់ទេ។ វត្តមានប្រជាពលរដ្ឋកាន់តែច្រើន ក្នុងនោះ ការកសាងបុរីថ្មីមាន ៧៤ បុរី, ផ្ទះសំបែងកសាងច្រើនណាស់ (ដែលធ្វើអោយ)ទំហំផ្ទៃនៃទីក្រុងភ្នំពេញបានកើន។ កាលពីមុនជាង ៣០០ គីឡូម៉ែត្រការ៉េ ឥឡូវជិត ៧០០ គីឡូម៉ែត្រការ៉េ គឺរីក ១ ជា ២។ វារីកទាំងទំហំទាំងជម្រៅ ... **រីកជម្រៅនៅត្រង់ថាពីដើមដី ១ ហិកតា មានសំណង់ត្រឹមតែ ៥ ៣ន់ម៉ែត្រការ៉េទេ ឥឡូវក្នុង ១ ហិកតា នេះ វាមានសំណង់រហូតទៅដល់ ៥ ម៉ឺន ឬ ១០ ម៉ឺនម៉ែត្រការ៉េឯណោះ ... ហ្នឹងហើយ ដែលហៅថារីកតាមរបៀបជម្រៅ** ...។

៣. កំណើនមានសម្ពាធ ទៅលើនគរូបនីយកម្ម

បើកការដ្ឋានស្ពានអាកាសតិចណូ, ថ្ងៃទី ០៩ កញ្ញា ២០១៤

... **ការរីកចម្រើនរបស់ប្រទេសជាតិ ធ្វើឲ្យកើនឡើងនូវសម្ពាធទៅលើបញ្ហានគរូបនីយកម្ម ដោយមកពីការតាំងទីលំនៅរបស់ប្រជាជនកាន់តែច្រើនឡើងៗ នៅក្នុងទីក្រុងភ្នំពេញ។ ពិនិត្យអំពីចំនួនប្រជាពលរដ្ឋដែលរស់នៅទីក្រុងភ្នំពេញ** ... ប្រមាណជាជាង ១០% នៃប្រជាជននៅទូទាំងប្រទេស (ហើយ)ផ្ទៃដីមានត្រឹមតែប្រមាណជាដិត ៧០០ គីឡូម៉ែត្រការ៉ ... ឯចំពោះផ្ទៃដីលើសពី ៩៥% ទៀត ទទួលប្រមាណជា ៩០% នៃប្រជាជន។ ដូច្នេះ សម្ពាធសម្រាប់ទីក្រុងភ្នំពេញ ទាមទារឲ្យមានការដោះស្រាយបញ្ហាជាច្រើន ក្នុងនោះបញ្ហាលំនៅដ្ឋាន ក៏ដូចជាការកកស្ទះចរាចរ បណ្តាលពីការកើនឡើងនូវចំនួនរថយន្ត និងម៉ូតូ មធ្យោបាយធ្វើដំណើររបស់ប្រជាពលរដ្ឋរបស់យើង។ ... បើសិនជាប្រទេសជាតិ បន្តមានកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ ចំនួនមធ្យោបាយរបស់ប្រជាជន ជារថយន្ត ជាម៉ូតូ នឹងមិនមានការថយចុះទេ មានតែការកើនឡើង ...។

៤. គ្រប់ទីក្រុង ត្រូវតែស្អាត

ពិធីបើកការដ្ឋានសាងសង់ស្ពានជ្រោយចង្វារ ទី ០២, ថ្ងៃទី ០២ វិច្ឆិកា ២០១១

... ស្ថានភាពទីក្រុងភ្នំពេញរបស់យើង បានឈានពីដំណាក់កាលមួយទៅដំណាក់កាលមួយ ... **សួនច្បារនានាចេះតែរីកចម្រើនធំទៅៗ ផ្តល់លក្ខណៈឲ្យប្រជាជនបានហាត់ប្រាណ កុមារដើរលេងកំសាន្តពេលល្ងាចៗ** ... ទីក្រុង ត្រូវតែស្អាត មិនមែនដោយសារតែតម្រូវការធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំអាស៊ានទេ ... **សុំថាធ្វើយ៉ាងណាឲ្យទីក្រុងស្អាត ដូចក្រសួងទេសចរណ៍គេយោសនា ទីក្រុងស្អាតរមណីយ៍ដ្ឋានស្អាត សេវាល្អ ហើយយើងក៏កំពុងបង្កើតគណៈកម្មការប្រឡងប្រណាំងទីក្រុងស្អាត ... ប្រឹងប្រែងធ្វើឲ្យទីក្រុង ក្លាយទៅជាទីក្រុងល្អ មានការអភិវឌ្ឍ មិនមែនតែទីក្រុងភ្នំពេញមួយទេ គឺគ្រប់ទីក្រុង ទីប្រជុំជនទាំងអស់** ...។

៥. ភ្នំពេញក្រុងសន្តិភាព ក្រុងលំហាត់ប្រាណ និងបង្កើតមិត្តភក្តិ

ពិធីបើកការដ្ឋានស្ថាបនា ទំនប់ការពារទឹកជំនន់និង កែលម្អប្រព័ន្ធប្រឡាយ/លូ ជំហានទី២, រាជធានីភ្នំពេញ, ថ្ងៃ ១៣ ធ្នូ ២០០៧

... ប៉ុន្មានឆ្នាំចុងក្រោយ មានការផ្លាស់ប្តូរឥរិយាបថច្រើនណាស់ ... កាលពីមុនផឹកដូងហើយយកសម្បកទៅបោះចោលក្នុងលូ ... ឥឡូវមានការចូលរួម ទោះបីមិនទាន់គ្រប់ ... សូមអំពាវនាវប្រជាជនចូលរួមអនាម័យទីក្រុង ... **ភ្នំពេញក្នុងសន្តិភាព សុវត្ថិភាព សោភ័ណ្ឌភាព និងវឌ្ឍនភាព រួមគ្នាកសាងទីក្រុងជាតំបន់សន្តិភាពពិតប្រាកដមួយ ហើយចលនាហាត់ប្រាណឲ្យបានគ្រប់គ្នា ដើម្បីកាត់បន្ថយជំងឺទឹកនោមផ្អែម លើសឈាម ទំនាក់ទំនងគ្នារកស៊ី បង្កើតបានជាមិត្តភក្តិស្អីៗ ទៅ វាកាន់តែសប្បាយរីករាយ** ... នេះជា ចំណុចដែលយើងរួមគ្នា ធ្វើអោយទីក្រុងមានសុវត្ថិភាព សុខដុមរមនា ...។

៦. ផលវិបាកនៃការមិនមានប័ណ្ណកម្មសិទ្ធិដីធ្លី

ចែកសញ្ញាបត្រជូន និស្សិតសាកលវិទ្យាល័យ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ០១ សីហា ២០១២

... ក្រុមគ្រួសាររបស់ខ្ញុំ ដីតែមួយផ្នែកទេ ដែលមានប្លង់ ហើយដែលរាជការជាន់នោះទារពន្ធ តែដីមួយផ្នែកទៀតមិនស្របច្បាប់ទេ ទោះបីថាតាំងពីខ្មោចដីទួតដីតាខ្ញុំ គាត់រុករានដីស្រែនៅតំបន់ទួលសំបួរ ទាំងស្រែប្រាំង ទាំងស្រែវស្សា អត់មានបង់ពន្ធទេ បង់ពន្ធតែដីនៅតាមមាត់ទន្លេទេ។ បើគេអត់យកពន្ធ មានន័យថាអត់ប្លង់។ **ប្រជាពលរដ្ឋរបស់យើងច្រើនណាស់ ដែលគ្មានប្លង់ដី បូកបន្ថែមដោយសង្គ្រាមឆ្នាំ ១៩៧០ ប្រជាពលរដ្ឋត្រូវរត់ចេញពីតំបន់ដែលខ្លួនកាន់កាប់ដី ហើយមកដល់ជំនាន់ ប៉ុល ពត ត្រូវដកហូតកម្មសិទ្ធិទាំងអស់។** ក្រោយមក ឆ្នាំ ១៩៧៩ ... ចង់ឲ្យប្រជាពលរដ្ឋទៅរុករានដីថ្មី ត្រូវផ្តល់លុយបន្ថែម ទើបគាត់ទៅរុករានដីថ្មី។ កាលហ្នឹងក្រសួងផែនការជាអ្នករៀបចំប្រាក់ឲ្យពួកគាត់។ ក្រោយមកទៀត**ក្នុងជំនាន់អតីតរដ្ឋកម្ពុជា យើងបានប្រឹងប្រែងចេញប័ណ្ណកម្មសិទ្ធិ មានបង្ហាន់ដៃផង ប័ណ្ណស្លាបមាន់ផង នៅតំបន់មួយចំនួន តែនៅតំបន់មួយទៀត មិនទាន់មានកម្មសិទ្ធិទេ។ ការកាន់កាប់ដីធ្លីមិនច្បាស់លាស់បែបនេះ បង្ករនូវផលប៉ះពាល់ ដែលគាត់មិនអាចអភិវឌ្ឍន៍ទៅបាន ដោយគ្មានលំនឹង ថា តើដីនេះជាដីរបស់យើង ឬ ថ្ងៃក្រោយរដ្ឋនឹងយកវិញ ឬ មួយផ្នែកទៀត ដោយសារតែគាត់មិនមានកម្មសិទ្ធិ បែបនេះ គាត់មិនអាចចាត់ចែងបានក្នុងការយកទៅបញ្ចាំ ឬក៏ផ្ទេរឲ្យកូនចៅ** ...។

៧. មិនថានិន្នាការនយោបាយណាមួយទេ ត្រូវទទួលបានការវាស់វែងដូចគ្នា

ពិធីកាត់ខណ្ឌសីមាព្រះវិហារ វត្តតាំងក្រសៅ ខេត្ត កំពង់ធំ, ថ្ងៃ ០៣ មិថុនា ២០១៣

... មានមោទនភាពបំផុត (ដែល)បណ្តាំត្រូវបានអនុវត្តន៍ ដោយមន្ត្រីថ្នាក់ក្រោមជាតិ មន្ត្រីសុរិយោដី និងយុវជនស្មគ្រចិត្ត ត្រង់ថា អ្នកណាក៏ដោយ ឱ្យតែមានដីត្រូវវាស់ យើងវាស់ឱ្យដូចៗគ្នា។ ... **អត់មានកើតឡើងនូវបញ្ហានិយមគណបក្សនយោបាយទេ ទោះបីជាគាត់ស្រឡាញ់បក្សណាជាសិទ្ធិរបស់គាត់ ប៉ុន្តែរឿងវាស់ដីឱ្យគាត់ គឺជាកាតព្វកិច្ចដែលយើងត្រូវធ្វើ** ... ល្អណាស់ដែលមិនបានកើតឡើងនូវបញ្ហារើសអើង ក្នុងការវាស់វែងដីធ្លី តាមនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី ...។

៨. រដ្ឋមានសិទ្ធិកាត់ដីពាក់ព័ន្ធក្រុមហ៊ុន គំរបព្រៃ ជម្រកសត្ត

ពិធីចែកប័ណ្ណកម្មសិទ្ធិដីនៅឃុំលាជ និងឃុំស្វាយត្រងិល ខេត្តពោធិសាត់, ០១ តុលា ២០១២

... ដោយសារតែមានភាពមិនច្បាស់លាស់នៅក្នុងតំបន់ ៣ ចំណុច ដែលខ្ញុំសូមបញ្ជាក់ឡើងវិញ ទី ១ ព្រៃសម្បទាន ទី ២ ដីសម្បទានសង្គមកិច្ច ហើយទី ៣ ដីរដ្ឋ ដែលដោយឡែកនៅក្នុងទីនេះ មានដីរដ្ឋរហូតទៅដល់ពីរប្រភេទគឺ ទី ១ គម្របព្រៃឈើឆ្នាំ ២០០២ ឯទី ២ គឺដែនជម្រកសត្វព្រៃសំកុស។ បញ្ហាស្ថិតនៅត្រង់ណា? ដូចជាដែនជម្រកសត្វព្រៃ និងដីសម្បទាន(នេះ) យើងនាំគ្នាគូសផែនទីនៅឯទីក្រុងភ្នំពេញ តែយើងមិនបានសិក្សាថា ប្រជាពលរដ្ឋរស់នៅក្នុងតំបន់នេះឬទេ។ **អញ្ចឹងបានជាអោយបទបញ្ជាកាត់ចេញពីដែនជម្រកសត្វព្រៃសំកុសនេះដល់ទៅ ១៤.៩៨១ ហិកតា ... យើងមានលទ្ធភាពដោះស្រាយ ទោះបីដីក្រុមហ៊ុន ទោះបីដីគម្របព្រៃឈើ ទោះបីដីត្រូវការពារ តែរដ្ឋមានសិទ្ធិដើម្បីនឹងដោះស្រាយ (លើភាពពាក់ព័ន្ធគ្នា ហើយ) កាត់អោយប្រជាពលរដ្ឋ។** អ្វីដែលយើងគ្មានសិទ្ធិ គឺជម្លោះម្តាយ និងកូន រឿងចេញប័ណ្ណ (...) ទុកអោយគាត់សម្របសម្រួលគ្នា ...។

៩. និរាករណ៍ព្រះរាជក្រឹត្យ ស្តីពី ការបង្កើតតំបន់សហគ្រាសសេរីនៅកំពង់ឆ្នាំង

ពិធីចែកប័ណ្ណកម្មសិទ្ធិជូនប្រជាជន ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង,
ថ្ងៃ ទី ២៧ មិថុនា ២០១១

... ខ្ញុំបានឃើញរបាយការណ៍របស់ឯកឧត្តម អ៊ឹម ឈុនលឹម ... ហើយក៏រកឃើញព្រះរាជក្រិត្យមួយនេះ ស្តីពីការបង្កើតតំបន់សហគ្រាសសេរី។ នៅក្នុងព្រះរាជក្រិត្យមានសរសេរ *"ត្រូវបានបង្កើតតំបន់សហគ្រាសសេរីមួយ ស្ថិតនៅជាប់នឹងព្រលានយន្តហោះក្នុងខេត្តកំពង់ឆ្នាំង ... ដ មាត្រា ៣ ទំហំទីតាំង បរិវេណ និងផ្នែកក្ឍានឹងត្រូវកំណត់ក្នុងអនុក្រឹត្យ ដោយមានភ្ជាប់ផែនទីជាកំណត់..."*។ ខ្ញុំ និងសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ជាអ្នកស៊ីញ្ជ៉ូអម ហើយព្រះករុណាព្រះបិតាឡាយព្រះហស្តនៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៦។ តែរកអនុក្រឹត្យមិនឃើញ។ **រឿងចាប់ផ្តើមពីទីណា ត្រូវចេញពីទីហ្នឹងវិញ។ ការស្នើរៀបចំការប្រើប្រាស់ដីធ្លីឡើងវិញ មិនអាចធ្វើទៅបានទេ ដរាបណាយើងមិនទាន់និរាករណ៍ចោលនូវព្រះរាជក្រឹត្យនេះ។ បើរកអនុក្រឹត្យមិនឃើញមានន័យថារកមិនឃើញទំហំដីនោះដែរ។ យ៉ាងណាក្តី វាអត់ចោទជាបញ្ហាទេ ទោះរកឃើញ ឬមិនឃើញអនុក្រឹត្យនោះ។** ... និរាករណ៍ព្រះរាជក្រឹត្យ នសរកត ១២៩៦/៩១ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតតំបន់សហគ្រាសសេរី ហើយបទបញ្ញត្តិទាំងឡាយ ដែលមានខ្លឹមសារផ្ទុយពីព្រះរាជក្រឹត្យនេះ ក៏ត្រូវនិរាករណ៍ ...។

១០. ការផ្តល់ដីសម្បទានសេដ្ឋកិច្ចមិនអាក្រក់ តែការអនុវត្តរបស់យើងមិនច្បាស់

ពិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ជូន ប្រជាពលរដ្ឋ ស្រុកឌ៉ាល់ ខេត្តកំពង់ស្ពឺ,
១៤ វិច្ឆិកា ២០១២

... ប្រទេសយើងនឹងមានស្ថេរភាពយូរអង្វែង អត់មានអស្ថេរភាពសង្គមកើតឡើងពីបញ្ហាដីធ្លីទេ។ នៅកម្ពុជាមិនមានបដិវត្តន៍ដីធ្លីទេ។ ព្រោះអ្វី? បក្សកាន់អំណាចបានធ្វើបដិវត្តន៍ដីធ្លីរួចហើយ លើកលែងតែពួកអ្នកធ្វើបដិរូបដីធ្លី ដូចជា **ប៉ុល ពត** អាហ្នឹងទើបយើងបាត់បង់សិទ្ធិ សុវត្ថិភាពនៃការកាន់កាប់ដីធ្លីសម្រាប់ប្រជាពលរដ្ឋយើង។ **... ចាប់ផ្តើមពីតំបន់ដីព្រៃសម្បទាន ដីសម្បទានសេដ្ឋកិច្ច**

និងដីកាន់កាប់មិនទាន់ស្របច្បាប់ ឥឡូវនេះ យើងបានធ្វើមួយចំនួនធំហើយ។ យើងផ្តល់អាទិភាពធ្វើនៅតំបន់ ដែលមានការទាក់ទងនឹងក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចក្នុងស្ថានភាពឈ្នះ-ឈ្នះ។ កន្លងទៅ ការផ្តល់ដីសម្បទានសេដ្ឋកិច្ចមិនអាក្រក់ទេ ក៏ប៉ុន្តែ ស្ថិតនៅត្រង់ការអនុវត្តរបស់យើងវាអត់ច្បាស់ ថាតើតំបន់ណាជាតំបន់ដីរបស់ប្រជាពលរដ្ឋ តំបន់ណាជាតំបន់ដីដែលឱ្យក្រុមហ៊ុន ...។

១១. កាត់ដីចេញពីចំការកៅស៊ូជូនប្រជាពលរដ្ឋ

ចែកប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាជន ឃុំព្រៃកកក់, ស្រុកស្ទឹងត្រង់, ខេត្តកំពង់ចាម, ១៣ តុលា ឆ្នាំ ២០១២...

... ប្រហែលជាខែ មេសា ឬ ឧសភា មានការរាលកៃទូរស័ព្ទ ធ្វើឱ្យខ្ញុំបានដឹង តាមរយៈការសន្ទនាគ្នារវាងកូនខ្ញុំ ដែលចុះជួយការងារនៅឃុំព្រៃកកក់ ជាមួយមេឃុំ និងក្រុមការងារ ... សួរមកអភិបាលខេត្ត គាត់ឆ្លើយថា ការងារអ្វីៗ (ដែលថ្នាក់កណ្តាល)មកធ្វើ មិនបានពិភាក្សាជាមួយខេត្តទេ។ ខ្ញុំបានចាត់ឱ្យឧបនាយករដ្ឋមន្ត្រី ឯកឧត្តម **ប៊ិន ឈិន** មកពិនិត្យ ... ចៅហ្វាយខេត្តប្រាប់ខ្ញុំ តាម Video Conference ថា **ឃុំរបស់សម្តេចគេយកដាក់ដេញថ្លៃទៅហើយ** ... ថ្ងៃនេះ ខ្ញុំសូមទោសចំពោះការដែលធ្វើឱ្យបងប្អូនមានការព្រួយបារម្ភតាំងពីដើមឆ្នាំ ២០០៨។ **សូមកុំបន្ទោសក្រុមហ៊ុន ព្រោះបើក្រុមហ៊ុនមិនចូលដេញថ្លៃ ក៏មានអ្នកផ្សេងដេញថ្លៃយកដែរ។ ... ទុកឱ្យខ្ញុំទទួលខុស។ ខ្ញុំសូមកែប្រែដោយកាត់ដីនេះចេញ (ពីចំការកៅស៊ូ) និងប្រគល់ឱ្យប្រជាពលរដ្ឋវិញ។ សូមអ្នកនយោបាយកុំលេងល្បិចមកយោសនាថា ជិតបោះឆ្នោតបានមកដោះស្រាយឱ្យសោះ យើងបានប្រគល់ដីតាំងពីឆ្នាំ ២០០៨ គឺមុនបោះឆ្នោតមកម្ល៉េះ សូមអញ្ជើញមើលប័ណ្ណ ...** ។

១២. ផ្អាកការផ្តល់ដីសម្បទានរយៈពេលវែង

ពិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ ២០០៩-២០១៣, ១៤ មិថុនា ២០១២

... កាលពីថ្ងៃទី ០៧ ខែ កក្កដា ខ្ញុំបានចេញបទបញ្ជាផ្អាកផ្តល់ដីសម្បទាន។ ការផ្អាកនេះ នឹងត្រូវធ្វើរយៈពេលវែង។ បើធ្វើ(ការងារវាស់វែង)នេះមិនទាន់ជាប់

ស្រេចទេ គឺកុំអាលផ្តល់អាផ្សេងទៀត។ ខ្ញុំសូមលើកជាឧទាហរណ៍សំអាង ស្តីពីការអនុវត្តដីសម្បទាន ... នេះជា ស.ជ.ណ ដែលមានចំណាររបស់ខ្ញុំ ... ក្នុងសំណើនេះ ក្រុមហ៊ុនបានស្នើដីដល់ទៅ ១០០១៥ (មួយម៉ឺនដប់ប្រាំ) ហិកតា ប៉ុន្តែបន្ទាប់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះទៅពិនិត្យ យើងអាចផ្តល់បានត្រឹមតែ ៧៨៦៦ ហិកតា តែប៉ុណ្ណោះ ដោយកាត់ធ្វៀលដីប្រជាពលរដ្ឋ ... ក្នុងការកំណត់របស់នាយករដ្ឋមន្ត្រី ដែលបានចេញ ស.ជ.ណ. បានបញ្ជាក់ ... *"ក្រៅពីការឯកភាពផ្តល់ដីសម្បទានសេដ្ឋកិច្ច ចំនួន ៧៨៦៦ ហិកតានេះ កិច្ចការដែលត្រូវបន្ត ក្រុមហ៊ុនត្រូវសហការណ៍ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមត្ថកិច្ចជំនាញ ចុះកំណត់ចំណុចគោលព្រំដី និងកាត់ចេញផ្នែដីពាក់ព័ន្ធនានាបន្ថែមទៀត តាមស្ថានភាពជាក់ស្តែង"* ... កន្លែងខ្លះ សម្រុកទៅចំតែកន្លែងប្រជាជន ខ្លះទៀតទៅចំតែកន្លែងព្រៃឈើធំ។ ត្រូវចុះទៅពិនិត្យ បើពិនិត្យទៅប៉ះពាល់ដីប្រជាពលរដ្ឋ ត្រូវកាត់ថែមទៅ។ ប៉ះនឹងព្រៃស្រោង ដែលត្រូវការពារ (ក็)កាត់ទៀត។ ឥឡូវក្នុង ៧៨៦៦ ហិកតានេះ កាត់ចុះកាត់ឡើងនៅសល់ ៤០០០ ហិកតា។ ក្រុមហ៊ុនធ្វើ ឬមិនធ្វើ ? បើមិនធ្វើ យកវិញ ...។

១៣. ដកហូតដីពីក្រុមហ៊ុន សម្រាប់គោលដៅដីសម្បទានសង្គមកិច្ច

> សន្និសីទ "ទស្សនៈវិស័យកម្ពុជា ឆ្នាំ២០១៣" ភាពជាដៃគូរវាង CDRI និង ANZ ក្រោមមូលបទ "ធានាអនាគតកម្ពុជា៖ ស្បៀង, ថាមពល និងធនធានធម្មជាតិ", ភ្នំពេញ, ២០ កុម្ភៈ ២០១៣

... កន្លងទៅ **យើងបានដកហូតដីពីក្រុមហ៊ុន ដែលអនុវត្តមិនបានត្រឹមត្រូវ ហើយបានប្រគល់ទៅឱ្យក្រសួងរៀបចំដែនដីនគរូបនីយ៍កម្ម និងខេត្តជាអ្នកគ្រប់គ្រង ដោយត្រូវរក្សាទុកសម្រាប់បម្រើឱ្យគោលដៅការផ្តល់ដីសម្បទានសង្គមកិច្ចដល់ប្រជាជនដែលកំពុងខ្វះដី។ យើងមិនទាន់ចប់ត្រឹមការផ្តល់កម្មសិទ្ធិដីសម្បទាន ១.៨០០.០០០ ហិកតានេះទេ** ... យើងត្រូវបែងចែកដីដែលមាននៅក្នុងប្រទេស សម្រាប់ប្រជាជនដែលខ្វះខាតដី ក្នុងក្របខណ្ឌនៃការដោះស្រាយដីធ្លីតាមរយៈសម្បទានសង្គមកិច្ច ...។

១៤. វាស់ដីធ្លីហើយ ចាំគូរផែនទីគម្របព្រៃឈើថ្មី

ពិធីចែកប័ណ្ណកម្មសិទ្ធិជូនប្រជាជន, ស្រុករមាសហែក ខេត្តស្វាយរៀង,
០៥ តុលា ឆ្នាំ ២០១២

... ខ្ញុំពិតជាមានការលំបាកចិត្តយ៉ាងខ្លាំង ក្នុងរយៈពេលមុននេះ ដោយសារតែទិដ្ឋភាពមួយចំនួន ដែលវាមិនគួរកើតក្នុងទឹកដីរបស់យើង ... នោះគឺ**ការធ្វេសប្រហែសរបស់យើង ពិសេសពាក់ព័ន្ធជាមួយអ្វីដែលហៅថា គម្របព្រៃឈើ ឆ្នាំ ២០១២ ដែលវាជាឧបសគ្គរារាំង នៃបញ្ហាដោះស្រាយដីធ្លី**។ ដោយហេតុនេះ បានជាយើងចាប់យកជំហានចាំបាច់ ផ្អាកជាបណ្តោះអាសន្នផែនទីគម្របព្រៃឈើឆ្នាំ ២០១២ ព្រោះបើប្រើតទៅទៀត វានៅតែមានបញ្ហា ... **ចាំវាស់រែងដីធ្លីរួចហើយ ចាំគូរផែនទីឡើងវិញ ជាក់ជាគម្របព្រៃឈើ បើមិនទាន់វាស់ចប់ទេ ក៏មិនចាំបាច់ទេ, វាស់ចប់អា ០១ លាន ០៨ សែន ហិកតា ហ្នឹងហើយ ត្រូវត្រៀមទុកប៉ុន្មានសិបម៉ឺនហិកតាទៀត ដែលបានផ្តល់ជាបណ្តើរៗ ទៅឱ្យក្រសួងរៀបចំដែនដីនគរូបនីយកម្មគ្រប់គ្រង ...**។

រ៉ែ និងថាមពល

១	បង្កើតក្រសួងរ៉ែ និងថាមពល ក្នុងអាណត្តិទី ៤	១៨៩
២	មិនប៉ះពាល់រ៉ែទីតាញ៉ូម នៅតំបន់ជីផាត	១៨៩
៣	សិក្សាអោយច្បាស់កន្លែងណាអាច និងមិនអាចបូមខ្សាច់	១៩០
៤	រៀបចំផែនការមេ យកទន្លេចិញ្ចឹមទន្លេ	១៩០
៥	ទម្លាយទន្លេបាសាក់ បូមខ្សាច់សំណង់ បូមដីសម្រួលចរាចរផ្លូវទឹកផង	១៩១
៦	តំបន់ បរិមាណ ប្រភពអគ្គិសនីនៅកម្ពុជា មុនឆ្នាំ ១៩៧៥ បច្ចុប្បន្ន	១៩១
៧	សាកលវិទ្យាល័យបាត់ដំបង មានជំនាញវិស្វកម្មនុយក្លេអ៊ែរ	១៩២
៨	កម្ពុជាមិនទាន់ឈានទៅថាមពលបរមាណូទេ	១៩២
៩	១៧ ទីតាំងអាចផលិតថាមពលវារីអគ្គីសនី, ៦ ដំណើរការគំរោងហើយ	១៩៣
១០	តម្លៃប្រើប្រាស់អគ្គិសនីនឹងចុះមួយកម្រិតទៀត	១៩៣
១១	ធ្វើអោយកម្មករ/ការិនី ទទួលផលប្រយោជន៍ពីការធ្លាក់ថ្លៃអគ្គិសនី	១៩៤
១២	កម្ពុជា មិនទាន់ធ្វើអាជីវកម្មប្រេង ឧស្ម័ន ធ្យូងថ្ម និងរ៉ែគ្រប់ប្រភេទទេ	១៩៤

១. បង្កើតក្រសួងវ៉ែ និងថាមពល ក្នុងអាណត្តិទី ៤

ពិធីចែកសញ្ញាបត្រ និស្សិត គរុនិស្សិត នៃវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស, ថ្ងៃ ០៧ វិច្ឆិកា ២០១៦

... ដល់អាណត្តិទី ៤ ពិនិត្យឃើញថា វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានជាតម្រូវការសំខាន់ណាស់។ កាលបោះឆ្នោត ឆ្នាំ ២០០៣ ជាប់គាំងមួយឆ្នាំ រហូតដល់ឆ្នាំ ២០០៤ ទើបអាចបង្កើត(រដ្ឋាភិបាល)បាន ដោយសារពេលនោះគណបក្សចាញ់ឆ្នោតចាប់គណបក្សឈ្នះឆ្នោតធ្វើជាចំណាប់ខ្មាំង ព្រោះតែប្រព័ន្ធ(សមាមាត្រ) ២ ភាគ ៣ ... **ពេលបង្កើតរាជរដ្ឋាភិបាល ... យើញថា ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល គឺជាក្រសួងមួយធំពេក យើងក៏ចាប់ផ្តើមរៀបចំអោយមានការកែទម្រង់ក្បាលម៉ាស៊ីនមួយទៀត តាមរយៈនៃការបង្កើតអោយមានក្រសួងរ៉ែ និងថាមពល ... ដល់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល កាលពីមុនហៅថា ក្រសួងឧស្សាហកម្ម និងសិប្បកម្មវិញ។ ខ្ញុំនិយាយ ដើម្បីអោយអ្នកទាំងអស់គ្នានៅទីនេះបានដឹងថា ការវិវត្តនៃសភាពការណ៍វាមិននៅទ្រឹងទេ ...**។

២. មិនប៉ះពាល់ដ៏ទីតាញ៉ូម នៅតំបន់ជីផាត

វេទិកាស្តីពីការការពារ និងអភិរក្សធនធានធម្មជាតិ, រ៉ាមានសន្តិភាព, ថ្ងៃទី ២២ សីហា ២០១៦

... តាមការសិក្សានៅតំបន់ជីផាតខាងលើ **ទីតាញ៉ូមនៅក្រោមដីមានតម្លៃប្រមាណ ២២ ពាន់លានដុល្លារ។ សិក្សារួចហើយៗ ក៏មានសំណើសុំឲ្យមានការវិនិយោគ។ ប៉ុន្តែ យើងបានសង្កេតឃើញថា ដើម្បីវិនិយោគយកទីតាញ៉ូម ២២ ពាន់លានដុល្លារនៅក្រោមដីនេះ វាត្រូវអស់នូវព្រៃដែលជាជម្រកសត្វដ៏រីតម្តង។ អញ្ចឹងទេ ខ្ញុំព្រះករុណាខ្ញុំ បានចារថារក្សាទុក មិនឲ្យមានការវិនិយោគទេ។ ក្នុងជំនាន់ក្រោយ គេគិតយ៉ាងណាជារឿងរបស់គេ** ... បើសិនជាយើងហ៊ានធ្វើទីតាញ៉ូម យើងដកគម្របព្រៃឈើ ដែលសុទ្ធតែឈើធំៗមិនតិចជាង ២ ម៉ឺនហិកតា ...ហើយមិនប្រាកដទេ ដែលហៅថាការសិក្សា គឺគ្រាន់តែទាយ។ ប៉ុន្តែសម័យឥឡូវ គេអាចដឹងបាន។ ពេលដែលយើងធ្វើតំបន់ហ្នឹងគ្រឹប ទឹកសមុទ្ររបស់យើងលែងទៅជា

ទឹកសមុទ្រខៀវហើយ ទៅជាសមុទ្រលឿង ... អញ្ចឹងរឿងនេះ សុខចិត្តទុក នៅក្នុងដី ៥០០ ឆ្នាំទៀត ឬ ៣០០ ឆ្នាំទៀត អ្នកក្រោយគេធ្វើយ៉ាងម៉េចទៀត ... ពេលខ្លះតម្រូវឲ្យមានការគិតពីការអភិវឌ្ឍ និងការអភិរក្ស ...។

៣. សិក្សាអោយច្បាស់កន្លែងណាអាច និងមិនអាចបូមខ្សាច់

ពិធីផ្សព្វផ្សាយការបញ្ជូលឆ្នេរសមុទ្រកម្ពុជា ជាសមាជិកឆ្នេរស្អាតបំផុតលើសកលលោក, ខេត្តព្រះសីហនុ, ថ្ងៃទី ១១ កក្កដា ២០១១

... ទាក់ទងជាមួយនឹងបញ្ហាការបូមខ្សាច់ រឿងបូមខ្សាច់នេះ អន្តរាយណាស់។ ខ្ញុំរកការសិក្សាមិនបាន។ ពីរឆ្នាំមុនខ្ញុំបានចុះហត្ថលេខាលុបចោលទាំងអស់ នូវការបូមខ្សាច់ ទាំងទឹកសាប និងទឹកសមុទ្រ ដោយវាមានរឿងច្រើនពេក ហើយសិក្សាមិនអស់។ បន្ទាប់ទៅទើបមានការអនុញ្ញាតឱ្យមានការសិក្សា តើកន្លែងណាគួរធ្វើ កន្លែងណាមិនគួរធ្វើ ? បញ្ហានេះគ្មានអ្នកណាមួយផ្តល់ចម្លើយឱ្យខ្ញុំបានទេ ក្រសួងបរិស្ថានក៏អត់ ក្រសួងធនធានទឹកក៏អត់ ក្រសួងឧស្សាហកម្មក៏អត់។ ឧទាហរណ៍ៈ តើការបូមខ្សាច់នៅកណ្តាល(ទន្លេ ឬសមុទ្រ) ក្រៅពីបំផ្លាញនៅតំបន់ដែលបូមនោះ ហើយដូចជា ផ្ការ៉ូ សារាយស្ពីឯ នៅហ្នឹង នៅមានរឿងមួយទៀត ដែលឆ្លើយមិនទាន់រួច តើជំរាលខ្សាច់វាទាញទៅទេ ? ... បើសិនជាវាជ្រាលកោះរបស់យើង និងឆ្នេររបស់យើងទាំងអស់ និងបំផ្លាញចោលអស់ហើយ ...។

៤. រៀបចំផែនការមេ យកទន្លេចិញ្ចឹមទន្លេ

ពិធីសម្ពោធកំពង់ផែស្វយ័តភ្នំពេញ, ស្រុកកៀនស្វាយ ខេត្តកណ្តាល,
ថ្ងៃទី ២២ មករា ២០១៣

... ត្រូវពិនិត្យ រៀបចំ យកទន្លេចិញ្ចឹមទន្លេទើបបាន ហើយគិតទន្លេទាំងមូលទើបបាន បើមិនដូច្នោះទេ នៅប្រទេសកម្ពុជាយើងបាក់ច្រាំងខាងណោះ មកដុះខាងនេះ បាក់ច្រាំងខាងនេះ ទៅដុះខាងណោះ ... អញ្ចឹង បើសិនជាយើងមិនគិតពីស្ថានភាពហ្នឹងទេ គឺមិនបានទេ ឱ្យក្រុមហ៊ុនបូមខ្សាច់ ថាឲ្យជួយបូមខ្សាច់ គាត់បូមតែអាកន្លែងណាដែលមានខ្សាច់សសាងសង់បាន ... **យើងមានតម្រូវការរៀបចំផែនការមេមួយ ហើយរៀបចំនូវសកម្មភាពទ្រទ្រង់ យកទន្លេចិញ្ចឹមទន្លេ។**

ខ្សាច់របស់យើងអាចនឹងនាំចេញ ប៉ុន្តែយកអាលុយពីការបូមខ្សាច់នេះ មកបូមនៅកន្លែងណាដែលវាគោកវាក់ ហើយបំពេញទៅកន្លែងណាដែលវាបាក់ យើងប្រើវិធីសាស្ត្រនេះ ... ត្រូវតែរៀបចំឱ្យបានហ្មត់ចត់ជាមួយក្រសួងធនធានទឹក និងគណៈកម្មការទន្លេមេគង្គ ដើម្បីឱ្យវាដើរស្របគ្នា បើមិនអញ្ចឹងយើងគិតតែពីគន្លងនាវា ក៏ប៉ុន្តែយើងអត់បានគិតអំពីផលប៉ះពាល់ នៃការផ្លាស់ប្តូរចរន្តទឹកក្នុងដងទន្លេមេគង្គរបស់យើងទេ ...។

៥. ត្រូវទម្លាយទន្លេបាសាក់ បូមខ្សាច់សំណង់ផង បូមដីសម្រួលចរាចរផ្លូវទឹកផង

វេទិកាស្តីពីការការពារ និងអភិរក្សធនធានធម្មជាតិ, រ៉ាមានសន្តិភាព,
ថ្ងៃទី ២២ សីហា ២០១៦

... ខ្ញុំចោទជាសំណួរថា តើគេបានសិក្សាហើយឬនៅ អំពីការបូមខ្សាច់ក្នុងសមុទ្រ? តើពេលដែលយើងបូមទៅ វាមានទាញយក(ខ្សាច់) ពីតំបន់ឆ្នេររបស់យើងទេ? ព្រោះលំនឹងដីវ៉ៃចម្រុះនោះ វាមានឆ្នេររបស់វានោះតៗ បានទៅទឹកជ្រៅ ... ទើបតែនិយាយអាហ្នឹងបាន ២ ខែ ស្រាប់តែមានសំណើមួយសូមបូម ៦ លានម៉ែត្រគូប។ គ្រាន់តែមើលសំណើហ្នឹង ខ្ញុំថា សូមអញ្ជើញយកទៅវិញចុះ (គេ)ថាទុកឲ្យសម្តេចពិចារណា ... ឥឡូវទន្លេបាសាក់ងាប់បាត់ទៅហើយ។ ត្រូវទម្លាយទន្លេបាសាក់ឡើងវិញ។ ប៉ុន្តែត្រូវធ្វើយ៉ាងម៉េចបូមខ្សាច់សម្រាប់សំណង់ផង និងបូមយកដី(ដុះ)ដើម្បីចរាចរណ៍ផ្លូវទឹកឡើងវិញ។ នៅតាមទន្លេរបស់យើងឡើងទៅលើ(ដុះ)សុទ្ធតែខ្សាច់ ដែលរំខានទៅដល់ចរាចរផ្លូវទឹក បន្ថែមទៅដោយចរន្តទឹកធ្វើអោយ(សណ្ឋានដី)ដុះខាងណោះ បាក់ខាងណោះ ... ឥឡូវសាកប្រកាសថ្ងៃនេះថា ឈប់ឲ្យបូមខ្សាច់ ស្អែកខ្សាច់ឡើងថ្លៃ សំណង់ស្រែកពេញប្រទេស។ អញ្ចឹង ត្រូវប្តឹងថ្លែង កុំឆ្វេងពេក កុំស្តាំពេក ...។

៦. តំបន់ បរិមាណ និងប្រភពផ្គត់ផ្គង់អគ្គិសនីនៅកម្ពុជាមុនឆ្នាំ ១៩៧៥ និងបច្ចុប្បន្ន

ពិធីបិទស្នឹងសាងសង់រ៉ារីអគ្គិសនីស្ទឹងតាតៃ, ថ្ងៃទី ១២ មករា ឆ្នាំ ២០១១

... (១)តំបន់ផ្គត់ផ្គង់អគ្គិសនីកាលពីមុនឆ្នាំ ១៩៧៥ មាន ១១ កន្លែង (ភ្នំពេញ, ក្រុងព្រះសីហនុ, ទីរួមខេត្តកណ្តាល, កំពត, តាកែវ, ក្រចេះ, កំពង់ចាម,

ស្ទឹងត្រែង, សៀមរាប, ពោធិសាត់ និងកំពង់ឆ្នាំង)។ តំបន់ជនបទ ពុំមានភូមិណាមួយទទួលបានការផ្គត់ផ្គង់ទេ។ ឥឡូវ(គិតមកដល់ឆ្នាំ ២០១០) ទីក្រុង និងទីរួមខេត្តទាំង ២៤ មានការផ្គត់ផ្គង់អគ្គិសនីទាំងអស់ ក្នុងនោះអគ្គិសនីកម្ពុជាផ្គត់ផ្គង់ ១៥ ទីរួមខេត្ត ក្រៅពីនោះប្រគល់ឲ្យផ្នែកឯកជនគេធ្វើ។ នៅតំបន់ជនបទ(ក្នុង)ចំនួន ១៤.២១០ ភូមិទូទាំងប្រទេស បច្ចុប្បន្ននេះ មាន ៧០៦១ ភូមិ ប្រហែល ៥០% មានការផ្គត់ផ្គង់អគ្គិសនីរួចហើយ ... (២)បរិមាណអគ្គិសនីនៅទូទាំងប្រទេសមុនឆ្នាំ ១៩៧៥ មាន ២២០ លានគីឡូវ៉ុលម៉ោង ឥឡូវមាន ២.៤០០ លានគីឡូវ៉ុលម៉ោង គឺលើសពីមុន ១០ ដង ... (៣) ប្រភពផ្គត់ផ្គង់អគ្គិសនីទូទាំងប្រទេស កាលពីមុនឆ្នាំ ១៩៧៥ មានប្រហែលជា ៦០ មេហ្គាវ៉ាត់, ឥឡូវមានប្រហែល ៥៧៩ មេហ្គាវ៉ាត់ នៅចុងឆ្នាំ ២០០៩ ...។

៧. សាកលវិទ្យាល័យបាត់ដំបង មានជំនាញវិស្វកម្មនុយក្លេអ៊ែរ

ពិធីសម្ពោធអគារ និងសមិទ្ធផលនានា បាត់ដំបង, ០៩ ធ្នូ ២០១០

... **អ្វីដែលប្លែកជាងគេនៅក្នុងបណ្តាមហាវិទ្យាល័យ** និងសាកលវិទ្យាល័យនៅទូទាំងប្រទេស នៅត្រង់ថា សាកលវិទ្យាល័យបាត់ដំបង មានមុខជំនាញវិស្វកម្មនុយក្លេអ៊ែរ ហើយដែលបញ្ហានេះ វាឆ្លើយតបជាមួយនឹងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ២ ... **ដំបូង ខ្ញុំព្រះករុណាខ្ញុំ បានឲ្យដកចេញនូវការនិយាយអំពីអគ្គិសនីដើរដោយថាមពលនុយក្លេអ៊ែរ ក៏ប៉ុន្តែនៅទីចុងបំផុត ខ្ញុំព្រះករុណាខ្ញុំ ក៏បានដាក់បញ្ចូលត្រឡប់មកវិញ ដោយសារនិន្នាការកាន់តែរីកចម្រើន ហើយប្រទេសមួយចំនួនគេក៏បានដើរទៅដល់ការផលិតអគ្គិសនីដោយថាមពលនុយក្លេអ៊ែរ។ ក្នុងរយៈពេលប៉ុន្មានខែនេះ ក៏មានសំណូមពរសុំវិនិយោគលើវិស័យអគ្គិសនីដើរដោយថាមពលនុយក្លេអ៊ែរ។ យើងមិនទាន់អនុញ្ញាតទេ តែចាប់ផ្តើមការបណ្តុះបណ្តាលធនធានមនុស្ស** ...។

៨. កម្ពុជាមិនទាន់ឈានទៅថាមពលបរមាណូទេ

ពិធីសម្ពោធវ៉ារីអគ្គិសនីអាតែ (១២០ មេហ្គាវ៉ាត់) ខ្សែបញ្ជូនរួម ភ្នំពេញ-កំពង់ឆ្នាំង-ពោធិ៍សាត់-បាត់ដំបង, ថ្ងៃទី ២៧ មីនា ២០១៤

... ឥឡូវសូម្បីថ្លៃអគ្គិសនីនេះ បើយើងពិនិត្យអំពីចំនួន (បរិមាណ) អគ្គិសនីអាតែហ្នឹង ១២០ (មេហ្គាវ៉ាត់), ឬស្សីជ្រុំក្រោម ៣៣៨ (មេហ្គាវ៉ាត់), តាតែ ២៤៦ (មេហ្គាវ៉ាត់) ... ជាង ៧០០ មេហ្គាវ៉ាត់ ប៉ុន្តែ មិនមែនបានសេចក្ដីថា កន្លែងដែលអគ្គិសនីឆ្លងកាត់ គិតថាតម្លៃថោកទេ ... **លើពិភពលោក គេពិភាក្សាគ្នារហូត ពីសន្តិសុខស្បៀង សន្តិសុខថាមពល ហើយប្រទេសមួយចំនួនឈានទៅរកការប្រើប្រាស់ដោយថាមពលបរិមាណូ ប៉ុន្តែ យើងមិនឈានទៅដល់ហ្នឹងទេ** ...។

៩. ១៧ ទីតាំងអាចផលិតថាមពលវ៉ារីអគ្គីសនីនៅកម្ពុជា, ៦ ដំណើរការគំរោងហើយ

ពិធីបើកការដ្ឋានសាងសង់វ៉ារី អគ្គិសនីស្ទឹងឫស្សីជ្រុំក្រោម, ថ្ងៃទី ២៨ ធ្នូ ២០១០

... រដ្ឋបំពេញខាតឲ្យអគ្គិសនី (ដើម្បីជួយប៉ះប៉ូវមិនឲ្យមានការឡើងថ្លៃ) បើសិនអគ្គិសនីឡើងថ្លៃភ្លាម ប្រជាពលរដ្ឋដែលប្រើប្រាស់អគ្គិសនី ដែលវាកំពុងតែថ្លៃរួចស្រេចហើយៗ បែរជាឡើងថ្លៃទៀត (នឹងមានការ)រង្គោះរង្គើតែម្តង។ បណ្តារោងចក្រ សហគ្រាស ត្រូវរង្គើទាំងអស់។ នយោបាយក្នុង(ការរៀបចំ)ថ្លៃអគ្គិសនីនេះ ទាមទារឲ្យមានការគិតគូរដោយប្រុងប្រយ័ត្ន ... រដ្ឋបំពេញខាត ក្នុងឆ្នាំ ២០០៨ ដូចជាជាង ២២ លានដុល្លារ នៅទីក្រុងភ្នំពេញ ... យើងបន្តតាមវិធីផលិតអគ្គិសនីដោយប្រេងឥន្ធនៈទៀតមិនបានទេ ត្រូវតែស្វះស្វែងរកទុនដើម្បីអភិវឌ្ឍន៍វ៉ារីអគ្គិសនី(ជំនួសវិញ)។ តាមការប៉ាន់ស្មាន នៃអ្នកសិក្សាទាំងឡាយ មាន ១៧ កន្លែង ដែលអាចផលិតថាមពលវ៉ារីអគ្គិសនី មានកម្លាំងប្រមាណជា ១.០០០ មេហ្គាវ៉ាត់។ ឥឡូវនេះ យើងកំពុងតែដំណើរការ ៦ គម្រោងហើយ។

១០. តម្លៃប្រើប្រាស់អគ្គិសនីនឹងចុះមួយកម្រិតទៀត

វេទិការាជរដ្ឋាភិបាល/ផ្នែកឯកជន លើកទី ១៧, ថ្ងៃទី ៤ មីនា ឆ្នាំ ២០១៤

... បើសិនជាចាប់បង្ខំឲ្យតម្លៃអគ្គិសនី ៥០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង កុំថាឡើយដល់ទៅមានលទ្ធភាពលក់ សូម្បីតែអគ្គិសនីត្រូវប្រើក៏គ្មានដែរ។ អត់មាននរណាហ៊ានមកវិនិយោគនៅស្រុកខ្មែរទេ ... ទាមទារឲ្យមានការគិតបញ្ញាជាកញ្ចប់។ បើយើងគិតពីការប្រកួតប្រជែងជាច់ដោយឡែករបស់ខ្លួនមិនបានទេ។ បើ(ប្រើវិធី)ឧបត្ថម្ភធនដូចប្រទេសថៃជិតខាង (ក៏ឃើញថា)កំពុងតែលំបាក

ដោយការឧបត្ថម្ភធនលើការទិញស្រូវ ...។ យ៉ាងណាក្តី ថ្លៃអគ្គិសនីនៅកម្ពុជា ពុំបានឡើងដូចនៅបណ្តាប្រទេសជិតខាងយើងទេ។ ឧទាហរណ៍ៈ នៅវៀតណាម កាលពីឆ្នាំ ២០១០ តម្លៃត្រឹមតែ ៦,៩ សេនអាមេរិក/គីឡូវ៉ាត់ម៉ោង ប៉ុន្តែ បានឡើងថ្លៃជាបន្តបន្ទាប់រហូតដល់ ៩,២១ សេន អាមេរិក/គីឡូវ៉ាត់ម៉ោង នៅខែ មករា ឆ្នាំ ២០១៤។ និយាយអញ្ចឹង មិនមែនបានសេចក្តីថាដាច់ណាត់ទេ នៅពេលអនាគត កម្ពុជានឹងផលិតអគ្គិសនី ដែលមានប្រភពពីវារីអគ្គិសនីកាន់តែច្រើន ដូច្នេះ តម្លៃអគ្គិសនីនឹងអាចចុះថ្លៃមួយកម្រិតទៀត។

១១. ធ្វើអោយកម្មករ/ការិនី ទទួលផលប្រយោជន៍ពីការធ្លាក់ថ្លៃអគ្គិសនី

ពិធីសម្ពោធវារីអគ្គិសនី ស្ទឹងឫស្សីជ្រុំក្រោម, ថ្ងៃទី ១២ មករា ២០១៥

... ពិនិត្យឃើញថា កម្មករ-កម្មការិនី ពីជនបទទៅជួលផ្ទះនៅភ្នំពេញស្នាក់នៅមាន ប្រមាណជា ៣ ម៉ឺនបន្ទប់ ចំនួនកម្មករប្រហែលជា ១៥ ម៉ឺននាក់ កំពុងប្រើប្រាស់ថ្លៃអគ្គិសនី ដែលម្ចាស់ផ្ទះជួល(យក) ក្នុងចន្លោះពី ៨៥០ ទៅ ២៥០០ រៀល/គីឡូវ៉ាត់ម៉ោង (ក្នុងពេល)ដែលតម្លៃពិតប្រាកដ គឺត្រឹមតែ ៦១០ រៀល ទៅ ៧២០ និង ៨២០ រៀល ... **បើសិនជាតាមបន្ទប់មួយៗ ប្រើមិនលើសពី ៥០ គីឡូវ៉ាត់ម៉ោង/ខែ តម្លៃតែ ៦១០ រៀល ... ខ្ញុំសុំឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា ក៏ដូចជាក្រុមហ៊ុនអគ្គិសនីកម្ពុជា ធ្វើការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាមួយសាលាក្រុងភ្នំពេញ ដើម្បីពិនិត្យមើល ... ពិតមែនហើយត្រូវរកដំណោះស្រាយតាំងពីកុងទ័រ អ្នកណាទិញ អ្នកណាចេញថ្លៃ ...** ធ្វើយ៉ាងម៉េចឲ្យកម្មករ/ការិនី **បានទទួលផលប្រយោជន៍ពីការធ្លាក់ថ្លៃនៃអគ្គិសនី ...**។

១២. កម្ពុជា មិនទាន់ធ្វើអាជីវកម្មលើប្រេងកាត ឧស្ម័ន ធ្យូងថ្ម និងរ៉ែគ្រប់ប្រភេទទេ

វេទិកាស្តីពីការការពារ និងអភិរក្សធនធានធម្មជាតិ, ថ្ងៃ ២២ សីហា ឆ្នាំ ២០១៦

... **ទាក់ទងនឹងឧស្ម័ន ប្រេងកាត ធ្យូងថ្ម និងរ៉ែគ្រប់ប្រភេទ។ កម្ពុជាមិនទាន់បានធ្វើអាជីវកម្មលើប្រេងកាត ឧស្ម័ន ធ្យូងថ្ម និងរ៉ែគ្រប់ប្រភេទនៅឡើយទេ។ យើងស្ថិតនៅក្នុងដំណាក់កាលសិក្សានៅឡើយ ក្នុងពេលដែលប្រទេសជាច្រើនបានប្រើប្រាស់រួចស្រេចហើយ រាប់ទាំង East Timor ដែលខ្ញុំទៅទស្សនកិច្ចរួច**

ហើយនោះ។ យើងបន្តការសិក្សា ហើយយើងធ្វើការងារនេះឱ្យល្អបំផុត។ កន្លងទៅ ទាល់តែខ្ញុំថាឲ្យ បានឈប់។ ប្រដៅនោះប្រដៅ ... វាជាពរជ័យ ឬបណ្តាសារ។ បានខ្ញុំជួបអស់លោកនានា ទាំងស្ថាប័នហិរញ្ញវត្ថុធំៗ ទាំងអគ្គរដ្ឋទូត ប្រទេសខ្លះ ដែលពូកែនិយាយអញ្ចឹង ថា(នៃពេលនេះមិនមែនជាពេល ដែលត្រូវនិយាយអំពីថាតើត្រីណាត្រូវអាំង ត្រូវស្ងោរ ត្រូវចៀនទេ ពេលនេះត្រូវនិយាយថា ធ្វើម៉េចត្រូវចាប់ត្រីឲ្យបាន)។ តាំងពីឆ្នាំ ២០០២ រហូតមកដល់ឥឡូវ ១៤ ឆ្នាំ ខ្ញុំហាមរដ្ឋមន្ត្រីទាំងអស់ អោយឈប់និយាយជាមួយរឿងដែលវាមិនទាន់ដល់។ ពិតហើយ ត្រូវគ្រោងជាមុន ប៉ុន្តែនិយាយច្រើនម្ល៉េះ អារឿងត្រូវនិយាយមិននិយាយទេ ...។

វប្បធម៌ និងវិចិត្រសិល្ប:

១	អន្តរជាតូបនីយកម្ម សិល្ប: វប្បធម៌	១៩៩
២	សូមបញ្ចូលចាប៉ីដងវែង ជាបេតិកភណ្ឌពិភពលោក	១៩៩
៣	បំផុសការអភិរក្ស និងអភិវឌ្ឍក្នុងចំណោមយុវជន, ប្រមូលទុនវប្បធម៌	២០០
៤	ការជញ្ជាំជើងមួយកន្លែង ជាសត្រូវរបស់សិល្ប:	២០១
៥	ជំនួបរវាងមនុស្ស វប្បធម៌រូបិយ និងអរូបិយ	២០២
៦	ការជួបជុំសម្រាប់អ្នកនិពន្ធ អ្នកដឹកនាំរឿង គឺជារឿងចាំបាច់	២០២
៧	ធម្មការ/សាសនា សហការនិងក្រសួងវប្បធម៌ បណ្តុះបណ្តាលអាចារ្យ	២០៣
៨	ច្នៃប្រឌិតស្នាដៃក្នុងកម្រិតវប្បធម៌ជាតិ	២០៤
៩	ស្នាដៃនិពន្ធ: ស្លាប់តែរស់, រស់តែស្លាប់ និងកុំកប់តាមអ្នកស្លាប់	២០៤
១០	គ្រប់គ្រង និងធានាចីរភាពក្រុមសិល្ប:	២០៥
១១	មិនទទួលយកវប្បធម៌ពីក្រៅ រក្សាអត្តសញ្ញាណជាតិ	២០៥
១២	គួរចាក់ផ្សាយសិល្ប:ខ្មែរគ្រប់ទម្រង់ក្នុងម៉ោងមាស	២០៦
១៣	យុទ្ធសាស្ត្របង្កសង្គ្រាមវប្បធម៌ប្រឆាំងកម្ពុជា ពីប្រទេសជិតខាង	២០៧

១. អន្តរជាតូបនីយកម្ម សិល្ប: វប្ផធម៌

ពិធីបិទសិក្ខាសាលាជាតិ ស្តីពី សិល្ប:ទស្សនីយភាពខ្មែរ ៣០ ឆ្នាំ នៃការរស់ឡើងវិញ, ថ្ងៃទី ២២ កក្កដា ២០០៩

... បញ្ហា**អន្តរជាតូបនីយកម្ម សិល្ប: វប្ផធម៌ ទស្សនីយភាពខ្មែរនេ: ខ្ញុំមិនមែនចង់និយាយសំដៅថា យករបស់ខ្មែរទៅធ្វើអន្តរជាតូបនិយកម្ម ពីខាងក្រៅឲ្យបាត់ពណ៌សម្ផុ:ខ្មែរនានា:ទេ។ សូមកុំកាន់ច្រឡំ។ គឺយើងសំដៅចង់ឲ្យអ្នកក្រៅយល់ពីសិល្ប: វប្ផធម៌ខ្មែ:។** រឿងនេ:ខ្ញុំបានដាក់ជាបញ្ហាឲ្យក្រសួងទេសចរណ៍ ធ្វើការចាត់ចំណាត់ថ្នាក់ និងផ្តល់រង្វាន់ចំពោ:បណ្ណាសណ្ឋាគារដែលប្រើប្រាស់សិល្ប:ខ្មែ:បានច្រើន ... ខ្ញុំគ្រាន់តែបញ្ជាក់ថាអន្តរជាតូបនីយកម្ម គឺយើងចង់ឲ្យគេយល់ពីវប្ផធម៌របស់យើង ...។

ទិវាវប្ផធម៌ជាតិលើកទី ១៧ និងពិធីបិទមហោ ស្រពសិល្ប: យុវជនទូទាំង ប្រទេស, ថ្ងៃទី ៣ មីនា ២០១៥

... បញ្ហាវប្ផធម៌ មិនមែនជាការណ្ណានពានមួយទេ។ និយាយឲ្យពិត។ **វាស្ថិតនៅត្រង់ថា យើងទទួលយកវប្ផធម៌របស់គេដោយការស្ម័គ្រចិត្តតែប៉ុណ្ណា:**។ លើការដាក់ស្តែង បារាំងបានត្រួតកម្ពុជាស្ទើ:តែមួយសតវត្ស: ក៏ប៉ុន្តែ តើបារាំងបានទុកវប្ផធម៌របស់គេនៅទីនេ: អ្វីខ្ល:ទៅ? ពេលនោ: ប្រជាពលរដ្ឋ ជាពិសេសព្រ:សង្ឆ និងប្រជាពលរដ្ឋរបស់យើងបានរក្សានូវអត្តសញ្ញាណរបស់ខ្លួនយ៉ាងច្បាស់លាស់ សូម្បីតែភាសាអក្ស:សាស្ត្រ។ នៅប្រទេសមួយចំនួនដែលបារាំងបានទៅត្រួតត្រាបាននិយាយភាសាបារាំងទៅហើយ ... ប៉ុន្តែ កម្ពុជាគឺអត់ទេ។ នេ:ជាចំណុចខ្លាំងរបស់យើងកាលពីអតីតកាល។ **ដូច្នេ: យើងគួ:តែជកពិសោធន៍ចំណុចខ្លាំងពីអតីតកាលនេ: ពង្រឹងនូវបច្ចុប្ផន្នកាល និងអនាគតកាលលើវិស័យវប្ផធម៌ ...**។

២. សូមបញ្ចូលចាប៉ីដងវ៉ែង ជាបេតិកភណ្ឌពិភពលោក

ទិវាវប្ផធម៌ជាតិលើកទី ១៧ និងពិធីបិទមហោស្រពសិល្ប:យុវជនទូទាំងប្រទេស, ថ្ងៃទី ៣ មីនា ២០១៥

... យើងនិយាយអំពីការត្រៀមបញ្ចូលចាប៉ីដងវែង ជាបេតិកភណ្ឌពិភពលោក។ គ្មានអ្នកណាមកជំទាស់កើតទេ ព្រោះចាប៉ីដងវែងមានតែខ្មែរទេ។ គេមានចាប៉ីបែបរបស់គេ។ គេដាក់ជារឿងរបស់គេ ប៉ុន្តែចាប៉ីបែបខ្មែរនេះ គឺមិនមានអ្នកណាមានដូចទេ។ ក្នុងពិភពលោក មានតែខ្មែរមួយគត់។ អញ្ចឹងទេ **ខ្ញុំគិតថា អង្គការយូនេស្កូ (UNESCO) ប្រហែលជាមិនជំទាស់ជាមួយនឹងការស្នើសុំរបស់កម្ពុជាដាក់ចាប៉ីដងវែងចូលនោះទេ** ...។

៣. បំផុសការអភិរក្ស និងអភិវឌ្ឍក្នុងចំណោមយុវជន, ប្រមូលទុនវប្បធម៌

ទិវាប្បធម៌ជាតិ ៣ មីនា លើកទី ១៨ និងពិធីបិទមហោស្រពសិល្ប:យុវជនទូទាំងប្រទេស, ថ្ងៃទី ៣ មីនា ២០១៦

... **យើងគួររក្សានូវប្រធានបទ(យុវជនដើម្បីវប្បធម៌ជាតិ)នេះតៗទៅទៀត ព្រោះថា បើសិនគ្មានការចូលរួមពីយុវជននោះទេ យើងក៏មិនអាចធ្វើអ្វីបានដែរ។** ពីឆ្នាំមួយទៅឆ្នាំមួយ យើងក៏ចល័តប្រធានបទ ដូច្នេះការចល័តប្រធានបទនោះ គឺមិនប្រាកដថាទទួលបានការពិនិត្យពិច្ច័យអំពីការកែលូតលាស់នោះទេ។ ដូច្នេះ **ចាប់ផ្តើមពីចលនាយុវជននេះ។ យើងគួរត្រូវរក្សានូវប្រធានបទនេះនៅជាបន្ត ទៀតដើម្បីជម្រុញបំផុសនៅក្នុងចំនោមយុវជនយើង ដើម្បីថែអភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិរបស់យើង** ...។

ទិវាវប្បធម៌ជាតិលើកទី ១៧ និងពិធីបិទមហោស្រពសិល្ប:យុវជនទូទាំងប្រទេស, ថ្ងៃទី ៣ មីនា ២០១៥

... **គួរតែផ្តួចផ្តើមរៀបចំជំនួបមួយ រវាងក្រុមយុវជន និងព្រឹទ្ធាចារ្យរបស់យើង។ កុំចាំបាច់ពឹងពាក់ក្រសួងណាផ្សេង ក្រៅពីក្រសួងវប្បធម៌ខ្លួនឯង ... បើបានរៀបចំជំនួបកើតឡើង ... អ្នកទាំងហ្នឹងហើយ ដែលជាធនធានមនុស្ស នៅសេសសល់ពីការកាប់សម្លាប់របស់ពួក ប៉ុល ពត ហើយដែលបានទុកកេរ្តិ៍មត៌កឲ្យយើងស្រាវជ្រាវ ...** ឆ្នាំ ១៩៧៩ ដំណាក់កាលលោកតា ឆេង ផុន ធ្វើជារដ្ឋមន្ត្រីនៃក្រសួងវប្បធម៌ និង វិចិត្រសិល្ប: គាត់ប្រើពាក្យថា ដំណាក់កាលប្រមូលទុន, **យុទ្ធសាស្ត្ររបស់គាត់ គឺប្រមូលធនធានមនុស្ស និងការចងក្រងត្រឡប់មកវិញនូវ**

ទុនទាំងឡាយ ... យើងមិនគួរឲ្យទុនទាំងអស់នេះ ក្លាយជាអាសាបង់ទេ...។

៤. ការជញ្ជាំជើងមួយកន្លែង ជាសត្រូវរបស់សិល្ប:

ទិវាវប្ផធម៌ជាតិលើកទី ១៦ និងពិធីបិទមហោស្រពសិល្ប:មហាជនថ្នាក់ជាតិ, ថ្ងៃទី ០៣ មីនា ២០១៤

... យើងគួរតែបង្ហាញនូវម្ហូបរបស់យើង ដើម្បីឲ្យគេឃើញ ... បើយើងចាត់ទុកម្ហូបនេះ ជាម្ហូបហួសសម័យ វាហ្នឹងបាត់បង់នូវភាពដើមរបស់ខ្មែរ។ ដូចបានលើកពីខាងដើមថា មិនថា វប្ផធម៌នេះអត់តម្លៃ វប្ផធម៌នេះមានតម្លៃ, នេះវប្ផធម៌ប្រទេសធំ, នេះវប្ផធម៌ប្រទេសតូចទេ។ ស្មើគ្នាទាំងអស់។ ម្យ៉ាងទៀត តាមសម័យកាលនីមួយៗ **ភាពជញ្ជាំជើងនៅហ្នឹងកន្លែង គឺជាសត្រូវ ហើយក៏អាចជា ចំណុចស្លាប់របស់សិល្ប:។ ពីដើមមកដល់បច្ចុប្បន្ននេះ តើវិត្តដល់ណា? យើងទាំងអស់គ្នា អាយុស្រករនេះ ប្រហែលជានៅចាំបានហើយ នៅក្នុងទសវត្ស ៦០ ពេលនោះ មានចម្រៀងសម័យចេញមួយចំនួន។ ចាស់ៗ សម័យនោះ អត់ពេញចិត្តទេ។ គាត់ចូលចិត្តស្តាប់តែចាប៉ី ស្តាប់តែចម្រៀងបាសាក់ ... វាវិត្តទៅតាមដំណាក់កាល។** ពេលខ្ញុំដឹងក្តី ខ្ញុំឃើញម្តាយខ្ញុំពាក់អាវបំពង់ ប៉ុន្តែឥឡូវអាវបំពង់មានតែក្នុងទម្រង់សិល្ប:ទេ។ ជា**ស្ថានភាពមានការវិវឌ្ឍ ប៉ុន្តែត្រូវរក្សាចំណុចដើមរបស់វា ... សិល្ប:ក៏ដូចគ្នាដែរ... យ៉ាងណា ក៏ដោយ ទម្រង់ខ្មែរត្រូវបានរក្សា ...។**

ទិវាវប្ផធម៌ជាតិលើកទី ១៥, ថ្ងៃទី ០៣ មីនា ២០១៣

... ខ្ញុំនៅតែបន្តគំនិតទាំងឡាយ ដែលខ្ញុំបានលើកឡើង កាលពីឆ្នាំ ២០១១ ទិវាវប្ផធម៌លើកទី ១៣ **ត្រូវបន្តជម្រុញសិល្ប:មហាជនជាបន្តទៀត។ រដ្ឋពិតជាមិនអាចធ្វើគ្រប់។ ដូចនេះ ត្រូវលើកទឹកចិត្តឲ្យសិល្ប:មហាជនធ្វើសកម្មភាព។ សូម្បីតែសិល្ប:ដែលរដ្ឋគ្រប់គ្រង ក៏គួរត្រូវបានទទួលការអនុញ្ញាតឲ្យបានទៅសម្តែង ដើម្បីបានកម្រៃខ្លះ ឲ្យក្លាយទៅជាចលនាជាតិមួយ។** ដូចយើងបានឃើញពីមុន ពេលសិល្ប:ចាប៉ី អាយ៉ៃ វាស្ទើរតែបាត់បង់ ខ្ញុំក៏មានការអំពាវនាវ ជម្រុញឲ្យមានការហ្វឹកហាត់ ... ឥឡូវឃើញថា ផ្នែកសិល្ប:ទាំងនោះ បានដុះដាលមួយផ្នែក។ យើងត្រូវមានការប្រឹងប្រែងបន្ថែម ជម្រុញសិល្ប:មហាជនឲ្យមានការ

អកិវ៉ៃ។ ... អង្គការក្រៅរដ្ឋាភិបាលមួយចំនួន គេធ្វើបានល្អ ដូចជាអង្គការខ្មែរអមត: ... **ចំណុចនេះ ត្រូវចាប់ឲ្យបាន បើទុកឲ្យសិល្ប:នៅទ្រឹងមួយកន្លែង មិនអាចទៅមុខរួចទេ អញ្ចឹងត្រូវយកសិល្ប:ចិញ្ចឹមសិល្ប: ...**។

៥. ជំនួបរវាងមនុស្ស វប្បធម៌រូបិយ និងអរូបិយ

អញ្ជើញបើកព្រឹត្តិការណ៍ អង្គរសង្ក្រានឆ្នាំ ២០១៦, ថ្ងៃទី ១៤ មេសា ២០១៦

... ខ្ញុំព្រះករុណាខ្ញុំ ចង់និយាយបញ្ជាក់អំពីជំនួបត្រីភាគីរវាងមនុស្ស និងវប្បធម៌រូបិយ, រវាងមនុស្ស និងវប្បធម៌អរូបិយ។ **នេះជាជំនួបដ៏ធំមួយ ដែលមនុស្សនាំមកនូវវប្បធម៌អរូបិយនៅលើទឹកដីនៃវប្បធម៌រូបិយ។** ចំណុចទាំងនេះ យើងគួរតែនឹកដល់គុណដូនតា អតីតព្រះមហាក្សត្រ ព្រះមហាក្សត្រយានី ដែលបន្សល់ទុកនូវប្រាង្គប្រាសាទ ដើម្បីការរៀបចំរបស់យើង។ **ប្រសិនបើគ្មានវប្បធម៌រូបិយ ដែលបន្សល់ទុកដោយដូនតាពីជំនាន់មុននោ: យើងក៏មិនចាំបាច់និយាយពីអង្គរសង្ក្រាន្តនោ: នៅលើទឹកដីនៃបេតិកភណ្ឌវប្បធម៌រូបិយផងដែរ ... នៅក្នុងរយ:ពេលប៉ុន្មានឆ្នាំចុងក្រោយនេះ សៀមរាបបានក្លាយទៅជាតំបន់នៃការទាក់ទាញក្នុងវិស័យទេសចរណ៍។ ... ជាមួយគ្នានេះ ការប្រារព្ធទិវារៀបចំអង្គរសង្ក្រាន្តជារៀងរាល់ឆ្នាំនេះ វាក៏បម្រើទៅដល់ប្រធានបទនៃទិវាវប្បធម៌ ៣ មីនា ដែលយើងបានប្រសិទ្ធនាមថា «យុវជនដើម្បីវប្បធម៌ជាតិ»។** ឥឡូវនេះ យើងបានប្រគល់តួនាទីអោយយុវជនជាអ្នករៀបចំនូវអង្គរសង្ក្រាន្តដោយមានការជួយជ្រោមជ្រែងពីស្ថាប័នថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ... នោ:ហើយ ដែលជាចំណុចត្រូវលើកទឹកចិត្ត និងបន្តលើកទឹកចិត្តយុវជន ដែលជាទំពាំងស្នងឫស្សីធ្វើចលនាឆ្ពោ:ទៅមុខ ...។

៦. ការជួបជុំសម្រាប់អ្នកនិពន្ធ អ្នកដឹកនាំរឿង គឺជារឿងចាំបាច់

ទិវាវប្បធម៌ជាតិលើកទី ១៣ និងបិទមហោស្រពមហាជនទូទាំងប្រទេស ឆ្នាំ ២០១១, ០៣ មីនា ២០១១

... **ទាក់ទិនជាមួយនឹងការជួបជុំសម្រាប់អ្នកនិពន្ធ អ្នកដឹកនាំរឿង គឺជារឿងចាំបាច់។ កន្លងទៅ ខ្ញុំឃើញថាមានករណីខ្ល:ហាក់ដូចជាគេហៅថា អធិរាជប្រចាំកន្លែងមួយៗ។ ដូចជាស្ថានីយ៍ទូរទស្សន៍មួយអញ្ចឹង វាមានអធិរាជមួយទៅ អធិរាជ**

ខាងធ្វើរឿងល្ងោន ខាងធ្វើរឿងកុនអញ្ចឹងទៅ។ អធិរាជហ្នឹង មិនទាំងស្តាប់ស្ថានីយ៍ទូរទស្សន៍ហ្នឹងទៅទៀត កុំថាឡើយមកជួបជុំផ្ទាស់ ប្តូរយោបល់ជាមួយក្រុមអ្នកនិពន្ធដទៃទៀត។ អញ្ចឹង មានរឿងខ្លះដាក់បញ្ចាំងទៅ ប្រតិកម្មឈុលមក បានខ្ញុំស្នើថា គួរតែមានការជួបជុំគ្នាបែបនេះ ដើម្បីដកពិសោធន៍គ្នាទៅវិញទៅមក។ បើធ្វើអធិរាជម្នាក់ៗ មិនកើតទេ។ វាចោលក្ស្ជនខ្ជាត។ ដូចជារឿងមួយ ដែលខ្ញុំនិយាយ "អីក៏ដល់ដំណាក់កាលដេញថ្លៃយកប្រពន្ធនោះ"។ បើមិនទប់ស្កាត់ទេ បន្តិចទៀតដេញថ្លៃយកប្តី។ **រឿងហ្នឹងដែលខ្ញុំសូមអំពាវនាវ ហើយស្ថានីយមួយៗដែលបញ្ចាំងចេញទៅ គួរតែត្រូវគ្រប់គ្រងឲ្យច្បាស់ ... ថាអ្នកដឹកនាំរឿង អ្នកនិពន្ធតាមស្ថានីយមួយៗ ចុះវាអធិរាជ កុំឲ្យក្រសួងស្ថាប័នយើងមួយៗ ធ្វើអធិរាជ ដាច់ដោយឡែកពីគ្នា ដែលធ្វើឲ្យទម្រង់មិនស៊ីសង្វាក់គ្នា ...**។

៧. ធម្មការ/សាសនា សហការជាមួយក្រសួងវប្បធម៌ បណ្តុះបណ្តាលអាចារ្យ

ទិវាវប្បធម៌ជាតិលើកទី ១៣ និងបិទមហោស្រពមហាជនទូទាំងប្រទេសឆ្នាំ ២០១១, ០៣ មីនា ២០១១

... ខ្ញុំមានកង្វល់លើបញ្ហាអាចារ្យ និងនៅតែនិយាយ**ថាមានអាចារ្យមិនទាន់គ្រប់ទេ។ រឿងហ្នឹងក្រសួងធម្មការ និងសាសនាបានធ្វើច្រើនហើយ ប៉ុន្តែកុំធ្វើដាច់ដោយឡែក ត្រូវមានការរៀបចំធ្វើជាមួយក្រសួងវប្បធម៌ផង ដើម្បីឲ្យវាទៅរួមគ្នា ព្រោះដូចគេថា ចេះដោយខ្ជ្ជនក្ស្ជនដោយវត្តនោះ ... អាចារ្យចាស់ៗ ចេះតែស្លាប់ អាចារ្យក្មេងបណ្តុះបណ្តាលអត់ទាន់។ ពិធីមានកាន់តែច្រើន។** ក្រៅពីអាចារ្យនៅមានអ្នកសិល្ប:ដូចជាក្ជ្ជយៗអម្ជាញ់មិញ សុទ្ធតែទៅច្រៀងភ្លេងការបានហើយ។ រឿងនេះត្រូវបន្តដោយសហការគ្នា ... ឧទាហរណ៍ ដូចជាអាចារ្យ វាមានការគួបផ្ទ:រវាងក្រសួងវប្បធម៌ ក្រសួងពត៌មានដែលត្រូវផ្សព្វផ្សាយ។ អញ្ចឹងតើត្រូវយកទម្រង់បែបណា អីបែបណា ត្រូវនាំគ្នាធ្វើអាកិច្ចការងារហ្នឹង បើមិនអញ្ចឹងទេ ថ្ងៃក្រោយ ដល់ដំណាក់កាល គេហៅថាតាមតំបន់ខ្លះពេលបុណ្យខ្មោចនាំគ្នារ:លេង ...។

៨. ច្នៃប្រឌិតស្នាដៃក្នុងកម្រិតវប្បធម៌ជាតិ

ទិវាវប្បធម៌ជាតិលើកទី ១៣ និងបិទមហោស្រពមហាជនទូទាំងប្រទេសឆ្នាំ ២០១១, ០៣ មីនា ២០១១

... ការបង្កើតស្នាដៃថ្មីៗ បង្កើតអីក៏បង្កើតចុះ អាណិតសូមកុំដាក់ដេញថ្លៃយកប្រពន្ធយកប្តី។ អាហ្នឹងបង្កើតស្នាដៃថ្មីមែន ប៉ុន្តែថ្មីខុសរឿង។ ហើយភាពសាំ វ៉ាជាសត្រូវជាមួយសិល្ប:។ ឧទាហរណ៍ ឡើងសម្តែងដដែលៗ ហើយបើដាក់តាមកញ្ចក់ទូទស្សន៍ទៀត តែ ២-៣ ដង គឺចប់ហើយ។ អញ្ចឹងទេ **យើងត្រូវចេះច្នៃប្រឌិត តែការច្នៃប្រឌិតបែបណាក៏ដោយ ត្រូវតែឲ្យវាស្ថិត នៅក្នុងកម្រិតដែលវប្បធម៌ជាតិ យើងអនុញ្ញាតឲ្យបាន។ កន្លងទៅ ក៏យើញថា មានការខិតខំមួយចំនួន ... ពាក់ព័ន្ធជាមួយនឹងប៉ុន្មានឆ្នាំមុននោះ អ្វីដែលហៅថា ថ្ងៃបុណ្យសង្សារ។ ស្អីទៅថ្ងៃបុណ្យសង្សារនោះ? ឥឡូវមានការកែសម្រួលមកជា ទិវានៃក្តីស្រឡាញ់ តែអាហ្នឹងវាមិនមែនជារបស់យើងទេ។** យើងបាននាំចូល។ កុំថាគេឈ្លានពានយើង គឺយើងទទួលពីគេដោយស្ម័គ្រចិត្ត ...។

៩. ស្នាដៃនិពន្ធ: ស្លាប់តែរស់, រស់តែស្លាប់ និងកុំកប់តាមអ្នកស្លាប់

ទិវាវប្បធម៌ជាតិលើកទី ១៣ និងបិទមហោស្រពមហាជនទូទាំងប្រទេសឆ្នាំ ២០១១, ០៣ មីនា ២០១១

... រឿងមួយទៀត ខ្ញុំគួរតែផ្តាំផ្ញើទុកឲ្យហើយ មានបីចំណុច **ទី ១: ស្លាប់តែរស់ ទី ២: រស់តែស្លាប់ និងទី ៣: កុំកប់ទៅជាមួយនឹងអ្នកស្លាប់។ ម៉េចទៅស្លាប់តែរស់។ ចំណុចនេះ ខ្ញុំចង់និយាយទៅដល់ការតែងនិពន្ធ។ មើលអ្នកជំនាន់ដើមនិពន្ធ អ្នកទាំងហ្នឹងស្លាប់អស់ហើយ ក៏ប៉ុន្តែស្នាដៃរបស់ពួកគាត់ គឺត្រូវបានក្សាទុកដល់សព្វថ្ងៃ។** ហ្នឹងហើយដែលហៅថាស្លាប់តែរស់។ ឧទាហរណ៍ រឿងទុំទាវ កុលាបប៉ៃលិន ផ្កាស្រពោន ឬរឿងតាំងពីកាកី ... ក្រុមអ្នកនិពន្ធក្នុងទសវត្សរ៍ ៥០-៦០-៧០ ខ្ញុំមិននិយាយពីរបប អាពត ទេ ... ស្នាដៃរបស់ពួកគាត់នៅ។ **ប៉ុន្តែមានមួយបែបទៀត អ្នកនិពន្ធនៅរស់ទេ ក៏ប៉ុន្តែ ស្នាដៃរបស់គាត់បានស្លាប់បាត់ទៅហើយ**។ ចម្រៀងខ្លះ ចេញបានតែ ២ ខែ ក៏បាត់ទៅ។ **មួយទៀត ខ្ញុំសូមកុំឲ្យមាន**

ភាពជ្រុលនិយម រហូតទៅដល់កប់ជាមួយអ្នកស្លាប់នោះ នៅក្នុងកិច្ចប្រជុំគណៈ
រដ្ឋមន្ត្រីមួយ ខ្ញុំនិយាយថា យើងសូមកុំឲ្យជ្រុលហួស គ្រាន់តែគ្នាយកចម្រៀង
ស៊ិន ស៊ីសាមុត, សុះ ម៉ាត់, រស់ សេរីសុទ្ធា, ប៉ែន រ៉ន អី យកមកច្រៀងមិនបាន។
ស្ថានភាពបែបហ្នឹង បានសេចក្ដីថា យកចម្រៀងទាំងហ្នឹង ទៅកប់ជាមួយខ្មោច ...
នេះយើងជ្រុលហួស។

១០. គ្រប់គ្រង និងធានាចីរភាពក្រុមសិល្ប:

ទិវាវប្ប:ធម៌ជាតិលើកទី ១៣ និងបិទមហោស្រពមហាជនទូទាំងប្រទេសឆ្នាំ
២០១១, ០៣ មីនា ២០១១

... **ការបង្កើតបានក្រុមសិល្ប: មានការលំបាកហើយ តែការគ្រប់គ្រង**
សិល្ប:ធានាមានចីរភាពនៃក្រុមរបស់ខ្លួន គឺជាបញ្ហាមួយទៀត។ ដំណាក់
កាលបច្ចុប្បន្ន ជាដំណាក់កាល ដែលប្រជាពលរដ្ឋចូលរួមច្រើនហើយ ... **អញ្ចឹង**
ក្រុមសិល្ប:មួយ បើពឹងផ្អែកលើរដ្ឋមិនគ្រប់ទេ ... ស្ថានភាពបច្ចុប្បន្នវាមិនដូច
ទសវត្ស៍ ៨១-៨២ នោ:ទេ ជំនាន់នោ: យក្សកាន់កាំភ្លើង និយាយរួមសិល្ប:កាន់
កាំភ្លើងទាំងអស់ ហើយពេល យប់មិនសូវហ៊ានលេងទេ លេងតែពេលព្រឹក ដល់
អាពតចូលមក កាន់កាំភ្លើងរត់ចូលត្រង់សេត្រៀមបាញ់ ... សម័យនេ: មិនដូច
សម័យនោ: **ដែលតម្រូវឲ្យក្រុមសិល្ប:ដើរលេង គេហៅថា យុទ្ធនាការរាប់ពាន់**
គីឡូ ជំនាន់ លោកតា ឆេង ផុន គាត់នាំដើរលេងតាមខេត្តទៀតទេ។ ក្រុមសិល្ប:
ច្រើនណាស់ បុណ្យទានក៏ច្រើន ប្រជាពលរដ្ឋគេមានលទ្ធភាពដើម្បីជួលក្រុម
សិល្ប:ទៅលេង ហើយក្រុមសិល្ប:អាជីព យើងអនុញ្ញាតឲ្យគាត់ទៅលេងទៅ។
សព្វថ្ងៃ បើត្រឹមក្រុមសិល្ប:របស់ក្រសួងវប្ប:ធម៌ ២-៣ ក្រុមហ្នឹងពិបាកបម្រើ
ប្រជាពលរដ្ឋមួយប្រទេសដែរ។ អញ្ចឹងទេត្រូវតែគ្រប់គ្រងអោយបានល្អ រក្សាក្រុម
អោយគង់វង្ស ...។

១១. មិនទទួលយកវប្ប:ធម៌ពីក្រៅ រក្សាអត្តសញ្ញាណជាតិ

ទិវាវប្ប:ធម៌ជាតិលើកទី ១៧ និងពិធីបិទមហោស្រពសិល្ប:យុវជនទូទាំងប្រទេស,
ថ្ងៃទី ៣ មីនា ២០១៥

... **បញ្ហាវប្បធម៌ មិនមែនជាការណ្ហានពានមួយទេ។ និយាយឲ្យពិត។ វាស្ថិតនៅត្រង់ថា យើងទទួលយកវប្បធម៌របស់គេ ដោយការស្ម័គ្រចិត្តតែប៉ុណ្ណោះ។ លើការជាក់ស្តែង បារាំងបានត្រួត កម្ពុជាស្ទើរតែមួយសតវត្ស៍ តើបារាំងបានទុកវប្បធម៌របស់គេនៅទីនេះ អ្វីខ្លះទៅ? ពេលនោះ ប្រជាពលរដ្ឋ ជាពិសេសព្រះសង្ឆ និងប្រជាពលរដ្ឋរបស់យើងបានរក្សានូវអត្តសញ្ញាណរបស់ខ្លួនយ៉ាងច្បាស់លាស់សូម្បីតែភាសាអក្សរសាស្ត្រ។** នៅប្រទេសមួយចំនួនដែលបារាំងបានទៅត្រួតត្រា បាននិយាយភាសាបារាំងទៅហើយ ... ប៉ុន្តែកម្ពុជាគឺអត់ទេ។ នេះជាចំណុចខ្លាំងរបស់យើងពីអតីតកាល។ ដូច្នេះ យើង គួរតែដកពិសោធន៍ចំណុចខ្លាំងពីអតីតកាលនេះ ពង្រឹងនូវបច្ចុប្បន្នកាល និងអនាគតកាល លើវិស័យវប្បធម៌ ...។

១២. គួរចាក់ផ្សាយសិល្ប:ខ្មែរគ្រប់ទម្រង់ ក្នុងម៉ោងមាស

ទិវាវប្បធម៌ជាតិ ៣ មីនា លើកទី ១៨ និងពិធីបិទមហោស្រពសិល្ប:យុវជនទូទាំងប្រទេស, ថ្ងៃទី ០៣ មីនា ២០១៦

... **កន្លងទៅក្រសួងព័ត៌មានបានតម្រូវអោយមានការចាក់ផ្សាយ នូវសិល្ប:ខ្មែរ ឬភាពយន្តខ្មែរក្នុងប៉ុន្មានម៉ោងនោះ។** បើខ្ញុំជាម្ចាស់ទូរទស្សន៍ ខ្ញុំគិតថាអ្វីដែលយើងកំពុងធ្វើនេះ ជាផលិតផលសម្រាប់ចិញ្ចឹមទូរទស្សន៍ក្នុងប៉ុន្មានម៉ោងនោះឯង។ ទូរទស្សន៍ខ្លះទៅយករឿងពីទសវត្ស៍ ៨០ មកចាក់(ផ្សាយ)។ អត់អីទេ។ ប៉ុន្តែ**មិនមែនតម្រូវតែយកភាពយន្តមួយមុខទៅចាក់ក្នុងកម្មវិធីនោះទេ។ ទាក់ទងជាមួយរបាំ ល្ខោនបាសាក់ ឬក៏ទម្រង់យីកេអី សហការជាមួយក្រុមសិល្ប:ថតយកទុក រួចហើយចាក់ផ្សាយម៉ោងហ្នឹងទៅ**។ ខ្ញុំជួយរំលឹកទេ ប្រសិនជាខ្ញុំជាម្ចាស់ទូរទស្សន៍ ... **សូមអំពាវនាវដល់ពាណិជ្ជករដែលមានផលិតផលផ្សាយពាណិជ្ជកម្ម សូមមេត្តាផ្សាយពាណិជ្ជកម្ម ក្នុងកម្មវិធីម៉ោងពេលទូរទស្សន៍នានាចាក់ផ្សាយសិល្ប:ខ្មែរ ទាំងភាពយន្តក្តី ទាំងចម្រៀងក្តី ទាំងទម្រង់សិល្ប:នានាៗក្តី ... គាំទ្រដល់វិស័យសិល្ប:ខ្មែរ និងដល់សកម្មភាពកីឡាខ្មែរ...**។

១៣. យុទ្ធសាស្ត្របង្កសង្គ្រាមវប្បធម៌ប្រឆាំងកម្ពុជា ពីប្រទេសជិតខាង

ទិវាវប្បធម៌ជាតិលើកទី ១៣ និងបិទមហោស្រពមហាជនទូទាំងប្រទេសឆ្នាំ ២០១១, ០៣ មីនា ២០១១

... រឿងមួយទៀត គឺប្រាសាទព្រះវិហារ ដែលខ្ញុំចង់និយាយពាក្យថា លុបបំបាត់ រាល់យុទ្ធនាការបង្កសង្គ្រាមវប្បធម៌ប្រឆាំងនឹងកម្ពុជា ចង់និយាយសំដៅអំពី **ការប្រឆាំងរបស់ថៃ បំផ្លាញប្រាង្គប្រាសាទព្រះវិហាររបស់យើង**។ រឿងនេះ ខ្ញុំនឹកមិនដល់ថា មេដឹកនាំនៅទីក្រុងបាងកក ពេលនេះ(ហើយនៅ)ហ៊ាននិយាយជាមួយ បេសកជន យូណេស្កូ ឲ្យដកប្រាសាទព្រះវិហារ ចេញពីបញ្ជីបេតិកភណ្ឌពិភពលោក។ ដំបូង ខ្ញុំគិតថា គេដំទាស់ត្រឹមតែជាមួយផែនការគ្រប់គ្រង ប៉ុន្តែដល់ពេលលោកអគ្គនាយកនេះមកជួបខ្ញុំ ខ្ញុំភ្ញាក់ខ្លួនព្រើតតែម្តង ... ដូច្នេះហើយ គេមិនខ្លាចនឹងវ៉ៃបំផ្លាញប្រាសាទនេះទេ។ ... អ្នកដែលបាញ់ប្រាសាទ ៤១៤ គ្រាប់ វាធ្ងន់ណាស់ **នេះហើយ គឺជាសង្គ្រាមពិត មិនគ្រាន់តែសង្គ្រាមឈ្លាន ពានទឹកដីទេ តែវាជាសង្គ្រាមប្រឆាំងនឹងវប្បធម៌ខ្មែរ ហើយសង្គ្រាមនេះ បានធ្វើនៅទល់ដែន និងធ្វើនៅលើវេទិកាអន្តរជាតិ យូណេស្កូ** ...។

សង្គមកិច្ច និងយុវនីតិសម្បទា

១	រដ្ឋ និងឯកជន អនុវត្តអត្រា ២% និង ១% ផ្តល់ការងារដល់ជនពិការ	២១១
២	ជនពិការត្រូវលើកសមត្ថភាព និងគុណធម៌របស់ខ្លួន	២១១
៣	រំកិលប្រាក់ឈៀវត្សអ្នកចូលនិវត្តមុន ឲ្យកៀកអ្នកចូលនិវត្តក្រោយ	២១២
៤	ការផ្តល់ដីសម្បទានសង្គមកិច្ច ដល់យុទ្ធជន និងការអភិវឌ្ឍតំបន់ជុំវិញ	២១២
៥	ធានារ៉ាប់រងសង្គមសំរាប់ជនពិការ ប្រសើជាងជំនួយបែបមនុស្សធម៌	២១៣
៦	គំនិតផ្តើមបង្កើត/ពង្រាយមជ្ឈមណ្ឌលអភិវឌ្ឍន៍សម្រាប់យុទ្ធជនពិការ	២១៤
៧	ផ្តល់អាហារូបករណ៍រៀនសូត្រជូនជនពិការ	២១៤
៨	ធានាសុវត្ថិភាពកុមារ និងសាលាតាមមជ្ឈមណ្ឌលកុមារកំព្រា គ-ថ្លង់	២១៥
៩	ទិន្នន័យ អំពីយុទ្ធជន ជាការចាំបាច់	២១៥
១០	ព្រមានសកម្មភាពកេងប្រវ័ញ្ច លើញើសឈាម/ទុក្ខលំបាកយុទ្ធជន	២១៦
១១	នយោបាយឈ្នះ-ឈ្នះ បញ្ចប់សង្គ្រាម លែងមានយុទ្ធជនពលី/ពិការ	២១៦
១២	បង្ការការស្លាប់ពីគ្រោះថ្នាក់ចរាចរណ៍ មីន/គ្រាប់មិនទាន់ផ្ទុះ និងការងារ	២១៧
១៣	ចាត់ចែងទីតាំងវត្តភ្នំ ជាកន្លែងសំដែងតន្ត្រីជនពិការ	២១៧

១. រដ្ឋ និងឯកជន អនុវត្តអត្រា ២% និង ១% នៃការផ្តល់ការងារដល់ជនពិការ

ពិធីប្រកាសជាផ្លូវការនូវការប្តេជ្ញាចិត្តអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិជនពិការ របស់អង្គការ សហប្រជាជាតិ ទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកឆ្នាំ ២០១៣-២០២២, យុទ្ធសាស្ត្រ អ៊ីនឈាន់ "ធ្វើឲ្យសិទ្ធិក្លាយជាការពិត" និងការបន្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីពិការភាព ឆ្នាំ ២០១៤/១៨, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣

... **(ដើម្បី)ទាក់ទាញការយកចិត្តទុកដាក់ពីស្ថាប័ននានា អត្រា ២% ត្រូវបានរម្លឹកសាជាថ្មីម្តងទៀត ក្នុងការជ្រើសរើស(ជនពិការ)ឱ្យចូលបម្រើការងារនៅតាមស្ថាប័ន។ នេះជាការកំណត់នៅក្នុងច្បាប់ ផ្នែកស្ថាប័នរដ្ឋគឺ ត្រូវមាន ២% នៅក្នុងវិស័យឯកជនគឺ ១%។ ឥឡូវនេះ មានស្ថាប័នខ្លះក៏បាន អនុវត្តរួចហើយ តែក៏នៅមានស្ថាប័នខ្លះមិនទាន់បានអនុវត្តទេ** ... ខ្ញុំផ្តល់អនុសាសន៍ថា ជ្រើសរើសពួកគេ បញ្ចូលទៅក្នុងក្របខណ្ឌ រួចហើយដាក់ឲ្យធ្វើការនៅតាមខេត្ត ឬនៅតាមស្រុកតែម្តងទៅជាការងាយស្រួលក្នុងការដោះស្រាយពីលំនៅដ្ឋាន ... សូមក្រសួង ស្ថាប័ន នីមួយៗ ដែលមានបណ្តាញរបស់ខ្លួននៅថ្នាក់ក្រោមជាតិ ពិនិត្យមើលអំពីរបៀប ចាត់ចែង និងដោះស្រាយ ... ជ្រើសរើសក្របខណ្ឌបញ្ចូលឲ្យធ្វើការនៅតាមស្រុក ឬនៅតាមខេត្តដែលនៅកៀកបំផុតទៅនឹងទីកន្លែងដែលពួកគេរស់នៅ ...។

២. ជនពិការត្រូវលើកសមត្ថភាព និងគុណធម៌របស់ខ្លួន

ទិវាជនពិការកម្ពុជាលើកទី ១៨ និងទិវាជនពិការ អន្តរជាតិលើកទី ៣៤, ថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ ២០១៦

... ខ្ញុំ អំពាវនាវដល់ វិស័យរដ្ឋ និងឯកជន។ ស្ថាប័នរដ្ឋពិនិត្យមើលជារៀងរាល់ ឆ្នាំ ... ប៉ុន្តែឥឡូវ តើស្ថាប័នរដ្ឋបានអនុវត្តអត្រា ២% រួចហើយឬនៅ? ត្រូវពិនិត្យ ជាប្រចាំអំពីបញ្ហានេះ។ ជាមួយគ្នានឹងលើកទឹកចិត្តឲ្យវិស័យឯកជនជ្រើសរើស ក្នុងសមាមាត្រតាមច្បាប់ សូមរំលឹកដល់បងប្អូនជនពិការទាំងឡាយឲ្យបានជ្រាប ថា **សេដ្ឋកិច្ចទីផ្សារ គ្មានមេត្តាធម៌ទេ។ សេដ្ឋកិច្ចទីផ្សារ ត្រូវការនូវផលចំណេញ។** ដូច្នេះ **បើសិនជាគិតអំពីក្រុមហ៊ុនតាមរបៀបជាអង្គការមនុស្សធម៌មួយគឺមិនបានទេ។ ទាមទារឲ្យយើងមាន សមត្ថភាពគ្រប់គ្រាន់ មានអត្តចរិកល្អផងដែរ ទើបគេ**

អាចជ្រើសរើសធ្វើការងារបាន។ ដូច្នេះ ត្រូវមានការបំពេញឲ្យគ្នាទៅវិញទៅមក។ ផ្នែកជនពិការក៏ត្រូវលើកកម្ពស់សមត្ថភាព និងគុណធម៌របស់ខ្លួន ដើម្បីឲ្យសមស្របទៅជាបុគ្គលិករបស់ក្រុមហ៊ុន ឯក្រុមហ៊ុនមើលឃើញនូវស្ថានភាពនោះ គេក៏អាចយកចូលនៅក្នុងការធ្វើការផងដែរ ...។

៣. រំកិលប្រាក់ហៀវត្សអ្នកចូលនិវត្តមុន ឲ្យកៀកអ្នកចូលនិវត្តក្រោយ

អញ្ជើញសួរសុខទុក្ខយោធិនពិការ ៣១៧ គូលែន, ថ្ងៃទី ១២ មេសា ២០១៦

... ខ្ញុំកំពុងឲ្យក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ **ធ្វើការកែសម្រួលពីអ្នកចូលនិវត្តមុន និងអ្នកចូលនិវត្តក្រោយ។ ពិការមុនដែលទទួលរបបទាប និងពិការក្រោយដែលទទួលរបបខ្ពស់ ដើម្បីរុញឡើង**។ ពីដើម កូនទាហានរបស់យើង ចាប់ពិការ ចូលទៅទទួលរបបនៅខាងសង្គមកិច្ចនៅសល់ជាង ២០ ម៉ឺនរៀលប៉ុណ្ណឹងៗ។ អ្នកផ្ទេរទៅក្រោយ បានប្រាក់របបដល់ទៅ ៧០ ម៉ឺន។ សក្តិប៉ុនគ្នា។ ត្រូវរកវិធីរំកិល ២០ ម៉ឺននេះ ឲ្យវាឡើងទៅកៀកនឹង ៧០ ម៉ឺននោះ។ **ឆ្នាំនេះរុញមួយកម្រិត ឆ្នាំក្រោយរុញបន្ត។ ... មិនមែនករណីជាច់ដោយឡែក ចំពោះជនពិការទេ ជាករណីទូទៅនៃមន្ត្រីរាជការ និងកម្លាំងប្រដាប់អាវុធ រវាងអ្នកចូលនិវត្តមុនដែលប្រាក់ខែទាប និងអ្នកចូលនិវត្តក្រោយ ដែលប្រាក់ខែខ្ពស់ ...**។

៤. ការផ្តល់ដីសម្បទានសង្គមកិច្ច ដល់យុទ្ធជន និងការអភិវឌ្ឍតំបន់ជុំវិញ

សំណេះសំណាលជាមួយយោធិនពិការ ភូមិអភិវឌ្ឍន៍យោធិនពិការ តាកែនកោះស្លា ស្រុកឈូក ខេត្តកំពត, ថ្ងៃទី ០៤ មេសា ឆ្នាំ ២០០៩

... មហិច្ឆតាខ្ញុំពិតជាធំ។ នេះជាតំបន់ពិសោធន៍មួយ ដើម្បីដកស្រង់ទៅធ្វើកន្លែងដទៃទៀត។ **ខ្ញុំគិតថា ដីនៅក្នុងប្រទេសអត់ខ្វះទេ ដោយតម្លៃណាក៏ដោយ កាត់ចេញពីព្រៃសម្បទាន ពីព្រៃអីក៏ដោយឲ្យតែដោះស្រាយចំគោលដៅដីសង្គមកិច្ច** ... បងប្អូនដែលមកនៅទីនេះជាង ១ ពាន់គ្រួសារ សុទ្ធតែទទួលដីសម្បទានទេតើ។ ឯកឧត្តម ចាន់ សារុន កុំទៅខ្វល់ **ដីខ្លះឲ្យទៅក្រុមហ៊ុនសម្បទានរួចហើយ បើគាត់មិនធ្វើទេ យកអាដីសម្បទានហ្នឹងឲ្យបងប្អូនទៅ។ កន្លែងខ្លះដីដែលយើងដកហូតពីអាណាធិបតេយ្យហ្នឹង ឲ្យតែសម្បទានសង្គមកិច្ចពិតប្រាកដ ...**។

ពិធីបិទមហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេស សមាគមអតីតយុទ្ធជនកម្ពុជា,
ថ្ងៃទី ២១ មិថុនា ឆ្នាំ ២០១០

... ការផ្តល់ដីសម្បទានសង្គមកិច្ចដល់អតីតយុទ្ធជន ត្រូវតែបន្តធ្វើក្នុងល្បឿនលឿនជាងពេលមុន។ ក្រសួងអភិវឌ្ឍន៍ជនបទដែលដឹកនាំដោយ ឯកឧត្តម ជា សុផារ៉ា កំពុងតែខិតខំជំរុញនៅទិសខាងជើង និងទិសពាយ័ព្យរបស់ប្រទេស ... ឥឡូវកំពុងធ្វើនៅតាមព្រំដែននៃខេត្តព្រះវិហារ ជំរុញចូលបន្ទាយមានជ័យ ហើយនៅខាងម៉ាឡៃ ប៉ៃលិនស្អីៗ ... ផ្នែកខាងក្រៅ ក៏ដូចផ្នែកខាងក្នុង គឺត្រូវធ្វើកិច្ចការនេះ ដោយល្បឿនលឿន ជាងពេលមុនដោយសារ តែលទ្ធភាពរបស់យើងក៏ខ្ពស់ជាងពេលមុនដែរ ... **ដីសម្បទានសង្គមកិច្ចពាក់ព័ន្ធជាមួយអតីតយុទ្ធជន ឬយុទ្ធជនពិការ គឺមិនរង់ចាំអ្វីទាំងអស់ ត្រូវធ្វើក្នុងក្របខណ្ឌផែនការរបស់យើង ឆ្នាំ ២០១០-២០១៣ ហើយគ្រប់ខេត្ត-ក្រុងទាំងអស់ ត្រូវពិនិត្យនូវកិច្ចការនេះ ឲ្យបានហ្មត់ចត់** ... ផ្ទៀងផ្ទាត់ដោយក្រសួងការពារជាតិ មហាផ្ទៃ ជាមួយនិងក្រសួងសង្គមកិច្ច ក្រសួងសេដ្ឋកិច្ច ថាតើអ្នកណាខ្លះសមនឹងទទួលដីនោះ ...។

៥. ធានារ៉ាប់រងសង្គមសំរាប់ជនពិការ ប្រសើរជាងជំនួយបែបមនុស្សធម៌

ទិវាជនពិការកម្ពុជាលើកទី ១៤ និង ទិវាជនពិការអន្តរជាតិលើកទី ៣០,
ថ្ងៃទី ០៣ ធ្នូ ២០១២

... **ពេលអ្នកផ្តល់ជំនួយមនុស្សធម៌ជកខ្លួនថយ សេវាធានារ៉ាប់រងតាមបែបមនុស្សធម៌ ត្រូវរក្សានិរន្តភាព ដំណើរការខាងផ្នែកពិការនេះ មិនត្រូវបានបោះបង់ ហើយអសកម្មភាពដែរទេ ... ត្រូវជំរុញចរិតជាប្រព័ន្ធធានារ៉ាប់រងសង្គម សំរាប់ជនពិការ ប្រសើរជាងការរង់ចាំជំនួយតាមបែបមនុស្សធម៌**។ ខ្ញុំកំពុងគិតថា ប្រសិនបើស្ថានភាពរបស់ខ្ញុំ (ប្រែប្រួល)ទៅ ទីកន្លែងមួយចំនួននឹងត្រូវទទួលឧបសគ្គតិចឬច្រើន ព្រោះមួយខែៗ ខ្ញុំកំពុងរ៉ាប់រងនូវមណ្ឌលកុមារកំព្រា និងជនពិការមួយចំនួន ដោយថវិកានៃក្រុមគ្រួសាររបស់ខ្ញុំ ... យើងត្រូវការនូវការផ្លាស់ប្តូរមួយ ដើម្បីធានាថា ថ្ងៃក្រោយអត់ពីយើងទៅ ទីកន្លែងទាំងនោះ មិនត្រូវខកខាននូវដំណើរការទាំងស្រុង ឬផ្នែកណាមួយនោះទេ ...។

៦. គំនិតផ្តើមបង្កើត និងពង្រាយមជ្ឈមណ្ឌលអភិវឌ្ឍន៍សម្រាប់យុទ្ធជនពិការ

សម្ពោធមជ្ឈមណ្ឌលអភិវឌ្ឍន៍យោធិនពិការ សម្តេចតេជោ ហ៊ុន សែន គូលេន ៣១៧ សៀមរាប, ថ្ងៃទី ៣១ កក្កដា ២០១១

... **ការរស់នៅត្រឹម ២ នាក់ប្តីប្រពន្ធ មិនចំណោទទេ ប៉ុន្តែនៅពេលដែលមានកូន ហើយកូននោះធំឡើងទៅទៀត តើការពឹងពាក់របស់ពួកគេអាស្រ័យទៅលើអ្វី? នេះជាចំណុចចាប់ផ្តើមនៃការពិចារណា។** បន្ទាប់ពីនោះ **យើងក៏បានចាប់ផ្តើមរៀបចំមានឡើងនូវការពង្រាយ និងរៀបចំមជ្ឈមណ្ឌលអភិវឌ្ឍន៍របស់យើងដោយចាប់ផ្តើមពីតាកែនកោះស្លា** ... ខ្ញុំបានសាកសួរយុទ្ធជនពិការ ... អ្នកខ្លះមានរហូតដល់ចៅទៅទៀត។ ការដោះស្រាយចំពោះយុទ្ធជនពិការ និងគ្រួសារ វាមិនលំបាកប៉ុន្មានទេ ក៏ប៉ុន្តែអត់ពីឪពុកម្តាយតើកូននេះបានអ្វី? ដូច្នេះហើយ បានជាយើងផ្តួចផ្តើមគំនិតទាក់ទងនឹងការអភិវឌ្ឍជំហានដំបូងនៅឯតាកែនកោះស្លា ... ដែលបានក្លាយ ទៅជាមជ្ឈមណ្ឌលប្រមូលផ្តុំមានទាំងសាលារៀនថ្នាក់បឋម អនុវិទ្យាល័យ និងវិទ្យាល័យ ...។

៧. ផ្តល់អាហារូបករណ៍រៀនសូត្រជូនជនពិការ

សម្ពោធភូមិ កុមារអរុណរះទី ៣ ភូមិស្មាច់ដែង សង្កាត់រាម ខណ្ឌព្រៃនប់ ខេត្តព្រះសីហនុ, ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១២

... ពួសូមធានាចំពោះមុខក្មួយៗ ចំពោះបងស្រី ហ៊ីរ៉ូល ឌីនខក្ស ចំពោះសប្បុរសជនទាំងឡាយថា **ពេលណាក្មួយៗ រៀនចប់បាក់ឌុប ពួសន្យាផ្តល់អាហារូបករណ៍មហាវិទ្យាល័យសម្រាប់ក្មួយ១ចៅៗ រៀនឲ្យចប់មហាវិទ្យាល័យ។ នៅពេលចប់បរិញ្ញាបត្រហើយ បើក្មួយ ១ចៅៗណា ចង់បន្តទៀត ពួផ្តល់អាហារូបករណ៍បន្តឲ្យទៀត។** ... កន្លងទៅ ខ្ញុំឲ្យទើបតែបាន ១៥ នាក់ទេ។ (គិតថា)ក្នុង ១ ឆ្នាំ ជាប់បាក់ឌុប ២០ ឬ ៣០ នាក់ ... នៅទីនេះ ក៏មានសាខាសាកលវិទ្យាល័យ នៅខេត្តសៀមរាប នៅខេត្តកណ្តាល ក៏មានសាខាសាកលវិទ្យាល័យ នៅភ្នំពេញក៏មានសាកលវិទ្យាល័យ ... បន្ទាប់ពីនោះ យើងពិនិត្យពីលទ្ធភាពផ្តល់ការងារធ្វើ ... នេះជាការបង្កើតឱកាស ហើយត្រូវចេះប្រើប្រាស់ឱកាសនេះ ដើម្បីកសាងអនាគត ...។

៨. ធានាសុវត្ថិភាពដល់កុមារ និងសាលាតាមមជ្ឈមណ្ឌលកុមារកំព្រា គ-ថ្លង់

សម្ពោធភូមិកុមារ SOS ក្រចេះ, ថ្ងៃទី ១៨ មករា ២០១៣

... ទទួលយកនូវសំណូមពររបស់លោក ស៊ីដា ថាខូល ដែលបានលើកឡើងពីសុវត្ថិភាពរបស់កុមារ ដែលមិនមែនគ្រាន់តែទាក់ទិនជាមួយនឹងកុមារនៅទីនេះទេ គឺទាក់ទងនៅគ្រប់ទីកន្លែងទាំងអស់។ **រាជរដ្ឋាភិបាលដាក់ចេញគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ... អាជ្ញាធរមូលដ្ឋានមានការកិច្ច ពិនិត្យឃ្លាំមើលជាប្រចាំ ដើម្បីធានាសុវត្ថិភាពដល់កុមារដែលនៅទីនេះ និងកន្លែងដទៃទៀត ... ត្រូវយកចិត្តទុកដាក់ពីសុវត្ថិភាព ក្នុងក្របខណ្ឌ ទូទាំងប្រទេស មិនអាចធ្វើឱ្យមានការថ្លោះធ្លាយណាមួយកើតឡើងទេ ...**។

៩. ទិន្នន័យ អំពីយុទ្ធជន ជាការចាំបាច់

បិទមហាសន្និបាតតំណាងសមាគមអតីតយុទ្ធជនកម្ពុជាទូទាំងប្រទេសលើកទី ២, ថ្ងៃទី ០២ កញ្ញា ២០១៥

... សមាគមមានបណ្តាញពីលើរហូតទៅដល់ក្រោម ... សមាជិក /ជិកា ភាគច្រើន ធ្វើការជាមួយនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ និងតាមស្ថាប័ន ... ដូច្នេះ **ការមានទិន្នន័យក្នុងដៃអំពីអតីតយុទ្ធជន ដែលមានភាពក្រីក្រលំបាកជាការចាំបាច់ ដើម្បីយើង ដោះស្រាយឲ្យចំគោលដៅ អ្នកណាមុន អ្នកណាក្រោយ។ មុននេះ លក្ខន្តិកៈសមាគម មានតែផ្នែកយោធាទេ ប៉ុន្តែឥឡូវមានទាំងកងទ័ព និងមានទាំងនគរបាលរួមបញ្ចូលគ្នា ... ចំណុចដែលគួរឲ្យសោកស្តាយ (គឺ)យើងរកឃើញនូវអតីតយុទ្ធជនដែលជួបការលំបាក នៅមិនឆ្ងាយប៉ុន្មានពីកន្លែងលោកខេត្ត ពីកន្លែងលោកស្រុក** ហើយក៏នៅមិនឆ្ងាយពីកន្លែងនគរបាល ឬកន្លែងកងទ័ព ឬអាវុធហត្ថនោះទេ។ នេះជារឿងដែលត្រូវរំលឹក។ ត្រូវចុះឲ្យបានជិតទៅនឹងពួកគាត់ ... ដែលហៅថាពិការភាពហើយ ត្រូវការជំនួយ។ គាត់មិនអាចរកអ្នកណាបាន អញ្ចឹងគឺសំដៅមករកយើង។ កុំឲ្យគាត់មករកយើងដល់ផ្ទះ យើងទៅរកគាត់ ...។

១០. ព្រមានសកម្មភាព កេងប្រវ័ញ្ចលើញើសឈាម និងទុក្ខលំបាករបស់យុទ្ធជន

ពិធីប្រារព្ធខួបលើកទី ៤ ទិវាអតីតយុទ្ធជនកម្ពុជា, ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១១

... វាបានផ្តល់ភាពអវិជ្ជមាន ទាក់ទងនឹងការទៅបើកប្រាក់ច្រើនដងមិនបានថាអស់លុយ អញ្ចឹងក៏លក់(សៀវភៅបន្ទុកគោលរបប)។ ហើយលក់ហ្នឹងលក់ទៅណា? បើតាមយើងធ្វើការអង្កេត លក់ឲ្យមន្ត្រីសង្គមកិច្ចហ្នឹងតែម្តង។ បញ្ហានេះអត់ត្រូវមានទៀតទេ។ ថ្ងៃក្រោយនឹងចាប់ខ្លួនហើយ។ **សូមព្រមានជាសាធារណៈ ... មន្ត្រីសង្គមកិច្ច ដែលមួយចំនួនណានោះធ្វើសកម្មភាពលើញើសឈាម និងទុក្ខលំបាករបស់យុទ្ធជនពិការ អតីតយុទ្ធជន ឬនិវត្តជន ... អង្គភាពប្រឆាំងអំពើពុករលួយបានរកឃើញគ្រប់ទិដ្ឋភាពអស់ហើយ ... អ្នកដែលបានទិញរបបគោលនយោបាយរបស់អតីត យុទ្ធជន ឬនិវត្តជន បញ្ជូនមកម្ចាស់ដើមវិញ** (រំលឹកករណីអ្នកស្លាប់ស្រាប់តែនៅរស់ ឈ្មោះ ចាន់ អូន)។ ... ថាពីមុនចុះ គេមិនដឹង។ ឥឡូវស៊ើបអង្កេតបានដឹងអស់ហើយ តែយើងមិនទាន់បានប្រើប្រាស់វិធានការ ចាប់ខ្លួននោះទេ។ ឥឡូវឃើញកំណែទំរង់បានដើរទៅមុខ តាមរយៈនៃការបើកផ្តល់តាមធនាគារ ... គ្នាប្រាក់វាតិចទៅហើយ មកចុះមកឡើងយូរពេកទៀត។ ត្រូវធ្វើម៉ូច(អោយ)សេវានេះបានល្អ ...។

១១. នយោបាយឈ្នះ-ឈ្នះ បញ្ចប់សង្គ្រាម លែងមានយុទ្ធជនពលី និងពិការ

សម្ពោធមជ្ឈមណ្ឌលអភិវឌ្ឍន៍យោធិនពិការ សម្តេច តេជោ ហ៊ុន សែន គូលេន ៣១៧ សៀមរាប, ថ្ងៃទី ៣១ កក្កដា ២០១១

... **ជាកំព្ងសំណាងរបស់ប្រទេសយើង ដែលបានបញ្ចប់សង្គ្រាម តាមរយៈនយោបាយឈ្នះ/ឈ្នះ** កាលពីឆ្នាំ **១៩៩៨។ ខ្ញុំប៉ាន់ប្រមាណថា បើយើងមិនបានបញ្ចប់ សង្គ្រាមផ្ទៃក្នុងដោយខ្លួនឯង ពីចុងឆ្នាំ ១៩៩៨ រហូតមកដល់បច្ចុប្បន្ននេះ សង្គ្រាមបន្ត ក្នុងរយៈពេលប្រមាណជា ១៣ ឆ្នាំ សួរថា តើអ្នកស្លាប់ និងអ្នកបួសមានប៉ុន្មានទៀត? ហើយវាមិនមែន គ្រាន់តែបញ្ហាយុទ្ធជន ឬបញ្ហារាជរដ្ឋាភិបាលទេ ក៏ប៉ុន្តែ ប្រជាពលរដ្ឋកម្ពុជាខ្លួនឯង ក៏អាចដឹងអំពីតម្លៃនៃសន្តិភាព និងការបង្រួបបង្រួមជាតិ ដែលយើងរកបានដោយលំបាកលំបិន និងដែលចាំបាច់ត្រូវការ**

ការ ... គ្រាន់តែយើងកើតសង្គ្រាមជាយដែនជាមួយថៃ ក៏មានយុទ្ធជនពលី និងយុទ្ធជនពិការមួយចំនួនទៀត។ សង្គ្រាមមិនមែនជាជម្រើសល្អសម្រាប់ពលរដ្ឋទេ វិធីបញ្ចប់សង្គ្រាមនៅកម្ពុជាតាមរយៈនយោបាយឈ្នះ/ឈ្នះ បានផ្តល់លទ្ធភាពអោយយើងអាចមកអង្គុយជុំគ្នានៅទីនេះ ...។

១២. បង្ការការស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ មីន/គ្រាប់មិនទាន់ផ្ទុះ និងការងារ

ទិវាជនពិការកម្ពុជាលើកទី ១៤ និងទិវាជនពិការអន្តរជាតិលើកទី ៣០ និង ពិធីបើកសិក្ខាសាលា ស្តីពីការដាក់បញ្ចូលពិការភាព ក្នុងការអភិវឌ្ឍការផ្សព្វផ្សាយរបាយការណ៍ពិភពលោក ស្តីពីពិការភាព និងអនុសញ្ញា ស្តីពីសិទ្ធិជនពិការ, ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២

... យើងមានជនពិការមកចូលរួមនៅទីនេះរាប់ពាន់នាក់ និងមានជនពិការរាប់ម៉ឺននាក់ នៅទូទាំងប្រទេស ... ប្រសិនបើមួយថ្ងៃៗ ពិការភាពចេះតែកើតមាននោះ (វានឹង)បន្ថែមបន្ទុកដ៏ធ្ងន់ធ្ងរពីលើទៀត។ នេះជាស្ថានភាពមួយ ដែលអាចថាមានចំណុចខុសគ្នាជាមួយនឹងជំងឺអេដស៍។ ... **អ្នកដែលកើតមានជំងឺអេដស៍ថ្មី មានចំនួនតិចតួច បើប្រៀបធៀបជាមួយនឹងអ្នកស្លាប់ទៅ។ ជនពិការមានអត្រាតិចតួចទេ ដែលស្លាប់ ប៉ុន្តែក្នុងមួយថ្ងៃៗ ចេះតែកើន។ កន្លែងខ្លះយើងអាចបញ្ចៀសបាន ជាពិសេស គឺផ្នែកគ្រោះថ្នាក់ចរាចរនេះតែម្តង។ បញ្ហាជនពិការ(តម្រូវអោយមានការ)ដោះស្រាយជាប្រចាំ អត់អាចប្រើពាក្យថា លុបបំបាត់នូវស្ថានភាពពិការបានទេ ... គ្រោះថ្នាក់ចរាចរណ៍ធ្វើឲ្យមនុស្សពិការ បូកបន្ថែមទៅដោយគ្រាប់មីន និងកាកសំណល់មិនទាន់ផ្ទុះ។** ... សូមអំពាវនាវយ៉ាងទទូច សុំស្រឡាញ់ជីវិតរូបកាយខ្លួនឯង នៅពេលដែលខ្លួនបើកបរ។ ក្នុងមួយប៉ប្រិចភ្នែក អាចធ្វើឲ្យខ្លួនឯងស្លាប់ ឬអាចធ្វើឲ្យអ្នកដទៃស្លាប់បាន ឬអាចធ្វើឲ្យអ្នកដទៃពិការបាន ... **យើងត្រូវរកគ្រប់វិធីរាប់ទាំងប្រព័ន្ធការងារត្រូវធានាយ៉ាងណា កុំឲ្យមានមនុស្សគ្រោះថ្នាក់ដោយសារការងារ** ...។

១៣. ចាត់ចែងទីតាំងវត្តភ្នំ ជាកន្លែងសំដែងតន្ត្រីជនពិការ

ទិវាជនពិការកម្ពុជាលើកទី ១៨ និងទិវាជនពិការ អន្តរជាតិលើកទី ៣៤,ថ្ងៃទី ០៦ ខែធ្នូ

ឆ្នាំ ២០១៦

... ខ្ញុំសូមផ្តល់ទីកន្លែងមួយ សម្រាប់ឲ្យមានការសំដែង ហើយចាត់ចែងរៀបចំ ទៅ គឺទីតាំងវត្តភ្នំ។ កន្លែងហ្នឹងគឺជាតំបន់ដែល មានការរៀបរយ។ យកកន្លែងហ្នឹង ជាកន្លែងសំដែងនៃក្រុមធំ ដែលមានឧបករណ៍គ្រប់គ្រាន់។ ខ្ញុំអំពាវនាវមើលក្រុម ណា(សិល្ប:ជនពិការ)ដែលអាចចូលជាមួយគ្នាបាន យើងនឹងគិតគូរបន្តអំពី បញ្ហានេះ ... បើសិនជានាំគ្នាបំបែក(ជាច្រើនក្រុម)អញ្ចឹង តើឲ្យរាជរដ្ឋាភិបាល ទៅរកកន្លែងណា(អោយសំដែង)? ... អ្នកខ្លះចែកផលប្រយោជន៍គ្នាមិនស្មើ ទៅ បែកគ្នាជាក្រុម។ ជួយមួយអត់មួយវាមិនកើត។ ខ្ញុំសូមអំពាវនាវឲ្យមានការគិតគូរ ឡើងវិញអំពីបញ្ហានេះ មិនមែនតម្រូវការគ្រាន់តែការដោះស្រាយ ពីសំណាក់រាជ រដ្ឋាភិបាល ពីអាជ្ញាធរតែមួយមុខទេ ... មានពាក្យចចាមអារាមថា ហាក់ដូចជាមាន សញ្ញាថា មានអ្នកនៅពីក្រោយខ្នង ប្រើប្រាស់បងប្អូនជនពិការធ្វើអាជីវកម្ម ... សូម ក្ជយ។ អ្នកចម្រៀង អ្នកភ្លេងនៃជនពិការ កុំក្លាយជាឧបករណ៍អ្នកនៅពីក្រោយ ខ្នង។ ត្រូវម្ចាស់ការ។ ពួនឹងតាមមើលការរៀបចំជាមួយអភិបាលក្រុង និងក្រសួង សង្គមកិច្ច ...។**

សាធារណការ និងដឹកជញ្ជូន

១	កសាងផ្លូវ/ស្ពាន ជំហានគីង្គក់	២២១
២	ការតភ្ជាប់ជាចំណុចអាទិភាពនៃរាជរដ្ឋាភិបាល	២២១
៣	ការតភ្ជាប់ផ្ទៃក្នុងកម្ពុជា សមាហរណកម្មអាស៊ាន មហាអនុតំបន់មេគង្គ	២២២
៤	បង្កើនហេដ្ឋារចនាសម្ព័ន្ធ ឆ្លើយតបនឹងកំណើនជីវភាពប្រជាជន	២២២
៥	កសាងផ្លូវថ្មីតាមស្តង់ដាកំណើនចរាចរ និង ជួសជុលផ្លូវជាប្រចាំ	២២៣
៦	រកហិរញ្ញប្បទាន ចាក់កៅស៊ូផ្លូវលំជនបទ	២២៤
៧	ដំណាក់កាលផ្លូវលំក្រាលកៅស៊ូ	២២៤
៨	លៃងមានការរារាំងដោយសង្គ្រាម ដោយគ្មានផ្លូវ/ស្ពាន	២២៥
៩	តម្លៃនៃការធ្វើផ្លូវ និងស្ពានត្រូវបូកបន្ថែមគម្រោងដោះមីន	២២៥
១០	ចក្ខុវិស័យហេដ្ឋារចនាសម្ព័ន្ធ/ស្ពាន ទន្លេមេគង្គ និងទន្លេបាសាក់	២២៦
១១	មានស្ពានឡឹបាសា រាជរដ្ឋាភិបាលកម្ពុជា/ជប៉ុន ជួនប្រាក់ជាប្រចាំ	២២៦
១២	អត្ថប្រយោជន៍តភ្ជាប់ត្រីទិស នៃការតភ្ជាប់ដោយស្ពានឡឹបាសា	២២៧
១៣	ត្រូវពិនិត្យសមត្ថភាពក្រុមហ៊ុន ដែលសូមវិនិយោគលើផ្លូវថ្នល់	២២៨
១៤	វិធានការចំពោះក្រុមហ៊ុនដែលដឹកលើសចំណុះ	២២៨
១៥	យានយន្តតន្ត្រេង និងប្រើប្រាស់មិនត្រូវតាមបច្ចេកទេស	២២៩
១៦	កម្ពុជានឹងមានកំពង់ផែពហុបំណង សម្រាប់ប្រើក្នុងការខ្ជងប្រេង	២២៩
១៧	ពង្រឹងសមត្ថភាពកំពង់ផែ ផ្លូវដែក សម្រាប់ការនាំចេញនាំចូលទំនិញ	២៣០
១៨	ការដឹកជញ្ជូនធ្ងន់ ត្រូវធ្វើតាមផ្លូវដែក	២៣០
១៩	រួមគ្នាគោរពច្បាប់ចរាចរណ៍ សង់ផ្លូវកាន់តែច្រើន តែមិនកើនគ្រោះថ្នាក់	២៣១
២០	បិទផ្លាកសុវត្ថិភាពដោយឥតគិតថ្លៃ និងចែកជូនដល់ផ្ទះ	២៣១
២១	ករណីឡានចង្កូតស្តាំ ហាមនាំចូល ត្រូវបង់ពន្ធ មិនបាច់ដូរចង្កូត	២៣២
២២	អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ជានយោបាយត្រឹមត្រូវសំរាប់អភិវឌ្ឍប្រទេស	២៣២

១. កសាងផ្លូវ/ស្ពាន ជំហានគីង្គក់

ពិធីបើកការដ្ឋានសាងសង់ផ្លូវជាតិលេខ ៥៥, ថ្ងៃទី ០៤ ឧសភា ២០១៥

... អ្នកខ្លះបង្ហាប់ជំហានគីង្គក់ហ្នឹងវាយឺត ... ក៏ប៉ុន្តែជំហានគីង្គក់បច្ចុប្បន្ននេះ មួយផ្លោត (បាន)១៨២ គីឡូម៉ែត្រ បើគិតជាយោជន៍ជិត ២០០ យោជន៍។ ម៉េចទៅមួយយោជន៍ ?មើលទៅក្តោងច្រមុះហ្នឹង គេថាមួយយោជន៍ហើយ។ ធ្វើព្រឹបឲ្យហើយថ្ងៃហ្នឹង គឺមិនបានទេ ព្រោះវាទាមទារនូវការឈូសឆាយ វាទាមទារត្រូវធ្វើគ្រឹះរឹងមាំ ទើបវាអាចធ្វើបាន។ ខុសពីលោក ឡុង ប៉ូ ទៅស្នើខ្ញុំព្រះករុណាខ្ញុំ ធ្វើអកិបាលក្រុង ៣ ខែ ធ្វើអោយដូចហ្ស៊ីណែរ ... ជាការជាក់ស្តែង មានលុយរួចរាល់អស់ហើយ ក៏(ផ្លូវនេះ)ត្រូវការ(ពេល) ៤២ ខែ ... សូមឯកឧត្តម ត្រាំ អ៊ីវ៉ាគីក ប្រមូលស្ពានដែកទុក ចាត់ចែងចែកចាយនៅក្នុងខេត្តនេះផង ឬទៅខេត្តដទៃផង ទៅធ្វើកូនស្ពានឆ្លងព្រែកតូចៗ។ ស្ពានដែកហ្នឹង ក៏ទិញពីចិនមកដែរ ...។

២. ការតភ្ជាប់ជាចំណុចអាទិភាពនៃរាជរដ្ឋាភិបាល

ពិធីបើកការដ្ឋានស្តាបនាឡើងវិញ ផ្លូវជាតិលេខ ៥៦ ចាប់ពី ក្រុងសិរីសោភ័ណ្ឌ ខេត្ត
បន្ទាយមានជ័យ ដល់ក្រុងសំរោង ខេត្តឧត្តរមានជ័យ ប្រវែង ១១៣ គីឡូម៉ែត្រ, ថ្ងៃទី
០៧ មិថុនា ២០១២

... យើងកំពុងធ្វើការតភ្ជាប់ ហើយការតភ្ជាប់នេះ គឺជាចំណុចអាទិភាពនៃនយោបាយរបស់រាជរដ្ឋាភិបាល ហើយក៏ស្ថិតនៅក្នុងក្របខ័ណ្ឌជាអាទិភាពនៃការអភិវឌ្ឍក្នុងមហាអនុតំបន់មេគង្គ ដែលធនាគារអភិវឌ្ឍន៍អាស៊ីគាំទ្រ បន្ថែមលើនោះ ក៏ជាអាទិភាពនៅក្នុងសមាហរណកម្មរបស់អាស៊ានឆ្នាំ ២០១៥។ ធនាគារអភិវឌ្ឍន៍អាស៊ី បានយកចិត្តទុកដាក់លើបញ្ហាការតភ្ជាប់នេះ ហើយមិនគ្រាន់តែជាបញ្ហាផ្ទៃក្នុងរបស់កម្ពុជាសុទ្ធសាធនោះទេ តែបានជួយតភ្ជាប់ជាមួយប្រទេសជិតខាង ទាំងនៅព្រំដែនជាមួយវៀតណាម ទាំងជាមួយថៃ ដើម្បីបង្កលក្ខណៈឲ្យមានលំហូរពាណិជ្ជកម្ម និងទេសចរណ៍ទៅមករកគ្នា ...។

៣. ការតភ្ជាប់ផ្ទៃក្នុងកម្ពុជា សមាហរណកម្មអាស៊ាន មហាអនុតំបន់មេគង្គ

ពិធីបើកការដ្ឋានស្ថាបនាឡើងវិញ ផ្លូវជាតិលេខ ៥៦ ចាប់ពី ក្រុងសិរីសោភ័ណ្ឌ ខេត្ត បន្ទាយមានជ័យ ដល់ក្រុងសំរោង ខេត្តឧត្តរមានជ័យ ប្រវែង ១១៣ គីឡូម៉ែត្រ, ថ្ងៃទី ០៧ មិថុនា ២០១២

... **បានបើកការដ្ឋានសម្រាប់ការតភ្ជាប់ពីផ្ទៃកខាងត្បូង មានផ្លូវលេខ ៥៧B ផ្លូវលេខ ៥៩ និងផ្លូវលេខ ៥៧** ដែលតភ្ជាប់ រវាងបាត់ដំបង និងប៉ៃលិន (ដែលផ្លូវជាតិ) ៥៧B និង ៥៩ មកដល់បន្ទាយមានជ័យ។ ថ្ងៃនេះ បើកការដ្ឋានតភ្ជាប់ពីបន្ទាយមានជ័យ ទៅឧត្តរមានជ័យ។ កាលពីខែមេសា ក៏បានតភ្ជាប់ពីព្រំដែនថៃចូលទៅក្រឡាញ់ ហើយយើងមានផ្លូវឡើងទៅអន្លង់រ៉ែង ភ្ជាប់ទៅព្រះវិហារ និងភ្ជាប់ពីប្រាសាទព្រះវិហារ ទៅទីរួមខេត្តព្រះវិហារមកកំពង់ធំ ហើយយើងមានផ្លូវពីព្រះវិហារកាត់ទៅស្ទឹងត្រែង ដែលខ្ញុំព្រះករុណាខ្ញុំ ទៅបើកការដ្ឋានកាលពីថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១២ នេះ។ មានន័យថា បើយើងមិននិយាយពីនិរតីទេ គឺយើងកំពុងភ្ជាប់ឧត្តរ និងឦសាន។ យើងមានផ្នែកនិរតី ដែលបានតភ្ជាប់ចាប់ពីកោះកុង ក្រុងព្រះសីហនុ កំពត ព្រៃកចាក ចូលដល់រៀតណាម។ **ជាការតភ្ជាប់ មួយជុំវិញប្រទេស ... នេះមិនគ្រាន់តែជាការរួមចំណែកតភ្ជាប់ផ្ទៃក្នុងកម្ពុជា និងការតភ្ជាប់(កម្ពុជា)ជាមួយប្រទេសជិតខាងប៉ុណ្ណោះទេ តែនៅបានជាការរួមចំណែកលើការធ្វើសមាហរណកម្មអាស៊ាន និងមហាអនុតំបន់មេគង្គ ធ្វើឲ្យប្រទេសកម្ពុជាអាចតភ្ជាប់ជាមួយនឹងប្រទេសជិតខាង ហើយប្រទេសជិតខាងក៏អាចតភ្ជាប់ជាមួយនឹងកម្ពុជាវិញផងដែរ ...**។

៤. បង្កើនហេដ្ឋារចនាសម្ព័ន្ធ ឆ្លើយតបនឹងកំណើនជីវភាពប្រជាជន

ពិធីបើកការដ្ឋានស្ថាបនាស្ពានអាកាស ៧ មករា ស្ពុបពេទ្យលោកសង្ឆ,
ថ្ងៃទី ២៩ ធ្នូ ២០១០

... បើសិនជាប្រទេសមិនមានការអភិវឌ្ឍ ហើយស្ថានភាពវាស្ថិត(ក្នុងស្ថានភាព)បែបឆ្នាំ ១៩៧៩ ឬ អាចថា មុនឆ្នាំ ១៩៩០ ដែលពេលនោះរថយន្តរបស់យើងក៏តិច ម៉ូតូក៏តិច កង់ក៏តិច វាមិនមានតំរូវការចាំបាច់ ដើម្បីនឹងពង្រីកផ្លូវ

ហើយរហូតដល់ធ្វើស្ពានអាកាសនោះទេ។ **ដោយមានការរីកចំរើននៃជីវភាពរបស់យើង ក្នុងនោះធ្វើឲ្យចំនួនយានយន្ត ទាំងរថយន្ត និងទោចចក្រយានយន្ត កើនឡើងយ៉ាងខ្លាំង។ ស្ថានភាពបែបនេះ តម្រូវឲ្យយើងប្រឹងប្រែង ដើម្បីរៀបចំបណ្តាញផ្លូវគមនាគមន៍ឲ្យកាន់តែប្រសើរឡើង រាប់ទាំងស្ពានអាកាសនេះផងដែរ ដើម្បីធានានូវសុវត្ថិភាព និងបំរើឲ្យចរាចរណ៍ ... តម្រូវការនៃការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ មិនគ្រាន់តែស្ពានអាកាស ឬក្រោមដីទេ ប៉ុន្តែផ្លូវថ្មីៗ ថែមទៀតនឹងត្រូវបានពង្រីក និងធ្វើបន្ថែម ដើម្បីឱ្យទីក្រុងរបស់យើងមានផ្លូវដឹកជញ្ជូនកាន់តែច្រើន រាប់ទាំងប្រព័ន្ធជុំវិញក្រុងផង ដើម្បីកាត់បន្ថយការកកស្ទះក្នុងក្រុង ...**។

៥. កសាងផ្លូវថ្មីតាមស្តង់ដាកំណើនចរាចរ និង ជួសជុលផ្លូវជាប្រចាំ

> បិទសន្និបាតសរុបការងារឆ្នាំ ២០១០ ក្រសួងសាធារណការ, រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១

... ខ្ញុំចង់បញ្ជាក់ចំណុចសំខាន់ ២ ... ទី១ ការកសាងផ្លូវថ្មីៗ យើងត្រូវគិតឲ្យច្បាស់ (ពីសេចក្តីត្រូវការដែលនឹងកើនឡើង) ... កាលពីក្នុងទសវត្សរ៍ ៩០ មានការគិតគូរថា កម្ពុជាមិនអាចរីកចម្រើនលឿនរហ័សទេ បានជាបន្តកសាង(ផ្លូវដែលមានទទឹង) ត្រឹមតែ ៦ ទៅ ៧ ម៉ែត្រ។ ការផ្តល់ជំនួយខ្លះ គឺបានមកត្រឹមប៉ុណ្ណឹង។ ឥឡូវ ផ្លូវទទឹង ៧ ម៉ែត្រហ្នឹងវាទៅលែងរួច (ជាហេតុនាំអោយ) យើងចាប់ពង្រីកផ្លូវដល់(ទទឹង) ១១ ម៉ែត្រ និងចាប់ពីគល់ស្ពានជ្រោយចង្វាររហូតដល់ផ្លូវកែងត្រូវពង្រីកដល់ ២ លីញទៅ ២ លីញមក (គឺមាន) ទទឹង ១៩ ម៉ែត្រ។ ពី(ភ្នំ-ពេញ)ទៅដល់ព្រៃកក្តាមក៏ត្រូវពង្រីកដល់ ២ លីញទៅ ២ លីញមកដែរ។ យើងត្រូវវាយតម្លៃឲ្យអស់ ដើម្បីថា ទោះបីជាយើងធ្វើបានខ្លីមែន ក៏យើងសង់វាត្រូវស្តង់ដាឲ្យហើយ ...។ ទី២ (ត្រូវធ្វើ)ការជួសជុល(ជាប្រចាំ) ... ខ្ញុំនិយាយរឿងនេះមិនតិចដងទេ រហូត(មានទាំង) ខ្ញុំដឹកនាំការប្រជុំគណៈរដ្ឋមន្ត្រីតាមឡាន Bus តាមផ្លូវជាតិលេខ ១ (ផង)។ រីឯផ្លូវជាតិលេខ ៥ វិញ បើកាលនោះ មិនសម្រុកឲ្យវិស្វកម្ម(យោធា)ធ្វើ អត់មានផ្លូវហ(ព្រះបរម)សារីរិកធាតុទេ ...។

៦. រកហិរញ្ញប្បទាន ចាក់កៅស៊ូផ្លូវលំជនបទ

ពិធីបិទសន្និបាទបូកសរុបការងារឆ្នាំ ២០១០ ក្រសួងអភិវឌ្ឍន៍ជនបទ, ២៩ ធ្នូ ២០១០

... យើងត្រូវប្រើប្រាស់ថវិការច្រើនក្នុងការជួសជុលផ្លូវលំ ... ឥឡូវឡានចុះទៅជនបទកាន់តែច្រើន ហើយមិនមែនដឹកស្រាលឯណា។ ឥឡូវគាត់ទៅដឹកស្រូវចេញពីស្រែ ហើយគ្រឿងសម្ភារៈសំណង់មួយចំនួន ដែលប្រជាពលរដ្ឋយើងសាងសង់នៅជនបទ ក៏គាត់ត្រូវការគ្រួស ខ្សាច់ ស៊ីម៉ង់ត៍ ដែក ក៏ដឹកធ្ងន់ដែរ។ អញ្ចឹងទេ ស្ថានភាពផ្លូវលំរបស់យើងជួបការលំបាក។ ... ក្រសួងពីរដែលធ្វើការងារហ្នឹង មានក្រសួងសាធារណការផង និងក្រសួងអភិវឌ្ឍន៍ជនបទផង។ ក្រៅពីហិរញ្ញប្បទានដែលយើងរកបានពីខាងក្រៅ យើងរុញហិរញ្ញប្បទានទៅការចាក់កៅស៊ូ (ផ្លូវលំ) មិនចាំបាច់ជាផ្លូវធំពេកទេ ព្រោះមិនមែនជាផ្លូវជាតិ។

៧. ដំណាក់កាលផ្លូវលំក្រាលកៅស៊ូ

ពិធីសម្ពោធ កំណាត់ផ្លូវជាតិលេខ ៦២ (ផ្នែកខាងត្បូង) ពីថ្នល់បែកផ្លូវជាតិ ៦ ខេត្តកំពង់ធំ ដល់ក្រុងព្រះវិហារ ខេត្តព្រះវិហារ ប្រវែង ១២៨ គីឡូម៉ែត្រ ក្រោមកម្ចីឥណទាន ពី សាធារណរដ្ឋប្រជាមានិតចិន, ០៨ សីហា ២០១២

... នៅខេត្តកំពង់ធំ ក្នុងគំរោងអភិវឌ្ឍជនបទ ដែលហិរញ្ញប្បទានដោយធនាគារអភិវឌ្ឍន៍អាស៊ី និងសាធារណរដ្ឋកូរ៉េ ក៏នឹងសាងសង់ផ្លូវតភ្ជាប់ពីសំបូរព្រៃគុហ៍ ទៅស្រុកសណ្តាន់ជាផ្លូវលំចាក់កៅស៊ូ។ ឥឡូវ **យើងចូលដល់ដំណាក់កាលផ្លូវលំចាក់កៅស៊ូហើយ។ យើងអត់ទាន់បានស្នើសុំចិនទេ តែបើយើងពឹងតែធនាគារអភិវឌ្ឍអាស៊ី ឬសាធារណរដ្ឋកូរ៉េហាក់ដូចជាមិនគ្រប់។ ខ្ញុំគិតថា សុំឯកឧត្តម ត្រាំ អ៊ីវតឹក ឯកឧត្តម ស៊ុន ចាន់ថុល និងក្រសួងហិរញ្ញវត្ថុពិភាក្សាគ្នាមើល តើគួរសុំចិនមួយឆ្នាំប៉ុន្មានគីឡូម៉ែត្រលើផ្លូវលំចាក់កៅស៊ូឬទេ? យោងទៅលើការអភិវឌ្ឍន៍ ឃើញថាចិនមានបទពិសោធន៍ច្រើន**។ ប្រទេសចិនធំ និងមានប្រជាជនច្រើនជាងគេ ចិនមិនអាចគ្រប់គ្រងប្រទេសបានទេ បើចិនគ្មានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ សម្រាប់ការតភ្ជាប់រវាងតំបន់រដ្ឋបាលកណ្តាល ជាមួយនឹងបណ្តាខេត្ត

... សូមឯកឧត្តម ផាន គ័ងស៊ា មេត្តាកត់ត្រាទុកថា នេះជាគំនិតផ្តួចផ្តើមថ្មី ...។

៨. លែងមានការរារាំងដោយសង្ក្រាម ដោយគ្មានផ្លូវ/ស្ពាន

ពិធីសម្ពោធផ្លូវជាតិលេខ ៧៦, ២១ វិច្ឆិកា ២០១៦

... ស្ថានភាពតភ្ជាប់ និងការរៀបចំហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការអភិវឌ្ឍ ផ្តល់ឱកាសឲ្យយើងអភិវឌ្ឍនៅគ្រប់វិស័យទាំងអស់។ **ស្ថានភាពកាលពីពេលមុនពិបាកតភ្ជាប់រវាងខេត្តមួយ និងខេត្តមួយ រវាងខេត្តខាងក្រោម ជាមួយនឹងខេត្តខាងលើ តាមរយៈការខិតខំរួម រវាងរាជរដ្ឋាភិបាលកម្ពុជា និងប្រជាជនកម្ពុជា ក៏ដូចជាដៃគូអភិវឌ្ឍន៍ ពិសេសសាធារណរដ្ឋប្រជាមានិតចិន ផ្តល់ឱកាសឲ្យយើងបានតភ្ជាប់នូវដែនដីទាំងមូល ដែលមុននេះកាត់ផ្តាច់ជាកង់ៗ តាមរយៈការារាំងដោយសង្ក្រាម ការារាំងដោយគ្រាប់មីន ការារាំងដោយគ្មានផ្លូវ គ្មានស្ពាន** ... យើងបានតភ្ជាប់ជាគម្រោងឆ្នឹងរួចស្រេចទៅហើយ ពីបណ្តាខេត្តនៃភាគកណ្តាល មកកាន់ខេត្តភាគឦសាន ...។

៩. តម្លៃនៃការធ្វើផ្លូវ និងស្ពានត្រូវបូកបន្ថែមគម្រោងដោះមីន

ពិធីសម្ពោធកំណាត់ផ្លូវជាតិលេខ ៥៧B ប្រវែង ១៧៦ គីឡូម៉ែត្រ ក្រោមថវិកាកម្ចីសម្បទានពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន, ថ្ងៃ ១០ មីនា ២០១៤

... **នៅកម្ពុជារបស់យើង តម្លៃសាងសង់នៅកន្លែងណាក៏ដោយ គឺសុទ្ធតែបញ្ចូលនូវការដោះមីន និងបំផ្លាញចោលគ្រាប់មិនទាន់ផ្ទុះ នេះហើយជាផលវិបាកនៃសង្ក្រាម ដែលបានកើតឡើងនៅក្នុងទឹកដីកម្ពុជា នៅក្នុងអតីតកាល។ នៅប្រទេសដទៃ គម្រោង(សាងសង់ផ្លូវ) អាចកាត់បន្ថយចំណាយផ្នែកនេះ ដោយសារប្រទេសរបស់គេអត់មានសង្ក្រាម អត់មានគ្រាប់មិនទាន់ផ្ទុះ** ... សូម្បីតែធ្វើស្ពានឆ្លងកាត់ទន្លេមេគង្គ ក៏យើងត្រូវរុករកគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះនោះនៅបាតទន្លេ។ យើងប្រើប្រាស់អង្គភាពដោះមីន មកធ្វើការនៅទីនេះ ជាការហ្វឹកហាត់ មុនបញ្ជូនទៅលីបង់ នៅស៊ូដង់ និងនៅប្រទេសម៉ាលី ...។

១០. ចក្ខុវិស័យហេដ្ឋារចនាសម្ព័ន្ធ/ស្ពាន ទន្លេមេគង្គ និងទន្លេបាសាក់

ពិធីសម្ពោធផ្លូវជាតិលេខ ៩ ស្ទឹងត្រែង-ត្បែងមានជ័យ និងស្ពានមិត្តភាពកម្ពុជា-ចិន មេគង្គស្ទឹងត្រែង, ថ្ងៃទី ១ មេសា ២០១៥

... នៅខាងក្រោមបន្តពីស្ពាន(មិត្តភាពកម្ពុជាចិនស្ទឹងត្រែង)នេះ ក្រៅពីស្ពានសេកុងនៅខាងលើ យើងមានស្ពានមេគង្គនៅខាងក្រោម។ មុនទៅដល់ស្ពានមេគង្គព្រែកតាមាក់ **ត្រូវមានស្ពាន ២ បន្ថែមទៀត ដែលមានស្ថិតនៅក្នុងគម្រោងនៃការសាងសង់ គឺ (១) ស្ពានឆ្លងកាត់ទន្លេមេគង្គ នៅទីរួមខេត្តក្រចេះ** ដើម្បីតភ្ជាប់ជាមួយនឹងបណ្តាញផ្លូវទៅកាន់ខេត្តកំពង់ធំ ដែលមានចំងាយជិតបំផុត (២) **បន្ទាប់ទៅយើងត្រូវធ្វើស្ពានមួយទៀត នៅចន្លោះស្រុកស្ទឹងត្រង់ និងស្រុកក្រូចឆ្មារបស់ខេត្តកំពង់ចាម** ដែលទាញយើងឲ្យកាន់តែកៀក កាន់តែជិត ហើយជាផលចំណេញសម្រាប់បងប្អូនប្រជាពលរដ្ឋ ... ឱកាសនេះ ខ្ញុំក៏សូមដាក់ចេញនូវចក្ខុវិស័យមួយចំនួនទៀត សម្រាប់គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកម្ពុជាបន្ថែម ... **ជាចក្ខុវិស័យនៅតាមដងទន្លេបាសាក់ យើងត្រូវការសង់ស្ពានពីរទៀត មួយនៅស្ពាង ... និងមួយទៀតនៅចំណុចព្រែកថ្មី ឬកំពង់កុង។ ខ្ញុំក៏គិតថា នៅតាមព្រែកដៃទន្លេនានា ទាំងខាងទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ ត្រូវតែមានស្ពានបេតុង ដូចជាស្ទឹងពោធិសាត់ ស្ទឹងសង្កែ ស្ទឹងមង្គលបុរី ស្ទឹងសែនជាដើម ... ខ្ញុំរំពឹងថា នឹងមានស្ពានពីរកាត់ទន្លេសាប និងទន្លេរមេគង្គ ដែលនឹងបម្រើអោយរថភ្លើងឆ្លងកាត់ ...**។

១១. តាមរយៈស្ពានឡឹបាសា រាជរដ្ឋាភិបាលកម្ពុជា/រដ្ឋាភិបាលជប៉ុន ជូនប្រាក់ជាប្រចាំ

ពិធីបើកការដ្ឋានសាងសង់ស្ពានអ្នកលឿង ថ្ងៃទី ១២ កុម្ភៈ ២០១១ និងពិធីចាក់បេតុងភ្ជាប់មុខតំណចុងក្រោយ នៃស្ពានអ្នកលឿង ឡឹបាសា ថ្ងៃទី ១៤ មករា ២០១៥

... តំណាងឲ្យភាពត្រេកអររបស់ប្រជាជនទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលចង់មានស្ពានឆ្លងទន្លេមួយមានសុវត្ថិភាព ជំនួសឲ្យការឆ្លងសាឡាង ដែលជួបការលំបាក ត្រូវបង់ថ្លៃ និងពេលខ្លះត្រូវស្ទះចរាចរណ៍ ពេលខ្លះក៏រហូតទៅដល់ ៧/៨ ម៉ោង ពិសេសក្នុងពេលចូលឆ្នាំ ឬបុណ្យភ្ជុំបិណ្ឌ។ ថ្ងៃនេះ **ការគិតទុករបស់យើង**

បានឈានមកដល់ការបើកការដ្ឋានមួយសម្រាប់ការសាងសង់ ... ទិដ្ឋភាពសេដ្ឋកិច្ចសង្គមរបស់ប្រជាជនកម្ពុជា នឹងមានការផ្លាស់ប្តូរសកម្មភាពយ៉ាងឆាប់រហ័ស នៅពេលដែលស្ពាននេះបានកសាងហើយ ... ខ្ញុំព្រះករុណាខ្ញុំក៏នឹងមានឱកាសមកចូលរួមសម្ពោធ បើទោះបីមិនធ្វើនាយករដ្ឋមន្ត្រី ... មានស្ពាននេះឆ្លងពេលណា (ប្រៀបដូចជា)រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជារដ្ឋាភិបាលជប៉ុន បានបើកផ្តល់ប្រាក់ឲ្យបងប្អូនជាប្រចាំ។ ពីដើមធ្លាប់បង់ថ្លៃឆ្លងសាឡាង ឥឡូវប្រជាជនជប៉ុនបានជួនមក តាមរយៈរាជរដ្ឋាភិបាលកម្ពុជា បានបង់ឲ្យប្រជាពលរដ្ឋ ...។

១២. អត្ថប្រយោជន៍តភ្ជាប់ត្រីទិស នៃការតភ្ជាប់ដោយស្ពានឡឿបាសា

ពិធីបើកការដ្ឋានសាងសង់ស្ពានអ្នកលឿង ថ្ងៃទី ១២ កុម្ភៈ ២០១១

... ស្ពាន(អ្នកលឿង) មានអត្ថប្រយោជន៍តភ្ជាប់ មិនមែនទ្វេទិសទេ គឺត្រីទិសៈ ទី ១ **ការតភ្ជាប់សមាហរណកម្មផ្ទៃក្នុងខ្លួនឯងរវាងត្រើយខាងកើត និងខាងលិច** ឬរវាង ខេត្តកណ្តាល និងខេត្តព្រៃវែង ដែលខ្ញុំព្រះករុណាខ្ញុំ ធ្លាប់និយាយថា អភិ-វឌ្ឍន៍ខាងលិច មិនភ្លេចខាងកើត ... ទី ២ **ជាផ្នែកមួយនៃផ្លូវតភ្ជាប់សមាហរណកម្ម ក្នុងមហាអនុតំបន់មេគង្គ និងក្នុងក្របខណ្ឌអាស៊ាន ដែលហៅថា ច្រករបៀងសេដ្ឋកិច្ចខាងត្បូង ឬហៅថាកើតលិច** ដែលមានការតភ្ជាប់រវាងផ្លូវជាតិលេខ ១ ទៅផ្លូវជាតិលេខ ៥ ហើយតភ្ជាប់ទីក្រុងធំៗ ៣ នោះគឺ ទីក្រុងហូជីមិញ ទីក្រុងភ្នំពេញ និងទីក្រុងបាងកក ដោយយើងស្ថិតនៅក្នុងចន្លោះកណ្តាល។ បើនិយាយឲ្យលើសពីនេះបន្តិច វាមិនមែនគ្រាន់តែក្នុងក្របខណ្ឌនៃអនុតំបន់មេគង្គ ឬអាស៊ានទេ ក៏ប៉ុន្តែ វាជា Highway អាស៊ី ដែលចងភ្ជាប់ទៅដល់ប្រទេសទួរគីឯណោះ ក្នុងផែនការនៃប្រព័ន្ធបណ្តាញដឹកជញ្ជូនក្នុងក្របខណ្ឌអាស៊ីបូព៌ា ... ទី ៣ ... ជា**ការតភ្ជាប់រវាងប្រជាជនកម្ពុជា និងប្រជាជនជប៉ុន** បន្ទាប់ពីការតភ្ជាប់នៅឯស្ពានគីហ្សូណា ឆ្នាំ ២០០១ ជា**ការតភ្ជាប់ក្នុងទំនាក់ទំនងរវាងប្រជាជនកម្ពុជា និងប្រជាជនជប៉ុនតែម្តង** ...។

១៣. ត្រូវពិនិត្យសមត្ថភាពក្រុមហ៊ុន ដែលសូមវិនិយោគលើផ្លូវថ្នល់

សង្គ្រាមថា, សម្តេចកំណាត់ផ្លូវជាតិលេខ ៥ និងលេខ ៦ និងស្ពានលូលើកំណាត់ផ្លូវជាតិ លេខ ៥៦ លេខ ៦៨ ក្រោមកម្មវិធីសម្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី, ខេត្តសៀមរាប, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៩

... (កំណាត់ផ្លូវជាតិលេខ ៥ និង ៦ នេះ) មានក្រុមហ៊ុនមួយចំនួន ដែលអាចថា ជាក្រុមហ៊ុនធ្វើនំអត់ម្សៅ ឬក៏ក្រុមហ៊ុនបោកប្រាស់ បានមកបំផើមយើងចោល ... វាជាមេរៀនដែលមន្ត្រីក្រសួងសាធារណការ ឬក៏ផ្នែកពាក់ព័ន្ធដល់ការវិនិយោគ នានាត្រូវចាំ និងមិនត្រូវបណ្តែតបណ្តោយឲ្យស្ថានការណ៍នេះ កើតឡើងសាជាថ្មីទៀតទេ។ រាប់ទាំង**គម្រោងសាងសង់ស្ពានជ្រោយចង្វារ ២ មានការលើកសំណើសុំធ្វើ BOT ហើយជាក់ឥណទានរហូតដល់ ៥៨ លានដុល្លារឯណោះ ក្នុងពេលដែលយើងបានសុំឲ្យភាគីចិនផ្តល់ទឹកប្រាក់ ... និងការសិក្សាដោយក្រុមហ៊ុនរបស់ចិនកំពុងចាប់ផ្តើម ... រឿងដែលគួរឲ្យចង់សើចនៅត្រង់ថា ក្រុមហ៊ុនធ្វើនំអត់ម្សៅមួយចំនួន (បានរហូតដល់)ស្នើថា បើ(បាន)ធ្វើផ្លូវហ្នឹង សុំយកភ្នំប៉ុន្មានកន្លែងទៀតឯណោះ... រឿង BOT យើងលើកទឹកចិត្តហើយ ប៉ុន្តែត្រូវមើលសមត្ថភាពក្រុមហ៊ុននោះអោយមែនទែន ...**។

១៤. វិធានការចំពោះក្រុមហ៊ុនដែលដឹកលើសចំណុះ

ពិធីតភ្ជាប់ស្ពានព្រែកក្តាម, ខេត្តកណ្តាល, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៩

... សហការគ្នា បើក្រុមហ៊ុនណានៅតែបំពាន ត្រូវបិទក្រុមហ៊ុនហ្នឹងចោល ព្រោះដាក់ជញ្ជីងគ្មានបានការអីប៉ុន្មានទេ ឱ្យតែគេហុចលុយ(ក៏តាំង)ឱ្យទៅទៀត ... មានតែវិធីហ្នឹងទេ ដើម្បីធានាផ្លូវ-ស្ពាន ដើម្បីធានាសុវត្ថិភាពជូនប្រជាពលរដ្ឋ។ (បើ)លេងដឹក(សុទ្ធតែ) ៨០ គោននៅពីលើ បើវាបាក់ស្ពានគ្រឹបទៅ អ្នកណាជាអ្នកទទួលខុសត្រូវ? អ្នកបើកក៏គ្រោះថ្នាក់ អ្នកជិះក៏គ្រោះថ្នាក់ ហើយបង្ក(គ្រោះថ្នាក់)ដល់អ្នកដទៃ រួចហើយរាជរដ្ឋាភិបាលចេញលុយធ្វើ។ អញ្ចឹងទេ កុំនិយាយច្រើនទៀត កុំអង្គុយបក់ផ្សែង ដូចជារឿងស្ពត់ម៉ាស៊ីន ... ចាំតាមផ្លូវអត់បានការទេ ទៅខ្ជប់ការចេញពីរោងចក្រ ឬពីឃ្លាំង ដូចជាស៊ីម៉ង់ត៍ ឬក៏ដែកអីនេះ ...

កុំចាំយាត់តាមផ្លូវ គ្មានបានការទេ ... រឿងនេះប្រជាពលរដ្ឋដឹងមួយប្រទេស ...។

១៥. យានយន្តតទ្រុង និងប្រើប្រាស់មិនត្រូវតាមបច្ចេកទេស

ពិធីបិទសន្និបាតសរុបការងារឆ្នាំ ២០១០ របស់ក្រសួងសាធារណការ, ១៦ មិនា ២០១១

... យើងពិនិត្យមើល រឿងច្រំដែលវានៅហ្នឹង អាគ្រោះថ្នាក់ចរាចរណ៍ អាដឹកលើសទម្ងន់ អាបើកបរលើសល្បឿនកំណត់ អាកុងត្រូលជជុះ ឥឡូវនាំគ្នាធ្វើបានឬមិនបាន ... បើថា តទ្រុងចាប់ចូលមកកាត់ចោលបណ្តោយ កុំខ្ជីនិយាយច្រើន ពេលកាត់ហើយ ម្ចាស់ត្រូវសងលុយ បើមិនមក យកទាំងឡានតែម្តងទៅ។ ទៅពិនិត្យតាំងពីកន្លែងចេញដំណើរ កុំចាំបាច់ពិនិត្យតាមផ្លូវ បើតាមផ្លូវចាប់បានយកទៅកាត់ចោល ហើយអំពាវនាវតុលាការជួយគាំទ្រកាត់ក្តី អារឿងដឹកលើសចំណុះនេះ។ បើមើលឃើញថាសំបកកង់សឹកអស់ កុំឲ្យឡានចេញ។ ថ្ងៃមុន ខ្ញុំបានព្រមានបិទក្រុមហ៊ុន សូ ងួន (គាត់)សរសេរមកនាយករដ្ឋមន្ត្រី។ ខ្ញុំថាអរគុណហើយដែលបានកែប្រែនោះ តែអស់លោកត្រូវត្រួតពិនិត្យទៀត។ ហៅក្រុមដឹកជញ្ជូនទាំងអស់មកប្រជុំគ្នាជាក់កំណត់ ... រដ្ឋមន្ត្រីពាណិជ្ជកម្មចូលរួមផង ដើម្បីកំណត់ថា បើសិនជាអ្នកឯងមិនកែ ខ្ញុំនឹងដកអាជ្ញាប័ណ្ណ មិនឲ្យធ្វើអាជីវកម្មបន្ត ...។

១៦. កម្ពុជានឹងមានកំពង់ផែពហុបំណង សម្រាប់ប្រើក្នុងការខ្ជងប្រេង

ពិធីសំណេះសំណាលជា កម្មករ កម្មការិនី បុគ្គលិក មន្ត្រីកំពង់ផែស្វយ័ត ក្រុងព្រះសីហនុ, ១ ឧសភា ២០១៦

... ឯកឧត្តម ស៊ុន ចាន់ថុល បានលើកឡើងរួចហើយ គឺជប៉ុនបានឲ្យខ្ជីលុយពង្រីកជាបន្តបន្ទាប់។ ឥឡូវបានឈានដល់ដំណាក់កាលដែលត្រូវគិតគូអំពីការបន្ថែមនៅក្រោយឆ្នាំ ២០២០។ **ឯកឧត្តម លូ គឹមឈុន បានយកផែនការមកទៅរាយការណ៍ឲ្យខ្ញុំ អំពីការបន្ថែមដែលយើងត្រូវរកទុន ... ជប៉ុនគេបានសិក្សាហើយ ដើម្បីពង្រីកយ៉ាងម៉េចអីយ៉ាងម៉េច ហើយថ្ងៃក្រោយយើងមានកំពង់ផែរបស់យើងនៅទីនេះ ដែលហៅថាកំពង់ផែពហុបំណង ដើម្បីផ្គត់ផ្គង់សម្រាប់ការខ្ជងប្រេងនៅក្នុងប្រទេសរបស់យើង។ ឥឡូវនេះ សម្រាប់ការខ្ជងប្រេង យើងប្រើ**

ប្រាស់(សេវា)ពីប្រទេសជិតខាង ដូចជាចេញមកពីថៃ និងចេញមកពីវៀតណាម។ ប៉ុន្តែនៅពេលខាងមុខ ត្រូវចេញដំណើរមកពីខាងកម្ពុជាតែម្តង ដើម្បីផ្តត់ផ្គង់ឲ្យតំបន់ខ្ពង់ប្រេងទាំងឡាយរបស់ប្រទេសកម្ពុជា ...។

១៧. ពង្រឹងសមត្ថភាពកំពង់ផែ និងផ្លូវដែក សម្រាប់ការនាំចេញនាំចូលទំនិញ

ពិធីសំណេះសំណាលជាកម្មករ កម្មការិនី បុគ្គលិក មន្ត្រីកំពង់ផែស្វយ័ត ក្រុងព្រះសីហនុ, ១ ឧសភា ២០១៦

... ការនាំចេញនាំចូលរបស់យើងកាន់តែច្រើន ដូច្នេះ ត្រូវពង្រឹងសមត្ថភាពកំពង់ផែនេះ ពង្រឹងសមត្ថភាពផ្លូវដែក។ (សម្រាប់)ការដឹកជញ្ជូនតាមផ្លូវដែកអំពាវនាវចំពោះប្រជាពលរដ្ឋ(អោយប្រើរថភ្លើង)។ ខ្ញុំដិះហើយ។ មានអ្នកសួរថាធ្វើដំណើរប៉ុន្មានម៉ោង? ក្រុមឆ្លើយតប (តាមហ្វេសប៊ុក) នៃក្រសួងសាធារណការបានឃើញឆ្លើយថា ៧ ម៉ោង។ ខ្ញុំឆ្លើយផ្ទាល់ថែមថា ក្នុងពេលនេះ ៧ ម៉ោង ប៉ុន្តែកំពុងរកវិធីឲ្យមកនៅ ៥ ម៉ោង ... អាចធ្វើដំណើរងាយស្រួល ទាំងអ្នកធ្វើដំណើរក៏មានសុវត្ថិភាព អត់រវល់នឹងរឿងស្ទះចរាចរណ៍អីទេ ... ផ្លូវដែកនេះ បានធ្វើសកម្មភាពយ៉ាងមមាញឹកមុនឆ្នាំ ១៩៧០ ប៉ុន្តែបន្ទាប់ពីរដ្ឋប្រហារមក គឺផ្លូវដែកត្រូវបានកាត់ផ្តាច់ដោយសង្គ្រាម។ ជំនាន់ ប៉ុល ពត ដំណើរការ ដល់ក្រោយ ប៉ុល ពត ថ្ងៃណាក៏រ៉ែគ្នា រ៉ែដាច់រទេះភ្លើង ... ឥឡូវអត់មានសង្គ្រាមអីតទៅទៀតទេ ...។

១៨. ការដឹកជញ្ជូនធ្ងន់ ត្រូវធ្វើតាមផ្លូវដែក

វេទិកាស្រូវអង្ករកម្ពុជា លើកទី ៥, ២៥ មករា ២០១៦

... បញ្ហាដែលគួរឲ្យត្រូវយកចិត្តទុកដាក់ នៅត្រង់ថា ការដឹកជញ្ជូន(ទំនិញដែល)ធ្ងន់ហួស តម្រូវឲ្យគិតគូរ (ពីការ)បង្វែរទៅកាន់ការដឹកជញ្ជូនតាមផ្លូវរថភ្លើងវិញ សម្រាប់បម្រើឲ្យការនាំចេញ និងការដែលត្រូវនាំចូលអាធ្ងន់ៗ ជារ៉ែក ជាស៊ីម៉ង់ត៍ ... បញ្ហានេះក៏ត្រូវគិតឲ្យបានហ្មត់ចត់ជាមួយហ្នឹងការបង្វែរទិស ធ្វើការជាមួយក្រុមហ៊ុនដឹកជញ្ជូន ដើម្បីឲ្យគេផ្ទេរបណ្តើរៗ ដើម្បីទៅកាន់ការដឹកជញ្ជូនតាមផ្លូវដែក ... ឥឡូវផ្លូវដែករបស់យើងបានដំណើរការហើយ ត្រូវបង្វែរទិសទៅកាន់ការដឹកជញ្ជូនតាមផ្លូវដែក តម្រង់ឆ្ពោះពីភ្នំពេញទៅកាន់ក្រុងព្រះសីហនុ និង

ពីក្រុងព្រះសីហនុមកកាន់ទីក្រុងភ្នំពេញ ទៅលើមុខទំនិញមួយចំនួន។ ខ្ញុំមិនថាទាំងអស់នោះទេ ...។

១៩. រួមគ្នាគោរពច្បាប់ចរាចរណ៍ សង់ផ្លូវកាន់តែច្រើន តែមិនកើនគ្រោះថ្នាក់

ពិធីបើកការដ្ឋានសាងសង់ឡើងវិញផ្លូវជាតិលេខ ២១ (តាខ្មៅ-ជ្រៃធំ), ២៨ មីនា ២០១៦

... សូមអំពាវនាវប្រជាពលរដ្ឋរបស់យើង មេត្តាគោរពច្បាប់ចរាចរណ៍ ហើយបើសិនជាមិននឹកទៅដល់ច្បាប់ចរាចរណ៍ទេ ក៏សូមគិតថា គោរពជីវិតរបស់ខ្លួន ទុកជីវិតរបស់ខ្លួនកុំឲ្យស្លាប់ដោយសារការបើកបរ ការធ្វើដំណើរដោយយានយន្ត ដោយមិនគោរពច្បាប់ចរាចរណ៍។ **ត្រូវនឹកគិតថា មិនគួរត្រូវក្លាយខ្លួនជាជនពិការ ឬរបួសស្នាម ដោយសារតែការជិះម៉ូតូ ឬបើកឡានទេ។ សូមមេត្តាគោរពជីវិតខ្លួនឯង និងជីវិតរបស់អ្នកដទៃ។ បើធ្វើដូច្នេះបាន ការសាងសង់ផ្លូវកាន់តែច្រើន នឹងមិនបង្កើតនូវការគ្រោះថ្នាក់សម្រាប់ប្រជាជននោះទេ** ... ឥឡូវនេះ ដោយសារតែមានផ្លូវល្អ និងចំនួនយានយន្តកើនឡើង បានជាមានគ្រោះថ្នាក់ចរាចរណ៍ ...គួរឲ្យភ័យខ្លាចណាស់ ដែលអ្នកធ្វើដំណើរមិនគិតពីសុវត្ថិភាពផ្ទាល់ខ្លួន ...។

២០. បិទផ្លាកសុវត្ថិភាពដោយឥតគិតថ្លៃ និងចែកជូនដល់ផ្ទះ

ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ ៤៤ ដែលតភ្ជាប់រវាងច្បារមន ឌ៉ាល់ អមលាំង ឧត្តុង្គ ទៅដល់ផ្លូវជាតិលេខ ៥, ០២ សីហា ២០១៦

... ដោយប្រជាជនយើងពិបាកហៅស្លាកចំណាំង សូមហៅថា ស្លាកសុវត្ថិភាពចុះ ព្រោះយើងធ្លាប់ហៅថា "ខ្សែក្រវាត់សុវត្ថិភាព" យើងហៅ ពាក់មួកសុវត្ថិភាព ... **ថ្ងៃនេះ ដើម្បីដោះស្រាយបញ្ហាការធ្វើចរាចរណ៍ពេលយប់ (ដែល)គ្រោះថ្នាក់កើតឡើងពេលឡានវ៉ាគ្នា ឬឡានមើលមិនឃើញដោយសារតែគោយន្ត ឬរ៉ឺម៉ក ឬរថយន្ត ឬរទេះ ដែលមិនមានស្លាកចំណាំងផ្លាត ... ឥឡូវយើងចាប់ផ្តើមបើកយុទ្ធនាក្នុងការបិតស្លាកសុវត្ថិភាពចំនួន ៣ លាន ៤ សែន ស្លាក ... ប្រគល់ឲ្យអាជ្ញាធរខេត្ត ក្រុមការងាររបស់រាជរដ្ឋាភិបាល ចុះតាមបណ្តាខេត្ត រួមចំណែកចែកដល់ផ្ទះ កុំដាក់កន្លែងមួយ ហើយឲ្យប្រជាជនមកយក** ... ទៅបិតឲ្យគាត់តែ

ម្តង ... សុំប្រជាពលរដ្ឋយល់ឲ្យច្បាស់ តិចមានអ្នកណាយកទៅលក់ឲ្យ ប្រជាពលរដ្ឋ ...។

២១. ករណីឡានចង្កូតស្តាំ ហាមនាំចូល ត្រូវបង់ពន្ធ មិនបាច់ដូរចង្កូត

សម្ពោធដាក់ដំណើរការស្ពានអាកាសតិចណូ ឬស្ពានអាកាស ៥ មករា, ០៥ មករា ២០១៦

... ចូលដល់បញ្ហាឡានចង្កូតស្តាំ ... សំណើ(របស់) ឯកឧត្តម ប៉ា សុជាតិវង្ស បានធ្វើតាំងពីថ្ងៃទី ៣០ ខែ ធ្នូ ... ចូលដល់ថ្ងៃទី ៤ (មករា) ឆ្នាំ ២០១៦ ផ្ញើទៅ ឧបនាយករដ្ឋមន្ត្រី សុខ អាន ... ប៉ុន្តែ ដោយសារ ខ្ញុំព្រះករុណាខ្ញុំ មកទីនេះ ក៏ អោយយកលិខិតមក ហើយចារ និងចាំចេញ ស.ជ.ណ តាមក្រោយ។ ត្រូវដោះ ស្រាយបញ្ហានេះ តាមវិធី **ទី១. ហាមនាំចូលបន្តទៀត មិនថាតែអ្នកនៅកន្លែងនេះ ឬត្រង់ណាទេ អត់អោយយកចូលមកទៀតទេ ... ទី២. អនុញ្ញាតអោយចូលមកបង់ ពន្ធ និងផ្តល់ភាពស្របច្បាប់ចំពោះរថយន្តចង្កូតស្តាំដែលកំពុងមាននៅកម្ពុជា**។ បងប្អូនដែលនៅក្នុង ៤០០ គ្រឿង ជារថយន្តដឹកដីអីនោះ សូមចូលមកបង់ពន្ធ ហើយអាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធត្រូវផ្តល់ភាពស្របច្បាប់ដូចគេឯង, **ទី៣. បង ប្អូនសំណូមពរថា កុំចាំបាច់ដូរចង្កូត។ ឯកភាព មិនបាច់ដូរចង្កូត ព្រោះ(ការ)ដូរ ចង្កូតនេះ គ្រោះថ្នាក់ជាង(បើកទាំងចង្កូត)ស្តាំហ្នឹងទៀត។ នេះជាកាដូសម្រាប់ ថ្ងៃ ៧ មករា ...**។

២២. អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ជានយោបាយត្រឹមត្រូវសម្រាប់អភិវឌ្ឍប្រទេស

ពិធីសម្ពោធផ្លូវជនបទ(ក្រាលកៅស៊ូ និងបេតុង) និងបើកការដ្ឋានផ្លូវប្រវែង ១២០០ គីឡូម៉ែត្រ, ០២ វិច្ឆិកា ២០១៦

... នយោបាយហេដ្ឋារចនាសម្ព័ន្ធរបស់ខ្ញុំព្រះករុណាខ្ញុំ ក៏ដូចជារបស់គណបក្ស ប្រជាជន នៅជានយោបាយត្រឹមត្រូវបំផុតសំរាប់ការអភិវឌ្ឍប្រទេសជាតិឲ្យឈាន ឡើង។ ដើម្បីឲ្យកម្ពុជាអាចលូតលាស់ទៅបាន យើងត្រូវខិតខំធ្វើផ្លូវ ធ្វើស្ពាន។ ពី ដើម យើងធ្វើស្ពានដែកតូចៗ ឆ្លងព្រែក ដៃព្រែក ឥឡូវនេះ យើងចាប់ផ្តើមក បេតុង ... យើងធ្វើស្ពានឆ្លងកាត់ទន្លេមេគង្គ ទន្លេសេកុង ទន្លេសាប ទន្លេបាសាក់

... នយោបាយហេង្ការចនាសម្ព័ន្ធ ការតភ្ជាប់ផ្ទៃក្នុង នៅតែមានសារៈសំខាន់។ ឆ្លងកាត់តាមពេលវេលាមួយៗ ដំណាក់កាលមួយៗ យើងក៏បានកសាងឡើងនូវហេង្ការចនាសម្ព័ន្ធ ដឹកជញ្ជូនចាំបាច់របស់យើង ដែលមានទាំងស្ពាន ទាំងផ្លូវ។ ខ្ញុំព្រះករុណាខ្ញុំ នៅតែផ្តល់អាទិភាពទៅវិស័យ ៤ គឺ ទឹក ផ្លូវ ភ្លើង មនុស្ស ដោយពេលនេះ យកមនុស្សយកមកជាក់ពីមុខ(ជាលំដាប់ទីមួយនៃអាទិភាព) ...។

សុខាភិបាល

១	រកវិធីគ្រប់គ្រង និងព្យាបាល ជំងឺឆ្លងថ្មី	២៣៧
២	ហេដ្ឋារចនាសម្ព័ន្ធ រួមចំណែកជួយវិស័យសុខាភិបាល	២៣៧
៣	កាត់បន្ថយអត្រាមរណភាពមាតានិងទារក, ពង្រាយគ្រូពេទ្យឡើងវិញ	២៣៨
៤	គោលដៅបំបាត់ជំងឺមួយចំនួន ក្នុងចំណោមមាតា ទារក និងកុមារ	២៣៨
៥	ឈានទៅអត្រាសូន្យនៃជម្ងឺគ្រុនចាញ់ ឆ្នាំ ២០២៥	២៣៩
៦	ចលនាឱ្យប្រជាពលរដ្ឋប្រើមុងជ្រលក់ថ្នាំ	២៣៩
៧	ទប់ស្កាត់ជម្ងឺគ្រុនផ្តាសាយបក្សី	២៤០
៨	ពង្រាយការចាក់ថ្នាំបង្ការ អោយដល់ជនបទ (ទសវត្ស ១៩៨០)	២៤០
៩	ការគាំទ្រផ្នែកសុខាភិបាលសំរាប់ប្រជាពលរដ្ឋរស់នៅជាប់ព្រៃរព្រំដែន	២៤១
១០	ការបង្កើនក្របខណ្ឌ បុគ្គលិកសុខាភិបាល	២៤១
១១	គ្រប់គ្រងគ្រូពេទ្យឯកជនឲ្យបានត្រឹមត្រូវ (ករណី ភូមិរកា)	២៤២
១២	តែងតាំងគ្រូពេទ្យឯកទេសចូលនិវត្ត ក្នុងមុខងារនយោបាយ	២៤២
១៣	ធានាសុវត្ថិភាពស្បៀងអាហារ និងអាហារូបត្ថម្ភ	២៤៣
១៤	គ្រូពេទ្យភាគច្រើន ជួយជីវិតមនុស្ស	២៤៣
១៥	ពង្រឹងក្រមសីលធម៌ និងគុណធម៌គ្រូពេទ្យ	២៤៤
១៦	ឱសថក្លែងក្លាយ និងគ្រូពេទ្យអត់ជំនាញ(គ្រោះថ្នាក់នៃការរំលូតកូន)	២៤៤
១៧	ការខ្វះចន្លោះជាបុគ្គល មិនមែនជាប្រព័ន្ធសុខាភិបាលទាំងមូលទេ	២៤៥
១៨	អនុវត្តស្តង់ដាអប់រំផ្នែកវេជ្ជសាស្ត្រ	២៤៥
១៩	ប្រសិទ្ធិភាព នៃសេវាសាធារណ ផ្នែកសេវាសុខាភិបាល	២៤៥
២០	ការបរិច្ចាកឈាម ស្រោចស្រង់ជីវិតមនុស្ស	២៤៦
២១	ការផ្តល់សេវាសុខាភិបាលដល់អ្នកទេសចរណ៍ និងអ្នកវិនិយោគ	២៤៧
២២	មិនអោយវិបត្តិសេដ្ឋកិច្ចពិភពលោក ប៉ះពាល់ចំណាយសុខាភិបាលទេ	២៤៧
២៣	ហាត់ប្រាណ បង្កើនសុខភាព ស្មារតីមិត្តភាព និងសាមគ្គីភាព	២៤៨

១. រកវិធីគ្រប់គ្រង និងព្យាបាល ជំងឺឆ្លងថ្មី

ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការមន្ទីរពេទ្យ រ៉ូយ៉ាល់ភ្នំពេញ, ភ្នំពេញថ្មី, សែនសុខ, រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤

... បញ្ហាសុខភាពនេះ បានក្លាយទៅជាប្រធានបទដ៏ធំ។ នៅកិច្ចប្រជុំណាក៏ដោយចុះ ការលើកឡើង ៣ សំខាន់ៃ គ្រោះមហន្តរាយធម្មជាតិ, ការប្រែប្រួលអាកាសធាតុ និងជំងឺឆ្លង ហើយចុងក្រោយនេះ មានជំងឺ អេបូឡា នៅអាហ្វ្រិកដែលយើងកំពុងរកវិធានការទប់ទល់។ **ប៉ុន្មានឆ្នាំមុន គ្រាន់តែមានជំងឺសារ, ជំងឺគ្រុនផ្តាសាយបក្សី ជំងឺផ្តាសាយជ្រូក ឥឡូវចេញដល់អេបូឡាទៀត ហើយមិនដឹងថាតើចេញអីបន្ថែមទៀត។ អញ្ចឹង ត្រូវរកវិធីគ្រប់គ្រង និងព្យាបាល** ...។

២. ហេដ្ឋារចនាសម្ព័ន្ធ រួមចំណែកជួយវិស័យសុខាភិបាល

ពិធីបិទសន្និបាតសុខាភិបាលលើកទី ៣៤ និង ពិនិត្យឡើងវិញរួមគ្នានូវសមិទ្ធផលសុខាភិបាលលើកទី ១១ , ថ្ងៃទី ២៨ មីនា ២០១៣

... **ត្រូវសិក្សាអំពីភូមិសាស្ត្រសុខាភិបាលនៅតំបន់នោះ។ យើងមិនអាចតម្រូវថា ១ ភូមិ ត្រូវតែមានមណ្ឌលសុខភាពមួយទៅរួចទេ។ ត្រូវសិក្សាតំបន់តាំងទីលំនៅថ្មីនេះ ប៉ុន្មានកន្លែង តំបន់ណា ដែលងាយដាក់ជាង ដែលយើងអាចថាជាប៉ុស្តិ៍សុខភាពសម្រាប់ជួយដល់ប្រជាពលរដ្ឋ។ បញ្ហាសុខាភិបាលនេះមិនមែននៅដាច់ដោយឡែកតែឯងទេ។ វានៅក្នុងចង្កោមនៃការអភិវឌ្ឍ។** យើងលើក ឧទាហរណ៍ មួយ ដូចជា**ការកសាងផ្លូវថ្នល់ ការកសាងស្ពាន មានចំណែកធំណាស់ជួយក្នុងវិស័យសុខាភិបាល។ ព្រោះអី?** បើសិនជាមានឡានពេទ្យហើយ មានឧបករណ៍ពេទ្យគ្រប់គ្រាន់ហើយ ប៉ុន្តែបើអត់ផ្លូវដឹកមកទេ តើពួកគាត់មកដល់មន្ទីរពេទ្យតាមរបៀបណាទៅ? ខ្ញុំធ្លាប់បាននិយាយហើយថា មានពេលខ្លះជំងឺ មិនសមស្លាប់ អាចស្លាប់បាន ដោយសារខ្វះផ្លូវ ខ្វះស្ពាន។ **រាជរដ្ឋាភិបាលត្រូវគិតអំពីបញ្ហានេះជាកញ្ចប់ មិនមែនត្រឹមតែប្រាក់ បៀវត្សរ៍បស់មន្ត្រីសុខាភិបាលទេ ប៉ុន្តែត្រូវតែសម្លឹងមើលព្រៃទាំងមូល** ...។

៣. កាត់បន្ថយអត្រាមរណភាពមាតា និងទារក, ក្រសួងត្រូវពង្រាយគ្រូពេទ្យឡើងវិញ

ពិធីបិទសន្និបាតសុខាភិបាលលើកទី ៣១ និងរួមគ្នាត្រួតពិនិត្យឡើងវិញនូវសមិទ្ធផលសុខាភិបាលលើកទី ០៨, ថ្ងៃទី ០២ មីនា ២០១០

... **ការកាត់បន្ថយអត្រាមរណភាពមាតា និងទារក បណ្តាលមកពីជំងឺចម្បងៗ ដូចជាអេដស៍ របេង ជំងឺគ្រុនចាញ់ និងជំងឺឆ្លង ដែលអាចការពារបាន ដោយការចាក់ថ្នាំបង្ការ ត្រូវការនូវធនធានមនុស្ស និងបរិក្ខារ**។ ខ្ញុំព្រះករុណាខ្ញុំ បានទៅភូមិមួយនៅតំបន់ ៣ ក្នុងអាងទន្លេសាបនៃខេត្តកំពង់ធំ ... ឥឡូវកសាងមន្ទីរពេទ្យរួចហើយ មិនដឹងថាបានពេទ្យពីណាទៅទៀត។ សំខាន់ដាក់ឆ្មបទៅមុន ដើម្បីឲ្យស្ត្រីរបស់យើងទទួលបាននូវសេវាផ្នែកឆ្មប ... **ក្រសួងសុខាភិបាលក៏ពង្រាយគ្រូពេទ្យឡើងវិញ ពេលនេះស្ថានភាពអំណោយផលពីការបញ្ចប់សង្គ្រាម។ សន្តិភាព ស្ថេរភាពនយោបាយ បង្កលក្ខណៈអនុគ្រោះច្រើនណាស់សម្រាប់គ្រូពេទ្យ** ... ក្នុងអំឡុងឆ្នាំ ១៩៩៧ ឬ ១៩៩៨ យើងមានអត្រាគ្រូពេទ្យ ៣០% បម្រើប្រជាជន ៧០% នៅជនបទ ឯគ្រូពេទ្យ ៧០% បម្រើប្រជាជន ៣០% នៅទីក្រុង។ តែស្ថិតិថ្មីបានពង្រាយគ្រូពេទ្យទៅកាន់ច្រើនកន្លែងហើយ ...។

៤. គោលដៅបំបាត់ជំងឺមួយចំនួន ក្នុងចំណោមមាតា ទារក និងកុមារ

ពិធីបិទសន្និបាតសុខាភិបាលលើកទី ៣១ និងរួមគ្នាត្រួតពិនិត្យឡើងវិញនូវសមិទ្ធផលសុខាភិបាលលើកទី ០៨, ថ្ងៃទី ០២ មីនា ២០១០

... សង្ឃឹមថា ដៃគូអភិវឌ្ឍន៍នឹងចូលរួម ដោយផ្តោតការ**យកចិត្តទុកដាក់ទៅលើការកាត់បន្ថយអត្រាមរណៈមាតា ទារក និងកុមារ ហើយឈានទៅលុបបំបាត់ជំងឺមួយចំនួន ដែលយើងបានដាក់ចេញជាគោលដៅ ... ក្នុងហ្នឹងជំងឺគ្រុនចាញ់ ត្រូវបញ្ចប់ឲ្យផុតរលត់នៅឆ្នាំ ២០២៥។ យើងធ្លាប់លុបបំបាត់ជំងឺគ្រុនស្វិតដៃ ជើងបានជោគជ័យរួចហើយ និងកំពុងបន្តលុបបំបាត់ជំងឺកញ្ជ្រិល និងតេតាណូសនៅឆ្នាំ ២០១២ ខាងមុខនេះ** ...។

៥. ឈានទៅអត្រាសូន្យនៃជម្ងឺគ្រុនចាញ់ ឆ្នាំ ២០២៥

> បិទសន្និបាតសុខាភិបាលលើកទី ៣១ និងរួមគ្នាត្រួតពិនិត្យឡើងវិញនូវសមិទ្ធិផលសុខាភិបាលលើកទី ០៨, ថ្ងៃទី ០២ មីនា ២០១០

... **កម្ពុជា ត្រូវបានប្រកាសថាបានបញ្ចប់ជម្ងឺគ្រុនស្វិតដៃជើងនៅឆ្នាំ ២០០២។ មកដល់ឆ្នាំ ២០១១ យើងបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រជាតិ សម្រាប់ការបំបាត់ជម្ងឺគ្រុនចាញ់នេះ នៅឆ្នាំ ២០២៥។** គិតពីពេលនេះទៅមានរយៈពេល ១៤ ឆ្នាំ ដែលត្រូវបញ្ចប់ស្ថានភាពជម្ងឺគ្រុនចាញ់ក្នុងប្រទេសយើង។ ពិតហើយ បើយោងលើផែនទីបង្ហាញអាចថា តំបន់ខ្លះពុំមានជម្ងឺគ្រុនចាញ់ទេ ដូចជា ភ្នំពេញ កណ្តាល ព្រៃវែង ស្វាយរៀង និងនៅតំបន់ខ្លះទៀត។ **ជាទូទៅ ជម្ងឺគ្រុនចាញ់នេះ បានថយច្រើនណាស់ទៅហើយ។ ប៉ុន្តែយើងត្រូវមានយុទ្ធនាការ និងសកម្មភាពប្រទាក់ក្រឡាគ្នា ដើម្បីធ្វើឲ្យជម្ងឺគ្រុនចាញ់ធ្លាក់ចុះ ហើយនឹងឈាន ទៅរកអត្រាសូន្យនៃជម្ងឺគ្រុនចាញ់នៅ ឆ្នាំ ២០២៥។ ខ្ញុំមានសុទិដ្ឋិនិយមថា ត្រឹមឆ្នាំ ២០២០ ឬ ២០២១ អាចថាអស់** ...។

៦. ចលនាឱ្យប្រជាពលរដ្ឋប្រើមុងជ្រលក់ថ្នាំ

> ពិធីបិទសន្និបាតសុខាភិបាលលើកទី ៣២ និងរួមគ្នាត្រួតពិនិត្យឡើងវិញនូវសមិទ្ធផលសុខាភិបាលលើកទី ០៩, ភ្នំពេញ, ១៥ មីនា ២០១១

... ឯខ្លួនខ្ញុំផ្ទាល់ មានជម្ងឺគ្រុនចាញ់តាំងពីអាយុ ១៨ ឆ្នាំឯណោះ។ ក្រោយមកទៅកន្លែង(ដែលមាន)គ្រុនចាញ់ វាអត់មានគ្រុនចាញ់ទៀតទេ។ មិនដឹងជាយ៉ាងម៉េចចម្លែកដែរ។ ប៉ុន្តែ ធ្លាប់គ្រុនចាញ់ម្តង។ ពេលជាប់គុកនៅឆ្នាំ ១៩៧៧ បានគ្រុនចាញ់យោងទេ បើកុំមានគ្រុនចាញ់ ប្រហែលជាជាប់គុកបានយូរជាងហ្នឹង ព្រោះពេលហ្នឹងរត់ចេញពី អាពត ទៅ។ ជាប់គុកសិនបាន ២២ ថ្ងៃដែរ ដល់មានជម្ងឺគ្រុនចាញ់គេយកទៅពេទ្យទៅ។ **ខ្ញុំមានជំនឿជឿជាក់ ដោយសារតែឥឡូវនេះ ស្ថានភាពរបស់យើង វាមិនដូចកាលពីពេលមុន ហើយស្ថានភាពយោសនាផ្សព្វផ្សាយ អំពីការប្រើមុងជ្រលក់ថ្នាំ បានដំណើរការមកយូរជ្រៃហើយ។ នេះ មិនមែនជារឿងថ្មីសម្រាប់យើងទេ ... បន្តសកម្មភាពដោយមានផែនទីចង្អុលផ្លូវសម្រាប់**

ដំណើរការទាំងអស់គ្នា ...។

៧. ទប់ស្កាត់ជម្ងឺគ្រុនផ្តាសាយបក្សី

ពិធីបិទសន្និបាតសុខាភិបាលលើកទី ៣៤ និងពិនិត្យឡើងវិញរួមគ្នានូវសមិទ្ធផលសុខាភិបាលលើកទី ១១ , ថ្ងៃទី ២៨ មីនា ២០១៣

... **ទាក់ទងជាមួយនឹងបញ្ហាគ្រុនផ្តាសាយបក្សីនេះ ក្រោយពេល ដែលយើងបានជួបនូវហេតុការណ៍ធ្វើអោយស្លាប់ដល់ជីវិតមនុស្ស យើងក៏បានចាប់ផ្តើមធ្វើយុទ្ធនាការក្នុងកម្រិតទ្រង់ទ្រាយធំមួយ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងតាមរយៈបណ្តាញរបស់យើង។ មកដល់ពេលនេះ មានការស្ងប់ស្ងាត់ ក៏ប៉ុន្តែកុំធ្វេសប្រហែសឲ្យសោះ។ និយាយរួម ត្រូវគ្រប់គ្រងស្ថានការណ៍នេះឲ្យជាប់ ... វាមិនមែនកើតនៅតែកម្ពុជាទេ ... ត្រូវតែបន្តការតាមដានការងារនេះតទៅទៀត** ... សូមថ្លែងអំណរគុណទៅដល់ក្បាលម៉ាស៊ីនឃោសនាទាំងអស់ ទាំងវិទ្យុ ទាំងទូរទស្សន៍ និងបណ្តាប្រព័ន្ធផ្សព្វផ្សាយជាសារព័ត៌មានក្តី ដែលបានជួយទៅដល់ការផ្សព្វផ្សាយនូវ spot ទាក់ទងជាមួយនឹងការអប់រំ អំពីគ្រុនផ្តាសាយបក្សីនេះ ...។

៨. ពង្រាយការចាក់ថ្នាំបង្ការ អោយដល់ជនបទ (ទសវត្ស ១៩៨០)

សៀវភៅ «ហ៊ុន សែន៖ ១០ ឆ្នាំ នៃដំណើរកម្ពុជា ១៩៧៩ - ១៩៨៩», ទំព័រ ៣១២

... ការប្រឆាំងនឹងជម្ងឺគ្រុនចាញ់ ជម្ងឺរាតត្បាត ជម្ងឺកូនក្មេង នៅជាបញ្ហាបច្ចុប្បន្ន ភាពមួយដែលត្រូវប្រយុទ្ធដោះស្រាយ។ ... **អត្រាស្លាប់នៃកុមារ ថ្នឹត្បិតតែបានកាត់បន្ថយ ប៉ុន្តែក៏នៅខ្ពស់នៅឡើយ។ ចលនាចាក់ថ្នាំការពារកុមារ ថ្នឹត្បិតតែមានយុទ្ធនាការធំៗ ជាច្រើន ដែលបំផុសដោយរដ្ឋាភិបាល និងក្រសួងសុខាភិបាល ដោយមានការជួយឧបត្ថម្ភពីអង្គការ អ៊ុយនីសេហ្ វ ផងក៏ដោយ ក៏ចលនានេះទើបតែមានការផុសផុលនៅទីក្រុងតែប៉ុណ្ណោះ។ ឯនៅជនបទធ្វើបានតិចតួចណាស់ ម្យ៉ាងដោយរដ្ឋខ្វះមធ្យោបាយ ខ្វះបុគ្គលិក ម្យ៉ាងទៀតដោយការអប់រំចំពោះ ប្រជាជនមិនបានល្អ ដែលជាហេតុធ្វើឲ្យគេមិនយកកុមារមកចាក់ថ្នាំការពារ។ កិច្ចការចាក់ថ្នាំការពារកុមារ យើងមានទុនជាបង្ហូរ សំខាន់គឺថ្នាំ** ។ អាស្រ័យដោយមានការជួយឧបត្ថម្ភពីអន្តរជាតិ ដូច្នេះ ត្រូវបន្តការងារនេះឲ្យបានខ្លាំងជាងនេះទៀត ដែលក្នុង

នោះត្រូវយកចិត្តទុកដាក់ដល់ការងារឃោសនាអប់រំក្នុងប្រជាជន ដោយដើរទន្ទឹមនឹងការចាត់តាំងអនុវត្ត ...។

៩. ការគាំទ្រផ្នែកសុខាភិបាល សំរាប់ប្រជាពលរដ្ឋរស់នៅជាប់ក្បែរព្រំដែន

ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការមន្ទីរពេទ្យជោរ, ភ្នំពេញ,
ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៤

... ជាមួយនឹងមោទនភាពដែលបានកើតឡើងនៅទីនេះ ក៏សូមយកឱកាសនេះ ថ្លែងអំណរគុណ **រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលបានជួយឧបត្ថម្ភគាំទ្រ តាមរយៈនៃការជួយព្យាបាលជំងឺដល់ប្រជាពលរដ្ឋកម្ពុជា នៅតាមមន្ទីរពេទ្យរបស់វៀតណាម ដោយមានកន្លែងខ្ជះ មិនយកប្រាក់ និងមានកន្លែងខ្ជះទៀត បង់ថ្លៃដូចប្រជាជនវៀតណាមដែរ គឺមិនយកថ្លៃតាមរបៀបជនបរទេសទេ ... ខ្ញុំព្រះករុណាខ្ញុំ បានធ្វើកិច្ចការនេះ ជាមួយនិងសាធារណៈរដ្ឋសង្គមនិយមវៀតណាម ជាមួយព្រះរាជាណាចក្រថៃ និងជាមួយសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវផងដែរ ដើម្បីសុំឲ្យមានការគាំទ្រផ្នែកវិស័យសុខាភិបាល សម្រាប់ប្រជាពលរដ្ឋដែលរស់នៅជាប់ក្បែរព្រំដែន** ព្រោះបើសិនជាប្រជាពលរដ្ឋនោះវិលត្រឡប់ចូលមកក្នុងផ្ទៃប្រទេស គឺមានចំងាយឆ្ងាយណាស់ ...។

១០. ការបង្កើនក្របខណ្ឌ បុគ្គលិកសុខាភិបាល

ពិធីប្រគល់សញ្ញាបត្រជូនដល់និស្សិតជ័យលាភីនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និងពិធីសម្ពោធអគារសិក្សាថ្មី នៃសាលាបច្ចេកទេសថៃទាំវេជ្ជសាស្ត្រ,
ថ្ងៃទី ១៥ មិថុនា ២០១១

... សូមបញ្ជាក់ថា **មានតែវិស័យ ២ ទេ ដែលបង្កើន ចំនួន(បុគ្គលិក)តាមរយៈជ្រើសរើសក្របខណ្ឌមិនឈប់ឈរ គឺសុខាភិបាល និងវិស័យអប់រំ។ វិស័យទាំង ២ នេះ ជាវិស័យដែលបង្កើនចំនួនរាប់ទាំងឆ្នាំ។ នៅឆ្នាំ ២០១០ ... ស្ថាប័ននានាមិនត្រូវបានអនុញ្ញាតឲ្យរើសក្របខណ្ឌទេ ដោយឡែកតែក្រសួងអប់រំ និងក្រសួងសុខាភិបាល (រាជរដ្ឋាភិបាលបាន)អនុញ្ញាតឲ្យរើសក្របខណ្ឌ ក្នុងមួយឆ្នាំ។ ជាង ៥០០០ នាក់ សម្រាប់ក្រសួងអប់រំ និងក្រសួងសុខាភិបាលជាង ១០០០ នាក់។**

ក្ជយៗ ខ្ះ បានរៀនហើយ តែគេកាត់បន្ថយការជ្រើសរើស ក៏មានបញ្ហា ហើយនាំគ្នាហែរទៅមុខផ្ទះខ្ញុំៗ ក៏សម្រេចឲ្យរើសបន្ថែមទៀតទៅ ព្រោះក្ជយៗបានរៀនហើយ តើយកទៅណាសុទ្ធតែកូនចៅរបស់យើង...។

១១. គ្រប់គ្រងគ្រូពេទ្យឯកជនឲ្យបានត្រឹមត្រូវ (ករណី ភូមិរកា)

ពិធីបិទសន្និបាតសុខាភិបាលលើកទី ៣៦, ថ្ងៃទី ១០ មីនា ២០១៥

... យើងកំពុងដំណើរការព្រមៗ ដោយម្ខាងរដ្ឋធ្វើ ឯម្ខាងទៀតផ្នែកឯកជនធ្វើ។ អ្វីដែលទាក់ទាញការយកចិត្តទុកដាក់ គឺនៅត្រង់ថា វិស័យឯកជនរាយប៉ាយតាមគ្រប់ភូមិសាស្ត្រ។ **ភូមិរកា ជាបញ្ហាធំណាស់ក្នុងការគ្រប់គ្រងក្រុមគ្រូពេទ្យ ដែលរាយប៉ាយនៅទូទាំងប្រទេស ... រឿងនេះជារឿងធំ ទាមទារទាំងអស់គ្នាត្រូវធ្វើការអោយហ្មត់ចត់។ អ៊ីវានារ៉ាអោយមានការចូលរួមពីប្រជាពលរដ្ឋ លើការព្យាបាលរបស់ពេទ្យផ្នែកឯកជនដែលមានទាំងរបៀបគ្លីនិក និងពេទ្យចល័ត។ ខ្មែរយើងមានទម្លាប់មួយ បើគេឲ្យលេបថ្នាំមិនសុខចិត្តទេ** ទាល់តែបានចាក់ ...។

១២. តែងតាំងគ្រូពេទ្យឯកទេសចូលនិវត្ត ក្នុងមុខងារនយោបាយ

ពិធីបិទសន្និបាតសុខាភិបាលប្រចាំឆ្នាំ លើកទី ៣៧, ថ្ងៃទី ១០ មីនា ២០១៦

... គ្រូពេទ្យឯកទេស ធម្មតារៀនច្រើនជាងវេជ្ជបណ្ឌិតធម្មតា តែពេលគាត់ចេញមកហួសអាយុបាត់ អត់ចូលធ្វើការបាន។ យើងផ្លាស់ប្តូរ និងបានចេញសេចក្តីសម្រេចហើយ ... យើងត្រូវការណាស់គ្រូពេទ្យឯកទេសហ្នឹង។ ដោយសារតែខ្ះគ្រូពេទ្យឯកទេសហើយ បានជាយើងតែងបញ្ជូន អ្នកជំងឺទៅព្យាបាលនៅខាងក្រៅ ... **ខ្ញុំប្រកាសបញ្ចូលជាស្វ័យប្រវត្តិតែម្តងទៅ... គ្រូពេទ្យឯកទេស ដល់អាយុ ៦០ ឆ្នាំ ចូលនិវត្ត ... គ្រូពេទ្យឯកទេសមួយចំនួនដែលចូលនិវត្ត យើងបានតែងតាំងមុខងារនយោបាយ ហើយគាត់ធ្វើការនៅមន្ទីរពេទ្យណាមួយបន្ត** ... ដូច្នេះយើង មិនខ្សោះឈាម។ ប្រឹងបណ្តុះបណ្តាលមកមិនទាន់បានប៉ុន្មាន ចូលនិវត្តអស់, ចូលក្របខណ្ឌមិនបាន ដោយសារលក្ខខណ្ឌអាយុ ...។

១៣. ធានាសុវត្ថិភាពស្បៀងអាហារ និងអាហារូបត្ថម្ភ

ពិធីបើកសិក្ខាសាលាផ្សព្វផ្សាយយុទ្ធសាស្ត្រជាតិ ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨, ១៨ សីហា ២០១៤

... **គ្រប់ក្រសួង-ស្ថាប័នមានសមត្ថកិច្ច ដែលបាននឹងកំពុងធ្វើការលើសុវត្ថិភាពចំណីអាហារ ត្រូវបង្កើនកិច្ចសហការគ្នា ឱ្យបានល្អប្រសើរ ដើម្បីធានាថាទាំងស្បៀងអាហារនាំចូល និងស្បៀងអាហារផលិតនៅក្នុងប្រទេសកម្ពុជា មានសុវត្ថិភាពខ្ពស់ និងគុណភាពល្អ ជៀសវាងគ្រោះថ្នាក់ដល់សុខភាពរបស់ប្រជាពលរដ្ឋ និងជាពិសេសការពារកុមារឱ្យចៀសផុតពីជំងឺ និងបញ្ហាកង្វះអាហារូបត្ថម្ភ**។ ចំណុចនេះ ក្រសួង-ស្ថាប័នពាក់ព័ន្ធ ចាំបាច់ត្រូវតែមានវិធានការលើការត្រួតពិនិត្យសុវត្ថិភាពស្បៀងអាហារ ចាប់តាំងពីការផ្គត់ផ្គង់ធាតុចូល ការផលិត ការកែច្នៃ ការស្តុកទុករហូតដល់ការប្រើប្រាស់។ ខ្ញុំធ្លាប់បានលើកច្រើនដងមកហើយថា មិនត្រូវឱ្យកម្ពុជាក្លាយជាធុងសំរាមរបស់គេនោះទេ។ ដូច្នេះ **យើងត្រូវចាត់វិធានការឱ្យបានធ្ងន់ធ្ងរ ចំពោះអ្នកដែលបាននាំចូល និងផលិតស្បៀងអាហារដែលអាចបង្ករគ្រោះថ្នាក់ដល់សុខភាពប្រជាពលរដ្ឋ ដើម្បីធានាសុវត្ថិភាពស្បៀងអាហារនៅកម្ពុជា** ...។

១៤. គ្រូពេទ្យភាគច្រើន ជួយជីវិតមនុស្ស

សម្ពោធអគារសិក្សា និងខួបទី ៧០ ឆ្នាំ នៃការបង្កើតសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល, ភ្នំពេញ, ថ្ងៃទី ១៦ មិថុនា ២០១៦

... **គ្រូពេទ្យភាគច្រើនណាស់ ដែលសង្គ្រោះជីវិតមនុស្ស ប៉ុន្តែក៏នៅមានចំណុចខ្វះខាតមួយចំនួននៃបុគ្គល ... (តែ)មិនមែនជាស្ថាប័នគ្រូពេទ្យទេ។ ខ្ញុំមិនយល់ស្របជាមួយមនុស្សដែលបាននិយាយថា គ្រូពេទ្យ ៩០% មិនល្អ ... (បើដូចនោះ) មនុស្សមិនអាចកើនពី ៥ លាននាក់ ទៅ ១៥ លាននាក់ទេ** ... នៅក្នុង អាស៊ាន (កម្ពុជា)ឈរនៅលំដាប់ទី ៧ ខាងផ្នែកប្រជាសាស្ត្រ។ ទី ១ ឥណ្ឌូនេស៊ី មានប្រជាជនជាង ២០០ លាននាក់, ទី ២ ហ្វីលីពីន ប្រជាជនជាង ១០០ លាននាក់, ទី ៣ វៀតណាម មានប្រជាជនជាង ៩០ លាននាក់, ទី ៤. ថៃ (មានប្រជាជនជាង) ៦០

លាននាក់, ទី ៥. ម៉ាឡេស៊ី (មានប្រជាជនជាង) ៣៩ លាននាក់, ទី ៦. មីយ៉ាន់ម៉ា, ទី ៧. យើង ...។

១៥. ពង្រឹងក្រមសីលធម៌ និងគុណធម៌គ្រូពេទ្យ

ពិធីសម្ពោធមន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ, ថ្ងៃទី ២៩ កុម្ភៈ ២០១៦

... ខ្ញុំនៅតែអំពាវនាវអោយពង្រឹងសីលធម៌របស់គ្រូពេទ្យ ស្រឡាញ់អ្នកជំងឺ ថ្នាក់ថ្នមអ្នកជំងឺ កុំអោយធ្លាក់ទៅក្នុងស្ថានភាពដូចដែលគេនិយាយថា ត្រីមួយកន្ត្រក ស្អុយមួយស្អុយទាំងអស់។ **សូមអំពាវនាវអោយអ្នកនិយាយទាំងឡាយ ខ្ញុំមិនហៅថាអ្នកវិភាគទេ ហៅអ្នកនិយាយ យកចិត្តទុកដាក់ ព្រោះគ្រូពេទ្យនាំគ្នាធ្វើបាតុកម្មប្រឆាំងរាជរដ្ឋាភិបាល ពិបាកការពារណាស់។ មានសម្ភារៈទំនើប បច្ចេកទេសទំនើប ចេះដឹងហើយ ប៉ុន្តែបើយើងខ្វះគុណធម៌ ខ្វះសីលធម៌វិជ្ជាជីវៈ រឿងក៏វានៅតែប៉ុណ្ណឹងដដែល ... ដោយសារតែបច្ចេកវិទ្យាអត់គុណធម៌ ហើយបានជាពិភពលោកសព្វថ្ងៃ កំពុងរងគ្រោះ** ... សង្ឃឹមថា មានការប្រែប្រួលឥរិយាបថនៃអ្នកដែលបានប្រព្រឹត្តមិនគប្បី អោយទៅជាការប្រព្រឹត្តដោយគប្បី ...។

១៦. ឱសថក្លែងក្លាយ និងគ្រូពេទ្យអត់ជំនាញ(គ្រោះថ្នាក់នៃការរំលូតកូន)

ពិធីបិទសន្និបាតសុខាភិបាលលើកទី ៣២ និងរួមគ្នាត្រួតពិនិត្យឡើងវិញនូវសមិទ្ធផលសុខាភិបាល លើកទី ០៩, ភ្នំពេញ ១៥ មីនា ២០១១

... **សូមបញ្ជាក់ដែរ លើបញ្ហាឱសថក្លែងក្លាយ ហើយនិងគ្រូពេទ្យអត់ជំនាញនេះ ត្រូវតាមដានពិនិត្យមើល ជាពិសេសច្រើនតែលួចទៅយកកូនចេញ ដែលគេហៅថាមានផ្ទៃពោះក្រៅបញ្ជីនោះ រួចហើយច្រើនទៅស្លាប់ស្ងាត់ៗ ទៅទៀត។ ជួនកាលវាបែកធ្លាយ តាមសារព័ត៌មានមក។ រឿងនេះមិនមែនមានតែក្នុងទីក្រុងភ្នំពេញទេ។** ប៉ុន្មានឆ្នាំមុន មានរហូតដល់តាមស្រុកនានាទៀត ដែលមានចុះតាមកាសែតព្រោងព្រាត ... បើបានជាជ្រុលខ្លួនហើយ នាំគ្នាការទៅបានទេ។ ប៉ុន្តែ វាណាស់ទៅប៉ះតែប្តីគេហ្នឹង ... រឿងហ្នឹង នៅមានការកង្វល់ច្រើនសម្រាប់យើង ...។

១៧. ការខ្វះចន្លោះជាបុគ្គល មិនមែនជាប្រព័ន្ធសុខាភិបាលទាំងមូលទេ

សេចក្ដីអធិប្បាយ ក្នុងពិធីបិទសន្និបាតសុខាភិបាលប្រចាំឆ្នាំ លើកទី ៣៧, ថ្ងៃ១០ មីនា ២០១៦

... ប្រធានបទមួយធំគឺ ឥរិយាបថរបស់គ្រូពេទ្យ។ មិនមែន ៩៩% ទេ។ ខ្ញុំស្តាប់ឡើងវិញ គេថាគ្រូពេទ្យខូច ៩០%។ បើគ្រូពេទ្យខូច ៩០% បានសេចក្ដីថា ស្រុកខ្មែរលាយហើយ ព្រោះគ្រួសារមួយមាន កូន ១០ នាក់ ខូចអស់ ៩ នាក់ទៅហើយ សល់តែ ១ នាក់។ ខ្ញុំមិនយល់ស្របទេ។ តែយើងទទួលស្គាល់នូវការខ្វះចន្លោះ និងភាពឆ្ងើងឆ្ងៃមួយចំនួនដោយគ្រូពេទ្យជាបុគ្គល មិនមែនជាសុខាភិបាលទេ។ ត្រូវតែប្រែឥរិយាបថទាំងអស់នោះ។ ធ្លាប់សំដីអាក្រក់ យើងបន្ថយសំដីអាក្រក់នោះទៅ។ ពិបាកបំផុត គឺពិបាកត្រង់ថា យើងអត់មានថ្នាំ យើងអត់មានស្អីៗ។ ចុះបើមានថ្នាំមានស្អីហើយ កុំតែនិយាយអាក្រក់ទៅ។ វាអត់អីពិបាកទេ...។

១៨. អនុវត្តស្តង់ដាអប់រំផ្នែកវេជ្ជសាស្ត្រ

ពិធីចែកសញ្ញាបត្រដល់ និស្សិតសាកលវិទ្យាល័យ អន្តរជាតិ (IU), ថ្ងៃទី ២៤ មីនា ២០០៩

... ខ្ញុំនៅតែបន្ត នូវភាពមុឹងម៉ាត់ ទាក់ទិនជាមួយនឹងបញ្ហាការអប់រំខាងផ្នែកវេជ្ជសាស្ត្រនេះ។ ជីវិតមនុស្សមិនមែនជារឿងសាមញ្ញទេ។ ខ្ញុំមិនស្នើឲ្យបញ្ឈប់ការបើកថ្នាក់វេជ្ជសាស្ត្រទាំងគ្រប់ផ្នែកនោះទេ ក៏ប៉ុន្តែ ខ្ញុំស្នើឲ្យអនុវត្ត នូវស្តង់ដាមួយ លើវិស័យអប់រំផ្នែកវេជ្ជសាស្ត្រ មិនថាសាលារដ្ឋ ឬសាលាឯកជននោះទេ ... ការបណ្តុះបណ្តាលនៅក្នុងគ្រឹះស្ថានឯកជនមួយនេះ ត្រូវតែធានាឲ្យបាន នូវនិយាមដែលដាក់ចេញដោយក្រសួងសុខាភិបាល ... ម៉ែត្រវាស់សម្រាប់ជំនាន់បន្ត គឺនិក្ខេបទ។ ធ្វើរបៀបនេះទើបមានស្តង់ដាតែមួយ។ ក្រុមប្រឹក្សាការពារនិក្ខេបទក៏ត្រូវចម្រុះដែរ ...។

១៩. ប្រសិទ្ធិភាព នៃសេវាសាធារណ ផ្នែកសេវាសុខាភិបាល

ពិធីបើកសន្និសីទអន្តរជាតិ ស្ដីពីសុខភាពកម្ពុជា ឆ្នាំ ២០០៨, សាលាពេទ្យ, រាជធានីភ្នំពេញ, ០៦ តុលា ២០០៨

... ចំពោះបញ្ហាទី ២ ដែលខ្ញុំបានលើកឡើងអម្បាញ់មិញទាក់ទង ជាមួយនឹងបញ្ហាក្រមសីលធម៌ **យើងទាំងអស់គ្នាមិនត្រូវមើលស្រាលទេ។ យើងបានធ្វើតាំងពីអាណត្តិមុនៗ មក តែអាណត្តិនេះ គឺជាអាណត្តិដែលសង្កត់ធ្ងន់ទៅលើប្រសិទ្ធិភាពនៃសេវាសាធារណៈ ផ្នែកសេវាសុខាភិបាល វាជាផ្នែកមួយនៃ សេវាសាធារណៈដែរ។ អញ្ចឹង ត្រូវធ្វើយ៉ាងម៉េចដើម្បីធានាថា សេវាសុខាភិបាលត្រូវបានផ្តល់ដោយ មិនមានការរើសអើងរវាងអ្នកមាន និងអ្នកក្រ ឬនិន្នាការនយោបាយទេ។** ខ្ញុំបានទទួលព័ត៌មានខ្លះពីមន្ទីរពេទ្យតិចតួចដែរទេ ប៉ុន្តែ អាតិចតួចនេះ ប្រសិនបើយើងទុក ក៏វាមិនល្អដែរ។ នៅពេលអ្នកជំងឺធ្ងន់ធ្ងរទៅដល់ តែគ្មានប្រាក់ ត្រូវទុកអ្នកជំងឺនោះចោល។ ចំណុចនេះ មិនមែនជាចិត្តអាណិតអាសូររបស់ក្រូពេទ្យចំពោះអ្នកជំងឺនោះទេ។ អំពីក្រមសីលធម៌វិជ្ជាជីវៈ ត្រូវបម្រើដោយអត់រើសអើង។ ខ្ញុំធ្លាប់បានលើកបង្ហើបខ្លះៗ មន្ទីរពេទ្យខ្លះ ក្រូពេទ្យមកដល់សួរអ្នកជំងឺថា អ្នកឯងបោះឆ្នោតឱ្យអ្នកណា? រឿងនេះ កើតពិតប្រាកដនៅ មន្ទីរពេទ្យកុមារមួយនៅមន្ទីរពេទ្យកុមារជាតិ ... ដែលហៅថាអ្នកជំងឺ ខ្ញុំសូមថាកុំគិតពីរឿងនិន្នាការនយោបាយគាំទ្រ មិនគាំទ្រ គឺ មិនត្រូវគិតទេ។ សូមកុំបែងចែក។ នេះជាចំណុចដែលខ្ញុំសូមអង្វរក **ពីពេលនេះទៅ ផ្នែកសុខាភិបាល មន្ត្រីសុខាភិបាល ត្រូវតែដើរតួជាអ្នកដែលជួយដល់ប្រជាពលរដ្ឋ ហើយជួយធ្វើឱ្យសង្គមនេះមានការអភិវឌ្ឍន៍។ ចង់ស្អីក៏ដោយ ឱ្យតែសុខភាពមិនល្អហើយ ទៅវាមិនរួចទេ។ អញ្ចឹង បានជាយើងចាត់ទុកសុខភាពប្រជាពលរដ្ឋជាផ្នែកជ័ំសំខាន់សម្រាប់ការអភិវឌ្ឍធនធានមនុស្ស ...**។

២០. ការបរិច្ចាកឈាម ស្រោចស្រង់ជីវិតមនុស្ស

ពិធីបិទសន្និបាតសុខាភិបាលលើកទី ៣៤ និងពិនិត្យឡើងវិញរួមគ្នានូវសមិទ្ធផលសុខាភិបាលលើកទី ១១, ថ្ងៃទី ២៨ មីនា ២០១៣

... **ខ្ញុំអំពាវនាវចំពោះប្រជាពលរដ្ឋ ពិសេសយុវជន អោយបន្តនូវការបរិច្ចាគឈាម ដើម្បីជួយស្រោចស្រង់ចំពោះជីវិតមនុស្ស។ ខ្ញុំមានការពេញចិត្ត ជាមួយនឹងចលនារបស់ប្រជាពលរដ្ឋយើង ពិសេសក្នុងចំណោមយុវវ័យ ដែលបានចូលរួមបរិច្ចាគឈាម ផ្គត់ផ្គង់ដល់អ្នកដែលមានតម្រូវការឈាម** ... អំពាវនាវមិនថាតែយុវជនទេ អ្នកណាក៏ដោយឲ្យតែអាចផ្តល់ឈាមបាន ដើម្បីយើងមានឈាមប្រើ

ប្រាស់គ្រប់គ្រាន់ឆ្លើយតបទៅនឹងតម្រូវការនៃអ្នកជំងឺ ... មិនដឹងថាណាមយើងដែលបានយកចេញទៅ (ត្រូវបាន)ឲ្យអ្នកណាទេ ប៉ុន្តែច្បាស់ថាជាបានធ្វើបុណ្យចំពោះជីវិតមនុស្ស ...។

២១. ការផ្តល់សេវាសុខាភិបាលដល់អ្នកទេសចរណ៍ និងអ្នកវិនិយោគ

ពិធីបើកសន្និសីទអន្តរជាតិ ស្តីពីសុខភាពកម្ពុជា ឆ្នាំ ២០០៨, សាលាពេទ្យ, រាជធានីភ្នំពេញ, ០៦ តុលា ២០០៨

... **ក្នុងប្រទេសមួយដែលទទួលទេសចរ ទទួលអ្នកវិនិយោគបានច្រើននោះ វាពាក់ព័ន្ធនឹងវិស័យសុខាភិបាលដែរ។ គេត្រូវបានទទួលព័ត៌មានដឹងថា នៅប្រទេសរបស់យើងក៏មានផ្នែកពេទ្យនេះគ្រប់គ្រាន់ល្អ ... យើងត្រូវខិតខំ ព្រោះជាង ២លាននាក់ក្នុងមួយឆ្នាំនៃវិស័យទេសចរណ៍ គ្មានថាទេសចរណា ដែលមិនចេះឈឺទេ?** ក្នុងមួយមឺននាក់ អាចមានមួយនាក់ឈឺដែរ។ ចុះបើគេឈឺ តើគេត្រូវទៅណា? យើងត្រូវផ្តល់នូវសេវាឱ្យអ្នកទេសចរ អ្នកវិនិយោគ ដែលមកស្នាក់នៅប្រទេសយើង។ កន្លងទៅ ខ្ញុំបានដឹងថានៅតាមមន្ទីរពេទ្យរដ្ឋយើងមួយចំនួន និងគ្លីនិកឯកជន បានទទួលព្យាបាលអោយទេសចរនេះដែរ ...។

២២. មិនអោយវិបត្តិសេដ្ឋកិច្ចពិភពលោក ប៉ះពាល់ចំណាយសុខាភិបាលទេ

ពិធីបិទសន្និបាតសុខាភិបាលលើកទី ៣០ និងរួមគ្នាត្រួតពិនិត្យឡើងវិញនូវសមិទ្ធផលសុខាភិបាលលើកទី ០៧, ថ្ងៃទី ២៣ មីនា ២០០៩

... មិនគ្រាន់តែធ្មេបដាច់ដោយឡែកនោះទេ អ្នកដែលបម្រើសេវា ជាមួយនឹងធ្មេប ក៏ត្រូវទទួលបាននូវការយកចិត្តទុកដាក់ដែរ។ លើសពីនេះទៅទៀត មិនមែនចេះតែពង្រាយគ្រូពេទ្យ ឯមូលដ្ឋានសម្ភារៈអត់មាន ក៏វាមិនកើតដែរ។ **ខ្ញុំសូមផ្តាំកុំយកកត្តាវិបត្តិសេដ្ឋកិច្ចពិភពលោក (មក)ធ្វើឲ្យមានផលប៉ះពាល់ចំណាយទៅលើវិស័យសុខាភិបាល។ វិបត្តិសេដ្ឋកិច្ចពិភពលោក មានផលប៉ះពាល់ដល់កម្ពុជាហើយ ក៏ប៉ុន្តែ ក្នុងឋានៈជានាយករដ្ឋមន្ត្រី ខ្ញុំអាចនិយាយបានថា អ្វីដែលមានក្នុងច្បាប់ថវិការួចហើយ អត់មានការកាត់បន្ថយសម្រាប់សុខាភិបាលទេ។** តិចថា ឆ្នាំមិនទាន់មកដល់ដោយសារវិបត្តិសេដ្ឋកិច្ចពិភពលោក គឺអត់ទេ ...។

២៣. ហាត់ប្រាណ បង្កើនសុខភាព ស្មារតីមិត្តភាព និងសាមគ្គីភាព

ដកស្រង់ពីហ្វេសប៊ុកសម្តេចតេជោ, ថ្ងៃទី ៣១ មករា ២០១៦

... តាមពិត ទៅខ្ញុំតែងតែមានគំនិតជំរុញការហាត់ប្រាណនេះ និងបានគិតដល់ការរៀបចំទីកន្លែងសាធារណៈ ដើម្បីប្រជាពលរដ្ឋមានទីធ្លាហាត់ប្រាណ ... **ខ្ញុំពិតជាមានការរីករាយ ដែលបានឃើញប្រជាពលរដ្ឋយ៉ាងច្រើន ចេញទៅហាត់ប្រាណនៅតាមសួនច្បារ មិនថាពេលព្រឹក ពេលល្ងាច ឬពេលយប់ ដែលការហាត់ប្រាណទាំងនេះ បានបង្កើននូវសុខភាព និងកាត់បន្ថយជំងឺទាំងឡាយ បន្ថែមទៅដោយស្មារតីមិត្តភាព សាមគ្គីភាព** ក្នុងចំណោមប្រជាពលរដ្ឋដែលមកហាត់ប្រាណជាមួយគ្នា (ប្រកបដោយភាព)សប្បាយរីករាយ នៅក្នុងសង្គមប្រកបដោយសន្តិភាព និងស្ថេរភាព ...។

សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

១	ស្ថាប័នអន្តរជាតិបបួលធ្វើឯកជនភាវូបនីយកម្មគយ	២៥១
២	កាត់បន្ថយពន្ធប៉ាតង់ និងមិនយកពន្ធលើអាជីវករលក់ដូរតូចតាច	២៥១
៣	ឆ្នាំ ២០១៦ លែងយកពន្ធផ្លូវ ទោចក្រយាន្ត ត្រីចក្រយាន្ត និងជលយាន	២៥២
៤	ការចរចាពីការមិនយកពន្ធត្រួតពីសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវបរទេស	២៥២
៥	បំបាត់ការលួច និងគេចពន្ធ	២៥៣
៦	រដ្ឋាភិបាលធ្វើការជាមួយ មីក្រូហិរញ្ញវត្ថុ បន្ធូរបន្ថយអត្រាការប្រាក់	២៥៣
៧	មីក្រូហិរញ្ញវត្ថុ ៣ រូបភាព កុំក្លាយជាកន្លែងបញ្ចាំរបស់កសិករ	២៥៤
៨	កុំច្រឡំថា មីក្រូហិរញ្ញវត្ថុ ជាគ្រឹះស្ថានរបស់រដ្ឋ	២៥៥
៩	មាន ហ៊ុន សែន គណបក្សប្រជាជន, មិនមានយកពន្ធដីស្រែ	២៥៥
១០	ពិនិត្យការដំឡើងប្រាក់បៀវត្សជូនគ្រូបង្រៀន	២៥៦
១១	ព្យួរពន្ធប្រថាប់ត្រាផ្ទះរមត៌ក	២៥៦
១២	ប្រាក់ខែពី ១ លានរៀនឡើង ជាប់ពន្ធសំរាប់ឆ្នាំ ២០១៧	២៥៧
១៣	ប្រាក់ចាយបាន ប្រាក់បម្រុង ក្នុងរតនាគារ	២៥៧

១. ស្ថាប័នអន្តរជាតិបបួលធ្វើឯកជនភាវូបនីយកម្មគយ

ពិធីបើកសន្និសីទប្រចាំតំបន់លើកទី ៨ ស្តីពីការប្រឆាំងអំពើពុករលួយនៃគំនិតផ្តួចផ្តើមប្រឆាំងអំពើពុករលួយសម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក, ថ្ងៃទី ០៣ កញ្ញា ២០១៤

... សូមលើករឿងមួយដើម្បីឲ្យដឹង **តើវាសមហេតុសមផលទេ? ពេលស្ថាប័នអន្តរជាតិមកបបួលខ្ញុំឲ្យលក់គយ ឲ្យធ្វើឯកជនភាវូបនីយកម្មខាងគយ, ខ្ញុំមិនព្រម។ តើនៅប្រទេសណាខ្លះ ដែលបានលក់គយ ហើយធ្វើឯកជនភាវូបនីយកម្មគយ? គយជា សេវាអធិបតេយ្យ មានសិទ្ធិប្រើប្រាស់ទាំងកាំភ្លើង ទាំងយន្តហោះ ទាំងម៉ារីន**។ នេះជាសេវាអធិបតេយ្យ ហេតុអីបានស្ថាប័ន អន្តរជាតិ (មកបបួលខ្ញុំ ឲ្យលក់គយ ឲ្យធ្វើឯកជនភាវូបនីយកម្មខាងគយ) ... ខ្ញុំរក្សាទុកឯកសារហ្នឹង។ ជំនាញការ ២ នាក់ (ធ្វើការឲ្យគេ អត់ហ៊ានបញ្ចេញឈ្មោះ) សរសេរសំបុត្រទុកថា បើមានការអីថ្ងៃក្រោយ សុំកុំបន្ទោសគាត់ (ព្រោះ)គាត់អត់ឯកភាពទេ។ មេនៅ វ៉ាស៊ីនតោនបញ្ជា ... ខ្ញុំចារជូនឯកឧត្តម គាត ឈន់ សូមបញ្ចប់ការប្រជុំបែបនេះ បើ ចង់ទិញសិទ្ធិ គួរទិញសិទ្ធិនាយករដ្ឋមន្ត្រីតែម្តងទៅ ព្រោះវាធំជាង ... អ្នកណាហ៊ានចូលប្រជុំ ត្រូវដកខ្លួនចេញពីរដ្ឋាភិបាលភ្លាម ... ខ្ញុំដឹងថាក្រុមហ៊ុន ២ មកកៀកទៅហើយ ឲ្យតែយើងអនុម័តដាក់សំណុំឯកសារចូលដេញថ្លៃ ... គេថា មិនស្រួលមានប្រតិកម្មថា រឿងពី ១០ ឆ្នាំមុន ឆ្នាំ ២០០៤ យកមកនិយាយអីទៀត ... ប៉ុន្តែ បើជាយើងវិញ រឿង ១០០ ឆ្នាំមុន ក៏គេគាស់យកមកដែរ ...។

២. កាត់បន្ថយពន្ធប៉ាតង់ និងមិនយកពន្ធលើអាជីវករលក់ដូរតូចតាច

ពិធីសម្ពោធស្ពានមិត្តភាពកម្ពុជា-ចិន ជ្រោយចង្វារ ទី ២ ខ័ណ្ឌជ្រោយចង្វារ, ថ្ងៃទី ២២ តុលា ២០១៥

... **ចំពោះប្រជាពលរដ្ឋដែលជាអាជីវករ (ដ្ឋបានសម្រេច)លុបចោលពន្ធតាមរបបម៉ៅការ និងកាត់បន្ថយតម្លៃប៉ាតង់ តាមទំហំក្រុមហ៊ុនពាណិជ្ជកម្ម។ រឿងនេះបានសម្រួលយ៉ាងច្រើនសម្រាប់អាជីវកររបស់យើងដែលលក់តិចតួច មិនត្រូវបានជាប់ពន្ធគឺចាប់ពីប៉ុន្មានទៅ បានត្រូវជាប់ពន្ធ។ ឯបងប្អូនលក់បន្តិចបន្តួច គឺមិនត្រូវបានជាប់ពន្ធទៀតទេ។ នេះជាការបន្ធូរបន្ថយសម្រាប់ប្រជាពលរដ្ឋក្រីក្រ** ... ការ

ជាប់របបម៉ៅការនេះ ជួនកាលតាំងពីឆ្នាំ ១៩៩៥ ដល់ ២០០៥, ២០ ឆ្នាំក្រោយ គឺនៅដដែល។ មានន័យថាម៉េច? ម៉ៅការ កាលពីជាន់នោះ បង់ពន្ធមួយឆ្នាំ ៥០ ម៉ឺនរៀល។ ២០ ឆ្នាំ ក្រោយនៅតែបង់ពន្ធ ៥០ ម៉ឺនរៀល តែដដែល។ នេះជាការបាត់បង់ចំណូលមួយ។ ប៉ុន្តែ រឿងដែលលំបាកជាងគេ (គឺ)មន្ត្រីពន្ធជាច្រើនទៅ ប៉ះពាល់ប្រជាពលរដ្ឋលក់ដូរតូចតាច ...។

៣. ឆ្នាំ ២០១៦ លើកលែងការយកពន្ធផ្លូវពីទោចក្រយាន្ត ត្រី ចក្រយាន្ត និងជលយាន

ពិធីសម្ពោធស្ពានមិត្តភាពកម្ពុជា-ចិន ជ្រោយចង្វារ ទី ២ ខ័ណ្ឌ ជ្រោយចង្វារ, ថ្ងៃទី ២២ តុលា ២០១៥

... មានការឆ្លងច្បាប់ថវិកា ... ទាមទារឲ្យមានការកែទម្រង់ និងការយោគយល់ចំពោះប្រជាពលរដ្ឋ ... **ចាប់ពីឆ្នាំក្រោយទៅ ពន្ធផ្លូវរបស់ប្រជាពលរដ្ឋយើងសំរាប់ម៉ូតូ ម៉ូតូកង់បី សម្រាប់គ្រឿងយន្តកសិកម្មជាគ្រាក់ទ័រ ជាគោយន្ត ជាទូក កាណូត គេហៅថាជលយាន អត់យកទៀតទេ។ លុបចោលហើយ។ សូមអំពាវនាវអ្នកមិនទាន់បានបង់ពន្ធ មេត្តាចូលទៅបង់ពន្ធ ... ចាត់ទុកថា ជាការបង់ពន្ធលើកចុងក្រោយ ដើម្បីរួមវិភាគទាន ជួសជុលផ្លូវថ្នល់** ... ពេលច្បាប់ហិរញ្ញវត្ថុថ្មី ចូលជាធរមាន ពីឆ្នាំក្រោយទៅ អត់មានការបង់ពន្ធទេ។ ប្រជាជននឹងទទួលផល។ គាត់ធ្លាប់យកលុយហ្នឹងមកបង់ពន្ធ ឥឡូវមិនចាំបាច់បង់ពន្ធទៀតទេ ...។

៤. ការចរចាពីការមិនយកពន្ធត្រួត ពីសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវបរទេស

ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់នូវសាលាអន្តរជាតិភ្នំពេញ សង្កាត់ចាក់អង្រែក្រោម ខ័ណ្ឌមានជ័យ, ថ្ងៃទី ១៩ កញ្ញា ២០១៥

... **ដើម្បីទាក់ទាញគ្រូពូកែៗ អ្នកស្រាវជ្រាវពូកែៗ មកកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានស្នើសុំមកនាយករដ្ឋមន្ត្រី ... ជាក់អ្នកស្រាវជ្រាវ និងសាស្ត្រាចារ្យ ទៅក្នុងការមិនយកពន្ធត្រួតគ្នា។ ប្រធានបទនេះ ទាក់ទាញសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវល្អមកកម្ពុជា។ ប្រទេសមានការពាក់ព័ន្ធ ដែលមានបញ្ជូនសាស្ត្រាចារ្យមកកាន់កម្ពុជា ក៏អាចនឹងទទួលផលប្រយោជន៍ពីនយោបាយរបស់រាជរដ្ឋាភិបាល** ក្នុងការធ្វើឲ្យមានកិច្ចព្រមព្រៀងជាមួយនឹង ប្រទេសកំណើតរបស់សាស្ត្រាចារ្យ

ទាំងនោះ តាមរយៈការមិនយកពន្ធត្រួតគ្នា ... សង្ឃឹមថា ប្រទេសអ្នកមានកុំយកពន្ធសាស្ត្រាចារ្យទាំងហ្នឹង ទុកឲ្យសាស្ត្រាចារ្យទាំងហ្នឹងបង់ពន្ធឲ្យកម្ពុជា ព្រោះកម្ពុជាជាប្រទេសក្រ។ ប៉ុន្តែ ប្រទេសអ្នកមានស្ងួតណាស់ គាត់ចង់ឲ្យសាស្ត្រាចារ្យទាំងហ្នឹង បង់ពន្ធទៅប្រទេសរបស់គាត់ ប៉ុន្តែគាត់មកសុំលើកលែងប្រាក់ពន្ធនៅស្រុកខ្មែរ ...។

៥. បំបាត់ការលួច និងគេចពន្ធ

ពិធីសម្ពោធមធ្យោបាយលើកដាក់កុងតឺន័រ និងជួបសំណេះសំណាលជាមួយកម្មករ និង និយោជិត កំពង់ផែស្វយ័តក្រុងព្រះសីហនុ, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៩

... **គ្រប់ផ្នែកពាក់ព័ន្ធ ពិសេសសមត្ថកិច្ចទាំងគយ ទាំងនគរបាល ទាំងអារ៉ុងហត្ថ ទាំងកងទ័ពពីរប្រភេទ សហប្រតិបត្តិការគ្នា បំបាត់ចោលនូវការលួចគេចពន្ធ ក៏ងវាឲ្យមកចូលច្រកបង់ពន្ធ ទើបធ្វើឲ្យថវិកាជាតិរបស់យើងមានកំណើនកើនឡើង។ ចូលតាមច្រកគយ កុំចូលតាមរបៀង ហើយវាយតម្លៃឲ្យបានត្រឹមត្រូវនូវតម្លៃពិត។** ឧទាហរណ៍ថា អាហ្នឹងថ្លៃ ១០០ ត្រូវវាយតម្លៃថា ១០០ កុំលេងតម្លៃ ១០០ វាយតំលៃពន្ធតែ ៧០ ទុកអា ៣០ ចែកគ្នា ...។

៦. រដ្ឋាភិបាលធ្វើការជាមួយ មីក្រូហិរញ្ញវត្ថុ បន្ធូរបន្ថយអត្រាការប្រាក់

ការឆ្លើយតបនឹងសំណួរពីតំណាងរាស្ត្រ គណបក្សសង្គ្រោះជាតិ ក្នុងសម័យប្រជុំសភាលើកទី ៤ នីតិ កាល ទី ៥ ស្តីពី ច្បាប់គ្រប់គ្រងគ្រោះមហន្តរាយ, ថ្ងៃទី ០៨ មិថុនា ២០១៥

... **វាគ្មិនខ្លះលើកឡើងពីការបន្ធូរបន្ថយអត្រាការប្រាក់ ទាក់ទិននឹងមីក្រូហិរញ្ញវត្ថុ។ មិនមែនជារឿងថ្មីសម្រាប់រាជរដ្ឋាភិបាលទេ ហើយក៏មិនចាំបាច់មានអ្នកតំណាងរាស្ត្របក្សប្រឆាំងស្នើសុំដែរ។ រាជរដ្ឋាភិបាលតែងតែធ្វើការជាមួយនឹងម្ចាស់មីក្រូហិរញ្ញវត្ថុរៀងរាល់ពេល គ្រាន់តែពេលខ្លះ គេមិននិយាយ ដើម្បីយកចំណេញខាងនយោបាយទេ**។ សួរឯកឧត្តម គាត ឈន់ ទៅ ដែលជាអតីតរដ្ឋមន្ត្រីហិរញ្ញវត្ថុ ហើយឥឡូវសួរឯកឧត្តម អូន ព័ន្ធមុន្នីរ័ត្ន ទៅ គេធ្វើរឿងហ្នឹងជាប់ជាប្រចាំមក។ តំបន់រងគ្រោះ ត្រូវអនុគ្រោះយ៉ាងម៉េច? អីយ៉ាងម៉េច? បន្ធូរបន្ថយអីយ៉ាងម៉េច?

គេធ្វើការ មិនមែននិយាយ ត្រឹមតែនៅក្នុងកន្លែងសភាហ្នឹងទេ ...។

ពិធីចែកសញ្ញាបត្រជូននិស្សិតនៃសាកលវិទ្យាល័យបញ្ញាជាតិ, ថ្ងៃ ១៩ កញ្ញា ២០១៦

... ក្នុងក្របខណ្ឌនេះ **ខ្ញុំអំពាវនាវអោយខាងផ្នែកធនាគារពាណិជ្ជទាំងឡាយ ជួយផ្តល់ឲ្យក្រុមហ៊ុនទិញស្រូវ ផលិតស្រូវអង្ករ កែច្នៃស្រូវអង្ករ បានទទួលនូវប្រាក់កម្ចី ដែលក្នុងហ្នឹងរដ្ឋក៏បានធានានូវហានិភ័យពាក់កណ្តាល ឬ ៥០%។ អំពាវនាវចំពោះមីក្រូហិរញ្ញវត្ថុទាំងឡាយសុំមេត្តាយោគយល់ ចំពោះប្រជាពលរដ្ឋ នៅក្នុងស្ថានភាពនៃការលំបាកនេះ ដល់ដំណាក់កាលដែលត្រូវសងគាត់លក់ស្រូវមិនដាច់ ឬលក់ស្រូវបានថោកពេក គាត់មិនអាចសងបាន ... សុំកុំប្តឹងតុលាការទៅរឹបអូសផ្ទះ ដីធ្លីគាត់**។ បន្ថែមលើនោះ ស្នើឲ្យមានការយោគយល់ពន្យារពេលសង ហើយបើអាចធ្វើទៅរួច មិនយកការប្រាក់ ឬបន្ថយការប្រាក់ចំពោះកសិករ ដែលបានខ្ចីទុន។ ប៉ុន្តែ សម្រាប់តែអ្នកខ្ចីយកទៅធ្វើពិតប្រាកដ កុំរាលដាលទៅដល់កន្លែងផ្សេង ... មិនអាចយកមកច្រឡូកច្រឡំគ្នាទេ ...។

៧. មីក្រូហិរញ្ញវត្ថុ ៣ រូបភាព កុំក្លាយជាកន្លែងបញ្ចាំរបស់កសិករ

ពិធីចែកសញ្ញាបត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ២០១៥

... **ធ្វើម៉េចកុំឲ្យមីក្រូហិរញ្ញវត្ថុ ក្លាយជាទីកន្លែងបញ្ចាំរបស់កសិករ ... (ដែល) ធ្វើយ៉ាងដូច្នេះ វាគ្រាន់តែជាវិធីកេងចំណេញ មិនខុសពីសម័យដើម គេថាវស្សាមួយកន្ត្រាំង ប្រាំងមួយតៅនោះទេ។** ឥឡូវ ស្ថានភាពកំពុងកើតឡើងនៅតាមជនបទ មានបីរូបភាព ... រូបភាព **ទី ១ គឺមីក្រូហិរញ្ញវត្ថុស្របច្បាប់** មានអាជ្ញាប័ណ្ណត្រឹមត្រូវ ... **រូបភាពទី ២ អ្នកជ្រកក្រោមផ្លាកអង្គការក្រៅរដ្ឋាភិបាល** ឬរូបភាពនេះ រូបភាពនោះ ទៅឲ្យប្រជាជនខ្ចីដោយអត់មានច្បាប់ ហើយយកការប្រាក់ខ្ពស់។ រូបភាព **ទីបី រូបភាពខ្ចីចងការគ្នាតាមរបៀបសន្យាផ្ទាល់មាត់** អាហ្នឹង គឺការប្រាក់ខ្ពស់ណាស់ ...។

៨. កុំច្រឡំថា មីក្រូហិរញ្ញវត្ថុ ជាគ្រឹះស្ថានរបស់រដ្ឋ

ពិធីកាត់ឫសសីមាព្រះវិហារ និងសម្ពោធសមិទ្ធផល ក្នុងវត្តព្រៃកប្រា,
ថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ ២០១៧

... ខ្ញុំព្រះករុណាខ្ញុំ យកឱកាសនេះដើម្បីបញ្ជាក់សារជាថ្មី ចំពោះបងប្អូនជនរួមជាតិ **សុំមេត្តាយល់ថាមីក្រូហិរញ្ញវត្ថុ ទោះឈ្មោះអ្វីក៏ដោយ មិនមែនជារបស់រដ្ឋទេ កន្លងទៅមានការកន្ត្រេចច្រឡំធំណាស់ ថាមីក្រូហិរញ្ញវត្ថុឈ្មោះនេះឈ្មោះនោះ ជារបស់រដ្ឋ (ហើយ)រដ្ឋតែងតែទារការប្រាក់ រដ្ឋតែងតែរឹបអូសផ្ទះ រឹបអូសដីធ្លី ... (រួម)ដោយពួកអគតិ និងពួកបោកប្រាស់ ទៅយោសនាថែមទៀតថា បើគេឈ្នះ(ការបោះឆ្នោត)គេនឹងលុបបំណុលឲ្យ**។ សុំកុំសង្ស័យ នេះជារបស់ឯកជន មិនមែនរបស់រដ្ឋទេ។ បើចង់លុបបំណុលនេះចោល ទាល់តែធ្វើបដិវត្តន៍ រំលាយចោលរបបរាជានិយម ហើយបង្កើតរបបមួយថ្មី និងលុបចោលអ្វីៗ ទាំងអស់ ហ្នឹងបានទៅរួច។ បើដូច្នោះ ប្រទេសនឹងក្រឡាប់ចាក់ដូចជំនាន់ ប៉ុល ពត ទៀតហើយ ... អញ្ចឹង សុំឲ្យប្រជាពលរដ្ឋយល់ពីបញ្ហានេះ ហើយសុំឲ្យប្រុងប្រយ័ត្នចំពោះការខ្ជីបុល។ បើសិនជាយើងគ្មានសមត្ថភាពសងទេ កុំខ្ជីគេ។ អ្នកខ្លះខ្ជីគេយកទៅទិញម៉ូតូជិះ ដល់អត់មានសមត្ថភាពសងការប្រាក់ ចាប់ផ្តើមគេប្តឹង រឹបអូសដីធ្លី រឹបអូសផ្ទះ ហើយមកចោទគណបក្សកាន់អំណាច គណបក្ស(កាន់)រដ្ឋាភិបាល ...។

៩. មាន ហ៊ុន សែន គណបក្សប្រជាជន, មិនមានយកពន្ធដីស្រែ

សង្កថាពិធីចែកប័ណ្ណកម្មសិទ្ធិដីធ្លី ស្រុកត្រាំកក់, ខេត្តតាកែវ, ថ្ងៃទី ៣០ ខែ ធ្នូ ២០១២

... **ចាប់ពីឆ្នាំ ១៩៧៩ មកដល់បច្ចុប្បន្ននេះ យើងអត់យកពន្ធដីទេ។ ខ្ញុំបានប្រកាសហើយ ដរាបណានៅមាន ហ៊ុន សែន ដរាបណានៅមានគណបក្សប្រជាជន ពន្ធដីមិនត្រូវបានយកពីប្រជាពលរដ្ឋទេ**។ មានការផ្តល់មតិមួយចំនួនពីខាងក្រៅមកវិញទេ មិនមែនក្នុងគណបក្សប្រជាជនទេថា ត្រូវយកពន្ធដីទើបសេដ្ឋកិច្ចមានកំណើន ព្រោះមានប្រទេសតិចណាស់មិនយកពន្ធដីនេះ។ ខ្ញុំបានពន្យល់ប្រាប់វិញថា ប្រជាកសិករកម្ពុជាពេលនេះ **មិនត្រឹមតែមិនត្រូវបានយកពន្ធទេ ថែមទាំងត្រូវជួយគាត់តាមរយៈការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ដូចជាប្រព័ន្ធប្រឡាយទឹក ឬ**

ផ្នែកផ្សេងទៀតៗ ឱ្យពួកគាត់មានប្រាក់ចំណូល ...។

១០. ពិនិត្យការដំឡើងប្រាក់បៀវត្សជូនគ្រូបង្រៀន

ពិធីចែកសញ្ញាបត្រនិស្សិតនៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជា ថ្ងៃទី៣ ខែតុលា ២០១៦

... សង្ឃឹមយ៉ាងមុតមាំទៅលើកការួមចំណែកទាំងអស់របស់សង្គមទាំងមូលរបស់ប្រជាជាតិរបស់យើង ដើម្បីជម្រុញការអភិវឌ្ឍធនធានមនុស្ស ដែលយើងបានប្រឹងប្រែងក្នុងរយៈពេល ៣៧ ឆ្នាំ កន្លងផុតទៅ។ **ចុះទៅតាមមូលដ្ឋានមួយចំនួនបាននិយាយទៅកាន់គ្រូៗ ដែលបៀវត្សមកដល់ពេលនេះ ទាំងអត្ថប្រយោជន៍ទាំងស្ពឹ គឺភាគច្រើនបានលើស ១ លានទៅហើយៗ ឆ្នាំក្រោយបានលើស ១ លាន។ ដែលថាប្រាក់ខែគោលនៅឆ្នាំក្រោយនេះ ហៅថាប្រាក់ខែអប្បបរមាសំរាប់គ្រូបង្រៀននៅឆ្នាំក្រោយនេះ នឹងឡើងទៅដល់ជាង ៩០ ម៉ឺនរៀល ដោយមិនទាន់ប៉ះអត្ថប្រយោជន៍ផ្សេងទៀត។** ឆ្នាំនេះ ប្រាក់ខែគ្រូបង្រៀនមានត្រឹម ៨០៥ ០០០ រៀល។ នៅខែមករា គ្រោងនឹងឡើង ៨៥៣ ៥០០ រៀល។ ដល់ទៅខែមេសា នឹងឡើងទៅដល់ ៩៥៣ ៥០០ រៀល។ នៅជនបទ នឹងមានការរៀបចំអោយមានប្រាក់តំបន់ ដែលមានពី ៨ ម៉ឺន ដល់ ១០ ម៉ឺន និងដល់ ១២ ម៉ឺន ...។

១១. ព្យួរពន្ធប្រចាប់ត្រាផ្ទះមត៌ក

ពិធីចែកសញ្ញាបត្រជូននិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ថ្ងៃទី ៦ ខែតុលា ២០១៦

... តាមគោលដៅថវិការបស់យើង ក្នុង ១ ឆ្នាំ អោយឡើងត្រឹម ០.៥ ភាគរយ តែប៉ុណ្ណោះ។ ប៉ុន្តែ ឆ្នាំក្រោយជាឆ្នាំដែលត្រូវប្រឹងអោយឡើងបាន ០.៧ ភាគរយនៃប្រាក់ចំណូល នាំទៅដល់ ១៨,៥ ភាគរយ (ក្នុងខណៈ)ប្រទេសមួយចំនួនក្នុងតំបន់របស់យើងគេបានឡើងទៅ ២០ ភាគរយរួចស្រេចទៅហើយ។ សម្រាប់យើងៗ រំកិលបន្តិចម្តងៗ (តាមរយៈការធ្វើ)កែទម្រង់ហិរញ្ញវត្ថុសាធារណៈ។ **អញ្ចឹង វប្បធម៌នៃការបង់ពន្ធត្រូវធ្វើ។ រាជរដ្ឋាភិបាល បានគិតគូរទៅដល់បញ្ហាទាំងឡាយ រាប់ទាំងបញ្ហាផ្ទេរកម្មសិទ្ធិឲ្យពីឪពុកទៅកូន ពីជីដូនជីតាទៅចៅ**

ដែលមុននេះត្រូវបង់ពន្ធប្រថាប់ត្រា។ ឥឡូវគឺអត់បង់ពន្ធទេ ដើម្បីកាត់បន្ថយការលំបាករបស់ប្រជាពលរដ្ឋរបស់យើង ...។

១២. ប្រាក់ខែពី ១ លានរៀនឡើង ជាប់ពន្ធសំរាប់ឆ្នាំ ២០១៧

ពិធីចែកសញ្ញាបត្រជូននិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ
សេដ្ឋកិច្ច, ថ្ងៃទី ៦ តុលា ២០១៦

... យប់មិញ ខ្ញុំព្រះករុណាខ្ញុំ ត្រូវពិនិត្យឯកសារ ២០ ទំព័រ ដោយល្អិត(ល្អន់) មុននឹងចាប់ផ្តើមនាំឯកសារនេះ ចូលប្រជុំឆ្លងគណៈរដ្ឋមន្ត្រី ... **នោះគឺច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០១៧ (ដើម្បីនា) អាទិត្យទី ១ នៃ ខែវិច្ឆិកា ត្រូវឡើងទៅដល់សភា រួចហើយធ្វើយ៉ាងម៉េចត្រូវអោយរួចរាល់មុនពេលសភាត្រូវឆ្លង រួចហើយត្រូវទៅដល់ព្រឹទ្ធសភា រួចហើយត្រូវឡាយព្រះហស្តព្រះរាជក្រមដាក់ឲ្យប្រើប្រាស់ មិនឲ្យផុតពាក់កណ្តាលខែធ្នូ។** (សម្រេចបានអីចឹង)ហ្នឹងគឺល្អបំផុតហើយ ... សូមជូនជាព័ត៌មានផងថា កាលមុនប្រាក់បៀវត្សត្រឹមតែ ៥០ ម៉ឺនរៀល ត្រូវជាប់ពន្ធ។ **ឆ្នាំទៅ ច្បាប់ហិរញ្ញវត្ថុរបស់យើងបានអនុញ្ញាត (រំកិលរបារ) ពន្ធលើប្រាក់បៀវត្សពី ៥០ ម៉ឺន ទៅ ៨០ ម៉ឺន បានជាប់ពន្ធ ... ច្បាប់ហិរញ្ញវត្ថុឆ្នាំក្រោយនេះ ចាប់ពី ១ លាន ១ រៀលឡើងទៅបានជាប់ពន្ធ។** បានសេចក្តីថា អ្នកដែលជាប់ពន្ធពីមុនតាំងពី ៥០ ម៉ឺនរៀលបានបញ្ឈប់ហើយ ... (ក្រោយមក)ឡើងទៅដល់ ៨០ ម៉ឺនបានជាប់ពន្ធ។ ឥឡូវ យើងបានរំកិលពី ៨០ ម៉ឺនរៀល ទៅ ១ លានរៀល។ ប៉ុន្តែ មិនមែនយក ១ លានទៅគិតទាំងអស់ទេ (ឧបមា)ថា ១ លាន ២០ ម៉ឺន គេយកតែ ២០ ម៉ឺនរៀលមកគិត ... បានជាប្រាក់ចំណូល(រដ្ឋ)ដែរ ...។

១៣. ប្រាក់ចាយបាន ប្រាក់បម្រុង ក្នុងរតនាគារ

សំណេះសំណាលជាមួយប្រជាពលរដ្ឋ ក្នុងពេលចុះពិនិត្យការងារបង្កបង្កើនផល,
ស្រុកខ្សាច់កណ្តាល, ខេត្តកណ្តាល, ថ្ងៃទី ២ សីហា ២០១៣

.... សូមអង្វរចិត្តបានទេ កុំហាឡើងធ្វើបាតុកម្ម។ គិតដល់សិទ្ធិរបស់គេផង។ អ្នកប្រកាសផ្តាច់ជំនួយនោះ កុំនិយាយច្រើនពេក ពិបាកស្តាប់ណាស់។ សេដ្ឋកិច្ចនៅឆ្នាំ ២០០៣ ពិបាកជាងនេះឆ្ងាយណាស់។ លុយក្នុងថ្ងៃបោះឆ្នោត ក្នុង

រតនាគារមានតែ ២០០០ លានរៀលទេ។ ខ្ញុះសាច់ប្រាក់។ **ឥឡូវខ្ញុំប្រកាស សាច់ប្រាក់នៅក្នុងរតនាគារដែលចាយបាន មានប្រមាណជាង ១០០០ ៣ន់លានរៀល គិតជាដុល្លារមានប្រមាណលានដុល្លារ ដែលអាចចាយបាន។ យើងនិយាយឲ្យស្លូត។ យ៉ាងហោចណាស់(មាន)ប្រាក់ក្នុងដៃ ដោយមិនគិតប្រាក់បម្រុងអន្តរជាតិគឺ ៣៥០០ លានដុល្លារ (និង)ដោយមិនគិតពីមាស។** ហ្នឹង ប្រាក់បម្រុងដែលមិនយកមកចាយ។ ប្រាក់សម្រាប់ចាយ ឆ្នាំ ២០០០ មានកន្លះលានដុល្លារ ដល់**ឥឡូវ មានជាង ៣០០ លានដុល្លារ ជាប្រាក់សម្រាប់ចាយ ... ថវិកាមានពីរប្រភេទ៖ មួយក្រដាស, មួយសាច់លុយ។ បើមានក្រដាស អត់សាច់លុយ ទៅដល់រតនាគារ បើកក៏អត់បានដែរ។ ឥឡូវ មានក្រដាសមានសាច់លុយ លើសពីសេចក្ដីត្រូវការ។ ប្រាក់ខែចាយប្រហែល ១០០ លានដុល្លារទេ ក្នុងមួយខែនោះ ...**។

អប់រំ យុវជន និងកីឬា

១	អភិវឌ្ឍន៍ធនធានមនុស្ស យកជាអាទិភាពទី ១	២៦១
២	បង្កៀកសាលាទៅជិតសិស្ស	២៦១
៣	ការពង្រឹងគុណភាពអប់រំជាកត្តាសំខាន់	២៦១
៤	បន្ថយគម្លាតអភិវឌ្ឍន៍ ផ្តើមពីហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្ស	២៦២
៥	គ្រោះមិនចេះអក្សរ និងគ្រោះភ្លេចអក្សរ	២៦២
៦	កើនចំនួនសិស្ស កើនចំនួនគ្រូ	២៦៣
៧	បណ្តុះបណ្តាលគ្រូបង្រៀន ពី ៩+១ មក ១២+២	២៦៣
៨	ការប្រឡងប្តូរក្របខណ្ឌគ្រូបង្រៀន	២៦៤
៩	បន្តកសាងអន្តេវាសិកដ្ឋាន និងផ្ទះគ្រូ	២៦៤
១០	គ្រូបង្រៀនទាំងអស់ ឱ្យចូលនិវត្តក្នុងអាយុ ៦០ ឆ្នាំ	២៦៥
១១	ការបើកប្រាក់ខែក្នុងខែ ជួយសម្រួលគ្រូបង្រៀនមួយផ្នែក	២៦៥
១២	ដំឡើងប្រាក់បៀវត្ស ជូនគ្រូបង្រៀន	២៦៦
១៣	ភាពខុសគ្នាក្នុងការសិក្សា នៃយុវជនកើតសម័យសង្គ្រាម និងសន្តិភាព	២៦៦
១៤	យុវជនត្រូវចេះប្រើឱកាសឈានឡើង កុំពឹងសម្បត្តិ/អំណាចឪពុកម្តាយ	២៦៧
១៥	ប្រែការឈឺចាប់ពី សម្តីមាក់ងាយសញ្ញាបត្រ ទៅពង្រឹងសមត្ថភាព	២៦៧
១៦	អន្តរសកម្មកំណែទម្រង់វិស័យអប់រំ ទៅវិស័យសុខាភិបាល	២៦៨
១៧	យុវជនជំនាន់ក្រោយត្រូវហ៊ានគិត ហ៊ានធ្វើ ហ៊ានទទួលខុសត្រូវ	២៦៨
១៨	យុវជនស្គាល់ប្រវត្តិសាស្ត្រ ថែរក្សា/បង្កើត សមិទ្ធផលដោយទទួលខុសត្រូវ	២៦៩
១៩	ប្រមូលធនធានមនុស្សវិស័យកីឬា ធ្វើការបណ្តុះបណ្តាល	២៦៩
២០	ងាកចេញពីគ្រឿងញៀន គ្រឿងអបាយមុខ ធ្វើសកម្មភាពកីឬា	២៧០
២១	ពង្រឹងការហ្វឹកហាត់ ភាពស្ទាត់ជំនាញ ដើម្បីប្រកួតយកជោគជ័យ	២៧០
២២	ជម្រុញប្រកួតកីឬាមធ្យមសិក្សា/សាកលវិទ្យាល័យ ទីក្រុង និងជនបទ	២៧១

១. អភិវឌ្ឍន៍ធនធានមនុស្ស យកជាអាទិភាពទី ១

ពិធីសម្ពោធសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ, ១១ កុម្ភៈ ២០១៦

... ខ្ញុំព្រះករុណាខ្ញុំ បាន**ប្រកាសតាំងពីឆ្នាំ ១៩៨៧ នូវអាទិភាព ៤ យ៉ាង ដែលត្រូវដោះស្រាយ ទឹក ផ្លូវ ភ្លើង មនុស្ស** (ក្នុងនោះ) ខិតខំដោះស្រាយទឹក សម្រាប់ប្រព័ន្ធស្រោចស្រព ការប្រើប្រាស់របស់ប្រជាពលរដ្ឋ ... ខិតខំដោះស្រាយផ្លូវ ដើម្បីតភ្ជាប់ក្នុងប្រទេស បន្ទាប់ពីសង្គ្រាមរយៈពេលដ៏យូរ របបប្រល័យពូជសាសន៍ និងបន្តមកសង្គ្រាមទៀត។ អគ្គិសនីក៏ត្រូវដើរទៅជាមួយគ្នា ... ភ្នំពេញដែលពីដើមប្រើថាមពលអគ្គិសនីត្រឹមតែ ៣០ ទៅ ៤០ ម៉េហ្គាវ៉ាត់ ឥឡូវប្រើរាប់រយ ... **រាជរដ្ឋាភិបាលបានប្តូរមុំ ប្តូរអាទិភាពរបស់ខ្លួន ពីផ្លូវ ទឹក ភ្លើង មនុស្ស ឥឡូវ ទៅជាមនុស្ស ទឹក ផ្លូវ ភ្លើង វិញ ដោយជាក់ មនុស្ស ជាអាទិភាពទី ១** ...។

២. បង្កៀកសាលា ទៅជិតសិស្ស

ពិធីចែកសញ្ញាបត្រជូននិស្សិត នៃសាកលវិទ្យាល័យវ៉ូស្ទ្រេន ,០៤ សីហា ២០១៤

... ប្រទេសយើងបានធ្វើដំណើរជាបណ្តើរៗ ចេញពីរបប ប៉ុល ពត ឈានមកដំណាក់កាលស្វែងរកដំណោះស្រាយនយោបាយ និងបន្តមកទៀត បញ្ចប់ដោយនយោបាយឈ្នះ-ឈ្នះ ដើម្បីស្វែងរកសន្តិភាព ... (ដែល)បើកឱកាសឱ្យពលរដ្ឋនៅគ្រប់ទីកន្លែងទទួលបាននូវសុខសន្តិភាព។ តាមរយៈសុខសន្តិភាព (យើង) សម្រេចបាននូវការអភិវឌ្ឍ ក្នុងនោះការបណ្តុះបណ្តាលធនធានមនុស្សធ្វើនៅនឹងកន្លែង ... ពីពេលមុន មួយស្រុកជួនកាលមានអនុវិទ្យាល័យតែមួយទេ វិទ្យាល័យជួនកាលមួយខេត្តមានតែមួយ ឬពីរតែប៉ុណ្ណោះ ... ឥឡូវនេះ **ឃុំមួយមានអនុវិទ្យាល័យយ៉ាងហោចមួយ ... ដើម្បីធានាថា សិស្សរបស់យើងនឹងបានចូលរៀន ០៩ ឆ្នាំ យ៉ាងតិច។ នេះជាការបង្ហិតសាលាឱ្យចូលទៅកៀកជាមួយនឹងសិស្ស** ...។

៣. ការពង្រឹងគុណភាពអប់រំជាកត្តាសំខាន់

ពិធីចែកសញ្ញាបត្រជូននិស្សិត នៃសាកលវិទ្យាល័យ អាស៊ី អ៊ីរ៉ុប, ២៨ មេសា ២០១៤

... **ការពង្រឹងសមត្ថភាពសាស្ត្រាចារ្យ និងគុណភាពសិក្សារបស់និស្សិត គឺជា**

វិធានការដ៏ចាំបាច់បំផុត ក្នុងន័យធានាថា ការអប់រំប្រកបដោយគុណភាព គឺជាបុព្វហេតុដ៏ចម្បងក្នុងការលើកកម្ពស់កិត្យានុភាពនៅលើឆាកអន្តរជាតិ។ ... នៅគ្រប់គ្រឹះស្ថានសិក្សា ចាប់ពីបឋម មធ្យម រហូតដល់ឧត្តម ដែលមានគ្រឹះស្ថានជាង ១០០ ទាំងរដ្ឋ និងឯកជន ត្រូវយកចិត្តទុកដាក់ដូចគ្នា ទៅលើបញ្ហាគុណភាព។ យើងនឹងមិនអាចប្រកួតប្រជែង ឬធ្វើការជាមួយអ្នកណាបានទេ ពេលដែលគុណភាព(អប់រំ) មិនអាចតាមទាន់ដៃគូសហប្រតិបត្តិការដូចជាក្នុងក្របខណ្ឌអាស៊ាន ឬក្របខណ្ឌ ACMECS ក្របខណ្ឌ GMS (មហាអនុតំបន់មេគង្គ) ...។

៤. កាត់បន្ថយគម្លាតអភិវឌ្ឍន៍ ចាប់ផ្តើមពីហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្ស

ពិធីសម្ពោធសាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ, ១១ កុម្ភៈ ២០១៦

... គោលដៅរបស់រាជរដ្ឋាភិបាល ដែលដឹកនាំដោយគណបក្សប្រជាជន គឺកាត់បន្ថយគម្លាតអភិវឌ្ឍន៍ ដោយត្រូវចាប់ផ្តើមពីហេដ្ឋារចនាសម្ព័ន្ធ និងពីការបណ្តុះបណ្តាលធនធានមនុស្ស ... យើងចោទជាសំណួរថា នៅលើពិភពលោកនេះ តើការកាត់បន្ថយគម្លាតខាងទ្រព្យសម្បត្តិអាចធ្វើបានឬទេ? មានតែ ប៉ុល ពត មួយគត់ ដែល(វិធី)បន្ថយគម្លាត រវាងអ្នកមាន/ក្រ គឺឲ្យមកនៅដូចគ្នា ធ្វើរួមស៊ីរួម ... ការខិតខំរបស់យើង គឺធ្វើឲ្យអ្នកក្រីក្រទទួលបានប្រាក់ចំណូល មិនទៅរំលាយចោលអ្នកមានដូចគោលនយោបាយ នៃបក្សនយោបាយ (ដទៃ) ឬដូច ប៉ុល ពត នោះទេ ... **ការកាត់បន្ថយគម្លាតផ្នែកខ្ជះខ្ជាលអាចធ្វើទៅរួច តាមរយៈការវិនិយោគរបស់រដ្ឋ ... គ្មាននរណាកើតមកយកមកជាមួយនូវមាសប្រាក់ទ្រព្យសម្បត្តិ ឬក៏ការវិល្លាតមកនោះទេ ...**។

៥. គ្រោះមិនចេះអក្សរ និងគ្រោះភ្លេចអក្សរ

ពិធីចែកសញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្តម និងគ្រូបង្រៀនឯកទេសភាសាបារាំង-ខ្មែរ, ២៨ មេសា ២០០៩

... ការរីកចម្រើនជាជំហានៗនេះ អនុញ្ញាតឲ្យយើងមានឱកាសកាន់តែច្រើនក្នុងការលើកកម្ពស់វិស័យអប់រំ ដោយបង្កើនទាំងបរិមាណ និងគុណភាពផងដែរ។ ... គ្រូដែលមានកម្រិតបណ្តុះបណ្តាលខាងផ្នែកគរុកោសល្យមិនច្រើនទេ ដែលនៅ

សេសសល់ពីការកាប់សម្លាប់ក្នុងរបប ប៉ុល ពត។ ក្រៅពីនោះ **ក៏រៀនតាមបែបអ្នកចេះច្រើន បង្រៀនអ្នកចេះតិច ហើយអ្នកចេះតិច បង្រៀនអ្នកមិនចេះ។ ក្រោយមកយើងក៏កើតមានគ្រោះមិនចេះអក្សរ និងមានគ្រោះភ្លេចអក្សរទៅទៀត។** ភ្លេចអក្សរមានន័យថា បានរៀនដែរ ក៏ប៉ុន្តែវាភ្លេចទៅវិញ ព្រោះអត់មានការសែតមើល អត់មានសៀវភៅ ដល់យូរៗទៅវាភ្លេច ទើបបានវាកើនចំនួនអ្នកមិនចេះអក្សរតាមរយៈអ្នកចេះហើយភ្លេច។ ទាំងនេះ ជាអនុស្សាវរីយ៍ដែលយើងបានជួប ...។

៦. កើនចំនួនសិស្ស កើនចំនួនគ្រូ

ពិធីចែកសញ្ញាបត្រជូននិស្សិត នៃវិទ្យាស្ថាន ខ្មែរ ជំនាន់ថ្មី, ថ្ងៃទី ១១ មីនា ២០១៣

... ខ្ញុំមិនយល់ព្រមទេ រឿងកាត់បន្ថយគ្រូពេទ្យ និងគ្រូបង្រៀននេះ មានតែបន្ថែម មានតែបង្កើន រឿងកាត់គ្មានទេ។ បើ(មិន) ដូច្នោះ(ទេ) តើយើងត្រូវពង្រីកសាលាយ៉ាងម៉េច? តើកុមារត្រូវនៅក្រៅសាលាប៉ុន្មាន? ... អញ្ចឹងទេ បានតែក្នុងក្របខណ្ឌគ្រូបង្រៀន មួយឆ្នាំឱ្យរើស ៥.០០០ នាក់ ... **ក្នុងវិស័យអប់រំ ត្រូវតែមានការកើនឡើងចំនួនកុមារដល់អាយុចូលរៀន ដូចនេះក៏ត្រូវតែបង្កើនចំនួនគ្រូ ហើយលើការជាក់ស្តែង អ្វីដែលខ្ញុំនិយាយកាលពីឆ្នាំ ១៩៩៤ បាននិងកំពុងកើតពេលនេះ** ...។

៧. បណ្តុះបណ្តាលគ្រូបង្រៀន ពី ៩+១ មក ១២+២

ពិធីចែកសញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបូកមួយ) ជំនាន់ទី ១៧ និងគ្រូបង្រៀនកម្រិតមូលដ្ឋាន ឯកទេសភាសាបារាំង-ខ្មែរ ជំនាន់ទី ១៤, ០៤ មីនា ២០១៣

... ពិនិត្យមើលនៅក្នុងប្រទេសរបស់យើង បន្ទាប់ពីបាត់បង់ធនធានមនុស្សដ៏ធ្ងន់ធ្ងរនៅចន្លោះឆ្នាំ ១៩៧៥ ឆ្នាំ ១៩៧៩ គ្រូបង្រៀនរបស់យើងនៅតិចណាស់ ... **សាស្ត្រាចារ្យ គ្រូបង្រៀន ដែលសល់ពីការកាប់សម្លាប់នៃរបប ប៉ុល ពត ក៏ត្រូវបានស្ថាប័នមួយចំនួនទាញយកទៅ(បម្រើការ)ទៀត រាប់ទាំងក្រសួងការបរទេស ដែលខ្ញុំធ្វើជារដ្ឋមន្ត្រីកាលពីជំនាន់នោះ** ... ទាំង ឯកឧត្តម អ៊ីម ឈុនលឹម អ៊ីវ សុទ្ធតែយកទៅក្រសួងការបរទេសសិន ... **ខ្ញុំបានសរសេរក្នុងសៀវភៅ ១០ ឆ្នាំ នៃដំណើរការកម្ពុជា ថាគ្រូ(ជាការ)ចាប់ផ្តើមពីជំបូងរបស់យើង។ នៅពេលនោះ**

ធ្វើម៉េចឱ្យខាងតែបានទេ កន្លែងរៀនឱ្យតែខាងតែបាន នាំគ្នាអង្គុយរៀនក្រោមដើមឈើក៏ធ្វើទៅ អង្គុយក្រោមកុដិលោកដែលគ្មានព្រះសង្ឆក៏ធ្វើទៅ អង្គុយក្រោមផ្ទះប្រជាជនក៏ធ្វើទៅ ធ្វើឱ្យខាងតែបាន។ ... ក្រោយមកទៀត យើងបានពង្រីងជាបន្តបន្ទាប់ តាមដំណាក់កាលស្របនឹងការពង្រីកខ្លួនកាន់តែធំដែរ គឺពី ៩+១ មក ១២+២ ...។

៨. ការប្រឡងប្តូរក្របខណ្ឌគ្រូបង្រៀន

ពិធីបិទសន្និបាត ក្រសួងអប់រំ យុវជន និងកីឬា ឆ្នាំសិក្សា ២០១២-២០១៣ និងទិសដៅ ឆ្នាំ ២០១៣-២០១៤, ២១ មីនា ២០១៤

... ខ្ញុំសុំអភ័យទោសពីលោក/អ្នកគ្រូផង ដែលកន្លងទៅខំទៅប្រឡង ដើម្បីឱ្យបានគេហៅថា ប្តូរកាំប្រាក់/ប្រឡងប្តូរក្របខណ្ឌ។ ខ្ញុំអត់ដឹង។ មិនមែនបានសេចក្តីថា ខ្ញុំមិនទទួលខុសត្រូវទេ ខ្ញុំសូមទទួលខុស ដោយសារខ្ញុំគ្រប់គ្រងវាអត់បាន។ គ្នាប្រឹងរៀន ឯណាបង្រៀនកូនសិស្ស ឯណាប្រឹងទៅរៀនខ្លួនឯង រួចហើយទៅប្រឡងជាប់ ដល់ប្រឡងជាប់គេមិនឱ្យទៅធ្វើកម្មសិក្សា គេហៅថា គរុនិស្សិត/សិស្ស នោះ ហើយកាត់ប្រាក់ខែគ្នាទៀត។ រឿងហ្នឹងទើបនឹង ឯកឧត្តម ហង់ ជួនណារ៉ុន ធ្វើសំណើមកដូចជាមួយអាទិត្យមុននេះ។ **យើងបើកប្រាក់ខែឱ្យដដែលទៅ មានទៅទាស់ខុសអី។ ដល់រៀនចប់ហើយ ចូលទៅក្របខណ្ឌថ្មី (បាន)ប្រាក់ខែខ្ពស់ជាងមុនទៅ។** ពេលខ្លះ មិនមែនបានសេចក្តីថា ធ្វើនាយករដ្ឋមន្ត្រីក្តាប់បានគ្រប់តែរឿងទាំងអស់ មិនចាំបាច់មានរដ្ឋមន្ត្រីទេ? ឱ្យធ្វើជារដ្ឋមន្ត្រីហ្នឹង ដើម្បីឱ្យមើលការនៅក្នុងវិស័យដែលខ្លួនទទួលខុសត្រូវហ្នឹងហើយ ...**។**

៩. បន្តកសាងអន្តេវាសិកដ្ឋាន និងផ្ទះគ្រូ

ពិធីចែកសញ្ញាបត្រដល់គ្រូបង្រៀនកម្រិតឧត្តម និងគ្រូបង្រៀនឯកទេសភាសាបារាំង-ខ្មែរ, ២៨ មេសា ២០០៩

... មហិច្ឆតារបស់ខ្ញុំធំណាស់។ ក្រៅពីអន្តេវាសិកដ្ឋាន យើងកំពុងផ្តោតយកចិត្តទុកដាក់ទៅលើផ្ទះគ្រូ ដែលជាផ្ទះមុខងាររបស់គ្រូ ហើយរឿងនេះ បានធ្វើនៅកន្លែងមួយចំនួនហើយ ដូចជាវិទ្យាល័យដែលឯកឧត្តម ប៉ុល សារឿន កសាងនៅ

រមាសហែក។ អ្នកណាទៅបង្រៀននៅទីនោះ សំណាងធំហើយ ព្រោះមានផ្ទះគ្រូ ដូចវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន មេមត់។ មានផ្ទះមុខងារ ហើយមានទឹកស្អាតទៀត។ យើងនៅប្រឹងបន្ត នូវដំហាននេះតទៅទៀត ដើម្បីងាយស្រួលក្នុងការបែងចែកគ្រូ។ **បើចង់បានគ្រូពូកែ ចំណុចពិសេស លោកឯងត្រូវខិតខំធ្វើផ្ទះគ្រូ។ សូមផ្តាំទៅអាជ្ញាធរគ្រប់ខេត្តក្រុងថា បើចង់បានអ្នកដែលពូកែលំដាប់ខ្ពស់ចាប់ឆ្នោតទៅខេត្តខ្លួន ត្រូវខិតខំធ្វើផ្ទះគ្រូ។ ជួនកាលខេត្តឆ្ងាយ ប៉ុន្តែគ្រូសុខចិត្តទៅ ដោយនៅទីនោះមានផ្ទះហើយស្រេច។ ឥឡូវ ការអភិវឌ្ឍវាប្រជំប្រសងគ្នាទេ ...**។

១០. គ្រូបង្រៀនទាំងអស់ ឱ្យចូលនិវត្តក្នុងអាយុ ៦០ ឆ្នាំ

ពិធីចែកសញ្ញាបត្រនិស្សិតវិទ្យាស្ថានខ្មែរជំនាន់ថ្មី, ១១ មីនា ២០១៣

... បន្ថែមលើនេះ **ខ្ញុំបានតស៊ូកែច្បាប់ស្តីពីអាយុចូលនិវត្តសម្រាប់គ្រូបង្រៀនទាំងអស់គ្នា ឱ្យចូលនិវត្តក្នុងអាយុ ៦០ ឆ្នាំ។ កាលមុននេះ ច្បាប់របស់យើងមាន (កំណត់) ៥៥ ឆ្នាំ, មាន(កំណត់) ៥៨ ឆ្នាំ**។ ខ្ញុំបានលើករឿងនេះជាទស្សនទាននៅឯសាលាបច្ចេកវិទ្យានៅទីក្រុងភ្នំពេញ (តិចណូ) ហើយបន្ទាប់ទៅ គឺមានព្រះរាជក្រឹត្យទាក់ទិននឹងការដាក់ឱ្យចូលនិវត្តចំពោះគ្រូបង្រៀននៅអាយុ ៦០ ឆ្នាំ ...។

១១. ការបើកប្រាក់ខែក្នុងខែ ជួយសម្រួលគ្រូបង្រៀនមួយផ្នែក

ពិធីចែកសញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្តម/មូលដ្ឋាន ឯកទេសភាសាបារាំង-ខ្មែរ, ១១ មីនា ២០១៤

... ការចំណាយទៅលើបៀវត្សរ៍ក្នុងមួយខែៗ មិនមែនរឿងតូចទេ ហើយក៏មិនអាចដកហូតមកវិញបានទេ។ **ការបើកបៀវត្សរ៍មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ត្រូវបានធានាឱ្យបើកក្នុងខែ។ ស្ថានភាពនេះ ជួយសម្រួលមន្ត្រីរាជការគ្រូបង្រៀនរបស់យើងបានមួយផ្នែកដែរ។ កាលពីពេលមុន ការឡើងបៀវត្សតាមអត្រា ២០% ស្មើគ្នាទាំងអស់។ ឥឡូវនេះ យើងមិនអនុវត្តនូវអត្រា ២០% ស្មើគ្នាទេ។ យើងអនុវត្តពហុអត្រា។ ពហុអត្រានៅទីនេះ ឡើងកន្លងទៅ គឺ ค.๓ ១៤, ค.๓ ១៣, ค.๓ ១២ អីនេះ គឺឡើងដល់ទៅជាង ២០% ដូច ២២% ឬ ២៣% ប៉ុន្តែ ដល់ទៅក្របខណ្ឌ "ก" វិញ ឡើងបានតែ ២% ទេ។** មួយឡើង ២០% បាន ២០ ម៉ឺន

មួយទៀតឡើង ២០% បានតែ ៧ ម៉ឺន ... សម្រាប់ការរៀបចំប្រព័ន្ធបៀវត្សរ៍វិស័យគ្រូនេះ ត្រូវរៀបចំបើក(តាម)ធនាគារឱ្យបានលឿនជាងគេនៅក្នុងឆ្នាំនេះ ...។

១២. ដំឡើងប្រាក់បៀវត្សរ៍ ជូនគ្រូបង្រៀន

ពិធីចែកសញ្ញាបត្រ និស្សិត នៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជា, ០៣ តុលា ២០១៦

... **មកដល់ពេលនេះ ទាំងអត្ថប្រយោជន៍ទាំងស្ពឹ ភាគច្រើនបានលើស ១ លាន(រៀល)ហើយ ... ដែលថាប្រាក់ខែគោលនៅឆ្នាំក្រោយនេះ គេហៅថា ប្រាក់ខែអប្បបរមាសម្រាប់គ្រូបង្រៀននៅឆ្នាំក្រោយនេះ នឹងឡើងទៅដល់ជាង ៩០ ម៉ឺនរៀល ដោយមិនទាន់បូកអត្ថប្រយោជន៍ផ្សេងទៀត។ ឆ្នាំនេះ ប្រាក់ខែគ្រូបង្រៀនមានត្រឹម ៨០៥.០០០ រៀល។ នៅខែ មករា គ្រោងនឹងឡើង ៨៥៣.៥០០ រៀល ដល់ទៅខែ មេសា នឹងឡើងទៅដល់ ៩៥៣.៥០០ រៀល។** នៅជនបទនឹងមានការរៀបចំឲ្យមានប្រាក់តំបន់ ដែលមានពី ៨ ម៉ឺន(រៀល) ដល់ ១០ ម៉ឺន(រៀល) និងដល់ ១២ ម៉ឺន(រៀល) ...។

១៣. ភាពខុសគ្នាក្នុងការសិក្សា សំរាប់យុវជនកើតក្នុងសម័យសង្គ្រាម និងសន្តិភាព

ពិធីចែកសញ្ញាបត្រថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ថ្នាក់បណ្ឌិត នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង, ថ្ងៃទី ១០ កុម្ភៈ ២០១៤

... បញ្ហាស្ថិតនៅត្រង់ថា តើយើងមានឱកាសឬទេ? តើយើងចេះប្រើប្រាស់ឱកាសនោះឬអត់? ក្នុងស្ថានភាពនៃប្រទេសរបស់យើងនេះ បើយើងនិយាយពីប្រវត្តិទាក់ទិនជាមួយឱកាសរបស់យុវជន ឬឱកាសរបស់ប្រជាជន យើងបាត់បង់ច្រើនណាស់ នៅក្នុងដំណាក់កាលជាប្រវត្តិសាស្ត្ររបស់កម្ពុជា។ ឱកាសពិតប្រាកដដែលយើងបានមាន គឺនៅក្នុងចន្លោះឆ្នាំ ១៩៥៣ ក្រោយឯករាជ្យឆ្នាំ ១៩៥៣ មកទល់ឆ្នាំ ១៩៧០ ក្រោមព្រះរាជ្យកិច្ចដឹកនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចឪ សម្តេចតា សម្តេចតាទួត ព្រះបរមរតនកោដ្ឋ ... បន្ទាប់ពីការទាមទារឯករាជ្យពីបារាំង។ ឱកាសនេះត្រូវបាត់ចាប់តាំងពីរដ្ឋប្រហារ ថ្ងៃទី ១៨ មីនា ១៩៧០ នោះ ហើយជាការចាប់ផ្តើមនៃការបាត់ឱកាសរបស់យុវជន ... យុវជនធ្លាប់តែ កាន់ប៊ិច កាន់ខ្មៅដៃ

កាន់ដីស បានប្រែក្លាយខ្លួនទៅជាអ្នកកាន់កែកាំភ្លើងទៅវិញ នេះមិនមែនជាការបាត់បង់ឱកាសសម្រាប់យុវជន ដែលត្រូវការការរៀនសូត្រទេឬអី ? នេះជាការបាត់បង់ឱកាស ហើយឱកាសនោះបាត់ទាំងស្រុងបន្ថែមទៀត នៅពេលដែលរបប **ប៉ុល ពត** បានចាប់ផ្តើមកាន់កាប់ ...។

១៤. យុវជនត្រូវចេះប្រើឱកាសឈានឡើង កុំពឹងសម្បត្តិ និងអំណាច ឪពុកម្តាយ

ពិធីចែកសញ្ញាបត្រជូននិស្សិតនៃសាកលវិទ្យាល័យ អាស៊ី-អឺរ៉ុប,
ថ្ងៃទី ២៩ តុលា ២០១២

... ជំនាន់មុន ឱកាសចង្អៀតណាស់ រហូតដល់បាត់បង់ទាំងស្រុងតែម្តង។ ពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥ មិនមានឱកាសទេ។ អ្នកនៅទីក្រុងត្រូវបានចាប់បង្ខំធ្វើទាហាន ឬក៏ត្រូវត់លួនដោយសារតែគ្រាប់។ ឯអ្នកនៅជនបទ ត្រូវធ្វើទាហានព្រោះវាអត់មានជម្រើស ... ឥឡូវនេះ ឱកាសមានច្រើនចង់ជ្រុល។ **បន្ទាប់ពីប្រទេសបានឯកភាពទឹកដី យើងមានឱកាសច្រើន សម្រាប់ការសិក្សារៀនសូត្រ។ ទាមទារឱ្យយុវជនចេះប្រើប្រាស់ឱកាសអំណោយផលនេះ ដើម្បីឈានឡើង ព្រោះយើងមិនត្រូវផ្អែក ទៅលើទ្រព្យសម្បត្តិឪពុក-ម្តាយ ឬអំណាចរបស់ឪពុក-ម្តាយនោះទេ ត្រូវផ្អែកលើការខិតខំផ្ទាល់ខ្លួន ដើម្បីនឹងឈានឡើង** ... ចំណេះវិជ្ជា កណ្តៀរក៏មិនកោរ កណ្តុរក៏មិនកាត់។ **ប៉ុល ពត** អាចសម្លាប់ជីវិតមនុស្សបាន តែមិនអាចសម្លាប់នូវការចេះដឹងរបស់មនុស្សដែលនៅរស់រានមានជីវិតបានទេ...។

១៥. ប្រែការឈឺចាប់ពីសម្តីមាក់ងាយសញ្ញាបត្រ ទៅពង្រឹងសមត្ថភាពឲ្យកាន់តែខ្លាំង

ពិធីចែកសញ្ញាបត្រដល់និស្សិតសាកលវិទ្យាល័យធនធានមនុស្ស,
ថ្ងៃ ២០ មេសា ២០១៦

...មានការបន្ទុះបង្ហាប់ពីមនុស្សខ្លះថា សញ្ញាបត្រក្នុងប្រទេសនេះវាគ្មានតម្លៃ។ អញ្ចឹង ខ្ញុំគ្រាន់តែរំលឹកដាស់តឿនចំពោះសិស្សនិស្សិតដែលរៀននៅក្នុងប្រទេសទាំងឡាយ ហើយដែលមិនបានទៅរៀននៅក្រៅប្រទេស សូមប្រើប្រាស់ឱកាសនេះ ប្រើប្រាស់នូវការឈឺចាប់ដែលចេញពីសម្តីមាក់ងាយរបស់អ្នកនយោបាយខ្លះ ឲ្យទៅជាការខិតខំពង្រឹងនូវសមត្ថភាពរបស់យើងផ្ទាល់ កុំឲ្យត្រូវនឹងពាក្យគេថាវា

អត់តម្លៃ។ សូមបញ្ជាក់ថា អ្នកដែលទៅរៀនក្រៅប្រទេស មិនប្រាកដថាជាអ្នកដែលចេះនោះទេ។ ជួនកាលទៅនៅប្រទេសក្រៅ ... ចេះតែភាសានិយាយ ភាសាផ្លូវការសរសេរមិនកើត។ មិនមែនទៅទាំងអស់សុទ្ធតែជាប់មហាវិទ្យាល័យទាំងអស់នោះទេ ...។

១៦. អន្តរសកម្មកំណែទម្រង់វិស័យអប់រំ ទៅវិស័យសុខាភិបាល

ពិធីបិទសន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០១៣-២០១៤ និងទិសដៅឆ្នាំ ២០១៤-២០១៥, រាជធានីភ្នំពេញ, ថ្ងៃទី ២៦ មីនា ២០១៥

... **មុននេះ គឺយើងបានកម្រិតការចូលប្រឡងសម្រាប់និស្សិតពេទ្យ គឺនិទ្ទេស A B C តែប៉ុណ្ណឹងទេ D និង E ហ្នឹងអត់យកទេ។ ហ្នឹងគឺផ្នែកវេជ្ជសាស្ត្រ។ ឥឡូវយោងទៅលើបរិបទថ្មី បន្ទាប់ពីកំណែទម្រង់នៃការប្រឡងរបស់ក្រសួង អប់រំ យុវជន និងកីឡា ដែលការប្រឡងមានភាពម៉ត់ចត់ខ្លាំង ចាប់ពីពេលនេះទៅយើងផ្តល់ឱកាសសម្រាប់និស្សិតដែលមាននិទ្ទេស D និង E ចូលប្រឡងសម្រាប់មុខវិជ្ជាពេទ្យដែរ។** ខ្ញុំសូមបញ្ជាក់ មិនមែនថយក្រោយទៅយកសិស្សដែលប្រឡងជាប់បាក់ឌុបមុនឆ្នាំ ២០១៣ ទេ គឺចាប់យក ២០១៤ មកចូលប្រឡង ព្រោះឥឡូវនេះអ្នកចេះបានជាប់ ... អម្បាញ់មិញហៅឯកឧត្តម ផៀ គ្រុយ មកនិយាយ ហើយក៏បានប្រកាស ព្រោះថាមានសាលារដ្ឋផង និងមានសាលាឯកជន ... (ដូចនេះ) **យើងត្រូវឃើញថាមានអន្តរសកម្ម គ្រាន់តែកំណែទម្រង់វិស័យអប់រំមួយ វាជះឥទ្ធិពលភ្លាមទៅលើវិស័យដទៃទៀតតែម្តង ...**។

១៧. យុវជនជំនាន់ក្រោយត្រូវហ៊ានគិត ហ៊ានធ្វើ ហ៊ានទទួលខុសត្រូវ

ពិធីបើកព្រឹត្តិការណ៍អង្គរសង្ក្រាន ឆ្នាំ ២០១៥, ខេត្តសៀមរាប, ១៤ មេសា ២០១៥

... **វិធីសាស្ត្រនៃការ(ធ្វើ)ឲ្យយុវជនក្លាយទៅជាអ្នកបន្តវេននៅពេលក្រោយ គ្មានជម្រើសណាក្រៅពីទុកឲ្យគេចេះគិត ចេះទទួលខុសត្រូវ បើសិនគេសួរយោបល់ ចាំយើងប្រាប់ បើគេមិនសួរយោបល់ឲ្យគេធ្វើទៅ ... ប៉ុន្តែកុំភ្លេចថាមានអ្នកធ្វើ មានអ្នកឈរមើល មានអ្នកអង្គុយ និងមានអ្នកចង្អុល ... ត្រូវស្រូបយកធាតុទាំងអស់ ប៉ុន្តែចំណុចណាដែលគិតថាត្រូវ យើងត្រូវទទួលយក និងធ្វើ**។

គ្មានចាស់ណាមួយមិនឆ្លងកាត់នូវភាពជាយុវវ័យ និងយុវជនទេ ... យុវជនសម័យនេះ មានឱកាសរៀនសូត្រច្រើន ដូច្នេះបណ្តាយឲ្យពួកគេធ្វើ ... **អនុសាសន៍របស់ខ្ញុំតម្រង់ឆ្ពោះទៅរកយុវជនជំនាន់ក្រោយ ត្រូវហ៊ានគិត ហ៊ានធ្វើ ហ៊ានទទួលខុសត្រូវ និងហ៊ានទទួលយកនូវការខ្វះខាត ព្រមទាំងធ្វើការកែលម្អឲ្យកាន់តែប្រសើរ** ... គ្មាននរណាគិតត្រូវ ១០០% ហើយគ្មាននរណាម្នាក់ធ្វើល្អឥតខ្ចោះនោះដែរ ...។

១៨. យុវជនត្រូវស្គាល់ប្រវត្តិសាស្ត្រ ថែរក្សា បង្កើតសមិទ្ធផលដោយស្មារតីទទួលខុសត្រូវ

ពិធីបើកព្រឹត្តិការណ៍អង្គរសង្ក្រាន ឆ្នាំ ២០១៥, ខេត្តសៀមរាប,
ថ្ងៃទី ១៤ មេសា ២០១៥

... **យុវជនត្រូវស្គាល់ពីប្រវត្តិសាស្ត្រ និងអ្វីដែលប្រទេសជាតិយើងបានឆ្លងកាត់ ហើយត្រូវខិតខំចូលរួមថែរក្សាសមិទ្ធផលដែលមាននាពេលបច្ចុប្បន្ន និងបង្កើតថ្មីបន្ថែមទៀតដោយស្មារតីទទួលខុសត្រូវខ្ពស់** ... ខ្ញុំចាប់ផ្តើមជាមួយនឹងការរំលឹកនឹកគុណដល់អតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានី និងដូនតាយើងជំនាន់មុន ដែលបានកសាងប្រាង្គប្រាសាទទុកមក ... **បន្តបន្ទាប់មកទៀត ទឹកដីរបស់យើងត្រូវបានការពារគង់រង្សីដោយដូនតាយើង ប្រទេសមានសង្គ្រាមត្រូវត្រឡប់មកកាន់សន្តិភាព ត្រូវធ្វើអ្វីដែលវានាំទៅដល់ការពង្រឹងសន្តិភាព មិនមែនគ្រាន់តែសន្តិភាពអត់ស្នូរកាំភ្លើងទេ ក៏ប៉ុន្តែ ជាសន្តិភាពទាំងផ្លូវចិត្ត ទាំងអារម្មណ៍ សន្តិភាពអ្វីៗ ទាំងអស់** ...។

១៩. ប្រមូលធនធានមនុស្សវិស័យកីឡា ធ្វើការបណ្តុះបណ្តាល

ពិធីបើកការដ្ឋានសាងសង់ពហុកីឡាដ្ឋានជាតិ មរតកតេជោ, ខណ្ឌឫស្សីកែវ
រាជធានីភ្នំពេញ, ថ្ងៃទី ១២ មេសា ២០១៣

... ក្នុងបញ្ហាវិស័យកីឡា **យើងប្រមូលបានធនធានមនុស្ស ដែលសេសសល់ពីការស្លាប់ និងបានធ្វើការបណ្តុះ(បណ្តាល)ថ្មីមួយចំនួន។** ... ក្នុងដំណាក់កាលដំបូងនេះ បើពិនិត្យពីការរីកដុះដាលក្នុងវិស័យកីឡា បន្ទាប់ពី(ប្រទេសត្រូវបាន)បានរំដោះ យុវជនរបស់យើងពិតជាមានចំណង់ចំណូលចិត្តទៅលើបញ្ហាវិស័យកីឡានេះខ្លាំងណាស់។ ... **ពីដំណាក់កាលមួយទៅកាន់ដំណាក់កាលមួយ**

វិស័យកីឡារបស់យើងចេះតែរីកចម្រើន។ ពហុកីឡាដ្ឋានជាតិ ក៏ដូចជាស្តាតចាស់ ត្រូវបានស្តារបន្តិចម្តងៗ រួមជាយបណ្តាខេត្តនានា ក៏មានការរៀបចំវិស័យកីឡានេះជាបណ្តើរ ...។

២០. ងាកចេញពីគ្រឿងញៀន គ្រឿងអបាយមុខ ធ្វើសកម្មភាពកីឡា

ពិធីបើកការដ្ឋានសាងសង់ពហុកីឡាដ្ឋានជាតិ មរតកតេជោ, ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ, ថ្ងៃទី ១២ មេសា ២០១៣

... **សុំក្មួយៗ លោកគ្រូខាងកីឡា ហ្វឹកហាត់ឲ្យខ្លាំងពីឥឡូវ ប្រយ័ត្នដល់ពេលធ្វើម្ចាស់ផ្ទះ គេយកមេដាយអស់។ ឯងទទេ។** ប្រយ័ត្នម្ចាស់ផ្ទះអត់មានមេដាយមាស។ ... មិនត្រូវភ្លេចទេ (បើ)យើងខ្លាំង (ក៏គង់)មានអ្នកខ្លាំងលើសយើង អញ្ចឹងទេ យើងត្រូវហ្វឹកហាត់ឲ្យបានខ្លាំងឡើង (ហើយវាក៏)ជាផ្នែកមួយនៃសុខុមាលភាពរបស់ប្រជាជន(ដែរ)។ **តាមរយៈគ្រប់សកម្មភាពកីឡា មិនថាជំរើសជាតិ មិនថាកម្រិតណាទេ យុវជនត្រូវងាកចេញពីគ្រឿងញៀន ងាកចេញពីអំពើអបាយមុខផ្សេងៗ តាមរយៈការធ្វើសកម្មភាពកីឡាគ្រប់ប្រភេទ ...។**

២១. ពង្រឹងការហ្វឹកហាត់ ភាពស្ទាត់ជំនាញ ដើម្បីប្រកួតយកជោគជ័យ

ពិធីប្រគល់ប្រាក់រង្វាន់ជ័យលាភី និងបំពាក់ឋានន្តរសក្តិ ដល់កីឡាការនី កែ ឡេង និងគ្រូបង្វឹក, ថ្ងៃទី ០៩ មេសា ២០១៥

... មុននឹងដល់ ឆ្នាំ ២០២៣ យើងក៏ត្រូវដើរយកមេដាយនៅកន្លែងនេះ នៅកន្លែងនោះ... យ៉ាងណាក៏ដោយ គ្រប់វិញ្ញាសាទាំងអស់សុទ្ធតែមានការខិតខំ។ **ចំពោះវិស័យកីឡា ខ្ញុំធ្លាប់បាននិយាយហើយ មិនអាស្រ័យទៅលើប្រទេសដែលមានប្រជាជនច្រើន មិនអាស្រ័យទៅលើប្រទេសដែលជាអ្នកមាន ឬអ្នកក្រ ប្រទេសតូច ឬប្រទេសធំនោះទេ។ វាចំណុះទៅលើការហ្វឹកហាត់ម៉ត់ចត់ ដើម្បីធានាការឈ្នះនៅក្នុងការប្រកួត។** ប្រទេសខ្លះមានប្រជាជនដល់រាប់ពាន់លានអ្នក ក៏ប៉ុន្តែមិនអាចរកកីឡា ១១ នាក់បានទេ ដាក់ស្តែងចិន និងឥណ្ឌា ... **យើងត្រូវខិតខំជំនះចិត្តសាស្ត្រប្រទេសធំ ឬប្រទេសតូច និងប្រទេសអ្នកមាន ឬអ្នកក្រ ... ដោយសារការហ្វឹកហាត់ និងភាពស្ទាត់ជំនាញ យើងអាចទទួលនូវជោគជ័យ ...។**

២២. ជម្រុញការប្រកួតកីឡាតាមមធ្យមសិក្សា និងសាកលវិទ្យាល័យទាំងទីក្រុង និងជនបទ

ពិធីប្រគល់ប្រាក់រង្វាន់ជ័យលាភី និងបំពាក់ឋានន្តរសក្តិដល់កីឡាការនី កែ ឡេង និងគ្រូបង្វឹក, ថ្ងៃទី ០៩ មេសា ២០១៥

... ខ្ញុំសង្ឃឹមលើការដឹកនាំរបស់គណៈកម្មាធិការជាតិកីឡាអូឡាំពិកកម្ពុជា និងសហព័ន្ធកីឡាទាំងអស់ ព្រមទាំងកីឡាករ កីឡាការនី យុវជន យុវវ័យ និងកុមារជំនាន់ក្រោយ ដែលនឹងខិតខំតម្រង់ទិសចូលរួមទៅក្នុងវិស័យកីឡា នៅតាមទីសាលាគ្រប់កម្រិត ទាំងបឋម មធ្យម និងមហាវិទ្យាល័យ ... **ខ្ញុំសុំផ្តល់ជាអនុសាសន៍ឲ្យពង្រីកបន្ថែមនូវវិញ្ញាសាកីឡា ដែលត្រូវប្រកួតទៅតាមភូមិភាគ តាមសាលាមធ្យមសិក្សា និងតាមសាកលវិទ្យាល័យ ទើបអាចឲ្យកីឡានេះរីកធំធាត់ ... ប្រកួតកាន់តែច្រើន កាន់តែមានឱកាសរកបានជម្រើសជាតិកាន់តែច្រើន ចម្រាញ់យកគុណភាព ដើម្បីរកឲ្យបានគុណភាព វាទាល់តែមានបរិមាណ ...**។

អភិវឌ្ឍន៍ជនបទ

១	អភិវឌ្ឍន៍ជនបទ ទប់ស្កាត់ចំណាកស្រុកមកទីក្រុងរកការងារធ្វើ	២៧៥
២	រកឥណទានសង់ផ្លូវលំក្រាលកៅស៊ូ មិនតិចជាង ៤០០ គីឡូម៉ែត្រ/ឆ្នាំ	២៧៥
៣	ហេដ្ឋារចនាសម្ព័ន្ធជនបទ ធ្វើអោយមានកំណើនសេដ្ឋកិច្ចជនបទ	២៧៦
៤	ផ្លូវលំជនបទ ៧ ខេត្ត នឹងបង្កើតឱកាសការងារអោយយុវជន	២៧៦
៥	ហេដ្ឋារចនាសម្ព័ន្ធជនបទបញ្ចៀសការកេងប្រវ័ញ្ច បន្ទាបគុណភាព/ថ្លៃ	២៧៧
៦	ផ្លូវលំចាក់កៅស៊ូ នឹងមានប្រសិទ្ធិភាពសេដ្ឋកិច្ចខ្ពស់	២៧៧
៧	អភិវឌ្ឍតំបន់ព្រំដែន ជាគោលដៅអាទិភាព សំណាញ់សុវត្ថិភាពសង្គម	២៧៨
៨	អភិវឌ្ឍន៍ និងអភិរក្ស ជីវភាពជនជាតិភាគតិច	២៧៨
៩	វប្បធម៌ចែករំលែកជួយស្ត្រីមេម៉ាយ ចាស់ជរា ក្មេងកំព្រា ឆ្លងការលំបាក	២៧៩
១០	ខិតខំកុំអោយប្រជាជននៅកៀកបន្ទាត់ក្រីក្រ ធ្លាក់ចុះទៅក្រីក្រវិញ	២៧៩
១១	ពីអភិវឌ្ឍតាមបែបបើកទូលាយទៅបែបស៊ីជម្រៅ (ក្នុងផលិតកម្មស្បៀង)	២៨០
១២	បើដីក្រុមហ៊ុន និងប្រជាពលរដ្ឋជាន់គ្នា អោយអាទិភាពទៅប្រជាពលរដ្ឋ	២៨០
១៣	បញ្ចូលមុខវិជ្ជាចលនាភូមិថ្មី រុញសេដ្ឋកិច្ចសង្គមជនបទកក្រើកឡើង	២៨១
១៤	ការអភិវឌ្ឍ និងការអភិរក្ស កុំអោយមានសម្ពាធលើបរិស្ថានធម្មជាតិ	២៨២
១៥	ទំនាក់ទំនងស្និតរមួត រវាងកសិករ និងកម្មករ	២៨២
១៦	បន្ថយគម្លាតសេវាសុខាភិបាល រវាងទីក្រុង និងជនបទ	២៨៣

១. អភិវឌ្ឍន៍ជនបទ ទប់ស្កាត់ចំណាកស្រុកមកទីក្រុងរកការងារធ្វើ

ពិធីចែកសញ្ញាបត្រជូននិស្សិត នៃសាកលវិទ្យាល័យកូមិន្ទកសិកម្ម (ចំការដូង), ១៨ ធ្នូ ២០១៤

... យើងមិនអាចស្ថិតនៅទ្រឹងក្នុងវិស័យកសិកម្មតាមបែបបូរាណនោះទេ ត្រូវឈានចូលទៅក្នុងដំណាក់កាលថ្មីនៃកសិកម្មបែបទំនើប កសិកម្មដែលបម្រើឱ្យទីផ្សារ មិនគ្រាន់តែទីផ្សារក្នុងស្រុកទេ តែទីផ្សារនៅក្រៅប្រទេសទៀតផង ... មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍកសិកម្ម បានធ្វើសិក្ខាសាលានៅក្នុងតំបន់ អាស៊ីប៉ាស៊ីហ្វិក ពាក់ព័ន្ធជាមួយនឹងកសិកម្ម និងអភិវឌ្ឍន៍ជនបទ នៅឯខេត្តសៀមរាប បានធ្វើជាចំណោលមួយ ឃើញថា ចំណាកស្រុកពីជនបទមកកាន់ទីក្រុង គឺកាន់តែច្រើន។ អញ្ចឹងទេ ប្រទេសនីមួយៗ ត្រូវរកវិធីទប់ស្កាត់ ហើយការទប់ស្កាត់នេះ មិនមែនធ្វើរបងសម្រាប់ប្រជាជនកុំឱ្យចំណាកស្រុកមកទីក្រុង រកការងារធ្វើនោះទេ ក៏ប៉ុន្តែ គ្មានជម្រើសអ្វីល្អជាងការអភិវឌ្ឍនៅជនបទ តាមរយៈការផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធ និងភាពចាំបាច់ផ្សេងទៀត ឱ្យប្រជាកសិករ ដែលធ្វើការនៅទីនោះតែម្តង ក្នុងហ្នឹងរាប់ទាំងមន្ត្រីកសិកម្មរបស់យើង អ្នកបច្ចេកទេសកសិកម្មរបស់យើង ត្រូវតែមានវត្តមាននៅឯមូលដ្ឋានច្រើន ដើម្បីរុញវិស័យកសិកម្មនេះ ឱ្យឈានឡើងដល់កម្រិតមួយ ដែលអាចធានាចិញ្ចឹមប្រជាជនខ្លួនឯងបានហើយ និងធានាជម្រុញឱ្យការនាំចេញបានថែមទៀតផង ...។

២. រកឥណទានសង់ផ្លូវលំក្រាលកៅស៊ូ មិនតិចជាង ៤០០ គីឡូម៉ែត្រ/ឆ្នាំ

ពិធីសម្ពោធបើកឲ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ ៨ ,ថ្ងៃទី ២២ ខែ វិច្ឆិកា ២០១២

... យើងនៅតែខិតខំស្វះស្វែងរកឥណទានពីចិនក្នុងរង្វង់ពី ៣០០ ទៅ ៥០០ លានដុល្លារសហរដ្ឋអាមេរិក/ឆ្នាំ។ ប៉ុន្មានថ្ងៃមុននេះ បានចរចាជាមួយនឹងនាយករដ្ឋមន្ត្រី វេន ជាប៉ាវ ... នៅក្នុងឱកាសនៃការចរចានោះ គាត់បានស្នើសុំអោយមានការរៀបចំនូវអាទិភាពសម្រាប់ឆ្នាំ ២០១៣ ... **ឆ្នាំ ២០១៣ ត្រូវដាក់បញ្ចូលនូវគម្រោងផ្លូវលំក្រាលកៅស៊ូ មិនតិចជាង ៤០០ គីឡូម៉ែត្រក្នុងមួយឆ្នាំ ជារៀងរាល់ឆ្នាំ ក្នុងចន្លោះ ៣០០ ទៅ ៥០០ លានដុល្លារសហរដ្ឋអាមេរិក សម្រាប់(ការស្វែង**

រក)ឥណទានពីចិន ...។

៣. ហេដ្ឋារចនាសម្ព័ន្ធជនបទ ធ្វើអោយមានកំណើនសេដ្ឋកិច្ចជនបទ

> បើកការដ្ឋានកែលម្អផ្លូវជនបទ គំរោងកែលម្អផ្លូវ ប្រវែង ៥០៥,៤ គីឡូម៉ែត្រ
> ខេត្តពោធិសាត់, ថ្ងៃទី ០១ ខែ ធ្នូ ២០១១

ជារួម បងប្អូនប្រជាជនដែលរស់នៅក្នុងតំបន់គោលដៅរបស់គម្រោង នឹងពុំមានកង្វល់អំពីការហុយដីនៅរដូវប្រាំង ការអិលនៅរដូវវស្សា ដែលត្រូវធ្វើដំណើរទៅកាន់ទីកន្លែងផ្សេងៗ និងការដឹកជញ្ជូនកសិផលរបស់ពួកគាត់ ទៅកាន់ទីផ្សារទៀតឡើយ។ **(ការកសាង និងកែលម្អផ្លូវលំជនបទ) ពិតជាបានចូលរួមចំណែកយ៉ាងសំខាន់ សម្រាប់ជួយជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនៅជនបទ សំដៅលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន ឱ្យកាន់តែប្រសើរឡើង ពីមួយថ្ងៃទៅមួយថ្ងៃ និងឈានទៅលុបបំបាត់ភាពក្រីក្ររបស់ប្រជាជនកម្ពុជា នៅទូទាំងប្រទេសជាពិសេស ធ្វើឱ្យប្រជាជនជនបទនៅខេត្តទាំង ៧ មានកាលានុវត្តភាព និងមានសមត្ថភាពអាចស្រូបទាញយកអត្ថប្រយោជន៍អនុគ្រោះនៃការអភិវឌ្ឍជនបទ ទាំងក្នុងក្របខ័ណ្ឌជាតិ ក្របខ័ណ្ឌតំបន់ និងពិភពលោក ព្រមទាំងជំរុញល្បឿននៃការអភិវឌ្ឍជនបទ ឱ្យកាន់តែខ្លាំងក្លាថែមទៀត លើកកម្ពស់កម្រិតជីវភាពរស់នៅ ព្រមទាំងកាត់បន្ថយគម្លាតនៃការអភិវឌ្ឍរវាងទីក្រុង និងជនបទ ...។**

៤. ផ្លូវលំជនបទ ៧ ខេត្ត នឹងបង្កើតឱកាសការងារអោយយុវជន

> បើកការដ្ឋានកែលម្អផ្លូវជនបទ គំរោងកែលម្អផ្លូវ ប្រវែង ៥០៥,៤ គីឡូម៉ែត្រ
> ខេត្តពោធិសាត់, ថ្ងៃទី ០១ ខែ ធ្នូ ២០១១

... អាចនៅចាំបានថា ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ ១៩៧៩ ស្ថានភាពផ្លូវទាំងអស់នេះ ភាគច្រើន គឺជាផ្លូវលំតូចៗ ពេលនេះ ត្រូវធ្វើការកែលម្អទៅជាផ្លូវក្រាលកៅស៊ូពីរជាន់ ប្រភេទ DBST ... ក្នុងន័យនេះ យើងអាចមើលឃើញដោយត្រង់ពីផលប្រយោជន៍នៃផ្លូវ ក្នុងការកាត់បន្ថយនូវចំណាយថ្លៃដឹកជញ្ជូន កាត់បន្ថយពេលវេលាធ្វើដំណើរ បង្កភាពងាយស្រួល ក្នុងការធ្វើដំណើររបស់ប្រជាជនក្នុងផ្ទៃប្រទេស និងដល់ការដឹកជញ្ជូនជាលក្ខណៈតំបន់ ដែលតភ្ជាប់ទៅផ្លូវជាតិ និង

ផ្លូវខេត្ត ឆ្ពោះទៅកាន់ទីប្រជុំជនដទៃទៀត។ ម្យ៉ាងវិញទៀត **ដោយខេត្តទាំង ៧ ក៏ជាតំបន់ដែលមានតំបន់ទេសចរណ៍ធម្មជាតិ និងវប្បធម៌ដ៏ប្រណិតរបស់កម្ពុជា ដូច្នេះ ផ្លូវទាំងនេះនឹងទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិថែមទៀត នាពេលអនាគត ... លើសពីនេះ ខេត្តទាំង ៧ ជាតំបន់ដែលមានសក្តានុពល សម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម និងឧស្សាហកម្មផងដែរ ដែលការរីកចម្រើនឆាប់រហ័សនៃវិស័យទាំងនោះ នឹងផ្តល់ឱកាសបង្កើតការងារច្រើនទៀតដល់យុវជន ...**។

៥. ហេដ្ឋារចនាសម្ព័ន្ធជនបទ បញ្ជៀសការកេងប្រវ័ញ្ច បន្ទាបគុណភាពនិងថ្លៃ ចំណាកស្រុក

> បើកការដ្ឋានកែលម្អផ្លូវជនបទ គំរោងកែលម្អផ្លូវ ប្រវែង ៥០៥,៤ គីឡូម៉ែត្រ
> ខេត្តពោធិសាត់, ថ្ងៃទី ០១ ខែ ធ្នូ ២០១១

... ក្រៅពីភាពងាយស្រួលក្នុងការធ្វើដំណើរទៅមក ដឹកជញ្ជូនកសិផលទៅកាន់ទីផ្សារក្នុងតំបន់ ឬទៅទីផ្សារខេត្តក្រុងនានា (ក៏សម្រួលអោយ)ការដឹកជញ្ជូនឧបករណ៍ផលិតកម្មកសិកម្មពីទីប្រជុំជនទៅកាន់ជនបទវិញផងដែរ។ **សមិទ្ធផលនេះ នឹងផ្តល់កាលានុវត្តភាពជូនប្រជាជនឱ្យស្វែងរកបានទីផ្សារល្អ ផ្តល់លទ្ធភាពខ្ពស់ដល់កសិករ ចៀសវាងបានពីការកេងប្រវ័ញ្ច ការបន្ទាបគុណភាពកសិផលនិងការបន្ទាបថ្លៃ ដែលនាំឱ្យកសិករខាតបង់ប្រាក់ចំណូល បាត់បង់ក្តីសង្ឃឹមក្នុងការធ្វើស្រែចម្ការ សិប្បកម្មនានា និង ឈានទៅបោះបង់មុខរបរនេះ ហើយនាំគ្នាធ្វើចំណាកស្រុកស្វែងរកការងារ នៅតាមទីក្រុង ឬនៅក្រៅប្រទេស ...**។

៦. ផ្លូវលំចាក់កៅស៊ូ នឹងមានប្រសិទ្ធិភាពសេដ្ឋកិច្ចខ្ពស់

> បើកការដ្ឋានកែលម្អផ្លូវជនបទ គំរោងកែលម្អផ្លូវ ប្រវែង ៥០៥,៤ គីឡូម៉ែត្រ
> ខេត្តពោធិសាត់, ថ្ងៃទី ០១ ខែ ធ្នូ ២០១១

... ចំពោះមុខ និងតទៅអនាគត ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំព្រះករុណាខ្ញុំ នៅតែប្រកាន់ជំហរដ៏រឹងមាំ បន្តធន:ខិតខំប្រឹងប្រែង និងគាំទ្រយ៉ាងពេញទំហឹងជំរុញការស្តារ និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលជាគោលនយោបាយអាទិភាព។ ដោយឡែក **ខ្ញុំព្រះករុណាខ្ញុំ សូមគាំទ្រដល់ទិសដៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការកែលម្អ លើកកម្រិតផ្លូវ ដោយចាក់កៅស៊ូលើផ្លូវលំនានា**

ដើម្បីធានាអំពីការដឹកជញ្ជូនឱ្យមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់។ ក្នុងស្មារតីនេះ ខ្ញុំក៏សូមស្នើដល់អាជ្ញាធរខេត្ត-ក្រុងទាំងអស់ ពិនិត្យលទ្ធភាពក្នុងការកសាង និងស្តារកំណាត់ផ្លូវសំខាន់ៗ ដោយចាក់កៅស៊ូ ដើម្បីធានាបាននូវគុណភាពលើការដឹកជញ្ជូន ប្រសិទ្ធភាពសេដ្ឋកិច្ច និងសោភ័ណភាពផងដែរ ...។

៧. ការអភិវឌ្ឍតាមតំបន់ព្រំដែន ជា គោលដៅអាទិភាព និងសំណាញ់សុវត្ថិភាពសង្គម

ពិធីបិទសន្និបាទបូកសរុបការងារឆ្នាំ ២០១០ ក្រសួងអភិវឌ្ឍន៍ជនបទ,
២៩ ធ្នូ ២០១០

... សូមថ្លែងនូវការកោតសសើរចំពោះ ឯកឧត្តម ជា សុផារ៉ា ក៏ដូចជា គណៈកម្មាធិការអន្តរក្រសួង សប្បុរសជន ដែលបានជួយឧបត្ថម្ភជាថវិកា ក្រៅពីថវិការបស់រដ្ឋ កសាងផ្ទះមួយខ្នង ៣៧០០ ដុល្លារអាមេរិក ជូនគ្រួសារក្រីក្រ ... ការអភិវឌ្ឍនៅតាមតំបន់ព្រំដែន នៅតែជាគោលដៅអាទិភាព។ **ឆ្លងកាត់នូវបទពិសោធន៍មួយនេះ តម្រូវឲ្យយើងរៀបចំពលកម្មសង្គមឡើងវិញ ដើម្បីបម្រើឲ្យការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងបម្រើវិស័យការពារជាតិ។ នេះជាការផ្លាស់ប្តូរនៅក្នុងឥរិយាបថ និងផែនការជាយុទ្ធសាស្ត្ររបស់យើង ក្នុងនោះ ហេដ្ឋារចនាសម្ព័ន្ធតាមព្រំដែន ដែលមានផ្លូវក្រាលកៅស៊ូ មានផ្លូវលំ និងការចែកដីជូនក្រុមគ្រួសារកងទ័ព សម្រាប់ឲ្យពួកគាត់កសាងនូវជីវភាពរស់នៅ វាជាសំណាញ់សុវត្ថិភាពសង្គមមួយ សម្រាប់កងទ័ពនគរបាល អាវុធហត្ថ ដែលមិនគ្រាន់តែបច្ចុប្បន្នទេ នៅពេលដែលគាត់ចូលនិវត្តន៍ គាត់មានដីធ្លីហើយស្រេច ...។**

៨. អភិវឌ្ឍន៍ និងអភិរក្ស ជីវភាពជនជាតិភាគតិច

ពិធីបិទសន្និបាទបូកសរុបការងារឆ្នាំ ២០១០ ក្រសួងអភិវឌ្ឍន៍ជនបទ,
២៩ ធ្នូ ២០១០

... ខ្ញុំធ្លាប់ប៉ះពាក្យសំដីជាមួយ Peter Leuprecht តំណាងពិសេសអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលគាត់បាននិយាយជាមួយខ្ញុំថា ការអភិវឌ្ឍដំណាំកៅស៊ូនៅតំបន់ទំរីង ស្រុកស្នោង នឹងធ្វើឲ្យបាត់មុខរបរជនជាតិដើម។ ខ្ញុំប្រតិកម្មភ្លាមថា **តើឯកឧត្តមចង់ឲ្យខ្ញុំអភិវឌ្ឍន៍ជីវភាពប្រជាពលរដ្ឋ ឬឯកឧត្តមទុកឲ្យប្រជា**

ពលរដ្ឋខ្ញុំស្លៀកបឹង ពាក់កាដាទុក ឲ្យទេសចរណ៍មើល? ម្ខាងនិយាយពីការកាត់បន្ថយភាពក្រីក្រ ឯម្ខាងទៀតនិយាយពីការការក្សាមុខរបរដើមជនជាតិភាគតិច គឺការបោចផ្តៅ បោចវល្លិ រកជ័រទឹក ជ័ររុង និងការដាំស្រូវ ... អញ្ចឹងកូមិគំរូនៅទីនេះ ត្រូវធ្វើម៉េច? សម័យនេះ គាត់ជិះម៉ូតូដែរ ... មិនមែនភាគតិច ដើរជើងទទេទេ ... ត្រូវមើលឲ្យច្បាស់។ បើយើងមិនអភិរក្សទេ វាបាត់បង់ តែបើជ្រុលហួស វាទៅជាទុកឲ្យគាត់ស្ថិតក្នុងស្ថានភាពកាលពី ២០០ ឆ្នាំមុន ...។

៩. វប្បធម៌ចែករំលែក ជួយស្ត្រីមេម៉ាយ ជនចាស់ជរា ក្មេងកំព្រា ឆ្លងផុតការលំបាក

ពិធីបិទវេទិកាជាតិ ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ, ០៧ កក្កដា ២០០៩

... គ្មានប្រទេសណាមួយដែល មានកុមារកំព្រា និងស្ត្រីមេម៉ាយច្រើនជាងកម្ពុជាទេ បើគិតអត្រាភាគរយ។ ក្រោយរបប ប៉ុល ពត ប្រទេសនេះ មានកុមារកំព្រា និងជនចាស់ជរាគ្មានទីពឹងខ្ពស់បំផុត បើគិតតាមអត្រាភាគរយនៃចំនួនប្រជាជន។ ក៏ប៉ុន្តែ ដោយសារស្មារតីចែករំលែក ដែលជាវប្បធម៌ប្រពៃណីទំនៀមទំលាប់របស់ជនជាតិកម្ពុជានោះ បានធ្វើឲ្យកុមាររស់រានមានជីវិត។ វត្តអារាម សុទ្ធតែជាកន្លែងសម្រាប់ជួយពួកគេ ... នេះជាចំណុចនៃភាពល្អប្រសើររបស់សង្គមយើង ដែលទាមទាឲ្យមានការជួយថែរក្សា ហើយស្មារតីចែករំលែកនេះ វាបានកើតឡើងតាំងពីសម័យដែលទើបកើតមានទឹកដីមកនោះ ប៉ុន្តែគេបានបំភ្លេច។ ពេលនេះក៏បានកើតឡើងវិញ (ហើយនឹង)បន្តពីជំនាន់មួយទៅជំនាន់មួយ ...។

១០. ខិតខំកុំអោយប្រជាជននៅកៀកបន្ទាត់ក្រីក្រ ធ្លាក់ចុះទៅក្រីក្រវិញ

បើកសិក្ខាសាលាផ្សព្វផ្សាយយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨, ១៨ សីហា ២០១៤

... ខ្ញុំចង់និយាយបន្ថែមបន្ថែម ពាក់ព័ន្ធជាមួយនឹងបញ្ហាអាហារូបត្ថម្ភ ក៏ដូចជាស្ថានភាពទូទៅនៃការអភិវឌ្ឍប្រទេសរបស់យើង។ ពិតណាស់ហើយ អត្រានៃភាពក្រីក្របានទម្លាក់ពី ១០០% នៅឆ្នាំ ១៩៧៩ មកនៅត្រឹម ១៩% ឥឡូវនេះ អាចថានៅក្រោម ១៩% បន្តិច។ ប៉ុន្តែ ១៩% មិនមែនជាបញ្ហាតូចតាចទេ យើងគិតអត្រាប្រជាជន ១៥ លាននាក់ និង ១៩% តើនៅសល់ប៉ុន្មាន? ក្រៅពីនោះ ក៏នៅមាន

បញ្ហាពាក់ព័ន្ធនឹងអ្នកដែលនៅក្បែក ផុតហើយតែវានៅក្បែក តើនៅសល់ប៉ុន្មានភាគរយទៀត? ហើយនេះជាហានិភ័យមួយខ្ពស់ណាស់សម្រាប់យើង។ **ឆ្លងកាត់បន្ទាត់ភាពក្រីក្រហើយ ប៉ុន្តែនៅពេលមានគ្រោះទឹកជំនន់ រាំងស្ងួត ឬដោយប្រការណាផ្សេងៗ ងាយនឹងធ្លាក់មកនៅក្រោមបន្ទាត់នៃភាពក្រីក្រវិញ។ ឆ្នាំ ២០០៨ គឺជាឆ្នាំដែលចាប់ផ្តើមនៃវិបត្តិសេដ្ឋកិច្ចហិរញ្ញវត្ថុសកល ពេលនោះយើងពិតជាមានកង្វល់ថា អ្នកដែលឆ្លងកាត់បន្ទាត់ភាពក្រីក្រហើយ ងាយនឹងធ្លាក់មកក្រោមបន្ទាត់ភាពក្រីក្រវិញ ... យើងក៏ត្រូវតែខិតខំធ្វើយ៉ាងណាដើម្បីធានាថាពលរដ្ឋរបស់យើងនៅទី(ប្រឈមនៃគ្រោះធម្មជាតិ) មិនធ្លាក់ហួសដល់កម្រិតដែលពួកគាត់អាចបាត់បង់នូវអ្វីៗ ទាំងអស់នោះទេ ...**។

១១. បង្វែរពីអភិវឌ្ឍន៍តាមបែបបើកទូលាយ ទៅបែបស៊ីជម្រៅ(ក្នុងផលិតកម្មស្បៀង)

> បើកសិក្ខាសាលាផ្សព្វផ្សាយយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨, ១៨ សីហា ២០១៤

... ការអភិវឌ្ឍតាមបែបបើកទូលាយ ទៅកាន់ការអភិវឌ្ឍតាមបែបស៊ីជម្រៅ នៅតែជាគោលដៅរបស់រាជរដ្ឋាភិបាល។ អ្វីទៅដែលហៅថា បង្វែរពីការអភិវឌ្ឍតាមបែបបើកទូលាយ ទៅកាន់ការអភិវឌ្ឍតាមបែបស៊ីជម្រៅ(លើវិស័យស្បៀង)? ទម្លាប់របស់ប្រជាជនកម្ពុជាកាលសម័យដើម កាលណាមានសមាជិកគ្រួសារ ៥ នាក់ ត្រូវមានដីមួយហិកតា បើចំនួនគ្រួសារឡើងដល់ ១០ នាក់ ត្រូវមានដី ២ ហិកតា ឬ ៣ ហិកតា។ បើបន្តតាមរបៀបនេះតទៅទៀត ព្រៃឈើរបស់យើងត្រូវកាប់អស់នៅទូទាំងប្រទេសតែម្តង រួមនឹងការបន្តធ្វើចំណាកស្រុកទៅកាប់ទន្ទ្រានយកដីដោយអាណាធិបតេយ្យ ... ការចំណាយកម្លាំងពលកម្មកាន់តែច្រើន ដែលនាំមកវិញនូវផលចំណេញតិចតួច ឬអាចមិនចំណេញផង ...។

១២. បើដីជាន់គ្នា រវាងក្រុមហ៊ុន និងប្រជាពលរដ្ឋ ត្រូវអោយអាទិភាពទៅប្រជាពលរដ្ឋ

> បើកសិក្ខាសាលាផ្សព្វផ្សាយយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨, ១៨ សីហា ២០១៤

... បើយើញថា រវាងអ្នកវិនិយោគ ជាមួយនឹងប្រជាពលរដ្ឋ ដែលរ៉ាវ៉ាន់គ្នាក្នុងភាពមិនល្អាស់លាស់ ត្រូវឲ្យអាទិភាពទៅលើប្រជាពលរដ្ឋមុន មិនមែនឲ្យអាទិភាពទៅលើក្រុមហ៊ុនទេ។ ឥឡូវខ្ញុំសុំឲ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កសិកម្ម និងជនបទធ្វើកិច្ចការងារហ្នឹង ... តាំងពីអគារទីស្តីការគណៈរដ្ឋមន្ត្រីចាស់អត់ទាន់រុះរើ ពេលនោះប្រជុំជាមួយដៃគូ ខ្ញុំនិយាយអំពីស្ថានភាពស្បែកខ្លា អតីតអគ្គរដ្ឋទូតអាល្លឺម៉ង់ ស្នើឲ្យខ្ញុំរំឭក ហើយដាក់ចេញជាសូចនាករតាមដាន។ ប៉ុន្តែ ក្រោយមកអស់លោក (អត់)ធ្វើ បានជាបង្កើតរឿងបញ្ហាជម្លោះដីធ្លីនេះ។ ពិតហើយ មិនមែនរឿងណាសុទ្ធតែប្រជាពលរដ្ឋត្រូវទាំងអស់ទេ យុទ្ធសាស្ត្រឈ្នះបានដី ចាញ់បានលុយ គឺមានច្រើន។ ... ខ្ញុំអំពាវនាវឲ្យគ្រប់ទីកន្លែងពាក់ព័ន្ធខិតខំធ្វើការ ហើយកុំស្ងក់ពេក ស្ងក់រហូតទៅដល់ថា ប្រជាពលរដ្ឋមក គិតតែនាំគ្នាយកប៉ូលីសទៅខ្ទប់ បង្ខែរផ្លូវ រួចហើយទទួលយកញ្ជ្រិ ...។

១៣. បញ្ចូលមុខវិជ្ជាចលនាភូមិថ្មី រុញជនបទអោយកក្រើកឡើងក្នុងវិស័យសេដ្ឋកិច្ចសង្គម

បើកសិក្ខាសាលាផ្សព្វផ្សាយយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ២០១៤-២០១៨, ១៨ សីហា ២០១៤

... ខ្ញុំក៏បានធ្វើការសម្រេចរួចហើយ តាមរយៈសំណើរបស់ក្រសួងកសិកម្មផង និងក្រសួងអភិវឌ្ឍន៍ជនបទផង ទាក់ទងនឹងការបញ្ចូល "ចលនាភូមិថ្មី" ដែលមានការព្រមព្រៀងរវាងកម្ពុជា ជាមួយនឹងសាធារណរដ្ឋកូរ៉េ ជាមុខវិជ្ជា។ ខ្ញុំក៏បានស្នើសុំភាគីកូរ៉េបង្កើតនូវសាកលវិទ្យាល័យមួយ ដែលក្នុងចំណោមមុខវិជ្ជានានា ក៏មានចលនាភូមិថ្មីនៅទីនោះ ... យើងសម្រេចជំហានដំបូងនេះ គឺឱ្យសាលាដែលគ្រប់គ្រងដោយ ក្រសួងកសិកម្ម(ចំនួន)បី មានសាកលវិទ្យាល័យភូមិន្ទកសិកម្ម ចំការដូង, មានសាលាកសិកម្មព្រៃកលៀប និងសាលាកសិកម្មកំពង់ចាម បញ្ចូលនូវមុខវិជ្ជាទាក់ទិនទៅនឹងចលនាភូមិថ្មីនេះ។ ចលនាភូមិថ្មី កំពុងដើរស្របជាមួយនឹងភូមិឃុំមានសុវត្ថិភាពរបស់យើង។ យើងឃើញថា ខាងជប៉ុនមានចលនាភូមិមួយផលិតផលមួយ ឯខាងកូរ៉េ មានចលនាភូមិថ្មី អញ្ចឹងទេ យើងក៏បានអនុវត្តនូវចលនាភូមិថ្មីសាកល្បងលើតំបន់មួយចំនួន ... **យើងមិនគ្រាន់តែត្រូវការ(មុខវិជ្ជានេះ ដោយវា)ទាក់ទិនជាមួយនឹងការអភិវឌ្ឍក្នុងវិស័យផលិតកម្មទេ ក៏ប៉ុន្តែ**

ត្រូវការឱ្យមានគ្រប់ទិដ្ឋភាព ទាំងផលិតកម្ម ទាំងគុណធម៌ សីលធម៌ អនាម័យ ... សព្វបែបយ៉ាង រុញជនបទរបស់យើងឱ្យកក្រើកឡើង ទៅលើវិស័យសេដ្ឋកិច្ច ទៅលើវិស័យសង្គម ទៅលើវិស័យដទៃទៀត ...។

១៤. ការអភិវឌ្ឍ និងការអភិរក្ស កុំអោយមានសម្ពាធលើបរិស្ថានធម្មជាតិ

ពិធីបិទកិច្ចប្រជុំ ស្តីពី វិធានការ និងការការពារតំបន់ចឹងទន្លេសាប,
១២ សីហា ២០១០

... ដើម្បីចៀសវាងការពង្រីកគ្រួសារទៅលើដីថ្មីៗ នៅតំបន់អង្គរដែលត្រូវការ ៣ យើងបានកសាងភូមិមួយនៅរុនតាឯក ជាង ១០០០ គ្រួសារ គឺយកអ្នកដែលមានគ្រួសារថ្មីៗ។ ជាធម្មតា ឱ្យតែរៀបការហើយ គេតម្រូវឱ្យបែកផ្ទះ ដល់បែកផ្ទះ គាត់ត្រូវទៅកាប់រៀបផ្ទៃដីធ្វើផ្ទះបន្ថែម។ យូរៗទៅ តំបន់អង្គរមានសុទ្ធតែសំណង់ ទើបបានជាយើងរៀបចំនូវ(ភូមិគំរូ)រុនតាឯក ដែលឥឡូវ យើងលើកបានផ្ទះបានមួយចំនួនហើយ។ **យើងត្រូវរួមគ្នាគិត បើយើងគិតតែពី ផលប្រយោជន៍រយៈពេលខ្លី ដោយមិនគិតផលប្រយោជន៍រយៈពេលវែងនោះ គឺជាគ្រោះមហន្តរាយ ... ខ្ញុំស្នើឱ្យមានក្រុមអភិវឌ្ឍន៍ និងក្រុមអភិរក្ស ធ្វើជាដៃគូ ធ្វើការជាមួយគ្នា ធ្វើយ៉ាងម៉េចកាត់បន្ថយភាពក្រីក្ររបស់ពួកគាត់ (ដើម្បី)កុំឱ្យមានសម្ពាធទៅលើបរិស្ថានធម្មជាតិក្នុងចឹងទន្លេសាបធ្ងន់ធ្ងរ។** សេវាទេសចរណ៍នៅពេលខាងមុខ ក៏អាចបង្កើតនូវការងារមួយចំនួនបន្ថែមទៀតឱ្យពួកគាត់ ...។

១៥. ទំនាក់ទំនងស្និតរមួត រវាងកសិករ និងកម្មករ

សំណេះសំណាលជាមួយប្រជាពលរដ្ឋ ក្នុងពេលចុះពិនិត្យការងារបង្កបង្កើនផល
ឃុំសន្ទុង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល, ២ សីហា ២០១៣

... ពេលដែលអត់ទាន់មានរោងចក្រ យើងទាំងអស់គ្នាទាំងកូនទាំងចៅ នាំគ្នាចុះស្ទូង។ ដល់ទៅមានរោងចក្រ ចាប់ផ្តើមកូនចៅនាំគ្នាទៅធ្វើការនៅឯរោងចក្រ បានលុយពីរោងចក្រ យកមកជួលគេ ជាគោយន្តដើម្បីភ្ជួររាស់ និងម៉ាស៊ីនច្រូតជួលគេមកស្ទូង ... អ្នកជាក់លប ធ្វើស្រែផង ពេលចុះទៅលើកលបដិះម៉ូតូទៅ ... **ខ្ញុំចង់ស្វែងយល់ថា តើយើងមានតម្រូវការអីទៀត ក្នុងទំនាក់ទំនងជាកសិករផង**

និងកម្មករផង? (ខណៈដែល) តំបន់ជិតខាងចាប់ផ្តើមមានរោងចក្រមកដល់ បូកជាមួយរោងចក្រនៅទីក្រុងភ្នំពេញ និងនៅខេត្តកណ្តាល ហើយនៅក្នុងខ្សាច់កណ្តាលនេះ ក៏មានរោងចក្រនៅទីនេះដែរ។ អញ្ចឹងទេ **ចំណុចនេះ គឺជាការបំពេញឲ្យគ្នាដើម្បីដោះស្រាយបញ្ហា ... ទាមទារឲ្យយើងមានការស្រុះស្រួល នៅក្នុងគ្រួសារ និងការសម្របសម្រួលពលកម្ម។** យើងអត់បង្ខំបានទេ។ គ្រួសារនីមួយៗ គិតខ្លួនឯងទៅ ... យើងដាក់ផែនការដូច អាពត ប៉ុណ្ណោះទៅធ្វើស្រែ ប៉ុណ្ណោះទៅធ្វើកម្មករ ប៉ុណ្ណោះទៅធ្វើចំការកៅស៊ូ អត់បានទេ ...។

១៦. បន្ថយគម្លាតសេវាសុខាភិបាល រវាងទីក្រុង និងជនបទ

ពិធីបើកសន្និសីទអន្តរជាតិ ស្តីពីសុខភាពកម្ពុជា ឆ្នាំ ២០០៨ សាលាពេទ្យ, រាជធានីភ្នំពេញ, ០៦ តុលា ២០០៨

... ដូចខ្ញុំបានជម្រាបខាងលើពីគម្លាតរវាងទីក្រុង និងជនបទ យើងត្រូវតែមានការគិតគូរពីគោលដៅដែលយើងត្រូវទៅ រាប់ទាំងមូលដ្ឋានដែលយើងត្រូវរៀបចំ និងបែងចែកឡើងវិញនូវគ្រូពេទ្យ។ ស្ទើរតែគ្រប់វេទិកានៃការជួបមន្ត្រីសុខាភិបាល ខ្ញុំតែងតែផ្តល់នូវយោបល់ ពាក់ព័ន្ធជាមួយនឹងការបែងចែកគ្រូពេទ្យឡើងវិញ ... នេះជាបញ្ហាប្រឈមយូរអង្វែងរបស់យើង ក្នុងការដោះស្រាយ ហើយមានការទាក់ទងច្រើនណាស់ មិនមែនគ្រាន់តែកង្វះផ្នែកសុខាភិបាលមួយមុខទេ ដើម្បីឱ្យគ្រូពេទ្យទៅតំបន់ដាច់ស្រយាលបាន គឺចាប់ផ្តើមតាំងពីវិស័យគមនាគមន៍ដឹកជញ្ជូន, ផ្លូវថ្នល់ សន្តិសុខ និងបញ្ហាដទៃទៀត។ បញ្ហានេះ ត្រូវមានការគិតគូរជាកញ្ចប់ ... ពិតមែនតែតំបន់ខ្លះមានមូលដ្ឋានគ្រប់គ្រាន់ ប៉ុន្តែខ្វះការយកចិត្តទុកដាក់ ... ឧទាហរណ៍ ផ្លូវថ្នល់មានហើយ កន្លែងដែលអាចរៀបចំមានហើយ គ្រូពេទ្យមានហើយ ក៏ប៉ុន្តែខាងផ្នែកសុខាភិបាលខ្លួនឯង មិនបានយកចិត្តទុកដាក់។ នេះជាចំណុចដែលត្រូវយកចិត្តទុកដាក់ក្នុងការពិភាក្សា។ ខ្ញុំគិតថា យើងគួរតែធ្វើឱ្យមានការផ្លាស់ប្តូរក្នុងរយៈពេល ៥ ឆ្នាំ ខាងមុខនៃអាណត្តិទី ៤ នេះ តែយើងមិនមែនរង់ចាំឆ្នាំ ២០១៣ នោះទេ។ កន្លែងដែលយើងធ្វើបានមុន យើងត្រូវខិតខំធ្វើមុន ព្រោះម្តងមួយ ម្តងពីរ ម្តងបី ជាបណ្តើរៗ ...។

ខ្សាហកម្ម និងសិប្បកម្ម

១	គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម បង្កើនឧត្តមភាពប្រៀបធៀបថ្មី	២៨៧
២	ឧស្សាហកម្មអតិពលកម្ម ស្រូបបានកម្មករប្រមាណជា ៦០ ម៉ឺននាក់	២៨៧
៣	ឧស្សាហកម្មបច្ចេកវិទ្យាខ្ពស់ ត្រូវការធនធានមនុស្ស/ហេដ្ឋារចនាសម្ព័ន្ធ	២៨៨
៤	កម្ពុជាសល់លំហសំរាប់ការវិនិយោគ/ធ្វើទំនើបកម្មវិស័យឧស្សាហកម្ម	២៨៩
៥	កាលានុវត្តភាពក្នុងបរិការណ៍ការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន	២៨៩
៦	កម្ពុជាឈានដល់ឧស្សាហកម្មពលកម្មសកម្មនៅឆ្នាំក្រោយ	២៩០
៧	សូមកម្មករ/ការិនី កុំបំបែកឆ្នាំងបាយខ្លួនឯង	២៩១
៨	៤ ចំណុច គួរលើកទឹកចិត្ត/កោតសរសើរដល់ក្រុមហ៊ុន កូកាកូឡា	២៩១
៩	ពីនាយកដ្ឋានទឹកស្អាត ទៅអគ្គនាយកដ្ឋាននៃឧស្សាហកម្មនិងសិប្បកម្ម	២៩២
១០	គ្រប់ក្រសួង និងស្ថាប័ន ចូលរួមអនុវត្តគោលនយោបាយឧស្សាហកម្ម	២៩២
១១	សិក្សាតំបន់ឧស្សាហកម្មថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ	២៩៣
១២	ក្រុមហ៊ុន មីនីបៀ ជាក្រុមហ៊ុនផលិតម៉ូទ័រ មិនមែនផលិតស្រាបៀរទេ	២៩៣
១៣	អំពៅ ជាកសិឧស្សាហកម្មផង ជាកសិពាណិជ្ជកម្មផង	២៩៤

១. គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម បង្កើនឧត្តមភាពប្រៀបធៀបថ្មី

វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី ១៧, ថ្ងៃទី ០៤ មីនា ២០១៤

... **រាជរដ្ឋាភិបាលមានបំណងលើកស្ទួយផលិតកម្ម បង្កើនភាពប្រកួតប្រជែង និងច្បាមយកតម្លៃបន្ថែមឲ្យបានកាន់តែច្រើន នៅក្នុងវិស័យសំខាន់ៗ ដែលមានស្រាប់ រួមមានៈ វិស័យកសិកម្ម ឧស្សាហកម្មកាត់ដេរ និងទេសចរណ៍ ព្រមទាំងលើកស្ទួយប្រភេទឧស្សាហកម្មថ្មីៗ ដែលមានសក្តានុពលរីកលូតលាស់ និងខិតខំបង្កើនឧត្តមភាពប្រៀបធៀបថ្មី ក្នុងវិស័យឧស្សាហកម្មកម្ពុជា**។ គោលនយោបាយនេះ នឹងជួយកម្ពុជាឲ្យត្រៀមខ្លួនជាស្រេច សម្រាប់ទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស ដែលបច្ចុប្បន្នកំពុងមាននិន្នាការផ្លាស់ប្តូរទីតាំងមូលដ្ឋានផលិតកម្ម ពីប្រទេសចិន និងប្រទេសមួយចំនួនក្នុងតំបន់ ដោយសារកត្តាប្រាក់ឈ្នួលខ្ពស់ពេក។ ជោគជ័យនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម នឹងបង្កើតការងារថ្មីដល់ក្មួយៗយុវជន យុវនារី ដែលនឹងត្រូវចូលក្នុងទីផ្សារការងារ។ ចំណុចដែលបានលើកឡើងខាងលើ ពុំមែនជាការស្រមើស្រមៃរបស់រាជរដ្ឋាភិបាលទេ ប៉ុន្តែជាការប្តេជ្ញាចិត្តដើម្បីភាពរីកចម្រើនរបស់ប្រទេស ដើម្បីឱកាសការងារ និងកំណើនជីវភាពប្រជាពលរដ្ឋ សង្ឃឹមថាគ្រប់គ្នាទទួលបានអត្ថប្រយោជន៍ពីការលូតលាស់សេដ្ឋកិច្ចជាតិដោយសមធម៌... ។

២. កម្ពុជាចាប់ផ្តើមពីឧស្សាហកម្មអតិពលកម្ម ស្រូបបានកម្មករប្រមាណជា ៦០ ម៉ឺននាក់

ពិធីសម្ពោធរោងចក្រកេសជ្ជ: ក្វាកូឡា នៃក្រុមហ៊ុនកេសជ្ជ:កម្ពុជា,
ថ្ងៃទី ៥ ធ្នូ ២០១៦

... កាលពីពេលមុន **យើងប្រឹងខ្លាំងណាស់ ដើម្បីឲ្យមានឧស្សាហកម្ម ហើយចាប់ផ្តើមពីឧស្សាហកម្មអតិពលកម្ម ដែលប្រើប្រាស់កម្លាំងពលកម្មច្រើន ដើម្បីដោះស្រាយការងារឲ្យកម្មករ**ិនី ជាពិសេស **ក្នុងចំណោមយុវជនរបស់យើង។ ដូច្នេះ** រោងចក្រកាត់ដេរទាំងឡាយបានប្រមូលផ្តុំនៅលើទឹកដីកម្ពុជា **តាំងពីទំហំនៃការនាំចេញរបស់យើងត្រឹមតែប៉ុន្មានលានដុល្លារ ឡើងទៅដល់រាប់ពាន់លានដុល្លារសហរដ្ឋអាមេរិក។** ឥឡូវឡើងដល់ប៉ុន្មានពាន់លានដុល្លារហើយ? ៥ ពាន់

លានដុល្លារសហរដ្ឋអាមេរិក។ យើងមិនអាចអភិវឌ្ឍប្រទេសមួយ ដោយពឹងផ្អែកទៅលើកសិកម្មតែមួយមុខទេ ដូចជា ប៉ុល ពត ប្រើពាក្យថា មានស្រូវមានអ្វីៗទាំងអស់ លុបចោលខ្ទេចរោងចក្រ សហគ្រាស ឧស្សាហកម្ម សិប្បកម្ម រាប់ទាំងផ្សារលក់ដូរ ... យើងត្រូវធ្វើទាំងអស់ ទាំងកសិកម្ម ទាំងឧស្សាហកម្ម ហើយឧស្សាហកម្មក៏មានជម្រើសគោលនយោបាយឧស្សាហកម្មទៀត ... **ឧស្សាហកម្មដំណាក់កាលអតិពលកម្ម បានស្រូបយកកម្មករប្រមាណជា ៦០ ម៉ឺននាក់ រាប់ទាំងសេវាផង។ កម្មករបស់យើងដែលធ្វើការនៅគ្រប់ទីកន្លែងទាំងអស់ គឺសឹងតែជល់លាននាក់ទៅហើយ ...**។

៣. ឧស្សាហកម្មប្រើបច្ចេកវិទ្យាកាន់តែខ្ពស់ ត្រូវការធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធ

ពិធីសម្ពោធរោងចក្រកេសជ្ជ: កូកាកូឡា នៃក្រុមហ៊ុនកេសជ្ជ:កម្ពុជា,
ថ្ងៃទី ៥ ធ្នូ ២០១៦

... យើងចាំបាច់ត្រូវមាន**គោលនយោបាយឧស្សាហកម្មមួយផ្សេងទៀត ដើម្បីជម្រុញឧស្សាហកម្មដែលមានបច្ចេកវិទ្យាកាន់តែខ្ពស់ ដូចជាឧស្សាហកម្មប្រភេទនេះ ក៏ជាប្រភេទមួយប្រើបច្ចេកវិទ្យាខ្ពស់ ដែលហៅថាឧស្សាហកម្មខ្នាតពិភពលោក** ដូច(ម៉ូទ័រ)មីនីបៀរបស់ជប៉ុន ដែលខ្ញុំមកខានស្អែកនេះ ថ្ងៃ ៨ នេះ ផលិតនៅកម្ពុជា ក៏ប៉ុន្តែចែកចាយទូទាំងពិភពលោក។ ម៉ូទ័រនេះ ប្រើគ្រប់ទាំងអស់ ទូរស័ព្ទក៏ប្រើម៉ូទ័រ វិទ្យុក៏ប្រើម៉ូទ័រ ម៉ាស៊ីនថតក៏ប្រើម៉ូទ័រ រហូតមានម៉ូទ័រដែលអាចលេបហើយ ដើម្បីជំនួសឲ្យការបញ្ចុះ ព្រោះធម្មតាគេថតក្រពះថតអីនេះ។ នៅតំបន់ឧស្សាហកម្មកោះកុង មានរោងចក្រផលិតរថយន្ត ឬខ្ជួរក្បាលរថយន្ត ដែលគេយកទៅចែកចាយ រាប់ទាំងរថយន្តដែលផលិតនៅអាមេរិក ... **យើងត្រូវមានការបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃទីផ្សារពលកម្មដែលកាន់តែខ្ពស់ទៅ សម្រាប់ការចូលមកវិនិយោគ នៃក្រុមហ៊ុនដែលត្រូវការវិនិយោគ។ យើងក៏ត្រូវការកសាងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ផ្សេងៗ ការជីកជញ្ជូនកំពង់ផែ ព្រលានយន្តហោះ និងបញ្ហាអគ្គិសនី ...**។

៤. កម្ពុជានៅមានលំហសម្រាប់ការវិនិយោគ/កម្ពុជាត្រូវធ្វើទំនើបកម្មវិស័យឧស្សាហកម្ម

ពិធីបើកសន្និសីទវិនិយោគអន្តរជាតិឆ្នាំ ២០១៤ ក្រោមប្រធានបទ សក្តានុពលថ្មីនៃកាលានុវត្តភាព «កំណើនការផ្លាស់ប្តូរ និងសមាហរណកម្មអាស៊ាន», ថ្ងៃទី ៦ តុលា ២០១៤

... សេដ្ឋកិច្ចកម្ពុជា នៅមានសក្តានុពលរីកលូតលាស់ខ្ពស់ និងមានកាលានុវត្តភាពធ្វើពិពិធកម្មក្នុងវិស័យជាច្រើនទៀត ដែលនេះអាចបញ្ជាក់យ៉ាងច្បាស់ថា កម្ពុជានៅមានលំហ សម្រាប់ការវិនិយោគក្នុងចំនួនដ៏ច្រើន នាពេលខាងមុខ។ បច្ចុប្បន្នវិស័យកាត់ដេរ, ទេសចរណ៍, សំណង់, និងវិស័យកសិកម្ម ជាជនួ្ទល់នៃកំណើនរបស់កម្ពុជា ចង្អុលបង្ហាញពីភាពចាំបាច់ត្រូវវិនិយោគច្រើនថែមទៀត ក្នុងវិស័យផ្សេងៗ ដើម្បីបង្កើតក្បាលម៉ាស៊ីននៃកំណើនថ្មីៗ... ពីព្រោះខណៈនេះ កម្ពុជាត្រូវធ្វើ**ទំនើបកម្មនៃវិស័យឧស្សាហកម្មរបស់ខ្លួន ជាកិច្ចការដ៏ចាំបាច់មួយ ដោយវិស័យនេះនឹងដើរតួនាទីសំខាន់ក្នុងយុទ្ធសាស្ត្រកំណើន, ជាកម្លាំងចលករក្នុងការទ្រទ្រង់ជល់កំណើនរយៈពេលមធ្យម និងរយៈពេលវែង, ជាវិស័យសក្តានុពលសម្រាប់បង្កើតការងារជល់យុវជន និងជាជនួ្ទល់កំណើនសេដ្ឋកិច្ចថ្មី ដែលអាចស្រូបយកការវិនិយោគបន្ថែម ក្រៅពីវិស័យកសិកម្ម និងទេសចរណ៍...** ។

៥. កាលានុវត្តភាពកម្ពុជា ក្នុងបរិការណ៍ការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន

ពិធីបើកសន្និសីទវិនិយោគអន្តរជាតិឆ្នាំ ២០១៤ ក្រោមប្រធានបទ សក្តានុពលថ្មីនៃកាលានុវត្តភាព «កំណើនការផ្លាស់ប្តូរ និងសមាហរណកម្មអាស៊ាន», ថ្ងៃទី ៦ តុលា ២០១៤

... កម្ពុជាកំពុងទទួលបាននូវសក្តានុពលខ្ពស់ ក្នុងបរិការណ៍នៃការផ្លាស់ប្តូរនិម្មាបនកម្មតំបន់, ការបង្កើតឡើងនូវសហគមន៍សេដ្ឋកិច្ចអាស៊ាន និងភាពជាដៃគូសេដ្ឋកិច្ចតំបន់គ្រប់ជ្រុងជ្រោយ ដែលនឹងផ្តល់នូវកាលានុវត្តភាពសំខាន់ សំរាប់ការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា តាមរយៈការពង្រឹងការតភ្ជាប់ និងការពង្រីកវិជ្ជមាត្រសេដ្ឋកិច្ចតំបន់ និងកំណើននៃវិស័យពាណិជ្ជកម្ម និងផលិតកម្មក្នុងតំបន់។ ជាមួយនេះ ការផ្លាស់ប្តូររចនាសម្ព័ន្ធក្នុងតំបន់ ដូចជាកំណើនប្រាក់ឈ្នួលនៅចិន, ថៃ និងវៀតណាម ការរីកចម្រើននៃវិស័យឧស្សាហកម្មនៅទីក្រុងបាងកក និងទីក្រុងហូជីមិញ ព្រមទាំងគំនិតផ្តួចផ្តើមក្នុងការតភ្ជាប់ផ្លូវឧស្សា

ហាកម្ម រវាងប៉ូលទាំងពីរ **នឹងក្លាយជាកាលានុវត្តភាពសំខាន់មួយទៀត សំរាប់សមាហរណកម្មកម្ពុជា ទៅក្នុងខ្សែសង្វាក់ផលិតកម្មតំបន់ និងសកលដែលនឹងក្លាយជាកត្តាអំណោយផលដល់ការរីកលូតលាស់ នៃឧស្សាហកម្មនៅកម្ពុជា ... វិនិយោគិននឹងទទួលបាននូវការលើកទឹកចិត្តបន្ថែមទៀត ខណៈពេលដែលកម្ពុជាដាក់ចេញនូវ "គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម" ក្នុងន័យជម្រុញកំណើន ជម្រុញពិពិធកម្មសេដ្ឋកិច្ច ការផ្លាស់ប្តូររចនាសម្ព័ន្ធស៊ីជម្រៅ និងធ្វើឱ្យប្រសើរឡើងនូវភាពប្រកួតប្រជែងរបស់កម្ពុជា ...**។

៦. កម្ពុជាឈានដល់ឧស្សាហកម្មពលកម្មសកម្មនៅឆ្នាំក្រោយ

ពិធីចែកសញ្ញាបត្រនិស្សិត គរុនិស្សិត នៃវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស, ថ្ងៃ ០៧ វិច្ឆិកា ២០១៦

...ខ្ញុំបាននិយាយនៅក្នុងវេទិកាសេដ្ឋកិច្ចពិភពលោកទាក់ទងនឹងមេគង្គថា កាលពីមុនកម្ពុជាធ្វើឧស្សាហកម្មប្រើមនុស្សច្រើន ដោយប្រើពាក្យថា ពលកម្មតម្លៃថោក។ ឥឡូវនេះ កម្ពុជាមិនអាចនឹងប្រើពាក្យហ្នឹងបានទៀតទេ។ កម្ពុជាបានដើរដល់កម្រិតដែលនឹងអនុវត្ត ១៥៣ ដុល្លារ (ការផ្តល់ប្រាក់ខែអប្បបរិមា) សហរដ្ឋអាមេរិក ដែលមុននេះ យើងបានចាប់ផ្តើមពីប្រាក់ហ្ការ៉ូ (តែ) ជាង ៣០ ដុល្លារអាមេរិកតែប៉ុណ្ណោះ។ **ឥឡូវ យើងប្រើពាក្យមិនមែនពលកម្មថោកទេ គឺពលកម្មសកម្ម ដែលចាប់ផ្តើមអនុវត្តន៍ឆ្នាំក្រោយ ... យ៉ាងណាក៏ដោយ សូមអំពាវនាវអោយអ្នកទទួលសញ្ញាបត្រនៅថ្ងៃនេះ ប្រឹងបន្តឈានឡើងពីដំណាក់កាលដែលយើងមានសព្វថ្ងៃ ទៅកាន់ដំណាក់កាលខ្ពស់ជាង ព្រោះប្រទេសរបស់យើងត្រូវការអភិវឌ្ឍខ្ពស់ជាងដែរ ហើយក្រសួងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ត្រូវបន្តជាមួយនឹងការពង្រឹងសមត្ថភាពរបស់គ្រូ/សាស្ត្រាចារ្យ ដើម្បីការបណ្តុះបណ្តាលកាន់តែខ្ពស់ទៅ។ គុណភាពកាន់តែល្អប្រសើរឡើង ឈានទៅដំណាក់កាលឧស្សាហកម្ម**កាន់តែខ្ពស់ ...។

៧. សូមកម្មករ/ការិនី កុំបំបែកឆ្នាំងបាយខ្លួនឯង

ពិធីបើកសន្និសីទវិនិយោគអន្តរជាតិឆ្នាំ ២០១៤ ក្រោមប្រធានបទ សករាជថ្មីនៃកាលានុវត្តភាព «កំណើនការផ្លាស់ប្តូរ និងសមាហរណកម្មអាស៊ាន», ថ្ងៃទី ៦ តុលា ២០១៤

ខ្ញុំព្រះករុណាខ្ញុំ ចង់និយាយនៅទីនេះ មិនត្រឹមតែជាមួយកម្មករ/ការិនី ជាង ១ ម៉ឺននាក់ នៅក្រុងព្រះសីហនុ នេះទេ ក៏ប៉ុន្តែ កម្មករ/ការិនី នៅទូទាំងប្រទេស ក្នុងវិស័យឧស្សាហកម្ម និងសេវា ទាំងអស់ជាងមួយលាននាក់ ... **សួរថា បើសិនជារោងចក្រនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសនេះបិទ ក្ជួយៗ នឹងរំលៃត្រឡប់ទៅធ្វើស្រែចំការវិញ គ្មានប្រាក់ចំណូលទៀតទេ។ ដូច្នេះ សង្ឃឹមថាកម្មករ/ការិនី ខិតខំដើម្បីឆ្នាំងបាយ ចាត់ទុកតំបន់សេដ្ឋកិច្ចពិសេស រោងចក្រសហគ្រាសដែលយើងកំពុងធ្វើការជាឆ្នាំងបាយរបស់ខ្លួន។ សូមអ្នកកុំភ្លេចថា នៅពេលដែលមានការដកចេញនូវការវិនិយោគពីប្រទេសកម្ពុជា អ្នកខាតបង់មុនគេ គឺកម្មករ/ការិនីកម្ពុជា ...**។

៨. ៤ ចំណុច ដែលគួរត្រូវបានលើកទឹកចិត្ត និងកោតសរសើរដល់ក្រុមហ៊ុន កូកាកូឡា

ពិធីសម្ពោធរោងចក្រកេសជ្ជៈ កូកាកូឡា នៃក្រុមហ៊ុនកេសជ្ជៈកម្ពុជា, ថ្ងៃ ៥ ធ្នូ ២០១៦

... ខ្ញុំគួរតែនិយាយដល់ ៤ ចំណុច ដែលគួរតែបានលើកទឹកចិត្ត និងសរសើដល់ក្រុមហ៊ុន កូកាគូឡា ដែលចាប់ផ្តើមវិនិយោគពីតូចទៅធំ។ កាលពីសម័យដើម យើងមានក្រុមហ៊ុន 7up មួយ ប៉ុន្តែ ទីតាំង 7up នោះ ក្លាយទៅជាទីតាំងកូកាកូឡា នៅឯឫស្សីកែវឯណោះ។ **អ្វីដែលជាការគួរឲ្យកត់សម្គាល់នៅត្រង់ថា តាមរបាយការណ៍ស្ថិតិនេះ គឺក្រុមហ៊ុន បានប្រើជនជាតិកម្ពុជាយើងចំនួន ៩៩,៧%។ ដូច្នេះ វាជាការលើកទឹកចិត្តធំណាស់សម្រាប់ការប្រើប្រាស់ និងការបណ្តុះបណ្តាលធនធានមនុស្សនៅក្នុងស្រុក**។ ខ្ញុំមានការពេញចិត្ត ហើយមោទនភាពចំពោះជនជាតិកម្ពុជា ដែលមានឱកាសធ្វើការងារស្របតាមតម្រូវការបច្ចេកទេសរបស់អស់លោក។ ទី ២ ... ការ**ចូលរួមក្នុងកិច្ចការសង្គម ដែលអស់លោកបានធ្វើទាក់ទងទៅនឹងសុវត្ថិភាពចរាចរណ៍ ទាក់ទងជាមួយនឹងបញ្ហាជំងឺទៀត** រាប់ទាំងទាក់ទងនឹងការបណ្តុះបណ្តាលធនធានមនុស្ស តាមរយៈការផ្តល់អាហារូបករណ៍។ ទី ៣ .**ធ្វើអោយកម្ពុជាមានមោទនភាព តាមរយៈដាក់អក្សរខ្មែរ**

លើកំប៉ុងកូកាកូឡា និងទី ៤ ក្រុមហ៊ុនបានបង្ក្លលក្ខណៈបង្កើតជាលំនៅដ្ឋាន សម្រាប់ការស្នាក់នៅរបស់កម្មករ ការិនីដោយ/តម្លៃសមរម្យ ...។

៩. ពីនាយកដ្ឋានទឹកស្អាត ទៅអគ្គនាយកដ្ឋាន នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ពិធីសម្ពោធដាក់អោយប្រើប្រាស់នូវប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ខេត្តបាត់ដំបង
និងខេត្តកំពង់ចាម, ថ្ងៃ ២១ កក្កដា ២០១៦

... មានមោទនភាពចំពោះវឌ្ឍនភាពដែលបានកើតឡើងក្នុងរយៈកាលកន្លងទៅនេះ ក្នុងនោះ ការផ្គត់ផ្គង់ទឹកស្អាតកាន់តែប្រសើរពីមួយថ្ងៃទៅមួយថ្ងៃ បន្ថែមទៅដោយមានក្រុមហ៊ុនផលិតទឹកស្អាតយ៉ាងច្រើន ... ប៉ុន្មានថ្ងៃមុននេះ ខ្ញុំព្រះករុណាខ្ញុំ បានចុះហត្ថលេខា**តម្លើងនាយកដ្ឋានទឹកស្អាតនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ពីថ្នាក់នាយកដ្ឋានអោយទៅជាអគ្គនាយកដ្ឋាន ដើម្បីបង្កើនការទទួលខុសត្រូវ។ នេះជាជំណើរកំណែទម្រង់មួយ ជំរុញល្បឿននៃការដោះស្រាយទឹកស្អាតបន្ថែមទៀត យោងទៅតាមការទាមទារនូវលក្ខណៈបច្ចេកទេស និងធនធានមនុស្ស បម្រើដល់សេចក្ដីត្រូវការទាំងឡាយនៃការអភិវឌ្ឍរបស់ប្រទេសរបស់យើង**។ ជាថ្មីម្ដងទៀត តាមរយៈ ឯកឧត្តម គូម៉ាម៉ារ៉ូ សូមផ្ញើជូនចំពោះការអរគុណរបស់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ជូនចំពោះរដ្ឋាភិបាល និងប្រជាជនជប៉ុន ក្នុងការផ្ដល់ជំនួយបែបនេះដល់កម្ពុជា ។...

១០. គ្រប់ក្រសួង និងស្ថាប័ន ចូលរួមអនុវត្តគោលនយោបាយឧស្សាហកម្ម

ពិធីប្រកាសផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តគោលនយោបាយអភិវឌ្ឍវិស័យ
ឧស្សាហកម្មកម្ពុជា ២០១៥-២០២៥, ថ្ងៃ ២៦ សីហា ឆ្នាំ២០១៥

... **កុំយើញថាគោលនយោបាយឧស្សាហកម្មនេះ សម្រាប់តែក្រសួងឧស្សាហកម្ម។ គ្រប់ផ្នែក គ្រប់ភ្នអង្គ សុទ្ធតែមានការពាក់ព័ន្ធទាំងអស់។ តិចថា ក្រសួងធនធានទឹក អត់ពាក់ព័ន្ធអ្វីទាំងអស់។ កុំភ្លេចថា ក្រសួងធនធានទឹកហ្នឹងកាន់តែសំខាន់ ព្រោះត្រូវរកទឹកអោយគេផលិតចេញជាវត្ថុធាតុដើម សំរាប់ឧស្សាហកម្មនេះឯង។ ត្រូវមើលឃើញឲ្យច្បាស់ ក្រសួងនីមួយៗ សុទ្ធតែមានការពាក់ព័ន្ធ បើទោះបីថាក្រសួងខ្លះមានការងារច្រើន ក្រសួងខ្លះមានការងារតិច** រហូតដល់អត់

មានឈ្មោះក្រសួងខ្លះ ក៏ប៉ុន្តែ សុំកុំភ្លេចថា យើងមិនស្ថិតនៅតែលតោលក្រៅពីក្របខណ្ឌរួមនោះទេ។ ត្រូវទទួលស្គាល់ថា នេះជាកិច្ចការរួមរបស់យើង មិនមែនជាកិច្ចការដោយឡែករបស់ស្ថាប័នណាមួយនោះទេ ។...

១១. សិក្សាតំបន់ឧស្សាហកម្មថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ពិធីប្រកាសផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តគោលនយោបាយអភិវឌ្ឍវិស័យ
ឧស្សាហកម្មកម្ពុជា ២០១៥-២០២៥, ថ្ងៃ ២៦ សីហា ឆ្នាំ២០១៥

... ខេត្តរាជធានី ត្រូវគិតគូរឲ្យបានច្បាស់។ ស្ថាប័នថ្នាក់ជាតិគ្មានដីទេ...ត្រូវតែសិក្សាគ្រប់ទីកន្លែងទាំងអស់ ថាតំបន់ណានឹងក្លាយទៅជាតំបន់ឧស្សាហកម្ម, តំបន់ណាដែលអាចឲ្យមានរោងចក្រសហគ្រាស។ នេះជាចំណុចដែលត្រូវឆ្លើយតប ព្រោះមិនមែនជាបញ្ហាដាច់ដោយឡែករបស់ថ្នាក់ជាតិទេ។ អាជ្ញាធរថ្នាក់ក្រោមជាតិមានតួនាទីសំខាន់ រាប់ទាំងទីតាំងតំបន់រោងចក្រផងដែរ។ យើងមានគោលបំណងមិនមែនគ្រាន់តែប្រមូលផ្តុំរោងចក្រនៅទីក្រុងភ្នំពេញទេ។ យើងចង់ឲ្យរោងចក្ររាយប៉ាយទៅតាមបណ្តាខេត្ត។ អញ្ចឹងខេត្តប្រណាំងប្រជែង ក្នុងការទាញឧស្សាហកម្ម ឬសិប្បកម្មទៅកាន់តំបន់របស់ខ្លួន ដើម្បីជម្រុញនូវកំណើនសេដ្ឋកិច្ចកាត់បន្ថយភាពក្រីក្រនៅទីនោះ។ នៅតំបន់ខ្លះ មិនមានការចាំបាច់សោះ ក្នុងការដឹកវត្ថុធាតុដើមចេញត្រូវត្រៀមខ្លួនទទួលនូវការរៀបចំ...តំបន់រោងចក្រដែលនឹងត្រូវកើតថ្មីៗ មិនត្រូវប្រមូលផ្តុំតែមួយកន្លែងនោះទេ ហើយពលករក៏ងាយដោះស្រាយជាងប្រមូលផ្តុំនៅទីក្រុងភ្នំពេញ។...

១២. ក្រុមហ៊ុន មីនីបៀ ជាក្រុមហ៊ុនផលិតម៉ូទ័រ មិនមែនផលិតស្រាបៀរទេ

ពិធីអបអរសាទរខួប ៥ ឆ្នាំ នៃប្រតិបត្តិការរបស់ក្រុមហ៊ុន មីនីបៀ (ខេមបូឌា)
ខូអិលធីឌី នៅកម្ពុជា, ថ្ងៃ ៨ ធ្នូ ឆ្នាំ ២០១៦

... មានក្រុមគ្រួសាររបស់កម្មករ/ការិនី សុំផ្តាំសួរសុខទុក្ខពីចម្ងាយ តាមរយៈក្រុមគ្រួសារទាំងនោះ ទៅដល់បងប្អូននៅតាមភូមិឃុំនានា ដែលមិនបានមកដល់ទីនេះ ផ្តាំសួរសុខទុក្ខផង។ ឥឡូវក៏ចំរដូវប្រមូលផលស្រូវផងដែរ។ តំបន់ដែលត្រូវបង្កបង្កើនផលតាមមាត់ទន្លេ ក៏ត្រូវកំពុងបង្កបង្កើនផល។ **យើងធ្វើទាំងកសិកម្ម**

ក្ងយៗ នៅទីនេះ កំពុងតែផ្សារភ្ជាប់គ្នាខ្លាំង(បំរើការក្នុងវិស័យឧស្សាហកម្ម) ណាស់។ ចេញពីកសិករ **មកធ្វើជាកម្មករ។ បច្ចុប្បន្នក្នុងឋានៈជាប្រទេស ដែលកំពុងរីកលូតលាស់គ្រួសាររបស់យើង កំពុងតែផ្សារភ្ជាប់ជើងម្ខាងនៅ ខាងឧស្សាហកម្ម ជើងម្ខាងនៅខាងកសិកម្ម តាមរយៈនៃការដែលក្រុម គ្រួសារនៅបន្តការងារស្រែចម្ការជាកសិករ ហើយចែករំលែកកូនរបស់ខ្លួន មកធ្វើជាកម្មករ ទទួលបានបៀវត្ស៍ ហើយផ្ញើជូនទៅហើយគ្រួសារដែលធ្វើ ស្រែចម្ការ។** ឆ្នាំនេះ អត្រានៃការក្ងរាស់ដោយគោ ក្របី មានត្រឹមតែជាង ៨ ភាគរយ ក្រៅពីនោះក្ងរាស់ដោយគ្រឿងយន្ត ទាំងអស់។ ក្នុងចំណោមហ្នឹងពិតជា មានក្រុមគ្រួសាររបស់កម្មករ/ការិនីយើងហើយ ដែលផ្ញើលុយទៅឲ្យឪពុកម្តាយ ដើម្បីជួលគ្រឿងយន្តកសិកម្មក្ងរាស់ផងដែរ។ ទំនាក់ទំនងនេះ វាស្អិតរមួតខ្លាំង ណាស់ ...។

១៣. អំពៅ ជាកសិឧស្សាហកម្មផង ជាកសិពាណិជ្ជកម្មផង

ពិធីសម្ពោធរោងចក្រផលិតស្ករស កៀបទឹកអំពៅ ក្រុមហ៊ុនចិន Rui Feng Cambodia International Co., Ltd, ព្រះវិហារ, ថ្ងៃ ១៩ មេសា ២០១៦

... បន្ទាប់ពីដាច់ឆ្នាំចាស់ចូលឆ្នាំថ្មីហើយ ក៏ចាប់ផ្តើមមកសម្ពោធដាក់ឲ្យប្រើ ប្រាស់នូវរោងចក្រផលិតស្ករសដ៏ធំ វិនិយោគពីសំណាក់ក្រុមហ៊ុន Rui Feng International មកពីប្រទេសចិន។ **នេះជាផ្នែកទាក់ទិនទៅនឹងឧស្សាហកម្ម ប៉ុន្តែ មើលឲ្យជ្រៅ នេះគឺជាកសិឧស្សាហកម្ម ហើយក៏ជាកសិពាណិជ្ជកម្មផងដែរ។ ទីតាំងមួយនេះ ដែលយើងសម្ពោធដាក់ឲ្យប្រើប្រាស់ មិនត្រូវភ្លេចថាជាទីផ្សារ ដ៏សំខាន់របស់កសិករសម្រាប់ការដាំអំពៅ ហើយលក់មកកាន់រោងចក្រ ... គឺ ឧស្សាហកម្មកែច្នៃវត្ថុធាតុដើមដែលចេញពីកសិកម្ម** ... កសិកររបស់យើងនឹងលក់ កសិផល ជាពិសេសគឺអំពៅដែលខ្លួនដាំបាន ដែលយើងប្រើពាក្យ កសិពាណិជ្ជ កម្មសំរាប់ទីផ្សារមួយនៅទីនេះដែរ... ដោយសារតែទំហំនៃការវិនិយោគ(ដែល) ចាត់ទុកថាធំសម្បើមមួយ ប្រៀបជាមួយនឹងការវិនិយោគធ្វើរោងចក្រស្ករសមុនៗ នោះ ការវិនិយោគនេះ អាចនាំទៅដល់ការផលិតច្រើនបែបច្រើនយ៉ាង ក្នុងនោះ គឺមានការផលិតស្ករស ដែលជំហាននៃការចាប់ផ្តើមដំបូងនេះ ប្រើកាកអំពៅ

ផលិតអគ្គិសនីរហូតដល់ ៣៩ មេហ្គាវ៉ាត់ ... អាចមួយភាគផ្គត់ផ្គង់ឲ្យរោងចក្រ ស្ករដែក ដែលពីមុនយើងគ្រោងថានឹងទិញអគ្គិសនីពីឡាវមកផ្គត់ផ្គង់នៅខេត្ត ព្រះវិហារ ...។

ឧបសម្ព័ន្ធ ក៏ **ការបកស្រាយប្រធានបទនយោបាយមួយចំនួន**

១	ជួបអ្នកស្រែថាស្រូវថោក ជួបអ្នកក្រុងថាអង្ករថ្លៃ	២៩៩
២	នយោបាយទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី គួរតែបញ្ចប់	២៩៩
៣	អ្នកថា និងអ្នកធ្វើ ខុសគ្នា	៣០០
៤	ការកំណត់ឲ្យមានអាណត្តិសំរាប់នាយករដ្ឋមន្ត្រី	៣០១
៥	មានអ្នកមិនចង់រំលឹកពី ថ្ងៃ ៧ មករា	៣០១
៦	ការឃោសនាថាវាស់/ចែកដីមុនបោះឆ្នោត ក្រោយបោះឆ្នោតដកយកវិញ	៣០២
៧	ការរិះគន់ថា គណបក្សប្រជាជនគ្មានមនុស្សជំនួស ហ៊ុន សែន	៣០២
៨	ចោទថា ហ៊ុន សែន ជាអាយ៉ង, ឯខ្លួនឯងក៏ធ្លាប់ធ្វើអាយ៉ងដែរ	៣០៣
៩	និយាយប្រមាថដល់ជនរងគ្រោះសម័យ ប៉ុល ពត	៣០៣
១០	បក្សប្រឆាំងថា គណបក្សប្រជាជនកំពុងបំបែកបំបាក់គេ	៣០៤
១១	ចោទថា ហ៊ុន សែន ជាអ្នកគាបសង្កត់រដ្ឋាភិបាល	៣០៤
១២	ចោទថាគណបក្សប្រជាជនជាអ្នករៀបចំរឿងមានស្រីកំណាន់	៣០៥
១៣	ចូលរួមបោះឆ្នោត តែប្រកាសមុនថា មិនទទួលស្គាល់លទ្ធផល	៣០៦
១៤	ករណីថា អន្តោប្រវេសន៍រៀតណាម ៤ លានកន្លះ នៅស្រុកខ្មែរ	៣០៦
១៥	ករណីសន្យាឲ្យគោ ១០០ ក្បាល/គ្រួសារ និងចាស់ៗ ៤ ម៉ឺនរៀល/ម្នាក់	៣០៧
១៦	ការសន្យាទម្លាក់ថ្លៃអគ្គិសនី និងប្រេង	៣០៧
១៧	ករណីសន្យាលុបបំណុលប្រជាពលរដ្ឋចោលទាំងអស់	៣០៨
១៨	ករណីចោទថា សភាឯកបក្ស និងមិនគ្រប់ទឹក	៣០៨
១៩	សម្លេងភាគតិចចង់ទាមទារធ្វើប្រធានសភា	៣០៩
២០	ទាមទារតំណែងប្រធានសភា និងក្នុងគណៈអចិន្ត្រៃយ៍ស្មើៗគ្នា	៣០៩
២១	គ្មានលាលែងតំណែងនាយករដ្ឋមន្ត្រី គ្មានបោះឆ្នោតឡើងវិញ	៣១០
២២	ករណីបង្កើតឡើងនូវវប្បធម៌សន្ធនា	៣១១
២៣	កុំចាប់ដៃជាន់ជើង ដើម្បីរក្សាវប្បធម៌សន្ធនា	៣១១
២៤	វប្បធម៌សន្ធនានឹងដាក់ចូលក្នុងច្បាប់	៣១២
២៥	ជំហរចរចាររបស់គណបក្សប្រជាជន	៣១២
២៦	វប្បធម៌សន្ធនា បន្តមានតាមគណអចិន្ត្រៃយ៍សភា	៣១៣

២៧	**ករណីចោទ (ហ៊ុន) ម៉ាណែត ជាកូនរបស់មេដឹកនាំវៀតណាម**	៣១៣
២៨	**សម រង្ស៊ី ថា "គណបក្សប្រជាជនខ្លាចចាញ់ឆ្នោត មិនហ៊ានបោះឆ្នោត"**	៣១៤

១. ជួបអ្នកស្រែថាស្រូវថោក ជួបអ្នកក្រុងថាអង្ករថ្លៃ

ពិធីសំណេះសំណាល និងចែកបណ្ណកម្មសិទ្ធិដីធ្លី នៅខេត្តមណ្ឌលគិរី, ថ្ងៃទី ១៦ មករា ២០១៣

... ប៉ុន្មានថ្ងៃមុន **គណបក្សប្រឆាំងគេស្នើឲ្យខ្ញុំដករដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ចេញពីតំណែង ដោយសារមិនអាចរកទីផ្សារឲ្យកសិករបាន។ គ្រាន់តែផ្តាំត្រឡប់ទៅវិញថា ជាសភាពការណ៍ឡើងចុះ។ ប៉ុន្តែ អ្នកដែលប្រឆាំង គេអាចរកអាជីវកម្ម បានភ្លាម។ ក្នុងដំណើរលើផ្លូវតែមួយ គេអាចរកចំណេញបានពីរ។** នៅពេលដែលជួបជាមួយនឹងអ្នកទៅទិញអង្ករ គេយកចំណេញបានមួយពេល ដោយគេទៅសួរអង្ករហ្នឹងថ្លៃប៉ុន្មាន? ថាថ្លៃ ២០០០ រៀលក្នុងមួយគីឡូក្រាម។ គេថា ស្លាប់ហើយ បងប្អូនអើយ អង្ករថ្លៃណាស់ ជាច់ពោះស្លាប់អស់ហើយ។ ហ្នឹងគេយកចំណេញពីអ្នកទិញអង្ករ អ្នកដែលមិនផលិតស្រូវ។ បន្ទាប់ពីហ្នឹងទៅ គេធ្វើដំណើរទៅកន្លែងអ្នកធ្វើស្រែ សួរស្រូវថ្លៃប៉ុន្មាន? ថាស្រូវថ្លៃ ៧០០ រៀល ឧទាហរណ៍អញ្ចឹងទៅចុះ។ រួចគេស្រែកថា បងប្អូនអើយ ស្លាប់ហើយ ស្រូវតម្លៃថោកណាស់ មិនរួចថ្លៃពលកម្ម មិនរួចថ្លៃក្ជូរាស់ មិនរួចថ្លៃជីទេបងប្អូន ... **បើប្រជាពលរដ្ឋមិនយល់ទេ ប្រជាពលរដ្ឋ អាច(គិត)ថា គាត់នេះនិយាយត្រូវ ប៉ុន្តែកុំភ្លេចថាគាត់ជដែលហ្នឹង មុខជដែលហ្នឹង មនុស្សជដែលហ្នឹង យោសនាជាមួយអ្នកផ្សារ អ្នកទីក្រុង អ្នកទីប្រជុំជន ដែលអត់ផលិតស្រូវថា អង្ករថ្លៃណាស់ ជាច់ពោះស្លាប់អស់ហើយ ...**។

២. នយោបាយទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី គួរតែបញ្ចប់

ពិធីប្រគល់សញ្ញាបត្រ និស្សិត នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា, ថ្ងៃទី ១៤ មករា ២០១៣

... **ខ្ញុំគាំទ្រពេញទីនូវការកំណត់ជាក្រមសីលធម៌សម្រាប់និយាយ ជាពិសេសគឺសម្រាប់មេដឹកនាំតែម្តង កុំឲ្យពួកែជេរគ្នា ហើយជេរអាក្រក់ណាស់ស្រុកខ្មែរ ... អញ្ចឹងជាក់ច្បាប់តែម្តង បើគ្រាន់តែធ្វើក្រមសីលធម៌ វាមិនកើតទេ ជាក់ច្បាប់តែម្តង អ្នកឯងហ៊ានជេរថា អាក្បត់ជាតិ ត្រូវជាប់គុកប៉ុន្មានឆ្នាំអញ្ចឹងទៅ។** ហ៊ានទេ? ឥឡូវ អ្នកនយោបាយនានា យើងអនុម័តច្បាប់ឲ្យហើយ ទាន់សកានៅ គឺនៅសល់

តែប៉ុន្មានខែទៀតទេ សភាឈប់ធ្វើការហើយ។ កុំឱ្យចេះតែបញ្ចោរគ្នា ចាប់ឡើងតាមផ្លូវ។ ខ្ញុំស្ពប់បំផុតអានយោបាយទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី។ អញ្ចឹង បានជាក្រោមការគ្រប់គ្រងរបស់ខ្ញុំ អ្នកជេរក៏នៅបាន អ្នកមិនជេរក៏នៅបាន អ្នកគាំទ្រក៏នៅបាន នៅបានទាំងអស់គ្នា។ ស្រុកខ្មែរយើង បានកើតរឿងហ្នឹងមកជាហូរហែ។ កែចរិតខ្មែរមួយហ្នឹងចោល។ ពេលដែល លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ អ្នកដែលស្និទ្ធនឹងសម្តេចព្រះ នរោត្តម សីហនុ ត្រូវ លន់ នល់ ចាប់ដាក់គុក ដល់ ប៉ុល ពត ឡើងមក (ក៏)កម្ទេចចោលទាំងអស់ នូវអ្នកជំនាន់សម្តេចព្រះ នរោត្តម សីហនុ និង លន់ នល់។ ក្រោយឆ្នាំ ១៩៧៩ យើងមានឈ្លើយសឹក តែយើងមិនដែលបានសម្លាប់ឈ្លើយសឹក ...។

៣. អ្នកថា និងអ្នកធ្វើ ខុសគ្នា

ពិធីបើកការដ្ឋានស្តារឡើងវិញ កំណាត់ផ្លូវជាតិលេខ ៦ ចាប់ពីថ្នល់កែង ឃុំផ្ការ ស្រុកបាធាយ ខេត្តកំពង់ចាម ដល់ អង្ក្រង ខេត្តសៀមរាប ប្រវែង ២៤៨ គីឡូម៉ែត្រ, ថ្ងៃទី ០៥ មីនា ២០១៣

...យើងត្រូវធ្វើ ទាំងអស់ **ធ្វើសន្សឹមៗ យើងមិនអាចជប់បានទេ សូម្បីតែផ្លូវនេះ ក៏ត្រូវការរយៈពេល ៣ ឆ្នាំ ៦ ខែ ស្មើនឹង ៤២ ខែ ទើបរួចរាល់។ ប៉ុន្តែ សម្រាប់អ្នកថា គេថាបានតាមចិត្ត។ បើសិនជាខ្ញុំមិនមែនជានាយករដ្ឋមន្ត្រី ខ្ញុំក៏អាចថាបានដែរ ... ព្រោះខ្ញុំអត់ទទួលខុសត្រូវផង**។ តែបើក្នុងឋានៈខ្ញុំ ជាយករដ្ឋមន្ត្រីត្រូវយកលុយមកបើកអោយភ្លាម បើមិនបានទេ បើអ្នកឯងមិនរត់ចោលស្រុក ខ្ញុំសូមថ្វាយបង្គំ។ ឥឡូវប្រកាសមួយខែ ៥០ ម៉ឺនរៀលក្នុងម្នាក់ៗ ហើយចុះបើមិនបាន? ត្រូវធ្វើម៉េច? ត្រូវតែទាមទារហើយ ឥឡូវនេះ **មើលអាការសន្យាទាំងឡាយនោះ ឡានគេបានដឹកយើងអត់យកលុយទេ? ឬក៏យកលុយ? មើលអាការសន្យារបស់គេនោះ មន្តេយ្យសាលា បានធ្វើរួចហើយឬនៅ?** អ្នកឯងសន្យាថា យកមកដឹកអ្នកជំងឺ បើយកមកដឹកយកលុយដដែល ដិះតាក់ស៊ីវិញល្អជាង។ ខ្ញុំថា ប្រជាពលរដ្ឋយើងចេះវិនិច្ឆ័យហើយ ...។

៤. ការកំណត់ឲ្យមានអាណត្តិសំរាប់នាយករដ្ឋមន្ត្រី

ពិធីចែកសញ្ញាបត្រជូននិស្សិតនៃសាកលវិទ្យាល័យ IIC នៃបច្ចេកវិទ្យា,
ថ្ងៃទី ១៨ តុលា ២០១០

... **រុញត្រង់ណោះបន្តិច រុញត្រង់ណោះបន្តិច ដើម្បីឱ្យខ្ញុំតបត។** ខ្ញុំធ្លាប់និយាយកាលពី ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៣ និយាយជាមួយ ឯកឧត្តម ញ៉ុក ប៊ុនឆៃ ថា បើរបៀបភាសាយោធា(គេថា) អញមិនខ្ជីនិយាយរកហ្អែងតែម្តង។ គេថា អ្នកណាក៏បានដែរ កុំឱ្យតែ ហ៊ុន សែន។ **ចរចារចុះ ចរចារឡើង នៅក្នុងព្រះបរមរាជវាំង ព្រះករុណា បិតា ព្រះអង្គដឹកនាំការប្រជុំចុះឡើងៗ គិតតែតែពីរឿងអាណត្តិរបស់នាយករដ្ឋមន្ត្រី ហើយនៅលើពិភពលោក អត់មានអ្នកណាកំណត់អាណត្តិនាយករដ្ឋមន្ត្រីទេ។ គេកំណត់ អាណត្តិប្រធានាធិបតី ហើយក៏ទើបតែកើតឡើងក្នុងដំណាក់កាលរីហ្គេន ព្រោះបើ រីហ្គេន ជាប់ ២ អាណត្តិ ហើយបើឈរឈ្មោះជាប់ទៀត។ តែរឿងនាយករដ្ឋមន្ត្រី គេអត់កំណត់អាណត្តិទេ ស៊ីសងលើប្រជាពលរដ្ឋ បោះឆ្នោតឱ្យបក្សណាឈ្នះ បក្សនោះធ្វើទៅ ហើយគណបក្សរើសមនុស្សរបស់គេធ្វើទៅ។** ... គណបក្សប្រជាជនកម្ពុជា ដាក់ក្នុងកម្មវិធីនយោបាយ យកទៅឃោសនាជាមួយប្រជាពលរដ្ឋថា បើគណបក្សប្រជាជនកម្ពុជាឈ្នះ ហ៊ុន សែន ធ្វើជានាយករដ្ឋមន្ត្រី ... ដល់គេឈ្នះ ហើយមិនចង់ឱ្យគេធ្វើយ៉ាងម៉េច ... បង្កើតរដ្ឋាភិបាលថ្មីមិនបាន ទុកអាចាស់នៅហ្នឹង ចាំចាបក៏ដោយ ចាំខ្ជមក៏ដោយ ចាំស្រែក៏ដោយ ... ពួកឯងអត់ប្រាក់ខែទៅ (យើង)ចាយថវិកា ១/១២ ...។

៥. មានអ្នកមិនចង់រំលឹកពី ថ្ងៃ ៧ មករា

ពិធីចែកសញ្ញាបត្រ និស្សិត គរុនិស្សិត នៃវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស,
ថ្ងៃទី ០៧ វិច្ឆិកា ២០១៦

... **ការគង់រង្សជីវិតរបស់ពួកគាត់ ដោយសារការរំដោះថ្ងៃទី ៧ មករា ១៩៧៩ បានបង្កើតឡើងឲ្យមានជីវិតរបស់កូនៗ ក្មួយៗ មកដល់ពេលនេះ បើសិនជាពួកគាត់ស្លាប់អស់ មិនដឹងថា កូនៗ ក្មួយៗ កើតមកពីកន្លែងណាទេ ... ពិតហើយ**

រឿង ៧ មករា ពិតជាមានហើយ មានអ្នកខ្លះ គេមិនចង់ឲ្យយើងរំលឹកទៅទៀត ... គ្រាន់តែបញ្ជាក់ជូនអញ្ចេះ មានការដើរដង្ហែរក្បួននៅប្រទេសអាឡឺម៉ង់ដើម្បីរំលឹកអំពីការបញ្ចប់នៃរបប ណាស៊ី តាំងពីសម័យសង្គ្រាមលោកលើក ទី២ ... ឯជនជាតិអាល់មេនីនោះ តាំងពីសង្គ្រាមលោកលើកទី ១ គេក៏នៅតែរំលឹកអំពីប្រវត្តិដែលពួកទ្ធរគី ទៅប្រល័យពូជសាសន៍នៅទីនោះ ... **ពួកគេចេះរំលឹកថ្ងៃ ១៧ មេសា (តែ)អត់រំលឹកថ្ងៃ ១៨ មីនា ១៩៧០ ដែលគេធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ហើយបង្កើតសង្គ្រាម ហើយអត់រំលឹកថ្ងៃ ៧ មករា ...**។

៦. មានគេយោសនាថា វាស់ និងចែកដីតែមុនបោះឆ្នោត ក្រោយបោះឆ្នោតនឹងដកយកវិញ

ពិធីកាត់ខណ្ឌសីមាព្រះវិហារ វត្តទួលខ្សាច់, ថ្ងៃទី ១១ ឧសភា ២០១៣

... អ្នកដែលគេមិនពេញចិត្ត នៅតែគេមិនពេញចិត្តហ្នឹង រាប់ទាំងនៅទីនេះ គឺការវាស់រ៉ែងដីធ្លី។ កូនៗ ក្មួយៗ ក៏ដូចជាមន្ត្រីសុរិយោដី ប្រឹងណាស់។ ឯកឧត្តមទូច ម៉ារីម បានធ្វើរបាយការណ៍អំពីការវាស់រ៉ែងដីធ្លីនៅទីនេះ ប៉ុន្តែ**ឮថា មានអ្នកយោសនានៅហ្នឹងថា "គេវាស់ដី គេចែកប័ណ្ណកម្មសិទ្ធិហ្នឹង គេចែកមុនបោះឆ្នោត ក្រោយបោះឆ្នោត គេដកយកវិញ"។ សូមផ្តាំទៅអ្នកនិយាយហ្នឹង បើសិនជា ខ្ញុំព្រះករុណាខ្ញុំ មានអំណាចដកអញ្ចឹង ខ្ញុំព្រះករុណាខ្ញុំ យកផ្ទះ(អ្នកនិយាយ) មុន**។ ចេះមកកូត។ ហេតុអីបានជាគេចេះកូតម្ល៉េះ ហើយគេពូកែមុសាម្ល៉ឹងៗ តើសមនឹងធម៌ព្រះពុទ្ធឬអត់ ...។

៧. រិះគន់ថាគណបក្សប្រជាជនគ្មានមនុស្សជំនួស ហ៊ុន សែន

ពិធីកាត់ខណ្ឌសីមាព្រះវិហារ វត្តទួលខ្សាច់, ថ្ងៃទី ១១ ឧសភា ២០១៣

... ពីមុនលោកប្អូនថា **គណបក្សប្រជាជនអត់ធនធានមនុស្សទេ ដាក់តែ ហ៊ុន សែន អត់មានធនធានមនុស្សធ្វើនាយករដ្ឋមន្ត្រី។ ខ្ញុំក็ទទួលទៀត ព្រោះគណបក្សប្រជាជនដាក់ ហ៊ុន សែន មក (ហើយ)បើ ហ៊ុន សែន វាអន់ លោកប្អូនគួរតែសប្បាយ ព្រោះលោកប្អូននឹងឈ្នះឆ្នោត ហើយមនុស្សរបស់លោកប្អូន គឺតែងតែនិយាយអំពីបញ្ហាឈ្នះ។** លោកប្អូនប្រើប្រាស់ចំណុច ដែលនាយករដ្ឋមន្ត្រីក្នុងតំណែង និងជាបេក្ខជននាយករដ្ឋមន្ត្រី ធ្វើជាចំណុចខ្សោយ វាយប្រហារគណបក្ស

ប្រជាជនបណ្តោយទៅ ...។

៨. ចោទថា ហ៊ុន សែន ជាអាយ៉ង, ឯខ្លួនឯងក៏ធ្លាប់ធ្វើអាយ៉ងដែរ

ពិធីកាត់ខណ្ឌសីមាព្រះវិហារ វត្តទួលខ្សាច់, ថ្ងៃទី ១១ ឧសភា ២០១៣

... ព្រឹកមិញឆ្លៀតមើលបន្តិច **អំពីបញ្ហាបក្សប្រហារតាមបែបទំនើង។ ហ្នឹងល្អ តើ។ មានអី។ កុំដល់ពេលចាញ់ថា អាហ្នឹងមកពី ហ៊ុន សែន ជាក់មនុស្សបង្ក់ ... ធ្លាប់ប្រើពីមុនដែរ។ អ្នកតាំងខ្លួនថាឯករាជ្យ ហើយតាំងខ្លួនមកជេរអាយ៉ង ក្រែងធ្លាប់ធ្វើអាយ៉ងដែរតើហ្ម? ខ្លះធ្វើអាយ៉ងកែរដ្ឋធម្មនុញ្ញ វិសោធនកម្មរដ្ឋធម្មនុញ្ញទៀតណ៎។** អ្នកដែលលើកអំណាចជូនគណបក្សប្រជាជនទាំងស្រុង គឺអ្នកដែលចោទប្រកាន់ ហ៊ុន សែន ថាជាអាយ៉ង ហើយគេចោទអាយ៉ងរបស់អាយ៉ងទៀត ... បញ្ហានៅត្រង់អញ្ចេះ។ ខ្ញុំអត់ហៅគេថាអាយ៉ងទេ។ សហការរួមគ្នាទេ។ ប៉ុន្តែ ដល់គេជេរយើងអាយ៉ង។ អញ្ចឹងមានន័យថាម៉េច? ជេរខ្ញុំជាអាយ៉ង ស្មើនឹងជេរខ្លួនឯងថាជាអាយ៉ងរបស់អាយ៉ង ព្រោះមនុស្សហ្នឹងធ្លាប់បម្រើការឲ្យខ្ញុំ។ មិនអញ្ចឹង ...។

៩. និយាយប្រមាថដល់ជនរងគ្រោះសម័យ ប៉ុល ពត

ពិធីបណ្ដុះខណ្ឌសីមាព្រះវិហារ វត្តមង្គលវង្ស ស្រុកត្បូងឃ្មុំ, ថ្ងៃទី ៣០ មិថុនា ២០១៣

... អនុញ្ញាតឲ្យខ្ញុំព្រះករុណាខ្ញុំបាននិយាយបន្តិចថា **កម្តៅនយោបាយពេលនេះឡើងខ្លាំង ប៉ុន្តែមិនមែនជាបក្សនយោបាយ និងបក្សនយោបាយ អ្នកនយោបាយ និងអ្នកនយោបាយទេ គឺវាងប្រជាជន និងបុគ្គលមេដឹកនាំបក្សនយោបាយម្នាក់ ដែលបាននិយាយទាក់ទិនជាមួយនឹងទួលស្លែង។ កម្តៅនយោបាយ វាធ្ងន់ធ្ងរ បើមេដឹកនាំបក្សនយោបាយរូបនោះ មិនសុំទោសទេ បាតុកម្មទ្រង់ទ្រាយធំនឹងអាចកើតមាន មិនមែនត្រឹមតែនៅរាជធានីភ្នំពេញទេ វាអាចកើតនៅទូទាំងប្រទេសតែម្តង** ... សូមអស់លោកមេគ្គាកុំផ្ទេរជម្លោះមកជាមួយខ្ញុំ ឬមកជាមួយមេដឹកនាំរដ្ឋាភិបាល ឬគណបក្សប្រជាជនឲ្យសោះ។ នេះជាជម្លោះរវាងលោកជាមួយនឹងប្រជាជនកម្ពុជា។ សូមអំពាវនាវទុកជាមុនឲ្យហើយ បើសិនជាមានបាតុកម្មកើតឡើង ទោះបីកម្រិតណាក៏ដោយ សូមឲ្យបាតុកម្មប្រព្រឹត្តទៅដោយអហិង្សា ត្រូវរក្សាសេចក្ដីថ្លៃថ្នូរ រក្សាសណ្ដាប់ធ្នាប់សាធារណៈ។ នេះជាសិទ្ធិរបស់ប្រជាជន

... **ខ្លួនឯងនិយាយបង្ក កំហឹងពីសំណាក់ប្រជាជនថា ប៉ុល ពត អត់សម្លាប់មនុស្ស ហើយគុកទួលស្ពែង គ្រាន់តែកន្លែងរៀបចំទុកឲ្យគេថត**។ ប្រើពាក្យថា "ប៉ុល ពត អីក៏ល្ងង់ម្ល៉េះ អីក៏ឆោតម្ល៉េះ បើដឹងថា វាសម្លាប់មនុស្សច្រើនអញ្ចឹង មិនបំផ្លាញចោល ទុកឲ្យគេថតជាកស្តុតាង" សម្តីអញ្ចឹងៗ អ្នកណាទៅកាត់តកើត ទោះបីពួក Hollywood ក៏ពួកគេធ្វើមិនកើតដែរ ...។

១០. បក្សប្រឆាំងថា គណបក្សប្រជាជនកំពុងបំបែកបំបាក់គេ

សម្ពោធសមិទ្ធផលនានា នៅសង្កាត់លលកស ក្រុងពោធិសាត់ ខេត្តពោធិសាត់, ថ្ងៃទី ១១ មិថុនា ២០១៣

... **ខ្ញុំព្រះករុណាខ្ញុំចង់បញ្ជាក់បន្តិច មានសេចក្តីថ្លែងការណ៍ថ្មីៗ ថា "គណបក្ស ប្រជាជនកំពុងតែបំបែកបំបាក់គេ"។ ខ្ញុំសូមឆ្លើយត្រឡប់ទៅវិញ ឱ្យលោកឯងបាន ដឹងបន្តិចទៅ លោកឯងជាមនុស្ស ឬក៏ជាសត្ត ដែលអោយគេបំបែកបំបាក់បាន ងាយៗ ... ស្តាប់សម្លេងទៅ ចាក់អាយ៉ើឆ្លើយឆ្លងរវាងអ្នកខ្លាំងទាំងពីរ ... កាល ដែលលោកឯងជេរគ្នានោះ ខ្ញុំអ្នកបំបែកបំបាក់ដែរ ឬអី ... បើដូចនោះ លោកមិន សក្តិសមធ្វើមេដឹកនាំនយោបាយទេ ហើយកាន់តែមិនសក្តិសមធ្វើជា មេដឹកនាំ ប្រទេសទៅទៀត ព្រោះត្រចៀកស្រាលពេក**។ ការដឹកនាំ ទាមទារនូវភាពអំណត់ ហើយវិភាគសភាពការណ៍ឱ្យបានត្រឹមត្រូវណាស់ ហើយលោកឯងមកបន្ទោសថា គេមកបំបែកបំបាក់លោកឯង ... ប្រើខួរគិតខ្លួនឯង លោកឯងគួរតែខ្មាសអៀន ដែលថា គណបក្សប្រជាជនប្រើវិធីបំបែកបំបាក់ ... សូមផ្តាំទៅលោកឯងវិញ កុំបន្ត និយាយថា គណបក្សប្រជាជនប្រើវិធីបំបែកបំបាក់ បើគេប្រើវិធីបំបែកបំបាក់បាន លោកឯងបែកបាក់តាមគេ លោកឯងជាមនុស្សធុនអន់បំផុតហើយ ...។

១១. ចោទថា ហ៊ុន សែន ជាអ្នកគាបសង្កត់រដ្ឋាភិបាលថៃ

សម្ពោធសមិទ្ធផលនានា នៅសង្កាត់លលកស ក្រុងពោធិសាត់ ខេត្តពោធិសាត់, ថ្ងៃទី ១១ មិថុនា ២០១៣

... វិលមក(រឿងនឹង)ថៃវិញ។ **បែរជាមេបក្សមួយនេះ និរទេសខ្លួនឯង ជាទណ្ឌិត មកចោទប្រកាន់ថា ខ្ញុំព្រះករុណាខ្ញុំ ជាអ្នកជាក់ការគាបសង្កត់ទៅលើរដ្ឋាភិបាល**

ថៃ។ ប្រហែលជាទណ្ឌិតមួយនេះឱ្យតម្លៃ ខ្ញុំព្រះករុណាខ្ញុំ ខ្ពស់ពេកហើយ ខ្ពស់នៅត្រង់អញ្ចេះ ខ្ញុំព្រះករុណាខ្ញុំ មិនគ្រាន់តែមានសិទ្ធិជាក់បទបញ្ជាក្នុងប្រទេសកម្ពុជាទេ មានសិទ្ធិជាក់បទបញ្ជាទៅដល់រដ្ឋាភិបាលថៃទៀត ... (ដែល)ថៃគេមិនឱ្យចូល ជាសិទ្ធិរបស់ប្រទេសថៃ រាជរដ្ឋាភិបាលថៃ ជារាជរដ្ឋាភិបាលអធិបតេយ្យ គ្មានអ្នកណាទៅអាចសម្រេចចិត្តជំនួស រាជរដ្ឋាភិបាលថៃបានទេ។ នេះជាសម្តីប្រមាថមួយ ចំពោះរាជរដ្ឋាភិបាលថៃ ដែលជារដ្ឋអធិបតេយ្យ ហើយថ្ងៃនេះ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស ដឹកនាំគណៈប្រតិភូសឹងតែមួយគណៈរដ្ឋមន្ត្រីមកប្រជុំ ... បើគេឲ្យតម្លៃ ខ្ញុំព្រះករុណាខ្ញុំ អញ្ចឹងគួរតែទទួលដែរ ព្រោះអី? ... កាសែតថៃក៏បានសរសេរហើយពីដំណាក់កាលខ្មែរពឹងសៀម និងដំណាក់កាលសៀមពឹងខ្មែរ គឺដំណាក់កាលតេជោសែន។ ប៉ុន្មានរយឆ្នាំហើយ ដែលខ្មែរពឹងពាក់សៀមរាប់ទាំងប្រវត្តិ អ្នកតាឃ្លាំងមឿង ជំទាវ ខាន់ ខៀវ នេះ បណ្តាលមកពីអ្វី ព្រះចន្ទរាជា រឿងរ៉ាវទាក់ទិននឹងដំរីសស្ពឺ។ ... អញ្ចឹងទេ បើ ហ៊ុន សែន ខ្លាំងដល់ម្ល៉ឹងៗ ត្រូវតែបោះឆ្នោតឲ្យ ហ៊ុន សែន ដឹកនាំប្រទេសតទៅទៀត បានវាត្រូវ ...។៖

១២. ចោទថាគណបក្សប្រជាជនជាអ្នករៀបចំរឿងមានស្រីកំណាន់

ពិធីសម្ពោធទីស្នាក់ការគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា,
ថ្ងៃទី ១៣ មិថុនា ២០១៣

... គេនិយាយថា គណបក្សប្រជាជន បានទៅយកស្រីកំណាន់មេដឹកនាំម្នាក់ឲ្យទៅតាមធាតៅ។ ពីមុនគេថា ស្រីកំណាន់នេះ ឈ្មោះ កែវ សុផាន់ណារី ហើយដែលមានរូបភាពផ្សាយតាមទូរទស្សន៍នេះ ទូរទស្សន៍នោះ (មិនដឹង)ជាស្រីមកពីណា ដែលគណបក្សប្រជាជនរៀបចំ ... ខ្ញុំប្រាប់ទៅ បើយើងបដិសេធថា (បើពិត) មិនស្គាល់ ចេញមុខប្រាប់ទៅ។ បានទេ។ យើងជាមាសសុទ្ធ ចេញមុខមក។ ឥឡូវ បើសិនជានាងនេះ អះអាងថាជាប្រពន្ធចុងរបស់ខ្លួន ម៉េចក៏យើងមិនជួប(បដិសេធ) ... ដល់ធ្វើអញ្ចឹង កាន់តែធ្វើឲ្យគាត់កាន់តែតាមជាប់ស្អិត ... ពីមុនថា គុកទួលស្លែងជាសិប្បនិម្មិត ឥឡូវប្រពន្ធចុងរបស់ខ្លួន ក៏ក្លាយទៅជាសិប្បនិម្មិតទៀតហើយ ... ប៉ុន្តែ **ហេតុអីបានជាខ្លួនទម្លាក់កំហុសថា គណបក្សប្រជាជនជាអ្នករៀបចំ។ គណបក្សប្រជាជនមិនអាចទទួលបានទេ ... ហើយក៏គប្បីពិនិត្យមើល ខាងផ្លូវ**

ច្បាប់ដែរ តែកុំធ្វើពេលនេះ។ ចាំធ្វើក្រោយការបោះឆ្នោត។ គេចោទគណបក្ស (យើង) គណបក្សមានសិទ្ធិប្តឹង ...។

១៣. ចូលរួមបោះឆ្នោត តែប្រកាសមុនថា មិនទទួលស្គាល់លទ្ធផល

ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់នូវអគារសិក្សាចំនួន ២ នៅស្រុកអង្គស្នួល
ខេត្តកណ្ដាល, ថ្ងៃទី ១៩ មិថុនា ២០១៣

... **ប្រកាសថា ចូលរួមបោះឆ្នោត តែអត់ទទួលស្គាល់លទ្ធផល។ ឥឡូវអញ្ចេះ តែម្តងទៅ បងប្អូនប្រជាពលរដ្ឋដែលគាំទ្របក្សប្រឆាំង សុំមេត្តាកុំបោះឲ្យបក្សប្រឆាំង ព្រោះបក្សប្រឆាំងអត់ទទួលស្គាល់ឡើយ អញ្ចឹង សន្លឹកឆ្នោតបងប្អូនក្លាយទៅជាសន្លឹកឆ្នោតអត់បានការ ព្រោះគេមិនទទួលស្គាល់ផង វាមិនអាសារបង់។** សូមងាកមកបោះឲ្យគណបក្សប្រជាជន ហើយបើមិនបោះឲ្យគណបក្សប្រជាជនទេ គណបក្សផ្សេងទៀត ដែលប្រណាំងប្រជែង ... ប្រកាសចូលរួមបោះឆ្នោត ប៉ុន្តែមិនព្រមទទួលស្គាល់ អញ្ចឹងកុំបោះឲ្យតែម្តងទៅ ព្រោះបោះឲ្យបានប្រយោជន៍អី ... ខ្ញុំឲ្យសារបញ្ជ្រាសស្រកីត្រឡប់ទៅវិញ។ វាមិនដែលអ្នកណាចូលបោះឆ្នោត ហើយប្រកាសទុកជាមុនថាអត់ទទួលស្គាល់ ... គណៈកម្មការជាតិរៀបចំការបោះឆ្នោតបានប្រកាសប្រាប់ហើយ ពេលដែលគណបក្សអ្នកឯងបោះបង់ចោលអាសនៈ គេយកអាសនៈអ្នកឯង ទៅចែកជាមួយនឹងគណបក្សដទៃទៀត ដែលមាននៅក្នុងមណ្ឌលជាមួយគ្នា។ គេអត់ទុកឲ្យអ្នកឯងវេតូ ចូលបោះ ឬមិនបោះទេ ...។

១៤. ករណីថា អន្តោប្រវេសន៍វៀតណាម ៤ លានកន្លះ នៅស្រុកខ្មែរ

ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់នូវអគារសិក្សាចំនួន ២ នៅស្រុកអង្គស្នួល
ខេត្តកណ្ដាល, ថ្ងៃទី ១៩ មិថុនា ២០១៣

... **សូមសង្គមស៊ីវិលធ្វើអោយត្រឹមត្រូវបន្តិចមើល។ លោកឯងស្វែងរកណាស់ចំណុចខ្សោយរបស់គណបក្សកាន់អំណាច រឿងមិនពិត លោកឯងប្រឌិតទៅជារឿងពិត។ ដូចជាឥឡូវនេះ អាណិកជនវៀតណាមដែលនៅស្រុកខ្មែរ មានត្រឹមមិនដល់ ១០ ម៉ឺននាក់ ប៉ុណ្ណោះ ៧ ឬ ៨ ម៉ឺននាក់ប៉ុណ្ណឹង លោកឯងថា មាន ៤ លានកន្លះ នៅស្រុកខ្មែរ។** ឥឡូវ បើ ៤ លានកន្លះ ប្រហែលជានៅអង្គស្នួលមានមិនគិច

ទេ។ ខូចម្ល៉េះ។ កន្លះលានច្រើនណាស់។ យើងថតសម្លេងបាន។ ឱ!របស់គេហ្នឹង ខ្ញុំមើលប្រវត្តិរូបថ្ងៃមុន ហើយក៏មើលអត្ថបទឆ្នាំ ១៩៨៥ ដែលគាត់សរសេរផ្ទាល់ដៃ ៦ ទំព័រ។ គាត់ប្តូរផ្តាច់ស្មោះស្ម័គ្រជាមួយគណបក្សប្រជាជន ស្មោះត្រង់ជាមួយលទ្ធិម៉ាក្សលេនីនសម្បើមណាស់ ស្មោះត្រង់ជាមួយមិត្តភាពកម្ពុជា-វៀតណាមសម្បើមណាស់។ ឥឡូវ គាត់ហ្នឹងជាអ្នកស្អប់វៀតណាមជាងគេ។ កូនរបស់គាត់និយាយថា ១០ នាក់ មានតែម្នាក់ទេ ឆ្លើយ "អូយ" ក្រៅពីនេះឆ្លើយ "ឌូមែ"។ ឥឡូវមានក្នុងដៃយើង។ នឹងផ្ញើអោយបណ្តាស្ថានទូតមើល ដើម្បីអោយឃើញចរិតប្រកាន់ពូជសាសន៍បែបណា ...។

១៥. ករណីសន្យាឲ្យគោ ១០០ ក្បាល/គ្រួសារ និងចាស់ៗ ៤ ម៉ឺនរៀល/ម្នាក់

វេទិការាជរដ្ឋាភិបាល និងវិស័យឯកជនលើកទី ១៦, ថ្ងៃទី ២៣ វិច្ឆិកា ២០១១

... **យើងអ្នកកាន់អំណាច យើងគិតថា ក្របខណ្ឌម៉ាក្រូយ៉ាងម៉េច បំពេញឲ្យគ្នាអាចរស់នៅបានទាំងអស់គ្នា ឡើងក៏មិនឡើងហួសទាបក៏មិនទាបហួស ដែលត្រូវប្រឹងប្រែង ធ្វើយ៉ាងម៉េចឲ្យប្រទេសជឿនលឿនទៅមុខទាំងអស់គ្នា។ នេះ ខុសពីបក្សនយោបាយ មិនកាន់អំណាច ដែលចេះតែសន្យា។** ឥឡូវវាខុសពីមុនទៀត កាលពីមុនត្រឹមសន្យាថា ឲ្យគោ ១០០ ក្នុងមួយគ្រួសារ ហើយបើគោ ១០០ មួយគ្រួសារ ខ្ញុំគិតទៅប្រហែលនៅទីក្រុងភ្នំពេញមិនចាំបាច់យកឡានចេញពីផ្ទះទេ គឺគោចូលផ្ទះពេញតែម្តង ព្រោះមួយគ្រួសារ ១០០ ច្រើនណាស់ ... រួចចាស់ៗ បានប្រាក់ខែ ៤ ម៉ឺនរៀលក្នុងមួយខែ។ ហ្នឹងអាណត្តិមុន។ តែអាណត្តិនេះ ចាស់ៗ បើបាក់ធ្មេញ ដាក់ធ្មេញមាសឲ្យទៀត។ ឱ! បើមានលុយសម្រាប់ដាក់ធ្មេញមាសឲ្យចាស់ៗ ដាក់បានមួយភ្លែតគាត់យកទៅផ្សារហើយ ...។

១៦. សន្យាទម្លាក់ថ្លៃអគ្គិសនី និងប្រេង

ពិធីបើកការដ្ឋានសាងសង់ទំនប់វារីអគ្គិសនីស្ទឹងឫស្សីជ្រុំក្រោម, ថ្ងៃទី ២៨ ធ្នូ ២០១០

... ប៉ុន្តែ អាចបក្សនយោបាយដទៃ ហ៊ានសន្យារយៈពេល ៥ ឆ្នាំ ឬក៏ខ្លីជាងហ្នឹងផង ហើយគេឲ្យអគ្គិសនីចុះថ្លៃ ឲ្យមកនៅត្រឹម ២ សេនដុល្លារ ក្នុង ១ KW។ នៅចាំបានទេ ឯកឧត្តម ញ៉ឹក ប៊ុនឆែ យោសនាបោះឆ្នោតឆ្នាំ ២០០៣។ ខ្ញុំថា ពួកនេះ

ក្រុមហ៊ុនប្រេងតើ។ ធ្វើបាបកន្លែងលក់សាំងមួយនៅខេត្តកំពង់ចាម។ គេយោសនា កាលហ្នឹងមានគណបក្សនយោបាយ ២ ដែលគាត់រត់ប្រណាំងគ្នា មួយថា បើសិនបក្សខ្ញុំឈ្នះ ឲ្យតម្លៃប្រេងមួយលីត្រ ១.៥០០ រៀល ដល់បក្សមួយទៀតឮថា បើបក្សខ្ញុំឈ្នះ ឲ្យថោកជាងហ្នឹងទៀត។ មានហាងសាំងមួយ នៅខាងកំពង់ចាម យោសនាអញ្ចឹងដែរ។ ដល់ទៅចាក់សាំងរួច ឲ្យលុយប៉ុណ្ណឹង ចាក់តែ ៥ ឡាន បិទហាងបណ្តោយ ស្បថអត់ហ៊ានបើកទៀតទេ ...។

១៧. សន្យាលុបបំណុលប្រជាពលរដ្ឋចោលទាំងអស់

ពិធីកាត់ឫសសីមាព្រះវិហារ និងសម្ពោធសមិទ្ធផល ក្នុងវត្តព្រៃកប្រា,
ថ្ងៃទី ២៨ ធ្នូ ២០១០

... អ្នកនយោបាយខ្លះថា បើគេឈ្នះ (ការបោះឆ្នោត) គេលុបចោលបំណុលទាំងអស់។ អត់ផ្លូវទេ។ លើកលែងតែ អ្នកឯងរំលាយចោលរបបរាជានិយមអាស្រ័យធម្មនុញ្ញ។ របបសព្វថ្ងៃមិនមែនរបប ខ្ញុំព្រះករុណាខ្ញុំទេ។ ខ្ញុំព្រះករុណាខ្ញុំ គ្រាន់តែជានាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល, នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ ប៉ុន្តែ របបនេះជារបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។ ទាល់តែលុបចោលរបបហ្នឹងបង្កើតរបបរដ្ឋមួយថ្មី ធ្វើដូច **ប៉ុល ពត** អញ្ចឹង អាហ្នឹងទៅរួច ...។

១៨. ករណីចោទថា សភាឯកបក្សមិនគ្រប់ទឹក

បើកសម័យប្រជុំសភានីតិកាលទី ៥ និងការថ្លែងទៅកាន់សារព័ត៌មាន,
ថ្ងៃទី ២៤ កញ្ញា ២០១៣

... គេបានលើកឡើងថា សភាឯកបក្ស។ ការប្រជុំរបស់យើង គឺខុសច្បាប់ ប៉ុន្តែ នៅក្រោមអគារនេះ និងនៅក្នុងអគារនេះ កាលពីម្សិលមិញ គ្មានទ្វារណាមួយ ដែលបានចាក់សោ រារាំងសមាជិក សមាជិកាគណបក្ស ដែលមកពីគណបក្សដទៃ តំណាងរាស្ត្រដទៃ មិនឲ្យចូលរួមនោះទេ។ ដូច្នេះ អ្នកដែលចោទប្រកាន់ថា ខុសច្បាប់ ទាំងព្រះមហាក្សត្រ ទាំងសម្តេងភាគច្រើនរបស់សភា និងបណ្តាស្ថាប័នជាតិ ដែលរៀបចំឡើងក្រោមក្របខណ្ឌនៃរដ្ឋធម្មនុញ្ញ ត្រូវគិតយ៉ាងម៉េច។ នេះជា

ស្ថានភាពផ្នែកច្បាប់។ ម្សិលមិញយើងបានទៅចូលរួមសច្ចៈ នៅក្នុងព្រះបរមរាជវាំង ហើយថ្ងៃនេះ សមាជិក/ជិកា គណៈរដ្ឋមន្ត្រី ក៏នឹងត្រូវចូលទៅសច្ចៈនៅក្នុងព្រះបរមរាជវាំងទៀត។ តើយើងជាអ្នកខុសច្បាប់ ព្រះមហាក្សត្រជាអ្នកខុសច្បាប់ សភាជាអ្នកខុសច្បាប់ ឬយ៉ាងណា? គេនិយាយអំពីឯកបក្សនៅក្នុងសភា ប៉ុន្តែគេដើរចេញ ... យើងទៅខេត្តសៀមរាប ដើម្បីទៅចូលរួមជាមួយគេ ឬយើងសុខចិត្តនៅក្រោមដំបូលសភា ក្រោមព្រះរាជាធិបតីព្រះមហាក្សត្រនៅរាជធានីភ្នំពេញ ...។

១៩. សម្លេងភាគតិចចង់ទាមទារធ្វើប្រធានសភា

បើកសម័យប្រជុំសភានីតិកាលទី ៥ និងការថ្លែងទៅកាន់សារព័ត៌មាន,
ថ្ងៃទី ២៤ កញ្ញា ២០១៣

... តើអស់លោកដែលឃើញបក្សភាគតិចណាឡើងធ្វើប្រធានរដ្ឋសភាទេ? ការទាមទារស្នើសុំឱ្យខ្លួនបានធ្វើប្រធានរដ្ឋសភា។ ការមកចរចាថ្ងៃទីពីរ មិនមែនជាការចរចាដើម្បីបង្កើតគណៈកម្មការឯករាជ្យស្វែងរកការពិតអ្វីទេ គឺបានបញ្ជាក់ច្បាស់ហើយថា ទទួលយក ៦៨-៥៥ ហើយទទួលយកសម្តេច ហ៊ុន សែន ជានាយករដ្ឋមន្ត្រី (ហើយ)ថាគេបានធ្វើសម្បទានធំណាស់។ ខ្ញុំបានប្រាប់ថា កុំនិយាយពាក្យធ្វើសម្បទាន ហើយខ្ញុំនេះក៏(មិន)ចាំបាច់មានអ្នកណាគាំទ្រដែរ ព្រោះសម្លេងឆ្នោតរបស់ប្រជាពលរដ្ឋបានបោះឆ្នោតឱ្យខ្ញុំធ្វើជានាយករដ្ឋមន្ត្រីទៅហើយ។ យើងគួរប្រើពាក្យសម្រុះសម្រួល។ ក្នុងពេលជាមួយគ្នា គេបានស្នើឱ្យចែកអំណាចនៅក្នុងសភា ដោយឱ្យបក្សប្រឆាំងកាន់កាប់សភា ដោយសុំធ្វើប្រធានសភា និងចែកគណៈកម្មការ ៦ ម្ខាងក្នុងអចិន្ត្រៃយ៍ ...។

២០. ទាមទារតំណែងប្រធានសភា និងក្នុងគណៈអចិន្ត្រៃយ៍ស្មើៗគ្នា

សម្ពោធភូមិកុមារ SOS ខេត្តក្រចេះ, ថ្ងៃទី ១៨ មករា ២០១៤

... បើមានការចាំបាច់ត្រូវបង្ហោះតាមរ៉ែបសាយត៍ទាំងអស់ ចរចាថ្ងៃទី ១៧ គេបានទទួលរួចហើយនូវបីចំណុច នេះគ្រាន់តែបញ្ជាក់ដើម្បីបើកមុខ ទី ១) ឈប់ទាមទារបង្កើតគណៈកម្មការឯករាជ្យស្វែងរកការពិត ដែលថាភាពមិនប្រក្រតីនៃការបោះឆ្នោតនោះ, ទី ២) ទទួលស្គាល់លទ្ធផល ៦៨ និង ៥៥ និងទី ៣) គាំទ្រ

សម្តេចធ្វើជានាយករដ្ឋមន្ត្រី ... ហ្នឹងជាចំណុចច្បាស់ណាស់ មានកំណត់ហេតុត្រឹមត្រូវនៃការចរចា។ ប៉ុន្តែ ចេញតែពីឯងទៅ ទារឱ្យឯងចុះចេញពីដំណែងទៀត បោះឆ្នោតឡើងវិញ។ រួចចុះអាខ្លួនមកនិយាយនេះ។ មកនិយាយជាមួយឯងផ្សេង ទៅនិយាយជាមួយអ្នកគាំទ្រផ្សឹង, បើសុំវិញ សុំធ្វើប្រធានសភា។ បាន(ខ្ញុំ)ប្រាប់ថា វាមិនដែលមាននៅលើពិភពលោក សម្លេងភាគតិចហើយជាបក្សឆាំង ធ្វើជាប្រធានរដ្ឋសភា ហើយសមាជិកគណៈអចិន្ត្រៃយ៍ស្មើគ្នានេះ វានឹងធ្វើឱ្យគាំងរដ្ឋាភិបាល ...។

២១. គ្មានលាលែងតំណែងនាយករដ្ឋមន្ត្រី, គ្មានបោះឆ្នោតឡើងវិញ, គ្មានរំលាយសភា

សន្និសីទសារព័ត៌មានរបស់សម្តេចតេជោ ហ៊ុន សែន ក្រោយកិច្ចប្រជុំសភា, ថ្ងៃទី ២០ ធ្នូ ២០១៣

... នៅប្រទេសកម្ពុជា មាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញបានកំណត់ថា សភាមាននីតិកាល ៥ ឆ្នាំ, សភាមិនអាចរំលាយមុនផុតអាណត្តិបានទេ លើកលែងតែរាជរដ្ឋាភិបាលត្រូវរំលាយ ២ ដង ក្នុងរយៈពេល ១២ ខែ។ ដូច្នេះ នៅទីនេះ នាយករដ្ឋមន្ត្រីក៏គ្មានសិទ្ធិ, ព្រះមហាក្សត្រគ្មានសិទ្ធិរំលាយសភា, សភាខ្លួនឯងក៏គ្មានសិទ្ធិរំលាយសភា។ តើអ្នកណាមួយដែលមានសិទ្ធិរំលាយសភា ដើម្បីធ្វើការបោះឆ្នោតឡើងវិញ? ដូច្នេះ សូមអ្នកទាមទារទាំងឡាយមើលច្បាប់ឱ្យបានច្បាស់។ មួយទៀត ទាមទារឱ្យខ្ញុំចុះចេញពីតំណែង តើខ្ញុំបានធ្វើកំហុសអ្វី? បើសិនជាសភាទម្លាក់ខ្ញុំ នោះគឺជារឿងមួយ ក៏ប៉ុន្តែការចុះចេញពីតំណែងរបស់ខ្ញុំ មិនមែនជាការចង់បានរបស់អ្នកគាំទ្រគណបក្សប្រជាជន និងគាំទ្រខ្ញុំនោះទេ។ ពិតណាស់ អ្នកដែលមិនគាំទ្រខ្ញុំ មិនមែនត្រឹមតែថ្ងៃនេះទេ តាំងពីជំនាន់ក្រោយពីរំដោះចេញពី ប៉ុល ពត ភ្លាម ក៏គេចង់ឱ្យខ្ញុំចាកចេញពីតំណែងរួចទៅហើយ ... ខ្ញុំឡើងតាមរដ្ឋធម្មនុញ្ញ ខ្ញុំចុះ ក៏ចុះតាមរដ្ឋធម្មនុញ្ញ ... សូមបញ្ជាក់ឱ្យហើយ គ្មានការបោះឆ្នោតឡើងវិញ ព្រោះគ្មានអ្នករំលាយសភា ហើយក៏គ្មានយន្តការណាកំណត់អំពីការបោះឆ្នោតមុនអាណត្តិនោះទេ ...។

២២. ករណីបង្កើតឡើងនូវវប្បធម៌សន្ទនា

សន្និសីទកាសែត ក្រោយសម័យប្រជុំវិសាមញ្ញរដ្ឋសភា នីតិកាលទី ៥,

ថ្ងៃទី ០៨ សីហា ២០១៤

... ដូចដែលបានថ្លែងកាលពីម្សិលមិញ ពេលនោះខ្ញុំមានការកង្វល់យ៉ាងខ្លាំងថា តើយើងអាចប្រជុំបាននៅថ្ងៃនេះឬអត់? ព្រោះបញ្ហាដែលត្រូវដោះស្រាយពីនេះទៅមុខ គឺសម្រាប់ ឯកឧត្តម លោកជំទាវ ដែលជាសមាជិកតំណាងរាស្ត្រនៃគណបក្សសង្គ្រោះជាតិ ទាក់ទិនជាមួយតួនាទីក្បាលម៉ាស៊ីននៅក្នុងរដ្ឋសភា ដើម្បីជួយទៅដល់ឯកឧត្តម ដើម្បីស្របទៅតាមអ្វីដែលយើងបានស្រុះស្រួលគ្នា។ **ជំហានបន្ត គឺយើងនៅតែបន្តក្នុងការធ្វើវិសោធនកម្ម បទបញ្ញាផ្ទៃក្នុងជាបន្តទៅទៀត ដែលក្នុងនោះ យើងបានឯកភាពគ្នាក្នុងថ្ងៃប្រជុំ ថាត្រូវបង្កើននូវវប្បធម៌សន្ទនា។** នេះជាចំណុចដែលត្រូវធ្វើ ដែលខ្ញុំសូមអំពាវនាវសហការីក្នុងសភា ជាពិសេសថ្នាក់ដឹកនាំនៅក្នុងគណៈអចិន្ត្រៃយ៍សភា និងនៅក្នុងគណៈកម្មការនៃសភា ធ្វើការសន្ទនាឱ្យបានច្រើន ជាជាងនាំបញ្ហាមកប្រឈមមុខនៅក្នុងសភា ... **បង្កើនវប្បធម៌នៃការសន្ទនាឱ្យបានច្រើន ដើម្បីស្វែងយល់ចិត្តថ្លើមគ្នា ហើយធ្វើកិច្ចការដើម្បីប្រទេសជាតិ ...**។

២៣. កុំចាប់ដៃជាន់ជើង ដើម្បីរក្សាវប្បធម៌សន្ទនា

ពិធីសម្ពោធគម្រោងដំណាក់កាលទីបី ជាជំនួយជប៉ុន ការពារទីក្រុងភ្នំពេញពីទឹកជំនន់ និងកែលម្អប្រព័ន្ធលូ/ប្រឡាយ, ០៥ វិច្ឆិកា ២០១៥

... **មានការជួបគ្នារវាងសម្តេចក្រឡាហោម ស ខេង ប្រធានក្រុមតំណាងរាស្ត្ររបស់បក្សកាន់អំណាច បក្សក្នុងរាជរដ្ឋាភិបាល ជាមួយនិងឯកឧត្តម សម រង្ស៊ី ប្រធានក្រុមតំណាងរាស្ត្ររបស់ក្រុមបក្សក្រៅរដ្ឋាភិបាល។ ការជួបគ្នានោះ ផ្តោតសំខាន់ទៅលើការពង្រឹងវប្បធម៌សន្ទនា។ សង្ឃឹមថា មេបក្សទាំងសងខាង រៀបរយក្នុងបក្ស កុំលេងចាប់ដៃ ជាន់ជើង។** ខាងនេះគេដឹងហើយ អ្នកណាឈរបញ្ជាបាតុកម្មនៅប៉ារីស អ្នកណាឈរបញ្ជាបាតុកម្មនៅញូយ៉ក។ មិនមែនគេមិនដឹងទេ បើយើងសន្ទនា ត្រូវតែសន្ទនា កុំយើងសន្ទនាមេ ទុកឲ្យកូនដេរ។ អាហ្នឹងទទួលយក

អត់បានទេ។ កូនជេរស្មើនឹងមេជេរ។ ដូចតែគ្នា ... បើចង់សន្ធនាល្អ វិធីមានតែមួយគត់ គឺអប់រំផ្ទៃក្នុងសងខាងទៅ កុំឲ្យប៉ះពាល់គ្នា កុំឲ្យប្រមាថគ្នា ...។

២៤. រ៉ាប្ធម៉ីសន្ធនានឹងដាក់ចូលក្នុងច្បាប់

ពិធីចែកសញ្ញាបត្រនៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ថ្ងៃទី ២៨ ធ្នូ ឆ្នាំ ២០១៥

... ខ្ញុំដូចធ្ងល់ដែលយកពីរ៉ាប៊ីច មកតម្លៃជាមួយអាត់។ នៅក្រោមគេហើយ គេវ៉ៃ ឡើងសំប៉ែតមុខហើយ នៅតម្លៃ ដាក់លក្ខខណ្ឌទៀត ... **រ៉ាប្ធម៉ីសន្ធនា នឹងត្រូវដាក់ចូលក្នុងច្បាប់។ ខ្ញុំសូមទោស បើអ្នកឯងជេរគេ អ្នកឯងត្រូវមានទោសយ៉ាងម៉េច ... មិនមែនអោយជាប់ទោសតែក្នុងយុទ្ធនាការ(ឃោសនា)មួយខែទេ ត្រូវអោយជាប់ទោសតាំងពីឥឡូវ។ និយាយរួម មិនមែនជាប់ទោសតែគេទេ យើងជេរគេ ក៏ជាប់ទោសដែរ។ ច្បាប់ត្រូវគោរពទាំងអស់គ្នា។** រ៉ាប្ធម៉ីសន្ធនាកន្លងទៅ ចេញតែពីបាយជាមួយឯង ប្រៀបធៀបឯងដូច ហ្ការ៉ាហ្ស៊ី, ចង់ចាប់ចោរទាល់តែចូលក្បែរចោរ ...។

២៥. ជំហរចរចារបស់គណបក្សប្រជាជន

ពិធីចែកសញ្ញាប័ត្រ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, សម្ពោធមជ្ឈមណ្ឌលកម្ពុជាស្រាវជ្រាវផ្លូវសូត្រសមុទ្រ, ថ្ងៃទី ១៣ មិថុនា ២០១៦

... ខ្ញុំក៏ធ្វើបទសម្ភាសន៍មួយភ្លាម ... **ទី ១ នឹងមិនមានការចរចាណាមួយរវាងគណបក្សប្រជាជន និងគណបក្សសង្គ្រោះជាតិ នៅពេលខាងមុខនេះទេ។ ច្រកជួបជុំតែមួយគត់គឺសភា។ ប៉ុន្តែ គណបក្សសង្គ្រោះជាតិបានបោះបង់ចោលរួចទៅហើយ។ ទី ២ ប្រសិនមានការពិភាក្សាណាមួយនៅពេលខាងមុខ គណបក្សប្រជាជនមិនពិភាក្សាលើបញ្ហាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់តុលាការ និងពួកអ្នកជាប់គុកនោះទេ** ... បើអ្នកឯងបបួលពិភាក្សារឿងថា ឥឡូវយើងត្រូវធ្វើច្បាប់នេះបន្ថែម គណបក្សប្រជាជនជជែក។ យើងមាន Ad hoc មួយហើយតើ ... មិនចរចាលើបញ្ហាណាដែលមិនមែនជាសមត្ថកិច្ចរបស់គណបក្ស នេះជាជំហរផ្លូវការ បើទាក់ទងរឿងរបស់អ្នកណា អ្នកហ្នឹងប្រឈម ...។

២៦. វប្បធម៌សន្ធនា បន្តមានតាមគណៈអចិន្ត្រៃយ៍សភា

កិច្ចប្រជុំសភាដើម្បីធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុង ត្រង់មាត្រាទី ៤៨ ថ្មី, ៣១ មករា ២០១៧

... មិនអាចប្រើយន្តការនេះទៅបំពានអំណាច ជាពិសេសសមត្ថកិច្ចរបស់តុលាការតែម្តង។ អាចមានការផ្តល់យោបល់អំពីបញ្ហានេះបញ្ហានោះ ប៉ុន្តែសូមបញ្ជាក់ឲ្យហើយ **វប្បធម៌សន្ធនានៅតែមាន ប៉ុន្តែមានតាមណា? មានតាមគណៈអចិន្ត្រៃយ៍សភានោះ។ ទៅនិយាយគ្នាទៅ។ គណៈអចិន្ត្រៃយ៍សភាមានទេតើ តែអស់លោកមិនដែលមក។** យើងនៅតែនិយាយ ឲ្យតែគេមក។ តែឥឡូវនិយាយជាមួយអ្នកណាបើគេអត់នៅផង។ យន្តការសភាគ្រប់គ្រាន់ហើយមិនចាំបាច់ធ្វើអីទេ ...។

២៧. ករណីចោទ (ហ៊ុន) ម៉ាណែត ជាកូនរបស់មេដឹកនាំវៀតណាម

ពិធីចែកសញ្ញាបត្រ ជូននិស្សិត នៃសាកលវិទ្យាល័យ IIC នៃបច្ចេកវិទ្យា, ថ្ងៃទី ២៨ មីនា ២០១១

... **ឥឡូវគេបានបង្ហោះតាមហ្វេសបុកថា ហ៊ុន ម៉ាណែត មិនមែនជាកូនរបស់ហ៊ុន សែន ទេ ឲ្យមើល DNA ទៅ** ... បងប្អូនប្រជាពលរដ្ឋកម្ពុជា ហ៊ុន ម៉ាណែត ជាកូនប្រុសរបស់ខ្ញុំដ៏កំសត់ ភរិយារបស់ខ្ញុំកំសត់ណាស់ ទម្រាំបានរៀបការជាមួយខ្ញុំ ... **ខ្ញុំអត់នឹកថាពួកប្រឆាំងអាចធ្វើអំពើថោកទាបបែបនេះបានទេ ... ខ្ញុំបាននិយាយហើយ បើអ្នកឯងមិនឲ្យខ្ញុំសុខ ខ្ញុំក៏មិនឲ្យអ្នកឯងសុខដែរ។ ថ្នាក់ដល់ថាកូនរបស់ខ្ញុំ ប្រពន្ធរបស់ខ្ញុំនេះ ជាប្រពន្ធរបស់មេដឹកនាំវៀតណាមណាមួយនោះ ... គេអាច(ធ្វើការ)មួលបង្កាច់បែបនេះទៅរួច តើរឿងស្អីទៀតដែលគេមិនអាចមួលបង្កាច់បាន?** ... កូនប្រុសរបស់ខ្ញុំ(សរសេរសារមក)ថា "ពុក! ខ្ញុំសុំប្រកាសតែម្តង។ ត្រូវដាក់ខសន្យាជាមួយគ្នាថាបើធ្វើ DNA ទៅ បើខ្ញុំជាកូនពុក អ្នកឯងត្រូវដកខ្លួនចេញពីនយោបាយ។ ផ្ទុយទៅវិញ បើខ្ញុំមិនមែនជាកូនរបស់ពុកមែន គឺខាងយើងក៏ត្រូវដកខ្លួនពីនាយករដ្ឋមន្ត្រីដែរ"។ ខ្ញុំវ៉ៃត្រឡប់ទៅវិញថា កុំវល់ជាមួយពួកវា។ ហ៊ុន ម៉ាណែត គឺជាមនុស្សដែលនឹងនរជាងគេក្នុង ចំណោមកូន ក៏ប៉ុន្តែ វាអត់ទ្រាំមិនបានជាមួយនិងការប្រមាថ ...។

២៨. សម រង្ស៊ី ថា «គណបក្សប្រជាជនខ្លាចចាញ់ឆ្នោត មិនហ៊ានធ្វើការបោះឆ្នោត»

ការបកស្រាយបំភ្លឺ ករណីឆ្លើយតបចំពោះការវាយប្រហារបំផ្លាញវប្បធម៌សន្ធនា ដោយមេបក្សប្រឆាំង, ១២ វិច្ឆិកា ២០១៥

... មួយរយៈចុងក្រោយនេះ ឯកឧត្តមបែរជានិយាយថា **គណបក្សប្រជាជនខ្លាចចាញ់ឆ្នោត មិនហ៊ានធ្វើការបោះឆ្នោត ចង់បំផ្លាញចោលការបោះឆ្នោត។ ខ្ញុំគួរតែជម្រាបជូនឯកឧត្តមវិញថា ឯកឧត្តមនៅចាំបានទេ នៅមុនបោះឆ្នោតឆ្នាំ ២០១៣ គណៈប្រតិភូ ICAPP ដឹកនាំដោយអនុប្រធានាធិបតី ឥណ្ឌូនេស៊ីបច្ចុប្បន្ន និងអតីតប្រធានរដ្ឋសភាហ្ជីលីពីនបានជួបឯកឧត្តមដល់ទីស្នាក់ការ។ ឯកឧត្តមបាននិយាយថា "ចូលរួមបោះឆ្នោត តែមិនទទួលស្គាល់លទ្ធផលបោះឆ្នោត"។ មិនទាន់ទាំងបោះឆ្នោតផង ឯកឧត្តមមិនទទួលស្គាល់លទ្ធផលបោះឆ្នោត** ... មិនមែនជាលើកទី ១ ទេ ឯកឧត្តមបាននិយាយភាសានេះ។ ឥឡូវមិនទាន់ដល់ពេលវេលាបោះឆ្នោត ឯកឧត្តមដើរទៅបំផុសប្រាប់ប្រទេសថា គណបក្សប្រជាជនដឹងថាខ្លួនចាញ់ មិនចង់ធ្វើការបោះឆ្នោត។ ឯកឧត្តមត្រូវមានកស្តុតាងឲ្យច្បាស់ ប្រយ័ត្នជាប់បទល្មើសព្រហ្មទណ្ឌ (ពី)ការចោទប្រកាន់ដោយគ្មានកស្តុតាង។ អំពើនេះជាការបរិហារកេរ្តិ៍ ឬក៏យ៉ាងណា យើងខ្ញុំត្រូវពិនិត្យអំពីផ្លូវច្បាប់ ហើយសូមកុំបន្ទោស បើសិនជាផ្លូវច្បាប់ត្រូវចាត់ការចំពោះឯកឧត្តម ...។

ឧបសម្ព័ន្ធ ខ៖ នយោបាយឈ្លះ-ឈ្លះ

ក. ហេតុអ្វី ត្រូវមាននយោបាយឈ្លះ-ឈ្លះ

ក.១ កម្ពុជា តែងមានតំបន់ត្រួតត្រាច្រើន ក្នុងពេលតែមួយ ៣១៧
ក.២ ប៉ែ\ លិន សម័យសង្គ្រាម កុមារ និងយុវជនគ្មានក្តីសុខទេ ៣១៧
ក.៣ បើស្លាប់ៗ តែខ្ញុំ ... បើជោគជ័យ បានផែនដីទាំងមូល ខ្មែរលែងច្បាំង ៣១៨
ក.៤ សង្គ្រាមលើចំណែកដ៏តូច និងពេលវេលាដ៏តិច រំខានដល់ភាគច្រើន ៣១៩
ក.៥ បើគ្មានបាតដៃ ហ៊ុន សែន ទេ កិច្ចព្រមព្រៀងក្រុងប៉ារីសក៏គ្មានដែរ ៣១៩
ក.៦ សង្គ្រាមមិនអាចបញ្ចប់សង្គ្រាមបានទេ ៣២០
ក.៧ ជាងពាក់កណ្តាលជីវិត ធ្វើការចរចាសន្តិភាព ច្រើនជាងកិច្ចការច្បាំង ៣២១
ក.៨ ទុកច្រកឲ្យគេរស់ និងធ្វើអ្វីដែលខុសពីគំនិតរបស់យើង ៣២២

ខ. គោលការណ៍ ៣, សារ ៣, កិច្ចការ ៥, ការអនុវត្តន៍

ខ.១ គោលការណ៍ ៣ នៃ នយោបាយឈ្លះ-ឈ្លះ ៣២២
ខ.២ សារនយោបាយ ៣ ស្តីពី ការទទួលមេដឹកនាំ ខ្មែរក្រហម ៣២៣
ខ.៣ បានធ្វើភារកិច្ច ៥ អំពីរបបប្រល័យពូជសាសន៍ ៣២៤
ខ.៤ សាសនារួមជាមួយនយោបាយឈ្លះ-ឈ្លះ នាំដល់ការបញ្ចប់សង្គ្រាម ៣២៥
ខ.៥ គណិតវិទ្យានយោបាយ “អត់លើសអត់ខ្វះ” ៣២៥
ខ .៦ ត្រូវការសមាហរណកម្មនយោបាយ/រដ្ឋបាលនិងសមាហរណកម្មរវាន្ត ៣២៦

គ. សមិទ្ធផល នៃនយោបាយឈ្លះ-ឈ្លះ

គ.១ នយោបាយឈ្លះ-ឈ្លះ នាំមកនូវសន្តិភាព មានឥទ្ធិពលលើវិស័យដទៃ ៣២៧
គ.២ កម្ពុជា ពីសូរកាំភ្លើង ទៅជាព្រះធម៌ និងដូរ្យតន្ត្រី ៣២៧
គ.៣ នយោបាយឈ្លះ-ឈ្លះ បញ្ចប់សង្គ្រាម បន្ថយការស្លាប់ របួសយុទ្ធជន ៣២៩
គ.៤ នយោបាយឈ្លះ-ឈ្លះ ធ្វើឲ្យសេដ្ឋកិច្ច មានការកើនឡើង ៣២៩
គ.៥ ការអភិវឌ្ឍទាំងអស់ កើតចេញពីនយោបាយឈ្លះ-ឈ្លះ ៣៣០
គ.៦ នយោបាយឈ្លះ-ឈ្លះ នាំអោយកើតវ៉ារីអគ្គិសនី ៣៣០
គ.៧ នយោបាយឈ្លះ-ឈ្លះ ផ្តល់ឱកាសសម្រាប់យុវជនបន្តការរៀនសូត្រ ៣៣១
គ.៨ នយោបាយឈ្លះ-ឈ្លះ មិនទាន់មានលើលោក, ផ្ទៃក្នុងស្រុះស្រួល ... ៣៣២

ក. ហេតុអ្វី ត្រូវមានតយោបាយឈ្នះ-ឈ្នះ

ក.១. កម្ពុជា តែងមានតំបន់ត្រួតត្រាច្រើន ក្នុងពេលតែមួយ

ពិធីបញ្ចុះខណ្ឌសីមា និងឆ្លងសមិទ្ធផលនានា នៅវត្តសន្សំកុសល, ថ្ងៃទី ០៤ កុម្ភៈ ២០០៩

... មុននេះ ប្រទេសកម្ពុជាមួយ តែងតែមានតំបន់ត្រួតត្រាច្រើនក្នុងពេលតែមួយ។ ពិនិត្យមើលឆ្នាំ ១៩៧០-៧៥ ម្ខាងគ្រប់គ្រងដោយពួក លន់ នល់ ដែលមានកងទ័ពអាមេរិក កងទ័ពវៀតណាមខាងត្បូង ... ម្ខាងទៀតគ្រប់គ្រងដោយរណសិរ្ញរួបរួមជាតិកម្ពុជា ដែលដឹកនាំដោយ សម្តេចព្រះនរោត្តម សីហនុ ក្រោយមក ប៉ុល ពត ចាប់យក ហើយបំផ្លាញជីវិតប្រជាជន។ ឆ្នាំ ១៩៧៩-៩៣ ប្រទេសកម្ពុជាមួយមានតំបន់ត្រួតត្រា ៤ មួយគឺរដ្ឋាភិបាលភ្នំពេញ ៦ ៣ ទៀត គឺរដ្ឋាភិបាលចម្រុះត្រីភាគី។ ឆ្នាំ ១៩៩៣-៩៨ ប្រទេសកម្ពុជាមួយមានតំបន់ត្រួតត្រា ២ ទៀត មួយគឺរាជរដ្ឋាភិបាលនៅភ្នំពេញ ឯមួយទៀត គឺរដ្ឋាភិបាលនៅអន្លង់រ៉ែង។ អញ្ចឹង ទម្រាំរកឃើញនូវរូបមន្តនយោបាយឈ្នះ-ឈ្នះ ធ្វើឲ្យប្រទេសមានសន្តិភាព មានការបង្រួបបង្រួមជាតិ បំបាត់ចោលទឹកដីអបគមន៍ មិនមែនជាការងាយនោះទេ។ ដូច្នេះ ទាំងព្រះសង្ឆ ទាំងគ្រហស្ថ ទាំងផ្នែកពុទ្ធចក្រ និងអាណាចក្រ មានកាតព្វកិច្ចដូចៗគ្នា ថែរក្សាសន្តិភាព ស្តេរភាពនយោបាយ ដែលយើងបានប្រឹងប្រែងរកបានដោយលំបាក ...។

ក.២. ប៉ៃលិន សម័យសង្គ្រាម កុមារ និងយុវជនគ្មានក្តីសុខទេ

ពិធីសម្ពោធសមិទ្ធផលនានា នៃខេត្តប៉ៃលិន, ថ្ងៃទី ០៣ មករា ២០១៣

... យើងក៏មិនត្រូវភ្លេចថា តើការចាប់ផ្តើមចេញពីទីណា? បើយើងគិតអំពីអ្នកកើតនៅក្នុងតំបន់នេះ មិនថាតែប៉ៃលិនទេ គឺតំបន់មួយចំនួនដូចជា សំឡូត កំរៀង ភ្នំព្រឹក្ស ... អាចនិយាយបានថា ប្រវត្តិនៃការកើតរឿងរ៉ាវ ដែលប្រើពេល ២៦ ឆ្នាំ ទើបអាចបញ្ចប់បាន។ បើនៅខាងអន្លង់រ៉ែងវិញ គឺ ២៨ ឆ្នាំ ទើបអាចបញ្ចប់បាន។ យើងមិនអាចមិនគិតពីដំណាក់កាលការកកើតសង្គ្រាមបានទេ។ សង្គ្រាមបានផ្ទុះឡើង ក្រោយពីការធ្វើរដ្ឋប្រហារថ្ងៃទី ១៨ ខែ មិនា ឆ្នាំ ១៩៧០។ ដូច្នេះ

ក្នុងដំណាក់កាលចាប់ពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥ គ្មានទេ ដែលហៅថា សេចក្តីសុខសម្រាប់កុមារ ដែលបានកើតឡើងនៅក្រោយរដ្ឋប្រហារឆ្នាំ ១៩៧០។ បន្តមកទៀត កុមារដែលរស់នៅក្នុងជំនាន់ **ប៉ុល ពត,** ៣ ឆ្នាំ ៨ ខែ និង ២០ ថ្ងៃ។ ក្នុងចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ គ្មានទេសេចក្តីសុខ។ របបប្រល័យពូជសាសន៍ បានលាតសន្ធឹងកាប់សម្លាប់ប្រជាពលរដ្ឋរបស់យើង។ បន្តទៀត គ្មានទេ សេចក្តីសុខសម្រាប់កុមារ និងយុវជនដែលកើតក្នុងតំបន់នេះក្នុងឆ្នាំ ១៩៧០។ អញ្ចឹងអាចថា **យុវជនដែលកើតក្រោយរដ្ឋប្រហារឆ្នាំ ១៩៧០ មកទល់នឹងពេលធ្វើសមាហរណកម្ម នៅឆ្នាំ ១៩៩៦ មានរយៈពេល ២៦ ឆ្នាំ ទើបពួកគេបានស្រាកស្រាន្ត ទទួលបានមនុញ្ញផលពីសន្តិភាព តាមរយៈនៃនយោបាយឈ្នះ-ឈ្នះនេះ**។ ខ្ញុំព្រះករុណាខ្ញុំ ពិតជាមានមោទនភាព ដែលបានកើតលើទឹកដីខ្មែរ បានរួមចំណែកជាមួយជនរួមជាតិ អនុវត្តនូវនយោបាយឈ្នះ-ឈ្នះ នាំមកនូវសន្តិភាពទាំងស្រុង ...។

ក.៣. បើស្លាប់ៗ តែខ្ញុំ ... បើជោគជ័យ បានផែនដីទាំងមូល ខ្មែរលែងច្បាំង

ពិធីសម្ពោធសមិទ្ធិផលនានា នៃខេត្តប៉ៃលិន, ថ្ងៃទី ០៣ មករា ២០១៣

... បើមិនមាន ៧ មករា ក៏មិនមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស ហើយក៏អត់មានឈ្លួនផ្ទុះសន្តិភាពនៅប៉ៃលិននេះដែរ។ ព្រោះអី ? ព្រោះ អ៊ី ឈាន ក៏ងាប់ដែរ។ គ្មាន អ៊ី ឈាន ទេ។ ... តា ម៉ុក ទៅចាប់ ប៉ុល ពត គឺចូលដល់កម្រិតការសម្រិតសម្រាំងហើយ។ នេះជាការសោកស្តាយមួយ ដែលយើងទៅអត់ទាន់បងប្អូនថ្នាក់កងពលមួយចំនួន នៅខាងឃុំត្រពាំងប្រាសាទ លោក សាន លោកអ៊ីហ្ម៉ឹង បានស្លាប់ ... ខ្ញុំគិតថា យើងទាំងអស់គ្នាបានដឹងរៀងៗខ្លួនហើយ អ្វីដែលបានកើតឡើងលើទឹកដីដ៏កម្សត់របស់យើងនេះ ... ម្តាយខ្ញុំ និងម្តាយធំខ្ញុំ សួរខ្ញុំ។ ម្តាយខ្ញុំ រាងធ្ងន់ត្រចៀកបន្តិច។ គាត់ថា "អ្ហែងទៅកន្លែងគេ មិនខ្លាចគេបាញ់សម្លាប់ទេអី ?"។ ម្តាយធំគាត់ថា ក្ងុយឯងចូលទៅតំបន់គេ មិនខ្លាចគេសម្លាប់ទេអី ? ខ្ញុំបាននិយាយប្រាប់ម្តាយធំខ្ញុំ និងម្តាយខ្ញុំថា **"ម៉ែ! ធំ! បើស្លាប់ ស្លាប់តែខ្ញុំ និងអ្នកដែលទៅជាមួយខ្ញុំតែប៉ុន្ម្មាននាក់ទេ ប៉ុន្តែ បើបានមកវិញ បានផែនដីទាំងមូលតែម្តង។ ខ្មែរលែងច្បាំងគ្នាហើយ។"** នោះជាការប្រជុំយជីវិត។ **កាលពីមុន**

នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៧៧ ចាប់ផ្តើមយកដីវិតធ្វើដើមទុន ដើម្បីរំដោះប្រទេសចេញពីរបប ប៉ុល ពត។ ពេលអនុវត្តន៍នយោបាយឈ្នះ-ឈ្នះ បើខ្ញុំព្រះករុណាខ្ញុំ មិនមក តើបងប្អូនអាចជឿបានទេ? នេះជារឿងមិនសាមញ្ញ មិនធម្មតាទេ។ យើងត្រូវចារទុកក្នុងប្រវត្តិសាស្ត្រទីនេះ ដែលជាឈ្នួនផ្ទុះនៃសន្តិភាព...។

ក.៤. សង្គ្រាមលើចំណែកដ៏តូច និងពេលវេលាដ៏តិច រំខានទៅដល់ភាគច្រើន

ពិធីផ្សព្វផ្សាយគោលនយោបាយជាតិ និងផែនការសកម្មភាពជាតិ ស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ឆ្នាំ ២០១៤-២០១៨, ថ្ងៃទី ០១ កញ្ញា ២០១៤

... កុំនិយាយដល់ការគិតគូរពីអាហារូបត្ថម្ភ និយាយត្រឹមតែបញ្ហាឱ្យវារស់ គឺមិនបានរស់ផង។ ឆ្នាំ ១៩៧០ សង្គ្រាមបានកើតឡើងនៅក្នុងទឹកដីកម្ពុជា គ្រាប់បែក គ្រាប់ផ្លោងរាប់លានគោននៅលើទឹកដីកម្ពុជា តើកុមារប៉ុន្មាននាក់ទៅដែលបានស្លាប់? បន្ទាប់ពីសង្គ្រាម របបប្រល័យពូជសាសន៍បានមកដល់ កុមារបានបាត់បង់ឱកាសផ្តល់ការស្រឡាញ់ ពីមាតាបិតាទៅហើយ បន្តទៅទៀត យើងមានសង្គ្រាម។ **ពិតមែនតែដំណាក់កាលពីឆ្នាំ ១៩៧៩ មកទល់ឆ្នាំ ១៩៩៨ ទើបយើងមានសន្តិភាពទាំងស្រុង តាមរយៈនយោបាយឈ្នះ-ឈ្នះ ប៉ុន្តែ យើងមិនត្រូវភ្លេចថា យើងបានស្ថិតក្នុងស្ថានភាពដែលប្រទេសមានសន្តិភាពផង និងមានសង្គ្រាមផង។ ពិតមែនតែសង្គ្រាមបានកើតឡើងនៅចំណែកភាគតិចនៃដែនដី និងពេលវេលា ហើយសន្តិភាពបានកើតមាននៅចំណែកភាគច្រើននៃដែនដី និងពេលវេលា ក៏ប៉ុន្តែ សង្គ្រាម ដែលកើតមានលើចំណែកដ៏តូច និងពេលវេលាដ៏តិចនេះ វាក៏រំខានទៅដល់ភាគច្រើននោះ។** ពិតណាស់ថា ក្នុងកាលៈទេសៈនោះ មានតំបន់មួយចំនួនផ្តោតការយកចិត្តទុកដាក់លើបញ្ហាទាក់ទិនទៅនឹងការអភិវឌ្ឍកុមារតូច ក៏ប៉ុន្តែ ក៏មានតំបន់មួយចំនួន គិតតែពីបីកូនរត់តែម្តង? ជាភ័ព្ធសំណាងដែលយើងមានការបង្រួបបង្រួមជាតិ មានការឯកភាពទឹកដី ហើយពីប្រទេសមួយ ដែលមានតំបន់ត្រួតត្រាច្រើន និងកម្លាំងប្រដាប់អាវុធច្រើនត្រួតត្រា ...។

ក.៥. បើគ្មានបាតដៃ ហ៊ុន សែន ទេ កិច្ចព្រមព្រៀងក្រុងប៉ារីសក៏គ្មានដែរ

ពិធីចាក់បេតុងតភ្ជាប់នូវមុខតំណចុងក្រោយនៃស្ពានអ្នកលឿង ត្សឹបាសា(Tsubasa),

ថ្ងៃទី ១៤ មករា ២០១៥

... ខ្ញុំអរគុណទាំងអស់គ្នា ទាំងអ្នកថាអាក្រក់ ទាំងអ្នកថាល្អ។ ប៉ុន្តែ សូមក្រឡេកមើលក្រោយទៅវិញ។ ឆ្នាំ ១៩៧៩-៨៦ ហ៊ុន សែន ជាឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីការបរទេស រួមចំណែកដឹកនាំពីឆ្នាំ ១៩៨៥ ដល់បច្ចុប្បន្ន គឺជានាយករដ្ឋមន្ត្រី។ គុណសម្បត្តិ និងគុណវិបត្តិ តែងតែកើតមាន។ ប៉ុន្តែ **នៅពេល ហ៊ុន សែន ចាប់ផ្តើមធ្វើនាយករដ្ឋមន្ត្រី សង្គ្រាមនៅហែកហួរប្រទេសនេះនៅឡើយ។ សូមកុំកាន់ច្រឡំ បើគ្មានបាតដៃ ហ៊ុន សែន ទេ ក៏គ្មានកិច្ចព្រមព្រៀងក្រុងប៉ារីសមកដែរ ... ហ៊ុន សែន អ្នកទៅចរចា បើ ហ៊ុន សែន រាយការណ៍ឲ្យសម្តេចហេង សំរិន, សម្តេច ជា ស៊ីម ថា អត់បានទេ មិនបាច់ចរចាទៅទៀត គឺវ៉ៃគ្នាតែម្តង។ អញ្ចឹង វាអាចនៅតែវ៉ៃគ្នាដល់ថ្ងៃនេះ។ ហ្នឹងនិយាយពីសមិទ្ធផលនៃសន្តិភាពនយោបាយឈ្នះ-ឈ្នះ ការចប់សង្គ្រាម អ្នកណាអ្នកធ្វើ បើ ហ៊ុន សែន មិនចូលរួងខ្លា** ... នាំនយោបាយឈ្នះ-ឈ្នះចូលទៅ ... អ៊ុនតាក់ប្រើលុយ ២០០០ លានដុល្លារ បញ្ចប់សង្គ្រាមអត់បានទេ។ សុំទៅសួរ អាកាស៊ី ខ្លួនឯងទៅ ចូលប៉ែលិនអត់បានទេ។ អាកាស៊ី ជនជាតិជប៉ុន ចូលប៉ែលិនអត់បាន តែខ្ញុំយកប៉ែលិនបាន យកទឹកដីទាំងអស់(មកអោយ)ប្រជាជនខ្មែរ។ (យើងនាំគ្នា)រួបរួមគ្នា កសាងប្រទេស ....។

ក.៦. សង្គ្រាមមិនអាចបញ្ចប់សង្គ្រាមបានទេ

ពិធីប្រគល់សញ្ញាបត្រ ជូននិស្សិតនៃសាកលវិទ្យាល័យអាស៊ីអឺរ៉ុប,
ថ្ងៃទី ១១ ឧសភា ២០១៥

... ខ្ញុំព្រះករុណាខ្ញុំ ចង់និយាយបន្តិចថា បញ្ហាវប្បធម៌សន្ធនាមិនមែនជារឿងចម្លែកសម្រាប់ ហ៊ុន សែន ទេ ព្រោះជាងពាក់កណ្តាលជីវិតរបស់ ហ៊ុន សែន គឺសន្ធនាជានិច្ច។ **តាំងពី ហ៊ុន សែន ធ្វើជារដ្ឋមន្ត្រីការបរទេសនៅក្នុងវ័យ ២៧ ឆ្នាំ ហើយធ្វើជានាយករដ្ឋមន្ត្រីតាំងពីអាយុ ៣២ ឆ្នាំ ហ៊ុន សែន មិនដែលជឿលើការដោះស្រាយជម្លោះតាមរយៈនៃការវាយប្រហារគ្នា ការប្រើប្រាស់សង្គ្រាម ដើម្បីបញ្ចប់សង្គ្រាមទេ។ វប្បធម៌សន្ធនា គឺជាទម្លាប់របស់ ហ៊ុន សែន គ្រាន់តែដៃគូផ្សេង ការដោះស្រាយបញ្ហាវាផ្សេង និងបរិបទនយោបាយវាផ្សឹងតែប៉ុណ្ណឹងទេ។**

ការចរចា សីហនុ-ហ៊ុន សែន ហ្វ្រេអង់តាដឺន័រ តើវាជាអ្វី ? នោះហើយគឺការសន្ធនា ដើម្បីឈានឆ្ពោះទៅដោះស្រាយបញ្ហាបញ្ចប់សង្គ្រាម ប្រធានបទពេលនោះ គឺបញ្ចប់សង្គ្រាម ... ទោះបីទៅទីណាក៏ដោយ លំបាកវេទនាយ៉ាងណាក៏ដោយ ហ៊ុន សែន ទៅរកកន្លែងចរចា ទោះបីពេលនោះត្រួតគ្រាទឹកដី ៩០% ជាង ប្រជាជនលើស ៩០% ក៏ដោយ។ **ខ្ញុំមិនដែលជឿថាមានដំណោះស្រាយតាមផ្លូវយោធា ដើម្បីបញ្ចប់សង្គ្រាមទេ។ រាប់ទាំងសង្គ្រាមលោកលើកទី ២ ផង គ្មានប្រទេសណាមួយ ដែលបញ្ចប់សង្គ្រាមដោយមិនមានការចរចាទេ សូម្បីតែសង្គ្រាមនៅតំណ្ហ្ចិននេះ។ សង្គ្រាមនៅវៀតណាម បានរាលដាលដល់កម្ពុជា ដល់ឡាវ។ តើមានការចរចាទេ ? មានការចរចារវាង Kissinger និង Le Duc Tho ដែលបង្កើតនូវកិច្ចព្រមព្រៀងប៉ារីសឆ្នាំ ១៩៧៣ តម្រូវឲ្យអាមេរិកដកកងទ័ពចេញ រាប់ទាំងការវាយតាមដើងអាកាស។ នោះជាផ្នែកមួយ នៃការសន្ធនានយោបាយ ...**។

ក.៧. ជាងពាក់កណ្តាលជីវិត ធ្វើការចរចាសន្តិភាព ច្រើនជាងកិច្ចការច្បាំង

ពិធីបើកព្រឹត្តិការណ៍ «អង្គរសង្ក្រាន្ត ឆ្នាំ ២០១៥», ថ្ងៃទី ១៤ មេសា ២០១៥

... ប្រហែលជាឯកឧត្តម លោកជំទាវ អគ្គរាជទូត អគ្គរដ្ឋទូត ប្រិយមិត្តបរទេស មានការចាប់អារម្មណ៍នៅត្រង់ថាប្រទេសកម្ពុជា បានដើរដល់ដំណាក់កាលមួយថ្មី នោះគឺវត្តមានរបស់ឯកឧត្តម សម រង្ស៊ី និងលោកជំទាវ នៅក្នុងវេទិកា នៅថ្ងៃនេះ។ **រឿងធម៌សន្ធនាមួយ បានចាប់ផ្តើមនៅលើទឹកដីកម្ពុជា ជំនួសឲ្យរឿងធម៌ នៃការប្រទូស្តរាយ និងការកាប់សម្លាប់គ្នា។ ខ្ញុំបានធ្វើកិច្ចការនេះ ដោយអំណត់ជាមួយ សមភាគី ... ជាងពាក់កណ្តាលជីវិតរបស់ខ្ញុំ ខ្ញុំបានធ្វើកិច្ចការពាក់ព័ន្ធនឹងការចរចាសន្តិភាព ច្រើនជាងកិច្ចការចំបាំង។** <u>**ចំនុចទី ១**</u> ដំណើរការស្វែងរកសន្តិភាពតាមរយៈការចរចារវាងខ្ញុំព្រះករុណាខ្ញុំ ជាមួយសម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ នៅថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៨៧ ហ្វ្រេអង់តាដឺន័រ ជាការបើកផ្លូវដើម្បីឈានឆ្ពោះទៅរកវេទិកាដទៃទៀត និងកិច្ចព្រមព្រៀងទីក្រុងប៉ារីស បានទទួលជោគជ័យរួចហើយ។ <u>**ចំនុចទី ២**</u> ការបង្កើត និងដឹកនាំអនុវត្តនយោបាយឈ្នះ-ឈ្នះ បានជោគជ័យរួចហើយដែរ ដែលធ្វើឲ្យទូទាំងព្រះរាជាណាចក្រកម្ពុជាបញ្ចប់នូវការបែកបាក់ ចាប់ផ្តើមមានបន្ទាប់ពីព្រះរាជាពញ្ញាយ៉ាត ចូលទីវង្គត និងព្រះនរាយណ

ជាចូលទីវង្គ៌ត ... សាមកុក មិនមែនមានតែនៅក្នុងប្រទេសចិនទេ។ សាមកុកក៏បានកើតឡើងនៅក្នុងស្រុកខ្មែរដែរ ...។

ក.៨. ទុកច្រកឲ្យគេរស់ និងធ្វើអ្វីដែលខុសពីគំនិតរបស់យើង

ពិធីបើកព្រឹត្តិការណ៍ «អង្គរសង្ក្រាន្ត ឆ្នាំ ២០១៥», ថ្ងៃទី ១៤ មេសា ២០១៥

... ចំណុចដែលគួរឲ្យឃើញ **មុនឆ្នាំ ១៩៧០ ខ្មែរមានដល់ ៥ ក្រុម ... ខ្ញុំបានសិក្សាលើប្រវត្តិនៃសង្គ្រាមនេះ តើត្រូវធ្វើដូចម្តេច និងធ្វើយ៉ាងណា ដើម្បីបញ្ចប់សង្គ្រាមនោះឲ្យបាន? ជាមេរៀនបទពិសោធន៍របស់ខ្ញុំព្រះករុណាខ្ញុំ ជម្រើសតែមួយគត់ គឺយើងត្រូវទុកច្រកឲ្យគេរស់ ទុកច្រកឲ្យគេមានលទ្ធភាព ដើម្បីធ្វើអ្វីដែលអាចខុសពីគំនិតរបស់យើង**។ ដោយសារតែវប្បធម៌ឯកបក្ស មិនបើកឲ្យមានសារព័ត៌មានសេរី មានសង្គមស៊ីវិល ឬបក្សនយោបាយផ្សេងៗ ដែលមានគំនិតខុសពីខ្លួន ជម្រើសនៅសល់ គឺតស៊ូប្រដាប់អាវុធតែម្តង។ នេះជាបទពិសោធន៍ធំណាស់។ ហេតុនេះហើយ បានជាពេលខ្ញុំព្រះករុណាខ្ញុំ ចាប់ផ្តើមកាន់ការងារ រឿងបញ្ហាអាវុធយុទ្ធកណ្ឌ រឿងវ៉ៃគ្នា គ្រាន់តែការទប់ទល់បណ្តោះអាសន្ន រង់ចាំនូវឱកាសនយោបាយមួយមកដល់។ ជាបន្តបន្ទាប់ កម្ពុជាយើងទៅមុខទៅក្រោយ ឬក៏នៅទ្រឹង ... ខ្ញុំបាននិយាយនៅក្នុងការចរចាថា យើងត្រូវបង្កើតការសន្ទនាឲ្យបានច្រើនបំផុតតាមអាចធ្វើទៅបាន។ ឯកឧត្តម សម រង្សី បានទទួលយក។ យើងបានក្លាយជាស្ថាបនិកនៃវប្បធម៌សន្ទនា ...។

ខ. គោលការណ៍ ៣, សារ ៣, កិច្ចការ ៥, ការអនុវត្ត

ខ.១. គោលការណ៍ ៣ នៃ នយោបាយឈ្នះ-ឈ្នះ

ពិធីចែកសញ្ញាបត្រជូនដល់និស្សិត នៃវិទ្យាស្ថានវ៉ាន់ដា គណនេយ្យ,
ថ្ងៃទី ១០ មករា ២០១១

... គេថា ខ្ញុំជាមនុស្សឆេវឆាវ តែក្នុងរឿងនយោបាយ មិនឆេវឆាវទេ។ ឥឡូវនយោបាយឈ្នះ-ឈ្នះ របស់យើងវាស្ថិតស្ថេរ។ ព្រោះអី? ព្រោះមិនមែនជារបស់ដែលគេចាប់បង្ខំ មិនមែនបរទេសដាក់អោយយើង។ ខ្ញុំសូមជម្រាបនយោបាយឈ្នះ-ឈ្នះ គិតទៅមានតែ ៣ ចំណុចទេ ដែលសំខាន់ ដែលធ្វើអោយអង្គការចាត់

តាំងនយោបាយ និងយោធារបស់ខ្មែរក្រហមរលំរលាយ ទាញខាងក្រោមឯកោខាងលើ ហើយទាញខាងលើឲ្យមកចុះចូល។ **ទី ១ ការារក្សានូវសន្តិសុខ ទាំងអាយុជីវិត និងសន្តិសុខរូបកាយរបស់គេ។** យើងត្រូវធានាយ៉ាងម៉េចឲ្យគេរស់ ហើយកុំចាប់គេដាក់គុក។ អារឿងព្រហ្មទណ្ឌដទៃទៀត ដូចជា ឈូក រិន, សំ ប៊ិត ជារឿងមួយផ្សេង។ **ទី ២ ការារអាជីព និងមុខរបរ** ធ្លាប់ធ្វើទាហាន ឲ្យធ្វើទាហានវិញ គ្រាន់តែដោះឯកសណ្ឋានខ្មែរក្រហមចេញ ពាក់ឯកសណ្ឋានរដ្ឋាភិបាលចូល អនុវត្តច្បាប់តែមួយ។ ធ្លាប់ធ្វើគ្រូ នៅធ្វើគ្រូ រហូតដល់ជ្រុលទៀតនោះ គឺតំបន់ខ្មែរក្រហមឯណាមានគយ ដល់ធ្វើសមាហរណកម្មគយ ក៏យើងចេះតែសម្រួលអោយតិចតួចទៅ។ **ទី ៣ ទទួលស្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិ ទាំងអចលនទ្រព្យទាំងចលនទ្រព្យ**។ បីចំណុចនេះ មើលទៅក្រឡេះខេះ ប៉ុន្តែសុទ្ធតែជាការធានាទាំងអស់ ហើយយើងមិនត្រឹមតែធ្វើប៉ុណ្ណឹងទេ សាលារៀន ផ្លូវថ្នល់ធ្វើព្រឹបៗ ... មានគេកាន់ច្រឡំថា តំបន់នោះស្វយ័ត មិនមែនស្វយ័តទេ អនុវត្តច្បាប់របស់រដ្ឋាភិបាលដូចគ្នា បើនិយាយតាមមួយបែបទៀត គឺយុទ្ធសាស្ត្រ ៥ តួអក្សរ DIFID មានន័យថា បំបែក ឯកោ បញ្ចប់ សមាហរណកម្ម និងអភិវឌ្ឍន៍ ... ឥឡូវ តំបន់ជាយដែនទទួលផលដូចគ្នា។ អ្វីដែលខ្ញុំប្រយ័ត្នបំផុត គឺខ្លាចមានការសងសឹកណាមួយ។ ផ្ទុយទៅវិញ មិនត្រឹមតែមិនសងសឹកទេ ថែមទាំងរួបរួមគ្នាយ៉ាងល្អ ...។

ខ.២. សារនយោបាយ ៣ ស្តីពី ការទទួលមេដឹកនាំ ខ្មែរក្រហម

ពិធីចែកសញ្ញាបត្រ វិទ្យាស្ថានវ៉ាន់ដា គណនេយ្យ, ថ្ងៃទី ២២ ធ្នូ ២០០៨

... ចំពោះតុលាការកាត់ក្តីខ្មែរក្រហម ជារឿងផ្លូវច្បាប់មួយផ្សេង។ ប៉ុន្តែ ពេលនោះ លោក ខៀវ សំផន បាននាំមកជាមួយទាំងប្រពន្ធ ទាំងកូន កូនប្រសារ និងចៅទៀត មកទទួលទានបាយផ្ទះខ្ញុំ។ ខ្ញុំទទួលបាយមួយពេល។ គេទិតៀនខ្ញុំថា ទទួលមេដឹកនាំខ្មែរក្រហម។ ដល់ខ្ញុំព្រលះទៅវិញថា ន៏ ! មុនពេលស្ថិតក្នុងស្ថានភាពនេះ ខៀវ សំផន ទៅអង្គការសហប្រជាជាតិ ចូលប្រទេសអាមេរិក ចូលប្រទេសបារាំង ដោយបានទទួលទិដ្ឋាការការទូត ដើរលើកម្រាលព្រំក្រហម។ ម៉េចក៏គេធ្វើបាន។ ខ្ញុំមានគោលដៅរបស់ខ្ញុំ ក្នុងការទទួល ខៀវ សំផន, នួន ជា និងគណៈរដ្ឋមន្ត្រីរបស់ខ្មែរក្រហម ឲ្យមកដល់ផ្ទះ ... **ខ្ញុំចេញសារបីយ៉ាង ទី ១ៈ ប្រាប់**

ទៅកំលាំងខ្មែរក្រហម នៅសេសសល់អោយបញ្ឈប់ការប្រយុទ្ធ ព្រោះមេដឹកនាំ
របស់អ្នកឯងបានចុះចូលដល់ផ្ទះខ្ញុំហើយ។ ពេលនោះ តា ម៉ុក មិនទាន់ត្រូវចាប់
ខ្លួន ហើយអាចមានមនុស្សមួយចំនួនទៅតាម ... សារទី ២៖ ប្រាប់ទៅប្រជាជន
កម្ពុជាថា សង្គ្រាមនៅក្នុងប្រទេសកម្ពុជាបញ្ចប់ហើយ និងសារ ទី ៣៖ ប្រាប់
ទៅសហគមន៍អន្តរជាតិថា សូមអញ្ជើញមកធ្វើទេសចរណ៍ និងវិនិយោគនៅ
កម្ពុជា ព្រោះនៅកម្ពុជាបញ្ចប់សង្គ្រាមហើយ ...៖

ខ.៣. បានធ្វើភារកិច្ច ៥ អំពីរបបប្រល័យពូជសាសន៍

ចែកសញ្ញាបត្រដល់និស្សិត សាកលវិទ្យាល័យធនធានមនុស្ស,
ថ្ងៃទី ២៤ កុម្ភៈ ២០០៩

... ខ្ញុំបានធ្វើការកិច្ចខ្ញុំចប់ហើយ។ ការកិច្ចរបស់ខ្ញុំ **កិច្ចការទី ១ បានដឹកនាំ**
និងរួមចំណែកផ្ដួលរំលំ ប៉ុល ពត ចាប់ដំណើរការពីឆ្នាំ ១៩៧៧ ដល់ ១៩៧៩
កិច្ចការទី ២ បានទប់ស្កាត់ការវិលត្រឡប់នៃរបប ប៉ុល ពត។ យើងធ្វើបានដោយ
ទ្រាំស៊ីអត់ ស៊ីឃ្លាន ជាមួយឯកឧត្តម លោកជំទាវមួយចំនួននៅទីនេះ។ គេដាក់
ទណ្ឌកម្មលើយើង ក្នុងពេលដែលគេគាំទ្រ **ប៉ុល ពត** និងពួកសម្ព័ន្ធភាពឲ្យអង្គុយ
នៅអង្គការសហប្រជាជាតិ និងវ៉ៃយើង ... **កិច្ចការទី ៣ ដែលខ្ញុំបានធ្វើ ហើយដែល**
មានការគាំទ្រពីជនរួមជាតិ ក៏ដូចជាក្នុងក្របខណ្ឌនៃថ្នាក់ដឹកនាំរបស់គណបក្ស
ប្រជាជន គឺនយោបាយឈ្នះ-ឈ្នះ ដែលនាំមកនូវការឯកភាពទឹកដីទាំងស្រុង
បញ្ចប់នូវអង្គការចាត់តាំងទាំងនយោបាយ និងយោធារបស់ខ្មែរក្រហម ... **កិច្ចការ**
ទី ៤ បានចរចាជាមួយអង្គការសហប្រជាជាតិ ណែនាំផ្ទាល់ ពេលខ្លះជួប **ហ្ស៊ី អា**
ណាន់ តាមទូរស័ព្ទផ្ទាល់ពីផ្ទះវិមានឯករាជ្យទៅញ្ជូរយ៉ក ដើម្បីសម្របសម្រួល
ចំណុចដែលមិនស្របគ្នា **បង្កើតឡើងនូវអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា**
... និង**កិច្ចការទី ៥** ពេលតុលាការចេញដីកា ទៅ**នាំខ្លួនអ្នកទាំងនោះ មកឲ្យ**
តុលាការកាត់ទោស។ ដែលលោកឯងទាស់ទែងគ្នាក្នុងតុលាការ នោះជារឿងរបស់
លោកឯង។ ម៉េចបានថាយើងមិនធ្វើ ? ...៖

ខ.៤. សាសនារួមជាមួយនយោបាយឈ្នះ-ឈ្នះ នាំមកនូវការបញ្ចប់សង្គ្រាម

ពិធីបិទអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឆទូទាំងប្រទេសលើកទី ១៧, ថ្ងៃទី ១៨ ធ្នូ ២០០៨

... ក្នុងឋានៈទូលបង្គំ ខ្ញុំព្រះករុណាខ្ញុំ **ជាអ្នកជាក់ចេញ និងជាអ្នកដឹកនាំអនុវត្តនូវនយោបាយឈ្នះ-ឈ្នះ ដើម្បីបញ្ចប់សង្គ្រាមនេះ ទូលបង្គំ ខ្ញុំព្រះករុណាខ្ញុំ ក៏ត្រូវដឹកពិសោធន៍ថា ហេតុអ្វីបានជាយើងធ្វើបាន។ មានចំណុចមួយ មិនមែនអត់តួនាទីព្រះពុទ្ធសាសនាទេ។ ទោះបីថា ខ្មែរនៅខាងភាគីនេះភាគីនោះ ភាគីណាក៏ដោយ ប៉ុន្តែ អ្វីដែលសំខាន់ភាគីទាំងឡាយមានសាសនាដូចគ្នា។ មានចំណុចជាច្រើនដែលប្រហាក់ប្រហែលគ្នា ចង់បានសន្តិភាពដូចគ្នា ចង់បានប្រទេសអភិវឌ្ឍន៍ដូចគ្នា ក៏ប៉ុន្តែ មានចំណុចសំខាន់មួយដែរ គឺចំណុចត្រង់ថា យើងមានសាសនាដូចគ្នា។** ដូច្នេះ អត់ពិបាកទេ។ នៅប្រទេសជិតខ្ទមានការពិបាកណាស់ ដោយសារតែភាគីម្ខាងជាមូស្លីម ភាគីម្ខាងជាគ្រិស្ត និងភាគីម្ខាងទៀតជាព្រះពុទ្ធ។ គេអាចចុះសម្រុងគ្នាជានយោបាយ តែមិនអាចចុះសម្រុងគ្នាខាងសាសនា។ ... ឥឡូវ ១០ ឆ្នាំគត់ (គិតត្រឹម ២០០៨) គិតតែពេលវេលាត្រឹមតែគណៈរដ្ឋមន្ត្រីទាំងមូលរបស់កម្ពុជាប្រជាធិបតេយ្យ មកចុះចូលដល់ផ្ទះរបស់ខ្ញុំ ព្រះករុណាខ្ញុំ ...។ ប្រវត្តិសាស្ត្រលើពិភពលោកមានតែមួយគត់ដែលប្រមុខរដ្ឋ នាយករដ្ឋមន្ត្រី ប្រធានសភា និងគណៈរដ្ឋមន្ត្រី (នៃជម្លោះមួយ) បានចុះចូលដល់ផ្ទះនាយករដ្ឋមន្ត្រីកាន់អំណាច ... ទូលបង្គំ ខ្ញុំព្រះករុណាខ្ញុំ ពិតជាមានមោទនភាព ជាមួយនឹងចំណងទាក់ទងគ្នា រវាងពុទ្ធចក្រ និងអាណាចក្រ ដែលដើរទន្ទឹម គ្នា ...។

ខ.៥. គណិតវិទ្យានយោបាយ "អត់លើសអត់ខ្វះ"

ពិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋ ស្រុកឱ៉ាល់, ខេត្តកំពង់ស្ពឺ, ថ្ងៃទី ១៤ វិច្ឆិកា ២០១២

... ខ្ញុំសូមបញ្ជាក់បន្តិច ដើម្បីឲ្យយល់ថា តើអ្វីទៅជានយោបាយ**ឈ្នះ-ឈ្នះ**? ដើម្បីធ្វើការប្លឹងប្លែង។ រឿងនេះវាអញ្ចេះ ចាប់ផ្តើមពី **កែវ ពង្ស** ជាមេធំជាងគេ នៅ

ក្នុងតំបន់ឱ៉ាល់នេះ និងទិសខាងត្បូងផ្លូវជាតិលេខ ៤ ផងដែរ។ ពេលនោះ បងប្អូនបានយក កែវ ពង្ស ទៅទីក្រុងភ្នំពេញ បន្ទាប់ទៅឲ្យ កែវ ពង្ស ត្រឡប់ចូលព្រៃវិញដោយស្ងាត់បំផុត។ **បងប្អូនបានសួរយោបល់ខ្ញុំថា ចុះបើ កែវ ពង្ស ទៅហើយមិនត្រឡប់មកវិញ និងក្បត់ជាមួយនឹងយើង តើយ៉ាងម៉េច? ចម្លើយរបស់ខ្ញុំ គឺគិតតាមគណិតវិទ្យាក្នុងវិស័យនយោបាយ ខ្ញុំថា អត់លើស អត់ខ្វះ។ បើ កែវ ពង្ស មិនត្រឡប់មកវិញទេ គឺមិនលើស ហើយក៏មិនខ្វះ។ ខាងយើងក៏មិនបានបាត់បង់អ្វី ហើយខាងទ័ពព្រៃក៏អត់មានបាត់បង់អីដែរ។ តែបើសិនជាយើងទុក កែវ ពង្ស យើងបាន កែវ ពង្ស តែមួយនាក់ទេ។ ផ្ទុយទៅវិញ បើ កែវ ពង្ស អនុវត្តតាមនយោបាយឈ្នះ-ឈ្នះ យើងបានតំបន់ឱ៉ាល់ទាំងមូលតែម្តង។** សម្រាប់អ្នកដែលធ្វើនយោបាយក្រោយៗទៀត សូមប្លឹងថ្លែង ... **នេះជាការចាប់ផ្តើមនៃការអនុវត្តនូវនយោបាយឈ្នះ-ឈ្នះ ជំហានដំបូង រួចហើយបានចាប់រុញចូលតំបន់ម៉ាឡៃ ប៉ៃលិន និងតំបន់ដទៃៗទៀត ឈានទៅរៀបចំឡើងជានយោបាយឈ្នះ-ឈ្នះ សម្រាប់ក្របខ័ណ្ឌទូទាំងប្រទេស ធ្វើឲ្យកម្ពុជាក្លាយជាប្រទេស ដែលមានតំបន់ត្រួតត្រាតែមួយ រដ្ឋាភិបាលតែមួយ រដ្ឋធម្មនុញ្ញតែមួយ ព្រះមហាក្សត្រតែមួយ កងទ័ពជាតិតែមួយ** ... ផ្តល់ឱកាសសម្រាប់យើងគ្រប់ៗគ្នា ... នយោបាយឈ្នះ-ឈ្នះរបស់យើង អនុវត្តដោយមិនបានប្រើគ្រាប់កាំភ្លើងសូម្បីតែមួយគ្រាប់ ...។

២.៦. សមាហរណកម្មនយោបាយ/រដ្ឋបាល មិនគ្រប់គ្រាន់ទេ ត្រូវមានសមាហរណកម្មយោធា

ពិធីបើកការដ្ឋានសាងសង់ផ្លូវជាតិលេខ ៥៥ ប្រវែង ១៨២ គីឡូម៉ែត្រ, ថ្ងៃទី ០៤ ឧសភា ២០១៥

... ស្ថានភាពកាលពីពេលមុនបានផ្លាស់ប្តូរអស់ហើយ តាមរយៈនៃនយោបាយឈ្នះ-ឈ្នះ។ យើងមិនបានបន្សល់ទុកនូវសង្គ្រាមនៅកន្លែងណាមួយទេ បន្ទាប់ពីអ៊ុនតាក់បានដកចេញ ... **នៅពេលដែលយើងធ្វើសមាហរណកម្មហើយ យើងបានបង្កើតស្រុកវាលវែងនេះ។ ក្រោយមកបានជាយើងត្រូវការកំណត់ភ្ជាប់ព្រោះរឿងនេះ វាស្ថិតនៅក្នុងនយោបាយឈ្នះ-ឈ្នះ ដែលខ្ញុំព្រះករុណាខ្ញុំ បានដាក់ចេញ និងបានដឹកនាំអនុវត្ត។ ពេលនោះ ខ្ញុំព្រះករុណាខ្ញុំ បាននិយាយដោយច្បាស់ៗថា បើគ្រាន់តែធ្វើសមាហរណកម្មខាងនយោបាយ និងរដ្ឋបាល មិន**

គ្រប់គ្រាន់ទេ គឺត្រូវសមាហរណកម្មរួមបន្ថែ បានសេចក្ដីថា ត្រូវតែធ្វើការតភ្ជាប់ផ្លូវ
បន្ទាន់ និងផ្ដល់ភ្លាមនូវវិស័យអប់រំ និងសុខាភិបាលឲ្យដូចគ្នា។ ប្រជាពលរដ្ឋ
កម្ពុជានៅកន្លែងណាក៏ដោយ គឺទទួលផលប្រយោជន៍ឲ្យបានដូចគ្នា។ អញ្ចឹងទេ
បានកើតឡើងនូវគំនិតផ្ដើមជាច្រើន គ្រាន់តែទាក់ទងនឹងទុនតែប៉ុណ្ណោះ។ កន្លែង
ណាដែលយើងអត់មានទុន យើងចាប់ធ្វើបណ្ដើរៗ គេហៅថា ជំហានគីង្គក់ ...។

គ. សមិទ្ធផល នៃនយោបាយឈ្នះ-ឈ្នះ

គ.១. នយោបាយឈ្នះ-ឈ្នះ នាំមកនូវសន្តិភាព និងមានឥទ្ធិពលទៅលើវិស័យដទៃទៀត

ពិធីបើកសន្និបាតក្រសួងសុខាភិបាល, ថ្ងៃទី ២៣ មីនា ២០០៩

... បញ្ហាវាមិនទាក់ទងជាច់ដោយឡែកតែកិច្ចការសុខាភិបាល មណ្ឌលសុខ
ភាព ឬមន្ទីរពេទ្យបង្អែកទេ។ វាទាក់ទងកត្តាច្រើនណាស់។ ដំបូងបំផុត កត្តាសន្តិ
ភាព ... សង្គ្រាមដែលស្គាល់សញ្ញាពេទ្យពីអង្កាល់។ អញ្ចឹង សន្តិភាពយើងបានបង្ក
លក្ខណៈឲ្យយើងធ្វើសកម្មភាពទូទៅតែម្ដង។ **កាលពីប៉ុន្មានឆ្នាំមុន ខ្ញុំមានការ
កង្វល់ថា តើយើងអាចមានលទ្ធភាពធ្វើសកម្មភាពបញ្ចប់ជំងឺគ្រុនស្ទិតដៃជើង
បានឬទេ ព្រោះពេលដែលយើងចាប់ផ្ដើមយុទ្ធនាការបំបាត់ជំងឺគ្រុនស្ទិតដៃជើង
វាចំពេលដែលយើងនៅជាប្រទេសមួយ មានតំបន់ត្រួតត្រា ២ នៅឡើយ។ ភ្នំវល្លិ
នៅកាន់កាប់ដោយខ្មែរក្រហមនៅឡើយទេ។ ... នយោបាយឈ្នះ-ឈ្នះ អនុញ្ញាត
ឲ្យយើងធ្វើសកម្មភាពបានគ្រប់ទីកន្លែងទាំងអស់** ...។

គ.២. កម្ពុជា ពីសូរកាំភ្លើង ទៅជាព្រះធម៌ និងដូរ្យតន្ត្រី

ពិធីបើកការដ្ឋានស្ថាបនាផ្លូវជាតិលេខ ៥៩ ដែលមានប្រវែង ១៤៤ គីឡូម៉ែត្រ ទទឹង
១១ ម៉ែត្រ និងស្ពានបេតុង ១៣ កន្លែង, ថ្ងៃទី ០៥ ធ្នូ ២០០៩

... សុំធ្វើការកែតម្រូវ ហើយខ្ញុំគិតថា ឯកឧត្តម ទៀ បាញ់, ឯកឧត្តម កែ គឹម
យ៉ាន, ឯកឧត្តម ប៉ុល សារឿន អាចសរសេរទុក ដើម្បីកុំឱ្យធ្វើការតាមរបៀបហ្នឹង ...
ឯកឧត្តម ត្រាំ អ៊ីវតឹក បានលើកថា "ឆ្នាំ ១៩៩៩ បន្ទាប់ពីធ្វើសមាហរណកម្ម ...
ពិសេសមូលដ្ឋានចុងក្រោយនៅប៉ៃលិន"។ ទៅជាប៉ៃលិន ជាមូលដ្ឋានចុងក្រោយ។

មូលដ្ឋានចុងក្រោយនៅអន្លង់រ៉ែងឯណោះ។ មូលដ្ឋានប៉ៃលិន និងម៉ាឡែនេះ ខ្ញុំប្រសិទ្ធនាមថា ជាឈ្នួនផ្ទុះនៃសន្តិភាព គឺចាប់ផ្តើមពីតំបន់ម៉ាឡែ និងប៉ៃលិននេះឯង ដែលនាំទៅដល់ការធ្វើសមាហរណកម្មក្នុងក្របខណ្ឌនយោបាយឈ្នះ-ឈ្នះ។ ថ្ងៃក្រោយកុំច្រឡំទៀត។ មិនមែនឆ្នាំ ១៩៩៩ ទេ។ សូម្បីតែអ្នកអន្លង់រ៉ែងក៏បានចូលរួមបោះឆ្នោតនៅក្នុងឆ្នាំ ១៩៩៨ ដែរ។ និយាយខុសប្រវត្តិសាស្ត្រ មិនបានទេ។ បើមិនមានសន្តិភាពគ្រប់គ្រាន់ទេ កុំថាឡើយដល់ទៅកសាងផ្លូវ សូម្បីតែជីវិតមនុស្ស ក៏មិនអាចការពារបានផង។ ... **ប្រទេសយើងបានប្រែក្លាយពីស្នូរគ្រាប់ស្នូរកាំភ្លើង ទៅជាសូរព្រះសង្ឆសូត្រធម៌ និងទេសនា និងការស្តាប់ដូរ្យតន្ត្រីហើយ** ... យើងបានរួមគ្នា បង្កើតឡើងនូវស្ថានភាពសន្តិភាពសម្រាប់ប្រទេសជាតិទាំងមូល និងបន្ទាប់ពីនោះ យើងអភិវឌ្ឍបណ្តើរៗ តាមដំហានគីង្គក់ ...។

ពិធីសម្ពោធសមិទ្ធផលនានា នៃខេត្តប៉ៃលិន, ថ្ងៃទី ០៣ មករា ២០១៣

... សមិទ្ធផលដែលចេញមកអំពីនយោបាយឈ្នះ-ឈ្នះ ដែលចាប់ផ្តើមសាកល្បងនៅដើមឆ្នាំ ១៩៩៦ នៅតំបន់ឌ៉ាល់ បន្ទាប់ទៅឈ្នួនផ្ទុះសន្តិភាពមួយ បានកើតលើទឹកដីប៉ៃលិន ក្នុងនោះក៏មានចំណែកនៅម៉ាឡែ។ អនុញ្ញាតឲ្យ ខ្ញុំព្រះករុណាខ្ញុំ បាននិយាយចំណុចនេះបន្តិចថា តើអ្វីទៅដែលបានកើតឡើងនៅទីនេះ ហើយចាប់ផ្តើមពីពេលនោះមកដល់ពេលនេះ ការប្រែប្រួលវាយ៉ាងដូចម្តេច? ... **ឯកឧត្តម អ៊ី ឈាន បានលើកឡើងអម្បាញ់មិញ ប៉ៃលិនបានប្រែខ្លួនពីសំណល់ខ្ទេចខ្ទាំនៃសង្គ្រាម ពីទីរហោឋានគួរឲ្យខ្លាច មកជាទីកន្លែងទាក់ទាញគួរឲ្យចង់រស់នៅ។ តើអ្នកប៉ៃលិនខាត ឬចំណេញ ដែលយើងបានអនុវត្តនូវនយោបាយឈ្នះ-ឈ្នះ បញ្ចប់នូវសង្គ្រាម** ... សម្រាប់អ្នកប៉ៃលិន គ្មានអ្នកណាមួយចាញ់ក្នុងល្បែងនៃនយោបាយឈ្នះ-ឈ្នះនេះទេ។ រឿងក្តីក្តាំង និងបញ្ហាតុលាការឧក្រិដ្ឋកម្មគឺជារឿងមួយ ប៉ុន្តែ សម្រាប់អតីតកម្លាំងប្រដាប់អាវុធ សម្រាប់ប្រជាជននៅប៉ៃលិន គឺសុទ្ធតែជាអ្នកទទួលផលពីសន្តិភាពទាំងអស់ ... បើនិយាយឲ្យច្បាស់ ប្រជាជនមួយប្រទេសត្រូវទទួលស្គាល់ផលប្រយោជន៍ ដែលបានមកពីឈ្នួនផ្ទុះសន្តិភាពនៅប៉ៃលិន និងម៉ាឡែ ...។

ค.๓. នយោបាយឈ្នះ-ឈ្នះ បញ្ចប់សង្គ្រាម កាត់បន្ថយការស្លាប់ និងរបួសយុទ្ធជន

សម្ពោធមជ្ឈមណ្ឌលអភិវឌ្ឍន៍យោធិនពិការ សម្តេច តេជោ ហ៊ុន សែន គូលេន ៣១៧ ខេត្តសៀមរាប, ថ្ងៃទី ៣១ កក្កដា ២០១១

... **នេះជាកិត្តិសំណាងរបស់ប្រទេសយើង ដែលបានបញ្ចប់សង្គ្រាមតាមរយៈនយោបាយឈ្នះ-ឈ្នះ កាលពីឆ្នាំ ១៩៩៨។ ខ្ញុំប៉ាន់ប្រមាណថា បើយើងមិនបានបញ្ចប់សង្គ្រាមផ្ទៃក្នុងដោយខ្លួនឯង ពីចុងឆ្នាំ ១៩៩៨ រហូតមកដល់បច្ចុប្បន្ននេះ សង្គ្រាមបន្តក្នុងរយៈពេលប្រមាណជា ១៣ ឆ្នាំ សួរថា តើអ្នកស្លាប់ និងអ្នករបួសមានប៉ុន្មានទៀត? នេះជាចំណុចដែលមិនមែនគ្រាន់តែបញ្ហាយុទ្ធជន ឬបញ្ហារាជរដ្ឋាភិបាលទេ ក៏ប៉ុន្តែ ប្រជាពលរដ្ឋកម្ពុជាខ្លួនឯងក៏អាចដឹងអំពីតម្លៃនៃសន្តិភាព និងការបង្រួបបង្រួមជាតិ ដែលយើងរកបានដោយលំបាកលំបិន និងដែលចាំបាច់ត្រូវការពារនេះ**។ ... គ្រាន់តែយើងកើតសង្គ្រាមជាយដែនរវាងកម្ពុជា និងថៃ ក៏មានយុទ្ធជនពលី និងយុទ្ធជនពិការមួយចំនួនថែមទៀត។ ដូច្នេះសង្គ្រាមមិនមែនជាជម្រើសល្អ សម្រាប់ប្រជាពលរដ្ឋណាមួយទេ។ វិធីបញ្ចប់សង្គ្រាមនៅកម្ពុជា តាមរយៈនយោបាយឈ្នះ-ឈ្នះ បានផ្តល់លទ្ធភាពអោយយើងអាចមកអង្គុយជុំគ្នានៅទីនេះ ...។

ค.๔. នយោបាយឈ្នះ-ឈ្នះ ធ្វើឲ្យសេដ្ឋកិច្ច មានការកើនឡើង

ពិធីសម្ពោធសមិទ្ធផលនានានៃខេត្តពោធិសាត់, ថ្ងៃទី ១១ មិថុនា ២០១៣

... នយោបាយឈ្នះ-ឈ្នះនេះហើយ ដែលធ្វើឱ្យប្រទេសកម្ពុជា ក្លាយពីមានតំបន់ត្រួតគ្រាច្រើន ទៅជាប្រទេសមួយដែលមានតំបន់ត្រួតគ្រាតែមួយ ព្រះមហាក្សត្រតែមួយអង្គ នីតិបញ្ញត្តិតែមួយ នីតិប្រតិបត្តិតែមួយ តុលាការតែមួយ កងកម្លាំងប្រដាប់អាវុធតែមួយ។ **តាំងពីពេលនោះមក កំណើនសេដ្ឋកិច្ចរបស់យើង គឺទាំងធនាគារពិភពលោក ទាំង IMF ទាំងធនាគារអភិវឌ្ឍន៍អាស៊ី សុទ្ធតែមានសុទិដ្ឋិនិយម។** ក្នុងចន្លោះឆ្នាំ ២០០៤-២០០៧ កំណើនសេដ្ឋកិច្ចមានដល់ជាងពីរខ្ទង់ឯណោះ។ ឆ្នាំ ២០០៥ មាន ១៣,៣%។ ប៉ុន្តែ វិបត្តិសេដ្ឋកិច្ចពិភពលោកទាញយើងឱ្យធ្លាក់។ យើងប្រឹងដើបឈរឡើង ធ្វើ ឱ្យកំណើនសេដ្ឋកិច្ចលូតលាស់

ឡើងវិញក្នុងអត្រាជាង ៧%។ ឆ្នាំ ២០១១ ទឹកជំនន់ផង សង្គ្រាមទល់ដែនផង តែយើងនៅជម្រុញកំណើនសេដ្ឋកិច្ច ៧,១%។ ឆ្នាំ ២០១២ កន្លងទៅ ៧,៣% ហើយឆ្នាំនេះ សង្ឃឹមថានឹងលើ ៧% ទៀត ...។

គ.៥. ការអភិវឌ្ឍទាំងអស់ កើតចេញពីនយោបាយឈ្នះ-ឈ្នះ

ពិធីសម្ពោធផ្លូវជាតិលេខ ៥៩ ស្ទឹងកាច់ខេត្តប៉ៃលិន ដល់កូនដំរី ខេត្តបន្ទាយមានជ័យ, ថ្ងៃទី ២១ មិថុនា ២០១៣

... ចាប់ផ្តើមពីសន្តិភាព និងការបង្រួបបង្រួមជាតិ យើងចាប់ផ្តើមមានឱកាសពេជ្រតែម្តង ដើម្បីនឹងការអភិវឌ្ឍប្រទេស។ អញ្ចឹងទេ ការអភិវឌ្ឍនេះ វាបានឃើញនឹងភ្នែកហើយនៅថ្ងៃនេះ។ សន្តិភាព និងការអភិវឌ្ឍ វាទៅជាមួយគ្នានោះឯង បើគ្មានសន្តិភាពទេ មិនអាចអភិវឌ្ឍបានទេ ធ្វើស្ពានផ្តាច់ស្ពាន ធ្វើផ្លូវផ្តាច់ផ្លូវ ធ្វើសាលាដុតឆេះសាលា ធ្វើវត្តខូចវត្ត។ ប៉ុន្តែ **ឥឡូវនេះ ប្រជាពលរដ្ឋដែលមកនៅទីនេះ ទាំងអ្នកដែលមកនៅពីចម្ងាយ ដែលមិនធ្លាប់ប៉ះពាល់នឹងសង្គ្រាម ទាំងអ្នកដែលធ្លាប់ប៉ះពាល់សង្គ្រាម ទាំងបងប្អូននៅម៉ាឡេ ឬនៅបន្ទាយមានជ័យនេះបាន និងកំពុងទទួលផលក្នុងសម័យសន្តិភាព គឺបានសេចក្តីថា មានទាំងសន្តិភាពមានទាំងការអភិវឌ្ឍក្នុងហ្នឹង តើលោកយាយ លោកតា លោកអ៊ំ មាមីង ធ្លាប់ដែលបានឃើញផ្លូវចាក់កៅស៊ូទេ នៅក្នុងតំបន់នេះ?** តាំងពីកកើតទឹកជីមក ដែលឃើញផ្លូវចាក់កៅស៊ូតាមហ្នឹងដ៏វែងទេ ...។

គ.៦. នយោបាយឈ្នះ-ឈ្នះ នាំអោយកើតវារីអគ្គិសនី

ពិធីសម្ពោធវារីអគ្គិសនីស្ទឹងឫស្សីជ្រុំក្រោម ស្រុកមណ្ឌលសីមា ខេត្តកោះកុង, ថ្ងៃទី ១២ មករា ២០១៥

... នេះហើយជាសមិទ្ធផលសន្តិភាពសម្រាប់ប្រទេស ដែលឯកឧត្តម ស៊ុយ សែម បានលើកឡើងអម្បាញ់មិញ។ បើសភាពការណ៍មុនឆ្នាំ ១៩៩៨ មិនបាច់ចាំមកគិតធ្វើអាហ្នឹងទេ។ កុំនិយាយឡើយដល់ថ្ងៃហ្នឹងមកសម្ពោធ សូម្បីតែគិត ក៏គិតមិនចេញផង។ តំបន់នេះមិនងាយអ្នកណាមកគ្រប់គ្រងទេ។ បើនិយាយឲ្យពិតទៅ ហើយរដ្ឋាភិបាលមិនដឹងប៉ុន្មានជំនាន់ហើយទេ តាំងពីបារាំងចូលមក ក៏

គ្រប់គ្រងមិនបានដែរតំបន់នេះ។ បារាំងគ្រប់គ្រងខ្មែរជិត ១០០ ឆ្នាំ មិនដែលគ្រប់គ្រងបានតំបន់នេះទេ។ ជប៉ុនចូលមកវ៉ៃបារាំង ជប៉ុនក៏មិនដែលបានគ្រប់គ្រងតំបន់ហ្នឹងដែរ ... **ប៉ុន្តែ ចាប់តាំងពីឆ្នាំ ១៩៩៨ មក គឺអនុញ្ញាតឲ្យយើងមានលទ្ធភាពសូម្បីតែទីតាំងតំបន់នេះ គឺបន្តិចទៀតក៏ក្លាយទៅជាតំបន់ទេសចរណ៍ទៅទៀត ព្រោះអ្នកដែលមកលេងនៅខាងកោះកុង គេក៏ចង់ស្គាល់ឫស្សីជ្រុំក្រោមហ្នឹងវាយ៉ាងម៉េច តំបន់វារីអគ្គិសនីមួយចំនួន នឹងក្លាយទៅជាតំបន់ទេសចរណ៍តែម្តង ... សូមអរគុណដល់ទឹកចិត្តបង្រួបបង្រួមជាតិ នៃប្រជាពលរដ្ឋកម្ពុជា និងគ្រប់ភាគីពាក់ព័ន្ធ ដែលអនុញ្ញាតឲ្យប្រទេសរបស់យើងអាចបង្រួបបង្រួមបាន និងមានសន្តិភាពពេញលេញ ហើយផ្តល់ឱកាសឲ្យយើងអភិវឌ្ឍនៅថ្ងៃនេះ ...**។

គ.៧. នយោបាយឈ្នះ-ឈ្នះ ផ្តល់ឱកាសដ៏ធំសម្រាប់យុវជនបន្តការរៀនសូត្រ

ពិធីប្រគល់សញ្ញាបត្រ និស្សិត នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា,
ថ្ងៃទី ១៤ មករា ២០១៣

... ពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៩១ ប្រទេសមានសន្តិភាពផង និងមានសង្គ្រាមផង។ ពិតមែនតែសន្តិភាពបានកើត មានភាគច្រើននៃដែនដី និងពេលវេលាខ្លះ ក៏ប៉ុន្តែ វាមានឥទ្ធិពលទៅដល់បញ្ហាទូទៅ ក្នុងនោះ មានវិស័យអប់រំសិក្សាធិការ។ ក្រោយកិច្ចព្រមព្រៀងទីក្រុងប៉ារីស យើងអនុវត្តកិច្ចព្រមព្រៀងប៉ារីស ដោយលំបាក ព្រោះភាគីខ្មែរក្រហមអត់ចូលរួម។ សង្គ្រាមនៅបន្ត។ សន្តិភាព មិនទាន់មានទាំងស្រុងនៅក្នុងប្រទេសកម្ពុជា ដូចដែលកិច្ចព្រមព្រៀងប៉ារីស ចង់បាននោះទេ។ កិច្ចព្រមព្រៀងប៉ារីសចង់បានសន្តិភាព ការបង្រួបបង្រួមជាតិ លទ្ធិប្រជាធិបតេយ្យសេរីពហុបក្សស្អីៗ ប៉ុន្តែ សន្តិភាពអត់មាន មានតែប្រជាធិបតេយ្យ អញ្ចឹងរឿងរ៉ាវរ៉ាចេះតែបន្ត រហូតដល់មានការវ៉ៃគ្នានៅទីក្រុងភ្នំពេញនេះទៀត ... **តាមរយៈនយោបាយឈ្នះ-ឈ្នះ យើងបានបញ្ចប់នូវ សការាជសង្គ្រាម ដែលបានផ្តើមតាំងពីឆ្នាំ ១៩៧០ នៅឆ្នាំ ១៩៩៨។ បានសេចក្តីថា ឱកាសនេះមានធំណាស់សម្រាប់យុវជនរបស់យើង ដើម្បីបន្តការរៀនសូត្រ។ យុវជនរបស់យើងមានឱកាសច្រើនណាស់ បើប្រៀបធៀបជាមួយនិងឱកាសកាលពីពេលមុន។** ខ្លួនខ្ញុំនេះតែម្តង បាត់បង់ឱកាសស្ទើរតែ ១០០% ទៅហើយ ...។

ค.៨. នយោបាយឈ្នះ-ឈ្នះ មិនទាន់មានលើលោក, ផ្ទៃក្នុងស្រុះស្រួល, អ្នកជិតខាងល្អ

ពិធីបើកការដ្ឋានសាងសង់ផ្លូវជាតិលេខ ៥៥ ប្រវែង ១៨២ គីឡូម៉ែត្រ,
ថ្ងៃទី ០៤ ឧសភា ២០១៥

... ខ្ញុំព្រះករុណាខ្ញុំ សូមអរគុណចំពោះប្រជាពលរដ្ឋ ក៏ដូចជាកម្លាំងប្រដាប់អាវុធនៃគ្រប់ភាគីទាំងអស់ ដែលបានចូលរួមក្នុងនយោបាយឈ្នះ-ឈ្នះ របស់ខ្ញុំ ព្រះករុណាខ្ញុំ។ **ខ្ញុំព្រះករុណាខ្ញុំ ក៏ចង់អរគុណចំពោះអ្នកគាំទ្រនូវប្បធម៌សន្ធនាដែរ ព្រោះវាគ្មានការចាំបាច់ជេរគ្នា ចាត់ទុកគ្នាជាសត្រូវ បានហៅថាធ្វើប្រឆាំងគ្នានោះទេ។ ប្រទេសជាតិ តម្រូវការឲ្យមានការស្រុះស្រួលគ្នា ជៀសវាងជាងការជេរប្រមាថណាមួយ។ អញ្ចឹងទេ បានជាយើងមានប្រវត្តិនៃនយោបាយឈ្នះ-ឈ្នះ មិនទាន់មានលើពិភពលោកនេះទេ។** ប្រទេសដែលមានសង្គ្រាម គឺនៅរងគ្រោះដោយសារសង្គ្រាមមិនទាន់ចប់ ... ព្រោះវាអត់មាននយោបាយឈ្នះ-ឈ្នះ ... នយោបាយប្រែក្លាយសមរភូមិឲ្យក្លាយជាទីផ្សារ ឲ្យទៅជាតំបន់អភិវឌ្ឍនេះ បាននិងកំពុងទទួលជោគជ័យហើយ។ ឥឡូវនេះ យើងកំពុងធ្វើផ្លូវតភ្ជាប់ទៅជាមួយនឹងប្រទេសថៃ មិនមែនធ្វើដើម្បីដឹកកងទ័ពទៅវ៉ៃជាមួយថៃទេ ក៏ប៉ុន្តែការធ្វើទំនាក់ទំនងសេដ្ឋកិច្ចរវាងកម្ពុជា និងថៃ ... **តើវាមិនងាយស្រួលទេអី ដែលយើងមានផ្ទៃក្នុងស្រុះស្រួលគ្នា និងមានអ្នកជិតខាងល្អ មានទំនាក់ទំនងខាងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការវិនិយោគ។ ការរាប់រកគ្នាទៅវិញទៅមកជាការល្អ ...**។

ខុទ្ធកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
ក្រុមព្រឹត្តិប័ត្រ រ៉ែបសាយត៍ កម្ពុជាទស្សនៈថ្មី
បោះពុម្ព លើកទីមួយ - មីនា ២០១៧

រោងពុម្ព JSRC 2017

ការងារ ចំណាកស្រុក ឧត្តមនិយម សេដ្ឋកិច្ច ឥស្លាម
កីឡា ព្រៃវែង បេតិកភណ្ឌពិភពលោក សេវាសាធារណៈ
ព្រំដែនកម្ពុជា-ថៃ ប្រជាធិបតេយ្យ ជលផល វិទ្យាល័យ
បារាំង ព្រៃឈើ នយោបាយឈ្នះ-ឈ្នះ
ក្រចេះ ព្រះមហាក្សត្រ ឧស្សាហកម្ម ព្រំដែន
ច្បាប់ អភិវឌ្ឍ ប្រាសាទព្រះវិហារ ត្រី តុលាការ
អប់រំ បរិស្ថាន វត្ត អង្គការក្រៅរដ្ឋាភិបាល អគ្គិសនី
ភ្នំពេញ មហាផ្ទៃ និស្សិតបរទេស ទេសចរណ៍
កំពង់ចាម សោធនកម្ម ការទូត គ្រប់គ្រងដីធ្លី អាស៊ាន ដីធ្លី ប្រែប្រួលអាកាសធាតុ
នីតិរដ្ឋ វិមជ្ឈការ មនុស្សធម៌
ប្រកួតប្រជែង ទឹកស្អាត សហគមន៍ ប្រល័យពូជសាសន៍
ព្រៃលិចទឹក មជ្ឈិមបូព៌ា ទំនៀមទម្លាប់ កសិឧស្សាហកម្ម
កសិកម្ម ខ្មែរក្រហម យុទ្ធសាស្ត្រចតុកោណ កិច្ចការនារី ដែនទី
សម្បទានសេដ្ឋកិច្ច គរុកោសល្យ វិនិយោគ ជម្លោះព្រំដែន ត្បូងឃ្មុំ
សុខភាព ថៃ កម្លាំងប្រដាប់អាវុធ តាកែវ ៧ មករា
គ្រោះមហន្តរាយ ការពារជាតិ ពុទ្ធសាសនា
វិស័យឯកជន កំពង់ឆ្នាំង ធនធានមនុស្ស ដឹកជញ្ជូន ធនធានទឹក
ទ្បូត៍នេសាទ ហិរញ្ញវត្ថុ សង្គ្រាម ព្រះវិហារ សន្តិភាព
គ្រឿងញៀន វប្បធម៌ ចិន សង្គមកិច្ច យុវជន ស្រូវ គណបក្សប្រជាជន
ពន្ធ ប្រាក់ខែ កណ្ដាល ស្ពាន វារីអគ្គិសនី ពាណិជ្ជកម្ម កំពត
នេសាទ ផ្លូវ ជប៉ុន សភា ថាមពល ការបរទេស
អាមេរិក បក្សប្រឆាំង វិនិយោគ សាធារណៈការ ចរាចរណ៍
បាតុកម្ម កម្មករ វៀតណាម បាត់ដំបង ប្រពៃណី ស្ត្រី
សៀមរាប យុត្តិធម៌ ជនពិការ កែទម្រង់ គ្រោះធម្មជាតិ
ទឹក សមុទ្រចិនខាងត្បូង ពុទ្ធចក្រ ម៉ាក្រូសេដ្ឋកិច្ច
កុមារ ធនាគារ ភាពក្រីក្រ សន្តិសុខស្បៀង